# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

និង

# បរមត្ថមញ្ជូសាមហាដីកា

## សមាធិនិទ្ទេស

ភាគ ទី ១

ប្រែរៀបរៀង

ដោយខ្ញុំបាទ អ៊ឹម រ៉ៃយ៉ា

ដើម្បីបូជាចំពោះព្រះរតនត្រៃ

ថ្ងៃ ១៥ កើត ខែ ផល្គុន ព.ស ២៥៥២

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

និង

# បរមត្ថមញ្ជូសាមហាដីកា

## សមាធិនិទ្ទេស

ភាគ ទី ១



ប្រែរៀបរៀង

ដោយខ្ញុំបាទ អ៊ឹម រ៉ៃយ៉ា

ដើម្បីបូជាចំពោះព្រះរតនត្រៃ

ថ្ងៃ ១៥ កើត ខែ ផល្គុន ព.ស ២៥៥២

# និទានវចនៈ

***វិសុទ្ធិមគ្គ*** ជាបករណ៍វិសេស ដែលព្រះថេរៈ អ្នកស្រុកជម្ពូទ្វីប មានឈ្មោះ ពោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅបានប្រមាណ ១.០០០ ឆ្នាំ នៅកោះលង្កាទ្វីប ព្រះថេរៈរូបនេះគឺព្រះពុទ្ធឃោសៈ ព្រោះលោក បានរចនាគម្ពីរទុកជាច្រើនក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារដ៏ធំ និងជាមរតករហូតមកដល់សព្វថ្ងៃ ។ ការប្រែគម្ពីរព្រះត្រៃបិដក អដ្ឋកថា ពីភាសាសីហឡៈមក ជាភាសា មគធៈ ឬ ភាសាបាលី ព្រះពុទ្ធឃោសៈ បានប្រមូលធម៌ក្នុងព្រះត្រៃបិដក មកសម្តែងទុកជាពួក ៗ តាំងពី ***សីល សមាធិ*** និង ***បញ្ញា*** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬ លំដាប់នៃការឆ្លើយសំណួរធម៌ក្នុងបច្ចុប្បន្ន គឺអធិប្បាយសេចក្តីសង្ខេបឲ្យពិស្តារ បទសំណួររបស់វិសុទ្ធិមគ្គ ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំងអស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈបានអធិប្បាយដោយវិចិត្រពិស្តារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋានទុកក្នុងទីនោះៗ ទូទៅ នេះសម្តែងឲ្យដឹងថា លោកមានការដឹងបែកធ្លាយក្នុងព្រះត្រៃបិដក អាចលើកយកធម៌ដែលពោលដោយសីល មករួបរួមទុកក្នុងពួកសីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែល

ទាក់ទងជាមួយបញ្ហា មករួមទុកជាមួយពួកបញ្ហា ដោយចែកជានិទ្ទេសៗ រួមទាំងអស់មាន ២៣ និទ្ទេស និង ប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡងដេញដោល ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើកគម្ពីរអដ្ឋកថាភាសាសីហឡៈឲ្យលោកប្រែជាភាសាមគធៈ តទៅព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និង ល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង , ដូច្នោះ គម្ពីរវិសុទ្ធិមគ្គនេះ ជាវិជ្ជានិពន្ធ ដើម្បីសាកល្បង ចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទាព្រះពុទ្ធជាម្ចាស់ ប្រៀបដូចជា ព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាកួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វដែលប្រៀបដូចជាផ្កាឈូក ឲ្យដឹងវិសេស ទ្រង់មានព្រះបញ្ញាគុណ ដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និង ព្រះករុណាគុណដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មង រះឡើងក្នុងលោក គប្បីបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោក រុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជៈនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យ ដែលកើតឡើងហើយដោយប្រការនោះ ៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបុរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារ នៃបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងល្អ ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេច

ភាពបរិសុទ្ធិ ដែលលោកជានាថ មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ ទ្រង់បានសម្រេច ហើយសម្តែងទុក មិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈសម្មាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្តីដ៏ល្អិត ឲ្យបរិសុទ្ធ និង ប្រកបដោយ របៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គ នោះឯង របស់ខ្ញុំម្ចាស់ ដែលប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះ ។

# អារម្ភកថា

ការប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** ដែលពន្យល់ដោយបរមត្ថមញ្ជូសាមហាដីកា ខ្ញុំបាទបានរៀបរៀងដោយល្អ មកជាខេមរភាសា និង រៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជន ! ទាំងឡាយដែលមានចិត្តកក្តី ចំពោះព្រះរតនត្រៃ អនុមោទនានូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ខ្ញុំបាទសូមឧទ្ទិសកុសលជូនមាតាបិតាជាព្រះអរហន្តបច្ចុប្បន្ន ព្រមទាំងអតីតកាលផង ពួកញាតិក្នុងសង្សារវដ្តផង និង សព្វសត្វក្នុងត្រៃលោកផង លោកគ្រូបណ្ឌិត ទាំងពីរ គឺ :

លោកគ្រូ **អគ្គបណ្ឌិតធម្មាចារ្យ** **ប៊ុត សាវង្ស** ផង

លោកគ្រូ **បណ្ឌិតធម្មាចារ្យ** **រស់ សុផាត** ផង

ដែលលោកទាំងពីរជាអាចារ្យរបស់ខ្ញុំ ជាអ្នកមានសីល មានចរិយាបរិសុទ្ធ ។ ខ្ញុំអាស្រ័យលោកទាំងពីរហើយ ទើបបានសិក្សានូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ក្នុងបដិបទាដ៏ត្រង់តែមួយគត់ គឺសតិប្បដ្ឋាន ៤ ប្រព្រឹត្តទៅដើម្បី វិសុទ្ធិ គឺ **ព្រះនិព្វាន** ។

បាត់ដំបង , ថ្ងៃ១៥ កើត ខែកត្តិក ព.ស ២៥៤៨

ធ្វើជាធម្មទានដោយខ្ញុំបាទ **ហាយ ចំរើន-អ៊ុម រ៉ៃយ៉ា**

# កម្មដ្ឋានគហណនិទ្ទេស

ព្រោះហេតុនៃសមាធិ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្តែងទុកដោយមាតិកា គឺ **ចិត្ត** តាមព្រះបាលី ( និក្ខេបបទ ) ថា :

***សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ*** នោះដែលព្រះយោគាវចរអ្នកតាំងមាំនៅក្នុងសីលនេះ ដែលផូរផង់ដោយគុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ដែលខ្លួនធ្វើឲ្យដល់ព្រមដោយការរក្សាធុតង្គយ៉ាងនេះហើយ គួរបំពេញតទៅ ក៏តែថា សមាធិនោះមិនងាយសូម្បីត្រឹមតែនឹងយល់ នឹងនិយាយថ្វីដល់ទៅការបំពេញនោះ ព្រោះទ្រង់សម្តែងទុក( ក្នុងព្រះគាថានោះ )សង្ខេបណាស់ ព្រោះហេតុនោះ ដើម្បីសម្តែងសេចក្តីពិស្តារ និង ន័យនៃការបំពេញសមាធិនោះ ទើបសូមតាំងសំណួរឡើងដូច្នេះគឺ :

១- អ្វីជាសមាធិ ?

២- ដែលឈ្មោះថា សមាធិ ព្រោះអត្ថដូចម្តេច ?

៣- អ្វីជាលក្ខណៈ រស បច្ចុប្បដ្ឋាន និង បទដ្ឋាននៃសមាធិនោះ ?

៤- សមាធិ មានប៉ុន្មានយ៉ាង ?

៥- អ្វីជាសេចក្តីសៅហ្មង និង ផូរផង់របស់សមាធិនោះ ?

៦- សមាធិ នឹងគប្បីចម្រើនឡើងយ៉ាងណា ?

៧- អ្វីជាអានិសង្សនៃការចម្រើនសមាធិ ?

តទៅនេះជាពាក្យឆ្លើយក្នុងបញ្ហានេះ :

# សមាធិដោយសង្ខេប

មាតិកាថា **អ្វីជាសមាធិ** ដោះស្រាយថា សមាធិមានច្រើនយ៉ាង ច្រើនប្រការ កាលនឹងឆ្លើយ ដើម្បីឲ្យសមាធិនោះជាក់ច្បាស់ទៅគ្រប់យ៉ាងនោះ នឹងមិនគប្បីញុំាងប្រយោជន៍ ដែលបំណងឲ្យសម្រេចបាននោះឡើយ ហើយថែមទាំងប្រព្រឹត្តទៅដើម្បីភាពស្មុគស្មាញក្រៃលែងឡើង ព្រោះដូច្នោះ យើងមកនិយាយគ្នាសំដៅសេចក្ដីបំណងក្នុងទីនេះតែមួយចុះថា “ **ភាពមានអារម្មណ៍តែមួយនៃចិត្តដែលជាកុសល ជា សមាធិ** ” ។

# អត្ថនៃសមាធិសព្ទ

មាតិកាថា ឈ្មោះថា **សមាធិ** ព្រោះអត្ថដូចម្ដេច ដោះស្រាយថា ឈ្មោះថា **សមាធិ** ព្រោះអត្ថថា តាំងមាំ សួរថា ឈ្មោះថា តាំងមាំនោះដូចម្ដេច ឆ្លើយថា ឈ្មោះថា **តាំងមាំនេះ** គឺ ការតម្រង់នៅ អធិប្បាយថា តាំងនៅស្មើល្អផង ត្រូវផ្លូវផងនៃចិត្ត និងចេតសិកទាំងឡាយ ក្នុងអារម្មណ៍តែមួយ ព្រោះហេតុនោះ គប្បីជ្រាបថា ចិត្តចេតសិកជាធម្មជាតិ មិនរវើរវាយ និងមិនរាយមាយទៅ តាំងនៅស្មើនិងត្រូវផ្លូវ ដោយអានុភាពនៃធម៌ណា ការតាំងនៅនៃចិត្តនិងចេតសិកស្មើល្អ និងត្រូវផ្លូវ ដោយអានុភាពនៃធម៌នោះ នេះឈ្មោះថា **ការតាំងមាំ** ។

## លក្ខណៈ រស បច្ចុប្បដ្ឋាន បទដ្ឋាននៃសមាធិ

ចំណែកក្នុងមាតិកាថា អ្វីជាលក្ខណៈ រស បច្ចុប្បដ្ឋាន បទដ្ឋាននៃសមាធិនោះ មានពាក្យដោះស្រាយថា សមាធិមានការមិនរាយមាយជាលក្ខណៈ មានការ

កម្ចាត់ភាពរាយមាយជារស ( កិច្ច ) មានការមិនញាប់ញ័រជាបច្ចុប្បដ្ឋាន ចំណែក បទដ្ឋាននៃសមាធិនោះ គឺ សេចក្តីសុខ តាមព្រះបាលីថា ចិត្ត របស់អ្នកមាន សេចក្តីសុខ រមែងតាំងមាំ ដូច្នេះ ។

# ប្រភេទនៃសមាធិ

ត្រង់មាតិកាថា **សមាធិ មានប៉ុន្មានយ៉ាងនោះ** មានចម្លើយថា ពោលដោយ លក្ខណៈ គឺ ការមិនរាយមាយ **សមាធិ** ក៏មានត្រឹមតែម្យ៉ាង (តែ)អាចចែកជា ២ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ , ដោយអំណាចនៃលោកិយ-សមាធិ និងលោកុត្តរសមាធិ , ដោយអំណាចនៃសប្បីតិកសមាធិ ( សមាធិដែល សម្បយុត្តដោយបីតិ) និងនិប្បីតិកសមាធិ( សមាធិមិនសម្បយុត្តដោយបីតិ ) និង ដោយអំណាចនៃសមាធិដែលជាសុខសហគត( កើតរួមដោយសុខ ) និងឧបេក្ខា-សហគត( កើតរួមដោយឧបេក្ខា ) ចែកជា៣ ដោយចាត់ជាគ្រោតគ្រាត កណ្តាល ប្រណីត ដោយចាត់តាមអង្គ គឺ វិតក្កៈ វិចារៈ មានសវិតក្កសវិចារសមាធិ(សមាធិ នៅមានវិតក្កវិចារ) ជាដើម ដោយចាត់តាមធម៌ដែលសហគត មានបីតិសហគត-សមាធិ ( សមាធិដែលសហគតដោយបីតិ ) ជាដើម និងដោយចាត់ ( តាម គុណានុភាព ) ជា បរិត្ត មហគ្គត និងអប្បមាណ, បើចែកជា ៤ គឺ ដោយចែក តាមការបដិបត្តិ និង ការត្រាស់ដឹង មានទុក្ខាបដិបទាទន្ធាភិញ្ញាសមាធិជាដើម , ដោយចែកតាមអានុភាព និង អារម្មណ៍ មានបរិត្តបរិត្តារម្មណ៍សមាធិជាដើម , ដោយជាអង្គនៃចតុត្ថជ្ឈាន , ដោយចែកតាមចំណែក មានហានភាគិយសមាធិ ជាដើម , ដោយចែកតាមភូមិ មានកាមាវចរសមាធិជាដើម និង ដោយចែកតាម

ឥទ្ធិបាទ ដែលជា អធិបតី , បើចែកជា ៥ ដោយអំណាចជាអង្គនៃបញ្ចកជ្ឈាន ក្នុងបញ្ចកនយ ។

ក្នុងសមាធិទាំងនោះ សមាធិដែលចែកបានជាចំណែកមួយ មានសេចក្តីរាក់ទាំងអស់ ។

# មហាដីកា

## ពណ៌នាកម្មដ្ឋានគហណនិទ្ទេស

ពាក្យថា ( ដោយគុណទាំងឡាយ ) **មានការប្រាថ្នាតិចជាដើម** គឺ មានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស ការជុសខាត់កិលេស ភាពស្ងប់ស្ងាត់ ការមិនសន្សំ និង ការប្រារព្ធសេចក្តីព្យាយាមជាដើម ។

ពាក្យថា **ដែលផូរផង់** គឺ បរិសុទ្ធល្អ បានដល់ ដែលប្រាសចាកនូវឧបក្កិលេស ។

ពាក្យថា **ក្នុងសីលនេះ** បានដល់ ក្នុងចតុប្បារិសុទ្ធិសីល តាមដែលពោលហើយ ។ លោកអាចារ្យពោលថា ព្រោះភាពដែលទ្រង់សម្តែងទុកដោយសង្ខេបក្រៃលែងណាស់ ដូច្នេះសំដៅយកព្រះធម៌ទេសនាដែលថា **ចិត្តំ ភាវយំ** ចម្រើនចិត្តនេះនោះឯង ។ ពាក្យថា **អ្វីគឺសមាធិ** ជាពាក្យសួរដល់សភាវៈដែលមានហើយ ( ដែលហៅថា **សមាធិ** )។ ពាក្យថា **ឈ្មោះថាសមាធិព្រោះអត្ថថាដូចម្តេច** គឺ ព្រោះអត្ថន័យដូចម្តេច ទើបហៅថា **សមាធិ** , សេចក្តីថា បទថា “ **សមាធិ** ” ប្រព្រឹត្តទៅអាស្រ័យអត្ថន័យដូចម្តេច ដើម្បីតាំងឈ្មោះ ។

ពាក្យថា **មានប៉ុន្មានយ៉ាង** ជាពាក្យសួរដល់ប្រភេទ ។

ពាក្យថា “ **អ្វីគឺសមាធិ** ” នេះ ជាពាក្យសួរដល់សភាវៈដែលមានពិត តែថា ការបើកផ្ទាសភាវៈដែលមាន នៃធម៌ទាំងឡាយដែលមានការចែកបាន រមែងមានបានដោយសម្ដែងនូវ ការចែកទុកជាចន្លោះនោះឯង ព្រោះហេតុនោះ គួរសម្ដែងការចែកដោយមិនមានសល់ជាមុនសិន ។ តែលោកអាចារ្យបំណងឲ្យឃើញថា ក្នុងការសម្ដែងការចែកដោយមិនមានសល់នោះ មានសេចក្ដីនេះជាទោស ដូច្នេះទើបពោលថា “ **សមាធិមានច្រើនយ៉ាង** ” ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **មានច្រើនយ៉ាង** ក៏មានច្រើនយ៉ាងជាអនេកដោយទាក់ទិនជាមួយ ភាពជាកុសលជាដើម ។ ពាក្យថា **មានច្រើនប្រការ** គឺមានច្រើនប្រការ ព្រោះភាពដែលមាន អារម្មណ៍ វិមោក្ខ សញ្ញា មនសិការៈ ឆន្ទៈ បណិធិ អធិមោក្ខៈ អភិនីហារ និង បញ្ញា ផ្សេងៗគ្នាជាដើម ។ ពាក្យថា **នឹងមិនគប្បីញុំាង**(ប្រយោជន៍ដែលបំណង)ឲ្យសម្រេច មានន័យថា ការចម្រើនលោកិយសមាធិឈ្មោះថា ប្រយោជន៍ក្នុងទីនេះ , ហើយមិនគប្បីញុំាងប្រយោជន៍ដែលប្រាថ្នានោះឲ្យសម្រេចបាន ។ ពិតណាស់ ក្នុងបណ្ដា ឈាន និង វិមោក្ខ ជាដើម កាលលើកសមាធិឡើងធ្វើការវិសជ្ជនាសមាធិនោះទៅ ដោយការចែកបាន ក៏ជាការនឹងត្រូវវិសជ្ជនាប្រភេទនៃសមាធិទាំងអស់ ដែលមកក្នុងឈានវិភង្គជាដើម ។ ហើយកាលបើដូច្នេះ ក៏មិនមានឱកាសវិសជ្ជនាវិធីចម្រើនលោកិយសមាធិដែលបំណងនេះបានឡើយ ។ សូមសម្ដែងត្រឹមតែបន្តិចបន្តួច គឺថា ប្រភេទនៃភពរបស់សមាធិនោះមាន ៩ យ៉ាង ដោយទាក់ទិនជាមួយព្រហ្មបារិសជ្ជាជាដើម រមែងសម្រេចដោយការចែក ការប្រព្រឹត្តទៅ ដែលប្រកបដោយឈាន ៣ ឬ ឈាន ៤ ( ដែលមានវេទនាជាសោមនស្ស ) ដែលផ្សេងគ្នា ព្រោះភាពផ្សេងគ្នានៃឈានដែលគ្រោតគ្រាត

ជាដើម , មាន ១០ យ៉ាង ឬ ១១ យ៉ាង ដោយទាក់ទិននឹងព្រហ្មជាន់វេហប្ផលា ជាដើម រមែងសម្រេចដោយការចែក ការប្រព្រឹត្តទៅ ដែលប្រកបដោយឈានទី ៥ ឯណា ការចែកការប្រព្រឹត្តទៅនោះ នៃសមាធិនោះ ដែលដកចេញមកពោលថា នេះគឺ សមាធិនោះ ដូច្នេះគប្បីមានដើម្បីភាពសាំញ៉ាំ ស្មុគស្មាញ សេចក្ដីនោះ ហាក់ដូចជាប្រព្រឹត្តទៅក្នុងវត្ថុដែលមិនមែនជាវិស័យ ។

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ហើយនឹងគប្បីប្រព្រឹត្តទៅ ដើម្បីភាពសាំញ៉ាំស្មុគស្មាញក្រៃលែងឡើងដូច្នេះ ។

ពាក្យថា **ភាពមានអារម្មណ៍តែមួយនៃចិត្តដែលជាកុសល** គឺ មិនមាន ទោស និង មានវិបាកជាសុខ ជាលក្ខណៈ ។

សេចក្ដីតាំងមាំជានិច្ច ដោយទាក់ទិនជាមួយភាពមិនធ្វើឲ្យចិត្ត និង ចេតសិក ទាំងឡាយខ្ចាត់ខ្ចាយរាត់រាយ បីដូចជាប្រមូលទុក ឈ្មោះថា **សមាធាន** ។ ពិត ណាស់ សមាធិមានការមិនធ្វើឲ្យខ្ចាត់ខ្ចាយរាត់រាយជាលក្ខណៈ និងមានការប្រមូល ចូលទុកជារស ។ ការតាំងមាំដោយល្អ គឺ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា **សមាធាន** ។ ម្យ៉ាងទៀត **សមាធិ** មានការមិនរាយមាយជាលក្ខណៈ និងមានការកម្ចាត់ភាពរាយមាយជារស។ សមាធិនេះនោះ ព្រោះហេតុដែលជាហេតុ នៃការតាំងនៅបានក្នុងអារម្មណ៍តែមួយនៃចិត្ត ព្រោះហេតុនោះ ទើបលោកពោលថា មានអធិប្បាយថា ជាការតាំងនៅបានដូច្នេះ ។ ពិតយ៉ាងនោះ សមាធិនេះ ទ្រង់ សម្ដែងលំអិតទុកហើយថា " **ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ** " ការតាំងនៅបាន ការតាំងនៅដោយល្អ ការតាំងស៊ប់នៃចិត្ត ដូច្នេះ ។

ក៏ក្នុងទីនេះលោកប្រើសព្ទថា អារម្មណ៍តែមួយដើម្បីជាការតាំងនៅបានដោយ

ជាប់តគ្នានៃសមាធិ ។ ពិតយ៉ាងនោះ ក្នុងអដ្ឋកថាលោកសម្ដែងលំអិតទុកថា សមាធិនោះ មានការតាំងនៅដូចអណ្ដាតប្រទីប ។ ពាក្យថា **ដោយអានុភាព** គឺ ដោយកម្លាំង មានន័យថា ដោយភាពជាបច្ច័យ។ ពាក្យថា **អវិក្ខិបមានា** ប្រែថា ជាធម្មជាតិមិនរាយមាយ គឺ ចូលទៅស្ងប់ ។ ដូច្នេះ **សមាធិ** មានការចូលទៅស្ងប់ជាបច្ចុប្បដ្ឋាន ។ ដោយពាក្យថា **អវិក្ខិបមានា** នេះ លោកសម្ដែង ភាពជាបដិបក្ខចំពោះការរាយមាយនៃសមាធិនោះ ។

ពាក្យថា **អវិប្បកិណ្ណា** ប្រែថា មិនរាត់រាយ ។ ដោយពាក្យនេះ លោកសម្ដែងការមិនធ្វើឲ្យខ្ចាត់ខ្ចាយរាត់រាយជាលក្ខណៈ ។

ឈ្មោះថា **អវិក្ខេប** ព្រោះអត្ថថា មិនរាយមាយនោះឯង , ឬជាហេតុឲ្យសម្បយុត្តធម៌ទាំងឡាយមិនរាយមាយ , **សមាធិ** ឈ្មោះថា **អវិក្ខេប លក្ខណោ** ព្រោះអត្ថថា មានអវិក្ខេបៈនោះឯងជាលក្ខណៈ ។ ពាក្យថា **វិក្ខេបវិទ្ធំសន រសោ** ព្រោះអត្ថថា កម្ចាត់សេចក្ដីរាយមាយបាន ឬដល់ព្រមដោយអាការដែលកម្ចាត់នូវការរាយមាយនោះ ។ ឈ្មោះថា **អវិកម្បន បច្ចុប្បដ្ឋានោ** ព្រោះអត្ថថា ប្រាកដដោយអំណាចនៃការមិនញាប់ញ័រដោយឧទ្ធច្ចៈ ឬ ញ៉ាំងការមិនញាប់ញ័រនៃសម្បយុត្តធម៌ទាំងឡាយនោះឲ្យប្រាកដ ។ ពាក្យថា **សុខ** គប្បីឃើញថា បានដល់ សុខដែលមិនមានអាមិស ។

ឈ្មោះថា **លក្ខណៈ** គឺ **អវិក្ខេប** ( មិនរាយមាយ ) ជាសភាវៈមានចំពោះសម្រាប់សមាធិដោយលក្ខណៈនោះ សមាធិនោះ រមែងមិនបានការចែកជាចំណែកណា ៗ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដំបូង សមាធិមានតែម្យ៉ាងដោយលក្ខណៈគឺ **មិនរាយមាយ** ដូច្នេះ ។ **វិតក្ក** ឈ្មោះថា **អប្បនា** ព្រោះអត្ថថា

ប្រព្រឹត្តទៅហាក់បីដូចជា ញ៉ាំងសម្បយុត្តធម៌ទាំងឡាយឲ្យស៊ប់សួនក្នុងអារម្មណ៍ ។ ពិតយ៉ាងនោះ ទ្រង់សម្តែងលម្អិតវិតក្កនោះទុកថា **អប្បនា ព្យប្បនា** ដូច្នេះ ។ តែមានពាក្យក្នុងអដ្ឋកថា ថា " **អប្បនា** " មានក្នុងឈានធម៌ដែលជាមហគ្គតៈ និងលោកុត្តរទាំងពួង ដោយអំណាចនៃការដែលមានអប្បនាវិតក្កនោះជាប្រធានដូច្នេះ។ ដូចគ្នានោះដែរ វោហារថា **ឧបចារ** រមែងមានក្នុង **បរិត្តឈាន**( កាមាវចរឈាន ) ដែលមិនជាទីកើតឡើងនៃអប្បនាវិតក្កនោះ ដូចយើងហៅយ៉ាងសាមញ្ញថា ឧបចារផ្ទះជាដើម រមែងមានក្នុងទីជិតផ្ទះជាដើមដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា " មាន ២ យ៉ាង គឺ ឧបចារសមាធិ និង អប្បនាសមាធិ " ដូច្នេះ ក៏ក្នុងទីនេះ គប្បីជ្រាបពាក្យនិយាយដែលទាក់ទងនឹងសមាធិ ។ **វដ្តៈ** លោកហៅថា **លោក** ព្រោះអត្ថថា វិនាស ឬ បែកធ្លាយ ។

ឈ្មោះថា **លោកិយសមាធិ** ព្រោះអត្ថថា ជាសមាធិដែលប្រកបក្នុងលោក ព្រោះភាពដែលសង្គ្រោះចូលក្នុងលោក ឬ ជាសមាធិដែលជួបបានក្នុងលោក ។

ឈ្មោះថា **លោកុត្តរសមាធិ** ព្រោះអត្ថថា ជាសមាធិដែលឆ្លងផុត គឺឆ្លងផុតបានហើយអំពីលោក ព្រោះភាពដែលមិនសង្គ្រោះចូលក្នុងលោក ។ ក្នុងទីនេះ លោកកាន់យកលោកិយសមាធិ ដោយភាពជាសមាធិដែលគួរចម្រើន ក៏ពិត តែដើម្បីនឹងរួបរួមសមាធិទាំង២ ឲ្យជាចំណែក១ ហើយដកយក លោកុត្តរសមាធិនេះចេញទៅអំពីទីរួមគ្នានោះ ទើបពោលថាមាន ២ យ៉ាង គឺ លោកិយសមាធិ និង លោកុត្តរសមាធិដូច្នេះ ។ ពាក្យថា **សមាធិដែលមានបីតិ និងសមាធិដែលមិនមានបីតិ** មានន័យថា សមាធិឈ្មោះថាមានបីតិ ក៏ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយបីតិ បានដល់ សមាធិដែលសម្បយុត្តជាមួយបីតិ ។ សមាធិដែលរកបីតិមិនបាន

ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានបីតិ បានដល់ សមាធិដែលវិប្បយុត្ត ជាមួយ បីតិ ។ សមាធិមាន ២ យ៉ាង គឺ សមាធិដែលមាន បីតិ និង សមាធិដែលមិនមាន បីតិ ។ សមាធិឈ្មោះថា **សហគតដោយសុខ** ព្រោះអត្ថថា ដល់នូវភាពកើតឡើងព្រមគ្នាជាមួយសុខជាដើម បានន័យថា ជាសមាធិសម្បយុត្តជាមួយសុខ។ សូម្បីក្នុងសមាធិដែលសហគតដោយឧបេក្ខា ក៏មានន័យយ៉ាងនេះដែរ ។

ក៏ក្នុងបទថា **ឧបេក្ខា** នេះ បំណងយកអទុក្ខមសុខវេទនា ។ ពិតណាស់ អទុក្ខមសុខវេទនានោះ រមែងព្រងើយកន្តើយនឹងភាពប្រព្រឹត្តទៅដោយអាការដែលជាសុខ និង ទុក្ខ ព្រោះតាំងមាំនៅដោយអាការដែលជាកណ្ដាល ( ព្រោះដូច្នោះ វេទនានេះ ទើបមានឈ្មោះ ម្យ៉ាងទៀតថា **ឧបេក្ខា** ) ។ ម្យ៉ាងទៀត ក្នុងទីនេះ សង្គ្រោះយកសមាធិដែលមានបីតិ ( ឈាន ៣ ខាងដើម ) និង ចំណែកមួយនៃសមាធិដែលមិនមាន បីតិ ( ឈានទី៤ ) ចូល ដោយបទថា សហគតដោយសុខ ឬក៏ថា សង្គ្រោះយកចំណែកមួយនៃសមាធិ ដែលមិនមានបីតិ( ឈានទី៥ ) ចូល ដោយបទថា សហគតដោយឧបេក្ខា សេចក្ដីដែលពោលមកយ៉ាងនេះៗ ជាសេចក្ដីផ្សេងគ្នានៃបទទាំងឡាយនោះ ។

**សមាធិ** ឈ្មោះថា **គ្រោតគ្រាត** ក៏ព្រោះអត្ថថា អន់ជាងសមាធិជាកណ្ដាល និងដែលជាប្រណីត ដោយសភាវៈ ដោយបច្ច័យ និងដោយផល ឬថា ប្រាសចាកគុណទាំងឡាយរបស់សមាធិថ្នាក់កណ្ដាល និង ថ្នាក់ប្រណីតនោះ សមាធិដែលបច្ច័យទាំងឡាយរបស់ខ្លួននាំចូលទៅកាន់ភាពជាប្រធាន ឈ្មោះថា យ៉ាងប្រណីត សមាធិដែលមានក្នុងរវាងនៃសមាធិទាំង ២ ឈ្មោះថា **កណ្ដាល** សមាធិដែលប្រព្រឹត្តទៅជាមួយវិតក្ក ដែលប្រព្រឹត្តទៅដោយការប្រកបរួមគ្នា ឈ្មោះថា **មាន**

**វិតក្ក** ដែលប្រព្រឹត្តទៅជាមួយវិចារ ឈ្មោះថា **មានវិចារ** សមាធិមានវិតក្កផងមានវិចារផង ព្រោះហេតុនោះ ទើបឈ្មោះថា **មានវិតក្កៈ មានវិចារៈ** ។ ដោយ **អាទិ** ស័ព្ទ ( ដែលប្រែថា ជាដើម ) កាន់យកសមាធិដែលមិនមានវិតក្ក មានត្រឹមតែវិចារ និង សមាធិដែលមិនមានវិតក្ក មិនមានវិចារ ។ ក្នុងបណ្ដាសមាធិទាំងនោះ សមាធិមិនមានវិតក្កៈ ព្រោះមិនមានការប្រកបរួមជាមួយវិតក្កៈ ដែលមានត្រឹមអំពីវិចារៈឡើងទៅ ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានវិតក្កៈ មានត្រឹមតែវិចារៈ។

ម្យ៉ាងទៀត **មត្ត** ស័ព្ទ(ក្នុងពាក្យថា **អវិតក្កវិចារមត្តោ**) មានអត្ថថា ហាមធម្មវិសេស។ ពិតហើយ សមាធិ មានប្រកបដោយវិតក្កៈវិចារៈ, ឈ្មោះថា សមាធិដែលមានវិចារៈ ព្រោះវិចារៈពិសេសក៏ដោយវិតក្កៈ តែថា សមាធិនេះ ព្រោះមានតែវិចារៈ ដែលវៀរចាកធម្មវិសេស ពោលគឺ វិតក្កៈ, ព្រោះដូច្នោះ ទើបឈ្មោះថា មិនមានវិតក្កៈ មានត្រឹមវិចារៈ ។ ន័យម្យ៉ាងទៀត ដើម្បីសម្ដែងថា សមាធិនេះ ឈ្មោះថា មានតែវិចារៈ ព្រោះមិនមានវិតក្កៈ ព្រោះហេតុ ត្រូវលះបង់ទៅដោយភាវនា , ដែលឈ្មោះថា មានតែវិចារៈ ព្រោះមិនមានធម៌ណាៗ ដែលសម្បយុត្តជាមួយខ្លួនក្រៅអំពីវិចារៈនោះក៏ទេ ដូច្នេះ ទើបលោកពោលបទថា **វិចារមត្ត** មានត្រឹមតែវិចារៈឲ្យវិសេសទៅ ដោយពាក្យថា **អវិតក្ក** មិនមានវិតក្កៈ ។

សមាធិដែលវៀរចាកធម៌ទាំង ២ ឈ្មោះថា សមាធិដែលមិនមានវិតក្កៈ មិនមានវិចារៈ ។

ពាក្យថា **គឺ សមាធិដែលសហគតដោយបីតិជាដើម** គឺ សមាធិដែលសហគតដោយបីតិ សមាធិដែលសហគតដោយសុខ និង សមាធិដែលសហគតដោយឧបេក្ខា ។ មានពាក្យណា ដែលគួរពោលក្នុងតិកៈនេះ ពាក្យនោះមានន័យ

ដូចបានពោលហើយ ក្នុងទុកៈនៃសមាធិដែលសហគតដោយសុខជាដើមនោះឯង ។ សមាធិឈ្មោះថា **បរិត្ត** ព្រោះត្រូវធម៌ដែលជាសត្រូវទាំងឡាយ កាត់ផ្តាច់ដោយជុំវិញ ។ ម្យ៉ាងទៀត វត្ថុដែលមានប្រមាណតូចច្មារ លោកហៅថា **បរិត្ត** , សូម្បីសមាធិនេះ ក៏មានសភាពតូចច្មារ ព្រោះហេតុនោះ ទើបឈ្មោះថា **បរិត្ត** ។

**សមាធិ** ឈ្មោះថា **មហគ្គត** ព្រោះអត្ថថា ទៅកាន់ភាពក្រៃលែងដោយការគ្របសង្កត់កិលេសបាន , ដោយមានផលច្រើន និង ដោយមានការបន្តគ្នាបានយូរ ឬថា **ទៅ** គឺ ដំណើរទៅ ដោយធម៌ទាំងឡាយដ៏ធំក្រៃលែង មានឆន្ទៈដែលជាឱឡារិកៈជាដើម ។

**សមាធិ** ឈ្មោះថា **អប្បមាណ** ព្រោះអត្ថថា មិនមានធម៌ដែលធ្វើប្រមាណទាំងឡាយ សូម្បីដោយទាក់ទងជាមួយនឹងការធ្វើឲ្យជាអារម្មណ៍ ឬថា ជាបដិបក្ខចំពោះធម៌ដែលធ្វើឲ្យមានប្រមាណទាំងនោះ ។

**ភាវនា** ដែលជាចំណែកខាងដើម ឈ្មោះថា **បដិបទា** ព្រោះអត្ថថា ជាគ្រឿងបដិបត្តិឈាន ។ **សមាធិ** ឈ្មោះថា **ទុក្ខាបដិបទ** ព្រោះអត្ថថា មានបដិបទាជាទុក្ខ គឺ លំបាក ។ ភាវនាបញ្ញាដែលនាំមកនូវអប្បនា ឈ្មោះថា **អភិញ្ញា** ព្រោះភាពជាបញ្ញា ដែលវិសេសក្រៃលែងជាង បកតិប្បញ្ញា , **សមាធិ** ដែលឈ្មោះថា **ទន្ធាភិញ្ញ** ព្រោះអត្ថថា មានអភិញ្ញាយឺតយូរ គឺ ទន់ខ្សោយ ។ **សមាធិ** ឈ្មោះថា **ទុក្ខាបដិបទ** ផង **សមាធិ** ឈ្មោះថា **ទន្ធាភិញ្ញ** ផង ព្រោះហេតុនោះ ទើបឈ្មោះថា **ទុក្ខាបដិបទាទន្ធាភិញ្ញសមាធិ** , សមាធិមាន៤យ៉ាង គឺ ទុក្ខាបដិបទាទន្ធាភិញ្ញសមាធិជាដើមនោះ ។

បទថា **ចតុក្កឈានង្គវសេន** ប្រែថា គឺ ភាពជាអង្គនៃឈាន ៤ , ក៏ពាក្យនេះ

លោកពោលទុកដោយទាក់ទងជាមួយឈាន **ចតុក្កន័យ** ។ ពាក្យថា **គឺ សមាធិដែលជាហានភាគិយជាដើម** មានន័យថា គឺ សមាធិដែលមានចំណែក នៃសេចក្តីវិនាសជាដើម ។

☹ **នត្ថិ ខន្ធា សមា ទុក្ខា** ☹

( ចប់មហាដីកា )

## ទុកៈទី ១ (សមាធិពូក ២)

អត្ថាធិប្បាយក្នុងសមាធិដែលចែកជា ២ គប្បីជ្រាបដូចតទៅនេះ ឯកគ្គតានៃចិត្តដែលព្រះយោគាវចរបានដោយអំណាចធម៌ទាំងនេះ គឺ អនុស្សតិដ្ឋានទាំង ៦ មរណស្សតិ ឧបសមានុស្សតិ អាហារេបដិកូលសញ្ញា ចតុធាតុវវដ្ឋានក្តី ឯកគ្គតាក្នុងចំណែកខាងដើមនៃអប្បនាសមាធិទាំងឡាយក្តីឯណា ឯកគ្គតានោះ ជាឧបចារ-សមាធិ ចំណែកឯកគ្គតាក្នុងលំដាប់នៃបរិកម្មតាមព្រះបាលីថា បរិកម្មនៃបឋមជ្ឈានជាបច្ច័យដោយអនន្តរប្បច្ច័យនៃបឋមជ្ឈាន ដូច្នេះជាដើមឯណា ឯកគ្គតានោះ ជាអប្បនាសមាធិ យ៉ាងនេះឯង សមាធិចែកជា ២ ដោយអំណាចនៃឧបចារសមាធិ និង អប្បនាសមាធិ ។

## ទុកៈទី ២

ឯកគ្គតានៃចិត្តដែលជាកុសលក្នុងភូមិ ៣ ជាលោកិយសមាធិ ឯកគ្គតាដែលសម្បយុត្តដោយអរិយមគ្គ ជាលោកុត្តរសមាធិ យ៉ាងនេះឯង សមាធិជា ២ ដោយអំណាចនៃ លោកិយ និង លោកុត្តរ ។

## ទុកៈទី ៣

ឯកគ្គតាក្នុង ២ ឈាន ក្នុងចតុក្កន័យ , ក្នុង ៣ ឈាន ក្នុងបញ្ចកន័យ ជាសប្បីតិកសមាធិ ឯកគ្គតាក្នុងឈាន២ដ៏សេសជា និប្បីតិកសមាធិ តែឧបចារសមាធិជួនកាលជាសប្បីតិកសមាធិ ជួនកាលជានិប្បីតិកសមាធិ យ៉ាងនេះឯង សមាធិជា ២ ដោយអំណាចនៃ សប្បីតិកៈ និង និប្បីតិកៈ ។

## ធុកៈទី៤

ឯកគ្គតាក្នុង៣ឈាន ក្នុងចតុក្កន័យ , ក្នុង៤ឈាន ក្នុងបញ្ចកន័យ ជាសុខ-សហគតសមាធិ ឯកគ្គតាក្នុងឈានដ៏សេស ជាឧបេក្ខាសហគតសមាធិ តែឧបចារសមាធិ ជួនកាលក៏ជាសុខសហគត ជួនកាលក៏ជាឧបេក្ខាសហគត យ៉ាងនេះឯង សមាធិជា ២ ដោយអំណាចនៃសុខសហគត និង ឧបេក្ខាសហគត ។

## មហាដីកា

## ពណ៌នាសមាធិពួក១ និងពួក២

ពាក្យថា **អនុស្សតិដ្ឋាន ៦** បានដល់ អនុស្សតិកម្មដ្ឋាន ៦ មានពុទ្ធានុស្សតិជាដើម ។

ពាក្យថា **ដោយអំណាចកម្មដ្ឋានទាំងនោះ** គឺ ដោយអំណាចកម្មដ្ឋាន ១០ យ៉ាងទាំងនេះ ។ ដោយពាក្យនិយាយថា **ឯកគ្គតាក្នុងចំណែកខាងដើម** នេះគប្បីឃើញថា រួមយកទាំងឧបចារសមាធិដែលមានអាវជ្ជនៈផ្សេង ៗ គ្នា ដែលឧបការចំពោះ អប្បនា , មិនមែនរួមយកចំពោះឧបចារសមាធិដែលមានអាវជ្ជនៈតែម្យ៉ាងប៉ុណ្ណោះនោះទេ ។ ព្រោះថា បទថា **អប្បនាសមាធិនំ** ( របស់អប្បនាសមាធិទាំងឡាយ ) ជាឆដ្ឋីវិភត្តិ ក្នុងការសម្ព័ន្ធគ្នានៃធម៌ដែលគប្បីឧបការ និងធម៌ដែលជាអ្នកឧបការ ដូចក្នុងប្រយោគថា “**បុរិសស្ស អត្ថោ**” ប្រយោជន៍របស់បុរសជាដើមដូច្នេះ ។ ពាក្យថា **បរិកម្ម** បានដល់ គោត្រភូ ។ ដើម្បីសម្ដែងថា មិនមែនសមាធិដែលជាបរិត្ត( ជាកាមាវចរ ) ទើបលោកអាចារ្យពោលថា ដល់បឋមជ្ឈាន ដូច្នេះជាដើម ។

ក្នុងពាក្យថា **ក្នុងភូមិ ៣** បានដល់ ក្នុង កាមភូមិ រូបភូមិ និង អរូបភូមិ ។ លោកពោលថា ដែលសម្បយុត្តជាមួយនឹងព្រះអរិយមគ្គដូច្នេះ ព្រោះលោកបំណងយក ឯកគ្គតានៃចិត្តដែលជាកុសល ។ ពាក្យថា **ជាសមាធិ ដែលមានបីតិក៏មាន សមាធិ ដែលមិនមានបីតិក៏មាន** ជាពាក្យពោលដែលមិនកំណត់ពិតប្រាកដ ។

ម្យ៉ាងទៀត ព្រោះភាពជាឧបចារសមាធិ ដូចគ្នានឹងឧបចារសមាធិក្នុងវិថីដែលមានអាវជ្ជនៈផ្សេងៗគ្នា នៃឈានសូម្បីទាំងពួង ជាសមាធិដែលមានបីតិក៏មាន ជាសមាធិដែលមិនមានបីតិក៏មាន ។ តែឧបចារសមាធិនៃឈាន២ ឬ ឈាន៣ ខាងដើម ក្នុងវិថីដែលមានអាវជ្ជនៈដូចគ្នា ជាសមាធិដែលមានបីតិតែម្យ៉ាង , ឧបចារ-សមាធិនៃឈានក្រៅពីនេះ ( គឺ ឈាន ២ ខាងចុង ) ជាសមាធិដែលមិនមានបីតិណាមួយឡើយ , ព្រោះចិត្តដែលមានវេទនាជាវិសភាគៈគ្នា មិនមានភាពជាអាសេ-វនប្បច្ច័យ និងព្រោះក្នុងវិថីជាមួយគ្នា មិនមានការផ្លាស់ប្តូរនៃវេទនា ។ សូម្បីក្នុងពាក្យថា **ជាសមាធិដែលសហគតដោយសុខក៏មាន , ជាសមាធិដែលសហគតដោយឧបេក្ខាក៏មាន** នេះគប្បីជ្រាបអត្ថន័យ តាមន័យដែលបានពោលហើយនោះឯង ។ ក្នុងទុកៈទី៣ នោះ ខ្ញុំម្ចាស់ពោលថា ( ឧបចារសមាធិ ) " នៃឈាន២ ឬ ឈាន៣ " ( ... ជាសមាធិដែលមានបីតិតែម្យ៉ាង ) ក្នុងទុកៈទី ៤ នេះគួរពោលថា ( ឧបចារសមាធិ )" នៃឈាន៣ ឬឈាន៤ "( ... ជាសមាធិដែលសហគតដោយសុខតែម្យ៉ាង ) ។

( ចប់ មហាដីកា )

# តិកៈទី១(សមាធិពួក៣)

សមាធិដែលទើបតែបានមក ចាត់ជាសមាធិគ្រោតគ្រាត សមាធិដែលអប់រំហើយនៅមិនទាន់ល្អណាស់ណា ចាត់ជាសមាធិកណ្តាល សមាធិដែលអប់រំល្អហើយ ដល់នូវភាពជាវសី ចាត់ជាសមាធិយ៉ាងប្រណីត យ៉ាងនេះឯង សមាធិជា ៣ ដោយចាត់ជាសមាធិប្រភេទគ្រោតគ្រាត ប្រភេទកណ្តាល ប្រភេទប្រណីត ។

# តិកៈទី២

**សមាធិ** ក្នុងបឋមជ្ឈាន និង ឧបចារសមាធិ ចាត់ជាសវិតក្កសវិចារសមាធិ ( សមាធិមានទាំងវិតក្កៈ មានទាំងវិចារៈ ) សមាធិក្នុងទុតិយជ្ឈាន ក្នុងបញ្ចកន័យ ចាត់ជាអវិតក្កវិចារមត្តសមាធិ( សមាធិមិនមានវិតក្កៈ មានតែវិចារៈ ) ក៏បុគ្គលណាឃើញទោសតែក្នុងវិតក្កប៉ុណ្ណោះ មិនឃើញទោសក្នុងវិចារៈ គិតដើម្បីតែនឹងលះវិតក្កៈតែម្យ៉ាង ធ្វើផុតបឋមជ្ឈានទៅ បុគ្គលនោះរមែងបានសមាធិ ដែលមិនមានវិតក្កៈ មានតែវិចារៈ ពាក្យដែលថា សមាធិក្នុងទុតិយជ្ឈានក្នុងបញ្ចកន័យ ចាត់ជាអវិតក្កវិចារមត្តសមាធិនោះ ខ្ញុំម្ចាស់ពោល សំដៅយកសមាធិរបស់បុគ្គលនេះ ចំណែកឯកគ្គតាក្នុង ៣ ឈាន ក្នុងចតុក្កន័យ មានទុតិយជ្ឈានជាដើម និង ក្នុងបញ្ចកន័យ មានតតិយជ្ឈានជាដើម ចាត់ជាអវិតក្កអវិចារសមាធិ ( សមាធិ មិនមានទាំងវិតក្កៈ ទាំងវិចារៈ ) យ៉ាងនេះឯង សមាធិជា ៣ ដោយចាត់តាមអង្គ គឺ វិតក្កៈ វិចារៈ មានសវិតក្កសវិចារសមាធិជាដើម ។

## តិកៈទី៣

ឯកគ្គតាក្នុងឈាន២ខាងដើម ដោយចតុក្កន័យ និងក្នុងឈាន ៣ ខាងដើម ដោយបញ្ចកន័យ ចាត់ជាបីតិសហគតសមាធិ( សមាធិទៅព្រមជាមួយបីតិ ) ឯកគ្គតាក្នុងតតិយជ្ឈាន និង ចតុត្ថជ្ឈានដោយចតុក្កន័យ និង បញ្ចកន័យនោះឯង ចាត់ជាសុខសហគតសមាធិ ( សមាធិទៅព្រមជាមួយនឹងសុខ ) ឯកគ្គតាក្នុងឈានចុងក្រោយ ( ទាំង២ន័យ ) ចាត់ជាឧបេក្ខាសហគតសមាធិ ( សមាធិទៅព្រមជាមួយនឹងឧបេក្ខា ) តែឧបចារសមាធិ រមែងសហគតដោយបីតិ-សុខខ្លះ សហគតដោយឧបេក្ខាខ្លះ យ៉ាងនេះឯង សមាធិជា ៣ ដោយចាត់តាមធម៌ដែលសហគត មានបីតិសហគតសមាធិជាដើម ។

## តិកៈទី៤

ឯកគ្គតាក្នុងភូមិឧបចារ ចាត់ជាបរិត្តសមាធិ( សមាធិមានគុណានុភាពតិច ) ឯកគ្គតាក្នុង( ភូមិ )រូបាវចរ និង អរូបាវចរ ដែលជាកុសល ចាត់ជាមហគ្គតសមាធិ ( សមាធិមានគុណានុភាពធំ ) ឯកគ្គតាដែលសម្បយុត្តដោយអរិយមគ្គ ចាត់ជាអប្បមាណសមាធិ ( សមាធិ មានគុណានុភាពប្រមាណមិនបាន ) យ៉ាងនេះឯង សមាធិជា៣ ដោយចាត់តាមគុណានុភាពជា បរិត្ត មហគ្គត និងអប្បមាណដូច្នេះ ។

## មហាដីកា

### ពណ៌នាសមាធិពួក៣

ពាក្យថា **ទើបតែបានមក** គឺ គ្រាន់តែថាបានសម្រេច នៅមិនទាន់សេពស្អិទ្ធ

នៅមិនទាន់ធ្វើឲ្យច្រើន ។ ក៏សមាធិនោះ ចាត់ជាប្រភេទគ្រោតគ្រាត ព្រោះមានកម្លាំងខ្សោយ ។

ពាក្យថា **ដែលចម្រើនបានមិនល្អណាស់ណា** គឺ ដែលនៅមិនទាន់បានធ្វើឲ្យដល់ភាពក្លៀវក្លាក្រៃលែងឡើង ។ ពាក្យថា **ដែលចម្រើនល្អហើយ** គឺ ដែលចម្រើនបានដោយល្អ បានដល់ នាំចូលទៅកាន់ភាពស្ទាត់ជំនាញបានដោយល្អហើយនោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថាដល់ **វសី** ដូច្នេះ ។

គប្បីជ្រាបសេចក្ដីដែលសមាធិទាំងនេះ ដែលគ្រោតគ្រាតជាដើម សូម្បីដោយទាក់ទងជាមួយសភាពនៃធម៌ទាំងឡាយមានឆន្ទៈជាដើម ថ្នាក់គ្រោតគ្រាតជាដើម ។

ពិតយ៉ាងនោះ សមាធិដែលបុគ្គលធ្វើឲ្យប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រូវការក្នុងផលបុណ្យដ៏ឱឡារ ឈ្មោះថា **គ្រោតគ្រាត** ដែលធ្វើឲ្យប្រព្រឹត្តទៅ ដើម្បីញុំាងលោកិយអភិញ្ញាឲ្យសម្រេចឈ្មោះថា **យ៉ាងកណ្ដាល** ដែលបុគ្គលតាំងនៅក្នុងភាពជាអរិយៈ ធ្វើឲ្យប្រព្រឹត្តទៅដោយភាពត្រូវការវិវេក ឈ្មោះថា **យ៉ាងប្រណីត** ។

ម្យ៉ាងទៀត សមាធិដែលបុគ្គលធ្វើឲ្យប្រព្រឹត្តទៅដើម្បីប្រយោជន៍ខ្លួន គឺ ដើម្បីភពសម្បត្តិ ឈ្មោះថា **ប្រភេទគ្រោតគ្រាត** ដែលធ្វើឲ្យប្រព្រឹត្តទៅដោយមានអធ្យា-ស្រ័យក្នុងអលោភៈសុទ្ធៗ ឈ្មោះថា **ប្រភេទកណ្ដាល** ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍អ្នកដទៃ ឈ្មោះថា **ប្រភេទប្រណីត** ។ ម្យ៉ាងទៀត ធ្វើឲ្យប្រព្រឹត្តទៅដោយមានអធ្យាស្រ័យក្នុងវដ្ដៈ ឈ្មោះថា **ប្រភេទគ្រោតគ្រាត** , ធ្វើឲ្យប្រព្រឹត្តទៅដោយមានអធ្យាស្រ័យក្នុងវិវេក ឈ្មោះថា **ប្រភេទកណ្ដាល** ដែលធ្វើឲ្យដើម្បីជាបាទនៃលោកុត្តរធម៌ដោយមានអធ្យាស្រ័យក្នុងវិវដ្ដៈ ឈ្មោះថា **ប្រភេទប្រណីត** ។

ពាក្យថា **ព្រមជាមួយឧបចារសមាធិ** គឺ ព្រមជាមួយឧបចារសមាធិនៃឈាន

ឈាន សូម្បីគ្រប់ឈាន ( ទាំងអស់ ) ។

ពាក្យថា **ឃើញទោសត្រឹមតែវិតក្កប៉ុណ្ណោះ** មានន័យថា កាលធ្វើឲ្យប្រាកដថា ជារបស់គ្រោតគ្រាតចំពោះក្នុងវិតក្កៈប៉ុណ្ណោះ ក៏ឃើញទោសថា " វិតក្កៈនេះជាធម៌ដែលធ្វើឲ្យចិត្តកម្រើក " ហើយធ្វើទុកក្នុងចិត្តនូវវិចារៈថា ជាធម៌ស្ងប់ ។

ព្រោះហេតុនោះ ទើបលោកពោលថា " **មិនឃើញក្នុងវិចារៈ** " ដូច្នេះ ។

ពាក្យថា **សំដៅយកសមាធិនោះ** គឺ សំដៅយកសមាធិដែលបានមក តាមប្រការដែលពោលហើយនេះ ។ ឈ្មោះថា **ពាក្យថា សមាធិដែលមិនមានវិតក្កៈ មានត្រឹមវិចារៈនេះ** លោកពោលដល់បទទីពីរ ដែលថា **អវិតក្កវិចារមត្តោសមាធិ** សមាធិដែលមិនមានវិតក្កៈ មានត្រឹមវិចារៈ ។ ពាក្យថា **ក្នុងឈាន ៣** បានដល់ក្នុងឈាន៣ខាងដើម ។ ពាក្យថា **ក្នុងន័យទាំងនោះ នុ៎ះឯង** គឺក្នុងចតុក្កន័យ និងបញ្ចកន័យទាំងនោះ នុ៎ះឯង ។ ពាក្យថា **ក្នុងឈានទី ៣ ( និង ) ឈានទី ៤** គប្បីប្រកបសេចក្ដីថា ក្នុងឈានទី៣ ក្នុងចតុក្កន័យ ក្នុងឈានទី៤ ក្នុងបញ្ចកន័យ។ ពាក្យថា **ក្នុងឈានទីបំផុត** គឺ ក្នុងឈានទីបំផុតជុំវិញ ក្នុងន័យសូម្បីទាំង ២ គឺ ក្នុងឈានទី៤ ឬទី៥ តាមលំដាប់ ។ សូម្បីក្នុងពាក្យថា ជាសមាធិដែលសហគតដោយបីតិ និងសុខខ្លះនេះ គប្បីជ្រាបអត្ថន័យ តាមន័យដែលខ្ញុំម្ចាស់បានពោលទុកក្នុងខាងដើមនោះឯង ។

ម្យ៉ាងទៀត ក្នុងពួកនេះ សមាធិសូម្បីដែលសហគតដោយបីតិ សូម្បីកាលមានការសហគតដោយសុខ ( ផងក៏ដោយ ) ព្រះសាស្ដាទ្រង់ បំណងសំដែងបទទាំង៣ដោយមិនលាយឡំគ្នា ទើបទ្រង់មានព្រះទេសនា **បីតិតិក** ទុក ដើម្បីសំដែងសេចក្ដីផ្សេងគ្នារវាងសុខដែលមិនមានបីតិ និង សុខដែលមានបីតិ ព្រោះហេតុនោះ

ទើបគប្បីឃើញថា ទ្រង់កាន់យកសមាធិដែលសហគតដោយសុខ ដោយទាក់ទង ជាមួយនឹងសុខដែលមិនមានបីតិនោះឯង ។

ពាក្យថា **ក្នុងឧបចារភូមិ** បានដល់ ក្នុងចិត្តុប្បាទដែលសម្បយុត្តជាមួយ ឧបចារជ្ឈាន ។ ពិតណាស់ ចិត្តុប្បាទ លោកហៅថា “ **ភូមិ** ” ព្រោះជាស្ថានទី ដែលឧប្បត្តិនៃធម៌ដែលកើតរួមគ្នាទាំងឡាយ ដូចក្នុងប្រយោគថា “ **សុខភូមិយំ កាមាវចរេ** ” ក្នុងកាមាវចរដែលជាសុខភូមិ ដូច្នេះជាដើម ឈ្មោះថា **បរិត្តសមាធិ** ក៏ព្រោះភាពជាកាមាវចរ ។

( ចប់ មហាដីកា )

# ចតុក្កទី ១ " សមាធិពួក ៤ "

គប្បីជ្រាបថា សមាធិដែលមានបដិបទាលំបាកទាំងមានអភិញ្ញាយឺតយូរក៏មាន សមាធិមានបដិបទាលំបាក តែមានអភិញ្ញាឆាប់រហ័សក៏មាន សមាធិដែលមានបដិបទាងាយស្រួល តែមានអភិញ្ញាយឺតយូរក៏មាន សមាធិដែលមានបដិបទាងាយស្រួល តែមានអភិញ្ញាឆាប់រហ័សក៏មាន ក្នុងពាក្យថា **បដិបទា** និង **អភិញ្ញា** នោះ សមាធិភាវនា ការបំពេញសមាធិដែលប្រព្រឹត្តទៅផ្ដើមអំពីបឋមសមន្នាហារ ( ការប្រមូលចិត្តតាំងចុះក្នុងកម្មដ្ឋានជាដំបូង ) ទៅរហូតដល់ឧបចារនៃឈាននោះៗ កើតឡើង លោកហៅថា **បដិបទា** ចំណែកបញ្ញា ដែលប្រព្រឹត្តទៅតាំងអំពីឧបចាររហូតដល់អប្បនា លោកហៅថា **អភិញ្ញា** ឯបដិបទានេះនោះ រមែងជាការលំបាក គឺ ជាការយ៉ាប់យ៉ឺន មានន័យថា ចម្រើនមិនស្រួលសម្រាប់មនុស្សពួកខ្លះ ព្រោះធម៌ដែលជាសឹកសត្រូវ មាននីវរណៈជាដើមរាំង( ចិត្ត ) ដោយកើតឡើងត្រាច់ទៅ( ក្នុងចិត្ត ) ( តែ )ជាការងាយស្រួលសម្រាប់បុគ្គលពួកខ្លះ ព្រោះមិនមានធម៌ដែលជាសឹកសត្រូវនោះ ឯអភិញ្ញាវិញ ក៏រមែងយឺតយូរ គឺ សន្សឹមៗ មិនឆាប់រហ័សសម្រាប់មនុស្សពួកខ្លះ ( តែ )កើតឆាប់រហ័ស គឺ មិនកើតសន្សឹមៗ ប្រព្រឹត្តទៅឆាប់រហ័សសម្រាប់មនុស្សពួកខ្លះ ។

( គប្បីជ្រាបវិនិច្ឆ័យ )ក្នុង **បដិបទា** និង **អភិញ្ញា** នោះ( ដូច្នេះ ) ក្នុងបណ្ដាវត្ថុដែលជា សប្បាយ និង អសប្បាយ ទាំងឡាយក្ដី បុព្វកិច្ចទាំងឡាយមានការកាត់បលិពោធជាដើមក្ដី អប្បនាកោសល្លទាំងឡាយក្ដី ដែលខ្ញុំម្ចាស់នឹងពណ៌នាខាងមុខ ព្រះយោគាវចរណាបានសេពវត្ថុអសប្បាយ បដិបទារបស់ព្រះយោគាវចរនោះរមែងជាការលំបាក និង អភិញ្ញា របស់លោកក៏កើតយឺតយូរ បដិបទារបស់

ព្រះយោគាវចរដែលសេពវត្ថុជាសប្បាយ រមែងជាការសុខស្រួល និង អភិញ្ញា ក៏កើតឆាប់រហ័ស ចំណែកព្រះយោគាវចរណា សេពវត្ថុដែលជាអសប្បាយក្នុងខាងដើម ហើយបានសេពសប្បាយជាខាងក្រោយ ឬថា សេពវត្ថុដែលជាទីសប្បាយក្នុងខាងដើម ហើយទើបសេពវត្ថុដែលជាអសប្បាយ ក្នុងកាលជាខាងក្រោយ គប្បីជ្រាបថា បដិបទា និងអភិញ្ញារបស់ព្រះយោគាវចរនោះក៏ច្រាស់គ្នា ក្នុងន័យនេះក៏ដូចគ្នាដែរ បដិបទារបស់ព្រះយោគាវចរដែលមិនធ្វើបុព្វកិច្ច មានការកាត់បលិពោធជាដើមឲ្យហើយ រួចមកប្រកបភាវនា រមែងជាការលំបាក ដោយបរិយាយផ្ទុយគ្នាក៏ជាការស្រួល ។ ម្យ៉ាង អភិញ្ញារបស់បុគ្គលមិនធ្វើអប្បនាកោសល្លឲ្យដល់ព្រមរមែងយឺតយូរ របស់អ្នកធ្វើអប្បនាកោសល្លឲ្យដល់ព្រមរមែងឆាប់រហ័ស ម្យ៉ាងទៀត ប្រភេទនៃបដិបទា និងអភិញ្ញាទាំងនោះ គប្បីជ្រាបដោយអំណាចតណ្ហានិងអវិជ្ជា និង ដោយអំណាចនៃការសន្សំ ដែលធ្លាប់ធ្វើមក ក្នុងសមថៈនិងវិបស្សនា។ ពិតណាស់ បដិបទារបស់អ្នកត្រូវតណ្ហាគ្របសង្កត់ រមែងជាការលំបាក របស់អ្នកមិនត្រូវតណ្ហាគ្របសង្កត់ រមែងជាការងាយស្រួល ហើយអភិញ្ញារបស់អ្នកត្រូវអវិជ្ជាគ្របសង្កត់ រមែងយឺតយូរ អ្នកដែលមិនត្រូវអវិជ្ជាគ្របសង្កត់ រមែងឆាប់រហ័ស ។ ម្យ៉ាងទៀត បុគ្គលណាមិនបានធ្វើការសន្សំមកក្នុងសមថៈ បដិបទារបស់បុគ្គលនោះ រមែងជាការលំបាក របស់អ្នកមានការសន្សំបានធ្វើទុក រមែងជាការស្រួល ចំណែកបុគ្គលណា មិនបានធ្វើការសន្សំមកក្នុងវិបស្សនា អភិញ្ញារបស់អ្នកនោះរមែងយឺតយូរ របស់អ្នកមានការសន្សំបានធ្វើទុក រមែងរហ័ស ។ ម្យ៉ាងវិញទៀត ប្រភេទនៃបដិបទានិងអភិញ្ញាទាំងនោះ គប្បីជ្រាបដោយអំណាចនៃកិលេសនិងឥន្ទ្រិយផងដែរ ពិតណាស់ បដិបទានៃអ្នកមានកិលេសខ្លាំងក្លា តែឥន្ទ្រិយទន់ខ្សោយ

រមែងជាការលំបាក ទាំងអភិញ្ញាក៏យឺតយូរ តែអភិញ្ញារបស់អ្នកមានឥន្ទ្រិយចាស់ក្លា រមែងឆាប់រហ័ស ចំណែកបដិបទារបស់អ្នក មានកិលេសស្រាលស្តើង និងឥន្ទ្រិយទន់ខ្សោយ ជាការងាយស្រួល តែអភិញ្ញាយឺតយូរ តែថា អភិញ្ញារបស់អ្នកមានឥន្ទ្រិយចាស់ក្លា រមែងឆាប់រហ័ស ដូច្នេះ ក្នុងអភិញ្ញានិងបដិបទាទាំងនេះ បុគ្គលណាបានបដិបទា ដោយបដិបទាលំបាកនិងដោយអភិញ្ញាយឺតយូរ សមាធិនោះ របស់បុគ្គលនោះ ហៅថា **ទុក្ខាបដិបទោ ទន្ធាភិញ្ញោ** ដោយប្រការដូច្នេះ ន័យនេះគប្បីពោលក្នុងសមាធិ ៣ ដ៏សេស ។ យ៉ាងនេះឯង សមាធិ ជា ៤ ដោយចែកតាមការបដិបត្តិនិងការត្រាស់ដឹង មានទុក្ខាបដិបទាទន្ធាភិញ្ញសមាធិ ជាដើម ។

## ចតុក្កទី២

គប្បីជ្រាបថា **សមាធិ** ជាបរិត្តបរិត្តារម្មណ៍ ( មានអានុភាពតិចតួច ទាំងមានអារម្មណ៍តូចច្មារ )ក៏មាន , **សមាធិ** ជាបរិត្តអប្បមាណារម្មណ៍ ( មានអានុភាពតិច តែមានអារម្មណ៍ប្រមាណមិនបាន )ក៏មាន, **សមាធិ** ជាអប្បមាណបរិត្តារម្មណ៍ ( មានអានុភាពរកប្រមាណមិនបាន តែមានអារម្មណ៍តូចច្មារ ) ក៏មាន , **សមាធិ** ជាអប្បមាណអប្បមាណារម្មណ៍ ( មានអានុភាពរកប្រមាណមិនបាន ទាំងមានអារម្មណ៍រកប្រមាណមិនបាន )ក៏មាន ។ ក្នុងសមាធិ ៤ នោះ សមាធិណានៅមិនទាន់ស្ទាត់ជំនាញ មិនអាចជាបច្ច័យនៃឈានជាន់ខ្ពស់បាន សមាធិនោះចាត់ជាបរិត្ត ( មានអានុភាពតិច ) ចំណែកសមាធិណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមិនអាចពង្រីកបាន សមាធិនោះចាត់ជាបរិត្តារម្មណ៍ ( មានអារម្មណ៍តូចច្មារ ) សមាធិណាជំនាញ ដែលព្រះយោគាវចរអប់រំល្អហើយ អាចជាបច្ច័យនៃឈានជាន់លើបាន សមាធិនោះ ចាត់ជាអប្បមាណ ( មានអានុភាពរកប្រមាណមិនបាន ) ម្យ៉ាងទៀត

សមាធិណាប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលអាចពង្រីកបាន សមាធិនោះចាត់ជាអប្បមាណារម្មណ៍ ( មានអារម្មណ៍ប្រមាណមិនបាន ) ចំណែកន័យនៃសមាធិដែលឆ្លាស់គ្នា ( ខទី២ ទី៣ ) គប្បីជ្រាបដោយឆ្លាស់លក្ខណៈនៃសមាធិ( ខទី១ ទី៤ ) ដែលបានពោលបញ្ចូលគ្នាហើយ ។ យ៉ាងនេះឯងសមាធិជា ៤ ដោយចែកតាមអានុភាព និង អារម្មណ៍ មានបរិត្តបរិត្តារម្មណសមាធិ ជាដើម ។

## ចតុក្កទី៣

បឋមជ្ឈានប្រកបដោយអង្គ៥ ដោយអំណាចនៃវិតក្ក វិចារ បីតិ សុខ និង សមាធិដែលគ្របសង្កត់នីវរណធម៌បានហើយ តអំពីនោះ ទុតិយជ្ឈាន វិតក្កវិចារស្ងប់ទៅ សល់អង្គ ៣ តអំពីនោះ តតិយជ្ឈាន បីតិអស់ទៅសល់អង្គ ២ តអំពីនោះ ចតុត្ថជ្ឈានលះសុខចោល សល់អង្គ ២ ដោយអំណាចនៃសមាធិដែលប្រកបដោយឧបេក្ខាវេទនា សមាធិ៤ ជាអង្គនៃឈានទេះដូច្នេះ ។ យ៉ាងនេះឯងសមាធិជា ៤ ដោយអំណាចជាអង្គនៃចតុក្កឈាន ។

## ចតុក្កទី៤

សមាធិជា **ហានភាគិយ** ( ប្រព្រឹត្តទៅខាងចំណែកនៃផ្លូវវិនាស ) ក៏មាន , ជា **ឋិតិភាគិយ**(ប្រព្រឹត្តទៅក្នុងចំណែកនៃការតាំងនៅ) ក៏មាន, ជា **វិសេសភាគិយ** ( ប្រព្រឹត្តទៅក្នុងចំណែកវិសេសឡើង ) ក៏មាន , ជា **និព្វេធភាគិយ**( ប្រព្រឹត្តទៅក្នុងចំណែកឲ្យដឹងច្បាស់រហូតដល់អរិយសច្ចៈ) ក៏មាន ។

ក្នុងសមាធិ៤នោះ ភាពដែលសមាធិជា **ហានភាគិយ** គប្បីជ្រាបថា ( រមែងកើត ) ដោយអំណាចនៃការផ្សាយឡើងមកនៃបច្ចនិកធម៌ ភាពដែលសមាធិជា

**ឋិតិភាគិយ** គប្បីជ្រាបថា ( រមែងកើត )ដោយអំណាចការស្ងប់នៃសតិដែលមានសភាពគួរដល់សមាធិនោះ ភាពដែលសមាធិជាវិសេសភាគិយគប្បីជ្រាបថា( រមែងកើត ) ដោយការបានសម្រេចនូវគុណវិសេសជាលំដាប់ឡើងទៅ និងភាពដែលសមាធិជា **និព្វេធភាគិយ** គប្បីជ្រាបថា ( តែងកើត )ដោយអំណាចនៃការប្រាកដឡើងនៃសញ្ញា និង មនសិការដែលសហគតដោយនិព្វិទា ( កើតវិបស្សនា ) ដូចលោកពោលទុកថា សញ្ញា និងមនសិការដែលសហគតដោយកាម កើតឡើងគ្របសង្កត់បុគ្គលដែលបានបឋមជ្ឈាន បញ្ញា( ក្នុងបឋមជ្ឈាននោះ ) ក៏ជាហានភាគិនី ( មានចំណែកនៃសេចក្តីវិនាស ) សតិដែលជាសភាវៈគួរដល់បឋមជ្ឈាននោះ ក៏តាំងនៅ បញ្ញាក៏ជាឋិតិភាគិនី ( មានចំណែកខាងទ្រទ្រង់នៅ ) សញ្ញា និងមនសិការ ដែលសហគតដោយការមិនមានវិតក្កកើតឡើង( ប្រព្រឹត្តទៅ ) បញ្ញាក៏ជា **វិសេសភាគិនី** ( មានចំណែកវិសេសឡើង ) សញ្ញា និង មនសិការដែលសហគតដោយនិព្វិទាជិតចំពោះ វិរាគៈកើតឡើង(ប្រព្រឹត្តទៅ) បញ្ញាជានិព្វេធភាគិនី ( មានចំណែកខាងការចាក់ធ្លុះ ដឹងច្បាស់ ) ដូច្នេះសូម្បីសមាធិដែលសម្បយុត្តដោយបញ្ញានោះ ក៏ជាសមាធិ ៤ ដែរ យ៉ាងនេះឯងសមាធិជា ៤ ដោយចែកតាមចំណែក មានហានភាគិយសមាធិជាដើម ។

## ចតុក្កទី៥

សមាធិ ៤ យ៉ាងនេះ គឺ សមាធិជាកាមាវចរ សមាធិជារូបាវចរ សមាធិជាអរូបាវចរ សមាធិជាអបរិយាបន្ន (មិនទាក់ទងជាមួយភូមិទាំង៣ នោះជាលោកុត្តរ) ក្នុងសមាធិ ៤ នោះ ឯកគ្គតាថ្នាក់ឧបចារទាំងអស់ចាត់ជាកាមាវចរសមាធិ ឯកគ្គតា

នៃកុសលចិត្ត មានរូបាវចរចិត្តជាដើម ចាត់ជាសមាធិ ៣ ក្រៅពីនេះ ។ យ៉ាងនេះឯង សមាធិជា ៤ ដោយចែកតាមភូមិ មានកាមាវចរសមាធិជាដើម ។

## ចតុក្កទី៦

បើភិក្ខុធ្វើឆន្ទៈឲ្យជាធំ បានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយនោះសោត សមាធិនេះ ហៅថា **ឆន្ទសមាធិ** , បើភិក្ខុធ្វើវីរិយៈឲ្យជាធំ បានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយសោត សមាធិ នេះហៅថា **វីរិយសមាធិ** , បើភិក្ខុធ្វើចិត្តឲ្យជាធំ បានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយសោត សមាធិនេះ ហៅថា **ចិត្តសមាធិ** , បើភិក្ខុធ្វើវិមំសាឲ្យជាធំ បានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយសោត សមាធិនេះ ហៅថា **វិមំសាសមាធិ** , យ៉ាងនេះឯង សមាធិជា ៤ ដោយចែកតាមឥទ្ធិបាទដែលជាអធិបតីដូច្នេះឯង ។

## បញ្ចក្ក "សមាធិពូក ៥"

គប្បីជ្រាបឈាន ៥ ព្រោះចែក ( ទុតិយជ្ឈានក្នុងចតុក្កន័យ )ជា២ ដោយវិធីយ៉ាងនេះ គឺ ទុតិយជ្ឈានដែលពោលក្នុងចតុក្កន័យ(នោះឯង) ចែកជាទុតិយជ្ឈាន ព្រោះវិតក្កតែម្យ៉ាងកន្លងទៅ ជាតតិយជ្ឈាន ព្រោះទាំងវិតក្កៈវិចារៈកន្លងទៅ សមាធិជាអង្គនៃឈាន ៥ នោះ ទើបជាសមាធិ ៥ ។ គប្បីជ្រាបសេចក្តីដែលសមាធិជា ៥ ដោយជាអង្គបញ្ចកឈានយ៉ាងនេះ ។

## ភាពសៅហ្មង និង ផូរផង់នៃសមាធិ

ក៏ក្នុងពាក្យឆ្លើយ ក្នុងបញ្ហាថា “ **អ្វីជាសេចក្តីសៅហ្មង និង សេចក្តីផូរផង់**

**នៃសមាធិនោះ** ” នេះលោកពោលទុកហើយក្នុងវិភង្គ ពិតណាស់ ក្នុងវិភង្គនោះ លោកពោលទុកថា **ហានភាគិយធម៌** ( ធម៌ដែលប្រព្រឹត្តទៅខាងចំណែកវិនាស ) ឈ្មោះថា សេចក្តីសៅហ្មង , **វិសេសភាគិយធម៌** ( ធម៌ដែលប្រព្រឹត្តទៅខាងចំណែកវិសេសឡើង ) ឈ្មោះថា សេចក្តីផូរផង់ ដូច្នេះក្នុងធម៌ ២ យ៉ាងនោះ ហានភាគិយធម៌ គប្បីជ្រាបតាមន័យនេះថា សញ្ញា និង មនសិការ ដែលសហគតដោយកាម កើតឡើង គ្របសង្កត់អ្នកបានបឋមជ្ឈាន បញ្ញា( ក្នុងបឋមជ្ឈាននោះ ) ក៏ជាហានភាគិនី ចំណែកវិសេសភាគិយធម៌ គប្បីជ្រាបតាមន័យនេះថា “ សញ្ញា និង មនសិការ ដែលសហគតដោយភាពមិនមានវិតក្កៈ កើតឡើង(ប្រព្រឹត្តទៅ) បញ្ញា ក៏ជាវិសេសភាគិនី ” ដូច្នេះ ។

## មហាដីកា

## ពណ៌នាសមាធិពួក៤

ការសន្សំគ្រាដំបូងក្នុងកម្មដ្ឋានដោយន័យថា “ **បឋវី បឋវី** ” ជាដើម នៃបុគ្គលអ្នកផ្តើម **ភាវនា** ឈ្មោះថា **បឋមសមន្នាហារ** ។ ពាក្យថា **ឧបចារនៃឈាននោះ ៗ** បានដល់ កាមាវចរជ្ឈានដែលដល់នូវភាពមាំទាំ ព្រោះចូលទៅស្ងប់បច្ចនិកធម៌ មាននីវរណៈ វិតក្កៈ វិចារៈ និកន្តិ(តណ្ហា)ជាដើមបាន ។ ដោយពាក្យថា “ **ដរាបដល់អប្បនាកើតឡើង** ” នេះពោលបានថា រមែងប្រាកដ ហាក់បីដូចលោកពោលដល់ភាពជាអភិញ្ញាទុកសម្រាប់បញ្ញាដែលជាចំណែកខាងដើមប៉ុណ្ណោះ ។ សូម្បីដូច្នេះ អប្បនាបញ្ញាក៏ចាត់ជាអភិញ្ញាបានដូចគ្នា ។ ពិតណាស់ បញ្ញាដែលជាចំណែកខាងដើម មានភាពយឺតយូរ ឬឆាប់រហ័សបានដោយហេតុណា សូម្បីអប្បនាបញ្ញាក៏មាន

កាលយឺតយូរ ឬឆាប់រហ័សបានដោយហេតុនោះ ដូច្នោះដែរ ។ ពាក្យថា **ព្រោះភាពដែល ( បច្ចនិកធម៌ ) ប្រកាន់ទុក ដោយការជាប់ជំពាក់** មានន័យថា ព្រោះបច្ចនិកធម៌ដែលរសេមរសាម ប្រកាន់ទុក គឺ ព្រោះបច្ចនិកធម៌ មានការប្រព្រឹត្តទៅច្រើន ។ ពាក្យថា **សេពមិនសប្បាយ** បានដល់ ចម្រើនបានដោយលំបាក ។

ពាក្យថា **បុព្វកិច្ចទាំងឡាយមានការកាត់បលិពោធជាដើម** ដោយ **អាទិស័ព្ទ** ( ប្រែថា ជាដើម ) លោកសង្គ្រោះយកវិធីចម្រើន( កម្មដ្ឋាន ) ការការពារមិនឲ្យកម្មដ្ឋានវិនាសទៅដោយជុំវិញជាដើម ។ ពាក្យថា **ជាអ្នកសេពវត្ថុ ដែលជាអសប្បាយ** មានសេចក្តីថា ព្រោះភាពជាអ្នកសេពវត្ថុដែលជាអសប្បាយក្នុងកាលមុន ការសម្រេចនូវឧបចារជ្ឈាន ទើបជា **ទុក្ខាបដិបទា** ។ ព្រោះភាពជាអ្នកសេពនូវវត្ថុដែលជាអសប្បាយ ក្នុងកាលជាខាងក្រោយ បន្ទាប់ពីការសម្រេចឧបចារជ្ឈាន ទើបជា **ទន្ធាភិញ្ញា** ។ សូម្បីក្នុងពាក្យថា (បដិបទា) របស់ព្រះយោគីអ្នកសេពនូវវត្ថុដែលជាទីសប្បាយនេះ ក៏ន័យនេះឯង ។ ពាក្យថា **ក្នុងខាងដើម** គឺ ក្នុងចំណែកខាងដើម មុនការសម្រេច ឧបចារជ្ឈាន ។ ពាក្យថា **ក្នុងខាងក្រោយ** គឺ បន្ទាប់អំពីការសម្រេចឧបចារជ្ឈាននោះ ។ ពាក្យថា **ភាពដែលព្រះយោគីនោះមានបដិបទា និង អភិញ្ញាច្នាស់គ្នា** គឺថា ព្រះយោគីបុគ្គលណា ក្នុងខាងដើមសេពវត្ថុដែលជាអសប្បាយហើយ ពេលក្រោយជាអ្នកសេពនូវវត្ថុដែលជាសប្បាយ ព្រះយោគីបុគ្គលនោះ មានបដិបទាលំបាក មានអភិញ្ញារហ័ស ។ ព្រះយោគីក្រៅពីនេះ មានបដិបទាងាយស្រួល មានអភិញ្ញាយឺតយូរ ។

សេចក្តីថា **បដិបទា និង អភិញ្ញា ទី ២ និង ទី ៣** រមែងមានបាន ព្រោះ

សេចក្ដីដែល **បដិបទា** និង **អភិញ្ញា** ទី ១ និង ទី ៤ ច្បាស់គ្នា តាមប្រការ ដែលពោលមកនេះ ។ បដិបទារបស់ព្រះយោគីដែលមិនបានធ្វើការកាត់បលិពោធ ជាការលំបាក ព្រោះមានភាពកង្វល់ បដិបទារបស់ព្រះយោគីក្រៅពីនេះ ជាការងាយស្រួល ។ ព្រះយោគីដែលមិនបានធ្វើអប្បនាកោសល្យឲ្យសម្រេច ឈ្មោះថា មានអភិញ្ញាយឺតយូរ ព្រោះញាណមិនទាន់ចាស់ក្លា ព្រះយោគីក្រៅពីនេះ ឈ្មោះថា មានអភិញ្ញារហ័ស ព្រោះភាពដែលញាណចាស់ក្លា ។ ពាក្យថា **ដោយអំណាចតណ្ហា និង អវិជ្ជា** គឺ ដោយអំណាចនៃ តណ្ហា និង អវិជ្ជា គ្របសង្កត់ និង មិនគ្របសង្កត់ ។

ពាក្យថា **ដោយអំណាចអធិការនៃសមាធិ និងវិបស្សនា** គឺ ដោយអំណាចនៃអធិការដែលមិនមាន និង មាន នៅក្នុងសមថៈ និង វិបស្សនា ។ ព្រោះតណ្ហាជាបដិបក្ខចំពោះសមាធិ តណ្ហានោះ ទើបចាត់ជាហេតុរាំង នៃការបដិបត្តិសមថៈ ព្រោះហេតុនោះ ទើបលោកពោលថា ពិតណាស់សម្រាប់ព្រះយោគីអ្នកត្រូវតណ្ហាគ្របសង្កត់ ក៏មានបដិបទាលំបាកដូច្នេះ ។

ក៏តណ្ហានោះ មានការគ្របសង្កត់បាន ព្រោះជាធម្មជាតិដែលធំក្រៃលែងជាងកិលេសទាំងឡាយ ក្រៅពីនេះ គប្បីជ្រាបដោយអធិការថា ឈ្មោះថា អ្នកមិនត្រូវគ្របសង្កត់ ក៏គឺ មិនត្រូវតណ្ហាគ្របសង្កត់ ។ ដូចគ្នានេះដែរ អវិជ្ជាជាបដិបក្ខចំពោះបញ្ញា ព្រោះហេតុនោះ ទើបលោកពោលថា ភាពជាអ្នកមានអភិញ្ញាយឺតយូរទុកសម្រាប់ព្រះយោគីអ្នកត្រូវអវិជ្ជានោះគ្របសង្កត់ ។ ពាក្យថា **ជាអ្នកមិនបានធ្វើអធិការទុក** គឺ មិនបានធ្វើការសន្សំទុកក្នុងភពដទៃ ភាវនារបស់ព្រះយោគីអ្នកបានធ្វើការសន្សំទុកក្នុងភពមុន រមែងសម្រេចបានដោយមិនលំបាកឡើយ ដូចជាគន្ធៈ

( បរិយត្តិ ) ដែលគេធ្វើឲ្យស្ទាត់ជំនាញហើយ ក៏លើក(ការខ្វាយខ្វល់)ចោល រមែង ឡើងកាន់វាចាប្រព្រឹត្តទៅបានដោយងាយ (រត់មាត់) ដោយសេចក្តីព្យាយាមត្រឹមតែ បន្តិចបន្តួចប៉ុណ្ណោះ ។ ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលសម្រាប់ព្រះយោគី អ្នកបានធ្វើអធិការទុក ( ក្នុងសមថ: ) ហើយក៏មានបដិបទាងាយស្រួលដូច្នេះ ។ អធិការដែលអាស្រ័យសមថ: ដែលមិនបានធ្វើទុក និងដែលបានធ្វើទុកនេះ នោះ លោកពោលទុកសម្រាប់បដិបទា ព្រោះបដិបទាមានសមាធិជាប្រធាន ។ អធិការ ដែលអាស្រ័យវិបស្សនា លោកពោលទុកសម្រាប់អភិញ្ញា ព្រោះអប្បនាមានញាណ ជាប្រធាន ។

ពាក្យថា **ដោយទាក់ទងជាមួយកិលេស និង ឥន្ទ្រិយ** គឺ ដោយទាក់ទងជា មួយកិលេស និង ឥន្ទ្រិយដែលចាស់ក្លានិងមិនចាស់ក្លា ។ ព្រោះហេតុនោះ ទើប លោកពោលថា សម្រាប់ព្រះយោគីដែលមានកិលេសក្រាស់ ដូច្នេះជាដើម ។ ក្នុង ធម៌ទាំងនោះ ឈ្មោះថា **កិលេស** បានដល់ ធម៌ទាំងឡាយ មានកាមច្ឆន្ទ:ជាដើម។ ឈ្មោះថា **ឥន្ទ្រីយ៍** បានដល់ ធម្មជាតិទាំងឡាយមានសទ្ធាជាដើម ។

បដិបទា និងអភិញ្ញា តាមដែលពោលហើយ ជាបុគ្គលាធិដ្ឋាន( មានបុគ្គល ជាទីតាំង ) ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បុគ្គលណាជាដើម** ក៏ ដើម្បីសម្តែង សូម្បីធម្មនិទ្ទេស ដោយបុគ្គលាធិដ្ឋានជាមុខ ។ ពាក្យថា **មិន ទាន់ស្ទាត់ជំនាញ** បានដល់ មិនទាន់ចម្រើនបានល្អ គឺ នៅមិនទាន់ធ្វើឲ្យដល់ភាព ជាវសី ។ ព្រោះហេតុនោះ ទើបលោកពោលថា មិនអាចជាបច្ច័យដល់ឈានជាន់ លើបានដូច្នេះ ។ ពាក្យថា **សមាធិនេះឈ្មោះថា បរិត្ត** គឺ សមាធិនេះឈ្មោះថា **បរិត្ត** ព្រោះមានអានុភាពតិច ។ ពាក្យថា (ក្នុងអារម្មណ៍) **ដែលនៅមិនទាន់ពង្រីក**

គឺ ក្នុងអារម្មណ៍ដែលនៅមិនទាន់ពង្រីក សូម្បីត្រឹមតែ ១ ម្រាម ឬ ២ ម្រាម ក្នុងអារម្មណ៍តាមដែលប្រាកដហើយ ។ ពិតណាស់ លោកពោលដល់អារម្មណ៍ ដែលពង្រីកហើយ សូម្បីត្រឹមតែ១ម្រាមថាជា **អប្បមាណ** ដូច្នេះ។ លោកអាចារ្យពោលថា ស្ទាត់ជំនាញចម្រើនបានល្អហើយ ដូច្នេះហើយ ក៏ពោលដល់សមាធិ សូម្បីដែលចម្រើនបានល្អហើយថា ឈ្មោះថា **អប្បមាណ** ដូច្នេះឯង ព្រោះសេចក្តីសម្រេចនៃកិច្ចដែលចម្រើនបានល្អហើយ ពោលគឺ ជាបច្ច័យដល់ឈានជាន់លើ ទុកដោយពាក្យថា " **អាចជាបច្ច័យដល់ឈានជាន់លើបាន** " នេះ ព្រោះអត្ថថា សមាធិរបស់លោកអ្នកក្រៃលែងដោយញាណឈ្មោះថាជា **អប្បមាណ** មិនឈ្មោះថាជា **បរិត្ត** ដោយការធ្វើឈានជាន់ខ្ពស់ឲ្យកើតឡើងបាន ដោយការអន្តុយត្រឹមតែម្តងប៉ុណ្ណោះ សមាធិសូម្បីថា ស្ទាត់ជំនាញ បើមិនអាចជាបច្ច័យដល់ឈានជាន់លើ ក៏ឈ្មោះថាជា **បរិត្ត** តែម្យ៉ាង មិនឈ្មោះថាជា **អប្បមាណ** ឡើយ ។

ចំណែកអាចារ្យពួកមួយពោលថា ប្រសិនបើជាសមាធិដែលចម្រើនបានល្អហើយស្ទាត់ជំនាញ ដល់នូវភាពជាវសី សូម្បីមិនជាបច្ច័យដល់ឈានជាន់លើ ក៏ឈ្មោះថា **អប្បមាណ** ដូចគ្នា ព្រោះនៅក្នុងទីឆ្ងាយអំពីធម៌ដែលជាបដិបក្ខទាំងឡាយមានរាគៈជាដើម ដែលធ្វើឲ្យមានប្រមាណដូច្នេះ ។

ពាក្យថា **ដោយការលាយឡំគ្នានៃលក្ខណៈដែលពោលហើយ** មានន័យថា គប្បីជ្រាបន័យនៃសមាធិដែលលាយគ្នា ដែលរួបរួមយកសមាធិ ទី២ និង ទី៣ ដោយការៈដែលលាយឡំគ្នា នៃលក្ខណៈដែលពោលទុកសម្រាប់សមាធិទី ១ និង ទី ៤ យ៉ាងនេះថា សមាធិណាមិនស្ទាត់ជំនាញ មិនអាចជាបច្ច័យដល់ឈានជាន់លើបាន ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលបានពង្រីកហើយ សមាធិនេះ ឈ្មោះថា

**បរិត្តអប្បមាណារម្មណ**( ជាបរិត្ត មានអារម្មណ៍ជាអប្បមាណ )ដូច្នេះ ។ ចំណែក សមាធិណាដែលស្ទាត់ជំនាញ អាចជាបច្ច័យដល់ឈានជាន់លើបាន ប្រព្រឹត្តទៅក្នុង អារម្មណ៍ដែលមិនទាន់ពង្រីក សមាធិនោះ ឈ្មោះថា **អប្បមាណបរិត្តារម្មណ**( ជា អប្បមាណ មានអារម្មណ៍ជាបរិត្ត )

ពាក្យថា **បន្ទាប់អំពីនោះទៅ** គឺ លើអំពីបឋមជ្ឈានទោះទៅ ។ ពាក្យថា **ប្រាសចាកបីតិ** បានដល់ បានឈានកន្លងបីតិ ឬ វៀសក្នុងបីតិ ។ ចំណែកតូចៗ នៃចំណែកធំ លោកហៅថា **អង្គ** ដូចក្នុងពាក្យថា " អង្គសេនា អង្គរថជាដើម " ព្រោះហេតុនោះ ទើបលោកពោលថា សមាធិចាត់ថា មាន ៤ គឺ ជាអង្គនៃឈាន ៤ ដូច្នេះ ។

**សមាធិ** ឈ្មោះថា **ហានភាគិយ** ព្រោះអត្ថថា ចូលដល់ភាពវិនាស ម៉្យាង ទៀត ឈ្មោះថា **ហានភាគិយ** ព្រោះអត្ថថា មានចំណែកនៃសេចក្ដីវិនាស មាន ន័យថា ជាសមាធិដែលមានចំណែកនៃសេចក្ដវិនាសដោយជុំវិញ ។ **សមាធិ** ឈ្មោះថា **ឋិតិភាគិយ** ព្រោះអត្ថថា ចូលដល់ការតាំងនៅ ព្រោះ មិនទាន់លះបង់ ការជាប់ជំពាក់នូវអាល័យ ( កាមគុណ ) ឬព្រោះអត្ថថា មានចំណែកនៃការតាំង នៅ ។ **សមាធិ** ឈ្មោះថា **វិសេសភាគិយ** ព្រោះអត្ថថា ប្រកបដោយគុណ វិសេស ( ឬ មានចំណែកនៃគុណវិសេស ) ។ ពាក្យថា **ដោយអំណាចការ ប្រព្រឹត្តទៅនៃធម៌ដែលជាសឹកសត្រូវ** គឺ ដោយអំណាចការប្រព្រឹត្តទៅនៃធម៌ទាំង- ឡាយ មាននីវរណៈ វិតក្កៈ វិចារៈ ជាដើម ដែលជាសត្រូវរបស់ឈាននោះ ៗ ។ បទថា **តទនុធម្មតាយ** ប្រែថា នៃសតិដែលដល់នូវភាពសមគួរចំពោះសមាធិនោះ។ បទថា **សណ្ឋានវសេន** ប្រែថា ដោយអំណាចការតម្កល់នៅ គឺ ដោយអំណាច

ការតាំងមាំ ។

មានពាក្យពោលទុកក្នុងសម្មោហវិនោទនីថា “ **សា បន តទសប្បាទសង្ខាតា តទសប្បទសម្បយុត្តក្ខន្ធសង្ខាតា វា មិច្ឆាសតិ** ” ក៏សតិនោះ ដែលរាប់ថាជា ខន្ធ ដែលសម្បយុត្តជាមួយសេចក្ដីត្រេកអរក្នុងសមាធិនោះ ជាមិច្ឆាសតិដូច្នេះ , ក៏សតិនោះ រាប់បានថា ជាសេចក្ដីរីករាយក្នុងសមាធិនោះ ឬ រាប់បានថា ជាខន្ធដែលសម្បយុត្តជាមួយសេចក្ដីរីករាយ ក្នុងសមាធិនោះ ជាមិច្ឆាសតិ ។

ក្នុងពាក្យនោះ គួរនឹងពោលបានថា ជាសតិក្នុងការរក្សាសមាធិនោះៗ ដែលនៅមិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ ព្រោះព្រះយោគី ដែលមានសេចក្ដីជាប់ជំពាក់ មិនគប្បីធ្វើគុណវិសេសជាន់លើ ឲ្យកើតឡើងបានឡើយ ។ ក៏ព្រោះធ្វើអធិប្បាយទុកយ៉ាងនេះ ពាក្យនិយាយដែលជាគោលកំណត់ថា “ នៃសតិក៏បាន នៃនិកន្តិក៏បាន ” ដូច្នេះ ទើបជាការប្រើបានផងដែរ ។ ពាក្យថា **ដោយអំណាចជាហេតុនៃការសម្រេចគុណវិសេស** គឺ ដោយអំណាចភាពជាបច្ច័យដល់ការសម្រេចគុណវិសេស ម្យ៉ាងទៀត **សមាធិ** ឈ្មោះថា **វិសេសាធិគម** ព្រោះអត្ថថា ជាហេតុឲ្យសម្រេចគុណវិសេស បានដល់ ដោយអំណាចជាហេតុឲ្យសម្រេចគុណវិសេសនោះ ។

ពាក្យថា **ដោយអំណាចការប្រព្រឹត្តទៅនៃ សញ្ញា និង មនសិការ ដែលសហគតដោយនិព្វិទា** គឺ ដោយអំណាចការប្រព្រឹត្តទៅនៃសញ្ញា ដែលសម្បយុត្តដោយនិព្វិទាញាណដែលមានការឃើញទោសជាខាងដើម និងការពិចារណាដល់ ។

ពាក្យថា **ភាពជានិព្វេធភាគិយ** មានន័យថា ភាពជាសមាធិមានក្នុងចំណែកនៃការចាក់ធ្លុះសច្ចៈទាំងឡាយ រមែងប្រព្រឹត្តទៅព្រមដើម្បីវិបស្សនា ។

បទថា **កាមសហគតា** ប្រែថា ដែលមានកាមជាអារម្មណ៍ ឬដែលដោកដាំដោយកាមសញ្ញាទាំងឡាយ ។ បទថា **អវិតក្កសហគតា** មានន័យថា មានឈានដែលមិនមានវិតក្កៈជាអារម្មណ៍ គឺមានឈានដែលមិនមានវិតក្កៈ ជាវិស័យ យ៉ាងនេះគឺ " ឈានដែលមិនមានវិតក្កៈ នឹងមានដល់យើងដូចម្ដេចហ្ន៎ !" ដូច្នេះ ។ បាឋៈដែលថា " ( របស់បុគ្គលអ្នកបាន ) បឋមជ្ឈាន " ជាដើមនេះមកហើយដោយទាក់ទងជាមួយបញ្ញាក៏ពិត តែសមាធិ ក៏មានការសង្គ្រោះចូលក្នុងបាឋៈនេះបានដូចគ្នា ព្រោះហេតុនោះ ដើម្បីសម្ដែងដល់សេចក្ដីដែលឧទាហរណ៍ ( ដែលជារឿងទាក់ទងជាមួយបញ្ញា ) ជារបស់មានប្រយោជន៍ ( គឺ ការសម្ដែងសមាធិ ) ទើបលោកអាចារ្យពោលទុកយ៉ាងនេះ ដោយទាក់ទងជាមួយសមាធិទាំងនោះ ថាសូម្បីសមាធិដែលសម្បយុត្តជាមួយបញ្ញានោះ ក៏ចាត់បានថា មាន ៤ យ៉ាង ។

លោកអាចារ្យពោលថា ឯកគ្គតាក្នុងឧបចារជ្ឈាន ឈ្មោះថា **កាមាវចរ-សមាធិ** ដូច្នេះ ព្រោះក្នុងទីនេះលោកបំណងយកសមាធិដែលសម្រេចដោយភាវនា។

ពាក្យថា **ធ្វើ** ( ឆន្ទៈ ) **ឲ្យជាអធិបតី** គឺ ព្រះយោគីគិតថា " ប្រសិនបើសមាធិនឹងមានដល់អ្នកដែលមានឆន្ទៈហើយសោត នឹងមានដល់យើងក៏យ៉ាងនេះ " ដូច្នេះ ហើយធ្វើឆន្ទៈឲ្យជាអធិបតី ធ្វើឆន្ទៈឲ្យជាធុរៈ គឺ ឲ្យជាធំ ឲ្យចេញមុខ ។

ពាក្យថា **បានសមាធិ** គឺ បានសមាធិណាមួយ ដោយប្រការយ៉ាងនេះ **សមាធិ** នេះហៅថា **ឆន្ទសមាធិ** មានន័យថា សមាធិដែលមានឆន្ទៈជាអធិបតី ។

សូម្បី **វីរិយសមាធិ** ជាដើម គប្បីជ្រាបតាមប្រការដូចដែលបានពោលមកនេះចុះ ។

ពាក្យថា **ក្នុងប្រភេទសមាធិពួក ៤** គឺ ក្នុងការសម្ដែងលំអិតប្រភេទនៃ

សមាធិដោយទាក់ទងជា ៤ ពួក ។ វិតក្កៈដែលប្រព្រឹត្តទៅព្រមនឹងវិចារ ដោយអំណាចការប្រកបរួមគ្នា ក្នុងន័យដទៃ( ក្នុងចតុក្កន័យ ) សូម្បីត្រូវប្រាសទៅហើយក្នុងឈានទី២ ក្នុងបញ្ចកន័យ ក៏មិនឈ្មោះថា ត្រូវប្រាសទៅដោយល្អ ព្រោះហេតុនោះ លោកបំណងសម្តែងនូវការឈានកន្លងវិចារព្រមទាំងវិតក្កនោះឯង ទើបពោលថា ឈ្មោះថា **តតិយជ្ឈាន** ក៏ដោយការឈានកន្លងទាំងវិតក្កវិចារៈដូច្នេះ ។ ប្រកបសេចក្តីថា បែកឈានទី ២ ដែលបានពោលទុកក្នុងប្រភេទនៃចតុក្កន័យចេញជា ២ ឈាន ។ ពាក្យថា **គឺជាអង្គនៃឈាន៥** មានន័យថា គប្បីជ្រាបដល់ ភាពដែលសមាធិមាន ៥ យ៉ាង ដោយអំណាចជាអង្គនៃឈាន ៥ ។

ពាក្យថា **ក្នុងគម្ពីរវិភង្គ** គឺ ក្នុងឈានវិភង្គ ។ ពិតណាស់ ក្នុងឈានវិភង្គនោះ ទ្រង់ត្រាស់ទុកថា **សង្កិលេសំ** សេចក្តីសៅហ្មងជាដើម ទុកក្នុងបទថា “ **ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសវោទានំ** ” ឈាន វិមោក្ខ សមាធិ និង សមាបត្តិ មានសេចក្តីសៅហ្មង និង សេចក្តីផូរផង់យ៉ាងនេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ហានភាគិយធម៌** បានដល់ កាលព្រះយោគាវចរ ចេញចាកឈានទាំងឡាយ មានបឋមជ្ឈានជាដើម ដែលនៅមិនទាន់ស្ទាត់ជំនាញ សញ្ញានិងមនសិការ ក៏មានការបង្អោនទៅកាន់កាមជាដើមរឿយ ៗ ។

ពាក្យថា **វិសេសភាគិយធម៌** បានដល់ ភាពដែល កាលព្រះយោគីចេញចាកឈានទាំងឡាយ មានបឋមជ្ឈានជាដើម ដែលស្ទាត់ជំនាញហើយ សញ្ញា និង មនសិការ ក៏មានការបង្អោនទៅកាន់គុណវិសេសមានទុតិយជ្ឈានជាដើមរឿយៗ ។ ព្រោះហេតុនោះ ទើបលោកពោលថា អ្នកបានបឋមជ្ឈានជាដើម ។ អត្ថន័យរបស់ពាក្យនោះ គឺ អ្នកបានបឋមជ្ឈានដែលនៅមិនទាន់ស្ទាត់ជំនាញ ដូច្នេះ សញ្ញា និង

មនសិការ ជាកាមសហគតដោយទាក់ទងជាមួយនឹងការធ្វើ( កាម )ឲ្យជាអារម្មណ៍ រមែងប្រព្រឹត្តទៅ គឺ រមែងរំលឹក រមែងដាស់តឿនព្រះយោគីដែលចេញពីបឋមជ្ឈាន ជាដើមនោះៗ ឯបញ្ញាក្នុងបឋមជ្ឈាននោះ រមែងវិនាសទៅដោយអំណាចនៃសញ្ញា និងមនសិការ ដែលមានការបង្អោនទៅកាន់កាមរឿយៗ របស់ព្រះយោគីនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ហានភាគិនីបញ្ញា** ។

ពាក្យថា **ដែលមានឈានមិនមានវិតក្កជាអារម្មណ៍** មានន័យថា សញ្ញា និង មនសិការដែលជាអវិតក្កសហគត ដោយទាក់ទងនឹងការធ្វើ ( ឈានដែលមិនមានវិតក្ក ) ឲ្យជាអារម្មណ៍នៃព្រះយោគីដែលមនសិការទុតិយជ្ឈាន ដែលមិនមានវិតក្ក ជាស្ងប់ ជាប្រណីត រមែងប្រព្រឹត្តទៅ គឺ រមែងដាស់តឿន រមែងរំលឹកព្រះយោគី ដែលចេញចាកបឋមជ្ឈាន ដែលស្ទាត់ជំនាញហើយ ដើម្បីប្រយោជន៍ដល់នូវការសម្រេចទុតិយជ្ឈាន ឯបញ្ញាក្នុងបឋមជ្ឈាន ដោយអំណាចនៃសញ្ញា និង មនសិការ ដែលមានការបង្អោនទៅកាន់ទុតិយជ្ឈាន របស់ព្រះយោគាវចរនោះ ក៏ឈ្មោះថា **វិសេសភាគិនីបញ្ញា** ព្រោះជាបទដ្ឋាននៃការកើតឡើង នៃទុតិយជ្ឈាន ដែលជាគុណវិសេស ។ ក្នុងទីនេះ បំណងយកសមាធិដែលសម្បយុត្តដោយបញ្ញានោះ ។

ពាក្យថា **ដោយន័យនេះ** មានន័យថា គប្បីជ្រាបនូវហានភាគិយធម៌ និង វិសេសភាគិយធម៌ សូម្បីក្នុងទុតិយជ្ឈានជាដើម ដោយតាមវិធីដែលបានពោលហើយក្នុងបឋមជ្ឈាននេះ ។

( ចប់មហាដីកា )

# ការចម្រើនសមាធិ

ចំណែកពាក្យឆ្លើយក្នុងបញ្ហាថា “ **សមាធិនោះគប្បីចម្រើនដូចម្តេច** ” នេះ គប្បីជ្រាបដូចតទៅនេះ :-

សមាធិណាដែលសម្បយុត្តដោយអរិយមគ្គ ដែលខ្ញុំម្ចាស់បានពោលទុករួច ហើយក្នុងទុកសមាធិ មានប្រការថា “ នេះសមាធិជា ២ ជាលោកិយ និង លោកុត្តរ ” ដូច្នេះជាដើម ។

ន័យនៃការចម្រើនអរិយមគ្គ សមាធិនោះសង្គ្រោះចូលជាមួយនឹងន័យនៃការ ចម្រើនបញ្ញា បានដូចគ្នា ព្រោះថា កាលបញ្ញាចម្រើនហើយ មគ្គសមាធិនោះ ក៏ ចម្រើនផងដែរ ដោយពិត ព្រោះហេតុនោះ យើងនឹងមិនសំដៅយកមគ្គសមាធិនោះ មកពោលជាផ្នែកមួយទេ ។

ចំណែកសមាធិដែលជាលោកិយ សមាធិនោះ ដែលព្រះយោគាវចរញ៉ាំង សីលទាំងឡាយឲ្យបរិសុទ្ធ តាមន័យដែលបានពោលហើយ តាំងនៅក្នុងសីលដែល បរិសុទ្ធល្អហើយ បណ្តាបលិពោធ១០ប្រការ បលិពោធណា របស់លោកនៅមាន កាត់បលិពោធនោះចេញហើយ ចូលទៅរកលោកអ្នកឲ្យកម្មដ្ឋានដែលជាកល្យាណ មិត្ត កាន់យកកម្មដ្ឋាន៤០ ណាមួយ ដែលអនុកូលដល់ចរិយារបស់ខ្លួន លះបង់នូវ វិហារដែលមិនសមគួរដល់ការចម្រើនសមាធិចេញ នៅក្នុងវិហារដែលសមគួរ កាត់ កង្វល់តូចតាច( ចេញឲ្យអស់ផង ) ហើយគប្បីជាអ្នកមិនធ្វើការនៅទាំងពួងឲ្យថយ ចុះទៅ ចម្រើនសាចុះសាឡើង នេះជាសេចក្តីសង្ខេប ក្នុងការចម្រើនសមាធិនោះ ចំណែកសេចក្តីពិស្តារ មានដូចតទៅនេះ :-

# បលិពោធ ១០

វិនិច្ឆ័យក្នុងប្រការថា “ បណ្ដាបលិពោធ ១០ ប្រការ បលិពោធណារបស់លោកនៅមាន កាត់បលិពោធនោះចេញ ” នេះជាដំបូង ។

គ្រឿងកង្វល់នោះគឺ :-

**អាវាស ត្រកូល លាភ គណៈ** និង **ការងារ** ជាទី ៥

**ការដើរផ្លូវ ញាតិ អាពាធ ការរៀនសូត្រ** និង **ឫទ្ធិ** រួមជា ១០

គ្រឿងកង្វល់ ១០ នេះឯង ឈ្មោះថា **បលិពោធ** ក្នុងបលិពោធ១០នោះ អាវាសនោះឯង ហៅថា **អាវាសបលិពោធ** ន័យក្នុងបលិពោធក្រៅពីនេះ មាន ត្រកូលជាដើម ក៏ដូចន័យនេះ ។

អធិប្បាយក្នុង បលិពោធ ១០ យ៉ាងនោះ គប្បីជ្រាបដូចតទៅនេះ :-

## ១. អាវាសបលិពោធ

### ( កង្វល់ដោយការគ្រប់គ្រងទីលំនៅ )

សូម្បីបន្ទប់ ( ដេកបាន ) តូច ៗ មួយបន្ទប់ ក៏ហៅថា **អាវាស** សូម្បីបរិវេណទីមួយ ៗ ក៏ហៅថា **អាវាស** សូម្បីសង្ឃារាមទាំងមូលក៏ហៅថា **អាវាស** អាវាសនេះនោះ( សង្ឃារាមទាំងមូល ) មិនជាបលិពោធចំពោះភិក្ខុទៅនោះឡើយ បើភិក្ខុណាត្រូវខ្វល់ខ្វាយក្នុងការងារផ្សេងៗ មានការសាងសង់ជាដើម ក្នុងអាវាសនោះក្ដី មានការសន្សំរបស់របរទុកច្រើនៗក្នុងអាវាសនោះក្ដី មានសេចក្ដីអាល័យចិត្ត ជាប់ជំពាក់នៅក្នុងអាវាសនោះ ដោយហេតុណាមួយក្ដី អាវាសនោះ ទើបជាបលិពោធសម្រាប់ភិក្ខុនោះប៉ុណ្ណោះ ជាកង្វល់ដល់ភិក្ខុដទៃក៏ទេ រឿងតទៅនេះជា

និទស្សនៈ ក្នុងអាវាសដែលមិនបលិពោធនោះ ។

មានរឿងពោលថា កុលបុត្ត ២ នាក់ ចេញអំពីក្រុងអនុរាធបុរៈ ( ដើរផ្លូវទៅ ) រហូតបានទៅបួសក្នុងវត្តថូបារាម ។ បព្វជិត ២ អង្គនោះ មួយអង្គរៀនមាតិកាបានស្ទាត់ជំនាញ ៣ មាតិកា ជាអ្នកមានវស្សាគ្រប់៥ បវារណាហើយ ទៅកាន់ជនបទឈ្មោះ បាចីនខណ្ឌរាជី។ មួយអង្គទៀតគង់នៅក្នុងថូបារាមនោះ ។ មួយអង្គដែលទៅបាចីនខណ្ឌរាជី នៅទីនោះយូរទៅ បានជាព្រះថេរៈ ហើយគិតថា “ ទីនេះជាទីសមគួរដល់ការស្នាក់នៅ ដូច្នេះយើងនឹងប្រាប់សេចក្ដីនោះ ដល់ភិក្ខុដែលជាសំឡាញ់ផងចុះ ” ហើយចេញអំពីជនបទនោះ រហូតចូលទៅដល់ថូបារាម ព្រះថេរៈ អ្នករួមវស្សាឃើញលោកកំពុងដើរចូលវត្ត ក៏ទៅទទួលជួយយកបាត្រ ចីវរធ្វើវត្ត ព្រះថេរៈអាគន្តុកៈចូលកាន់សេនាសនៈ ហើយគិតថា “បន្តិចទៀត សំឡាញ់របស់យើងនឹងបញ្ជូនទឹកដោះ ឬទឹកអំពៅ ឬទឹកបានៈមកឲ្យហើយមើលទៅ ព្រោះលោកជាអ្នកនៅយូរហើយក្នុងនគរនេះ ( រង់ចាំ )រហូតដល់កណ្ដាលយប់ លោកក៏មិនបានទទួល(នូវវត្ថុដែលគិតទុក) ពេលព្រឹកទើបគិតជាថ្មីថា “ ពេលនេះលោកនឹងត្រូវបញ្ជូនបបរ និង ម្ហូបដែលពួកឧបដ្ឋាកប្រគេន មកឲ្យយើងមិនខាន សូម្បីបបរ និងម្ហូបដែលគិតទុកនោះ ក៏មិនបានឃើញ ទើបគិតតទៅទៀតថា “ អើហ្ន៎ ! របស់បញ្ជូនមកមិនមាន ពួកឧបដ្ឋាកគង់នឹងរង់ចាំប្រគេនលោក នៅពេលចូលទៅបិណ្ឌបាតមិនខាន ” លុះដល់ចូលក្រុង(ដើម្បីបិណ្ឌបាត) ជាមួយព្រះថេរៈម្ចាស់ទីកន្លែងនោះអំពីព្រលឹម លោកទាំងពីរដើរទៅក្នុងផ្លូវមួយខ្សែ បានបបរមួយផ្តិលក៏ទៅអង្គុយហុតជាមួយគ្នាក្នុងរោងឆាន់ ពេលនោះលោកអាគន្តុកៈ ក៏គិតទៀតថា បបរប្រចាំកន្លែងមិនមាន ក្នុងពេលឆាន់បាយថ្ងៃត្រង់នេះឯង មនុស្សទាំងឡាយគង់

នឹងប្រគេនបាយយ៉ាងប្រណីតមិនខាន តែសូម្បីដល់វេលាឆាន់ត្រង់ លោកនៅតែមិនបាន លោកក៏ឆាន់អាហារដែលទៅបិណ្ឌបាតមកនោះឯង ទើបសួរឡើងថា "លោកដ៏ចម្រើន លោកចិញ្ចឹមអត្តភាពរហូតមកយ៉ាងនេះឬ " កាលព្រះថេរៈទទួលថា "យ៉ាងនោះហើយ " ទើបចេញសម្ដីបបួលថា " លោកដ៏ចម្រើន ជនបទ បាចីនខណ្ឌរាជី ជាទីផាសុក យើងទៅទីនោះជាមួយគ្នាចុះ " ព្រះថេរៈទទួលសម្ដី យល់ព្រមទៅ ក៏ចេញអំពីព្រះនគរតាមទ្វារខាងត្បូង ដើរទៅតាមផ្លូវដែលទៅកាន់ភូមិជាងស្មូនឆ្នាំង ទៅតែម្ដង មិនត្រឡប់ទៅវត្តជាមុនឡើយ ភិក្ខុអាគន្តុកៈក៏និយាយប្រទាញថា " ហេតុអ្វី លោកដើរផ្លូវនេះវិញ " ព្រះថេរៈឆ្លើយថា "អាវុសោ លោកពោលសរសើរជនបទបាចីនខណ្ឌរាជី មិនមែនឬ ការទៅជនបទនោះ ក៏ត្រូវដើរទៅផ្លូវនេះឯង " ភិក្ខុអាគន្តុកៈចំឡែកចិត្ត ដែលលោកមិនត្រឡប់ទៅទុកដាក់របស់របរឯវត្ត ទើបសួរថា " ចុះក្នុងទីលំនៅ ដែលលោកនៅមកយូរប៉ុណ្ណេះ អតិរេកបរិក្ខារឯណានីមួយមិនមានទេឬ " លោកតបថា " អាវុសោ ! គ្រែ តាំង ដែលយើងប្រើ ក៏ជារបស់សង្ឃ ឯខ្ញុំក៏រក្សាវាទុករៀបរយហើយ របស់ដទៃក៏មិនមាន ( ទើបមិនចាំបាច់ត្រឡប់ទៅវត្តជាមុនទេ ) លោកអាគន្តុកៈប្រាប់ថា " ឈើច្រត់ និងបំពង់ប្រេង ស្បែកជើង ស្ពាយបាត្ររបស់ខ្ញុំ នៅទីនោះ ព្រះថេរៈពោលថា " អាវុសោ លោកមកស្នាក់នៅមួយថ្ងៃ មានរបស់មកទុកដល់ប៉ុណ្ណោះឬ " លោកអាគន្តុកៈទទួលថា យ៉ាងនេះហើយ ក៏មានចិត្តជ្រះថ្លាថ្វាយបង្គំព្រះថេរៈ រួចពោលថា " លោកដ៏ចម្រើន ភិក្ខុដូចលោក អរញ្ញវាស ( ការនៅដូចនៅព្រៃ ) រមែងទៅបានក្នុងទីគ្រប់កន្លែងដែលត្រូវទៅ ចូបារាមជាទីបញ្ចុះព្រះធាតុរបស់ព្រះពុទ្ធជាម្ចាស់ ៤ ព្រះអង្គ បានស្ដាប់ធម៌ដែលជាសប្បាយក្នុងលោហប្រាសាទ បាននមស្ការព្រះចេតិយនិង

បានជួបភិក្ខុដ៏ជាធំ ប្រព្រឹត្តទៅហាក់បីដូចជាពុទ្ធកាល សូមលោកចូរនៅតទៅក្នុងថូបារាមនេះចុះ ដូច្នេះហើយ ថ្ងៃស្អែកឡើងក៏កាន់បាត្រត្រឡប់ទៅតែម្នាក់ឯង ។ អាវាសរមែងមិនជាបលិពោធសម្រាប់ភិក្ខុដូច( ព្រះថេរៈនៅក្នុងថូបារាម )នេះឯង ។

## ២. កុលបលិពោធ

### ( កង្វល់ព្រោះត្រកូល )

ត្រកូលញាតិក្តី ត្រកូលឧបដ្ឋាកក្តី ឈ្មោះថា **កុល** ពិតណាស់ សម្រាប់ភិក្ខុរូបខ្លះដែលនៅប្រឡូកប្រឡំ( ជាមួយមនុស្សក្នុងត្រកូល ជិតដិតស្និទ្ធស្នាលគ្នា ) ដោយន័យថា កាលគេជាសុខក៏សុខដែរ ដូច្នេះជាដើម សូម្បីតែត្រកូលឧបដ្ឋាកក៏ជាបលិពោធបាន (ទឹងពោលថ្វីដល់ត្រកូលញាតិនោះ) ភិក្ខុដូច្នោះ សូម្បីនឹងព្រាត់អំពីមនុស្សក្នុងត្រកូល ទៅគ្រាន់តែវិហារជិតខាងដើម្បីស្តាប់ធម៌ ក៏មិនបាន សម្រាប់ភិក្ខុរូបខ្លះ សូម្បីតែញោមប្រុសញោមស្រី ក៏មិនជាបលិពោធ ដូចភិក្ខុកំលោះដែលជាក្មួយរបស់ព្រះតិស្សត្ថេរ ដែលនៅក្នុងកោរន្ទកវិហារ ។

មានរឿងពោលថា ភិក្ខុកំលោះរូបនោះបានទៅរោហណជនបទ ដើម្បីរៀនបាលី ចំណែកឧបាសិកា(ញោមស្រី) ដែលជាប្អូនរបស់ព្រះថេរៈ តែងសួរដំណឹងរបស់លោកកូននឹងព្រះថេរៈរឿយ ៗ ព្រះថេរៈគិតថា ជាការរំខាន ក៏ទៅនាំភិក្ខុកំលោះត្រឡប់មកវិញ ទើបចេញដំណើរឆ្ពោះទៅកាន់រោហណជនបទ ។ ខាងភិក្ខុកំលោះក៏គិតថា យើងនៅទីនេះយូរហើយ ឥឡូវនេះយើងនឹងទៅសួរសុខទុក្ខព្រះឧបជ្ឈាយ៍ និងជម្រាបដំណឹងដល់ឧបាសិកាហើយ សឹមត្រឡប់មកវិញ ។ ហើយក៏ចេញអំពីរោហណជនបទមក លោកទាំងពីរនាក់មកជួបគ្នានៅត្រង់ឆ្នេរស្ទឹង ( មួយ

កន្លែង) ភិក្ខុកំលោះ ក៏ធ្វើឧបជ្ឈាយវត្តដល់ព្រះថេរៈត្រង់គល់ឈើមួយដើម លោកសួរថា នឹងទៅណា ក៏ប្រាប់សេចក្តីដែលគិតនោះឲ្យជ្រាប ទើបព្រះថេរៈពោលថា អ្នកធ្វើនេះល្អហើយ ឧបាសិកាក៏សួរដល់អ្នករឿយៗ សូម្បីអាត្មាភាពមកនេះ ក៏ដើម្បី(ការត្រឡប់ទៅរបស់អ្នក)នោះឯង អ្នកទៅចុះ ចំណែកអាត្មា នឹងស្នាក់នៅចាំវស្សា( ក្នុងវិហារណាមួយ )ក្នុងទឹកដីនេះ ដូច្នេះហើយក៏បញ្ជូនភិក្ខុកំលោះនោះទៅ លោកទៅដល់គោរន្ទកវិហារនោះ ក្នុងថ្ងៃចូលវស្សាល្មម សូម្បីសេនាសនៈដែលបានដល់លោក ក៏គឺសេនាសនៈ ដែលញោមប្រុសរបស់លោកកសាងទុកនោះឯង កាលថ្ងៃរះឡើងបន្ទាប់ពីថ្ងៃចូលវស្សា ញោមប្រុសរបស់លោកមកសួរ ( សេនា-សនគាហាបកៈ ) ថា " បពិត្រលោកម្ចាស់ សេនាសនៈរបស់ខ្ញុំករុណា បានដល់ភិក្ខុអង្គណា " បានឮថា បានដល់ភិក្ខុកំលោះអាគន្តុកៈ ទើបទៅរកថ្វាយបង្គំ ហើយពោលថា " បពិត្រលោកម្ចាស់ សម្រាប់ភិក្ខុដែលចូលវស្សា ក្នុងសេនាសនៈរបស់ខ្ញុំករុណា ត្រូវមានវត្ត(ដែលនឹងគប្បីបដិបត្តិ) លោកសាកសួរថា " វត្តអ្វីឧបាសក " ញោមប្រុសប្រាប់ថា " វត្តគឺ ត្រូវទទួលភត្តក្នុងផ្ទះរបស់ខ្ញុំម្ចាស់តែម្យ៉ាង រហូត ១ត្រីមាស( ប្រការ១ ) បវារណាហើយវេលានឹងទៅ ត្រូវមកលា( ប្រការ១ ) " លោកទទួលដោយតុណ្ហីភាព ។ ចំណែកឧបាសកត្រឡប់ទៅផ្ទះប្រាប់ឧបាសិកាថា " ព្រះគុណម្ចាស់អាគន្តុកៈមួយអង្គចូលវស្សាក្នុងអាវាសរបស់យើង យើងគប្បីទំនុកបម្រុងដោយគោរពចុះ " ឧបាសិកាទទួលពាក្យថា សាធុ ! ហើយឲ្យចាត់ខាទនីយ ភោជនីយ ដ៏ប្រណីតទុក ។ ខាងភិក្ខុកំលោះដល់ពេលឆាន់ក៏ទៅកាន់ផ្ទះរបស់ញោម មិនមាននរណាចាំលោកបាន សូម្បីត្រឹមតែម្នាក់ លោកឆាន់បិណ្ឌបាតត្រង់ផ្ទះនោះ ចាំវស្សារហូតអស់ត្រីមាស ហើយក៏ពោលលាថា អាត្មានឹងទៅ កាល

នោះ ពួកញាតិរបស់លោក ក៏សំណូមពរថា "ស្អែកនេះសឹមទៅ លោកម្ចាស់" ថ្ងៃស្អែកឡើងប្រគេនចង្ហាន់លោកត្រង់ផ្ទះនោះ ហើយថែមប្រេងឲ្យពេញបំពង់ ប្រគេនស្ករអំពៅមួយដុំ និងសំពត់សាដកប្រវែង ៩ ហត្ថ មួយផ្ទាំង ហើយទើបអនុញ្ញាតឲ្យលោកទៅ លោកធ្វើអនុមោទនាហើយ ក៏ត្រឡប់ទៅកាន់រោហណជនបទវិញ ។

ចំណែកឧបជ្ឈាយ៍របស់លោក បវារណាហើយ ដើរផ្លូវមក ក៏បានជួបលោកក្នុងទីដែលបានជួបគ្នានោះឯង លោកបានថ្វាយបង្គំព្រះថេរៈហើយ បានធ្វើឧបជ្ឈាយវត្តដល់ព្រះថេរៈ ត្រង់គល់ឈើកន្ទេងមុនស្រេចហើយ ព្រះថេរៈសួរលោកថា នែបា ! ភទ្រមុខ( អ្នកមានមុខស្រស់ ) អ្នកបានជួបឧបាសក និងឧបាសិការបស់អ្នកហើយឬ ? លោកទទួលថា " បានជួបហើយ " ហើយក៏និយាយព្រឹត្តិការណ៍ទាំងពួងប្រគេន លាបជើងរបស់ព្រះថេរៈដោយប្រេងនោះ ធ្វើទឹកបានទឹកអំពៅប្រគេន ថ្វាយសំពត់សាដកមួយផ្ទាំងនោះឯងដល់ព្រះថេរៈ ថ្វាយបង្គំហើយពោលថា រោហណជនបទប៉ុណ្ណោះជាទីសប្បាយ សម្រាប់ខ្ញុំព្រះករុណាទានប្រោស ហើយក៏លាទៅ ចំណែកព្រះថេរៈក៏មកកាន់(កោរន្ទក)វិហារ ស្អែកឡើងទើបចូលទៅកាន់ស្រុកកោរន្ទកគ្រាម ។

ចំណែកឧបាសិកា ដែលតែងឈរចាំមើលផ្លូវរាល់ថ្ងៃ សង្ឃឹមក្នុងចិត្តថា លោកបងរបស់ខ្លួននឹងនាំលោកកូនរបស់ខ្លួនមកថ្ងៃនេះឯង ( ថ្ងៃនោះ )នាងឃើញលោកមួយអង្គឯង ក៏ សម្គាល់ថា ប្រហែលកូនរបស់ខ្លួនស្លាប់បាត់ទៅហើយ ទើបព្រះថេរៈមកតែមួយអង្គឯង ក៏ដួលចុះស្រែកយំរៀបរាប់ទៀបព្រះបាទាព្រះថេរៈ ព្រះថេរៈជ្រាបបានថា " ភិក្ខុកំលោះមកហើយ មិនឲ្យនរណាស្គាល់ខ្លួន ព្រោះសេចក្តីប្រាថ្នាតិច( ត្រឡប់ ) ទៅហើយមែនពិតហ្ន៎ !" ទើបលួងលោមនាង ( ឲ្យស្បើយ

បរិទេវៈ ) ហើយនិយាយព្រឹត្តិហេតុទាំងពួងឲ្យស្ដាប់ ក៏នាំយកសំពត់សាដកមួយផ្ទាំងនោះចេញអំពីស្បោកបាត្រសំដែង (ឲ្យឃើញជាបន្ទាល់) ឧបាសិកាជ្រាបសេចក្ដីពិតដូច្នោះ កើតសេចក្ដីជ្រះថ្លា បែរមុខទៅទិសដែលលោកកូនទៅ ក្រាបចុះនមស្ការពោលថា " ព្រះដ៏មានព្រះភាគជាម្ចាស់ គង់នឹងទ្រង់ធ្វើភិក្ខុដូចបុត្ររបស់យើងនេះឯងហ្ន៎ ឲ្យជាកាយសក្ខី(អ្នកមានខ្លួនជាបន្ទាល់) ត្រាស់រថវិនីតបដិបទា នាលកបដិបទា តុវដ្ដកបដិបទា និងមហាអរិយវង្សបដិបទា ដែលសំដែងនូវសេចក្ដីសន្ដោសដោយបច្ច័យ ៤ និង សេចក្ដីត្រេកអរដោយភាវនា គួរសរសើរ សូម្បីឆាន់អាហារនៅក្នុងផ្ទះរបស់មាតាបង្កើតដល់ទៅ៣ខែ លោកក៏មិនបានបង្ហើបថា ខ្ញុំជាកូនរបស់អ្នក អ្នកជាមាតា ឱ ! អច្ឆរិយមនុស្ស " សម្រាប់ ( ភិក្ខុអ្នកមានចិត្តមិនជាប់ជំពាក់ ) យ៉ាងនេះឯង សូម្បីតែមាតាបិតាគង់ជាបលិពោធមិនបាន នឹងពោលថ្វីដល់ត្រកូលឧបដ្ឋាកដទៃ ដោយប្រការដូច្នេះឯង ។

## ៣. លាភបលិពោធ

### ( កង្វល់ព្រោះលាភ )

បច្ច័យ ៤ ឈ្មោះថា **លាភ** សួរថា បច្ច័យនោះជាបលិពោធ បានយ៉ាងណា ? ឆ្លើយថា ក្នុងកន្លែងដែលភិក្ខុអ្នកមានបុណ្យ និមន្ដទៅ មនុស្សទាំងឡាយរមែងថ្វាយបច្ច័យ មានរបស់បរិក្ខារជាច្រើន លោករវល់អនុមោទនា រវល់សំដែងធម៌ដល់មនុស្សទាំងនោះ រមែងមិនបានឱកាសធ្វើសមណធម៌ តាំងអំពីអរុណរះឡើងរហូតដល់បឋមយាម ត្រូវជាប់រវល់ជាមួយមនុស្សម្នាមិនដាច់រយៈ លុះពេលជិតភ្លឺ ពួកភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្ត ប្រភេទពាហុល្លិក ( ប្រាថ្នាច្រើនក្នុងបច្ច័យ )

ក៏នាំគ្នាមកប្រាប់ថា “ លោកដ៏ចម្រើន ឧបាសកនោះ ឧបាសិកានោះ អមាត្យនោះ បុត្តអមាត្យនោះ ធីតាអមាត្យនោះ ប្រាថ្នានឹងឃើញលោក ” លោកឃាត់គេមិនបាន ក៏ប្រាប់ភិក្ខុទាំងនោះឲ្យជួយកាន់បាត្រចីវរផង ជាអ្នកត្រៀមនឹងទៅតែម្តង ជាអ្នកត្រូវខ្វល់ខ្វាយ( ក្នុងការសង្គ្រោះអ្នកដទៃ )ជានិច្ច បច្ច័យទាំងនោះ រមែងជាបលិពោធចំពោះភិក្ខុនោះដូច្នេះ ។ ឯភិក្ខុនោះត្រូវលះពួកគណៈចេញ ត្រាច់ទៅតែម្នាក់ឯង ក្នុងទីដែលពួកមនុស្សអ្នកដទៃមិនស្គាល់លោក យ៉ាងនេះ ទើបកាត់នូវបលិពោធនោះចេញបាន ។

## ៤. គណបលិពោធ

### ( កង្វល់ព្រោះពួកគណៈ )

គណៈភិក្ខុអ្នករៀនព្រះសូត្រក្តី គណៈភិក្ខុអ្នករៀនព្រះអភិធម្មក្តី ឈ្មោះថា **គណៈ** ភិក្ខុណាវល់ឲ្យឧទ្ទេសក្តី បរិបុច្ឆាក្តី ដល់គណៈនោះ រមែងមិនបានឱកាសសម្រាប់សមណធម៌ **គណៈ** ទើបជាបលិពោធចំពោះភិក្ខុនោះ គណបលិពោធនោះលោកគួរកាត់ចេញដោយឧបាយដូចតទៅនេះ បើការងារ ( រៀនសូត្រ ) របស់ភិក្ខុទាំងនោះស្រេចទៅហើយបានច្រើន ការងាររៀនសូត្រដែលសល់តិចសោត ភិក្ខុគប្បីធ្វើការងារនោះបង្ហើយឲ្យសម្រេច ហើយចូលទៅកាន់ព្រៃចុះ បើការងារដែលសម្រេចហើយតិច ដែលនៅសល់ច្រើនជាងសោត ភិក្ខុនោះ(គប្បីទៅរកគណ-វាចកៈ“ អ្នកបង្រៀនគណៈ ”ដទៃឲ្យបង្រៀនជំនួស ) កុំគប្បីទៅឆ្ងាយហួសពី ១ យោជន៍ ចូលទៅរកគណវាចកៈដទៃ ( ដែលតាំងសម្នាក់នៅ ) ខាងក្នុងទីកំណត់ ១ យោជន៍ សូមពរឲ្យលោកជួយសង្គ្រោះភិក្ខុក្នុងគណៈរបស់ខ្លួនដោយ សង្គហវិធី

មានឧទ្ទេសជាដើម (ជំនួសខ្លួន)ចុះ បើមិនបានដូចពោលមកនេះ គប្បីប្រាប់ ( ភិក្ខុទាំងនោះ ) ថា “ អាវុសោទាំងឡាយ កិច្ចឯណានីមួយរបស់ខ្ញុំករុណាមាននៅ( មិនអាចបង្រៀនលោកទាំងឡាយតទៀតបាន ) និមន្តលោកទាំងឡាយចែកផ្លូវគ្នាទៅរកទីដទៃរៀនតាមសមគួរចុះ ” ដូច្នេះហើយ លះបោលគណៈ ទៅបំពេញការងាររបស់ខ្លួន តាមសមគួរចុះ ។

## ៥.កម្មបលិពោធ

### ( កង្វល់ព្រោះការងារ )

នវកម្ម( ការកសាង ) ឈ្មោះថា **កម្ម** ( ការងារ )ដែលភិក្ខុអ្នកធ្វើនវកម្មនោះ ចាំបាច់ត្រូវដឹងទព្វសម្ភារដែលអ្នកធ្វើការងារមានជាងឈើជាដើមទុកហើយ និងនៅរកមិនទាន់បាន ត្រូវខ្វល់ខ្វាយ(មើលថែ) ក្នុងការងារដែលគេធ្វើសម្រេចហើយ និងនៅមិនទាន់ធ្វើ ។ អ្នកធ្វើនវកម្មត្រូវមានបលិពោធគ្រប់យ៉ាងដូច្នេះឯង ។

សូម្បីកម្មបលិពោធនោះ ក៏គប្បីកាត់ចេញដោយឧបាយ ដូចតទៅនេះ បើការងារសល់តិច គប្បីធ្វើបង្ហើយឲ្យស្រេច បើសល់ច្រើន ហើយជានវកម្មរបស់សង្ឃសោត គប្បីប្រគល់ដល់សង្ឃ ឬ ដល់ភិក្ខុអ្នកនាំការៈក្នុងសង្ឃកិច្ចទាំងឡាយ ប្រសិនបើជានវកម្មផ្ទាល់ខ្លួន គប្បីប្រគល់ដល់អ្នកនាំការៈរបស់ខ្លួន បើមិនមានភិក្ខុអ្នកនាំការៈ ដូច្នោះ ក៏គប្បីលះបង់(ការងារ)នោះ ឲ្យដល់សង្ឃហើយ ទៅចុះ ។

## ៦.អទ្ធានបលិពោធ

### ( កង្វល់ព្រោះដំណើរផ្លូវឆ្ងាយ )

ការដើរផ្លូវឈ្មោះថា **អទ្ធាន** ក៏បព្វជ្ជាបេក្ខៈរបស់ភិក្ខុណាមាននៅក្នុងទីណាក្តី

បច្ច័យប្រភេទណា ៗ ដែលភិក្ខុណានឹងគប្បីបាននៅទីណាក្តី បើភិក្ខុនោះនៅមិនទាន់បានជួបបព្វជ្ជាបេក្ខៈ និង បច្ច័យនោះ លោកមិនអាចឈប់នៅបាន ដែលគមិកចិត្ត ( ចិត្តគិតនឹងទៅ ) សូម្បីនៃភិក្ខុអ្នកចូលព្រៃធ្វើសមណធម៌ ក៏ជារបស់លំបាកនឹងបន្ទាបង់បាន ព្រោះដូច្នោះ លោកគប្បីទៅចាត់ចែងធ្វើកិច្ចការនោះ ឲ្យស្រេចហើយទើបធ្វើសេចក្តីខ្វល់ខ្វាយក្នុងសមណធម៌ចុះ ។

## ៧. ញាតិបលិពោធ

### ( កង្វល់ព្រោះញាតិ )

បុគ្គលទាំងឡាយដែលចាំបាច់ត្រូវស្គាល់ មានដូច្នេះគឺ ( ក្នុងចំណែក ) វត្តមានព្រះអាចារ្យ ព្រះឧបជ្ឈាយ៍ សទ្ធិវិហារិក អន្តេវាសិក ភិក្ខុរួមឧបជ្ឈាយ៍ ភិក្ខុរួមអាចារ្យ , ក្នុង( ចំណែក ) ផ្ទះសម្បែង មានមាតាបិតា បងប្អូនស្រី បងប្អូនប្រុសជាដើម ឈ្មោះថា **ញាតិ** បុគ្គលទាំងនោះកើតជំងឺឡើង ទើបជាបលិពោធដល់ភិក្ខុនេះ ព្រោះហេតុនោះ បលិពោធនោះ លោកគប្បីកាត់ដោយការឧបដ្ឋាកធ្វើបុគ្គលដែលជាអ្នកឈឺទាំងនោះ ឲ្យជាសះស្បើយ ជាធម្មតាចេញ ។

ក្នុងបុគ្គលទាំងនោះ ពោលដល់ព្រះឧបជ្ឈាយ៍ មានជំងឺមុន បើលោកក្រជាគប្បីប្រតិបត្តិលោករហូតអស់ជីវិតចុះ ទាំងព្រះបព្វជ្ជាចារ្យ ព្រះឧបសម្បទាចារ្យ សទ្ធិវិហារិក អន្តេវាសិក ដែលខ្លួន(សូត្រកម្មវាចា) ឲ្យឧបសម្បទ និង ឲ្យបព្វជ្ជា និងភិក្ខុរួមឧបជ្ឈាយ៍(មានជំងឺ) ក៏គប្បីប្រតិបត្តិដូច(ឧបជ្ឈាយ៍)នោះចុះ ចំណែកព្រះនិស្សយាចារ្យ ព្រះឧទ្ទេសាចារ្យ និស្សយន្តេវាសិក ឧទ្ទេសន្តេវាសិក និងភិក្ខុរួមអាចារ្យគប្បីប្រតិបត្តិត្រឹមតែនិស្ស័យ និង ឧទ្ទេសនៅមិនទាន់ដាច់ តែបើអាច ក៏គួរ

ប្រតិបត្តិតទៅទៀតចុះ ។

ក្នុងមាតាបិតា គប្បីប្រតិបត្តិដូចក្នុងឧបជ្ឈាយ៍ចុះ ពិតណាស់ មាតាបិតានោះ សូម្បីលោកជាអ្នកស្ថិតនៅក្នុងរាជសម្បត្តិ បើលោក(ប្រឈួន) សង្ឃឹមបានទទួលការឧបដ្ឋាកអំពីបុត្រសោត ភិក្ខុក៏គួរធ្វើ(ឲ្យលោក)ចុះ ម្យ៉ាងទៀត ថ្នាំរបស់លោកមិនមាន ក៏គប្បីឲ្យថ្នាំរបស់ខ្លួន បើថ្នាំរបស់ខ្លួនមិនមាន ក៏គួរស្វែងរកដោយភិក្ខាចារមកឲ្យ(លោក) ដរាបទាល់តែបានចុះ ។

តែសម្រាប់បងប្អូនប្រុសស្រីមានជំងឺ គប្បីផ្សំថ្នាំដែលជារបស់គេនោះឯងឲ្យគេ បើរបស់គេមិនមាន ទើបឲ្យរបស់ផងខ្លួន ជារបស់ខ្ចី បើរកបានខាងក្រោយទើបកាន់យកវិញជាសំណង បើរកមិនបានក៏កុំទារឡើយ នឹងធ្វើថ្នាំ នឹងឲ្យថ្នាំដល់សាច់ថ្លៃដែលមិនមែនជាញាតិ រមែងមិនគួរ តែគប្បីឲ្យដល់បងប្អូនស្រី ប្រាប់គេឲ្យដល់ប្តីរបស់គេ សូម្បីកិរិយារបស់បងប្អូនប្រុសក៏មានន័យដូចគ្នា ចំណែកបុត្តទាំងឡាយរបស់ពួកគេដែលជាញាតិរបស់លោកពិត ព្រោះដូច្នោះ ធ្វើថ្នាំឲ្យដល់បុត្តរបស់ពួកគេទាំងនោះ រមែងគួរ ។

## ៨. អាពាធបលិពោធ

( កង្វល់ព្រោះអាពាធ )

រោគប្រភេទណាមួយ ឈ្មោះថា **អាពាធ** រោគនោះវាបៀតបៀន ទើបឈ្មោះថា **បលិពោធ** ព្រោះហេតុនោះ គប្បីកាត់វាចេញដោយការធ្វើភេសជ្ជៈ តែកាលបើភិក្ខុព្យាបាលពីរបីថ្ងៃហើយ អាពាធមិនស្ងប់សោត ក៏គប្បីតិះដៀលអត្តភាពថា អញមិនមែនខ្ញុំបម្រើ មិនមែនកូនឈ្នួលរបស់ឯងឡើយ ក៏ព្រោះអញចិញ្ចឹមឯង

នោះឯង ទើបបានទទួលទុក្ខក្នុងសង្សារវដ្ដ ដ៏យូរលង់ មិនប្រាកដខាងដើម និងខាងចុង ដូច្នេះហើយធ្វើសមណធម៌ចុះ ។

## ៩. គន្ថបលិពោធ

### ( កង្វល់ព្រោះរៀនព្រះបរិយត្តិ )

ធុរកិច្ចក្នុងបរិយត្តិ ឈ្មោះថា **គន្ថ** ការបរិហារបរិយត្តិនោះ រមែងជាបលិពោធដល់ភិក្ខុអ្នកខ្វល់ខ្វាយជានិច្ច ដោយកិច្ចមានការស្វាធ្យាយន៍ជាដើមប៉ុណ្ណោះ តែមិនបលិពោធដល់ភិក្ខុក្រៅពីនេះ ( អ្នកមិនបានខ្វល់ខ្វាយ )នោះទេ រឿងខាងក្រោមជានិទស្សនៈក្នុងសេចក្ដីដែលគន្ថៈមិនជាបលិពោធសម្រាប់ភិក្ខុអ្នកមិនខ្វាយខ្វល់ :-

បានឮមកថា ព្រះទេវត្ថេរ ដែលជាមជ្ឈិមភាណក(អ្នកសូត្រមជ្ឈិមនិកាយ) ទៅកាន់សម្នាក់របស់ព្រះទេវត្ថេរអ្នកដែនមលយ សូមកម្មដ្ឋាន ព្រះថេរៈសួរថា អាវុសោលោកជាអ្នកបានរៀនប៉ុនណាក្នុងបរិយត្តិ ព្រះមជ្ឈិមភាណកតបថា លោកដ៏ចម្រើនមជ្ឈិមនិកាយ ខ្ញុំម្ចាស់ជំនាញ , ព្រះថេរៈពោលថា អាវុសោ មជ្ឈិមនិកាយនោះ បរិហារលំបាក កាលស្វាធ្យាយមូលបណ្ណាសកៈ មជ្ឈិមបណ្ណាសកៈក៏មកលាយ កាលស្វាធ្យាយមជ្ឈិមបណ្ណាសកៈវិញ ឧបរិបណ្ណាសកៈ(ក៏ច្របូកច្របល់) បើវល់មិនចេះចប់ដូច្នេះ ពេលណាកម្មដ្ឋាននឹងមានដល់លោកបាន ព្រះមជ្ឈិមភាណកប្ដេជ្ញាថា លោកដ៏ចម្រើន ខ្ញុំករុណាបានកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះគុណម្ចាស់ហើយ នឹងមិនងាកមើល(គន្ថៈនោះ)ឡើយ ដូច្នេះហើយ ក៏ទទួលយកកម្មដ្ឋាន ( ទៅធ្វើសេចក្ដីព្យាយាម ) មិនបានធ្វើការស្វាធ្យាយន៍ដល់ទៅ ១៩ឆ្នាំ លុះដល់ឆ្នាំទី ២០ ក៏បានសម្រេចនូវព្រះអរហត្ត ។ ថ្ងៃមួយ លោកពោលដល់ភិក្ខុទាំងឡាយ

ដែលនាំគ្នាមកដើម្បីនឹងស្វាធ្យាយ( ប្រឡង ) ថា អាវុសោទាំងឡាយ កាលយើង មិនបានងាកមើលបរិយត្តិ រហូតដល់ទៅ ២០ ឆ្នាំ តែថា យើងមានការសន្សំបានធ្វើ ទុកក្នុងបរិយត្តិនោះ និមន្តលោកទាំងឡាយ ផ្តើមស្វាធ្យាយទៅចុះ កាលភិក្ខុទាំងនោះ ស្វាធ្យាយទៅ ប្រាកដថា លោកនៅចាំបរិយត្តិនោះបានល្អ លោកមិនមានការ សង្ស័យស្មាក់ស្មើរសូម្បីក្នុងព្យញ្ជនៈ សូម្បីតែមួយតួ តាំងអំពីដើមរហូតដល់ចប់ ។

សូម្បីព្រះនាគត្ថេរ អ្នកនៅក្នុងភ្នំករុន្ទិយគីរី លះបង់បរិយត្តិដល់ទៅ១៨ ឆ្នាំ ហើយមកសម្តែងធាតុកថា ដល់ភិក្ខុទាំងឡាយ កាលភិក្ខុទាំងនោះ( ចាំបានហើយ យកទៅ ) ផ្ទៀងផ្ទាត់ជាមួយព្រះថេរៈគាមវាសីទាំងឡាយ ប្រាកដថា បញ្ហាសូម្បី មួយៗដែលមកខុសលំដាប់ ក៏មិនមាន ។ សូម្បីក្នុងមហាវិហារ ព្រះថេរៈឈ្មោះថា ចូឡាភយដែលជា តិបិដក ( ទ្រទ្រង់បិដកទាំង៣ ) មិនបានរៀនអដ្ឋកថាឡើយ លោកគិតក្នុកឡើងមក ឲ្យមនុស្សវាយសុវណ្ណភេរីថា នឹងបរិវត្ត ( ពណ៌នា ឬ ប្រែ ) បិដកទាំង ៣ ក្នុងវង្សអ្នកសិក្សាបញ្ចនិកាយ ។ ពួកភិក្ខុផងគ្នា ( បានឮថា ព្រះចូឡាភយ មិនមានគ្រូអាចារ្យ ) ទើបក្លែងធ្វើជាពោលជំទាស់ ថា “ បានរៀន អំពីអាចារ្យណាមក ព្រះចូឡាភយក៏ចូរពោលតែត្រង់ដែលបានរៀន អំពីអាចារ្យ របស់ខ្លួនចុះ យើងទាំងឡាយមិនព្រមឲ្យពោលទៅក្រៅអំពីនេះ ” សូម្បីឧបជ្ឈាយ៍ ក៏បានសួរលោក ដែលមកឧបដ្ឋាកលោកថា អាវុសោ លោកឲ្យវាយស្គរឬ លោក ទទួលថា “ ពិត ” ព្រះឧបជ្ឈាយ៍ក៏សួរទៀតថា “ ព្រោះហេតុអ្វី ” លោកទូល តបថា “ ខ្ញុំករុណានឹងបរិវត្តធម៌ ” ( ឲ្យមនុស្សស្តាប់ ) ព្រះឧបជ្ឈាយ៍សាកល្បង សួរថា នៃអាវុសោ អភ័យ អាចារ្យទាំងឡាយពោលបទនេះដូចម្តេច លោកឆ្លើយ ភ្លាមថា ពោលយ៉ាងនេះ ព្រះឧបជ្ឈាយ៍ ក្លែងធ្វើជាបដិសេធដោយសំឡេងថា ហ៊ឺ

ហ៊ឺ លោកក៏ឆ្លើយជាថ្មីដោយបរិយាយដទៃៗថា ពោលយ៉ាងនេះៗ ដល់ទៅ ៣ ដង ព្រះថេរក៏បដិសេធដោយសំឡេង ហ៊ឺ ហ៊ឺ ទាំងអស់ ហើយពោលថា នែអាវុសោ! គន្ថងដែលអ្នកពោលឆ្លើយជាដំបូងនោះឯង ជាអាចរិយមគ្គណា ( កថាមគ្គរបស់អាចារ្យ ) តែព្រោះអ្នកមិនបានរៀនពីអាចរិយមុខ( មាត់របស់អាចារ្យ ) ទើបមិនអាចប្រាកដប្រជាថា អាចារ្យទាំងឡាយពោលយ៉ាងនេះ ព្រោះដូច្នោះ អ្នកចូរទៅស្តាប់ក្នុងសម្នាក់នៃអាចារ្យទាំងឡាយ ដែលគួរនឹងជាអាចារ្យរបស់ខ្លួនចុះ ។ លោកទូលសួរថា នឹងទៅក្នុងទីណាល្អ ព្រះឧបជ្ឈាយ៍ ទើបប្រាប់ថា ព្រះថេរៈឈ្មោះមហាធម្មរក្ខិត អ្នកជំនាញក្នុងបរិយត្តិទាំងពួង នៅប្រចាំក្នុងវត្តក្ដុលាធារបព៌ត ក្នុងរោហណជនបទ ត្រើយនាយនៃស្ទឹងម្ខាង អ្នកចូរទៅកាន់សម្នាក់របស់លោកចុះ ។

ព្រះចូឡាភយទទួលពាក្យ ថ្វាយបង្គំលាព្រះថេរៈ ហើយទៅកាន់សម្នាក់ព្រះធម្មរក្ខិតត្ថេរ ព្រមដោយភិក្ខុបរិវារប្រមាណ ៥០០ អង្គ ( កាលទៅដល់ហើយចូលទៅថ្វាយបង្គំ ) ហើយអង្គុយចុះ ព្រះថេរៈសួរថា មកធ្វើអ្វី ក៏ពិតថេរៈដីកាថា មកដើម្បីស្តាប់ធម៌ ទើបព្រះថេរៈពោលថា អាវុសោ អភ័យ ភិក្ខុទាំងឡាយមកសួរខ្ញុំករុណា ក្នុងទីឃនិកាយ និង មជ្ឈិមនិកាយ ម្តងម្កាល ចំណែកសូត្រដ៏សេសខ្ញុំមិនធ្លាប់បែរមើលរំលឹកមកប្រមាណ ៣០ ឆ្នាំហើយ តែណ្ហើយចុះ ពេលយប់អ្នកមកបរិវត្តក្នុងសម្នាក់ខ្ញុំករុណា ពេលថ្ងៃខ្ញុំករុណានឹងពោលដល់អ្នក ( ឲ្យស្តាប់ថាខុសត្រូវយ៉ាងណា ) ព្រះចូឡាភ័យយល់ព្រមធ្វើយ៉ាងនោះ ។ ពួកអ្នកស្រុកឲ្យធ្វើបារាំធំត្រង់ម្ខាងទ្វារបរិវេណ ហើយមកស្តាប់ធម៌ជុំគ្នារាល់ថ្ងៃ ។ ព្រះថេរៈយកសូត្រដែលព្រះចូឡាភ័យបរិវត្តក្នុងពេលយប់ មកពោលផ្ទៀងផ្ទាត់ក្នុងវេលាថ្ងៃ មិនមានខុសរឿយៗ ទៅរហូតដល់ចប់ហើយ គង់សង្កេតឃើញថា ព្រះចូឡាភ័យមាន

បដិភាណខ្ពស់ជាងខ្លួន ទើបថ្ងៃមួយចូលទៅអង្គុយលើកទ្រូលជិតៗ ព្រះអភ័យត្ថេរ ហើយពោលថា "លោកចូរប្រាប់កម្មដ្ឋានដល់ខ្ញុំករុណាផងចុះ" ព្រះចូឡាភ័យ ទើបពោលថា " ព្រះគុណម្ចាស់ និយាយអ្វី ក្រែងកម្មដ្ឋាននោះ ខ្ញុំម្ចាស់ក៏ស្ដាប់មកក្នុងសម្នាក់របស់ព្រះគុណម្ចាស់នោះឯង មិនមែនឬ ខ្ញុំករុណានឹងប្រាប់កម្មដ្ឋានអ្វីទៀតទៅដែលព្រះគុណម្ចាស់នៅមិនទាន់ដឹងនោះ " លំដាប់នោះ ព្រះថេរៈទើបពោល ( ឲ្យច្បាស់ឡើង ) ថា " អាវុសោ ផ្លូវរបស់បុគ្គលអ្នកទៅដល់ហើយនោះ ជាផ្លូវមួយ ( ដែលលោកពោលមកនេះ ព្រោះជ្រាបថា ពេលនោះព្រះអភ័យត្ថេរជាព្រះសោតាបន្ន ) ។

គ្រានោះព្រះចូឡាភ័យ ឲ្យកម្មដ្ឋានដល់ព្រះថេរៈហើយ ក៏ត្រឡប់មកបរិវត្តធម៌នៅឯលោហៈប្រាសាទ( ក្រុងអនុរាធបុរៈ ) ក្រោយមកបានឮដំណឹងថា ព្រះថេរៈសម្រេចព្រះអរហត្ត បរិនិព្វានហើយ ។ កាលបានឮដូច្នេះ ទើបប្រាប់សិស្សឲ្យយកចីវរមកឲ្យ ឃ្លុំចីវរជាបរិមណ្ឌល ហើយពោលសរសើរព្រះថេរៈក្នុងចំណោមភិក្ខុទាំងឡាយថា " អាវុសោ ! ទាំងឡាយ ព្រះអរហត្តមគ្គ គួរដល់លោកអាចារ្យរបស់យើងហើយ លោកអាចារ្យរបស់យើងជាអ្នកស្មោះត្រង់ ជាអាជានេយ្យបុគ្គលទើបលោកព្រមអង្គុយលើកទ្រូលក្បែរធម្មន្តេវាសិករបស់ខ្លួន ពោលថា " អ្នកចូរប្រាប់កម្មដ្ឋានដល់ខ្ញុំករុណាផងចុះ " អាវុសោទាំងឡាយ ព្រះអរហត្តមគ្គ សមគួរដល់ព្រះថេរៈហើយ " ។

គន្ថៈរមែងមិនជាបលិពោធដល់ភិក្ខុទាំងឡាយ ដែលមានគុណធម៌ដូច្នេះឯង ។

# ១០. ឥទ្ធិបលិពោធ

( កង្វល់ព្រោះឥទ្ធិ )

ពាក្យថា **ឥទ្ធិ** សំដៅយកឫទ្ធិដែលមានក្នុងបុថុជ្ជននោះ ជាវត្ថុដែលរក្សាលំបាក ដូចទារកដែលនៅដេកផ្ងារ និងដូចសន្ទូងខ្ចី រមែងវិនាសបានដោយហេតុត្រឹមតែបន្តិចបន្តួច ឯឫទ្ធិនោះ រមែងជាបលិពោធចំពោះវិបស្សនា មិនជាបលិពោធចំពោះសមាធិឡើយ ព្រោះឫទ្ធិនោះ បុគ្គលសម្រេចសមាធិហើយ ទើបបាន ព្រោះហេតុនោះឯង ឥទ្ធិបលិពោធ ព្រះយោគាវចរដែលបំណងក្នុងវិបស្សនា ចាំបាច់ត្រូវលះបង់ ។ ( ចំណែក ) បលិពោធ( ៩ ) ដ៏សេស ព្រះយោគាវចរ ដែលបំណងក្នុងសមថ គប្បីកាត់ ។ នេះជាសេចក្ដីពិស្ដារក្នុងរឿងបលិពោធ គប្បីជ្រាបជាលំដាប់ដំបូងដូច្នេះ ។

# មហាដីកា

## ពណ៌នា បលិពោធ ១០

ពាក្យថា **ដែលសម្បយុត្តជាមួយអរិយមគ្គ** បានដល់ សមាធិដែលសម្បយុត្តជាមួយព្រះអរិយមគ្គ ដែលលោកពោលទុកដោយមិនសាធារណៈ ដោយលោកិយសមាធិទាំងឡាយដោយស័ព្ទថា លោកុត្តរខ្លះ អប្បមាណខ្លះ អបរិយាបន្នខ្លះ និង ដោយសាធារណៈស័ព្ទថា សប្បីតិកជាដើម ។ ឈ្មោះថា ជាការដែលចម្រើនសមាធិហើយនោះឯង ក៏ព្រោះភាពជាធម៌ ដែលសម្បយុត្តជាមួយបញ្ញា ។ បទថា **តំ** បានដល់ អរិយមគ្គសមាធិ ។ ស័ព្ទថា **វិសុំ** ផ្សេង ៗ មានន័យថា

ខ្ញុំម្ចាស់នឹងមិនពោលបំបែកចេញទៅជាដទៃផ្សេងទៀតពីការបម្រើនបញ្ហាទេ ។

**អាវាស** ជាដើម ឈ្មោះថា **បលិពោធ** ព្រោះអត្ថថា រំខាន គឺ ចូលទៅរារាំងការបម្រើន កម្មដ្ឋាន បានដល់ មិនឲ្យប្រព្រឹត្តទៅ លោកធ្វើ **រ** អក្សរ ជា **ល** អក្សរ ( គឺដោយពិតជា **បរិពោធ** នោះឯង ) មានសេចក្តីថា កង្វល់អំពល់ ។ ពាក្យថា **លះ** គឺ បញ្ចប់ដោយការធ្វើឲ្យស្រេច ឬប្រញាប់ប្រញាល់ធ្វើឲ្យហើយ មានន័យថា ធ្វើមិនឲ្យមានបលិពោធ ។

ឈ្មោះថា **អាវាស** ព្រោះអត្ថថា ជាកន្លែងរស់នៅ ។ ឈ្មោះថា **បរិវេណ** ព្រោះអត្ថថា ដែលគេរមែងដឹង គឺប្រាកដដោយទាក់ទិនជាមួយនឹងព្រំដែន បានដល់ ស្ថានទីលំនៅនោះ ៗ នៃភិក្ខុទាំងឡាយក្នុងវិហារ បានដល់ អាវាសនោះ ៗ ។

ពាក្យថា **ក្នុងការងារ មានការកសាងជាដើម** ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) លោកសង្គ្រោះយកហេតុដែលរំខាននៃអាវាសយ៉ាងដទៃ ក្រៅពីការកសាងនោះ ។ ពាក្យថា **ដោយហេតុ** គឺ ដោយហេតុ មានយ៉ាងនេះថា ជាស្ថានទីដែលសម្បូណ៌ដោយម្ហូបឈើ និងទឹក មានភិក្ខាវរកបានងាយ ដូច្នេះ ជាដើម ។

បទថា **អបេក្ខវា** ប្រែថា មានអាល័យ ។ បទថា **តត្រ** ប្រែថា ក្នុងការមិនមានអាវាសជាបលិពោធ ។ ពាក្យថា **បាចីនខណ្ឌរាជី** គឺ ស្ថានទីជាព្រៃចម្ការនៅចន្លោះភ្នំទិសខាងកើត ។ ដោយពាក្យថា **នាម** ( ឈ្មោះ ) នេះលោកសម្តែងថា **បាចីនខណ្ឌរាជី** នេះ ជាសមញ្ញារបស់ប្រទេសនោះ ។ ពាក្យថា **ឯខ្ញុំក៏រក្សាវាទុករៀបរយហើយ** លោកសំដែងថា ខ្ញុំរក្សាវាស្រេចហើយ ទើបនឹងចេញអំពីវិហារទៅយ៉ាងនេះជានិច្ច ។ ពាក្យថា **ស្ថានទីបញ្ចុះព្រះធាតុ** គឺ ស្ថានទីដែលរក្សាព្រះបរិភោគធាតុ និង ព្រះសរីរធាតុ ពោលគឺ វត្ថុពន្ធ តម្រងទឹក សំពត់ស្រង់

ទឹក និង ព្រះអក្ខកធាតុ ( ថ្មីងដងកាំបិត ) ។ សម្រាប់ភិក្ខុអ្នក មានចិត្តមិនជាប់ជំពាក់ក្នុងអាវាសបែបនេះ ក៏ដូចជាព្រះថេរៈនេះ ។ ដោយរឿងជានិទស្សនៈនេះ លោកអាចារ្យឲ្យឱវាទហើយថា ឈ្មោះថា **ភិក្ខុ គួរជាយ៉ាងនេះក្នុងអាវាស** ដូច្នេះ ។

ក្នុងវត្ថុទាំងឡាយ សូម្បីទីដទៃក្រៅអំពីអាវាស ក៏មានន័យដូច្នេះឯង ។

ពាក្យថា **កុល** មានន័យថា លោកកាន់យកមនុស្សទាំងឡាយក្នុងត្រកូល ដោយស័ព្ទថា **កុល** ដូចជាកាន់យកមនុស្សអ្នកនៅក្នុងស្រុក ដោយស័ព្ទថា **ស្រុក** ដូច្នោះ ។ ពាក្យថា **សូម្បីត្រកូលឧបដ្ឋាក** ដោយ **បិ** ស័ព្ទ ( ប្រែថា សូម្បី ) លោកសំដែងឲ្យឃើញថា នឹងមិនបាច់ពោលថ្វីដល់ត្រកូលញាតិនោះ ។ បទថា **ឧទ្ទេសត្ថំ** ប្រែថា ដើម្បីរៀនព្រះបាលី គឺ ដើម្បីឲ្យអាចារ្យបង្រៀន មានន័យថា ដើម្បីឲ្យអាចារ្យចង្អុលបង្ហាញព្រះបាលី ហើយខ្លួនស្វាធ្យាយ ។ ពាក្យថា **ក្នុងទីនេះឯង** គឺ ក្នុងប្រទេសនេះឯង មានន័យថា ក្នុងវិហារណាមួយ ។

២បទថា **តំ វិហារំ** គឺ កោរទ្ទកវិហារនោះ ។

បទថា **ឧបគតោ** បានដល់ នៅចាំវស្សា ។ ពាក្យថា **សព្វកាលវេលា អស់កាល គ្រប់កាល** គឺ រាល់ៗថ្ងៃ រាប់តាំងអំពីកាលដែលព្រះថេរៈទៅហើយ ដោយវិសេស គឺ តាំងអំពី ព្រះថេរៈបវារណាហើយ ។ ពាក្យថា **យំរៀបរាប់** បានដល់ យំរៀបរាប់ដោយប្រការផ្សេងៗ ដោយទាក់ទងជាមួយនឹងការរៀបរាប់ដល់រឿងនោះ ។ ពាក្យថា **ការប្រព្រឹត្តទៅទាំងអស់** គឺ ការប្រព្រឹត្តទៅទាំងអស់របស់ភិក្ខុកំលោះ តាំងអំពីកាលដែលខ្លួនបានជួបក្នុងទីនោះហើយ ត្រឡប់មកជួបគ្នាជាគ្រាចុងក្រោយ ( ក្នុងទីនោះ នោះឯង ) ។

ពាក្យថា **ធ្វើឲ្យជាកាយសក្ខី** គឺ ធ្វើឲ្យជាអ្នកទទួលយ៉ាងមាំទាំចំពោះមុខ ថា

" ចូរមើលចុះ អ្នកនេះជានរណា " ដូច្នេះ ។ ពាក្យថា **រថវិនីតបដិបទា** បានដល់បដិបទា គឺ វិសុទ្ធិ ៧ ដែលមានហើយក្នុងរថវិនីតសូត្រដែលព្រះបុណ្ណមន្តាណីបុត្តត្ថេរបានសម្តែងទុកដោយឧបមាដូចជា រថ ៧ ផ្លាស់គ្នា ដែលមានការលើកសរសើរកថាវត្ថុ ១០ ជាខាងដើម ។

ពាក្យថា **នាលកបដិបទា** បានដល់ បដិបទាដែលព្រះសាស្តាទ្រង់សម្តែងដល់ព្រះនាលកត្ថេរ ដោយពាក្យថា " **មោនេយ្យន្តេ ឧបញ្ញិស្សំ** " តថាគតនឹងសម្តែងបដិបទាដែលជារបស់មុនីដល់អ្នកដូច្នេះជាដើម ។ ពាក្យថា **តុវដ្តកបដិបទា** បានដល់ បដិបទាដែលព្រះមានព្រះភាគទ្រង់សម្តែងទុក ដោយពាក្យថា " **មូលំ បបញ្ចសង្ខាយ** " តណ្ហាជាមូលនៃការយឺតយូរ ដូច្នេះជាដើម ។ ពិតណាស់កថាដែលពោលដោយការប្រាថ្នាតិចយ៉ាងក្រៃលែង មកហើយក្នុងនាលកសូត្រ និងតុវដ្តកសូត្រនោះ តាមលំដាប់យ៉ាងនេះថា :

មុនីដល់ស្រុកហើយ មិនគប្បីត្រាច់ទៅ ដោយការប្រទូកប្រទូំក្នុងត្រកូលទាំងឡាយ គប្បីជាអ្នកកាត់ពាក្យសម្តី មិនពោលវាចាប្រកបការស្វែងរកអាហារ មិនគប្បីជាប់ជំពាក់ដោយការប្រទូកប្រទូំជាមួយគ្រហស្ថក្នុងស្រុក មិនគប្បីផ្គាប់ផ្គុនគ្រហស្ថ ព្រោះការចង់បានលាភ ។ ដូច្នេះជាដើម ។ ពាក្យថា **ដែលសំដែងដល់សេចក្តីសន្តោសក្នុងបច្ច័យ ៤ និង ភាពជាអ្នកមានភាវនាជាទីត្រេកអរ** គឺ ដែលប្រកាសដល់ភាពសន្តោសក្នុងបច្ច័យ៤ មានចីវរជាដើម និង ភាពជាអ្នកមានភាវនាជាទីត្រេកអរ ។ ឈ្មោះថា **លាភ** ព្រោះអត្ថថា បុគ្គលរមែងបាន ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា បានដល់បច្ច័យ ៤ ដូច្នេះ ។ បទថា **មហាបរិវារេ** ប្រែថា ដែលមានគ្រឿងបរិវារច្រើន មានន័យថា មនុស្សទាំងឡាយ

កាលប្រគេនបិណ្ឌបាត ដំបូងរមែងធ្វើគ្រឿងពុទ្ធបូជា មានបាត្រ ចីវរជាដើម ឲ្យជារបស់បរិវារនៃបិណ្ឌបាតនោះហើយ ទើបប្រគេន សូម្បីក្នុងការថ្វាយបច្ច័យដ៏សេសមានចីវរជាដើម ក៏ដូចគ្នា ។ បទថា **ពាហុល្លិកបិណ្ឌបាតិក** បានដល់ ជាភិក្ខុដែលត្រាច់បិណ្ឌបាតជាប្រក្រតី ដែលប្រាថ្នាច្រើនក្នុងបច្ច័យ ។ ពាក្យថា **ប្រាប់ថា** គឺប្រាប់ទៅតាមដែលបានឮ ក្នុងពេលដែលត្រាច់ទៅដើម្បីភិក្ខាក្នុងថ្ងៃមុន ។ ឈ្មោះថា **ជាអ្នកដែលខ្វល់ខ្វាយជាប្រចាំ** ក៏ព្រោះការជួយសង្គ្រោះពួកឧបាសកឧបាសិកាជាដើម ។

បទថា **តស្ស** ប្រែថា ដល់គណៈ ។ បទថា **សោ** បានដល់ គណៈបលិពោធ ។ ពាក្យថា **ដោយអាការយ៉ាងនេះ** គឺ ដោយអាការដែលនឹងពោលក្នុងពេលនេះ សូម្បីការត្រាច់ស្វែងរកគណវាចកៈ ក៏ជាវត្តដែលគប្បីត្រូវការធាប់ៗតែម្ដង ព្រោះហេតុនោះ ទើបលោកពោលថា មិនទៅឆ្ងាយជាង ១ យោជន៍ ដូច្នេះ ។ លោកពោលដល់ សមណធម៌ថា ការងាររបស់ខ្លួន ។ ពាក្យថា **ដែលធ្វើហើយនិង មិនទាន់បានធ្វើ** មានន័យថា ដល់នូវភាពខ្វាយខ្វល់ ដោយទាក់ទងជាមួយនឹងការទទួលដឹងក្នុងការងារកសាង ដែលបានធ្វើស្រេចហើយ និងមិនទាន់បានធ្វើ ។ ម្យ៉ាងទៀត បទថា **កតាកតេ** ប្រែថា ការងារកសាងទាំងតូចទាំងធំ ដែលធ្វើស្រេចហើយ ដូចគ្នានឹងពាក្យថា “ **ផលាផលេ** ” ផ្លែតូចនិងផ្លែធំដូច្នោះ ។ ភ្ជាប់សេចក្ដីថា **សាចេ ពហុំ អាវសិដ្ឋំ** ។ ឈ្មោះថា អ្នកនាំការៈ បានដល់ ភិក្ខុអ្នកនាំក្នុងកិច្ចរបស់សង្ឃ ។ ពាក្យថា **បព្វជ្ជាបេក្ខ** គឺ បានឮមកថា ការបព្វជ្ជារបស់កុមារនៃត្រកូលទាំងឡាយក្នុង សីហឡទ្វីប ក៏ដូចជាវិធីអាវាហៈ និង វិវាហៈ ( ពិធីភ្ជាប់ពាក្យ និង ពិធីរៀបការ ) ព្រោះដូច្នោះ ភិក្ខុមិនអាចនឹងកន្លងហួសថ្ងៃដែលគេកំណត់ទុកនោះបាន ។ ដោយពាក្យថា ប្រសិនបើលោកនៅមិនទាន់បានវត្តនោះ ក៏មិនអាចនឹង

នៅព្រៃឬឫកន្ត្រៃយបានជាដើម លោកពោលដល់ការកាត់បលិពោធ ដោយការធ្វើឲ្យសម្រេច ក៏ជាការដែលលោកអាចារ្យ បានសម្តែងនូវអត្ថន័យនេះ ទុកហើយថា " បើលោកមិនបានវត្តនោះ ក៏មិនអាចនឹងនៅស្ងៀម បើបានហើយសោត ក៏គួរចូលព្រៃធ្វើសមណធម៌ចុះ " ដូច្នេះ ដោយជាពាក្យដែលនៅសល់ ព្រោះហេតុនោះ គប្បីជ្រាបថា ជាការកាត់បលិពោធដោយការសង្គ្រោះ ។ សូម្បីក្នុងបលិពោធដ៏សេស ក៏មានន័យដូចគ្នា ។

បទថា **តថា** ( ក៏យ៉ាងនោះ ) គឺ អន្តេវាសិកដែលខ្លួនឲ្យឧបសម្បទហើយ គឺ ដែលខ្លួនពោលកម្មវាចា ឲ្យឧបសម្បទហើយ ក៏គួរទំនុកបម្រុងអស់មួយជីវិតដូចជាទំនុកបម្រុងព្រះឧបជ្ឈាយ៍អស់មួយជីវិតដូច្នោះ ។

ពាក្យថា **រោគឯណាមួយ** បានដល់ រោគដែលជាមូល ឬដែលប្រចាំកាយ ( នៅមិនទាន់ជា ) ដែលកើតឡើងហើយដល់ខ្លួន ។

ពាក្យថា **ដែលមានទីបំផុត ដែលនរណាៗដឹងមិនបាន** គឺ ដឹងថាមិនមានខាងដើម ក្នុងសង្សារវដ្តដែលមានទីបំផុតមិនប្រាកដ ។

ដោយបទថា **គន្ថ** នេះ ក្នុងទីនេះ លោកពោលដល់គន្ថបលិពោធ ព្រោះហេតុនោះ ទើបលោកពោលថា ការបរិហារបរិយត្តិ ដូច្នេះ ។

ពាក្យថា **ដោយកិច្ចទាំងឡាយមានការស្វាធ្យាយន៍ជាដើម** គឺ ដោយកិច្ចទាំងឡាយ មានការស្វាធ្យាយន៍ ( សូត្រ ) ការចងចាំ ការធ្វើសេចក្តីស្និទ្ធស្នាល ( ផ្ទៀងផ្ទាត់ )ការសាកសួរជាដើម ។ ពាក្យថា **សម្រាប់ភិក្ខុក្រៅពីនេះ** គឺសម្រាប់ភិក្ខុដែលមិនខ្វល់ខ្វាយ ។ គន្ថៈរបស់ភិក្ខុដែលលោកបោះបង់ចោលគន្ថធុរៈ នៅស្ងៀមរបស់អង្គណា នៅតែប្រព្រឹត្តទៅបាន ( គឺ មិនភ្លេច គន្ថៈរបស់ភិក្ខុរូបនោះ ) រមែង

មិនជាបលិពោធ ដូចគន្ថៈរបស់ព្រះថេរៈទាំងឡាយ ដែលមកក្នុងនិទស្សនៈនោះ ៗ ក៏គង់មិនជាបលិពោធសម្រាប់ភិក្ខុមិនខ្វល់ខ្វាយក្នុងគន្ថៈដោយប្រការទាំងពួង ។

ឈ្មោះថា **មជ្ឈិមបណ្ណាសកៈ** ក៏នឹងមក ក៏ព្រោះការប្រឡំ ព្រោះចំណែកនៃព្រះសូត្រ និងវារៈទាំងឡាយ មានការស្រដៀងគ្នា ។ ពាក្យថា **នឹងមិនងាកមើលទៀតឡើយ** មានអត្ថន័យថា ខ្ញុំទទួលកម្មដ្ឋានហើយ នឹងលះបង់គន្ថធុរៈចោល ។

ពាក្យថា ( ប្រៀបធៀប ) **ជាមួយព្រះថេរៈទាំងឡាយដែលជាគាមវាសី** គឺ ប្រៀបធៀប ជាមួយព្រះថេរៈទាំងឡាយ ដែលនៅក្នុងក្រុងអនុរាធបុរៈ ។ ពាក្យថា **មិនទាន់រៀនឡើយ** បានដល់ មិនទាន់បានកាន់យក គឺ មិនបានធ្វើការសន្សំទុកក្នុងអដ្ឋកថានោះ ។ ពាក្យថា **ក្នុងវង្សបញ្ចនិកាយ** គឺ ក្នុងបរិស័ទដែលសិក្សានិកាយ ៥ មានទីឃនិកាយជាដើម ។ ពាក្យថា **យើងនឹងបរិវត្ត** គឺ យើងនឹងពណ៌នា ។ ពាក្យថា **សុវណ្ណភេរី** គឺ ស្គរពិសេស ។ ពាក្យថា **មានការរៀនអំពីអាចារ្យណា** គឺ មានការរៀនអំពីអាចារ្យពួកណា អធិប្បាយថា អាចារ្យពួកណាឲ្យបរិវត្តបាន ។ ពាក្យថា **អាចរិយមគ្គ** បានដល់ កថាមគ្គ ( ពាក្យនិយាយដែលជាគន្លង ) របស់អាចារ្យទាំងឡាយ ។ ពាក្យថា **របស់អាចារ្យទាំងឡាយរបស់ខ្លួន** បានដល់ របស់អាចារ្យទាំងឡាយដែលសមគួរនឹងប្រាប់បាន របស់ខ្លួន ។ **បរិយត្តិ** គឺ ព្រះត្រៃបិដកទាំងអស់ដែលវិនិច្ឆ័យល្អហើយ មាននៅក្នុងភិក្ខុរូបនេះ ព្រោះហេតុនោះ ភិក្ខុរូបនេះទើបឈ្មោះថា **សព្វបរិយត្តិក** ( អ្នកជំនាញក្នុងបរិយត្តិទាំងពួង ) មានន័យថា ទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះថេរៈគង់លើតាំង រំកិលខ្លួនចុះអំពីតាំងនោះហើយអង្គុយលើកន្ទេលត្រង់ផែនដី ។ ពាក្យថា ( ធម្មតាផ្លូវ ) **នៃបុគ្គលអ្នកដល់ហើយ** គឺ នៃបុគ្គលអ្នកដល់ហើយដោយការទៅ គឺ បដិបត្តិ បានដល់ បុគ្គលអ្នកបានឃើញ

សច្ចះហើយ ។ ពាក្យថា **កាលដណ្តប់ចីវរហើយ** បានដល់ ឃ្លុំចីវរជាបរិមណ្ឌល ដើម្បីសំដែងសេចក្តីគោរពចំពោះអាចារ្យ ។ ឈ្មោះថា **ស្មោះត្រង់** ក៏ព្រោះមិនមានសាឋេយ្យ ( អំនួត ) ។ ឈ្មោះថា **អាជានេយ្យ** ក៏ព្រោះដឹងទូទៅដល់ហេតុ និង មិនមែនហេតុ ។ បទថា **បោថុជ្ជនិកា** ប្រែថា មានក្នុងបុថុជ្ជន ។ ឈ្មោះថា **រក្សាបានលំបាក** ព្រោះភាពដែលមានអន្តរាយច្រើន ។ ពិតយ៉ាងនោះ លោកសំដែងឫទ្ធិនោះទុកថា ដូចទារកដេកផ្ងារ និង ដូចសន្ទូងខ្ចី ។ ឈ្មោះថា ជាបលិពោធសម្រាប់វិបស្សនារបស់ព្រះយោគីដែលជាសមថយានិក មិនមែនសម្រាប់ព្រះយោគីដែលជាវិបស្សនាយានិកឡើយ ។ ពិតណាស់ ព្រះយោគីអ្នកបានឈានដោយច្រើនក៏ជាសមថយានិកនោះឯង ព្រោះងាយស្រួលចំពោះការពិចារណាឃើញច្បាស់ ។ ពាក្យថា **ភិក្ខុក្រៅពីនេះ** គឺ ភិក្ខុដែលមានសេចក្តីត្រូវការដោយសមថៈ ។ ឈ្មោះថា **បលិពោធដ៏សេស** បានដល់ បលិពោធ ៩ ( វៀរឥទ្ធិ ) ។

( ចប់មហាដីកា )

ចំណែកក្នុងសេចក្តីថា “ **ចូលទៅរកអ្នកឲ្យកម្មដ្ឋានដែលជាកល្យាណមិត្ត** ” នោះ មានវិនិច្ឆ័យដូចតទៅនេះ :

## កម្មដ្ឋាន ២ និង កម្មដ្ឋានទាយក

កម្មដ្ឋានមានពីរយ៉ាង គឺ **សព្វត្ថកម្មដ្ឋាន ១ បារិហារិយកម្មដ្ឋាន ១** ក្នុងកម្មដ្ឋានពីរយ៉ាងនោះ ( កម្មដ្ឋានគឺ ) មេត្តា ( ដែលផ្សាយទៅ ) ក្នុងពពួកជនផ្សេងៗ មានពពួកភិក្ខុជាដើមក្តី មរណស្សតិក្តី ឈ្មោះថា **សព្វត្ថកម្មដ្ឋាន** អាចារ្យមួយពួកពោលថា **អសុភសញ្ញា** ( ជាសព្វត្ថកម្មដ្ឋាន ) ក៏មាន ។ ពិតណាស់ មេត្តា(នោះ) ជាដំបូង ភិក្ខុអ្នកបំពេញកម្មដ្ឋាន គប្បីកំណត់យកពពួកភិក្ខុនោះ ហើយចម្រើនទៅក្នុងពពួកភិក្ខុដែលនៅក្នុងសីមា ( ជាមួយខ្លួន ) ដោយន័យថា សូមភិក្ខុដែលនៅក្នុងសីមាទាំងឡាយចូរជាអ្នកមានសេចក្តីសុខចុះ មិនបៀតបៀនគ្នាចុះ តអំពីនោះ ទើបចម្រើនទៅក្នុងពពួកទេវតាដែលនៅក្នុងសីមា ( តពីនោះទើបចម្រើនទៅក្នុងពពួកឥស្សរជនក្នុងគោចរគ្រាម ហើយទើបចម្រើនទៅក្នុងមនុស្ស ( អ្នកស្រុក ) ក្នុងគោចរគ្រាមនោះរហូតដល់សត្វតិរច្ឆានទាំងពួង ។ ដោយមេត្តាដែលលោកចម្រើនទៅក្នុងពួកភិក្ខុ លោករមែងធ្វើឲ្យភិក្ខុទាំងឡាយដែលនៅរួមគ្នា កើតមានចិត្តទន់ភ្លន់( ចំពោះលោកបាន ) កាលបើដូច្នោះភិក្ខុទាំងនោះក៏ជាសុខ សង្វាស ( មានការនៅរួមគ្នាជាសុខ ) សម្រាប់លោក ដោយមេត្តាចម្រើនទៅក្នុងពពួកទេវតាដែលនៅក្នុងសីមានោះ លោកនឹងជាអ្នកដែលទេវតាទាំងឡាយ អ្នកមានចិត្តដែលមេត្តានោះធ្វើឲ្យទន់ភ្លន់ហើយ ចាត់ការរក្សាយ៉ាងល្អ ជាការរក្សាប្រកបដោយធម៌ ។

ដោយមេត្តាដែលចម្រើនទៅក្នុងឥស្សរជនក្នុងគោចរគ្រាម លោកនឹងជាអ្នកដែលឥស្សរជនទាំងឡាយមានសន្តានចិត្ត ដែលមេត្តានោះ ធ្វើឲ្យទន់ភ្លន់ហើយ រក្សាជុំវិញយ៉ាងល្អដោយការរក្សាប្រកបដោយធម៌ ។ ដោយមេត្តាដែលចម្រើនទៅក្នុងមនុស្សទាំងឡាយក្នុងគោចរគ្រាមនោះ លោករមែងជាអ្នកដែលមនុស្សទាំងនោះ មានចិត្តដែលមេត្តានោះធ្វើឲ្យជ្រះថ្លាហើយ មិនបៀតបៀនសម្លុតកំហែង ត្រាច់ទៅណាបានតាមសប្បាយ ។ ដោយមេត្តា(ចំពោះសត្វ)តិរច្ឆានទាំងពួង លោកនឹងជាអ្នកមានការត្រាច់ទៅមិនទើសទាក់ក្នុងទីទាំងពួង ។ម្យ៉ាងទៀត មរណស្សតិ លោកគិតជានិច្ចថា **អវស្សំ មយា មរិតព្វំ** ( យើងត្រូវស្លាប់ដោយពិត ) ដូច្នេះ នឹងលះបង់អនេសនាចោលបាន មានសេចក្តីសង្វេគច្រើនឡើង ៗ ជាអ្នកមានការប្រព្រឹត្តមិនរួញរា ( ក្នុងសម្មាបដិបត្តិ ) ។

ម្យ៉ាងទៀត កាលលោកមានចិត្តដែលបានសន្សំ ( អប់រំ ) ហើយក្នុងអសុភសញ្ញា អារម្មណ៍ទាំងឡាយសូម្បីជាទិព្វ រមែងមិនទាក់ចិត្តរបស់លោកដោយធ្វើឲ្យលំបាកបាន ដោយប្រការដូចពោលមកដូច្នេះ ។ កម្មដ្ឋាន ៣ មានមេត្តាជាដើម ទើបលោកហៅថា **សព្វត្ថកម្មដ្ឋាន** ព្រោះជាកម្មដ្ឋានដែលគប្បីត្រូវការ គឺគប្បីប្រាថ្នាក្នុងការនានុយោគទាំងពួង ព្រោះភាពជាកម្មដ្ឋានមានឧបការៈច្រើនប្រការ ១ ហេតុជាទីតាំងនៃការងារ គឺ ការប្រកបរឿយ ៗ នូវយោគភាវនា ដែលបំណងប្រការ ១ ។ ចំណែកឯ កម្មដ្ឋានណាក្នុងកម្មដ្ឋាន ៤០ អនុកូលដល់ចរិយារបស់ភិក្ខុណា កម្មដ្ឋាននោះ លោកហៅថា **បារិហារិយកម្មដ្ឋាន** របស់ភិក្ខុនោះ ព្រោះជាកម្មដ្ឋានដែលលោកត្រូវបារិហារជានិច្ច និង ព្រោះជាបទដ្ឋាននៃការចម្រើនភាវនាជាន់លើ របស់លោកផង បុគ្គលណាបានឲ្យកម្មដ្ឋានទាំងពីរយ៉ាងដូចពោលមកនេះ

បុគ្គលនោះ ឈ្មោះថា ( កម្មដ្ឋានទាយក ) អ្នកឲ្យកម្មដ្ឋានដល់ព្រះយោគាវចរ , គប្បីចូលទៅរកលោកអ្នកឲ្យកម្មដ្ឋាននោះ ។

## កល្យាណមិត្ត

ពាក្យថា **អ្នកដែលជាកល្យាណមិត្ត** គឺ អ្នកជាមិត្តល្អ អ្នកតាំងខ្លួននៅក្នុងចំណែកចម្រើន ហើយស្វែងរកប្រយោជន៍ឲ្យ( អ្នកដទៃ )តែម្យ៉ាង ប្រកបដោយគុណ មានគុណយ៉ាងនេះគឺ :

គួរស្រឡាញ់១ គួរគោរព១ គួរសរសើរ១ ជាអ្នកប្រៀនប្រដៅ ( អ្នកដទៃមិនព្រងើយកន្តើយ ) ១ ជាអ្នកព្រមឲ្យអ្នកដទៃជាស់តឿន( មិនចចេសរឹងរូស )១ រៀបរៀងធម្មកថាដ៏ជ្រាលជ្រៅ ១ មិនបបួលអ្នកដទៃក្នុងផ្លូវដែលមិនគួរ១ ជាដើម ។ ក៏ព្រោះព្រះពុទ្ធវចនៈថា **ម្នាលអានន្ទ សត្វទាំងឡាយ មានការកើតជាធម្មតា អាស្រ័យតថាគតជាកល្យាណមិត្តហើយ រមែងផុតចាកការកើតបានដូច្នេះជាដើម** ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់មួយអង្គប៉ុណ្ណោះ ទើបជាកល្យាណមិត្ត ដែលដល់ព្រមដោយអាការទាំងពួង ព្រោះហេតុនោះ កាលព្រះអង្គគង់ព្រះជន្មនៅ កម្មដ្ឋានដែលកាន់យកក្នុងសម្នាក់របស់ព្រះអង្គនោះប៉ុណ្ណោះ ទើបជាការកាន់យកយ៉ាងល្អ តែកាលព្រះអង្គស្តេចបរិនិព្វានទៅហើយ បណ្តាព្រះមហាសាវក ៨០ អង្គ ព្រះមហាសាវកអង្គណាគង់ព្រះជន្មនៅ កាន់យក(កម្មដ្ឋាន)ក្នុងសម្នាក់ព្រះមហាសាវកអង្គនោះទើបគួរ បើសិនព្រះមហាសាវកនោះមិនមាន ព្រះយោគីប្រាថ្នាកាន់យកកម្មដ្ឋានបទណា ក៏គប្បីកាន់យកក្នុងសម្នាក់ព្រះខីណាស្រពដែលធ្វើចតុត្ថជ្ឈាន ឬបញ្ចមជ្ឈានឲ្យកើតឡើងដោយអំណាចកម្មដ្ឋានបទ( ដូចដែលខ្លួនប្រាថ្នាកាន់យក ) នោះ ហើយ

ចម្រើនវិបស្សនាដែលមានឈាននោះជាបទដ្ឋានរហូតបានសម្រេចអាសវក្ខ័យចុះ ។

សួរថា ព្រះខីណាស្រពប្រកាសខ្លួនថា អាត្មាជាព្រះខីណាស្រពឬ ?

ឆ្លើយថា នឹងត្រូវនិយាយថ្វីថា ព្រះខីណាស្រព(មួយអង្គ) ដឹងភាពដែលភិក្ខុមួយអង្គជា( ការកបុគ្គល )អ្នកធ្វើពិតហើយ ក៏ប្រកាសខ្លួនចេញមក ព្រះ-អស្សគុត្តត្ថេរ( នោះហេតុអ្វី ) ដឹងថាកម្មដ្ឋានដែលភិក្ខុនោះប្រារព្ធហើយ ភិក្ខុនេះជាអ្នកធ្វើពិត ដូច្នេះហើយ ( ហោះឡើងទៅ ) លាតកម្រាលស្បែកសត្វក្នុងអាកាសអង្គុយពត់ភ្នែន(ចម្រើនសមាធិ) នៅលើកម្រាលនោះ ឲ្យកម្មដ្ឋានមិនមែនឬ ? ។ ព្រោះដូច្នោះ បើព្រះយោគាវចរ មានព្រះខីណាស្រព(អ្នកឲ្យកម្មដ្ឋាន)សោត ការបានយ៉ាងនេះ នោះជាការល្អ បើមិនបានសោត គប្បីកាន់យកកម្មដ្ឋានក្នុងសម្នាក់ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន បុថុជ្ជនអ្នកបានឈាន អ្នកទ្រទ្រង់បិដក៣ អ្នកទ្រទ្រង់បិដក២ អ្នកទ្រទ្រង់បិដក១ ចុះជាលំដាប់មក ប្រសិនបើអ្នកទ្រទ្រង់បិដកមិនមាន ភិក្ខុណាជំនាញក្នុងព្រះសូត្រសូម្បី ១និកាយ ព្រមទាំងអដ្ឋកថានិងជាលជ្ជីភិក្ខុផង ក៏គប្បីកាន់យកក្នុងសម្នាក់ភិក្ខុនោះចុះ ព្រោះថា ភិក្ខុដែលជាពហុស្សូត និង ជាលជ្ជី ) ដូចនេះ រមែងជាអ្នកទ្រទ្រង់ទុកនូវបែបផែន តាមរក្សាវង្ស រក្សាប្រពៃណី ជាអាចារ្យដែលកាន់តាមអាចរិយមតិ(ជាសំខាន់) មិនកាន់យកអត្តនោមតិ ព្រោះហេតុនោះ ព្រះថេរៈទាំងឡាយអង្គខ្លះ ក្នុងកាលមុន ទើបបានពោលថា ( គតិព្យាករណ៍ ) ទុកជា ៣ ឃ្លាថា **លជ្ជី រក្ខិស្សតិ លជ្ជី រក្ខិស្សតិ លជ្ជី រក្ខិស្សតិ** ភិក្ខុលជ្ជីនឹងរក្សា ភិក្ខុលជ្ជីនឹងរក្សា ភិក្ខុលជ្ជីនឹងរក្សាដូច្នេះ ។ ក៏ក្នុងការឲ្យកម្មដ្ឋាននេះ ភិក្ខុ (ដែលសម្រេចមគ្គផល) មានព្រះខីណាស្រពជាដើមដែលពោលមកហើយ រមែងប្រាប់បានអំពីផ្លូវដែលខ្លួនបានសម្រេចហើយ ប៉ុណ្ណោះ

តែភិក្ខុជាពហុស្សូត ព្រោះការដែលលោកបានចូលទៅរកអាចារ្យនោះៗ ទ្រទ្រង់ឧគ្គហ និង បរិបុច្ឆា (អដ្ឋកថា) មកយ៉ាងវិសេសហើយ ( មុននឹងឲ្យកម្មដ្ឋានដល់យើង ) នឹងត្រូវកំណត់សូត្រ គឺ ( អត្ថន័យដែលពោលទុកក្នុងព្រះសូត្រដែលអនុរូបដល់កម្មដ្ឋាននោះៗ ) និង ករណៈ ( គឺ រឿងរ៉ាវទាក់ទងដោយការបំពេញកម្មដ្ឋានដែលមានមកក្នុងព្រះសូត្រ ) អំពីទីនេះខ្លះ អំពីទីនោះខ្លះ ( ក្នុង ៥ និកាយ រួបរួមមក )ប្រកបចូលឲ្យជាខដែលជាសប្បាយ ប្រើនតិច( ដល់អ្នករៀន ) ហើយសម្តែង ( កម្មដ្ឋានវិធី ) ជាផ្លូវទូលាយប្រាប់កម្មដ្ឋានឲ្យ ឧបមាដូចដំរីធំដើរទៅក្នុងព្រៃស្តុក រមែងសម្តែងផ្លូវដែលវាទៅជាប្រឡោះទូលាយដូច្នោះ ។ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីចូលទៅរកលោកអ្នកឲ្យកម្មដ្ឋាន ដែលជាកល្យាណមិត្តយ៉ាងនោះ ធ្វើវត្តបដិបត្តិចំពោះលោកហើយកាន់យកកម្មដ្ឋាន( ក្នុងសម្នាក់លោកនោះ ) ចុះ បើព្រះយោគាវចរបានលោកអ្នកឲ្យកម្មដ្ឋាននោះ នៅក្នុងវត្តជាមួយគ្នា ការបានយ៉ាងនេះ នោះជាការល្អ បើមិនបានសោត លោកនៅទីណា គប្បីទៅទីនោះ កាលនឹងទៅ មិនគប្បីពាក់ស្បែកជើង ព្រមទាំងលាង និងលាប(ប្រេង) ហើយបាំងឆ័ត្រ ប្រើមនុស្សឲ្យកាន់គ្រឿងប្រើប្រាស់ និងភេសជ្ជៈ មានបំពង់ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម មានអន្តេវាសិកហែហមទៅ តែគប្បីបំពេញគមិកវត្ត ហើយកាន់បាត្រនិងចីវររបស់ខ្លួន(ទៅ)ម្នាក់ឯង ចូលទៅកាន់វត្តណាៗ ក្នុងរវាងផ្លូវ ក៏ធ្វើវត្តបដិបត្តិគ្រប់កន្លែង ជាអ្នកមានបរិក្ខារស្រាល មានការប្រព្រឹត្តជុសខាត់យ៉ាងក្រៃលែង កាលនឹងចូលកាន់វត្ត(ដែលអាចារ្យនៅ)នោះ គប្បីពឹងពាក់នរណាម្នាក់ ឲ្យធ្វើឈើជម្រះធ្មេញឲ្យជាកប្បិយៈ ក្នុងរវាងផ្លូវនោះឯង កាន់ចូលទៅផង តែមិនគួរចូលទៅបរិវេណដទៃ ដោយគិតថា នឹងស្នាក់ធ្វើសរីរកិច្ច មានលាងជើង និង លាបជើង

ជាដើម ទើបទៅរកអាចារ្យយ៉ាងនេះឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបើភិក្ខុទាំងឡាយដែលជាវិសភាគៈរបស់អាចារ្យនោះ មាននៅក្នុងបរិវេណនោះសោត ពួកគេនឹងសាកសួរ( កាលជ្រាបហេតុ )នៃការមក( របស់លោក )ហើយ ក៏នឹងគប្បីលាតត្រដាងរឿងអាស្រូវរបស់អាចារ្យ( ឲ្យស្ដាប់ ) ហើយនិយាយថា " ចប់គ្នាហើយលោក បើលោកមករកអាចារ្យរូបនេះ មុខជា... " ធ្វើការខុសបំណងឲ្យកើត ( ដល់លោក ) រហូតជាហេតុឲ្យលោកត្រឡប់ទៅ វិនាសអំពីទីនោះក៏បាន ព្រោះហេតុនោះ សាកសួរជ្រាបទីលំនៅ របស់អាចារ្យហើយ គប្បីតម្រង់ទៅក្នុងទីនោះតែម្ដង ។ បើអាចារ្យខ្ចីវស្សាជាង កុំគប្បីត្រេកអរក្នុងសាមីចិកម្ម មានការទទួលបាត្រចីវរជាដើម (ដែលអាចារ្យនោះធ្វើចំពោះខ្លួន) បើអាចារ្យចាស់វស្សាជាង ទៅដល់ហើយគប្បីថ្វាយបង្គំអាចារ្យ ហើយឈរស្ងៀម លោកប្រាប់ឲ្យទុកបាត្រ ចីវរ សឹមទុក លោកប្រាប់ឲ្យផឹកទឹក បើត្រូវការក៏គប្បីផឹក បើលោកប្រាប់ឲ្យលាងជើង កុំអាលលាង ព្រោះបើទឹកលាងជើងនោះ ជាទឹកអាចារ្យដែលដងមកសោត ជាការមិនសមគួរ បើលោកប្រាប់ថា " លាងចុះអាវុសោ ទឹកនេះមិនមែនខ្ញុំដងមកឡើយ អ្នកដទៃដងទេ " ដូច្នេះហើយ គប្បីទៅអង្គុយក្នុងទីដែលអាចារ្យមើលមិនឃើញ និងជាទីទំនេរដែលមានវត្ថុបិទបាំង ឬថាកណ្ដាលវាលជាយៗវត្តក៏បាន ហើយលាងជើងចុះ បើអាចារ្យនាំត្រឡោកប្រេងមកឲ្យ គប្បីក្រោកឡើងទទួលដោយគោរព ដោយដៃទាំងពីរ ព្រោះបើលោកមិនទទួលត្រឡោកប្រេងនោះ អាចារ្យនឹងកើតការរអៀសចិត្តថា ភិក្ខុនេះធ្វើសម្ភោគ(ការប្រើរួមគ្នា) ឲ្យវិនាសទៅតាំងពីពេលនេះហ្ន៎ តែកាលទទួលមកហើយ ក៏មិនគួរលាបជើងជាដំបូងឡើយ ព្រោះបើប្រេងនោះ ជាប្រេងសម្រាប់លាបខ្លួនរបស់អាចារ្យនោះ ក៏ជាការមិនសមគួរ ព្រោះដូច្នោះ គប្បីលាប

ក្បាលមុន ហើយសឹមលាបអវយវៈដទៃ មានកជាដើម(តទៅ) បើលោកប្រាប់ថា " អាវុសោ ប្រេងនេះ ជាប្រេងសម្រាប់ប្រើបានគ្រប់យ៉ាង លាបជើងក៏បាន " ដូច្នេះ ទើបលាបត្រង់ក្បាលបន្តិច តអំពីនោះសឹមលាបជើង ហើយគប្បីសួរថា នឹងទុកត្រឡោកប្រេងនោះទីណា ដើម្បីលោកចង្អុលទីកន្លែងប្រាប់ តែបើអាចារ្យទទួលយកទៅ ( ទុកខ្លួនឯង ) ក៏ឲ្យលោកទៅចុះ ។ មិនគួរប្រញាប់ប្រញាល់ឲ្យលោកប្រាប់កម្មដ្ឋានតាំងពីថ្ងៃដែលទើបតែមកដល់នោះឡើយ តែចាប់ពីថ្ងៃទីពីរទៅ បើភិក្ខុជាឧបដ្ឋាកផ្ទាល់របស់អាចារ្យមាននៅ គប្បីសុំលោក ដើម្បីធ្វើវត្ត ( អាចារ្យខ្លះ ) បើសូម្បីសុំហើយ លោកមិនព្រមឲ្យ គប្បីឃ្លាំចាំមើល កាលបានឱកាសហើយ កាលនឹងធ្វើគប្បីបង្អោនប្រគេនឈើជម្រះធ្មេញទាំង ៣ ខ្នាត គឺ ខ្នាតតូច ខ្នាតកណ្ដាល និង ខ្នាតធំ ទឹកលុបមុខ និង ទឹកងូត គប្បីចាត់ចែងប្រគេនទាំងពីរយ៉ាង គឺ ត្រជាក់ និង ក្ដៅ អាចារ្យប្រើឈើជម្រះធ្មេញ និងទឹកយ៉ាងណារហូត៣ថ្ងៃ តអំពីនោះទៅ គប្បីចូលទៅតាំងឈើជម្រះធ្មេញ និង ទឹកយ៉ាងនោះប្រគេនជានិច្ចទៅ បើលោកមិនទៀងទាត់ ប្រើអ្វីក៏បាន គប្បីប្រគេនរបស់តាមដែលបានមកចុះ នឹងចាំបាច់ពោលច្រើ ។ សម្មាវត្ត (វត្តដ៏ប្រពៃ) ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់បញ្ញត្តទុកហើយក្នុងមហាខន្ធកៈ ថា **ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកគប្បីធ្វើវត្តដ៏ប្រពៃក្នុងអាចារ្យ** នេះជាការធ្វើវត្តប្រពៃក្នុងប្រការនោះ គឺ អន្តេវាសិកគប្បីក្រោកឡើងពីព្រលឹម ដោះស្បែកជើង ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយចូលទៅប្រគេនឈើជម្រះធ្មេញ ប្រគេនទឹកលុបមុខ ក្រាលអាសនៈ បើយាគូមាននៅគប្បីលាងភាជនៈ បង្អោនយាគូចូលទៅប្រគេនដូច្នេះជាដើម នោះយ៉ាងណា គប្បីធ្វើសម្មាវត្តនោះ គ្រប់ប្រការចុះ ។ សិស្សដែលញ៉ាំងគ្រូឲ្យពេញចិត្ត នៅដោយវត្ត

សម្បត្តិយ៉ាងនេះ ក្នុងវេលាល្ងាចលោកឲ្យឱកាស(ត្រឡប់)ទៅ សឹមក្រាបលាទៅៗ កាលណាលោកសួរថា លោកមកដើម្បីអ្វី សឹមប្រាប់ហេតុនៃការមកនោះ បើលោកមិនសួរទេ តែលោកពេញចិត្ត ( ក្នុងការធ្វើ )វត្តនោះសោត កាលកន្លងទៅ ១០ថ្ងៃ ឬមួយបក្ខហើយ (បានឱកាស)ក្នុងថ្ងៃមួយ សូម្បីលោកអនុញ្ញាតឲ្យទៅវិញ ( ក្នុងពេលល្ងាច ) ហើយក៏កុំទៅ ឲ្យលោកឲ្យឱកាស ហើយប្រាប់ហេតុនៃការមក ។ ឬក៏យើងក្លែងជាទៅរកលោកខុសវេលា ដើម្បីឲ្យលោកសួរថា មកធ្វើអ្វី សឹមពិតហេតុនៃការមកឲ្យលោកជ្រាប បើលោកប្រាប់ឲ្យមកពេលព្រឹក ក៏គប្បីទៅពីព្រឹក តែបើក្នុងពេលនោះ ពោះរបស់យើងក្តៅ ព្រោះទឹកប្រមាត់បៀតបៀនក្តី អាហារមិនរលាយក្តី ភ្លើងធាតុខ្សោយក្តី រោគដទៃៗបៀតបៀនក្តី គប្បីបើកបង្ហាញអាពាធនោះឲ្យអាចារ្យជ្រាបតាមដែលវាឈឺ ប្រាប់វេលាដែល( កាយចិត្ត ) សប្បាយសម្រាប់ខ្លួន ហើយទៅរកលោកក្នុងវេលានោះ ព្រោះថាក្នុងវេលាដែលមិនសប្បាយ សូម្បីលោកប្រាប់កម្មដ្ឋានឲ្យ យើងក៏មិនអាចមនសិការបាន នេះជាសេចក្តីពិស្តារក្នុងប្រការថា “ **ចូលទៅរកលោកអ្នកឲ្យកម្មដ្ឋានដែលជាកល្យាណមិត្ត** ” នោះ ។

## មហាដីកា

## ពណ៌នាកម្មដ្ឋានទាយក

ភិក្ខុអ្នកប្រកបក្នុងកម្មដ្ឋាន ឈ្មោះថា **កម្មដ្ឋានិក** គឺ អ្នកបំពេញភាវនាបានដល់ ភិក្ខុអ្នកប្រកបក្នុងកម្មដ្ឋាននោះ ។ ពាក្យថា **កំណត់** គឺ កំណត់យ៉ាងនេះថា “ សូម្បីភិក្ខុទាំងឡាយទាំងពួងក្នុងវិហារនេះ ” ដូច្នេះ ។ ឈ្មោះថា **សហវាសីនំ** (អ្នកនៅរួមគ្នា) បានដល់ ភិក្ខុទាំងឡាយ ។ ពាក្យថា **ភាពជាអ្នក**

មានចិត្តទន់ភ្លន់ គឺ ញ៉ាំងភាពជាអ្នកមានចិត្តទន់ភ្លន់ឲ្យកើតឡើងក្នុងខ្លួន ក៏អត្ថន័យពាក្យថា **ញ៉ាំងភាពជាអ្នកមានចិត្តទន់ភ្លន់ឲ្យកើតឡើងដល់ភិក្ខុទាំងឡាយដែលនៅរួមគ្នាជាដើមនេះ** បណ្ឌិតគប្បីសម្តែងដោយមេត្តានិសង្សសូត្រ ដែលប្រព្រឹត្តទៅដោយន័យថា " **មនុស្សានំ បិយោ ហោតិ** " រមែងជាទីស្រឡាញ់របស់ពួកមនុស្សទាំងឡាយដូច្នេះជាដើមចុះ ។ ភិក្ខុឈ្មោះថា ជាអ្នកមានការប្រព្រឹត្តមិនធូរ-ថយ គឺ ជាអ្នកមានការប្រព្រឹត្តមិនធូរថយក្នុងសម្មាបដិបត្តិ ។ ឈ្មោះថា **អារម្មណ៍ទាំងឡាយសូម្បីជាទិព្វ**( ក៏គ្របសង្កត់ចិត្តមិនបាន ) មានន័យថា ចាំបាច់និយាយថ្វីដល់អារម្មណ៍ក្រៅពីនេះនោះ ។ ឈ្មោះថា **សព្វត្ថ** គឺ ក្នុងកិច្ចដែលសមណៈគប្បីធ្វើទាំងពួង ឬថា ក្នុងការបំពេញកម្មដ្ឋានទាំងពួង ។ ឈ្មោះថា **គប្បីត្រូវការ** ក៏ដោយអំណាចការសេពរក ក្នុង ខាងដើម ។ ការប្រកបរឿយៗ នូវ **យោគៈ** គឺ ភាវនា ឈ្មោះថា **អនុយោគៈ** ការប្រកបរឿយៗនោះៗឯង ជាការងារ ព្រោះអត្ថថាគួរធ្វើ ឈ្មោះថា **ជាទីតាំង** គឺ ជាហេតុឲ្យកើតឡើងនៃការងារ គឺ ការប្រកបរឿយៗនូវយោគៈនោះ ។ ពាក្យថា **ព្រោះគប្បីបរិហារជាប្រចាំ** គឺ ព្រោះគប្បីប្រកបរឿយ ៗ ទុកមួយរយៈ ដូចជា សព្វត្ថកម្មដ្ឋាននោះឯង ហើយក៏គប្បីបរិហារ គឺ គប្បីប្រកបរឿយៗ ទៅអស់កាលទាំងពួង ។

បទថា **ឯវមាទិគុណសមន្នាគតំ** មានន័យថា ដល់ព្រមដោយគុណទាំងឡាយ មានភាពជាបុគ្គលគួរស្រឡាញ់ជាដើម ។ ពិតណាស់ បុគ្គលជាកល្យាណមិត្ត រមែងជាអ្នកដល់ព្រមដោយសទ្ធា ដល់ព្រមដោយសីល ដល់ព្រមដោយសុត្តៈ ដល់ព្រមដោយចាគៈ ដល់ព្រមដោយវីរិយៈ ដល់ព្រមដោយសតិ ដល់ព្រមដោយសមាធិ ដល់ព្រមដោយបញ្ញា ។ ក្នុងបណ្តាគុណទាំងនោះ **ដោយ**

**សទ្ធាសម្បត្តិ** លោកទើបជឿការត្រាស់ដឹងរបស់ព្រះតថាគត ជឿកម្ម និង ជឿផលកម្ម ព្រោះហេតុនោះ ទើបមិនលះបង់ភាពជាអ្នកស្វែងរកប្រយោជន៍ ដល់សត្វទាំងឡាយ ដែលជាហេតុនៃការត្រាស់ដឹងឯងដោយប្រពៃ ។ **ព្រោះសីលសម្បត្តិ** ទើបលោកជាមនុស្សគួរស្រឡាញ់សម្រាប់សត្វទាំងឡាយ ជាមនុស្សគួរគោរព និងគួរសរសើរ ជាអ្នកចោទ គឺ តិះដៀលបាប ជាអ្នកប្រៀនប្រដៅ អត់ធន់ចំពោះការប្រៀនប្រដៅ ។ **ដោយសុតសម្បត្តិ** ទើបលោកជាអ្នករៀបរៀងកថាដែលជ្រាលជ្រៅទាក់ទងនឹងសច្ចៈ បដិច្ចសមុប្បាទ ជាដើមបាន ។ **ដោយចាគសម្បត្តិ** ទើបលោកជាមនុស្ស ប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ មិនច្រឡូកច្រឡំ ។ **ដោយវីរិយសម្បត្តិ** ទើបលោក ជាអ្នកប្រារព្ធសេចក្ដីព្យាយាមក្នុងការបដិបត្តិ ដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍ អ្នកដទៃ ។ **ដោយសតិសម្បត្តិ** ទើបលោកជាអ្នកមានសតិតាំងមាំ ដោយសមាធិ-សម្បត្តិ ទើបលោកជាអ្នកមិនរាយមាយមានចិត្តតាំងមាំ ។ **ដោយបញ្ញាសម្បត្តិ** ទើបលោកដឹងច្បាស់បាន មិនភាន់ច្រឡំ ។

លោកជាកល្យាណមិត្តនោះ កាលប្រើសតិស្វែងរកដោយប្រពៃនិងគតិនៃធម៌ដែលជាកុសល និង អកុសលទាំងឡាយ ក៏ដឹងតាមសេចក្ដីពិតនូវវត្ថុដែលជាប្រយោជន៍ និង មិនជាប្រយោជន៍ដល់សត្វទាំងឡាយដោយបញ្ញា ជាអ្នកមានចិត្តដែលមានអារម្មណ៍តែមួយ ក្នុងវត្ថុដែលដឹងហើយនោះដោយសមាធិ ហាមឃាត់សត្វទាំងឡាយទុកអំពីវត្ថុដែលមិនជាប្រយោជន៍ ឲ្យប្រកបក្នុងវត្ថុដែលជាប្រយោជន៍ដោយវីរិយៈ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ ដល់ព្រមដោយគុណយ៉ាងនេះ គឺ គួរស្រឡាញ់ ១ ។ ល ។ មិនញ៉ាំងសត្វទាំងឡាយឲ្យប្រកបក្នុងឋានៈដែលមិនគួរ ១ ដូច្នេះជាដើម ” ។

លោកអាចារ្យ បំណងសម្ដែងនូវកល្យាណមិត្ត ដែលដល់នូវភាពឧត្តុង្គឧត្តម ក្រៃលែងនោះ ទើបពោលថា “ **មមញ្ហិ** ” ដូច្នេះជាដើម ។ ព្រះវីណាស្រពជ្រាប នូវភាពជាអ្នកធ្វើយោគកម្មពិត រមែងប្រកាសខ្លួនដើម្បីជំរុញភិក្ខុ និង ដើម្បីឲ្យអាចហ៊ាន ដោយការសម្ដែងភាវៈចំពោះការបដិបត្តិមិនជាមោឃៈ អធិប្បាយថា ដើម្បីជាការរក្សាបែបផែនទុក ក៏រមែងប្រាប់បាន មិនមែនឬ ។ ពាក្យថា **បុគ្គលដូចនេះ** បានដល់ លោកដែលជាអ្នកជំនាញ ជាពហុស្សូត មានសីលជាទីស្រឡាញ់ ។

ពាក្យថា **អ្នកទ្រទ្រង់ទុកនូវបែបផែន** គឺ អ្នកទ្រទ្រង់ព្រះសូត្រ ។

ក្នុងព្រះសូត្រនោះ សូម្បីនរណា ៗ ក៏ធ្វើឲ្យឃ្លៀងឃ្លាតមិនបាន ។ ពាក្យថា **ជាអ្នកតាមរក្សាវង្ស** គឺ ជាអ្នកតាមរក្សាវង្សរបស់ព្រះពុទ្ធជាម្ចាស់ និង ព្រះអនុ-ពុទ្ធជាម្ចាស់ ។ ពាក្យថា **រក្សាប្រវេណី** គឺ ជាអ្នករក្សាប្រពៃណី គឺ ការរៀនតអំពីអាចារ្យ ។ ពាក្យថា **ជាអ្នកកាន់មតិរបស់អាចារ្យ** គឺ ជាអ្នកប្រកបក្នុងមតិរបស់អាចារ្យ ដោយការមិនរំលងមតិរបស់អាចារ្យនោះ ។ ឈ្មោះថា **មិនកាន់យកមតិរបស់ខ្លួន** ព្រោះអត្ថថា មិនប្រកាស គឺ មិនពោលមតិរបស់ខ្លួន មានន័យថា មិនលើកមតិរបស់ខ្លួនពោលឡើង ។

លោកអាចារ្យផ្ដើមពាក្យថា “ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះវីណា-ស្រពជាដើម ដែលពោលក្នុងខាងដើម ” ដូច្នេះជាដើម ដើម្បីសម្ដែងថា ភិក្ខុជាពហុស្សូតគង់ល្អជាងព្រះវីណាស្រពអង្គខ្លះក្នុងការឲ្យកម្មដ្ឋាន ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រះអរិយបុគ្គលទាំងឡាយ មានព្រះវីណាស្រពជាដើមដែលពោលខាងដើម** បានដល់ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះវីណាស្រពជាដើម ដែលពោលទុក ដោយពាក្យថា “ សូម្បីកាលព្រះមហាសាវកនោះមិនមាន ភិក្ខុជាអ្នក

ពេញចិត្តកាន់យកកម្មដ្ឋានមួយណា ” ដូច្នេះជាដើម ។ ពាក្យថា **ព្រោះភាពដែលលោកជម្រះឧគ្គហៈនិងបរិបុច្ឆាឲ្យបរិសុទ្ធហើយ** មានន័យថា ព្រោះភាពដែលលោកជម្រះព្រះបាលីដែលជាឧបការៈដល់កម្មដ្ឋាន ដែលបានឈ្មោះថា “ **ឧគ្គហ** ” ព្រោះត្រូវរៀន និង ពណ៌នានូវអត្ថដែលសន្មតថា “ **បរិបុច្ឆា** ” ព្រោះជាហេតុសាកសួរនូវអត្ថនៃព្រះបាលីនោះ ឲ្យបរិសុទ្ធបានយ៉ាងវិសេស បានដល់ ធ្វើឲ្យជាក់ច្បាស់ មិនឲ្យស្មុគស្មាញ ហើយទើបកាន់យក ។ ពាក្យថា **កំណត់សូត្រ និង ហេតុអំពីសូត្រនោះ សូត្រនេះ** គឺ ចូលទៅកំណត់យ៉ាងល្អនូវបទនៃព្រះសូត្រ ដែលស័ក្តិសមចំពោះកម្មដ្ឋាននោះៗ អំពីសូត្រនោះ សូត្រនេះ ក្នុងបណ្តានិកាយ ទាំង ៥ និង **យុត្តិ** ( ពាក្យអធិប្បាយដែលត្រឹមត្រូវតាមហេតុផល ) ដែលស្របតាមព្រះសូត្រ ។ ពាក្យថា **ប្រកបឲ្យជាសប្បាយតូចធំ** គឺ ប្រកប ឬ កាន់យក ឲ្យជាគ្រឿងឧបការៈតូចធំ ដោយការស្វែងរកពាក្យអធិប្បាយ ដែលត្រឹមត្រូវដល់ភិក្ខុដែលខ្លួននឹងប្រាប់កម្មដ្ឋាន មានន័យថា តាំងទុកក្នុងចិត្តដោយប្រពៃនោះឯង ។

ពាក្យថា **សំដែងទុកជាផ្លូវធំទូលាយ** គឺ សំដែងវិធីធ្វើកម្មដ្ឋាន ឲ្យជាផ្លូវធំទូលាយ ។

ពាក្យថា **ក្នុងគ្រប់វិហារ** គឺ ក្នុងវិហារនោះៗ ។ ពាក្យថា **ធ្វើវត្តបដិបត្តិ** គឺ ធ្វើវត្តបដិបត្តិនោះៗ ឲ្យបរិបូរណ៍តាមសមគួរ គឺ អាគន្តុកវត្តក្នុងវេលាដែលចូលទៅ គមិកវត្តក្នុងវេលាដែលចេញមក ។ ពាក្យថា **ប្រេងប្រើបានគ្រប់យ៉ាង** គឺ ប្រេងដែលគប្បីប្រើដើម្បីប្រយោជន៍ ដល់អវយវៈបានគ្រប់ចំណែក ឬ ដល់ភិក្ខុបានគ្រប់រូប ។ ពាក្យថា **ខ្ញុំករុណាសូមដាក់** ( ត្រឡោកប្រេងនេះ ) ជាពាក្យសុំឲ្យលោកអនុញ្ញាត ។ ភ្ជាប់សេចក្តីថា **យន្តំ សម្មាវត្តំ បញ្ញត្តំ** សម្មាវត្តដែល

ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តទុកនោះ ឯណា ។ ប្រកបសេចក្ដីថា ឲ្យសម្បូរណ៍ថ្ងៃមួយក្នុងវេលាល្ងាច លោក សូម្បីអាចារ្យឲ្យទៅហើយ ក៏កុំទៅ ដូច្នេះ ។ ឈ្មោះថា **រឿងដែលគួរប្រាប់** គឺ ហេតុនៃការមក ។ សម័យដែលរាងកាយ និង ចិត្តថ្មើមសម្បូណ៌ ឈ្មោះថា វេលាដែលជាសប្បាយ ។

( ចប់មហាដីកា )

# ចរិយា និង ចរិត៦

ឥឡូវនេះគប្បីជ្រាបសេចក្តីពិស្តារក្នុងមាតិកាថា “ **កម្មដ្ឋានដែលអនុកូលដល់ចរិតរបស់ខ្លួន** ” នោះតទៅ :

ពាក្យថា **ចរិយា** បានដល់ ចរិយា ៦ គឺ រាគចរិយា ទោសចរិយា មោហ-ចរិយា សទ្ធាចរិយា ពុទ្ធិចរិយា វិតក្កចរិយា តែអាចារ្យពួកខ្លះ បំណងយកចរិយា ១៤ ដោយបន្ថែម ចរិយា ៨ នេះទៀតគឺ ដោយសង្សគ្គៈ ( ការប្រឡប់គ្នា ) និង សន្និបាត(ការរួមគ្នា)នៃវត្ថុ ៣ ខាងដើម មានរាគៈជាដើម បានចរិយា ៤ ពួក ១ , នៃវត្ថុ ៣ ខាងចុង មានសទ្ធាជាដើមក៏បានចរិយា ៤ ទៀត ពួក ១ ដូចគ្នា តែកាល នឹងពោលប្រភេទចេញទៅ យ៉ាងនេះ ចរិយា ក៏រមែងមានបានច្រើនយ៉ាង ព្រោះ លាយច្រាស់គ្នាដោយវត្ថុ ៣ ខាងដើម មានរាគៈជាដើម ចូលជាមួយវត្ថុ ៣ ខាងចុង មានសទ្ធាជាដើមទៀតក៏បាន ព្រោះដូច្នោះ គប្បីជ្រាបថា ដោយសង្ខេប ចរិយាមាន ត្រឹមតែ ៦ ប៉ុណ្ណោះ ។

ពាក្យថា **ចរិយា បកតិ ឧស្សន្នតា** ( គឺ ក្រាស់ ) ៣ នេះ ដោយសេចក្តី ក៏ដូចគ្នាតែម្យ៉ាង ។

ទាក់ទងដោយចរិយា ៦ នោះ បុគ្គលក៏មាន ៦ ដូចគ្នា គឺ បុគ្គលរាគចរិត បុគ្គលទោសចរិត បុគ្គលមោហចរិត បុគ្គលសទ្ធាចរិត បុគ្គលពុទ្ធិចរិត បុគ្គល វិតក្កចរិត ព្រោះហេតុដែលបុគ្គល៦ពួកនោះ **បុគ្គលរាគចរិត** ក្នុងពេលធ្វើកុសល រមែងមានសទ្ធាខ្លាំងក្លា ព្រោះសទ្ធាជាគុណដែលជិតចំពោះរាគៈ ពិតណាស់ ក្នុង ចំណែកអកុសល **រាគៈ**ជាទោសដែលស្រស់ថ្លា មិនអាប់អួរយ៉ាងណា ចំណែក កុសល **សទ្ធា**ក៏ជាគុណដែលថ្លូរថង់ មិនអាប់អួរដូច្នោះដែរ ។

**រាគៈ**រមែងស្វែងរកវត្ថុកាមយ៉ាងណា **សទ្ធា**ក៏ស្វែងរកសីលាទិគុណដូច្នោះដែរ

**រាគៈ** មិនលះបង់វត្ថុដែលមិនជាប្រយោជន៍យ៉ាងណា **សទ្ធា** ក៏មិនលះបង់វត្ថុដែលជាប្រយោជន៍ក៏យ៉ាងនោះ ព្រោះហេតុនោះ **បុគ្គលដែលជាសទ្ធាចរិត** ទើបជាសភាគៈនៃមនុស្សដែលជារាគចរិត ។ **ចំណែកបុគ្គលទោសចរិត** ក្នុងពេលប្រព្រឹត្តកុសល រមែងមានបញ្ញាខ្លាំងក្លា ព្រោះបញ្ញាជាគុណជិតចំពោះទោសៈ ពិតណាស់ក្នុងចំណែកអកុសល **ទោសៈ** ជាទោសដែលមិនជាប់ជំពាក់ក្នុងអារម្មណ៍យ៉ាងណាចំណែកកុសល **បញ្ញា** ក៏ជាគុណដែលមិនជាប់ជំពាក់ក្នុងអារម្មណ៍ ក៏ដូច្នោះដែរ ម្យ៉ាងទៀត **ទោសៈ** រមិលមើលរកទោស សូម្បីដែលមិនពិតយ៉ាងណា **បញ្ញា** ក៏រមិលមើលរកទោសដែលពិតក៏យ៉ាងនោះដែរ **ទោសៈ**ដែលប្រព្រឹត្តទៅដោយការមិនយកចិត្តទុកដាក់ចំពោះសត្វយ៉ាងណា **បញ្ញា**ក៏ប្រព្រឹត្តទៅដោយការមិនអើពើ ចំពោះសង្ខារក៏យ៉ាងនោះដែរ ព្រោះហេតុនោះ **បុគ្គលដែលជាពុទ្ធិចរិត** ទើបជាសភាគៈនៃបុគ្គលទោសចរិត ។ **ចំណែកបុគ្គលមោហចរិត** កាលព្យាយាមធ្វើកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង វិតក្កទាំងឡាយដែលជាអន្តរាយ( ចំពោះការធ្វើកុសល ) រមែងកើតឡើង ព្រោះវិតក្កមានលក្ខណៈជិតចំពោះមោហៈ ពិតណាស់ **មោហៈ**មិនផ្ដោចចុះទៅបាន ព្រោះមានសភាពរាយមាយ ( មិនចុះស៊ប់ទៅបាន ) យ៉ាងណា **វិតក្ក** មិនឈប់នៅបាន ព្រោះមានសភាពត្រាច់ទៅ មានប្រការផ្សេងៗ មិនចេះចប់ដូច្នោះដែរ ម្យ៉ាងទៀត **មោហៈ** ជាទោសដែលស្ទាក់ស្ទើរ ព្រោះភាពដែលមិនតាំងចិត្តមាំយ៉ាងណា **វិតក្ក** ក៏ជាធម៌ដែលញាប់ញ័រវិលវល់ព្រោះគំនិត(ផ្លាស់ប្ដូររឿងរ៉ាវរហ័ស) ក៏យ៉ាងនោះ ព្រោះដូច្នោះ **វិតក្កចរិត** ទើបជាសភាគៈជាមួយនឹងមោហចរិតដូច្នេះ ។

អាចារ្យពួក ១ ពោលថា ចរិយា ៣ យ៉ាងដទៃទៀត ក៏មាន ដោយទាក់ទង

ជាមួយ តណ្ហា មានះ ទិដ្ឋិ ក្នុង ៣ យ៉ាងនោះ តណ្ហា ក៏គឺ រាគចរិតនោះឯង ឯ មានះវិញ ក៏សម្បយុត្តជាមួយរាគៈនោះដែរ ព្រោះដូច្នោះ តណ្ហា មានះ ទាំងពីរនោះ ក៏មិនក្រៅអំពីរាគចរិយានោះឡើយ ចំណែកទិដ្ឋិចរិយា ក៏ទៅតាមមោហចរិយា នោះឯង ព្រោះ ទិដ្ឋិ មានមោហៈជាដើមហេតុ ។

សួរថា ចរិយាទាំងនេះនោះ មានអ្វីជាដើមហេតុ ហើយតើគប្បីជ្រាបបាន យ៉ាងណាថា បុគ្គលនេះជារាគចរិត បុគ្គលនេះជាចរិតយ៉ាងណាមួយ ក្នុងចរិត ដ៏សេស មានទោសចរិតជាដើម ហើយអ្វីជាសប្បាយរបស់បុគ្គលចរិតអ្វី ? ។

## ដើមហេតុនៃចរិយា

ក្នុងចរិយា៦នោះ នឹងអធិប្បាយចរិយា៣ខាងដើមសិន អាចារ្យពួកខ្លះពោល ថា ចរិយា៣ខាងដើមនោះ មានអាចិណ្ណកម្មក្នុងភពមុនជាដើមហេតុ ប្រការ១ មាន ធាតុ និង ទោសក្នុងរាងកាយជាដើមហេតុ ប្រការ ១ ។

សេចក្តីថា បុគ្គលដែលច្រើនទៅដោយប្រយោគ ( គឺ ការសម្តែងកិរិយា វាចា ) គួរពេញចិត្ត និងកម្មដែលល្អ មានក្នុងកាលមុនក្តី បុគ្គលដែលចុតិពីសួគ៌ មកកើតក្នុងមនុស្សលោកនេះក្តី រមែងជាបុគ្គលរាគចរិត ។ បុគ្គលច្រើនទៅដោយ កម្មដែលជាពៀរ គឺ កាប់គេ វាយគេ សម្លាប់គេ ចាប់ចងគេ ក្នុងកាលមុនក្តី បុគ្គលដែលចុតិអំពីនរក ឬកំណើតពស់ មកកើតជាមនុស្ស ក្នុងមនុស្សលោកនេះ ក្តី រមែងជាមនុស្សទោសចរិត ។ បុគ្គលដែលច្រើនទៅដោយការផឹកទឹកស្រវឹង និង ព្រងើយកន្តើយក្នុងការស្តាប់ ការសាកសួរក្នុងកាលមុនក្តី បុគ្គលដែលចុតិអំពី កំណើតតិរច្ឆានមកកើតជាមនុស្ស ក្នុងមនុស្សលោកនេះក្តី រមែងជាមនុស្សមោហ-

ចរិត ដោយន័យដូច្នេះឯង ទើបលោកពោលថា ចរិយា៣ មានអាចិណ្ណកម្មក្នុងភពមុនជាដើមហេតុ ម្យ៉ាងទៀត បុគ្គលដែលជាមោហចរិតព្រោះធាតុ២យ៉ាង គឺ បឋវីធាតុ និងអាបោធាតុក្រាស់ ជាទោសចរិតព្រោះធាតុ២យ៉ាង ក្រៅពីនេះក្រាស់ ជារាគចរិតព្រោះធាតុទាំងពួងស្មើគ្នា ដោយន័យដូច្នេះ ១ ។ ក្នុងទោសទាំងឡាយវិញ បុគ្គលដែលច្រើនដោយស្លេស្ម រមែងជារាគចរិត បុគ្គលដែលច្រើនដោយខ្យល់ រមែងជាមោហចរិត ឬថាបុគ្គលដែលច្រើនដោយស្លេស្មជាមោហចរិត បុគ្គលដែលច្រើនដោយខ្យល់ជារាគចរិត ដោយន័យដូច្នេះ១ ទើបលោកពោលថា ចរិយា៣ ខាងដើមមានធាតុ និង ទោសក្នុងរាងកាយជាដើមហេតុ ។

( តែ ) ព្រោះក្នុងបុគ្គលទាំងនោះ សូម្បីមនុស្សទាំងឡាយដែលច្រើនទៅដោយប្រយោគដែលគួរពេញចិត្ត និងកម្មដែលប្រណីតក្នុងកាលមុន និង សូម្បីអ្នកទាំងឡាយដែលចុតិអំពីសួគ៌មកកើតក្នុងមនុស្សលោកនេះក្តី ជារាគចរិតទាំងអស់ក៏ទេ ឬថាមនុស្សទាំងឡាយក្រៅពីនេះ គឺ មនុស្សច្រើនទៅដោយកម្មដែលជាពៀរវេរា មានកាប់ចាក់ជាដើម និង អ្នកចុតិអំពីនរកជាដើម មកកើតក្នុងមនុស្សលោកនេះ ក៏មិនមែនសុទ្ធតែជាទោសចរិត និងមោហចរិតគ្រប់គ្នានោះទេ ម្យ៉ាងទៀត ការកំណត់ចរិយាដោយភាពក្រាស់នៃធាតុទាំងឡាយ ដោយន័យ តាមដែលពោលនោះក៏មានមិនបាន ហើយការកំណត់ចរិយាដោយទោសក្នុងរាងកាយ លោកក៏ពោលទុកតែ២ គឺ រាគចរិត និង មោហចរិត ប៉ុណ្ណោះ សូម្បីពាក្យដែលពោលនោះសោតពាក្យមុន និង ពាក្យក្រោយក៏ខុសគ្នាដែរ ចំណែកចរិយា ៣ ខាងចុង លោកមិនពោលដើមហេតុទុកសូម្បីតែមួយឡើយ ព្រោះដូច្នោះ ពាក្យទាំងអស់នោះ ទើបជាពាក្យមិនបានកំណត់ទុក ( ឲ្យដាច់ខាត ) ។

ចំណែកសេចក្ដីតទៅនេះ ជាបទវិនិច្ឆ័យទៅតាមគន្លងមតិរបស់អដ្ឋកថាចារ្យទាំងឡាយ ក្នុងបញ្ហាថា ចរិយាទាំងឡាយមានអ្វីជាដើមហេតុនោះ ពិតណាស់ ក្នុង **ឧស្សទកិត្តន** ( ដែលពោលដោយភាពក្រាស់ក្នុងវិបាកកថា ) លោកពោល ពាក្យនេះទុកថា សត្វទាំងឡាយពួកនេះ ដោយនិយាមនៃហេតុក្នុងកាលមុន រមែងជាអ្នកក្រាស់ដោយលោភៈក៏មាន ក្រាស់ដោយទោសៈក៏មាន ក្រាស់ដោយមោហៈក៏មាន ច្រើនដោយអលោភៈក៏មាន ច្រើនដោយអទោសៈក៏មាន ច្រើនដោយអមោហៈក៏មាន ពិតណាស់ ក្នុងខណៈព្យាយាមធ្វើកម្ម បុគ្គលណាមានលោភៈខ្លាំង អលោភៈទន់ខ្សោយ តែអទោសៈអមោហៈខ្លាំងក្លា ទោសៈមោហៈស្រាលស្ដើង អលោភៈដែលទន់ខ្សោយរបស់បុគ្គលនោះ រមែងមិនអាចគ្របសង្កត់លោភៈបាន តែបើអទោសៈអមោហៈខ្លាំងក្លា រមែងអាចគ្របសង្កត់ទោសៈមោហៈបាន ព្រោះហេតុនោះ បុគ្គលនោះ កាលកើតមកដោយអំណាចបដិសន្ធិដែលកម្មនោះផ្ដល់ឲ្យ រមែងជាបុគ្គលលោភលន់ តែជាមនុស្សចិត្តត្រជាក់ មិនច្រើនដោយសេចក្ដីក្រោធ ឆ្លៀវ-ឆ្លាតមុតស្រួចដូចពេជ្រ ។ ចំណែកបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈនិងទោសៈខ្លាំងក្លា អលោភៈអទោសៈទន់ខ្សោយ តែអមោហៈខ្លាំងក្លា មោហៈស្រាលស្ដើង បុគ្គលនោះ ដោយន័យមុននោះឯង គឺ ( កើតមកដោយអំណាចបដិសន្ធិដែលកម្មនោះបញ្ជូនមក ) រមែងជាមនុស្សលោភលន់ផង ឆេវឆាវផង តែជាមនុស្សឆ្លៀវឆ្លាតមុតស្រួច ប្រៀបដូចគ្រាប់ពេជ្រ ដូចព្រះទត្តាភយត្ថេរដូច្នោះ ។ បុគ្គលណាក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ និង មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ បុគ្គលនោះ ដោយន័យមុនដូចគ្នា រមែងជាមនុស្សលោភលន់ផង រមែងជាមនុស្សល្ងង់ផង តែជាមនុស្សចិត្តត្រជាក់ មិនច្រើនដោយសេចក្ដី

ក្រោធ ដោយន័យនោះ បុគ្គលណាក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ ទោសៈ មោហៈខ្លាំងក្លាទាំង ៣ ចំណែកកុសល មានអលោភៈជាដើមទន់ខ្សោយ បុគ្គលនោះដោយន័យមុននោះ រមែងជាមនុស្សលោភលន់ផង ឆេវឆាវផង ល្ងង់ខ្លៅផង។ ចំណែកបុគ្គលណាក្នុងខណៈព្យាយាមធ្វើកម្ម មាន អលោភៈ ទោសៈ និង មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ បុគ្គលនោះ ដោយន័យមុនដូចគ្នា រមែងជាអ្នកមិនលោភលន់ និងមានកិលេសតិច ឃើញអារម្មណ៍ សូម្បីជាទិព្វ ក៏នៅព្រងើយកន្តើយ តែជាមនុស្សឆេវឆាវឆាប់ក្រោធ និង មានបញ្ញាស្ពឹក ។ បុគ្គលណាក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ អទោសៈ និង មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ បុគ្គលនោះ ដោយន័យមុនដូចគ្នា រមែងជា អ្នកមិនលោភលន់ផង ចិត្តត្រជាក់ផង តែជាមនុស្សមានបញ្ញាស្ពឹក ។ ដោយន័យ ដូចគ្នានេះដែរ បុគ្គលណាក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ ទោសៈ និង អមោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ បុគ្គលនោះ ដោយន័យមុនដូចគ្នា រមែងជាមនុស្សមិនលោភលន់ផង ឆ្លៀវឆ្លាតផង តែជាមនុស្សឆេវឆាវ ច្រើនដោយសេចក្តីក្រោធ ។ ចំណែកបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានចំណែកខាងកុសលទាំង៣ មានអលោភៈជាដើមខ្លាំងក្លា ចំណែកអកុសល មានលោភៈជាដើម ទន់ខ្សោយ បុគ្គលនោះ រមែងជាអ្នកមិនលោភលន់ មិនឆេវឆាវ និង មានបញ្ញាផង ដូចព្រះមហាសង្ឃរក្ខិតត្ថេរ ដូច្នោះ ។

ឯបុគ្គលដែលហៅក្នុង **ឧស្សទកិត្តន** ថា ជាមនុស្សលោភលន់នោះ បានដល់បុគ្គលរាគចរិត ( ក្នុងចរិយាវិចារនេះ ) ចំណែកដែលហៅថា មនុស្សឆេវឆាវ និង មនុស្សស្ពឹក បានដល់ បុគ្គលទោសចរិត និង បុគ្គលមោហចរិត ។ ដែលហៅថា

បុគ្គលឆ្លៀវឆ្លាត បានដល់ បុគ្គលពុទ្ធិចរិត ដែលហៅថា បុគ្គលមិនលោភលន់ និង មិនឆេវឆាវ បានដល់ បុគ្គលសទ្ធាចរិត ព្រោះបុគ្គលមិនលោភលន់ និង មិនឆេវឆាវនោះ មានប្រក្រតីជ្រះថ្លា ម្យ៉ាងទៀត គប្បីជ្រាបថា បដិសន្ធិជនកកម្មដែលមានបុព្វហេតុ មានលោភៈជាដើម ឯណានីមួយ ជាគ្រឿងហែហមដោយជុំវិញដល់គ្នានិងគ្នា ជាដើមហេតុនៃចរិយាទាំងឡាយ ដោយន័យដូច្នេះ គឺ អ្នកដែលកើតមកដោយកម្មដែលមានអមោហៈជាគ្រឿងហែហម រមែងជាបុគ្គលពុទ្ធិចរិត យ៉ាងណា អ្នកដែលកើតមកដោយកម្មដែលមានពលវសទ្ធាជាគ្រឿងហែហម រមែងជាសទ្ធាចរិត អ្នកដែលកើតមកដោយកម្មដែលមានវិតក្ក មានកាមវិតក្កជាដើម ជាគ្រឿងហែហម រមែងជាបុគ្គលវិតក្កចរិត អ្នកដែលកើតមកដោយកម្ម ដែលមានគ្រឿងហែហម មានលោភៈជាដើមលាយឡំគ្នា រមែងជាបុគ្គលវោមិស្សចរិត( ចរិតលាយឡំ ) ដូច្នោះឯង ។

## លក្ខណៈនៃចរិត

ចំណែកសេចក្តីដែលថា " **តើគប្បីជ្រាបបានយ៉ាងណាថា បុគ្គលនេះជារាគចរិត** " ដូច្នេះជាដើម គប្បីជ្រាបន័យក្នុងសេចក្តីនោះ ដូចតទៅនេះ :

## មាតិកានៃលក្ខណៈ

បណ្ឌិតគប្បីប្រាប់បង្ហាញចរិយាទាំងឡាយបាន ដោយឥរិយាបថ ដោយកិច្ច ដោយការបរិភោគ ដោយអាការមានការមើលជាដើម និង ដោយធម្មប្បវត្តិ ( ការប្រព្រឹត្តិទៅនៃធម៌ ) នោះឯង ។

# លក្ខណៈដោយឥរិយាបថ

ក្នុងមាតិកាថា “ **ដោយឥរិយាបថ** ” គប្បីជ្រាបន័យដូច្នេះ **បុគ្គលរាគចរិត** កាលដើរទៅតាមប្រក្រតី រមែងដើរដោយអាការគួរស្រឡាញ់ ដាក់ជើងស្រាលថ្នមៗ ដាក់ជើងលើកជើងស្មើ ៗ ហើយជានជើងកំពុងកណ្ដាល ។

**បុគ្គលទោសចរិត** ដើរហាក់បីដូចជាជីកដីដោយចុងជើង ដាក់ជើងលើកជើងដោយអាការរហ័សរហួន ហើយគន្ទុងជើងទាំចុងម្រាម ។

**បុគ្គលមោហចរិត** ដើរដោយសភាពរឡេមរឡើមៗ ភ្ញាក់ផ្អើលៗ ដាក់ជើងលើកជើងដូចជាផ្អើលខ្លាច ហើយគន្ទុងជើងមានស្នាមមិនប្រាកដ ( ខ្ទាត់ខ្ទាយ ) ។

ពិតណាស់ ក្នុងរឿងមាគន្ទិយសូត្រ ព្រាហ្មណីក៏បានពោលពាក្យប្រព័ន្ធនេះទុកថា **: ស្នាមជើងរបស់រាគបុគ្គល ជាស្នាមជើងកំពុងកណ្ដាល ស្នាមជើងរបស់ទោសបុគ្គលជាស្នាមជើងកញ្ចុំ ស្នាមជើងរបស់មោហបុគ្គលជាស្នាមជើងខ្ទាត់ខ្ទាយ តែស្នាមជើងបែបនេះ ជាស្នាមជើងរបស់បុគ្គលមានដំបូល គឺ កិលេសដែលរបើកហើយ ដូច្នេះ** ។

សូម្បីការឈរនៃបុគ្គលរាគចរិត ក៏មានការទន់ភ្លន់គួរជ្រះថ្លា បុគ្គលទោស-ចរិតមានអាការរឹង បុគ្គលមោហចរិតមានអាការរេទៅមក សូម្បីក្នុងការអង្គុយក៏មានន័យដូចគ្នា ។

ចំណែកការដេក បុគ្គលរាគចរិតមិនប្រញាប់ប្រញាល់ ក្រាលទីដេករៀបរយហើយ ដាក់ខ្លួនសន្សឹមៗហើយដេក ប្រមូលអង្គអវយវៈដាក់ដោយមានរបៀប ដេកលក់ដោយអាការគួរជ្រះថ្លា ហើយកាលត្រូវដាស់ឲ្យក្រោកក៏មិនស្ទុះភ្លាម(គឺសន្សឹមៗ ក្រោកឡើង ) ប្រើពាក្យឆ្លើយស្រាល ហាក់ដូចជាមនុស្សមានសេចក្ដីរង្កៀស ។

បុគ្គលទោសចរិត ( កាលដេក )ក៏ប្រញាប់ប្រញាល់ ក្រាលទីដេកតែល្មមៗ ហើយក៏ប្រះខ្លួនដេកចុះ ធ្វើមុខក្រញូវលក់ទៅ ហើយកាលត្រូវដាស់ឲ្យក្រោក ក៏ក្រោករហ័ស ឆ្លើយតបហាក់បីដូចជាខឹង ។

បុគ្គលមោហចរិត ក្រាលទីដេកមានសណ្ឋានមិនល្អ ដេកប្រវេងប្រវាង ផ្កាប់មុខចុះដោយច្រើន ហើយកាលត្រូវដាស់ឲ្យក្រោក ធ្វើសំឡេងហ៊ឺៗក្រោកឡើងយឺតយូរ ។

ក៏ព្រោះបុគ្គល ៣ ខាងចុង មានបុគ្គលសទ្ធាចរិតជាដើម ជាសភាគៈនៃបុគ្គល ៣ ខាងដើម មានបុគ្គលរាគចរិតជាដើម ព្រោះហេតុនោះ ឥរិយាបថ សូម្បីបុគ្គល ៣ ខាងចុង មានបុគ្គលសទ្ធាចរិតជាដើមនោះ ក៏មានសភាពដូចគ្នានោះឯង បណ្ឌិតគប្បីប្រាប់ចរិយាដោយឥរិយាបថ ដូចពោលមកនេះជាដំបូងសិន ។

## លក្ខណៈដោយកិច្ច

គប្បីជ្រាបន័យក្នុងចំណុចថា “ **ដោយកិច្ច** ” តទៅនេះ ក្នុងកិច្ចទាំងឡាយ ដូចជា ការបោសសម្អាត បុគ្គលរាគចរិតចាប់អំបោសល្មមៗ( មិនណែន មិនធូរ ) មិនប្រញាប់ប្រញាល់មិនរាត់ខ្សាច់ឲ្យខ្ចាយ បោសស្អាត ហាក់បីដូចជាក្រាលកន្ទេលខ្សាច់ ។

បុគ្គលទោសចរិត ចាប់អំបោសណែន ប្រញាប់ប្រញាល់(បោសសង្កត់)ធ្វើឲ្យខ្សាច់គរលើគ្នាជា២ចំណែក មានសម្លេងបោសឮខ្លាំង បោសស្អាតតែមិនរាបស្មើ ។

បុគ្គលមោហចរិត ចាប់អំបោសធូរ ៗ រាត់ទៅរាត់មក បោសមិនស្អាត មិនរាបស្មើល្អ ។

ក្នុងការបោសជាដើមយ៉ាងណា ក្នុងកិច្ចទាំងពួង មានការជ្រលក់ និងបោកគក់ចីវរជាដើម ក៏ដូច្នោះដែរ បុគ្គលរាគចរិតតែងធ្វើល្អិតល្អន់រៀបរយ និង ធ្វើដោយគោរព បុគ្គលទោសចរិត កាលធ្វើតែងធ្វើដែផ្ទន់ រម៉ាំងរម៉ោក មិនរៀបរយ បុគ្គលមោហចរិត តែងធ្វើដោយមិនល្អិតល្អន់ ខ្ជីខ្ជា មិនរៀបរយ និងមិនពិតប្រាកដ ហើយការទ្រទ្រង់ស្បង់ចីវរនៃបុគ្គលរាគចរិត ក៏មិនរឹតពេកមិនធូរពេក ជាបរិមណ្ឌលគួរជ្រះថ្លា ឯបុគ្គលទោសចរិត រឹតតឹង ហើយមិនជាបរិមណ្ឌល ឯបុគ្គលមោហចរិត (ស្លៀកពាក់) ធូររយីករយាក សូម្បីបុគ្គលបីពួកដ៏សេស មានបុគ្គលសទ្ធាចរិតជាដើម ក៏គប្បីជ្រាបតាមគន្លងនៃបុគ្គល ៣ ពួកដែលពោលហើយនោះចុះ ព្រោះជាសភាគៈគ្នានោះឯង បណ្ឌិតគប្បីប្រាប់ចរិយាដោយកិច្ច ដោយប្រការដូច្នេះ ។

## លក្ខណៈដោយការបរិភោគ

សេចក្តីថា " **ដោយការបរិភោគ** " មានន័យដូច្នេះ បុគ្គលរាគចរិតចូលចិត្តបរិភោគផ្លិតផ្លង់ប្រណីត និងរបស់ផ្អែម កាលបរិភោគរញ៉េសោត ក៏ធ្វើពំនូតបាយឲ្យមូលល្មម មិនធំពេក ជាបុគ្គលស្គាល់រសអាហារ បរិភោគមិនប្រញាប់ប្រញាល់ បានរបស់បរិភោគដែលល្អ សូម្បីតែបន្តិចក៏ត្រេកអរ ។

បុគ្គលទោសចរិត ចូលចិត្តបរិភោគរបស់ដែលគ្រោតគ្រាត( ឆាយៗ ) និងរបស់ជូរ កាលបរិភោគរញ៉េសោត ក៏ធ្វើពំនូតបាយ( ធំហួស ) ពេញមាត់ជាអ្នកមិនស្គាល់រសអាហារ បរិភោគលឿន បានរបស់ស៊ីមិនល្អបន្តិចបន្តួចក៏អន់ចិត្ត ។

បុគ្គលមោហចរិត ជាបុគ្គលចូលចិត្តបរិភោគរបស់មិនពិតប្រាកដ កាលបើបរិភោគរញ៉េសោត ក៏ធ្វើពំនូតបាយតូច ៗ មិនមូលល្អ ធ្វើគ្រាប់បាយឲ្យជ្រុះចុះក្នុង

ការជន៍ ធ្វើមាត់ឲ្យប្រឡាក់ គំនិតរាយមាយ ត្រិះរិះរឿងនោះៗ បណ្តើរ ស៊ីបណ្តើរ សូម្បីបុគ្គល ៣ ពួកដ៏សេស មានបុគ្គលសទ្ធាចរិតជាដើម គប្បីជ្រាបតាមដំណើរ នៃបុគ្គលដែលពោលហើយនោះចុះ ព្រោះជាសភាគៈគ្នានោះឯង បណ្ឌិតគប្បីជ្រាប ចរិយា ដោយការបរិភោគដោយប្រការដូច្នេះចុះ ។

## លក្ខណៈដោយអាការ មានការមើលជាដើម

សេចក្តីថា “ **ដោយអាការមានការមើលជាដើម** ” នោះ មានន័យដូច្នេះ :

**បុគ្គលរាគចរិត** ឃើញរូបដែលគួរមនោរម្យនៃចិត្ត សូម្បីបន្តិចបន្តួច ក៏តាមមើលអស់កាលដ៏យូរ ហាក់ដូចជាកើតនូវសេចក្តីកិសវង់ជាប់ចិត្តក្នុងចំណែកល្អ (របស់រូបនោះ) សូម្បីបន្តិចបន្តួច មិនកាន់យកចំណែកអាក្រក់របស់រូបនោះ សូម្បីច្រើន កាលចេញទៅ ក៏មិនផុតអំពីសេចក្តីជាប់ជំពាក់ ចេញទៅទាំងមានសេចក្តីអាល័យ ។

**បុគ្គលទោសចរិត** ឃើញរូបដែលមិនពេញចិត្ត សូម្បីតិចតួច ក៏មើលយូរមិនបាន ធ្វើឫកដូចជាហត់នឿយ អន់ចិត្តក្នុងចំណែកអាក្រក់ សូម្បីតិចតួច មិនកាន់យកចំណែកល្អ សូម្បីឃើញរបស់ចាស់ ៗ កាលនឹងចេញទៅសោត ក៏ផុតអំពីសេចក្តីស្រឡាញ់ ចេញទៅមិនមានអាល័យ ។

**បុគ្គលមោហចរិត** ឃើញរូបឯណាមួយ ក៏បណ្តោយតាមតែអ្នកដទៃ បានឮគេនិន្ទាក៏និន្ទាតាម បានឮគេសរសើរ ក៏សរសើរតាម តែចំណែកខ្លួនជាមនុស្សព្រងើយៗដោយអញ្ញាណុបេក្ខា ( ឧបេក្ខាល្ងង់ខ្លៅ ) ន័យនេះ គប្បីជ្រាប សូម្បីក្នុងអាការទាំងពួង មានការស្តាប់សំឡេងជាដើម ចំណែកបុគ្គល ៣ ពួកដ៏សេស មាន

សទ្ធាចរិតជាដើម គប្បីជ្រាបតាមគន្លងនៃបុគ្គល ៣ ពួក ដែលបានពោលហើយនោះចុះ ព្រោះជាសភាគៈគ្នា បណ្ឌិតគប្បីជ្រាបចរិយាដោយអាការ មានការមើលជាដើម ដោយប្រការដូច្នេះ ។

## លក្ខណៈដោយធម៌ប្រព្រឹត្ត

សេចក្ដីថា " **និងដោយធម៌ប្រព្រឹត្តនោះឯង** " នោះមានន័យដូច្នេះ ។ ក៏ធម៌ទាំងឡាយ គឺ **មាយា សាថេយ្យ មានះ បាបិច្ឆតា មហិច្ឆតា អសន្តុដ្ឋិតា សិង្គ** ( ការក្រែងបន្ទំឲ្យអ្នកដទៃទុកចិត្ត ឬពេញចិត្ត ) **ចាបល្យ**( ការស្អិតស្អាង ) យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅច្រើនដល់ **បុគ្គលរាគចរិត** ។

ធម៌ទាំងឡាយគឺ **កោធ ឧបនាហ មក្ខ បលាស ឥស្សា មច្ឆរិយ** ដូច្នេះជាដើម រមែងប្រព្រឹត្តទៅច្រើនដល់ **បុគ្គលទោសចរិត** ។

ធម៌ទាំងឡាយគឺ **ថីនមិទ្ធ ឧទ្ធច្ចកុក្កុច្ច វិចិកិច្ឆា អាទានគាហិតា** ( សេចក្ដីប្រកាន់ខុស ) **ទុប្បដិនិស្សគ្គិតា**( ភាពរឹងរូស ) ដូច្នេះជាដើម រមែងប្រព្រឹត្តទៅច្រើនដល់ **បុគ្គលមោហចរិត** ។

ធម៌ទាំងឡាយគឺ **មុត្តចាគតា**(ភាពលះបង់ដាច់ស្រឡះ), **អរិយានំ ទស្សនកាមតា**(ការប្រាថ្នាដើម្បីបានជួបព្រះអរិយបុគ្គលទាំងឡាយ) , **សទ្ធម្មំ សោតុកាមតា** (ការប្រាថ្នាដើម្បីស្ដាប់ព្រះធម៌) , **បាមោជ្ជ ពហុលតា**(ច្រើនដោយភាពរីករាយក្នុងធម៌) , **អសឋតា**(ភាពមិនអួតអាង) , **អមាយាវិតា**(ការមិនមានមាយាលាក់ពុត) , **បសាទនីយេសុ ឋានេសុ បសាទោ** (ការជ្រះថ្លាក្នុងឋានទាំងឡាយដែលគួរជ្រះថ្លា) ដូច្នេះជាដើម រមែងប្រព្រឹត្តទៅច្រើនដល់ **បុគ្គលសទ្ធាចរិត** ។

ធម៌ទាំងឡាយគឺ **សោវចស្សតា**(ប្រដៅងាយ) , **កល្យាណមិត្តតា** , **ភោជនេមត្តញ្ញុតា** , **សតិសម្បជញ្ញ** , **ជាគរិយានុយោគ**(ការភ្ញាក់រលឹក) , **សំវេជនីយេសុ ឋានេសុ សំវេគោ** (សង្វេគក្នុងឋានៈទាំងឡាយដែលគួរសង្វេគ) , **សំវិគ្គស្ស យោនិសោ បធានំ** កាលសង្វេគហើយ ធ្វើសេចក្តីព្យាយាម ប្រកបដោយបញ្ញា ដូច្នេះជាដើម ប្រព្រឹត្តទៅច្រើនដល់ **បុគ្គលពុទ្ធិចរិត** ។

ធម៌ទាំងឡាយគឺ **ភស្សពហុលតា** (និយាយច្រើនជាងធ្វើ) , **គណារាមតា** (ចូលចិត្តគ្នីគ្នា) , **កុសលានុយោគេ អរតិ** (ធុញទ្រាន់ក្នុងការធ្វើកុសល) , **អវដ្ឋិតកិច្ចតា** (មិនពិតប្រាកដក្នុងកិច្ចការ) , **រត្តិធុមាយនា**(ពេលយប់បែកគំនិត ហុយដូចផ្សែង) , **ទិវាបជ្ជលនា** (ពេលថ្ងៃមិនឆេះចេញជាអណ្តាតភ្លើង) , **ហុរាហុរំ ធាវនា** (ឆ្វេឆ្វា)ដូច្នេះជាដើម ប្រព្រឹត្តទៅច្រើនដល់ **បុគ្គលវិតក្កចរិត** បណ្ឌិតគប្បីប្រាប់ចរិយាដោយធម៌ប្រព្រឹត្ត ដោយអាការដូច្នោះហោង ។

តែក្នុងវិធីប្រាប់ចរិយានេះ មិនបានមកក្នុងព្រះបាលី មិនបានមកក្នុងអដ្ឋកថាគ្រប់ប្រការទេ ទើបខ្ញុំម្ចាស់ ពោលទៅតាមគន្លងអាចរិយមតិប៉ុណ្ណោះ ព្រោះហេតុនោះ បណ្ឌិតទើបមិនគួរជឿកាន់យកជាសារៈ ព្រោះថា សូម្បីបុគ្គលចរិតផ្សេងៗមានទោសចរិតជាដើម ដែលមិនបណ្តែតបណ្តោយខ្លួន ក៏អាច ( ធ្យុយ ) គឺ ធ្វើអ្វីផ្សេងៗ មានឥរិយាបថជាដើម ដែលពោលសម្រាប់បុគ្គលរាគចរិតបាន ហើយអាការទាំងឡាយ មានឥរិយាបថជាដើម ដែលមានលក្ខណៈផ្សេងគ្នា នឹងកើតឡើងដល់បុគ្គលមានចរិតលាយឡំតែឯងមិនបានឡើយ ចំណែកវិធីប្រាប់ចរិយា ឯណាដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយ វិធីប្រាប់ចរិយានោះប៉ុណ្ណោះ គួរជឿកាន់យកជាសារៈបាន ពិតណាស់ លោកពោលទុកក្នុងអដ្ឋកថា ថា អាចារ្យអ្នកបាន

ចេតោបរិយញ្ញាណ ដឹងចរិយារបស់អន្តេវាសិកហើយ ទើបប្រាប់កម្មដ្ឋានឲ្យ , អាចារ្យក្រៅអំពីនោះ ចាំបាច់ត្រូវសាកសួរអន្តេវាសិក ឲ្យដឹងចរិយាហើយ ទើបប្រាប់កម្មដ្ឋានឲ្យគេដូច្នេះ ព្រោះហេតុនោះ នឹងដឹងថា បុគ្គលនេះជារាគចរិត បុគ្គលនេះជាមនុស្សចរិតយ៉ាងណាមួយក្នុងចរិតដ៏សេស មានទោសចរិតជាដើមបានដោយចេតោបរិយញ្ញាណ ឬ បើមិនដូច្នោះ ដោយការសាកសួរបុគ្គលនោះៗ ទើបនឹងដឹងដោយប្រការដូច្នេះ ។

## សប្បាយរបស់បុគ្គលចរិតផ្សេងៗ

ចំណែកការវិនិច្ឆ័យក្នុងបញ្ហា ថា “ **អ្វីជាសប្បាយរបស់បុគ្គលចរិតអ្វី** ” នោះ គប្បីជ្រាបដូចតទៅនេះ :

## សប្បាយរបស់បុគ្គលរាគចរិត

សម្រាប់បុគ្គលរាគចរិត លំដាប់ដំបូង សេនាសនៈ ជាសេនាសនៈដែលកម្រាលមិនបានលាងជម្រះ សេនាសនៈដែលតាំងនៅផ្ទាល់លើផែនដី ញកភ្នំដែលមិនបានតុបតែង បណ្តាសេនាសនៈដែលអាក្រក់ៗទាំងឡាយ មានកុដិស្បូវនិងរោងស្លឹកឈើជាដើម យ៉ាងណាមួយ សេនាសនៈដែលប្រឡាក់ទៅដោយល្អងធូលី ពេញទៅដោយអាចម៍ប្រចៀវ បាក់ៗ ធ្លុះៗ ខ្ពស់ពេក ឬមិនខ្ពស់ ទាបពេក ស្ងួតហួតហែង គួរចំបែងចិត្ត ផ្លូវដើរក៏មិនស្អាត និង រដិបរដុប ក្នុងសេនាសនៈណា សូម្បីគ្រែ តាំង ក៏ទ្រេតទ្រោត គ្រាំគ្រា ពេញទៅដោយសង្កើច ឬខ្ទួត បុគ្គលក្រឡេកឃើញសេនាសនៈណា គ្រាន់តែចូលប៉ុណ្ណោះ សេចក្តីស្អប់ក៏កើតឡើង សេនាសនៈដូច្នោះជា សប្បាយ ។

សំពត់ស្លៀកដណ្ដប់ដែលមានជាយដាច់ហើយ ពាសពេញទៅដោយអំបោះខ្វាត់ខ្វែងរយ៉ៃ ប្រៀបដូចទំសំបុកចាប សម្លស្សគ្រោតគ្រាត ដូចព្រាលស្រស់ចាស់ ធ្ងន់ លំបាកប្រើ នោះឯងជា សប្បាយ ។

សូម្បីបាត្រក៏ជាបាត្រដី ពណ៌អន់ៗ ឬបើមិនដូច្នោះ ជាបាត្រដែកដែលកញ្ចូតទៅដោយមិន និង កន្ទះ ធ្ងន់ ទ្រទ្រង់ហើយគួរស្អប់ មើលទៅ ដូចលលាដ៏ក្បាលនោះ ជាសប្បាយ ។

សូម្បីផ្លូវស្វែងរកកិក្ខាចារ ក៏ជាផ្លូវដែលមិនគួរពេញចិត្ត នៅឆ្ងាយពីភូមិវេងបវេុប នោះសមគួរ ។

ភូមិដែលត្រូវរកកិក្ខាចារវិញ ក៏ជាភូមិប្រភេទដែលភិក្ខុទាំងឡាយ ត្រាច់ទៅស្វែងរកកិក្ខា ( គ្មានសញ្ញាថាគេនឹងប្រគេនកិក្ខា ) ហាក់បីដូចជាមនុស្សទាំងឡាយមិនឃើញ ជាភូមិប្រភេទដែលមនុស្សទាំងឡាយ និមន្តភិក្ខុដែលមិនបានទទួលកិក្ខាក្នុងត្រកូល សូម្បីត្រកូលណាមួយ ហើយត្រឡប់ចេញទៅវិញ ឲ្យចូលរោងធាន់ដោយពាក្យថា “ មកណេះ លោក ” ប្រគេនបបរ និង កត្តហើយ កាលទៅក៏ទៅមិនអាឡោះអាល័យ ដូចពេលមេគោចូលក្រោលហើយ ក៏ទៅមិនក្រឡេកមើលដូច្នោះ សមគួរ ។

សូម្បីមនុស្សអង្គាស ក៏ជាពួកទាសៈ ឬ កម្មករដែលមានស្បែកខ្មៅ សំពត់ស្លៀកដណ្ដប់ស្មោកគ្រោក ក្លិនមិនល្អ គួរស្អប់ពិត ៗ ដែលអង្គាសដោយអាការមិនគោរក្រែង ដូចចោល យាគូ និង កត្ត ដូច្នោះ ពួកមនុស្សអ្នកអង្គាសដូច្នោះ ជាសប្បាយ ។

យាគូ កត្ត និង របស់ទំពាវិញសោត ក៏ជារបស់អន់ៗ ពណ៌អាប់ៗ លាយ

ទៅដោយអបរណ្ណជាតិមាន ថ្លៅ ស្រូវស្លួយ និងបាយចុងអង្ករជាដើម គ្រឿងសម្ល ប្រកបដោយសំណល់សាច់ ឬ ធ្មឹង ទឹកជ្រក់ និងបន្លែចាស់ៗ ឯណាមួយក៏បាន លុះធ្វើពោះឲ្យពេញហើយជាការស្រេច នោះសមគួរ ។

សូម្បីឥរិយាបថ សម្រាប់បុគ្គលរាគចរិតនោះ ក៏ជាការឈរ ឬ ចង្ក្រមនោះ សមគួរ ។

អារម្មណ៍កម្មដ្ឋានវិញសោត ក៏ជា បណ្ឌុវណ្ណកសិណ មាននីលកសិណ ជាដើម យ៉ាងណាមួយ ដែលពណ៌មិនស្រស់ នោះសមគួរ ។

នេះឯងជាសប្បាយរបស់បុគ្គលរាគចរិត ។

# សប្បាយរបស់បុគ្គលទោសចរិត

សម្រាប់បុគ្គលទោសចរិត សេនាសនៈ ជាសេនាសនៈដែលមិនខ្ពស់ពេកមិន ទាបពេក មានម្លប់ និង ទឹក ព្រមទាំងជញ្ជាំងសសរជណ្ដើរត្រូវខ្នាតល្អ មានការ តុបតែងដោយភ្ញីផ្កា ភ្ញីវល្លិ៍ ទុកយ៉ាងស្រស់ស្អាត រៀបរយល្អ រចនាទៅដោយ ចិត្រកម្មផ្សេងៗ ផ្ទៃដីរាបស្មើ និងទន់ តុបតែងពិតានដោយ កម្រងផ្កា និង សំពត់ ពណ៌ដ៏វិចិត្រ មានកម្រាល និង គ្រែ តាំងដ៏ស្អាត គួររីករាយនៃចិត្ត ដែលគេក្រាល ទុកយ៉ាងល្អ មានផ្កាឈើ គ្រឿងអប់ និង គ្រឿងក្រអូប ទុកដាក់ដើម្បីអប់ក្លិនក្នុងទី នោះៗ ហាក់បីដូចជាព្រហ្មវិមាន សេនាសនៈវិញសោត គ្រាន់តែឃើញប៉ុណ្ណោះ ក៏ ញុំាងបីតិ បាមោជ្ជឲ្យកើតឡើងបាន សេនាសនៈបែបនេះឯងជា សប្បាយ ។

ចំណែកផ្លូវចូលទៅកាន់សេនាសនៈនោះ គួរជាផ្លូវផុតអន្តរាយទាំងពួង ផ្ទៃដី រាបស្មើ ស្អាត មានអ្នកចាំតុបតែងទុក ។

ចំណែកគ្រឿងបរិក្ខារសម្រាប់សេនាសនៈ ក្នុងសេនាសនៈនោះ គួរកុំមានច្រើនពេក មានគ្រែឬតាំងត្រឹមតែមួយប៉ុណ្ណោះក៏ល្មម ដើម្បីកាត់បន្ថយទីអាស្រ័យនៃសត្វល្អិត សង្កើច ពស់ និង កណ្ដុរទាំងឡាយ ។

សូម្បីសំពត់ស្លៀកដណ្ដប់ សម្រាប់បុគ្គលទោសចរិតនោះសោត ក៏គួរជាសំពត់ចិន សំពត់សោមារៈ សំពត់ធ្មៃ សំពត់អំបោះសាច់ល្អិត សំពត់សរសៃឈើសាច់ម៉ដ្តណាៗ ដែលមានសាច់ម៉ដ្តល្អ ធ្វើជាចីវរមួយជាន់ឬពីរជាន់ក៏ដោយ ត្រូវស្រាលល្អ ជ្រលក់យ៉ាងល្អ ពណ៌បរិសុទ្ធ តាមសមណសារូប ។

សូម្បីបាត្រ ក៏គួរជាបាត្រដែក ដែលទ្រទ្រង់ទៅស្អាត ដូចដុំពពុះទឹក រលីងមិនមានស្នឹម ដូចកែវ អប់ទុកយ៉ាងល្អ មានពណ៌បរិសុទ្ធតាមសមណសារូប ។

ផ្លូវភិក្ខាចារ គួរជាផ្លូវផុតអន្តរាយ រាបស្មើ គួររីករាយនៃចិត្ត មិនជិតមិនឆ្ងាយអំពីភូមិពេក ។ ភូមិដែលភិក្ខាចារវិញសោត គួរជាភូមិដែលមនុស្សទាំងឡាយរីករាយចិត្តថា ព្រះគុណម្ចាស់នឹងមកឥឡូវនេះ ហើយឲ្យក្រាលអាសនៈទុកក្នុងទីដែលប្រោះទឹក និងបោសសម្អាតហើយ (កាលភិក្ខុទៅដល់) ក៏ទៅទទួល ទទួលបាត្រ និមន្តឲ្យចូលកាន់ផ្ទះ ឲ្យគង់លើអាសនៈដែលក្រាលទុក ហើយអង្គាសដោយគោរព ដោយដៃខ្លួនឯង ។

ចំណែកពួកអ្នកអង្គាស ជាចំពូកមនុស្សស្អាតបាត គួរជ្រះថ្លា ឲ្យងូតទឹកលាបខ្លួនល្អហើយ ក្រអូបទៅដោយក្លិនធូបក្រអូប និងផ្កាឈើ តែងកាយដោយកស្ត្រាភរណៈ ចម្រុះពណ៌ និង ស្អាត គួរគេយកគន់ ធ្វើការអង្គាសដោយគោរព ដូច្នោះឯងជា សប្បាយរបស់បុគ្គលទោសចរិត ។

សូម្បីយាគូ កត្ត និង របស់ទំពា ក៏គួរជារបស់មានក្លិន រស ឱជាប្រណីតគួរ

ពេញចិត្ត មានតាមដែលត្រូវការ ។

សូម្បីឥរិយាបថ សម្រាប់បុគ្គលទោសចរិតនោះ ក៏គួរជាការដេក ឬអង្គុយ ។

អារម្មណ៍ គួរជា បណ្តាវណ្ណកសិណ មាននីលកសិណជាដើម ឯណាមួយ ដែលមានពណ៌ស្រស់ល្អ ។ នេះជាសប្បាយរបស់បុគ្គលទោសចរិត ។

## សប្បាយរបស់បុគ្គលមោហចរិត

សម្រាប់បុគ្គលមោហចរិត សេនាសនៈ គួរជាសេនាសនៈដែលបែរមុខទៅកាន់ទិស ( គឺ ទីដែលភ្លឺស្រឡះ ) ដែលមិនចង្អៀត ជាទីដែលទិសទាំងឡាយប្រាកដច្បាស់ សម្រាប់បុគ្គលដែលកំពុងអង្គុយ ។ ក្នុងឥរិយាបថទាំងឡាយ ការចង្ក្រមសមគួរ ចំណែកអារម្មណ៍ សម្រាប់បុគ្គលមោហចរិត មិនគួរជាបរិត្តកសិណទំហំប៉ុនត្បាល់ ឬ ប៉ុនផ្តិល ព្រោះក្នុងឱកាសដែលចង្អៀត ចិត្តនឹងដល់នូវភាពវង្វេងភ្លេចក្រៃលែងឡើង ព្រោះដូច្នោះ ទើបគួរជាកសិណ ដែលមានវង់ធំទូលាយជាមហាកសិណ សប្បាយដ៏សេស ក៏ដូចគ្នានឹងការពោលហើយសម្រាប់បុគ្គលទោសចរិត ។ នេះឯងជាសប្បាយរបស់បុគ្គលមោហចរិត ។

## សប្បាយរបស់បុគ្គលសទ្ធាចរិត និងពុទ្ធិចរិត

វិធីដែលពោលហើយក្នុងបុគ្គលទោសចរិតទាំងអស់ ក៏ជាសប្បាយរបស់បុគ្គលសទ្ធាចរិត ហើយក្នុងអារម្មណ៍ទាំងឡាយ សូម្បីអនុស្សតិកម្មដ្ឋាន ក៏សមគួរដល់លោកផងដែរ ។

ពាក្យដែលនឹងគប្បីពោលថា បណ្តាវត្ថុទាំងឡាយ មានសេនាសនៈជាដើម វត្ថុឈ្មោះនេះ ជាសប្បាយរបស់បុគ្គលពុទ្ធិចរិតដូច្នេះ មិនមាន ។

## សប្បាយរបស់បុគ្គលវិតក្កចរិត

សម្រាប់បុគ្គលវិតក្កចរិត សេនាសនៈមិនគួរជាសេនាសនៈល្អល្អៅ បែរមុខទៅកាន់ទិសដែលជាសួនច្បារ ព្រៃនិងស្រះបោក្ខរណីដែលគួរមនោរម្យតាមនិគមនិងជនបទដែលជាលំដាប់គ្នាទៅ និង ភ្នំដែលមានពណ៌ខៀវស្រងាត់ រមែងប្រាកដដល់បុគ្គលកំពុងអង្គុយ (ត្រង់សេនាសនៈនោះ) ព្រោះសេនាសនៈនោះ រមែងជាបច្ច័យនៃការត្រាច់ទៅនៃវិតក្កដោយពិត ព្រោះហេតុនោះ បុគ្គលវិតក្កចរិតគួរនៅក្នុងញកភ្នំដែលជ្រៅ ក្នុងសេនាសេនៈដែលមានព្រៃបាំង ដូចជាញោចពោះដំរី និងគុហារបស់ព្រះមហិន្ទ សូម្បីអារម្មណ៍សម្រាប់លោក ក៏មិនគួរជាវិបុលកសិណ ( កសិណធំទូលាយ ) ព្រោះកសិណដូច្នោះ ជាបច្ច័យនៃភាពត្រាច់ទៅ ដោយអំណាចនៃវិតក្កៈ តែគួរជាបរិត្តកសិណ សប្បាយដ៏សេស ក៏ដូចគ្នានឹងការដែលពោលហើយសម្រាប់បុគ្គលរាគចរិត ។ នេះឯងជាសប្បាយរបស់បុគ្គលវិតក្កចរិត ។

## មហាដីកា

## ពណ៌នាអំពីចរិយា

ការប្រព្រឹត្ត គឺ ការប្រព្រឹត្តទៅដោយការៈដែលក្រាស់ដោយរាគៈក្នុងសន្តានឈ្មោះថា រាគចរិយា , រាគចរិយានោះ គប្បីឃើញថា ដូចជាទិដ្ឋិទាំងឡាយ មានសស្សតទិដ្ឋិជាដើម ។ ចរិយាទាំងឡាយ មានទោសចរិយាជាដើម ក៏យ៉ាងនោះដូចគ្នា ។ គប្បីជ្រាបភាពចូលគ្នា ( នៃចរិយាទាំងឡាយ ) ដោយអំណាចភាពសមគួរចំពោះការប្រកបរួមគ្នាបាន ដូចជា “**រាគមោហចរិយា ទោសមោហចរិយា**” ដូច្នេះជាដើម ។ គប្បីជ្រាបដល់ការប្រជុំគ្នា ដោយអំណាចភាពជាចរិយាដែលពាក់

ព័ន្ធនៅក្នុងការបន្តបូលគ្នាតែមួយ ដូចជា " រាគទោសចរិយា រាគទោសមោហ-ចរិយា " ដូច្នេះជាដើម ។

ពិតណាស់ លោកអាចារ្យ សំដៅយកចរិយាដែលលាយឡំគ្នាជាដើម ទាំងនោះឯង ពោលថា សូម្បីចរិយា ៤ ដទៃទៀត ។

ពាក្យថា **ដូចយ៉ាងនេះ សេចក្តីថា ចរិយា ៤ យ៉ាង ដទៃទៀតទាំងនេះ** គឺ សទ្ធាពុទ្ធិចរិយា សទ្ធាវិតក្កចរិយា ពុទ្ធិវិតក្កចរិយា សទ្ធាពុទ្ធិវិតក្កចរិយា រមែងមានបានដោយអំណាចនៃការលាយគ្នា និងប្រជុំគ្នានៃចរិយា ៣ មានសទ្ធាចរិយាជាដើម ដូចចរិយា ៣ មានរាគចរិយាជាដើម ។ ពាក្យថា **ដោយប្រការដូចពោលមកនេះ** គឺ ដោយពាក់ព័ន្ធជាមួយការលាយគ្នា និង ប្រជុំគ្នា ។ បទថា **សំសគ្គំ** បានដល់ **សំសជ្ជនំ** គឺ ធ្វើឲ្យលាយឡំគ្នាដោយន័យថា "រាគសទ្ធាចរិយា ទោសសទ្ធាចរិយា" ដូច្នេះជាដើម ។ ពាក្យថា **រមែងមានបានច្រើនៗ** គឺ មានបានដល់ទៅ ៦៣ យ៉ាង ឬ ច្រើនជាងនោះ ក៏ចរិយាទាំងនោះ លោកបានសំដែងទុកដោយពិស្តារ ហើយក្នុងដីកាព្រះសូត្រសំយុត្តនិកាយ ដោយមិនស្រេពចស្រពិល ព្រោះហេតុនោះបណ្ឌិតគប្បីជ្រាបតាមន័យ ដែលលោកពោលទុកក្នុងទីនោះចុះ ។

ដោយពាក្យថា **បកតិ** នេះលោកសំដែងដល់ ភាពដែលចរិយាមាននៅពិតដោយភាវៈក្នុងសន្តាននោះៗ ក្នុងកាលនៅមិនទាន់មានភាវនាដែលជាបដិបក្ខ ។

ឈ្មោះថា **ភាពក្រាស់** បានដល់ ភាវៈដែលធម៌ទាំងឡាយមានរាគៈជាដើម ជាធម្មជាតិដែលក្រៃលែងជាងធម៌ពួកដទៃ ដែលជាហេតុឲ្យ កាលបុគ្គលដែលជារាគចរិតជាដើម មានភាពព្រមព្រៀងដោយបច្ច័យ ធម៌ទាំងឡាយមានរាគៈជាដើម នឹងជាធម្មជាតិមានកម្លាំង និង ប្រព្រឹត្តទៅរឿយៗ ។

ពាក្យថា **ដោយអំណាចនៃចរិយាទាំងនោះ** គឺ បុគ្គលរមែងមានត្រឹមតែ ៦ ប៉ុណ្ណោះ ព្រោះអំណាចនៃចរិយាជាមូល ៦ អធិប្បាយថា បើពោលដោយប្រការដទៃ បុគ្គលនឹងមានច្រើនណាស់ ហើយកាលបើដូច្នោះ នឹងមិនសម្រេចនូវប្រយោជន៍ដែលបំណង ។

ឈ្មោះថា សទ្ធា ជាធម្មជាតិមានកម្លាំង ក៏ព្រោះក្នុងសន្តានក្រាស់ដោយរាគៈ ធម៌ដែលមានគុណស្របតាមរាគៈនោះ មានភាពជាធម្មជាតិដែលក្រៃលែងដោយការប្រកបជាប្រចាំ ព្រោះហេតុនោះ ទើបលោកពោលថា “ ព្រោះ សទ្ធា មានគុណជិតចំពោះរាគៈ ” ដូច្នេះ មានសេចក្ដីថា ព្រោះជាធម៌ដែលសភាគៈគ្នា ( មានចំណែកដូចគ្នា ) ដោយហេតុទាំងឡាយ មានការស្រឡាញ់ ការស្វែងរក និង ការមិនលះបង់ ។ ពិតណាស់ ធម៌ដែលជាសភាគៈគ្នា សូម្បីនៅឆ្ងាយគ្នា ក៏ដូចជានៅជិតគ្នា ព្រោះហេតុនោះ ស័ព្ទថា **អាសន្ន** (ជិត) ក្នុងទីនេះ មានភាពជាសភាគៈគ្នាជាលក្ខណៈ ក្នុងហេតុជាសភាគៈគ្នាទាំងនោះ **សទ្ធា** មានការចូលចិត្ត គឺភាពមិនមួរម៉ៅ ភាពមិនសៅហ្មង ដោយទាក់ទងជាមួយភាពជ្រះថ្លា , **រាគៈ** ក៏មានការចូលចិត្ត ដោយទាក់ទងជាមួយនឹងការត្រេកអរនៃចិត្ត ។ **សទ្ធា** មានការស្វែងរក គឺ ការបង្អោនចិត្តទៅក្នុងវត្ថុនោះ ដោយអំណាចនៃការបង្អោនចិត្តជឿ , **រាគៈ** ក៏មានការស្វែងរកដោយអំណាចនៃចំណង់ ។ **សទ្ធា** មានការមិនលះបង់ គឺការបណ្ដោយតាមទៅ ដោយអំណាចការសម្រេចចិត្តជឿ ។ **រាគៈ** ក៏មានការមិនលះបង់ដោយអំណាចការជាប់ជំពាក់ ធម៌ពួកនោះ សូម្បីមានសភាពខុសគ្នា តាមប្រការដែលពោលមកហើយ យ៉ាងនេះ ក៏មានសភាពជាសភាគៈគ្នា ព្រោះមានភាពមិនសៅហ្មងជាដើមដូចគ្នា យ៉ាងណា បុគ្គលទាំងឡាយ សូម្បីព្រមព្រៀង

ដោយធម៌ទាំងនោះ ក៏មានភាពជាសភាគៈគ្នា យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា "បុគ្គលសទ្ធាចរិតជាសភាគៈ ចំពោះបុគ្គលរាគចរិត" ដូច្នេះ ។

ឈ្មោះថា **បញ្ញា** រមែងជាធម្មជាតិមានកម្លាំង ព្រោះក្នុងសន្តានក្រាស់ដោយទោសៈ ធម៌ដែលមានគុណបណ្ដោយស្របតាមទោសៈនោះ មានភាពជាធម្មជាតិដែលក្រៃលែងដោយការប្រកបជាប្រចាំ ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះភាពដែលបញ្ញា មានគុណជិតចំពោះទោសៈ ដូច្នេះ ព្រោះជាធម៌ដែលសភាគៈគ្នាដោយហេតុទាំងឡាយ មានការមិនជាប់ជំពាក់(ក្នុងអារម្មណ៍) ការស្វែងរក(ទោស) និងការវៀរបង់នូវសត្វ ឬ សង្ខារ ។ ក្នុងបណ្ដាហេតុទាំងនោះ **បញ្ញា** មានការមិនជាប់ក្នុងអារម្មណ៍ គឺការមិនជាប់ជំពាក់ ដោយអំណាចការឈានចុះកាន់អារម្មណ៍នោះបានតាមសភាវៈ ចំណែក **ទោសៈ** មានការមិនជាប់ក្នុងអារម្មណ៍ ដោយអំណាចនៃបំណងអាក្រក់ ។ **បញ្ញា** មានការស្វែងរក គឺ ការល្ហេចល្ហីរកទោសតាមដែលមានពិត , **ទោសៈ** មានការជ្រើសរើសរកទោសដែលមិនមានពិត ។ **បញ្ញា** មានការវៀរបង់ គឺ ការភ័យខ្លាចដោយញាណ ដោយអំណាចនៃការនឿយណាយជាដើម , **ទោសៈ** មានការលះបង់ចោល (វត្ថុដែលជាប្រយោជន៍) ដោយអំណាចភាពជាទីតាំងនៃវត្ថុដែលរកប្រយោជន៍មិនបាន ធម៌ទាំងនោះ សូម្បីមានភាវៈខុសគ្នាតាមប្រការដែលពោលមក យ៉ាងនេះ ក៏ជាសភាគៈគ្នា ព្រោះមានការមិនជាប់ជំពាក់ជាដើមដូចគ្នា យ៉ាងណា បុគ្គលទាំងឡាយ សូម្បីដែលព្រមព្រៀងគ្នាដោយធម៌ទាំងនោះ ក៏មានភាពជាសភាគៈគ្នា យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា "បុគ្គលពុទ្ធិចរិតជាសភាគៈចំពោះបុគ្គលទោសចរិត" ដូច្នេះ ។

ពាក្យថា ***វិតក្កទាំងឡាយដែលជាអ្នកធ្វើអន្តរាយ*** មានន័យថា ***មិច្ឆាវិតក្ក*** គឺ មិច្ឆាសង្កប្បៈ ទាំងឡាយរមែងកើតឡើងបាន ព្រោះក្នុងសន្តានដែលក្រាស់ដោយមោហៈ ធម៌ដែលមានគុណបណ្ដោយតាមមោហៈនោះ រមែងមានការប្រព្រឹត្តទៅដោយច្រើន ។

វិតក្កមានការត្រាច់ទៅបានរហ័សយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលថា " ***ព្រោះការដែលវិតក្កៈមានលក្ខណៈអែបជិត ចំពោះមោហៈ*** " មានន័យថា ព្រោះជាធម៌ដែលសភាគៈគ្នា ដោយហេតុទាំងឡាយ មានការមិនឈប់ស្ងៀម និង ការញាប់ញ័រ ។

ក្នុងហេតុទាំងនោះ វិតក្កៈមានការមិនឈប់ស្ងៀម ព្រោះមានការផ្សាយទៅដោយទាក់ទងជាមួយការត្រិះរិះ មោហៈមានការមិនឈប់ស្ងៀម ព្រោះការវិលវល់ដោយអំណាចនៃការវង្វេង ។ យ៉ាងនោះដូចគ្នា វិតក្កៈមានការញាប់ញ័រ ព្រោះការញាប់ញ័រជាគ្រាៗ ដោយការត្រិះរិះទៅបានឆាប់រហ័ស មោហៈក៏មានការញាប់ញ័រ ព្រោះភាពដែលមិនចុះស៊ប់ ធម៌ទាំងឡាយនោះ សូម្បីមានសភាវៈផ្សេងគ្នាដោយប្រការដែលពោលមកនេះ យ៉ាងនេះ ក៏មានភាពជាសភាគៈគ្នា ព្រោះមានការមិនឈប់ស្ងៀមជាដើមដូចគ្នាយ៉ាងណា បុគ្គលទាំងឡាយ សូម្បីព្រមព្រៀងដោយធម៌ទាំងនោះ ក៏មានភាពជាសភាគៈគ្នាដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា " បុគ្គលវិតក្កចរិតជាសភាគៈចំពោះបុគ្គលមោហចរិត " ដូច្នេះ ។

ឈ្មោះថា ***តណ្ហា*** គឺ រាគៈនោះឯងដោយសភាវៈ ព្រោះដូច្នោះ ទើបមិនផុតពីរាគចរិយា មានន័យថា តណ្ហាចរិយា មិនមាន ។ បទថា ***តំ សម្បយុត្តោ*** ប្រែថា ធម៌ដែលសម្បយុត្តជាមួយរាគៈនោះ អធិប្បាយថា មានះ ដែលវិប្បយុត្ត

ជាមួយរាគៈនោះបាន ដូចជាធម៌ មានទោសៈជាដើម មិនមាន ។ បទថា **តទុភយំ** បានដល់ តណ្ហា និង មានះ ទាំងពីរ ។ ពាក្យថា **រួចផុតអំពី** ( រាគចរិយា ) **ទៅមិនមាន** គឺ បានប្រព្រឹត្តទៅផុតអំពី( រាគចរិយា ) ដោយសភាវៈ និង ដោយការប្រកបរួមគ្នានោះមិនមាន ។

ក្នុងអធិការនេះ សម្រាប់មោហៈ សូម្បីប្រព្រឹត្តទៅព្រមជាមួយរាគៈ ឬទោសៈ ដោយអំណាចការប្រកបរួមគ្នា ក៏សមគួរជាចរិយាមួយ ដោយទាក់ទងជាមួយការមានភាពក្រាស់(ក្នុងសន្តាន) មិនមែនចំពោះមោហៈតែម្យ៉ាងប៉ុណ្ណោះនោះទេ សូម្បីសទ្ធា ពុទ្ធិ និង វិតក្កៈ ក៏យ៉ាងនោះដូចគ្នា យ៉ាងណា សូម្បី មានះ កាលមានការប្រកបរួមគ្នាជាមួយរាគៈ ក៏សមគួរជាចរិយាម្យ៉ាងបាន យ៉ាងនោះដូចគ្នា ក៏ពិតហើយ កាលបើយ៉ាងនេះ ចំពោះធម៌ទាំងឡាយ មានរាគៈជាដើមទាំងនេះប៉ុណ្ណោះមានសភាវៈជាចរិយាមួយផ្នែកបាន ដូចធម៌ មានរាគៈ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា និងអវិជ្ជា មានសភាវៈជាអនុស័យបាន ព្រោះហេតុនោះ ទើបគ្មានមានះចរិយា ។

ព្រោះហេតុដែលលោកហៅចរិយាថា **បកតិ** ហើយ **បកតិ** គឺ សភាវៈ ។ ដោយពាក្យនេះនោះឯង ទើបគប្បីឃើញថា ជាការដែលលោកពិពណ៌នាហើយថា សូម្បីទិដ្ឋិ ក៏រកភាពជាចរិយាមួយមិនបាន ។ ចំណែកក្នុងអដ្ឋកថា ដើម្បីសម្តែងថា ទិដ្ឋិចរិយា ក៏ប្រជុំចុះក្នុងមោហចរិយានោះឯង ទើបលោកពោលពាក្យថា ព្រោះភាពដែលទិដ្ឋិមានមោហៈជាហេតុ ដូច្នេះជាដើម ។ ក្នុងពាក្យនោះ លោកបន្ថែមយកការប្រកបរួមគ្នាទុកដោយ **ច** ស័ព្ទ ដូច្នេះ ព្រោះទិដ្ឋិមានមោហៈជាហេតុ និងទិដ្ឋិប្រកបរួមគ្នាជាមួយមោហៈដូច្នេះ ។ ពាក្យថា **មានសប្បាយដូចម្តេច** គឺ មានសប្បាយមានសេនាសនៈជាដើម ដូចម្តេច ។

ពាក្យថា **អាចិណ្ណកម្មក្នុងជាតិមុន** គឺកម្មដែលប្រព្រឹត្តរឿយៗ ក្នុងជាតិមុនៗ ទាំងឡាយ ។ ពាក្យថា **អាចារ្យពួកខ្លះ** លោកពោលសំដៅយក ព្រះឧបតិស្សត្ថេរ ព្រោះថា ព្រះឧបតិស្សត្ថេរនោះ ពោលទុកយ៉ាងនោះ ក្នុងបករណ៍វិមុត្តិមគ្គ ។ **កិរ** ស័ព្ទ ក្នុងពាក្យថា **បុព្វេ កិរ** មានអត្ថថា **អរុចិសូចន** ( ប្រាប់ភាពមិនប្រពៃ គឺ មិនកាន់យក ) ។ ឈ្មោះថា **ប្រយោគដែលគួរប្រាថ្នា** បានដល់ កិរិយាដែលគួរ ពេញចិត្ត ។ ឈ្មោះថា **អ្នកច្រើនដោយកម្មល្អ** គឺ អ្នកដែលមានប្រក្រតីធ្វើកម្មល្អ ដោយច្រើន នឹងជាបុគ្គលរាគចរិតទៅប្រាសហើយក៏ទេ ព្រោះបុគ្គលដែលមិនលោភ តែច្រើនទៅដោយប្រយោគដែលគួរពេញចិត្ត និងកម្មដែលល្អក្នុងជាតិមុន មានហើយ ទាំងឃ្លាតចាកឋានសួគ៌ហើយ ចូលដល់ គឺ កើតក្នុងលោកនេះក៏មាន ។ ដោយ ពាក្យនោះ លោកសំដែងន័យនេះថា កាលគោលកំណត់ដល់ហេតុក្នុងជាតិមុន មិន មាន បុគ្គលទាំងនោះនឹងមានភាពជាមនុស្សល្មោភ និងមានរាគចរិយាដែលជាហេតុ នៃបុគ្គលលោភ ដោយគ្រាន់តែអាស្រ័យហេតុតាមដែលពោលទុកក៏ទេ ។

ពាក្យថា **បុគ្គលក្រៅពីនេះ** ប្រកបសេចក្តីបានថា បុគ្គលអ្នកច្រើនដោយកម្ម មានការកាប់សម្លាប់ជាដើម ហើយឃ្លាតចាកអំពីទុគ្គតិ មាននរកជាដើម មកឧប្បត្តិ ក្នុងលោកនេះ នឹងជាបុគ្គលទោសចរិត និង មោហចរិតប៉ុណ្ណោះទាំងអស់ក៏ទេ ។ គប្បីជ្រាបថា សូម្បីក្នុងពាក្យនេះ ព្រោះហេតុតាមដែលពោលហើយ ក្នុងភាពជា បុគ្គលក្រោធ និងក្នុងភាពជាបុគ្គលវង្វេង មិនពិតប្រាកដ ភាពជាបុគ្គលទោសចរិត និងបុគ្គលមោហចរិត ទើបរកភាពប្រាកដប្រជាមិនបាន លោកអាចារ្យ កាលនឹង សម្តែងថា គោលកំណត់ភាពពិតប្រាកដនៃធាតុទាំងឡាយ គ្រាន់តែជាប្រមាណ , គោលកំណត់នោះក៏មិនមាន កាលបើដូច្នោះ ដោយភាពអាច សូម្បីគោលកំណត់

ដោយអំណាចនោះតែម្យ៉ាង(ដែលពិតប្រាកដ) ក៏មានមិនបានដូច្នេះ ។ ទើបពោលថា ឈ្មោះថា គោលកំណត់ភាពពិតប្រាកដនៃធាតុទាំងឡាយ តាមន័យ ដែលលោកពោលទុកនោះ មិនមានដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **តាមន័យដែលលោកពោលទុកនោះឯង** គឺ តាមប្រការដែលលោកពោលទុកថា “ ព្រោះធាតុ ២ យ៉ាង ក្រាស់ ” ដូច្នេះជាដើមនោះឯង ។

ពាក្យថា **ក្នុងគោលកំណត់ដែលទាក់ទងជាមួយទោស** គឺ ក្នុងគោលកំណត់ចរិយាដោយទាក់ទងជាមួយទោសថា បុគ្គលជារាគចរិតជាដើម ព្រោះជាអ្នកច្រើនដោយទោស មានស្លេស្មជាដើម ពាក្យពោលដែលជាគោលកំណត់ដោយទាក់ទងជាមួយទោសនោះ មានពាក្យមុន និង ពាក្យក្រោយខុសគ្នា ព្រោះលោកពោលថា “ បុគ្គលដែលច្រើនដោយស្លេស្ម ជាបុគ្គលរាគចរិត ” ដូច្នេះហើយ ក៏ពោលថា “ បុគ្គលអ្នកច្រើនដោយស្លេស្ម ជាបុគ្គលមោហចរិត ” ដូច្នេះទៀត ពោលថា “ ច្រើនដោយខ្យល់ ជាបុគ្គលមោហចរិត ” ដូច្នេះហើយ ក៏ពោលថា “ ច្រើនដោយខ្យល់ ជាបុគ្គលរាគចរិត ” ដូច្នេះទៀត ។

ពាក្យថា **ពាក្យដែលមិនកំណត់ឲ្យដាច់ខាត** គឺ ពាក្យដែលពោលទុកមិនកំណត់ឲ្យដាច់ខាត ដោយបញ្ញាដែលជាអ្នកធ្វើការកំណត់ មានន័យថា ជាពាក្យពោលដែលមិនទាន់បានធ្វើការពិចារណា ។

ពាក្យថា **ក្នុងការសម្តែងដល់ធម៌ដែលក្រាស់** គឺ ក្នុងការសម្តែងដល់ធម៌ដែលក្រាស់ ដែលលោកកាន់យកក្នុងកថាពោលដោយវិបាក ។ ពាក្យថា “ **ដោយនិយាមនៃហេតុក្នុងភពមុន** ” គឺ ដោយនិយាមនៃហេតុ មានលោភៈជាដើម ដែល

ប្រព្រឹត្តទៅក្នុងភពមុន ។

ពាក្យថា **និយាម** គប្បីយល់ថា បានដល់ សភាវៈដែលចង់បានជាដើម ដែលមានជាប្រចាំសម្រាប់ធម៌ មានលោភៈជាដើមទាំងនោះឯង ។ បុគ្គលឈ្មោះថា **លោភុស្សទ** ព្រោះអត្ថថា មានលោភៈជាធម៌ដែលក្រាស់ មានន័យថា មានលោភៈក្រាស់ គឺ ច្រើនដោយលោភៈ ។ **ច** ស័ព្ទ ក្នុងពាក្យថា **អមោហុស្សទា ច** នេះ មានអត្ថថា រួបរួមៗ ដោយ **ច** ស័ព្ទនោះ លោករួមទុកដោយមិនមានសេសសល់ នូវប្រភេទនៃបុគ្គលដែលមានលោភៈក្រាស់ជាដើម ទាំង ១៤ នេះ ដែលលោកត្រូវការញែកជាប្រភេទមួយៗ និងដោយលាយឡំគ្នា ព្រោះបុគ្គលទាំងនោះក៏ឈានចុះបានក្នុងបុគ្គល ៦ ប្រភេទ តាមដែលពោលហើយនោះ ។ ក្នុងអធិការនេះ ភាពជាអ្នកមានលោភៈក្រាស់ជាដើម គប្បីឃើញថាជាផល ។

ឥឡូវនេះលោកអាចារ្យ បំណងសំដែងភាពតែមួយ និង ភាពលាយឡំគ្នានៃអ្នកដែលមានលោភៈក្រាស់ជាដើមទាំងអស់នោះ ដោយការចែក ទើបផ្ដើមពាក្យថា **យស្ស ហិ** ជាដើម ។ ពាក្យថា **ក្នុងខណៈព្យាយាមធ្វើកម្ម** គឺ ក្នុងពេលធ្វើកម្ម ។ ពាក្យថា **លោភៈជាធម្មជាតិមានកម្លាំង** គឺ លោភៈជាធម្មជាតិ ដែលក្រៃលែងដោយអំណាច ក្នុងការព្រមព្រៀងគ្នានៃបច្ច័យដែលកើតអំពីកម្មនោះ ។

ពាក្យថា **អលោភៈខ្សោយ** គឺ អលោភៈ ដែលជាបដិបក្ខចំពោះលោភៈនោះ មានកម្លាំងទុព្វល ។ សួរថា ក៏លោភៈ និង អលោភៈនេះ ជាសឹកសត្រូវប្រឆាំងដល់គ្នានិងគ្នា នឹងប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នាបានដូចម្ដេច ? ឆ្លើយថា សេចក្ដីនេះមិនគប្បីឃើញយ៉ាងនេះថា " ប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា " ។ តែថាដែលលោកពោលទុកយ៉ាងនេះ ព្រោះធ្វើនិកន្តិខណៈ( ខណៈដែលចង់បាន ) ឲ្យតាំងនៅ

ក្នុងចំណែកនៃសេចក្តីព្យាយាម ។ សូម្បីក្នុងបទដ៏សេសក៏មានន័យដូច្នេះ ។ បទថា **បរិយាទាតុំ** គឺ មិនអាចគ្របសង្កត់បាន ។ ពិតណាស់ អលោភៈដែលសម្បយុត្តជាមួយចេតនា ដែលប្រព្រឹត្តទៅ ទាក់ទងជាមួយភាពជាអ្នកលះបង់មិនបាន ដោយន័យថា " យើងមិនអាចឲ្យរបស់ដែលល្អយ៉ាងនេះ ដែលច្រើនយ៉ាងនេះ និងដែលថ្លៃយ៉ាងនេះបានឡើយ " ដូច្នេះ ជាដើមយ៉ាងណា អលោភៈនោះ រមែងមិនអាចគ្របសង្កត់លោភៈបានដោយល្អឡើយ ។ ឈ្មោះថា អទោសៈ និងអមោហៈមានកម្លាំង ក៏ព្រោះទោសៈ និងមោហៈមិនកើតឡើង និង ព្រោះការបានបច្ច័យដែលជាប្រភេទនោះ ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា លោកបង្វែរចាប់យកហេតុដែលបានពោលហើយថា ព្រោះ លោភៈ អទោសៈ និង អមោហៈ មានកម្លាំង និង ព្រោះ អលោភៈ ទោសៈ និង មោហៈ ខ្សោយកម្លាំងដូច្នេះនោះឯង ។

ពាក្យថា **បុគ្គលនោះ** គឺ បុគ្គលអ្នកព្រមព្រៀងដោយការៈនោះ ។

ពាក្យថា **ដែលកម្មនោះ** (ឲ្យហើយ) គឺ កុសលកម្មដែលមានលោភៈជាដើម ជាឧបនិស្ស័យនោះឲ្យហើយ ។ ពាក្យថា **មានបកតិជាសុខ** គឺ មានភាពត្រជាក់លោកពោលដល់ន័យនោះៗឯង ដោយបរិយាយថា មិនក្រោធ ។

ពាក្យថា **តាមន័យមុននោះឯង** គឺ តាមទំនងនៃន័យដែលបានពោលហើយក្នុងខាងដើម ។

គប្បីជ្រាបដល់ អត្ថន័យដែលនៅមានចំណែកសល់ក្នុងវារៈនោះៗ តាមសមគួរយ៉ាងនេះថា អលោភៈ និង អទោហៈ ដែលខ្សោយ រមែងមិនអាចគ្របសង្កត់លោភៈ និង ទោសៈបាន ចំណែកអមោហៈដែលមានកម្លាំង រមែងគ្របសង្កត់មោហៈបានដូច្នេះ ។

ពាក្យថា **អាក់អន់** គឺ ក្រោធ ។ ពាក្យថា **យឺតយូរ** ( ស្ពឹក ) គឺ មានបញ្ញាខ្សោយ ។

បទថា **សីលកោ** បានដល់ មានប្រក្រតីជាសុខ ។

ក្នុងបណ្ដាចរិយាទាំងនេះ ក្នុងចំណែកអកុសលនោះឯងមាន ៧ វារៈ ដោយទាក់ទងជាមួយលោភៈជាដើមក្រាស់ គឺ វារៈដែលមានធម៌តែម្យ៉ាង ក្រាស់ មាន ៣ វារៈ គឺ ជាប់ទាក់ទង ដោយលោភៈ១ ដោយទោសៈ១ ដោយមោហៈ១ , វារៈដែលមានធម៌ ២ យ៉ាង ក្រាស់ មាន ៣ វារៈ គឺ ទាក់ទង ដោយលោភៈនិងទោសៈ១ ទាក់ទងដោយលោភៈនិងមោហៈ១ ទាក់ទងដោយទោសៈនិងមោហៈ១ , វារៈដែលមានធម៌ ៣ យ៉ាង ក្រាស់ មាន ១ វារៈ គឺ ទាក់ទងដោយ លោភៈ ទោសៈ និង មោហៈ ដូច្នេះ ។

ក្នុងចំណែកកុសលក៏មាន ៧ វារៈ យ៉ាងនោះដូចគ្នា ដោយទាក់ទងជាមួយអលោភៈជាដើមដែលក្រាស់ ទើបរួមបាន ១៤ វារៈ ។ ក្នុងវារៈទាំងនោះ វារៈដែលមានទោសៈក្រាស់ វារៈដែលមានមោហៈក្រាស់ និង វារៈដែលមានទោសៈ និង មោហៈក្រាស់ លោកកាន់យកហើយដោយ វារៈទី៣ វារៈទី២ និង វារៈទី១ តាមលំដាប់ ក្នុងចំណែកកុសលដែលមកហើយថា អលោភៈ ទោសៈ និងអមោហៈ មានកម្លាំង , អលោភៈ អទោសៈ និង មោហៈ មានកម្លាំង , អលោភៈ ទោសៈ និងមោហៈ មានកម្លាំងដូច្នេះ យ៉ាងនោះដូចគ្នា វារៈដែលមានអទោសៈក្រាស់ វារៈដែលមានអមោហៈក្រាស់ វារៈដែលមានអទោសៈនិងអមោហៈក្រាស់ លោកកាន់យកហើយដោយ វារៈទី៣ វារៈទី២ និង វារៈទី១ (តាមលំដាប់)។ ក្នុងចំណែកអកុសលដែលមកហើយថា **លោភៈ អទោសៈ** និង **មោហៈ**មានកម្លាំង , **លោភៈ**

***ទោសៈ*** និង ***អមោហៈ*** មានកម្លាំង , ***លោភៈ អទោសៈ*** និង ***អមោហៈ*** មានកម្លាំង ដូច្នេះឯង លោកធ្វើតែមួយឲ្យជា ៣ វារៈ ក្នុងចំណែកអកុសល និងចំណែកកុសលឲ្យចូលគ្នា ហើយសំដែងវារៈទាំងឡាយ ទុក ៨ ប៉ុណ្ណោះ ។

ចំណែក ៤៩ វារៈដទៃ មានវារៈដែលមានលោភៈ និង អលោភៈក្រាស់ជាដើម ដោយទាក់ទងជាមួយការលាយឡំគ្នានៃវារៈ២ចំណែក ដែលគប្បីសម្ដែងទុកឯណា វារៈទាំងនោះ លោកមិនបានសំដែងទុក ព្រោះរកមិនបានឡើយ ។

ពិតណាស់ សេចក្ដីថា ធម្មជាតិមួយដែលមានការតាំងចុះក្នុងការបន្តជាមួយធម្មជាតិដទៃទៀត ថា “ ទាំងលោភៈក៏មានកម្លាំង ទាំងអលោភៈក៏មានកម្លាំង ” ដូច្នេះ រមែងមិនត្រឹមត្រូវឡើយ ព្រោះថា ភាវៈដែលធម្មជាតិទាំងនេះមានកម្លាំង ឬខ្សោយកម្លាំង ក៏ព្រោះទាក់ទងជាមួយធម៌ដែលជាបដិបក្ខ ឬ ដោយទាក់ទងជាមួយធម៌ដែលកើតរួមគ្នា ក្នុងបណ្ដាធម៌ដែលជាបដិបក្ខគ្នា និងកើតរួមគ្នាទាំងនោះ ពោលដោយការទាក់ទងជាមួយធម៌ដែលជាបដិបក្ខគ្នាមុន ភាវៈដែលលោភៈមានកម្លាំងក៏ព្រោះភាពដែលមិនត្រូវអលោភៈគ្របសង្កត់ យ៉ាងនោះដូចគ្នា ភាវៈដែលទោសៈនិងមោហៈមានកម្លាំង ក៏ព្រោះភាពដែលមិនត្រូវអទោសៈ និងអមោហៈគ្របសង្កត់។

ចំណែកភាវៈដែលអលោភៈជាដើមមានកម្លាំង ក៏ព្រោះការគ្របសង្កត់លោភៈជាដើមបាន និងព្រោះធម៌ដែលមានអលោភៈជាដើមទាំងអស់ ជាធម៌ដែលកើតរួមគ្នាបាន ដោយអំណាចការប្រព្រឹត្តទៅគ្របសង្កត់ធម៌ដែលមានជាតិស្មើគ្នា ( ក្នុងទីនោះៗ អលោភៈមានជាតិស្មើជាមួយលោភៈ អទោសៈមានជាតិស្មើជាមួយនឹងទោសៈ អមោហៈមានជាតិស្មើជាមួយនឹងមោហៈ) ។ ព្រោះហេតុនោះ ទើបលោកពោលទុកក្នុងអដ្ឋកថា ថា “ លោភៈមានកម្លាំង អលោភៈខ្សោយ , អទោសៈ និង

អមោហៈមានកម្លាំង ទោសៈនិងមោហៈទន់ខ្សោយ " ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ភាវៈដែលធម៌ទាំងនោះទន់ខ្សោយ និងមានកម្លាំងនោះ ក៏ព្រោះភាពដែលអធ្យាស្រ័យត្រូវឧបនិស្សយប្បច្ច័យក្នុងជាតិមុនៗអប់រំហើយដោយអាការនោះៗ ។

ពាក្យថា **បុគ្គលណាដែលលោកហៅថាបុគ្គលលោភ** មានន័យថា ក្នុងរឿងសំដែងដល់ធម៌ដែលក្រាស់ បុគ្គលណាដែលលោកហៅថា " **បុគ្គលលោភ** " ក្នុងវិចារដែលទាក់ទងជាមួយនឹងចរិយានេះ បុគ្គលនេះគប្បីជ្រាបថា **បុគ្គលរាគចរិត** ។

បទថា **ទុដ្ឋទន្ធា** មានន័យថា បុគ្គលដែលលោកហៅថា " ទន់ខ្សោយ និងយឺតយូរ " បានដល់ បុគ្គលទោសចរិត និង បុគ្គលមោហចរិតតាមលំដាប់ ។

ពាក្យថា **មានបញ្ញា** គឺ មានបញ្ញាក្រៃលែង ។ សូម្បីមានសទ្ធា និង វិតក្កក៏ជាហេតុឲ្យហៅថា **បុគ្គលពុទ្ធិចរិត** ។ ភាវៈដែល អលោភៈ និង អទោសៈមានកម្លាំង មានបានដោយការវៀរភាពមានសទ្ធាជាឧបនិស្សយប្បច្ច័យមិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដែលហៅថា មិនលោភនិងមិនប្រទូស្តក៏គឺបុគ្គល **សទ្ធាចរិត** ព្រោះភាពជាអ្នកមានប្រក្រតីជ្រះថ្លាដូច្នេះ ។

ក៏ន័យនេះឯង លោកពោលទុកជាសាធារណៈ លោកអាចារ្យបំណងសំដែងដល់បុគ្គល សូម្បីដែលជាពុទ្ធិចរិតជាដើម ដោយអំណាចនៃគោលកំណត់នៃហេតុក្នុងភពមុន ដែលបានកើតហើយនោះឯង ទើបពោលថា **យថា វា** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដែលមានអមោហៈជាបរិវារ** គឺ ដែលមានអមោហៈហែហម មានន័យថា ដែលបញ្ញាតាក់តែងហើយ ដោយជាឧបនិស្សយប្បច្ច័យ និងដោយការប្រកបរួមគ្នា ។

សូម្បីក្នុង៣បទដ៏សេស ក៏មានន័យដូច្នេះឯង ។ ក្នុងពាក្យថា **ដែលមានធម៌លាយឡំគ្នា មានលោភៈជាដើមជាបរិវារ** មានសេចក្តីថា ដែលមានធម៌ត្រូវលោភៈលាយឡំ មិនជំទាស់ដល់គ្នានិងគ្នា មាន លោភៈ និង មោហៈ ជាដើមជាបរិវារ ។ តែគប្បីជ្រាបថា ជាការមិនជំទាស់គ្នាដោយមិនប្រព្រឹត្តទៅទាក់ទងគ្នាជាគូ ។ ពិតយ៉ាងនោះ គោត្តនៃសទ្ធានុសារី និង គោត្តនៃធម្មានុសារី មានសភាវៈផ្សេងគ្នា ។

មួយ៉ាងទៀត សូម្បីចរិយាលាយឡំគ្នា បណ្ឌិតក៏គប្បីព្រមទទួលបាន ដោយពិតប្រាកដ ព្រោះចរិយាសម្រេចដោយគោលកំណត់នៃហេតុក្នុងជាតិមុន ។ ហើយការសម្តែងធម៌ដែលក្រាស់ ដែលដំណើរទៅហើយយ៉ាងនោះ ក៏គប្បីព្រមទទួលបានដូចគ្នា ព្រោះធម៌ទាំងឡាយមានលោភៈ អលោភៈជាដើម មានភាពជាបច្ច័យដល់វិបាកតាមសមគួរ ។ ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរ ទើបពោលទុកក្នុងបដិសម្ភិទាមគ្គថា " ក្នុងខណៈនៃបដិសន្ធិដែលសម្បយុត្តជាមួយញាណ ក្នុងគតិ-សម្បត្តិ ការឧប្បត្តិរមែងមានព្រោះបច្ច័យនៃហេតុ ៨ យ៉ាង អ្វីខ្លះ ? ក្នុងជវន-ខណៈនៃកុសលកម្ម កុសលហេតុ ៣ រមែងជាសហជាតប្បច្ច័យដល់ចេតនាដែលកើតឡើងក្នុងខណៈនោះ ព្រោះហេតុនោះ ទើបពោលបានថា សង្ខារទាំងឡាយរមែងមាន សូម្បីព្រោះកុសលមូលជាបច្ច័យ ។

**និកន្តិក្ខណៈ** (ខណៈនៃលោភៈ) អកុសលហេតុ២ រមែងជាសហជាតប្បច្ច័យដល់ចេតនាដែលកើតឡើងក្នុងខណៈនោះ ព្រោះហេតុនោះ ទើបពោលបានថា សង្ខារទាំងឡាយរមែងមាន សូម្បីព្រោះអកុសលមូលជាបច្ច័យ ។

**ក្នុងបដិសន្ធិខណៈ** អព្យាកតហេតុ ៣ រមែងជាសហជាតប្បច្ច័យដល់ចេតនាដែលកើតឡើងក្នុងខណៈនោះ ព្រោះហេតុនោះ ទើបពោលបានថា វិញ្ញាណរមែង

មាន សូម្បីព្រោះនាមរូបជាបច្ច័យ ។ នាមរូបរមែងមាន ព្រោះ វិញ្ញាណជាបច្ច័យ ដូច្នេះជាដើម ។

ដោយនិយាមនៃហេតុក្នុងកពមុន បុគ្គលដែលមានហេតុ ២ មិនមានបញ្ញាដឹងច្បាស់ដូចជាបុគ្គលដែលមានហេតុ ៣ ទេ ។ ហើយបុគ្គលដែលមិនមានហេតុក៏មិនមាន **នេបក្កប្បញ្ញា** ( បារិហារិកប្បញ្ញា ) គឺ ការដឹងថា គួរធ្វើយ៉ាងនេះ យ៉ាងនេះ ដូចជាបុគ្គលដែលមានហេតុ ២ ។ ដោយប្រការដូចពោលមកនេះ ក្នុងអធិការនេះ ទើបគប្បីសម្រេចបានថា បុគ្គលអ្នកមានលោភៈក្រាស់ជាដើម រមែងជាបុគ្គលរាគចរិតជាដើម ។ លោកអាចារ្យពោលថា **ឯវំ លោភាទីសុ** ជាដើម ដើម្បីសម្តែងទំនាក់ទំនង និង ជាការបញ្ជាក់ដល់អត្ថន័យតាមដែលបានពោលហើយ ។

បទថា **តត្រ** ប្រែថា ក្នុងពាក្យសួរ ពាក្យថា **ន័យ** គឺន័យដើម្បីការដឹងបាន។ អត្ថន័យដែលលោកសម្តែងទុកដោយបុគ្គលាធិដ្ឋាន បណ្ឌិត ក៏រមែងដឹងបានដោយធម៌ជាប្រកផ្លូវនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោល ដោយធម្មាធិដ្ឋានថា បណ្ឌិតគប្បីសម្តែងចរិយាទាំងឡាយដូច្នេះ ។ ពាក្យថា **ដោយការដើរទៅតាមប្រក្រតី** គឺ ដោយការដើរទៅដល់សភាវៈ ( តាមសេចក្តីពិត ) មិនក្លែងធ្វើ ។

បទថា **ចាតុរិយេន** គឺ គួរស្រឡាញ់ ។ ពាក្យថា **ផតកណ្តាល** បានដល់ត្រង់កណ្តាលបាតជើងមិនប៉ះផែនដី ។ បទថា **ខណន្តោ វិយ** ប្រែថា ដូចជីកផែនដីដូច្នោះ ។ ពាក្យថា **ស្នាមកញ្ចុំ** មានន័យថា ក្នុងសម័យដែលដាក់ជើងចុះ រមែងដូចជាកន្ត្រាក់ជើងចូលក្នុងដូច្នោះ ។ ព្រោះហេតុនោះ ស្នាមជើងរបស់បុគ្គលនោះទើបជាស្នាមកញ្ចុំ (ខ្ញាំ) គឺ ជាស្នាមអូសមកខាងក្រោយ ។

បទថា **បរិព្យាកុលាយ** ប្រែថា ភ្ញាក់ៗ ផ្អើលៗ ដោយជុំវិញ ។

ពាក្យថា **ដូចស្រៀវខ្លាច** គឺ ដូចនៅស្ងៀមមិនបាន ។ អាចារ្យពួកខ្លះពោលថា ដូចភ័យខ្លាច ។

បទថា **សហសានុបីឡិតំ** គឺ ជាស្នាមសង្កត់ទៅរហ័សៗនោះឯង ទាំងចុងជើង និង កែងជើង ( ក្នុងទីនេះប្រែហួសថា ខ្ចាត់ខ្ចាយ ) ។ ពាក្យថា **របស់លោកអ្នកមានគ្រឿងប្រក់បាំងរបើកហើយ** បានដល់ លោកអ្នកដែលមានគ្រឿងប្រក់បាំងរបើកចេញបាន ដោយវិសេសហើយ គឺ របស់លោកអ្នកដែលលះបង់កិលេសបានហើយ ។ នាងព្រាហ្មណី ឃើញស្នាមព្រះបាទរបស់ព្រះមានព្រះភាគទើបពោលថា ស្នាមជើងដូច្នេះ នេះជាដើម ។

ពាក្យថា **គួរជ្រះថ្លា** គឺ នាំមកនូវភាពជ្រះថ្លា ។ ពាក្យថា **មានអាការផ្អែមល្ហែម** គឺ មានអាការគួរប្រាថ្នា ។ ពាក្យថា **មានអាការរឹង** គឺ មានអាការមិនទន់ភ្លន់ ។

បទថា **អគរមានោ** ប្រែថា មិនប្រញាប់ប្រញាល់ មានសេចក្ដីថា សន្សឹមៗ ( ក្រោកឈរ ) ។ ពាក្យថា **ប្រមូល** ( អវយវៈតូចធំ ) គឺ ដាក់ចុះទុកដោយល្អនោះឯង គឺ មិនប្រវេងប្រវាង ។ បទថា **និបជ្ជិត្វា** ប្រែថា ប្រាសខ្លួនដេក បានដល់ ដាក់ខ្លួនចុះលើទីដេកដោយអាការប្រាសខ្លួនដេក ដែលមានការសណ្ដូករាង-កាយជាលក្ខណៈ ហើយរមែង ដេកលក់ ។ ពាក្យថា **បោលកាយ** គឺ មិនមានកាយប្រាសទៅខាងនេះខាងនោះ តែគឺ ប្រាសខ្លួនចុះដោយរហ័ស ហាក់ដូចមិនមានអំណាច (មិនមានកម្លាំង) ដូច្នោះ ។ ពាក្យថា ( ក្រាលទីដេក ) **ជារូបគួរស្អប់** គឺ ទ្រង់ទ្រាយគួរស្អប់ ។ ពាក្យថា **មានកាយប្រវេងប្រវាង** គឺ មានអវយវៈតូចធំបោះទៅខាងនេះ បោះទៅខាងនោះ ។ បទថា **សម្បរិវត្តកំ** ផ្លាស់ជា **សម្បរិវត្តិត្វា**

ប្រែថា ពោសទៅមក ។ ឈ្មោះថា **ធ្វើឲ្យប្រឡាក់** គឺ ធ្វើខ្វាច់ និង សំរាមឲ្យប្រឡាក់ ។ ពាក្យថា **ជាអ្នកមានប្រក្រតីធ្វើបានល្អិតល្អន់រៀបរយ និង ដោយគោរព** គឺ ជាអ្នកមានប្រក្រតីធ្វើបានជំនាញល្អ ស្អាតបាត ប្រកបដោយរបៀបរៀបរយ និងមានការតាក់តែងល្អ ។ ពាក្យថា **ជាអ្នកមានប្រក្រតីធ្វើបានមាំទាំ រឹងប៉ឹង តែមិនរៀបរយ** គឺ ជាអ្នកមានប្រក្រតីធ្វើបាន មាំទាំ មិនរយីករយាក តែមិនរៀបរយ ។ ឈ្មោះថា **អបរិច្ឆិន្ន** បានដល់ ឲ្យសម្រេចល្អិតល្អន់មិនបាន ។ ពាក្យថា ( ធ្វើឲ្យជាពំនូត ) **ពេញមាត់** គឺ ជំពេញមាត់ ។ បទថា **អរសបដិសំវេទី** ប្រែថា មិនជាអ្នកស្គាល់រស ។ ពាក្យថា **សល់គ្រាប់បាយទុកក្នុងភាជន៍** គឺ សល់គ្រាប់បាយទុកក្នុងភាជន៍ដែលដាក់អាហារ ។ ពាក្យថា **ធ្វើមាត់ឲ្យប្រឡាក់** គឺ ធ្វើមាត់ខាងក្រៅឲ្យប្រឡាក់ ។ ពាក្យថា **ដូចមានអាកប្បកិរិយាហត់នឿយ** គឺ ដូចជាអ្នកដល់នូវភាពលំបាក ព្រោះធន់មិនបាននូវរូបនោះ ។ បទថា **អញ្ញាណុបេក្ខាយ** ប្រែថា ដោយការព្រងើយកន្តើយដែលជាការមិនដឹង ។ អាចារ្យពួកខ្លះពោលថា ដោយឧបេក្ខាដែល ហៅថា **ការមិនដឹង** ។

ក្នុងបណ្តាទោសទាំងឡាយ មានមាយាជាដើម :-

- **មាយា** ការបោកបញ្ឆោត មានការបិទបាំងទោសដែលមាន ជាលក្ខណៈ ។
- **សាឋេយ្យ** អំនួត មានការប្រកាសគុណដែលមិនមានជាលក្ខណៈ។
- **មានះ** ការប្រកាន់ខ្លួន មានការលើកខ្លួនជាលក្ខណៈ ។
- **បាបិច្ឆតា** ប្រាថ្នាលាមក មានការមិនដឹងប្រមាណក្នុងការទទួល ដោយការសម្តែងគុណដែលមិនមានជាប្រចក្ខផ្លូវជាលក្ខណៈ
- **មហិច្ឆតា** ប្រាថ្នាច្រើន មានការមិនដឹងប្រមាណក្នុងការទទួល ដោយការ

សម្តែងគុណដែលមានជាប្រកដ្ឋ ជាលក្ខណៈ ។

- **អសន្តុដ្ឋិតា** ការមិនសន្តោស មានការមិនត្រេកអរតាមលាភរបស់ខ្លួនជាលក្ខណៈ

ឈ្មោះថា **សិង្គ** ( សេចក្តីស្នេហា ) ព្រោះអត្ថថា ចាក់ទម្លុះ បានដល់កិលេសសិង្គ ពោលគឺ សេចក្តីត្រេកត្រអាលដែលជាធម៌របស់អ្នកស្រុក ។

ឈ្មោះថា **ចាបល្យ** ( ភាពសាវ៉ា ) គឺ សេចក្តីល្មោភដែលប្រព្រឹត្តទៅទាក់ទងដោយការតាក់តែងរាងកាយ និង បរិក្ខារ មានចីវរជាដើមរបស់ខ្លួន ។

ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **ឯវមាទយោ** នេះសង្គ្រោះយកទោសទាំងឡាយមាន **អហិរិក**( ការមិនខ្មាសបាប ), **អនោត្តប្ប**( ការមិនខ្លាចបាប ) , **មទ**( សេចក្តីស្រវឹង ) , **បមាទ**( សេចក្តីប្រមាទ ) ជាដើម ។

- **ឧបនាហ** ការចងកំហឹង មានការចូលទៅចងទុកនូវកំហុសអ្នកដទៃ ជាលក្ខណៈ ។

- **មក្ខ** ការរមិលគុណ មានការលុបគុណរបស់អ្នកដទៃជាលក្ខណៈ ។

- **បលាស** ការប្រណាំងវាសនា មានការចាប់គូប្រៀបផ្ទឹម ជាលក្ខណៈ ដូចធ្វើគុណរបស់អ្នកដទៃឲ្យប្រាកដ ហើយកម្ចាត់ចោលដូច្នោះ ។

- **ឥស្សា** ការច្រណែន មានការច្រណែនសម្បត្តិអ្នកដទៃជាលក្ខណៈ ។

- **មច្ឆរិយ** សេចក្តីកំណាញ់ មានការលាក់លៀមសម្បត្តិរបស់ខ្លួនជាលក្ខណៈ

ដោយ **អាទិ** សព្ទ ក្នុងអធិការនៃបុគ្គលទោសចរិតនេះ គប្បីឃើញថាសង្គ្រោះយកទោសទាំងឡាយមាន **ទោវចស្សតា**(ភាពជាអ្នកប្រដៅក្រ) **បាបមិត្តតា** ( ភាពជាអ្នកមាន មិត្តអាក្រក់ជាដើម ។

**ថីន** ការរួញរាមិនមានឧស្សាហៈ , **មិទ្ធ** ការខ្ជិលច្រអូសមិនមានសេចក្ដីត្រេកអរ , **ឧទ្ធច្ច** ការមិនស្ងប់នៃចិត្ត , **កុក្កុច្ច** ការក្ដៅក្រហាយចិត្ត , **វិចិកិច្ឆា** សេចក្ដីសង្ស័យ , **អទានគ្គាហិតា** ការប្រកាន់មាំ មិនត្រូវគន្លង , **ទុប្បដិនិស្សគ្គិតា** ភាវៈដែលប្រកាន់ខុសនៃបុគ្គលដែលកំពុងប្រកាន់ ជាវត្ថុដែលអ្នកដទៃដោះបានដោយកម្រ ។

ដោយ **អាទិ** សព្ទ (ដែលប្រែថា ជាដើម) ក្នុងអធិការនៃបុគ្គលមោហចរិតនេះ គប្បីឃើញថា សង្គ្រោះយកទោសទាំងឡាយមាន **មុដ្ឋសច្ច** ( ការវង្វេងភ្លេចសតិ ) **អសម្បជញ្ញៈ** ( ការមិនដឹងខ្លួន ) ជាដើម ។

ពាក្យថា **មុត្តចាគតា** ( ភាពជាអ្នកលះបង់បានដាច់ស្រឡះ ) គឺ ភាពជាអ្នកលះបង់បាន មិនជាប់ជំពាក់ បានដល់ បរិច្ចាគបានមិនជាប់ជំពាក់ ។ គប្បីជ្រាបថា **អកុសលក្ខន្ធ** ទាំងឡាយប្រព្រឹត្តទៅ ក៏ដូចទោសទាំងឡាយ មានមាយាជាដើមប្រព្រឹត្តទៅ , កុសលក្ខន្ធទាំងឡាយប្រព្រឹត្តទៅ ក៏ដូចគុណទាំងឡាយ មានភាពជាអ្នកប្រាថ្នាដើម្បីឃើញព្រះអរិយៈទាំងឡាយជាដើម ប្រព្រឹត្តទៅ ។

វត្ថុ ៣ ( ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ) ឈ្មោះថា ឋានៈដែលគួរជ្រះថ្លា ។ ទុក្ខទាំងឡាយ មានជាតិជាដើម ( ជាតិ ជរា ព្យាធិ មរណៈ ។ល។ ) ឈ្មោះថា ឋានៈដែលគួរសង្វេគ ។

ពាក្យថា **ក្នុងការប្រកបរឿយៗ នូវកុសល** គឺ ក្នុងការចម្រើនកុសលធម៌ ។ ការដែលត្រិះរិះដល់កិច្ចទាំងឡាយ ក្នុងន័យថា “ យើងនឹងធ្វើយ៉ាងនេះ និង យ៉ាងនេះ ” ដូច្នេះ ឈ្មោះថា **រត្តិធូមាយនា** ( ពេលយប់ហុយផ្សែង ) ។ ការមិនខ្វល់ខ្វាយក្នុងកិច្ចដែលត្រិះរិះទុកយ៉ាងនោះៗ ក្នុងពេលថ្ងៃ ឈ្មោះថា **ទិវាបជ្ជលនា**

( ពេលថ្ងៃមិនធេះជាអណ្តាត ) ។

ពាក្យថា **ហុរាហុរង្គជាវនា** (ការច្រំទៅខាងនេះខាងនោះ) គឺ ការបណ្តោយចិត្តទៅខាងនេះខាងនោះក្នុងអារម្មណ៍នោះៗ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា “ ចិត្តនេះត្រាច់ចារិកទៅមុន តាមសេចក្តីប្រាថ្នាក្នុងទីដែលសុខស្រួល ” ដូច្នេះ និង “ ចិត្តនេះរមែងស្ទុះទៅ ” ដូច្នេះ ។

ក៏ក្នុងបណ្តាហេតុឲ្យដឹងចរិយាទាំងឡាយ មានការប្រព្រឹត្តទៅនៃធម៌ និង អាការ មានការមើលជាដើម មិនអាចពោលបានថា មិនបានមកក្នុងព្រះបាលី និង អដ្ឋកថាឡើយ ព្រោះហេតុនោះ ទើបលោកពោលថា **សព្វាការេន** តែព្រោះហេតុដែល.... ដោយអាការទាំងពួងដូច្នេះជាដើម គឺ មានអធិប្បាយថា សូម្បីដែលមកហើយ ( ក្នុងព្រះបាលី និង អដ្ឋកថា ) ក៏មានដូចគ្នាបន្តិចបន្តួច ។ លោកអាចារ្យពោលថា “ បណ្ឌិតមិនគួរជឿកាន់យកជាសារៈ ” ដូច្នេះហើយ កាលនឹងសម្តែងដល់ហេតុក្នុងសេចក្តីនោះ ទើបពោលថា **រាគចរិតស្ស ហិ** ព្រោះធម្មជាតិទាំងឡាយមានឥរិយាបថជាដើម ដែលពោលទុកសម្រាប់បុគ្គលរាគចរិតដូច្នេះជាដើម ។

ពាក្យថា **ដែលទៅដោយការមិនប្រមាទ** គឺ ដែលមានប្រក្រតី មិនប្រមាទដោយបដិបត្តិនូវសេចក្តីស្ងប់ស្ងៀមក្នុងឥរិយាបថនោះៗ ។

ពាក្យថា **ឥរិយាបថជាដើម មានលក្ខណៈផ្សេងៗគ្នា** គឺ ឥរិយាបថមានការដើរជាដើមដែលគួរស្រឡាញ់ មិនគួរស្រឡាញ់ យឺត លឿន ។ ពាក្យថា **នឹងកើត** ( ឥរិយាបថជាដើម ដែលមានលក្ខណៈផ្សេងគ្នា ) **រកមិនបាន** គឺ មិនត្រឹមត្រូវ ។ ពាក្យថា **សាកសួររក ទើបនឹងជ្រាប** គឺ សាកសួរដល់ហេតុ មានការប្រព្រឹត្តទៅនៃធម៌ជាដើម ក៏នឹងអាចជ្រាបបាន ។

ឈ្មោះថា **សប្បាយ** បានដល់ វត្ថុដែលជាប្រយោជន៍ មានន័យថា ដុស ខាត់កិលេស ។ ពាក្យថា **ដែលមានកម្រាលមិនបានលាងជម្រះ** គឺ ដែលមាន កម្រាលមិនស្អាត ។ ពាក្យថា **តាំងនៅផ្ទាល់លើដី** គឺ តាំងនៅផុតពីផ្ទៃដី ប្រាស ចាកផ្ទៃដី ។

ចំណែកខាងក្រោមនៃជើងគ្រែដែលទេរទៅម្ខាង ដែលមិនបានធ្វើជញ្ជាំង និង មិនបានពង្រាបដី ឈ្មោះថា ញកក្តីដែលមិនបានរៀបចំ ។ ពាក្យថា **ពោរពេញទៅ ដោយប្រចៀវ** គឺ ពោរពេញទៅដោយប្រចៀវខ្ទួនតូចៗ ដែលសំយុងក្បាលចុះ ។

បទថា **ឱលុគ្គ វិលុគ្គំ** ប្រែថា បាក់ៗ បែកៗ ។ ពាក្យថា **ហួតហែង** គឺ ដែលសោះកក្រោះ រ៉ុងៗ ប្រាសចាកម្ទប់ និង ទឹក ។ ឈ្មោះថា គួរភិតភ័យ ដោយភ័យមាន សីហៈ និង ខ្លាធំ ជាដើម ។ បទថា **ទុរូបំ** ប្រែថា គួរ ស្អប់ ។ បទថា **ទុព្វណ្ណំ** ប្រែថា មានពណ៌មិនស្អាត ឬ មានទ្រង់ទ្រាយអាក្រក់ ។ **នំ** ដែលគេធ្វើដោយអាការដូចសំបុកចាប ឈ្មោះថា នំសំបុកចាប ។ ពាក្យថា **មាន សម្លស្សរើងដូចព្រាលស្រស់** គឺមានសម្លស្បជាទុក្ខ ដូចផ្សាំងសំពត់ព្រាលស្រស់ ។ សំពត់ស្មៀក សំពត់ដណ្តប់ ឈ្មោះថា រក្សាលំបាក ក៏ព្រោះភាពដែលធ្ងន់ និង ព្រោះត្រូវដេរប៉ះ ជាបំណះៗ ។ ពាក្យថា **ដែលត្រូវបោះធ្លុះទៅដោយមិន និង កន្ទាស់** គឺ ដែលមានភាពស្អាតត្រូវទម្លាយដោយ មិន និង កន្ទាស់ ។ នេះជា សប្បាយសម្រាប់បុគ្គលរាគចរិត អធិប្បាយថា ដោយប្រការយ៉ាងនេះ ទីងមិន មានការប្រាកដឡើងនៃកិលេស សូម្បីក្នុងបុគ្គលដ៏សេស ក៏មានន័យដូចគ្នា ។

បទថា **ទិសាមុខំ** ប្រែថា បែរមុខត្រង់ទិស អធិប្បាយថា បែរមុខទៅកាន់ទិស ដែលស្រឡះ ។ ពាក្យថា **កសិណធំ** គឺ ដួងកសិណដែលធំ ។ ក្នុងបណ្តាសប្បាយ

ទាំងឡាយ មានសេនាសនៈជាដើម សប្បាយដ៏សេស ដែលគួរពោលទុក សម្រាប់បុគ្គលមោហចរិតឯណា សប្បាយនោះ ក៏ដូចគ្នានឹងការដែលលោកពោលទុកសម្រាប់បុគ្គលទោសចរិតដែរ ។

ឈ្មោះថា នឹងជាបច្ច័យដល់ការស្ទុះទៅនៃវិតក្ក សេចក្ដីនោះរមែងដូចដែលមានដល់ព្រះមេឃិយត្ថេរ ដូច្នោះ ។ បទថា **ទរីមុខេ** ប្រែថា ក្នុងញកភ្នំ ។

ពាក្យថា **វង់កសិណតូចៗ** បានដល់ វង់កសិណទំហំប៉ុនត្បាល់ ឬ ផ្ដិល ។

**បរិច្ឆេទ** ស័ព្ទ ( ប្រែថា ការកំណត់ ) គប្បីប្រកបទុកត្រឹមតែមួយបទថា **បភេទបរិច្ឆេទតោ** ដោយការកំណត់ដល់ប្រភេទ , **និទានបរិច្ឆេទតោ** ដោយការកំណត់ដល់ហេតុ , **វិភាវនបរិច្ឆេទតោ** ដោយការកំណត់ដល់ការសម្ដែង , **សប្បាយបរិច្ឆេទតោ** ដោយការកំណត់ដល់វត្ថុដែលសប្បាយ ។

ពាក្យថា **ការសំដែង** គឺ ការសំដែងដើម្បីឲ្យដឹងដោយន័យថា " បុគ្គលនេះជាបុគ្គលរាគចរិត " ដូច្នេះជាដើម ។ លោកអាចារ្យពោលថា កម្មដ្ឋានដែលអនុកូលចំពោះចរិយា ខ្ញុំម្ចាស់មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ទុកដោយអាការទាំងពួងមុន ដូច្នេះ ព្រោះត្រឹមតែកសិណ និង អនុស្សតិដ្ឋានខ្លះ ៗ ប៉ុណ្ណោះ ដែលលោកបំណងពោលទុក ។

" *សេចក្ដីសន្ដោស គឺជា កំពូលនៃទ្រព្យសម្បត្តិទាំងពួង* "

**( ចប់ មហាដីកា )**

# សម្តែងចំនួនកម្មដ្ឋាន

សេចក្តីដែលពោលមកនេះ ជាសេចក្តីពិស្តារនៃចរិយាដែលមកក្នុងពាក្យថា “ ( កម្មដ្ឋាន ) **ដែលអនុកូលដល់ចរិយារបស់ខ្លួន** ” នោះ ដោយកំណត់ ប្រភេទ ហេតុ វិធីប្រាប់ និង វត្ថុដែលជាទីសប្បាយ ។

តែកម្មដ្ឋានដែលអនុកូលដល់ចរិយា មិនទាន់បានធ្វើឲ្យជាក់ច្បាស់ដោយអាការទាំងពួងមកមុន ព្រោះថា កម្មដ្ឋាននោះ នឹងមានច្បាស់ដោយពិតក្នុងសេចក្តីពិស្តារនៃបទមាតិកាដែលនឹងពោលជាលំដាប់ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងកម្មដ្ឋាន ក្នុងពាក្យដែលខ្ញុំម្ចាស់ពោលហើយថា “ **កាន់យកកម្មដ្ឋាន ក្នុងកម្មដ្ឋាន ៤០ ណាមួយ** ” នោះ ដោយអាការ ១០ យ៉ាង ទាំងនេះមុន គឺ :

១-**សង្ខាតនិទ្ទេសតោ** សំដែងដោយចំនួនកម្មដ្ឋាន ។

២-**ឧបចារប្បនាវហតោ** ជាកម្មដ្ឋានបានត្រឹមឧបចារ ឬ អប្បនាឈាន ។

៣-**ឈានប្បភេទតោ** ដោយភាពផ្សេងគ្នានៃឈាន ។

៤-**សមតិក្កមតោ** ដោយការឈានកន្លង ។

៥-**វឌ្ឍនាវឌ្ឍនតោ** ជាកម្មដ្ឋានគួរពង្រីក និង មិនគួរពង្រីក ។

៦-**អារម្មណតោ** ដោយអារម្មណ៍ ។

៧-**ភូមិតោ** ដោយភូមិ ។

៨-**គហណតោ** ដោយការកាន់យកនិមិត្ត ។

៩-**បច្ចយតោ** ដោយបច្ច័យ ។

១០-**ចរិយានុកូលតោ** ដោយអនុកូលតាមចរិយា ។

# សង្ខាតនិទ្ទេសតោ

ក្នុងបទមាតិកាទាំងនោះ បទថា **ដោយសំដែងចំនួន** មានវិនិច្ឆ័យថា ពាក្យឯណា ដែលខ្ញុំម្ចាស់ពោលទុកថា “ **ក្នុងកម្មដ្ឋាន ៤០** ” ដូច្នេះនេះ កម្មដ្ឋាន ៤០ ក្នុងពាក្យនោះ គឺ **កសិណ ១០ , អសុភ ១០ , អនុស្សតិ ១០ , ព្រហ្មវិហារ ៤ , អរូប ៤ , សញ្ញា ១ , វវដ្ឋាន ១** ។

ក្នុងកម្មដ្ឋានទាំងនោះ **:-**

**-កសិណ ១០** គឺ បឋវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាលោកកសិណ បរិច្ឆិន្នាកាសកសិណ ។

**-អសុភ ១០** គឺ ឧទ្ធុមាតកៈ វិនីលកៈ វិបុព្វកៈ វិច្ឆិទ្ទកៈ វិក្ខាយិតកៈ វិក្ខិត្តកៈ ហតវិក្ខិត្តកៈ លោហិតកៈ បុឡុវកៈ អដ្ឋិកៈ ។

**-អនុស្សតិ ១០** គឺ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ មរណានុស្សតិ កាយគតាសតិ អានាបានស្សតិ ឧបសមានុស្សតិ ។

**-ព្រហ្មវិហារ ៤** គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ។

**-អរូប ៤** គឺ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ ។

**-អាហារេបដិកូលសញ្ញា** ឈ្មោះថា សញ្ញា ១ ។

**-ចតុធាតុវវដ្ឋាន** ឈ្មោះថា វវដ្ឋាន ១ យ៉ាងនេះឯង ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយការសំដែងចំនួន ដូច្នេះ ។

## ឧបចារប្បនាវហតោ

បទថា “ **ជាកម្មដ្ឋាននាំមកបានត្រឹមឧបចារឈាន ឬ ដល់អប្បនាឈាន** ” មានវិនិច្ឆ័យថា ក៏ក្នុងកម្មដ្ឋានទាំងនោះ កម្មដ្ឋាន ១០ គឺ អនុស្សតិ វៀរកាយគតាសតិនិងអានាបាសស្សតិ សល់ ៨ , អាហារេបដិកូលសញ្ញា១ ចតុធាតុវវដ្ឋាន១ នេះប៉ុណ្ណោះជា **ឧបចារវហ** ( ជាកម្មដ្ឋាននាំមកបានត្រឹមឧបចារ ) កម្មដ្ឋានក្រៅពីនេះជា **អប្បនាវហ** ( នាំមកបានដល់អប្បនា ) យ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យ ដោយជាកម្មដ្ឋាននាំមកបានត្រឹម **ឧបចារឈាន** ឬ ដល់ **អប្បនាឈាន** ដូច្នេះឯង ។

## ឈានប្បភេទតោ

បទថា **ដោយភាពផ្សេងគ្នានៃឈាន** មានវិនិច្ឆ័យថា ក៏ក្នុងកម្មដ្ឋាន ២ យ៉ាង ដូចដែលបានពោលហើយនោះ បណ្ដាអប្បនាវហកម្មដ្ឋានទាំងឡាយ កសិណ ១០ និងអានាបានស្សតិ ជា **ចតុក្កជ្ឈានិក** ( ចម្រើនឲ្យកើតរហូតដល់ឈាន ទី ៤ ) អសុភ ១០ និង កាយគតាសតិ ជា **បឋមជ្ឈានិក** ( ចម្រើនកើតបានត្រឹមបឋមជ្ឈាន ) ព្រហ្មវិហារ ៣ ខាងដើម ជា **តិកជ្ឈានិក** ( ចម្រើនឲ្យកើតបានត្រឹមឈាន ទី ៣ ) ព្រហ្មវិហារទី ៤ និង អរូប ៤ ជា **ចតុត្ថជ្ឈានិក** ( ប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ) ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យដោយភាពផ្សេងគ្នានៃឈានដូច្នេះ ។

## សមតិក្កមតោ

បទថា **ដោយការឈានកន្លង** មានវិនិច្ឆ័យថា ការឈានកន្លងមាន ២ គឺ ឈានកន្លងអង្គ ១ ឈានកន្លងអារម្មណ៍ ១ ក្នុងការឈានកន្លង ២ យ៉ាងនោះ ការឈានកន្លងអង្គ រមែងមានក្នុងកម្មដ្ឋានទាំងឡាយដែលជា **តិកជ្ឈានិក** និង **ចតុក្កជ្ឈានិក** ទាំងពួង ព្រោះឈានខាងលើមានតតិយជ្ឈានជាដើម ព្រះយោគាវចរចាំបាច់ត្រូវឈានកន្លងអង្គឈាន មាន **វិតក្កៈ វិចារៈ** ជាដើម ហើយទើបសម្រេចបានក្នុងអារម្មណ៍ទាំងនោះៗឯង ក្នុងព្រហ្មវិហារទី ៤ ក៏ដូច្នោះដែរ ព្រោះព្រហ្មវិហារទី ៤ នោះ ព្រះយោគាវចរចាំបាច់ត្រូវឈានកន្លងសោមនស្សហើយ ទើបសម្រេចបាន ក្នុងអារម្មណ៍នៃព្រហ្មវិហារ ៣ ខាងដើម មានមេត្តាជាដើមនោះឯង ។ ចំណែកការឈានកន្លងអារម្មណ៍ រមែងមានក្នុងអរូប៤ ព្រោះអាកាសានញ្ចាយតនៈ ព្រះយោគាវចរចាំបាច់ត្រូវឈានកន្លងអារម្មណ៍ ក្នុងកសិណ ៩ ខាងដើម ឯណានីមួយហើយ ទើបនឹងសម្រេចបាន ឯអរូបខាងលើមានវិញ្ញាណញ្ចាយតនៈជាដើម ព្រះយោគាវចរ ក៏ចាំបាច់ត្រូវឈានកន្លងអារម្មណ៍ មានអាកាសជាដើមចេញ ទើបនឹងសម្រេចបាន ក្នុងកម្មដ្ឋានដ៏សេស ២១ គ្មានការឈានកន្លងទេ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដោយការឈានកន្លងដូច្នេះចុះ ។

## វឌ្ឍនាវឌ្ឍនតោ

បទថា **ដោយជាកម្មដ្ឋានដែលគួរពង្រីក និង មិនគួរពង្រីក** ( និមិត្ត ) មានវិនិច្ឆ័យថា ក្នុងកម្មដ្ឋាន ៤០ នេះ កសិណ ១០ ប៉ុណ្ណោះ គួរពង្រីក( និមិត្ត ) ព្រោះថា ព្រះយោគាវចរ ផ្សាយទៅដោយកសិណរហូតដល់ឱកាសត្រឹមណាខាងក្នុង

ឱកាសនោះ លោករមែងជាអ្នកអាចនឹងបានឮសំឡេងដោយសោតទិព្វ អាចនឹងឃើញរូបទាំងឡាយដោយចក្ខុទិព្វ និង នឹងអាចដឹងចិត្តអ្នកដទៃ ដោយចិត្តរបស់ខ្លួនបាន ចំណែកកាយគតាសតិ និង អសុភទាំងឡាយ មិនគួរពង្រីក(និមិត្ត) ព្រោះហេតុអ្វី ព្រោះកាយគតាសតិ និង អសុភនោះ ត្រូវកំណត់ដោយឱកាស ហើយព្រោះមិនមានអានិសង្សផង ឯសេចក្តីដែលកម្មដ្ឋានទាំងនោះត្រូវកំណត់ដោយឱកាសនោះ នឹងមានច្បាស់ដោយការនាន័យ ចំពោះកម្មដ្ឋានទាំងនោះ កាលព្រះយោគីពង្រីក(និមិត្ត)ទៅ គំនរសាកសពប៉ុណ្ណោះចម្រើន មិនមានអានិសង្ស សូម្បីតែបន្តិចបន្តួច ។

ពិតណាស់ សូម្បីព្រះថេរៈសោបាកៈ ក៏បានពោលពាក្យនេះ ក្នុងសោបាកបញ្ហាព្យាករណ៍ថា “ បពិត្រព្រះអង្គដ៏ចម្រើន រូបសញ្ញាប្រាកដច្បាស់ អដ្ឋិកសញ្ញាមិនប្រាកដច្បាស់ ” ដូច្នេះ ។ ក៏ក្នុងសញ្ញា ២ យ៉ាងនោះ រូបសញ្ញា លោកពោលថា ប្រាកដច្បាស់ ក៏ជាប់ដោយការពង្រីកនៃនិមិត្ត អដ្ឋិកសញ្ញា លោកពោលថា មិនប្រាកដច្បាស់ ក៏ជាប់ដោយការមិនពង្រីកនិមិត្ត ចំណែកពាក្យដែលព្រះថេរៈក្រាបទូលថា “ ខ្ញុំព្រះករុណា បានផ្សាយទៅ ដោយអដ្ឋិកសញ្ញា ពេញប្រឹថពីនេះ ” ដូច្នេះនោះ លោកពោល ដោយអាការ ដែលនិមិត្តចូលមកប្រាកដច្បាស់ដល់ខ្លួនលោក ដែលជាអ្នកជំនាញ ( ក្នុងអដ្ឋិកសញ្ញានោះ ) ដូចជានៅក្នុងរជ្ជកាល របស់ព្រះបាទធម្មាសោក មានសត្វករវិកមួយ គេរក្សាទុកនៅក្នុងទ្រុងកែវ ឃើញស្រមោលរបស់ខ្លួនក្នុងកញ្ចក់ដោយជុំវិញ ក៏សម្គាល់ថា ស្រមោលរបស់ខ្លួនជាសត្វករវិកពិតៗ នៅគ្រប់ទិស ក៏បន្លឺសំឡេងឡើងដ៏ពីរោះ យ៉ាងណា សូម្បីព្រះថេរៈ ក៏ដូច្នោះ ព្រោះលោកជំនាញក្នុងអដ្ឋិកសញ្ញា ឃើញនិមិត្តដែលប្រាកដ នៅ

គ្រប់ទិសទី ក៏គិតទៅថា ប្រែបពីពេញទៅដោយអដ្ឋិទាំងអស់ ដូច្នេះឯង ។

សួរថា បើដូច្នោះ សេចក្តីដែលអសុភឈានទាំងឡាយជា អប្បមាណារម្មណ៍ ដែលពោលទុក ( ក្នុងធម្មសង្គហៈ ) មិនខុសទៅហើយឬ ? ឆ្លើយថា សេចក្តីដែលពោលនោះ មិនខុសទេ ព្រោះព្រះយោគាវចរអង្គខ្លះ កាន់យកនិមិត្ត ក្នុងឧទ្ធុមាតកអសុភ ឬ ក្នុងអដ្ឋិកអសុភក៏ដោយ ដែលធំៗ អង្គខ្លះកាន់យកនិមិត្ត ក្នុងអសុភនោះៗ ដែលតូចៗ ដោយបរិយាយនេះ ឈានរបស់អង្គខ្លះ ទើបជាអប្បមាណារម្មណ៍ អង្គខ្លះទើបជាបរិត្តារម្មណ៍ ម្យ៉ាងទៀត បុគ្គលណាមិនឃើញទោសក្នុងការពង្រីកអសុភនិមិត្តនោះ ពង្រីកច្រើនទៅ លោកសំដៅយកឈានរបស់បុគ្គលនោះ ពោលថា អសុភឈានជាអប្បមាណារម្មណ៍ ( ក៏កើតបាន ) តែក៏មិន គួរពង្រីកទៅ ព្រោះមិនមានអានិសង្សនោះឯង ។

ហើយសូម្បីកម្មដ្ឋានដ៏សេស ក៏មិនគួរពង្រីក ដូចជាកាយគតាសតិ និងអសុភនោះឯង សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបណ្តាកម្មដ្ឋានដ៏សេសនោះ បើបុគ្គលពង្រីកអានាបាននិមិត្ត គំនរខ្យល់ប៉ុណ្ណោះចម្រើន ហើយអានាបាននិមិត្តនោះ ក៏ត្រូវកំណត់ដោយឱកាសដែរ ព្រោះមានទោស និងព្រោះត្រូវកំណត់ដោយឱកាស ដូច្នេះអានាបានស្សតិ ទើបមិនគួរពង្រីក ។

ព្រហ្មវិហារ ក៏មានសត្វជាអារម្មណ៍ កាលព្រះយោគាវចរ ពង្រីកនិមិត្តនៃព្រហ្មវិហារនោះ គំនរសត្វប៉ុណ្ណោះចម្រើន តែប្រយោជន៍ដោយការចម្រើនដោយគំនរសត្វនោះមិនមាន ព្រោះហេតុនោះ សូម្បីព្រហ្មវិហារនិមិត្តនោះ ក៏មិនគួរពង្រីក ។ ចំណែកពាក្យបាលីដែល ពោលថា **ភិក្ខុមានចិត្តសហគតដោយមេត្តាផ្សាយទៅកាន់ទិស ១** ដូច្នេះជាដើមនោះ លោកពោលដោយអំណាចការកំណត់ ( ខេត្តសត្វជា

អារម្មណ៍ ) មែនពិត ព្រះយោគាវចរ ដែលកំណត់យកសត្វទាំងឡាយក្នុងទិស ១ ភាវនា(មេត្តា) ទៅតាមលំដាប់ ដូចជា វត្ត១ វត្ត២ ... ព្រះបាលីហៅថា " **ដែលផ្សាយទៅកាន់ទិស១** " មិនមែនពង្រីកនិមិត្តទេ ដោយបដិភាគនិមិត្តដែលព្រះយោ-គាវចរ ធ្វើឲ្យចម្រើននោះ មានក្នុងព្រហ្មវិហារភាវនានោះក៏ទេ ចំណែកភាពជាបរិត្តារម្មណ៍ និងអប្បមាណារម្មណ៍ក្នុងព្រហ្មវិហារនេះ ក៏គប្បីជ្រាបថា ជាប់ដោយការកំណត់ ( ខេត្តសត្វជាអារម្មណ៍នោះឯង ) ។

សូម្បីក្នុងអារម្មណ៍នៃអរូបទាំងឡាយ អាកាសក៏មិនគួរពង្រីក ព្រោះធ្វើឲ្យកសិណបើក ។ ពិតណាស់ អាកាសនោះនឹងត្រូវមនសិការ ក៏ជាប់ដោយការបើកកសិណប៉ុណ្ណោះ កាលធ្វើឲ្យចម្រើនច្រើនទៅប៉ុនណានោះ ក៏មិនមានផលណាៗឡើយ វិញ្ញាណក៏មិនគួរពង្រីកព្រោះជាសភាវធម៌ ពិតណាស់ បុគ្គលណាក៏មិនអាចធ្វើសភាវធម៌ឲ្យចម្រើនបាន ការបាត់ទៅនៃវិញ្ញាណក៏មិនគួរពង្រីក ព្រោះត្រឹមតែជាភាពមិនមាននៃវិញ្ញាណ អារម្មណ៍នៃនេវសញ្ញានាសញ្ញាយតនៈ ក៏មិនគួរពង្រីកព្រោះជាសភាវធម៌ដូចគ្នា ។

កម្មដ្ឋានដ៏សេស ( អនុស្សតិ ) ក៏មិនគួរពង្រីក ព្រោះមិនមាន( បដិភាគ ) និមិត្ត មែនពិត បដិភាគនិមិត្តជានិមិត្តដែលចាំបាច់ឲ្យចម្រើនដោយពិត តែអារម្មណ៍នៃអនុស្សតិទាំងឡាយ មានពុទ្ធានុស្សតិជាដើម មិនមានបដិភាគនិមិត្តទេ ព្រោះដូច្នោះ អនុស្សតិកម្មដ្ឋាននោះ ទើបមិនគួរពង្រីក( និមិត្ត ) ឡើយ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយជាកម្មដ្ឋានដែលគួរពង្រីក និង មិនគួរពង្រីក ( និមិត្ត ) ដូច្នេះចុះ ។

## អារម្មណតោ

បទថា **ដោយអារម្មណ៍** មានវិនិច្ឆ័យថា ក្នុងកម្មដ្ឋាន ៤០ នេះ ។ កម្មដ្ឋាន២២ គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ ទាំងនេះ មានអារម្មណ៍ជាបដិភាគនិមិត្តបាន កម្មដ្ឋានដ៏សេស ១៨ មានអារម្មណ៍ជាបដិភាគនិមិត្តមិនបាន ដោយន័យនេះ កម្មដ្ឋាន ១២ គឺ ក្នុងអនុស្សតិ១០ វៀរអានាបានស្សតិ និង កាយគតាសតិ នៅសល់ ៨ ។ អាហារេបដិកូលសញ្ញា១ ចតុធាតុវវត្ថាន១ វិញ្ញាណញ្ចាយតនៈ១ នេវសញ្ញានាសញ្ញាយតនៈ១ នេះមានសភាវធម៌ជាអារម្មណ៍ , កម្មដ្ឋាន២២ គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ នេះមាននិមិត្តជាអារម្មណ៍ កម្មដ្ឋានដ៏សេស ៦ គឺ ( ព្រហ្មវិហារ៤ អាកាសានញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ ជា នវត្តព្វារម្មណ៍ ) គឺអារម្មណ៍មិនគប្បីពោល។

ម្យ៉ាងទៀត កម្មដ្ឋាន ៨ គឺ វិបុព្វកៈ លោហិតកៈ បុឡុវកៈ អានាបានស្សតិ អាបោកសិណ តេជោកសិណ វាយោកសិណ និង ពន្លឺថ្ងៃជាដើម ( ដែលចាំងចូលមកតាមប្រហោង ) ដែលជាអារម្មណ៍ក្នុងអាលោកកសិណ ទាំងនេះ ( ជាចលិតារម្មណ៍ ) គឺ មានអារម្មណ៍ញាប់ញ័រ តែអារម្មណ៍ញាប់ញ័រទាំងនោះ ក៏កើតក្នុងខាងដើម លុះដល់បដិភាគក៏ស្ងៀមនឹង កម្មដ្ឋានដ៏សេស៣២( ជា**នចលិតារម្មណ៍** ) គឺ មានអារម្មណ៍មិនញាប់ញ័រ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយអារម្មណ៍ដូច្នេះ ។

## ភូមិតោ

បទថា **ដោយភូមិ** មានវិនិច្ឆ័យថា ក្នុងកម្មដ្ឋាន ៤០ នេះ កម្មដ្ឋាន ១២ គឺ

អសុភ១០ កាយគតាសតិ១ អាហារេបដិកូលសញ្ញា១ នេះ រមែងមិនប្រព្រឹត្តទៅក្នុងពពួកទេវតាទេ , កម្មដ្ឋាន១៣ គឺ កម្មដ្ឋាន១២នោះ និង អានាបានស្សតិនេះ មិនប្រព្រឹត្តទៅក្នុងពពួកព្រហ្មលោក តែក្នុងអរូបភព កម្មដ្ឋានដទៃ ក្រៅពីអរូប៤ រមែងប្រព្រឹត្តទៅមិនបាន ។ ក្នុងពពួកមនុស្ស កម្មដ្ឋានរមែងប្រព្រឹត្តទៅបានគ្រប់ប្រការ ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យដោយភូមិដូច្នេះ ។

## គហណតោ

បទថា " **ដោយការកាន់យក** ( និមិត្ត ) " មានវិនិច្ឆ័យថា ការវិនិច្ឆ័យក្នុងបទនេះ បណ្ឌិតគប្បីជ្រាបដោយការកាន់យក ( និមិត្ត ៣ ផ្លូវគឺ ) តាមរយៈការមើល ការប៉ះខ្ទប់ និង ការស្តាប់ ក្នុង៣ផ្លូវនោះ កម្មដ្ឋាន ១៩ គឺ **កសិណ** វៀរចាក វាយោកសិណ សល់ ៩ , **អសុភ១០នេះ** ត្រូវកាន់យក ( និមិត្ត ) តាមរយៈការមើល បានន័យថា និមិត្តរបស់កម្មដ្ឋានទាំងនោះ ដំបូងត្រូវមើលដោយភ្នែក( ជាបរិកម្មនិមិត្ត ) ហើយទើបកាន់យក( ជាឧគ្គហនិមិត្ត ) បាន , ក្នុងកាយគតាសតិ អារម្មណ៍របស់កាយគតាសតិនោះ កាន់យកបានទាំងតាមការមើល និង ការស្តាប់ ចំណែកតចបញ្ចកកម្មដ្ឋានកាន់យកតាមការមើល កម្មដ្ឋានដ៏សេសកាន់យកតាមការស្តាប់ , អានាបានស្សតិកាន់យកតាមការប៉ះខ្ទប់ , វាយោកសិណ កាន់យកតាមការមើល និងការប៉ះខ្ទប់ , កម្មដ្ឋានសល់ ១៨ ទៀត កាន់យកតាមការស្តាប់ , តែកម្មដ្ឋាន ៤០ នោះ កម្មដ្ឋាន គឺ ឧបេក្ខាព្រហ្មវិហារ និងអរូប ៤ នេះ ព្រះយោគីជាអាទិកម្មិកមិនគួរកាន់យកទេ កម្មដ្ឋានដ៏សេស ៣៥ ទើបគួរកាន់យកយ៉ាងនេះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយការកាន់យកនិមិត្តដូច្នេះបុះ ។

# បច្ចយតោ

បទថា **ដោយបច្ច័យ** មានវិនិច្ឆ័យថា ក្នុងកម្មដ្ឋានទាំងនេះ កសិណ វៀរអាកាសកសិណ សល់ ៩ រមែងជាបច្ច័យដល់អរូបទាំងឡាយ , កសិណទាំង១០ ជាបច្ច័យដល់ អភិញ្ញា , ព្រហ្មវិហារ៣ ជាបច្ច័យដល់ព្រហ្មវិហារទី៤ អរូបជាន់ក្រោមៗ ជាបច្ច័យដល់អរូបជាន់លើៗ , នេវសញ្ញានាសញ្ញាយតនៈជាបច្ច័យដល់និរោធសមាបត្តិ , កម្មដ្ឋានទាំងអស់ជាបច្ច័យដល់(ទិដ្ឋធម្ម) សុខវិហារ វិបស្សនា និង ភពសម្បត្តិយ៉ាងនេះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយបច្ច័យដូច្នេះ ។

# ចរិយានុកូលតោ

បទថា **ដោយអនុកូលដល់ចរិយា** មានវិនិច្ឆ័យថា ការវិនិច្ឆ័យក្នុងបទនេះ បណ្ឌិតគប្បីជ្រាបតាមកម្មដ្ឋាន ដែលអនុកូលដល់ចរិយាទាំងឡាយ កម្មដ្ឋានដែលអនុកូលដល់ចរិយានេះ តើដូចម្តេច ?

ជាបឋមក្នុងកម្មដ្ឋាន ៤០ នោះ :

- **កម្មដ្ឋាន ១១** គឺអសុភ១០ កាយគតាសតិ១ អនុកូលដល់បុគ្គលរាគចរិត ។
- **កម្មដ្ឋាន ៨** គឺព្រហ្មវិហារ៤ វណ្ណកសិណ៤ អនុកូលដល់បុគ្គលទោសចរិត។
- **កម្មដ្ឋាន ១** គឺអានាបានស្សតិកម្មដ្ឋានតែមួយប៉ុណ្ណោះ អនុកូលដល់បុគ្គលមោហចរិត និង បុគ្គលវិតក្កចរិត ។
- **កម្មដ្ឋាន ៦** គឺអនុស្សតិ ៦ ខាងដើម អនុកូលដល់បុគ្គលសទ្ធាចរិត ។
- **កម្មដ្ឋាន ៤** គឺមរណស្សតិ ឧបសមានុស្សតិ ចតុធាតុវវត្ថាន អាហារេបដិ-

បដិកូលសញ្ញា អនុកូលដល់បុគ្គលពុទ្ធិចរិត ។

**កសិណដ៏សេស** និង **អរូប ៤** អនុកូលដល់បុគ្គលគ្រប់ចរិត ។

ម្យ៉ាងទៀត ក្នុងកសិណទាំងឡាយ កសិណឯណាមួយដែលជាបរិត្តារម្មណ៍ អនុកូលដល់បុគ្គលវិតក្កចរិត បើជាអប្បមាណារម្មណ៍ អនុកូលដល់បុគ្គលមោហ-ចរិត យ៉ាងនេះឯង ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងកម្មដ្ឋានទាំងនេះ ដោយអនុកូលដល់ចរិយា ដូច្នេះឯង ។

ឯពាក្យដែលពោលមកទាំងអស់ (ក្នុងបទចរិយានុកូលតោ) នេះ ពោលតាមដែល ( កម្មដ្ឋាននោះៗ ចរិយានោះៗ ) ជាសឹកសត្រូវដល់គ្នាដោយត្រង់ប្រការ១ តាមដែលសមគ្នាយ៉ាងក្រៃលែង ប្រការ១ តែដែលបានឈ្មោះថា កុសលភាវនា ដែលមិនគ្របសង្កត់ ទោសទាំងឡាយ មានរាគៈជាដើមក្តី ដែលមិនជាឧបការៈដល់គុណទាំងឡាយ មានសទ្ធាជាដើម មិនមាន ។ ពិតណាស់ សូម្បីក្នុងមេឃិយសូត្រ ព្រះមានព្រះភាគជាម្ចាស់ ក៏បានត្រាស់ពាក្យនេះថា **ធម៌ ៤ ប្រការ អ្នកគប្បីចម្រើនឲ្យក្រៃលែងឡើងទៅ គឺ អសុភៈទាំងឡាយ អ្នកគប្បីបំពេញ ដើម្បីលះបង់រាគៈ មេត្តា អ្នកគប្បីបំពេញ ដើម្បីលះបង់ព្យាបាទ អានាបានស្សតិ អ្នកគប្បីបំពេញដើម្បីលះវិតក្កៈ អនិច្ចសញ្ញាគប្បីបំពេញដើម្បីដកអស្មិមានះ** ដូច្នេះ សូម្បីក្នុងរាហុលសូត្រ ទ្រង់ត្រាស់កម្មដ្ឋាន ៧ ដល់ព្រះរាហុលដែរ ដោយន័យថា " **ម្នាលរាហុលអ្នកចូរបំពេញមេត្តាភាវនា** " ដូច្នេះជាដើម ព្រោះហេតុនោះ បណ្ឌិតកុំកាន់យកក្នុងពាក្យ ( ដែលពោលទុក ) ប៉ុណ្ណោះ គួរពិនិត្យរកអធិប្បាយក្នុងអាគតដ្ឋានទាំងពួងហោង ។

## ការកាន់យកកម្មដ្ឋាន

( តទៅ )នេះជាការវិនិច្ឆ័យក្នុងកម្មដ្ឋានកថា ក្នុងសេចក្តីថា “ **ការកាន់យកកម្មដ្ឋាន** ” នោះ ។

ឯពាក្យសម្តែងសេចក្តីនៃ បទថា **កាន់យក** នេះ មានដូចតទៅនេះ ដែលព្រះយោគីនោះគប្បីចូលទៅរកកល្យាណមិត្ត មានប្រការដូចដែលពោលហើយតាមន័យដែលពោលទុកក្នុងសេចក្តីថា **ចូលទៅរកកល្យាណមិត្តអ្នកឲ្យកម្មដ្ឋាន** នោះហើយ ប្រគល់ខ្លួនដល់ព្រះមានព្រះភាគជាម្ចាស់ ឬដល់ព្រះអាចារ្យ ធ្វើខ្លួនឲ្យជាអ្នកមានអធ្យាស្រ័យដល់ព្រម និង មានអធិមុត្តិដល់ព្រម ហើយសូមកម្មដ្ឋានចុះ ។

## ការថ្វាយខ្លួន

ក្នុងការប្រគល់ខ្លួននោះ គប្បីថ្វាយខ្លួនដល់ព្រះមានព្រះភាគជាម្ចាស់ ដោយពាក្យថា “ **ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ** ” បពិត្រ ព្រះមាន-ព្រះភាគជាម្ចាស់ ខ្ញុំព្រះករុណាសូមលះអត្តភាពនេះដល់ព្រះអង្គ ” ដូច្នេះ ភិក្ខុកាលមិនថ្វាយខ្លួនយ៉ាងនេះ នៅក្នុងសេនាសនៈទាំងឡាយដ៏ស្ងាត់ កាលអារម្មណ៍គួរភ័យខ្លាចមកប្រឈមមុខ មិនអាចទ្រាំនៅបាន ក៏អាចនឹងវិលត្រឡប់ទៅកាន់ស្រុកភូមិ ជាអ្នកនៅប្រឡូកប្រឡំជាមួយគ្រហស្ថ លោកក៏ដល់នូវការស្វែងរកមិនសមគួរ រហូតកើតការវិនាសទៅ តែកាលលោកបានប្រគល់ខ្លួនហើយ កាលអារម្មណ៍គួរភ័យខ្លាច សូម្បីមកប្រឈមមុខ ភាពខ្លាចក៏មិនកើតឡើង កាលបើលោកពិចារណាឃើញថា នែបាបណ្ឌិត បាបានថ្វាយខ្លួនដល់ព្រះពុទ្ធជាម្ចាស់ កាលពីថ្ងៃមុននេះឯងមិនមែនឬ ? ដូច្នេះសេចក្តីត្រេកអរនឹងកើតឡើង ដូចឧបមាថា សំពត់កាសិតម្លៃ

ថ្លៃរបស់បុរស ( ម្នាក់ ) បានរក្សាទុក កាលសំពត់នោះ ត្រូវកណ្ដុរកាត់ សត្វល្អិតកាត់ ការខូចចិត្តនឹងកើតឡើងដល់បុរសនោះ តែបើបុរសនោះ បានប្រគេនសំពត់នោះដល់ភិក្ខុអ្នកមិនមានចីវរសោត តមកសេចក្ដីត្រេកអរ នឹងកើតឡើងដល់បុរសនោះ សូម្បីព្រោះឃើញសំពត់នោះ ត្រូវភិក្ខុនោះ កាត់ធ្វើជាខ័ណ្ឌតូច ខ័ណ្ឌធំ ដោយឧបមានេះ យ៉ាងណា ឧបមេយ្យនេះ បណ្ឌិតគប្បីជ្រាបដូច្នេះ ។

សូម្បីកាលថ្វាយខ្លួនដល់ព្រះអាចារ្យ ក៏គប្បីពោលថា **ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ** “ បពិត្រលោកអាចារ្យដ៏ចម្រើន ខ្ញុំព្រះករុណា សូមលះអត្តភាពនេះដល់លោក ”ដូច្នេះ បើភិក្ខុមិនប្រគល់អត្តភាពយ៉ាងនេះ នឹងជាអ្នកដែលអាចារ្យហាមប្រាមមិនបានខ្លះ នឹងជាអ្នកប្រដៅក្រ មិនធ្វើតាមឱវាទខ្លះ នឹងជាអ្នកទៅតាមទំនើងចិត្ត មិនទាន់លាអាចារ្យ ក៏ទៅក្នុងទីដែលខ្លួនប្រាថ្នាខ្លះ លោកអាចារ្យនឹងមិនសង្គ្រោះបុគ្គលនោះដោយអាមិសខ្លះ ដោយធម៌ខ្លះ មិនឲ្យលោកសិក្សាមាតិកាដែលជ្រាលជ្រៅ ភិក្ខុនោះកាលមិនបានទទួលការសង្គ្រោះ ២ ប្រការនេះ ឈ្មោះថា មិនបានទីពឹងក្នុងព្រះសាសនា មិនយូរក៏នឹងដល់នូវភាពទ្រុស្តសីល ឬ ជាគ្រហស្ថទៅ តែភិក្ខុដែលបានប្រគល់អត្តភាពហើយ នឹងមិនជាអ្នកដែលអាចារ្យហាមប្រាមមិនបាន មិនជាអ្នកទៅតាមទំនើងចិត្ត ជាអ្នកប្រដៅងាយ មានការប្រព្រឹត្តទៅតាមជាប់ជាមួយអាចារ្យជានិច្ច លោកកាលបានការសង្គ្រោះទាំងពីរប្រការ អំពីអាចារ្យ រមែងដល់នូវភាពចម្រើនល្អ រុងរឿងក្នុងព្រះសាសនា ដូចពួកអន្តេវាសិករបស់ព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ដូច្នោះ ។

បានឮថា ភិក្ខុ ៣ អង្គ មកកាន់សម្នាក់របស់ព្រះថេរៈ ក្នុងភិក្ខុ ៣ អង្គនោះ អង្គមួយ ពិតព្រះថេរៈថា “ បពិត្រលោកដ៏ចម្រើន បើដើម្បីប្រយោជន៍ដល់លោក

ខ្ញុំព្រះករុណាអាចលោតចុះក្នុងជ្រោះជម្រៅ ១០០ ជួរបុរសបាន ” អង្គទី ២ ពិតថា “ បពិត្រលោកដ៏ចម្រើន បើដើម្បីប្រយោជន៍ដល់លោកហើយ ខ្ញុំព្រះករុណាអាចនឹងត្រដុសអត្តភាពនេះ ផ្តើមអំពីការដាក់ជើងចូលត្រង់ជុំថ្ម ឲ្យសឹកខ្លួនអស់ទៅមិនឲ្យសល់ឡើយបាន ” អង្គទី ៣ ពិតទូលថា “ បពិត្រលោកដ៏ចម្រើន បើដើម្បីប្រយោជន៍ដល់លោក ខ្ញុំព្រះករុណា អាចអត់សង្កត់ខ្យល់អស្សាសបស្សាសៈរហូតធ្វើកាលកិរិយាបាន ” ។ ព្រះថេរៈឃើញថា ភិក្ខុទាំងនេះជាភព្វបុគ្គល ទើបប្រាប់កម្មដ្ឋាន ពួកលោកតាំងនៅក្នុងឱវាទរបស់ព្រះថេរៈ បានសម្រេចព្រះអរហត្តទាំង ៣ អង្គយ៉ាងនេះ នេះជាអានិសង្សក្នុងការប្រគល់ខ្លួន ព្រោះដូច្នោះ ខ្ញុំម្ចាស់ទើបពោលថា “... គប្បីថ្វាយខ្លួនដល់ព្រះមានព្រះភាគជាម្ចាស់ ឬ ដល់ព្រះអាចារ្យ ”ដូច្នេះ ។

# អជ្ឈាស័យ ៦

ចំណែកសេចក្តីថា “ **ជាអ្នកមានអជ្ឈាស្រ័យដល់ព្រម និងមានអធិមុត្តិដល់ព្រម** ” នោះមានវិនិច្ឆ័យថា ដែលព្រះយោគីនោះមានអជ្ឈាស្រ័យដល់ព្រម ដោយអាការ ៦ ជាប់ទាក់ទងដោយគុណធម៌ មានអលោភៈជាដើម ដោយព្រះយោគីអ្នកមានអជ្ឈាស្រ័យដល់ព្រមយ៉ាងនេះ រមែងបានសម្រេចពោធិ ៣ ( សម្មាសម្ពោធិ បច្ចេកពោធិ និង សាវកពោធិ ) យ៉ាងណាមួយ ដូចដែលលោកពោលទុកថា អជ្ឈាស័យ ៦ ប្រការ របស់ព្រះពោធិសត្វទាំងឡាយ រមែងប្រព្រឹត្តទៅព្រមដើម្បីបន្ទុំនូវពោធិ គឺ :

**១-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអជ្ឈាស្រ័យប្រកបដោយ អលោភៈឃើញទោសក្នុង លោភៈ នៅដោយប្រក្រតី ១ ។

**២-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអធ្យាស្រ័យប្រកបដោយ អទោសៈ ឃើញទោសក្នុង ទោសៈ នៅដោយប្រក្រតី ១ ។

**៣-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអធ្យាស្រ័យប្រកបដោយ អមោហៈ ឃើញទោសក្នុង មោហៈ នៅដោយប្រក្រតី ១ ។

**៤-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអធ្យាស្រ័យក្នុងនេក្ខម្មៈ ឃើញទោសក្នុងការគ្រប់គ្រងផ្ទះ នៅដោយប្រក្រតី ១ ។

**៥-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអធ្យាស្រ័យក្នុង បវិវេក ឃើញទោសក្នុងសង្គណិកា( ការប្រឡូកប្រឡល់ដោយពួកគណៈ ) នៅដោយប្រក្រតី ១ ។

**៦-ព្រះពោធិសត្វទាំងឡាយ** ជាអ្នកមានអធ្យាស្រ័យក្នុងនិស្សរណៈ( ការចេញចាកទុក្ខ ) ឃើញទោសក្នុងភព និងគតិទាំងពួង នៅដោយប្រក្រតី ១ ។

មែនពិត បុគ្គលពួកណាមួយជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រព ព្រះបច្ចេកពុទ្ធ និង ព្រះសម្មាសម្ពុទ្ធ ទាំងដែលជាអតីត ជាអនាគត និង បច្ចុប្បន្ន លោកទាំងពួងនោះ បានសម្រេចនូវគុណវិសេសដែលខ្លួនគប្បីសម្រេចបានដោយអាការ ៦ នេះប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគី គប្បីជាអ្នកមានអធ្យាស្រ័យដល់ព្រមដោយអាការ ៦ នេះចុះ ។

ម្យ៉ាងទៀត ព្រះយោគីគប្បីជាអ្នកដល់ព្រមដោយអធិមុត្តិ ដោយភាពជាអ្នកមានចិត្តបង្អោនទៅក្នុងធម៌នោះ អធិប្បាយថា គប្បីជាអ្នកមានចិត្តបង្អោនទៅក្នុងសមាធិ ធ្ងន់ទៅក្នុងសមាធិ ទោរទន់ទៅក្នុងសមាធិ និងជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ធ្ងន់ក្នុងព្រះនិព្វាន ទោរទន់ទៅក្នុងព្រះនិព្វានហោង ។

ឯចរិយារបស់ព្រះយោគីនោះ ដែលមានអធ្យាស្រ័យ និង អធិមុត្តិដល់ព្រម

ហើយ យ៉ាងនេះ មកសូមកម្មដ្ឋាន ព្រះអាចារ្យអ្នកបានចេតោបរិយញ្ញាណរំពឹងមើល វារៈចិត្ត ហើយក៏គប្បីជ្រាបបាន អាចារ្យក្រៅពីនេះត្រូវសាកសួរដោយន័យថា :

១ . អ្នកជាបុគ្គលចរិតអ្វី ?

២ . ធម៌ពួកណាដែលប្រព្រឹត្តទៅច្រើនដល់អ្នក ?

៣ . កាលអ្នកមនសិការកម្មដ្ឋាន ខណៈទើបមានភាពជាផាសុក ?

៤ . ចិត្តរបស់អ្នកបង្អោនទៅក្នុងកម្មដ្ឋានបទណា ?

ដូច្នេះជាដើមទើបនឹងជ្រាបបាន ព្រះអាចារ្យបានជ្រាបយ៉ាងនេះហើយ ទើបប្រាប់កម្មដ្ឋានដែលអនុកូលដល់ចរិយានោះ ឯការប្រាប់គប្បីនឹងប្រាប់ដោយវិធី ៣ យ៉ាង គឺ :

១-សម្រាប់អ្នករៀនកម្មដ្ឋានដោយប្រក្រតី គប្បីឲ្យធ្វើការសាធ្យាយន៍ ( ស្តាប់លមើល ) អន្តិយ ១ ឬ ២ ផ្លូវ ហើយទើបឲ្យ ។

២-សម្រាប់អ្នកនៅក្នុងសម្នាក់គប្បីប្រាប់ឲ្យគ្រប់ពេលដែលលោកមករក ។

៣-សម្រាប់អ្នកដែលរៀនហើយប្រាថ្នានឹងទៅក្នុងទីដទៃ គប្បីប្រាប់កុំឲ្យសង្ខេបពេក កុំឲ្យពិស្តារពេក ។

ក្នុងកម្មដ្ឋានទាំងនោះ ដំបូងកាលនឹងប្រាប់បឋវីកសិណកម្មដ្ឋាន គប្បីប្រាប់អាការ ៩ នេះគឺ :

១ . ទោសកសិណ ៤

២ . ការធ្វើកសិណ

៣ . ការនាន័យនៃកសិណដែលធ្វើហើយ

៤ . និមិត្ត ២

៥ . សមាធិ ២

៦ . សប្បាយ និង អសប្បាយ ៧

៧ . អប្បនាកោសល្យ ១០

៨ . វិរិយសមតា ( ភាពស្មើគ្នានៃសេចក្តីព្យាយាម )

៩ . អប្បនាវិធាន ( វិធីចម្រើនអប្បនា )

សូម្បីក្នុងកម្មដ្ឋានដ៏សេស ក៏គប្បីប្រាប់វត្ថុដែលគួរដល់កម្មដ្ឋាននោះៗ វិធីទាំងពួងនោះ នឹងមានច្បាស់ក្នុងការនាវិធីនៃកម្មដ្ឋានទាំងនោះ ។

កាលកម្មដ្ឋានដែលអាចារ្យប្រាប់យ៉ាងនេះ ព្រះយោគីនោះ គប្បីស្តាប់កាន់យកនិមិត្តឲ្យបាន ។ ពាក្យថា **កាន់យកនិមិត្ត** មានសេចក្តីថា ចងអាការនោះ ៗ ទុកក្នុងចិត្ត យ៉ាងនេះថា នេះជាបទខាងក្រោម នេះជាបទខាងលើ នេះជាអត្ថន័យនៃបទនោះ នេះជាអធិប្បាយ នេះជាពាក្យឧបមា ដូច្នេះ ។ កាលព្រះយោគីស្តាប់ដោយគោរព កាន់យកនិមិត្តបានយ៉ាងនេះ ជាការដែលបានកាន់យកកម្មដ្ឋានដោយល្អហើយ ក្រោយមកការសម្រេចគុណវិសេស នឹងសម្រេចដល់លោក ព្រោះអាស្រ័យកម្មដ្ឋានដែលខ្លួនកាន់យកដោយល្អនោះ នឹងសម្រេចដល់បុគ្គលក្រៅពីនេះ ( ដែលមិនបានកាន់យកកម្មដ្ឋានដោយល្អយ៉ាងនោះ ) មិនមាន នេះជាពាក្យសម្តែងសេចក្តីនៃ បទថា “ **កាន់យក** ” នេះ ។

បទទាំងឡាយនេះ គឺ “ **ចូលទៅរកកល្យាណមិត្ត កាន់យកកម្មដ្ឋាន ណាមួយ ក្នុងកម្មដ្ឋាន ៤០ ដែលអនុកូលដល់ចរិយារបស់ខ្លួន** ” ដូច្នេះ ខ្ញុំព្រះករុណាបានអធិប្បាយឲ្យពិស្តារហើយ ដោយអាការទាំងពួង ដោយកថាមគ្គប៉ុណ្ណោះឯង ។

**បរិច្ឆេទទី ៣**

**ឈ្មោះ កម្មដ្ឋានគហណនិទ្ទេស** ក្នុងអធិការនៃសមាធិការនា ក្នុងបករណ៍ វិសុទ្ធិមគ្គ ដែលខ្ញុំព្រះករុណាធ្វើដើម្បីប្រយោជន៍ដល់កាពបាមោជ្ជ នៃសាធុជន ដូច្នេះឯង ។

# មហាដីកា

## អធិប្បាយ កម្មដ្ឋាន៤០

ឈ្មោះថា **សង្ខាតនិទ្ទេសតោ** ដោយការសម្តែងនៃកម្មដ្ឋានដែលបានរាប់ទុក គឺដែលកាន់យក លើកឡើងសម្តែងទុក ដោយទាក់ទងជាមួយការរាប់ថា **កម្មដ្ឋាន ៤០** ដូច្នេះ ។

ប្រការវិនិច្ឆ័យថា " **ក្នុងកម្មដ្ឋានទាំងនេះ កម្មដ្ឋានប៉ុណ្ណេះ នាំមកនូវ ឧបចារជ្ឈាន កម្មដ្ឋានប៉ុណ្ណេះ នាំមកនូវអប្បនាឈាន** " ដូច្នេះ ឈ្មោះថា **ឧបចារប្បនាវហតោ** ជាកម្មដ្ឋាននាំមកនូវ **ឧបចារជ្ឈាន** និង **អប្បនាឈាន** ។

ប្រការដែលវិនិច្ឆ័យថា " **កម្មដ្ឋានប៉ុណ្ណេះបានឈាន ១ កម្មដ្ឋានប៉ុណ្ណេះ បានឈាន ២ កម្មដ្ឋានប៉ុណ្ណេះបានឈាន ៣ កម្មដ្ឋានប៉ុណ្ណេះបានឈានទាំងអស់** " ដូច្នេះ ឈ្មោះថា **ឈានប្បភេទតោ** ដោយប្រភេទនៃឈាន ។

ប្រការវិនិច្ឆ័យមានយ៉ាងនេះថា " **ក្នុងកម្មដ្ឋានទាំងនេះ មានការឈានកន្លងអង្គ កម្មដ្ឋានទាំងនេះមានការឈានកន្លងអារម្មណ៍** "ដូច្នេះ ឈ្មោះថា **សមតិក្កមតោ** ដោយការឈានកន្លង ។

ប្រការវិនិច្ឆ័យថា “ **កម្មដ្ឋានទាំងនេះ កម្មដ្ឋានប៉ុណ្ណេះ គួរពង្រីក កម្មដ្ឋានប៉ុណ្ណេះមិនគួរពង្រីក** ” ដូច្នេះ ឈ្មោះថា **វឌ្ឍនាវឌ្ឍនតោ** ជាកម្មដ្ឋានគួរពង្រីក និង មិនគួរពង្រីក ។ ឈ្មោះថា “ **អារម្មណតោ** ” ដោយអារម្មណ៍ គឺដោយការចែកអារម្មណ៍ជាប់ជាមួយសភាវធម៌ជានិមិត្ត និងជា **ន វត្តព្វ** ( **ន វត្តព្វ** គឺ មិនអាចពោលបាន ថាជាសភាវៈណាៗ មានន័យថា ជាបញ្ញត្តិ ) និង ដោយសម្ពន្ធជាមួយអារម្មណ៍ដែលកម្រើក និង មិនកម្រើក ។ ឈ្មោះថា **ភូមិតោ** ដោយភូមិ គឺ ដោយការចែកភូមិ មានកាមាវចរភូមិជាដើម ។

ឈ្មោះថា **គហណតោ** ដោយការកាន់យក គឺ ដោយការចែកវិធីកាន់យក គឺ ដោយការចែកវិធីកាន់យកដែលជាប់ទាក់ទងជាមួយកម្មដ្ឋានដែលត្រូវសម្លឹងមើលជាដើម ។ ឈ្មោះថា **បច្ចយតោ** ដោយបច្ច័យ គឺ ដោយភាពជាបច្ច័យដល់គុណវិសេសទាំងឡាយ មានអរូបជ្ឈានជាដើម តាមសមគួរ ។

ឈ្មោះថា **ចរិយានុកូលតោ** ជាកម្មដ្ឋានដែលអនុកូលដល់ចរិយា គឺ ដោយភាពជាកម្មដ្ឋាន ដែលអនុកូលចំពោះចរិយាទាំងឡាយ មានរាគចរិយាជាដើម ។

ពាក្យថា **កម្មដ្ឋាន** បានដល់ ទីតាំងនៃការប្រព្រឹត្តទៅនៃការធ្វើនូវសេចក្តីព្យាយាមក្នុងភាពជាអារម្មណ៍ ។ ពាក្យថា **ចតុក្កជ្ឈានិក** គឺ បានរូបាវចរជ្ឈានទាំង ៤ យ៉ាង មានន័យថា អារម្មណ៍របស់រូបាវចរជ្ឈាន ៤ យ៉ាងនោះ ។ ពាក្យនេះលោកពោលទុកទាក់ទងជាមួយឈានចតុក្កន័យ ។ ពាក្យថា **ក្នុងបណ្តាកម្មដ្ឋានដែលបានឈាន៣ បានឈាន៤** គឺ ក្នុងបណ្តាព្រហ្មវិហារ ខាងដើម បានឈាន៣ ក្នុងអានាបា និង កសិណទាំងឡាយបានឈាន ៤ ។ ពាក្យថា **ក្នុងបណ្តាកម្មដ្ឋានដ៏សេស** គឺ ក្នុងបណ្តាកម្មដ្ឋាន ២១ ដ៏សេស អំពីកម្មដ្ឋានដែលបានពោលហើយ ។

ព្រះយោគីជាអាទិកម្មិក( ទើបតែបានឈាន ឬអភិញ្ញា ) រមែងអាចនឹងកំណត់ចិត្តរបស់សត្វដែលខ្លួនប្រើទិព្វចក្ខុសម្លឹងមើលហទយរូប ដោយចេតោបរិយញ្ញាណបាន មិនអាចកំណត់ចិត្តសត្វក្រៅពីនេះបានទេ ដូច្នោះការផ្សាយកសិណទៅ រមែងជាបច្ច័យដល់ចេតោបរិយញ្ញាណ ព្រោះហេតុនោះ ទើបលោកពោលថា " **ហើយរមែងជាអ្នកអាចដឹងចិត្តរបស់សត្វដទៃទាំងឡាយបានដោយចិត្តខ្លួនឯង** " ដូច្នេះ ។

ពាក្យថា **ព្រោះត្រូវកំណត់ដោយឱកាស** គឺ ព្រោះត្រូវកំណត់ដោយឱកាសដែលខ្លួនតាំងទៅ ។ មានអធិប្បាយថា ព្រោះព្រះយោគីធ្វើឧគ្គហកោសល្លឲ្យដល់ព្រមដោយអាការយ៉ាងនោះ កម្មដ្ឋានទាំងនោះ ទើបប្រាកដដោយអាការដែលត្រូវកំណត់នោះឯង ព្រោះដូច្នោះ ទើបមិនមានការពង្រីក ។ លោកអាចារ្យកាលនឹងសម្តែងថា បើបុគ្គលគប្បីពង្រីក គ្មានគុណអ្វី ព្រោះការពង្រីកនោះទេ ដូច្នេះទើបលោកពោលថា " **ព្រោះមិនមានអានិសង្ស** " ដូច្នេះ ។

ដោយពាក្យថា **ម្យ៉ាងទៀត កាលព្រះយោគីពង្រីកកម្មដ្ឋានទាំងនោះជាដើម** លោកបើកបង្ហាញការមិនមានអានិសង្សនោះៗ ឯង ។ ព្រោះថា កាលពង្រីកទៅគំនរសាកសពប៉ុណ្ណោះចម្រើនឡើង សូម្បីកាលមិនពង្រីក ក៏មានការគ្របសង្កត់កាមរាគៈបានដូចគ្នា ព្រោះដូច្នេះ ទើបឈ្មោះថា មិនមានអានិសង្ស ។ ពាក្យថា **វិភូតា** ប្រែថា ប្រាកដច្បាស់ ព្រោះភាពជាអារម្មណ៍ធំទូលាយ មានន័យថា ប្រាកដច្បាស់ដោយភាពជាអារម្មណ៍ ដែលរកប្រមាណមិនបាន ព្រោះភាពជានិមិត្តដែលបានពង្រីកហើយ ។

បទថា **កេវលំ** ប្រែថា ទាំងអស់ គឺ មិនមានសល់ ។ ពាក្យថា **កាន់យកបឋវីនោះ លោកពោលទៅតាមអាការដែលប្រាកដ** អធិប្បាយថា មិនមែនពោល

ទុកព្រោះមានការពង្រីកនិមិត្ត ។ ពាក្យថា **ព្រោះជាអ្នកបានភាពជំនាញ** គឺ ព្រោះជាអ្នកបានភាពស្ទាត់យ៉ាងល្អក្រៃលែង គឺថា ព្រោះភាពជំនាញ ដល់ភាពជាវសី ។ ពិតណាស់ ព្រះថេរៈព្រោះដល់នូវភាពជំនាញយ៉ាងក្រៃលែង មិនថាអង្គុយ មិនថាឈរក្នុងទីណា រមែងចូលឈាននោះ ក្នុងទីនោះបាន ដូចសារថីទាញសេះ ទៅក្នុងលានសេះដូច្នោះ ។ ព្រោះហេតុនោះ និមិត្ត ទើបប្រាកដដល់លោក ដោយជុំវិញដូចបានពង្រីក ។ ព្រោះហេតុនោះ ទើបលោកពោលថា **សព្វទិសាសុ** ក្នុងទិសទាំងពួង ដូច្នេះជាដើម ។

ពាក្យថា **ដែលត្រាស់ទុក** គឺ ដែលត្រាស់ទុកក្នុងធម្មសង្គហៈ(ធម្មសង្គណី) ។

បទថា **មហន្តេ** ប្រែថា ក្នុងនិមិត្តដ៏ធំ ។ ពិតណាស់ កាលព្រះយោគីកាន់យកនិមិត្តក្នុងសាកសពទាំងមូល ដោយទាក់ទងជាមួយការកាន់យកនិមិត្តជុំវិញខ្លួនមិន ឈប់នៅត្រង់ចំណុចមួយគឺចំណុចដែលផតនិងចំណុចដែលប៉ោងជាដើម និមិត្តនោះជានិមិត្តដែលធំ ។ ឬប្រែថា ក្នុងសាកសពដែលធំ ។ ពាក្យថា **ក្នុងសរីរៈតូច** ប្រកបសេចក្តីថា រមែងកាន់យកនិមិត្តក្នុងចំណែកមួយនៃសាកសព ។ ឬបានដល់ក្នុងសាកសពទារកដែលតូច គឺ តូច ៗ ។

បទថា **ឯតំ** បានដល់ អសុភនិមិត្ត ។ ពាក្យថា **ទោស** គឺ មិនឃើញទោសដែលលោកពោលទុកថា " **គំនរសាកសពប៉ុណ្ណោះដែលចម្រើនឡើង និងអានិសង្សណាៗ មិនមាន** " ដូច្នេះ ។

ដើម្បីនឹងបើកផ្សារនូវអត្ថន័យដែលបានពោលទុក ដោយសង្ខេបថា **សូម្បីកម្មដ្ឋានដ៏សេសទាំងឡាយ ក៏មិនគួរពង្រីកដូច្នេះ** ដោយចូលដល់ហេតុ ទើបលោកអាចារ្យពោលថា " **ព្រោះហេតុអ្វី** " ដូច្នេះជាដើម ។ លោកអាចារ្យ ធ្វើទុកក្នុងចិត្ត

ថា និមិត្តដែលកំពុងប្រាកដដោយទំនាក់ទំនងគ្នា ដូចប៉ុយគជាដើម មានគំនរខ្យល់ជាទីអាស្រ័យដូច្នេះហើយ ទើបពោលថា គំនរខ្យល់ប៉ុណ្ណោះចម្រើនឡើង ដូច្នេះ ។ ពាក្យថា **ជាកម្មដ្ឋានត្រូវកំណត់ដោយឱកាស** គឺ ជាកម្មដ្ឋានដែលមានការកំណត់ដោយឱកាស មានចុងច្រមុះ បបូរមាត់ជានិមិត្តជាដើម ។ គុណណាៗ ក្នុងការពង្រីកអានាបាននិមិត្តនេះ ដូចក្នុងការពង្រីកវាយោកសិណ មិនមាន មានតែការច្រើនដោយខ្យល់តែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះមានទោស ។ បទថា **តេសំ** ប្រែថា នៃ ព្រហ្មវិហារ ។ ពាក្យថា **និមិត្ត** បានដល់អារម្មណ៍ ។ ពាក្យថា **ប្រយោជន៍ដោយការចម្រើនឡើងនោះ មិនមាន** គឺ ប្រយោជន៍ណាៗ ដោយការពង្រីកគំនរសត្វនោះ ដូចជាក្នុងការពង្រីកបឋវីកសិណជាដើម មិនមាន ។

ពាក្យថា **ដោយការកំណត់កាន់យក** គឺ ដោយអំណាចការកំណត់កាន់យកអារម្មណ៍នៃការនៅដែលមិនទាន់បានកំណត់កាន់យក មិនមែនដោយអំណាចការពង្រីកនិមិត្តទេ ។ ព្រោះហេតុនោះ ទើបលោកពោលថា “ **ដោយស្ថានទីដែលមានអាវាស ១ - ២** ជាដើម ។

បទថា **ឯត្ថ** គឺ ក្នុងការចម្រើនព្រហ្មវិហារ ។ បទថា **យទយំ** កាត់បទជា **យំ** ដែលបានដល់ បដិភាគនិមិត្ត ( ប្រែថា បដិភាគនិមិត្តណា ) **អយំ** បានដល់ព្រះយោគី( ប្រែថា ព្រះយោគីនេះ ) ។ ពិតណាស់ ការកើតឡើងនៃឧបចារជ្ឈានរមែងមានបានដោយ សីមាសម្ភេទនោះឯង មិនមែនមានបានដោយការកើតឡើងនៃនិមិត្តនោះទេ ( **សីមាសម្ភេទ** គឺ ធ្វើការរួមខេត្ត បានដល់ ការចម្រើនមេត្តាដល់សត្វទាំងឡាយមិនរើសមុខ ) ។

សួរថា ប្រសិនបើយ៉ាងនេះសោត ឈាននឹងមានអារម្មណ៍ជាបរិត្តជាដើម បានដូចម្តេច ? លោកអាចារ្យឆ្លើយថា ម្យ៉ាងទៀតក្នុងព្រហ្មវិហារនេះ គប្បីជ្រាបដល់ភាពដែលឈានមានអារម្មណ៍ជាបរិត្ត និង អប្បមាណ ក៏ដោយអំណាចនៃការកំណត់កាន់យកដូច្នេះ មានន័យថា ធម៌ទាំងឡាយមានមេត្តាជាដើម ដែលប្រព្រឹត្តទៅកំណត់កាន់យកសត្វទាំងឡាយចំនួនបន្តិចបន្តួច ៗ ឈ្មោះថា មានអារម្មណ៍ជាបរិត្ត ដែលប្រព្រឹត្តទៅក្នុងការកំណត់យកសត្វចំនួនច្រើន ឈ្មោះថា មានអារម្មណ៍ជាអប្បមាណដូច្នេះ ។ ប្រកបសេចក្តីថា **អាកាស** ព្រោះជាទីដែលកសិណាត្រូវបើកទៅ ទើបមិនគួរពង្រីកដូច្នេះ ។ ឬថាលោកនឹងពោលដល់កម្មដ្ឋាន ( អារម្មណ៍ណា ) ក៏គួរភ្ជាប់( ពាក្យថា មិនគួរពង្រីក ) ចូលជាមួយកម្មដ្ឋាននោះ ។ អារម្មណ៍ដែលកើតពីបរិកម្មប៉ុណ្ណោះ អាចនឹងពង្រីកបាន មិនមែនជាអារម្មណ៍ក្រៅពីនេះទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ពិតណាស់ បុគ្គលមិនអាចពង្រីកសភាវធម៌បានឡើយ ។ គប្បីជ្រាបភាពដែលមានអារម្មណ៍ជាបរិត្ត និងអប្បមាណនៃអរូបកម្មដ្ឋានទាំងឡាយបានដោយការប្រព្រឹត្តទៅក្នុងអាកាស ដែលកសិណាតូចត្រូវបើកទៅ និងក្នុងអាកាសដែលកសិណាធំត្រូវបើកទៅ ។ ឈ្មោះថា **កម្មដ្ឋានដ៏សេសទាំងឡាយ** ( ដែលពោលថា មិនគួរពង្រីក ) បានដល់ កម្មដ្ឋាន១០ មានពុទ្ធានុស្សតិជាដើម។ ពាក្យថា **ព្រោះមិនមាននិមិត្ត** គឺ ព្រោះមិនមានបដិភាគនិមិត្ត។

បទថា **បដិភាគនិមិត្តារម្មណានិ** ប្រែថា មានអារម្មណ៍ជាបដិភាគនិមិត្ត ។

ឈ្មោះថា **កម្មដ្ឋានដ៏សេស** ( ដែលពោលថា មានអារម្មណ៍ជាបដិភាគនិមិត្តក៏ទេ ) បានដល់ កម្មដ្ឋាន ១៨ ។ ពាក្យថា **កម្មដ្ឋាន៦ដ៏សេស** ( ដែលពោលថា មានអារម្មណ៍ជានវត្តព្វធម៌ ) បានដល់ កម្មដ្ឋាន៦ដ៏សេសទាំងនេះគឺ ព្រហ្មវិហារ ៤

អាកាសានញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ ។ **វិបុព្វកកម្មដ្ឋាន** លោកពោលថា មានអារម្មណ៍កម្រើកញាប់ញ័រ ព្រោះភាពដែលនៅមានខ្ទុះកំពុងហូរ ។

**លោហិតកម្មដ្ឋាន** លោកពោលថា មានអារម្មណ៍កម្រើក ញាប់ញ័រ ព្រោះភាពដែលមានលោហិតជិតជាមពាសពេញ ។ **បុឡុវកកម្មដ្ឋាន** លោកពោលថា មានអារម្មណ៍កម្រើកញាប់ញ័រ ព្រោះមានពពួកដង្កូវរុករវើកទូទៅ ។ អាការដែលរំកិលរបស់ពន្លឺនៃព្រះអាទិត្យជាដើម ដែលចូលទៅខាងក្នុង ( បន្ទប់ ) មានចន្លោះបង្អួចជាដើម រមែងប្រាកដបាន ព្រោះហេតុនោះ **កសិណ** សូម្បីមានពន្លឺជាអារម្មណ៍ ក៏លោកពោលថា មានអារម្មណ៍កម្រើកញ័រ ។

ពាក្យថា **ក្នុងកាលដែលជាចំណែកខាងដើម** គឺ ក្នុងកាលដែលជាចំណែកខាងដើម អំពីការបានសម្រេចបដិភាគនិមិត្ត ។ ពាក្យថា **ជាអារម្មណ៍ស្ងប់** គឺ ជាអារម្មណ៍ស្ងប់មិនញាប់ញ័រ ។

ពាក្យថា **ក្នុងទេវតាទាំងឡាយ** គឺ ក្នុងទេវតាជាន់កាមាវចរទាំងឡាយ ព្រោះក្នុងទេវតាជាន់កាមាវចរនោះ មិនមានសាកសព និង អាហារដែលជាបដិកូល ។ លោកពោលថា ( **កម្មដ្ឋាន ១២ នោះ** ) និង **អានាបានស្សតិ** រមែងមិនប្រព្រឹត្តទៅក្នុងព្រហ្មលោក ព្រោះក្នុងព្រហ្មលោកមិនមានខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូល ។

បទថា **ទិដ្ឋេន** គឺ ដោយការមើល បានដល់ ដោយវត្ថុដែលជាហេតុនៃការមើល ។

ពាក្យថា **គប្បីកាន់យក** គឺ គប្បីឡើងកាន់ មានន័យថា មានឧគ្គហនិមិត្តដែលគប្បីធ្វើឲ្យកើតឡើង ។ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងកាលដែល

ជាចំណែកខាងដើម ដូច្នេះជាដើម ។

បទថា **តស្សា** បានដល់ នៃកាយគតាសតិ ។ លោកពោលថា **វាយោ-កសិណា** គប្បីកាន់យកបានដោយការមើលនិងការប៉ះខ្ទប់ដូច្នេះ ព្រោះវាយោកសិណានោះព្រះយោគីគប្បីកាន់យកបានក្នុងស្លឹកអំពៅ ស្លឹកសន្ទូងជាដើម ឬដោយការកាន់យកត្រង់ស្បែកកាយដែលកំពុងកម្រើកជាប្រចក្ខផ្ទូវ ។ ពាក្យថា **ព្រះយោគីដែលជាអាទិកម្មិកមិនគប្បីកាន់យក** គឺ ព្រះយោគីដែលជាអាទិកម្មិកមិនគួរកាន់យក បានដល់ មិនគួរតាំងចូលទុកមុន ដែលជាប់ទាក់ទងជាមួយការផ្ដើមចម្រើន ព្រោះមិនទាន់សម្រេចបានព្រហ្មវិហារ៣ខាងដើម និងរូបាវចរចតុត្ថជ្ឈានក្នុងកសិណទាំងឡាយហើយក៏មិនអាចធ្វើឲ្យសម្រេចបាន ។

ពាក្យថា **ក្នុងបណ្ដាកម្មដ្ឋានទាំងនោះ នេះដោយស័ព្ទថា កម្មដ្ឋាន** គប្បីជ្រាបថា លោកកាន់យកអារម្មណ៍ទាំងឡាយ និង ឈានទាំងឡាយតាមសមគួរ ។

ពាក្យថា **ដល់សុខវិហារ** គឺ ដល់ទិដ្ឋធម្មសុខវិហារ ។

ពាក្យថា **កម្មដ្ឋាន ១១ អនុកូល** ( ចំពោះបុគ្គលរាគចរិត ) នេះលោកពោលទុកដោយទាក់ទងជាមួយនឹងភាពជាបដិបក្ខដោយត្រង់ ។ សូម្បីក្នុងពាក្យដ៏សេស ក៏យ៉ាងនេះ ។ ពិតណាស់ លោកនឹងពោលថា “ **ពាក្យទាំងអស់នេះ** ” ដូច្នេះជាដើម ។ ឈ្មោះថា **អនុកូល** ព្រោះជាឧបាយគ្របសង្កត់រាគៈ ។

ប្រកបសេចក្ដីថា កម្មដ្ឋាន៨ អនុកូល ( ចំពោះទោសចរិត ) ។ សូម្បីក្នុងបទដ៏សេស ក៏មានពាក្យប្រកបសេចក្ដីយ៉ាងនេះ ។

ពាក្យថា **តែម្យ៉ាង** ( ក្នុងពាក្យថា អានាបានស្សតិកម្មដ្ឋានតែម្យ៉ាង ) នេះសំដៅដល់ពួកអនុស្សតិ គឺ ជាកម្មដ្ឋានតែម្យ៉ាង ក្នុងបណ្ដាពួកអនុស្សតិទាំងឡាយ

ព្រោះហេតុនោះ ទើបមិនបានសំដៅដល់បុគ្គលមោហចរិត និង វិតក្កចរិត ព្រោះបុគ្គលមោហចរិត និង វិតក្កចរិតទាំងនោះ គង់បានកម្មដ្ឋានដែលអនុកូលសូម្បីយ៉ាងដទៃ ។ ពាក្យថា **អនុស្សតិ ៦ អនុកូលចំពោះបុគ្គលសទ្ធាចរិត** នេះ លោកពោលទុកទាក់ទងជាមួយនឹងសប្បាយយ៉ាងក្រៃលែង ។

កសិណដ៏សេសទាំងឡាយ និងអរូប៤ ឈ្មោះថា អនុកូលចំពោះបុគ្គលចរិតទាំងពួង ព្រោះមិនមានភាពវិសេសដែលគប្បីកាន់យកបានថា ជាបដិបក្ខចំពោះចរិតនោះ ៗ ជាសប្បាយក្រៃលែងសម្រាប់ចរិតនោះ ៗ ដូច្នេះ ។ ពាក្យថា **ដែលជាបរិត្ត** គឺ ដែលមានទំហំប៉ុនផ្តិល ឬចាន ។ ពាក្យថា **ដែលជាអប្បមាណ** គឺ ដែលមានប្រមាណធំជាងផ្តិល ។

ម្យ៉ាងទៀត កសិណដែលមានទំហំប៉ុនចង្អេរ ឬផ្តិល ឈ្មោះថា **បរិត្ត** ដែលមានប្រមាណធំជាងនោះ ឈ្មោះថា **អប្បមាណ** បានដល់ មណ្ឌលលានជាដើមដែលព្រះយោគីកំណត់កាន់យកដោយភាពជាកសិណ ។ ពាក្យថា **ធម៌៤យ៉ាង** បានដល់ ធម៌ដែលភិក្ខុគប្បីមនសិការ៤យ៉ាង ។ ពាក្យថា **ឲ្យក្រៃលែងឡើងទៅ** គឺ ឲ្យខ្ពស់ជាងការតាំងមាំក្នុងធម៌ ៥ យ៉ាង គឺ **សីលសម្បទា** ការដល់ព្រមដោយសីល១ , **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត១ , **សប្បាយធម្មស្សវន** ការស្តាប់ធម៌ដែលជាសប្បាយ១ , **វីរិយ** ការព្យាយាម១ , **បញ្ញា** សេចក្តីដឹង១ ។

ពាក្យថា **អសុភ** គឺ អសុភភាវនា បានដល់ ការប្រកបរឿយៗនូវភាវនាក្នុងអសុភកម្មដ្ឋាន១១ ។ ពាក្យថា **មេត្តា** បានដល់ មេត្តាភាវនាដែលប្រព្រឹត្តទៅដោយមិនមានព្រំដែន ឬ ដោយមានព្រំដែន ។ ពាក្យថា **អានាបានស្សតិ** បានដល់សមាធិភាវនាក្នុងអានាបានស្សតិដែលមានវត្ថុ ១៦ ។ ពាក្យថា **ដើម្បីកាត់វិតក្ក** គឺ

ដើម្បីប្រយោជន៍ដល់ការចូលទៅកាត់បង់នូវមិច្ឆាវិតក្ក ។ ពាក្យថា **អនិច្ចសញ្ញា** បាន ដល់ អនិច្ចានុបស្សនាដែលប្រព្រឹត្តយ៉ាងនេះថា “ **សព្វេ សង្ខារា អនិច្ចា** ” សង្ខារទាំងពួងមិនទៀងដូច្នេះ ។ ពាក្យថា **ដើម្បីដកអស្មិមានះ** គឺ ដើម្បីកាត់ផ្ដាច់ មានះ៩យ៉ាង ដែលកើតឡើងថា “ **យើងមាន** ” ដូច្នេះ ។ ពិតណាស់ ក្នុងសូត្រ នេះសម្រាប់បុគ្គលមួយៗប៉ុណ្ណោះ ដែលត្រាស់ថា គួរចម្រើនធម៌៤យ៉ាង និង ទ្រង់ ត្រាស់ថា គួរចម្រើនធម៌៤យ៉ាង ព្រោះភាពនៃបុគ្គលម្នាក់ មានចរិត៤យ៉ាង ក៏ទេ ។

ព្រោះពាក្យនោះ ជនរមែងដឹងបានថា “ **កម្មដ្ឋានសូម្បីទាំងអស់ ជាគ្រឿង គ្របសង្កត់អកុសលទាំងពួង ជាគ្រឿងទំនុកបម្រុងកុសលទាំងពួង** ” ។

អធិប្បាយថា ទ្រង់ត្រាស់កម្មដ្ឋានសម្រាប់បុគ្គលមួយប៉ុណ្ណោះទុករហូតដល់ ទៅ៧កម្មដ្ឋាន តែថា ព្រះរាហុលមិនបានជាបុគ្គលចរិតគ្រប់ចរិតទេ ។

ពាក្យថា **គ្រាន់តែជាពាក្យពោលប៉ុណ្ណោះ** គឺ គ្រាន់តែជាពាក្យពោលហើយ យ៉ាងនេះថា កម្មដ្ឋាននេះអនុកូលចំពោះបុគ្គលចរិតនោះ។ ពាក្យថា **ពាក្យអធិប្បាយ** គឺ ពាក្យអធិប្បាយនៃពាក្យនោះ ។ ក៏ពាក្យអធិប្បាយនោះ លោកអាចារ្យបានបើក ផ្សាយហើយដោយពាក្យថា **សព្វញ្ចេតំ** ពាក្យទាំងអស់ដូចពោលមកនេះ ដូច្នេះជាដើម នោះឯង ។

ព្រះយោគី ឈ្មោះថា ចូលទៅរកកល្យាណមិត្ត ដែលមានប្រការដូចពោល ហើយយ៉ាងនេះ ដោយពាក្យថា “ គួរស្រឡាញ់ គួរគោរព ” ជាដើម តាមន័យ ដែលបានពោលទុកថា “ កាន់យកបាត្រ និងចីវររបស់ខ្លួនឯងប៉ុណ្ណោះ ”ជាដើម ។ ឈ្មោះថា នឹងកើតសោមនស្សតែម្យ៉ាង ក៏កាលពិចារណាយ៉ាងនេះថា “ អត្តភាព ដែលមានអន្តរាយច្រើនប្រការនេះ យើងបានប្រគល់ទៅក្នុងឋានៈដែលគួរហើយ ”។

ព្រោះហេតុនោះ ទើបលោកឧបមាថា “ **យថាហិ** ដូចជា ” ដូច្នេះជាដើម ។

បទថា **អតជ្ជនីយោ** ប្រែថា ជាអ្នកដែលអាចារ្យមិនអាចជាស់តឿនបាន គឺមិនអាចហាមបាន ។ លោកអាចារ្យបំណាំងសំដែងផលទាំងពីរយ៉ាងនោះថា ភាពជាបុគ្គលដែលអាចារ្យមិនអាចជាស់តឿនបាន ដូច្នោះ គឺ ជាអ្នកប្រដៅក្រខ្វះ គ្មានការស្រឡាញ់គិតគូរចំពោះអាចារ្យខ្វះ ដូច្នេះ ទើបពោលថា ជាអ្នកប្រដៅក្រខ្វះ ដូច្នេះជាដើម ។ ពិតណាស់ បុគ្គលណាកាលត្រូវអាចារ្យជាស់តឿនក៏អន់ចិត្ត ខឹងក្រោធនិងមិនជឿស្តាប់ឲ្យប្រាកដក្តី បុគ្គលណាគិតថា “ ប្រយោជន៍អ្វីដោយការនៅក្នុងសម្នាក់របស់បុគ្គលនោះវិញ ” ដូច្នេះ ហើយចៀសទៅក្តី បុគ្គលសូម្បីទាំងពីរជំពូកនេះ ឈ្មោះថា ជាអ្នកដែលអាចារ្យមិនអាចជាស់តឿនបាន ។ ពាក្យថា **សង្គ្រោះដោយធម៌** បានដល់ ដោយធម៌ គឺ ឱវាទ និង អនុសាសនី ។

ពាក្យថា **គន្ថៈដែលជ្រាលជ្រៅ** គឺ កម្មដ្ឋានគន្ថៈ ( ឱវាទដែលទាក់ទងដោយកម្មដ្ឋាន ) ដែលប្រកបដោយសច្ចៈ និងបដិច្ចសមុប្បាទជាដើម និង ដែលទាក់ទងជាមួយសុញ្ញតាដ៏ជ្រាលជ្រៅ ។

បទថា **តុម្ហាកំ អត្ថាយាតិ វិត្តេ** មានន័យថា អង្គមួយពោលថា “ ប្រយោជន៍ណាៗ មានដល់លោកដោយការដែលខ្ញុំព្រះករុណាលោតចុះទៅក្នុងជ្រោះមានជម្រៅ ១០០ ជួរបុរស ក៏ .....” ដូច្នេះ ។ ពាក្យថា **ត្រដុស** មានន័យថា ភិក្ខុមួយអង្គពោលថា “ ប្រយោជន៍ណាៗ មានដល់លោកដោយលំអិតកម្ទេចមនុស្សនៅមាន ក៏ .....” ខ្ញុំព្រះករុណាអាចដុសអត្តភាពឲ្យសឹកអស់ទៅមិនមានសល់ ។ មួយអង្គទៀតពោលថា “ ប្រយោជន៍ណាៗ មានដល់លោកម្ចាស់ដើម្បីព្យាបាលរោគបានជាដើម ដោយការអត់ដង្ហើមរបស់ខ្ញុំព្រះករុណានៅមាន ក៏ ..... ” ។ ជាការដែល

កិក្ខុទាំង៣អង្គ ប្រកាសការផ្តើមសេចក្តីព្យាយាម ដោយការប្រកាសកក្តីភាពដល់អាចារ្យ នោះ គឺ ជាប្រកផ្លូវ ។

**ចិត្ត** សូម្បីប្រព្រឹត្តទៅក្នុងអារម្មណ៍ដទៃៗ ហើយត្រឡប់មកអាស្រ័យនៅក្នុងអារម្មណ៍ណានោះ ឈ្មោះថា អាស្រ័យទីអាស្រ័យនៃចិត្តនោះ ដូចជាពាក្យថា " **មិគាសយ** " ទីអាស្រ័យនៃម្រឹគ ដូច្នោះ អាស្រ័យនោះឯងជា **អជ្ឈាសយ** ។

**អជ្ឈាសយ** នោះមានពីរយ៉ាងគឺ អជ្ឈាសយវិបត្តិ១ អជ្ឈាសយសម្បត្តិ១ ។

ក្នុង **អជ្ឈាសយ** ២ យ៉ាងនោះ អជ្ឈាសយវិបត្តិអាស្រ័យការប្រកាន់ខុសថាទៀង ជាដើម ។

**អជ្ឈាសយសម្បត្តិ** មាន២យ៉ាង គឺ អាស្រ័យវដ្ដៈ១ អាស្រ័យវិវដ្ដៈ១ ។

ក្នុងអជ្ឈាសយសម្បត្តិ២យ៉ាងនោះ ក្នុងពាក្យថា " **ជាអ្នកមានអធ្យាស្រ័យដល់ព្រម** " នេះសំដៅយកអធ្យាស្រ័យវិវដ្ដៈ ។

ឥឡូវនេះលោកអាចារ្យបំណងសំដែងអធ្យាស្រ័យសម្បត្តិនោះ ដោយការចែកទើបពោលថា " ដោយទាក់ទងជាមួយគុណទាំងឡាយ មានអលោភៈជាដើម " ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដោយអាការ៦** គឺ ដោយអាការ ៦ មានអាការដែលមិនលោភជាដើម ។ ពាក្យថា **ជាអ្នកមានអធ្យាស្រ័យសម្បត្តិ** មានន័យថា ឈ្មោះថា ជាអ្នកមានអធ្យាស្រ័យដល់ព្រម ព្រោះអត្ថថា មានអធ្យាស្រ័យដល់ព្រមដោយទាក់ទងជាមួយការធ្វើគុណដែលជាចំណែកខាងដើម មានសីល-សម្បទា ជាដើមឲ្យសម្រេច និង ដោយភាពជាឧបនិស្សយប្បច្ច័យដល់លោកុត្តធម៌ទាំងឡាយ បានដល់ ជាអ្នកមានអធ្យាស្រ័យដល់ព្រមនោះឯង ។

ពិតណាស់ ធម៌ទាំងឡាយ មានអលោភៈជាដើម មានឧបការៈច្រើនដល់

សត្វទាំងឡាយ ដោយការកម្ចាត់ទោសជាអនេក និង ដោយការនាំមកនូវគុណជាអនេក មានឧបការច្រើនដល់ព្រះយោគីដោយពិសេស ។ ពិតយ៉ាងនោះ ធម៌ទាំងឡាយមានអលោភៈជាដើម រមែងប្រព្រឹត្តទៅជាបដិបក្ខចំពោះមន្ទិលគឺ មច្ឆរិយៈជាដើម ។

សេចក្តីនេះសមតាមដែលព្រះអដ្ឋកថាចារ្យពោលទុកថា :

អលោភៈ ជាបដិបក្ខដល់មន្ទិល គឺសេចក្តីកំណាញ់ , អទោសៈ ជាបដិបក្ខដល់មន្ទិល គឺ ភាពទ្រុស្តសីល , អមោហៈ ជាបដិបក្ខដល់ភាពមិនចម្រើនក្នុងកុសលធម៌ទាំងឡាយដូច្នេះ ។

មយ៉ាងទៀត ក្នុងបណ្តាធម៌ មានអលោភៈជាដើមទាំងនេះ អលោភៈជាហេតុនៃទាន អទោសៈជាហេតុនៃសីល អមោហៈជាហេតុនៃភាវនា ។ មយ៉ាងទៀត ក្នុងបណ្តាធម៌ មានអលោភៈជាដើមនោះ បុគ្គលរមែងកាន់យកមិនច្រើនហួសប្រមាណដោយអលោភៈ ព្រោះបុគ្គលលោភមានការកាន់យកច្រើនហួសប្រមាណ , រមែងកាន់យកមិនខុសដោយអទោសៈ ព្រោះបុគ្គលក្រោធមានការកាន់យកកំហុស , រមែងកាន់យកមិនភ្លាំងភ្លាត់ដោយអមោហៈ ព្រោះបុគ្គលវង្វេងមានការកាន់យកភ្លាំងភ្លាត់ ។

មយ៉ាងវិញទៀត ក្នុងបណ្តាធម៌ មានអលោភៈជាដើមនេះ បុគ្គលរមែងទទួលទោសដែលមាន ដោយភាពជាទោស រមែងសារភាពទោសដោយអលោភៈ ព្រោះថា បុគ្គលលោភរមែងបិទបាំងទោស ។ រមែងទទួលគុណដែលមាន ដោយភាពជាគុណ រមែងប្រព្រឹត្តទៅក្នុងគុណព្រោះអទោសៈ ព្រោះថាបុគ្គលក្រោធ រមែងលុបគុណ ។ រមែងទទួលសភាវៈ តាមសេចក្តីពិត ដោយជាសភាវៈតាមសេចក្តីពិត រមែងប្រព្រឹត្តទៅក្នុងសភាវៈតាមសេចក្តីពិត ដោយអមោហៈ ព្រោះថា បុគ្គលវង្វេង

រមែងកាន់យកវត្ថុដែលពិតថា “ មិនពិត ” និង វត្ថុដែលមិនពិតថា “ ពិត ” ។

ម្យ៉ាងទៀត ទុក្ខព្រោះការព្រាត់ចាកពីវត្ថុដែលជាទីស្រឡាញ់ រមែងមិនមានដោយអលោភៈ ព្រោះបុគ្គលលោកត្រូវមានវត្ថុដែលខ្លួនស្រឡាញ់ជាប្រក្រតី និង ព្រោះបុគ្គលលោកអត់ធន់ចំពោះការព្រាត់ប្រាសអំពីវត្ថុជាទីស្រឡាញ់មិនបាន ។ ទុក្ខព្រោះការជួបវត្ថុដែលមិនជាទីស្រឡាញ់ រមែងមិនមានដោយអទោសៈ ព្រោះបុគ្គលក្រោធតែងស្អប់វត្ថុដែលមិនជាទីស្រឡាញ់ជាប្រក្រតី និង ព្រោះបុគ្គលក្រោធអត់ធន់ចំពោះការជួបប្រទះវត្ថុដែលមិនជាទីស្រឡាញ់មិនបាន ។ ទុក្ខព្រោះមិនបានវត្ថុដែលត្រូវការ រមែងមិនមានដោយអមោហៈ ព្រោះបុគ្គលមិនវង្វេង មានការពិចារណាយ៉ាងនេះថា “ សេចក្តីនេះយើងនឹងរកបានក្នុងធម៌នេះអំពីទីណា ” ដូច្នេះជាដើមជាប្រក្រតី ។

ម្យ៉ាងទៀត ក្នុងបណ្តាធម៌ មានអលោភៈជាដើមនេះ ជាតិទុក្ខ រមែងមិនមានដោយអលោភៈ ព្រោះអលោភៈជាបដិបក្ខចំពោះតណ្ហា និង ព្រោះជាតិទុក្ខមានតណ្ហាជាមូល ។ ជរាទុក្ខ រមែងមិនមានដោយអទោសៈ ព្រោះបុគ្គលដែលមានទោសៈខ្លាំងក្លា មានការចាស់ដោយឆាប់រហ័ស ។ មរណទុក្ខ រមែងមិនមានដោយអមោហៈ ឯសេចក្តីស្លាប់ដោយការវង្វេងជាទុក្ខ តែបុគ្គលមិនវង្វេងរមែងមិនជាទុក្ខព្រោះការស្លាប់ដោយវង្វេងនោះ ។

ម្យ៉ាងទៀត ការនៅរួមគ្នាជាសុខនៃពួកគ្រហស្ថ រមែងមានដោយអលោភៈ ការនៅរួមគ្នាជាសុខនៃពួកបព្វជិតរមែងមានព្រោះអមោហៈ ការនៅរួមគ្នាជាសុខនៃមនុស្សទាំងពួង រមែងមានព្រោះអទោសៈ ។

ម្យ៉ាងទៀត ដោយវិសេសក្នុងបណ្តាធម៌ មានអលោភៈជាដើមនេះ ការឧប្បត្តិ

ក្នុងបេតវិស័យ រមែងមិនមានព្រោះអលោភៈ ព្រោះថា សត្វទាំងឡាយដោយច្រើនចូលដល់បេតវិស័យព្រោះតណ្ហា ឯអលោភៈជាបដិបក្ខចំពោះតណ្ហា ។ ការឧប្បត្តិក្នុងនរករមែងមិនមានដោយអទោសៈ ព្រោះថា សត្វទាំងឡាយរមែងចូលដល់នរកដោយទោសៈ ព្រោះភាពដែលមានជាតិកាចបាន ក៏មកអំពីទោសៈ ឯអទោសៈជាបដិបក្ខចំពោះទោសៈ ។ ការកើតក្នុងកំណើតតិរច្ឆាន រមែងមិនមានព្រោះអមោហៈ ព្រោះថា សត្វទាំងឡាយចូលដល់កំណើតតិរច្ឆាន ដែលវង្វេងជានិច្ចនេះ មកពីមោហៈ ឯអមោហៈជាបដិបក្ខចំពោះមោហៈ ។

ម្យ៉ាងទៀត ក្នុងបណ្តាធម៌ មានអលោភៈជាដើមនេះ អលោភៈជាធម៌ធ្វើមិនឲ្យមានការជាប់ជំពាក់ដោយអំណាចរាគៈ អទោសៈជាធម៌ធ្វើមិនឲ្យមានការជាប់ជំពាក់ដោយអំណាចទោសៈ អមោហៈជាធម៌ធ្វើមិនឲ្យមានភាពលំអៀងដោយមោហៈ ។

ម្យ៉ាងទៀត សញ្ញា៣នេះ គឺ នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹង្សាសញ្ញា និង សញ្ញា៣ទៀត គឺ អសុភសញ្ញា អប្បមាណសញ្ញា ធាតុសញ្ញា រមែងមានបានដោយធម៌ទាំង៣នេះតាមលំដាប់ ។ ចំណែកការវៀរចាកទីបំផុតគឺ កាមសុខល្លិកានុយោគ រមែងមានបានដោយអលោភៈ ការវៀរចាកទីបំផុតគឺ អត្តកិលមថានុយោគ រមែងមានបានដោយអទោសៈ ការបដិបត្តិក្នុងមជ្ឈិមាបដិបទា រមែងមានបានព្រោះអមោហៈ ។

យ៉ាងនោះដូចគ្នាដែរ ការទម្លាយអភិជ្ឈាកាយគន្ថៈ រមែងមានបានដោយអលោភៈ ការទម្លាយព្យាបាទកាយគន្ថៈ រមែងមានបានដោយអទោសៈ ការទម្លាយគន្ថៈ ២ ដ៏សេស រមែងមានបានព្រោះអមោហៈ ។

ម្យ៉ាងទៀត សតិប្បដ្ឋានពីរខាងដើម រមែងសម្រេចបាន ដោយអានុភាពនៃ

ធម៌ពីរខាងដើម ( គឺ អលោភៈ និង អទោសៈ ) សតិប្បដ្ឋានពីរខាងចុង រមែង សម្រេចបានព្រោះ អានុភាពនៃធម៌ពួកខាងក្រោយ ( គឺ អមោហៈ ) នោះឯង ។

ម្យ៉ាងទៀត ក្នុងធម៌ ៣ យ៉ាង មានអលោភៈជាដើមនេះ អលោភៈ រមែងជា បច្ច័យដល់ការមិនមានរោគ ព្រោះថា បុគ្គលមិនលោភ រមែងមិនសេពវត្ថុដែលជា អសប្បាយ សូម្បីគួរឲ្យចង់បាន ព្រោះហេតុនោះ ទើបជាអ្នកមិនមានរោគ ។

អទោសៈ រមែងជាបច្ច័យដល់ភាពជាកំលោះក្រមុំ ព្រោះថា បុគ្គលមិនក្រោធ កាលមិនត្រូវភ្លើងគឺទោសៈដែលនាំមកនូវភាពជាអ្នកមានស្បែកជ្រីវជ្រួញ មានសក់ ស្កូវ ដោយការដុតរោល អាចជាកំលោះក្រមុំបានយូរ ។

អមោហៈ រមែងជាបច្ច័យដល់ភាពជាអ្នកមានអាយុវែង ព្រោះថា បុគ្គលមិន វង្វេង ស្គាល់វត្ថុដែលជាប្រយោជន៍ និង មិនមែនជាប្រយោជន៍ ហើយក៏វៀរចាក វត្ថុដែលគ្មានប្រយោជន៍ចេញ សេពតែវត្ថុដែលមានប្រយោជន៍ ទើបជាអ្នកមាន អាយុវែង ។

ម្យ៉ាងទៀត ក្នុងធម៌៣យ៉ាង មានអលោភៈជាដើមនេះ អលោភៈ រមែងជា បច្ច័យដល់ភោគសម្បត្តិ ព្រោះមានការបានភោគសម្បត្តិមកក៏ដោយការបរិច្ចាគ ។

អទោសៈ រមែងជាបច្ច័យដល់មិត្តសម្បត្តិ ព្រោះបាននូវមិត្តទាំងឡាយ និង មិនវិនាសមិត្តបានក៏ដោយមេត្តា ។

អមោហៈ ជាបច្ច័យដល់អត្តសម្បត្តិ ព្រោះថា បុគ្គលមិនវង្វេងកាលធ្វើនូវ ប្រយោជន៍ចំពោះខ្លួន ក៏រមែងធ្វើខ្លួនឲ្យដល់ព្រមបាន ។

ម្យ៉ាងទៀត អលោភៈ រមែងជាបច្ច័យដល់ទិព្វវិហារ អទោសៈ ជាបច្ច័យ ដល់ព្រហ្មវិហារ អមោហៈ ជាបច្ច័យដល់អរិយវិហារ ។

ម្យ៉ាងទៀត ក្នុងធម៌៣យ៉ាង មានអលោភៈជាដើមនេះ រមែងរំលត់នូវសេចក្ដីសោកក្នុងសត្វនិងសង្ខារទាំងឡាយដែលជាចំណែករបស់ខ្លួនដោយអលោភៈ ព្រោះសត្វ និងសង្ខារទាំងនោះវិនាសទៅ ក៏មិនកើតទុក្ខដែលមានការជាប់ជំពាក់ជាហេតុ។ ការមិនសោកព្រោះសត្វ និង សង្ខារដែលជាចំណែករបស់អ្នកដទៃ មានបានដោយអទោសៈ ព្រោះបុគ្គលមិនក្រោធ មិនមានការសម្គាល់ក្នុងជនទាំងឡាយ សូម្បីជាសត្រូវ ថាជាសត្រូវឡើយ ។

ការមិនសោកក្នុងសត្វ និង សង្ខារដែលជាក់ចិត្តស្មើៗ ( គឺ មិនប្រកាន់ថាជារបស់ខ្លួន និង របស់អ្នកដទៃ ) មានបានដោយអមោហៈ ព្រោះបុគ្គលមិនវង្វេងគ្មានការជាប់ជំពាក់ក្នុងវត្ថុទាំងពួង ។

ម្យ៉ាងទៀត ការឃើញថា មិនទៀង មានបានដោយអលោភៈ ព្រោះថា បុគ្គលលោភមិនឃើញសង្ខារទាំងឡាយដែលមិនទៀងថា **មិនទៀង** ព្រោះសង្ឃឹមនឹងប្រើប្រាស់ ។ ការឃើញថាជា **ទុក្ខ** មានបានព្រោះអទោសៈ ព្រោះថា បុគ្គលមានអធ្យាស្រ័យក្នុងអទោសៈ ជាអ្នកលះបង់ការប្រកាន់មាំក្នុងអាឃាតវត្ថុ រមែងឃើញសង្ខារនោះថាជាទុក្ខ ។ ការឃើញថាជា **អនត្តា** រមែងមានបានដោយអមោហៈ ព្រោះថា បុគ្គលមិនវង្វេង គឺជាអ្នកឆ្លាតក្នុងការកាន់យកតាមសេចក្ដីពិត រមែងដឹងខន្ធ៥ ដែលមិនមានម្ចាស់ថា មិនមានម្ចាស់ ។ ដូចការឃើញថា **មិនទៀង** ជាដើម រមែងមានបានដោយធម៌ទាំងនេះយ៉ាងណា សូម្បីធម៌ទាំងនេះ ក៏រមែងមានបានដោយការឃើញថា **មិនទៀង** ជាដើមដូច្នោះ ។

ពិតណាស់ អលោភៈ រមែងមានបាន ព្រោះការឃើញថា **មិនទៀង** , អទោសៈ រមែងមានបាន ព្រោះការឃើញថាជា **ទុក្ខ** , អមោហៈ រមែងមានបាន

ព្រោះការឃើញថាជា **អនត្តា** ។

នរណាហ្ន៎ ! ដឹងដោយប្រពៃថា “ វត្ថុនេះមិនទៀង ហើយក៏នៅធ្វើសេចក្ដីស្រឡាញ់ឲ្យកើតឡើងដើម្បីប្រយោជន៍ដល់វត្ថុនោះទៀត ឬថាកាលជ្រាបនូវសង្ខារទាំងឡាយថាជាទុក្ខក៏នៅធ្វើទុក្ខ គឺ សេចក្ដីក្រោធដទៃបន្ថែមឲ្យកើតឡើងទៀត និងដឹងភាពជារបស់ទទេអំពីអនត្តា ហើយក៏នៅដល់ភាពវង្វេងទៀតដូច្នេះ ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណា ទើបពោលថា “ ឈ្មោះថា ជាអ្នកមានអធ្យាស្រ័យ ដល់ព្រមព្រោះអត្ថថា មានអធ្យាស្រ័យដល់ព្រម ដែលទាក់ទងក្នុងការធ្វើគុណជាចំណែកខាងដើម មានសីលសម្បទាជាដើមឲ្យសម្រេច និង ដោយភាពជាឧបនិស្សយ-ប្បច្ច័យដល់លោកុត្តរធម៌ទាំងឡាយ ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា រមែងសម្រេចនូវពោធិឯណានីមួយនៃពោធិទាំង ៣ យ៉ាងនេះ ដូច្នេះ ។

ឥឡូវនេះលោកអាចារ្យបំណងនឹងបើកផ្សាយនូវអជ្ឈាសយៈទាំងនោះ ដោយព្រះបាលីនោះឯង ទើបពោលថា “ **ដូចដែលលោកពោលថា** ” ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **៦** ជាការកំណត់ចំនួន ។ ពាក្យថា **អជ្ឈាសយ** ជាការសម្ដែងដល់ធម៌ដែលបានកំណត់ទុក ។ តែព្រោះរួមទាំង ២ពាក្យ ឲ្យជាពាក្យមួយ ទើបមានអត្ថន័យថា **ឆព្វិធា អជ្ឈាសយា** អជ្ឈាសយៈមាន ៦ យ៉ាង ។ ពាក្យថា **ពោធិសត្វ** បានដល់ អ្នកដែលនឹងត្រាស់ដឹង ម្យ៉ាងទៀត សត្វដែលជាប់ជំពាក់ គឺការបង្អោនទៅដោយភាពជាសត្វទៀងក្នុងការត្រាស់ដឹង មានន័យថា ទោរទន់ទៅក្នុងការត្រាស់ដឹងនោះ បង្អោនទៅក្នុងការត្រាស់ដឹងនោះ ។

ពាក្យថា **រមែងប្រព្រឹត្តទៅព្រមដើម្បីភាពចាស់ក្លាដោយជុំវិញនៃពោធិ** គឺរមែងមានដើម្បីការធ្វើពោធិដែលខ្លួនគប្បីសម្រេចឲ្យទុំដោយជុំវិញ បានតាមសមគួរ

ដល់អភិនីហារ ។

ពាក្យថា **មានអធ្យាស្រ័យក្នុងអលោភៈ** គឺ មានអធ្យាស្រ័យប្រព្រឹត្តទៅដោយអាការដែលមិនលោភ បានដល់ អធ្យាស្រ័យប្រព្រឹត្តទៅដោយអំណាចមិនលោភមកតាំងពីដើម និង ក្នុងកណ្តាល ដោយន័យថា " យើងនឹងជាអ្នកមិនលោភឡើយក្នុងទីទាំងពួង និងអស់កាលទាំងពួងបានយ៉ាងណាហ្ន៎ ! " និង ដោយអំណាចការញុំាងភាពមិនលោភនោះឲ្យរុងរឿងឡើងក្នុងពេលក្រោយ ។

ពាក្យថា **មានប្រក្រតីឃើញទោសក្នុងលោភៈ** គឺ មានប្រក្រតីឃើញទោសដោយអាការទាំងពួងក្នុងលោភៈ ដែលមានការចង់បាន ជាលក្ខណៈ ។

ពាក្យនេះជាការសម្តែងអាការរីកចម្រើននៃអធ្យាស្រ័យនោះតែម្យ៉ាង ។

ពិតណាស់ អធ្យាស្រ័យក្នុងអលោភៈ រមែងចម្រើនដោយជុំវិញដល់បុគ្គលដែលសម្លឹងឃើញទោសក្នុងលោភៈ និងអានិសង្សក្នុងអលោភៈ វិធីសម្លឹងមើលទោស និងអានិសង្ស ក្នុងលោភៈ និងអលោភៈនោះ លោកក៏បានបើកបង្ហាញទុកហើយដែរ លោកបានអធិប្បាយទុកហើយក្នុងបទដ៏សេសទាំងឡាយ គប្បីជ្រាបអត្ថន័យដោយន័យនេះចុះ ។

ចំណែកតទៅនេះជាគោលផ្សេង ៗ តទៅ :

ពាក្យថា **នេក្ខម្ម** ក្នុងទីនេះ គឺ ការបួស ។ ឈ្មោះថា **បវិវេក** បានដល់ តទង្គវិវេក វិក្ខម្ភនវិវេក កាយវិវេក និង ចិត្តវិវេក ។ ឈ្មោះថា **និស្សរណ** បានដល់ និព្វាន ។ ពាក្យថា **ក្នុងភព** និង គតិទាំងពួង គឺ ក្នុងភពទាំងពួង និង ក្នុងគតិទាំងពួង ។ ពាក្យថា **ដោយភាពជាអ្នកបង្អោនចិត្តទៅក្នុងធម៌នោះ** មានន័យថា ការប្រកបរឿយៗ នូវការនា មានដើម្បីប្រយោជន៍ដល់ធម៌ណា និង ការបួស មាន

ធម៌ណាជាប្រយោជន៍ ក៏គប្បីជាអ្នកបង្អោនចិត្តទៅក្នុងធម៌នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា គប្បីជាអ្នកបង្អោនចិត្តទៅក្នុងសមាធិ ដូច្នេះជាដើម ។

ប្រសិនបើព្រះយោគីដែលត្រូវសួរថា លោកជាបុគ្គលចរិតណា គប្បីឆ្លើយថា " ខ្ញុំព្រះករុណាមិនដឹង ត្រូវសួរលោកថា ធម៌ពួកណា ប្រព្រឹត្តទៅច្រើនសម្រាប់លោក " ដូច្នេះ ។

ពាក្យថា **កម្មដ្ឋានអ្វី** គឺ អសុភកម្មដ្ឋាន ឬ អនុស្សតិកម្មដ្ឋាន ឬ កម្មដ្ឋានដទៃ ។ ពាក្យថា **កាលលោកមនសិការកម្មដ្ឋានណា** ទើបនឹងមានភាពជាផាសុក គឺ សុខទើបនឹងមានបានដោយភាពដែលចិត្តជាឯកគ្គតា ។ ពាក្យថា **ចិត្តបង្អោនទៅ** គឺ បង្អោនទៅដោយអំណាចសេចក្តីត្រេកអរក្រៃលែងតាមប្រក្រតីនោះឯង។ ដោយ **អាទិ** សព្ទ ក្នុងបទថា **ឯវមាទីហិ** គប្បីឃើញថា សង្គ្រោះយកហេតុ ប្រាប់ចរិយាដទៃមានឥរិយាបថជាដើម ។ ហេតុប្រាប់ចរិយាទាំងនោះ នឹងប្រព្រឹត្តទៅប្រាកដច្បាស់ដល់បុគ្គលម្នាក់មួយមុខក៏ទេ ពិតហើយ ការប្រព្រឹត្តទៅដែលគួរសាកសួរលោកអាចារ្យក៏ពោលដល់ហើយ ។ ហើយអាចារ្យគួរប្រាប់ព្រះយោគីថា " លោកគួរប្រកបរឿយ ៗ នូវវិធីមនសិការយ៉ាងនោះ និងយ៉ាងនោះ ត្រឹមតែ ២ - ៣ ថ្ងៃចុះ " ។ ពាក្យថា **សម្រាប់អ្នករៀនកម្មដ្ឋានតាមប្រក្រតី** លោកពោលសំដៅយកព្រះយោគីដែលបានធ្វើការស្និទ្ធស្នាលទុកដោយអំណាចការស្វាធ្យាយន៍ ឬ ដោយអំណាចការមនសិការក្នុងកម្មដ្ឋានដែលប្រាថ្នានឹងកាន់យកនោះ ។ ពាក្យថា **អស់កាលវេលាដែលអង្គុយ ២ ឬ ៣ លើក** គឺ អស់វេលាដែលអាសនៈក្តៅ ( អង្គុយរហូតដល់ក្តៅអាសនៈ ) ១ ឬ ២ ដង ។ ពាក្យថា **ដែលធ្វើការស្វាធ្យាយន៍** គឺ គួរឲ្យកម្មដ្ឋាន ដោយឲ្យទន្ទេញផ្ទាល់មាត់តែម្តង អធិប្បាយថា ប្រសិនបើព្រះយោគី

នោះ ជាអ្នកប្រាប្ថានឹងទៅក្នុងទីដទៃ ។ ព្រោះហេតុនោះ ទើបលោកពោលថា សម្រាប់ព្រះយោគីដែលនៅក្នុងសម្នាក់ អធិប្បាយថា គួរប្រាប់ឲ្យគ្រប់ពេលដែលលោកមក ព្រោះបានស្តាប់សេចក្តីទៅហើយ ។

ពាក្យថា **បបរិកសិណ** បានដល់ កម្មដ្ឋានគឺបបរិកសិណ។ បទថា **កតស្ស** ប្រែថា កសិណដែលធ្វើហើយ ។ ពាក្យថា **ចូលទៅចងទុកនូវអាការនោះ ៗ សេចក្តីថា កាលអាចារ្យប្រាប់កម្មដ្ឋានហើយ ក៏ចូលទៅចងទុកនូវអាការនោះៗ មាន បទ អត្ថន័យរបស់បទ ពាក្យអធិប្បាយឧបមាជាដើម ដែលជាក់ច្បាស់ដល់ញាណរបស់ខ្លួន** បានដល់ តែមួយអាការដែលលោកហៅថា និមិត្ត ។ ពាក្យថា **ចូលទៅចងទុក** គឺ ធ្វើដូចជានាំចូលទៅចងទុក មានន័យថា តាំងទុកក្នុងចិត្តធ្វើមិនឲ្យភ្លេច ។ ព្រះយោគីឈ្មោះថា ធ្វើដោយគោរព ក៏ព្រោះភាពជាអ្នកមានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការស្តាប់ នោះឈ្មោះថា ចាប់យកនិមិត្តបានយ៉ាងនេះ ក៏ព្រោះភាពជាអ្នកមានសតិដែលចូលទៅតាំងទុកយ៉ាងល្អ ។

បទថា **តំ** បានដល់ ព្រោះអាស្រ័យកម្មដ្ឋានដែលលោកកាន់យកបានល្អតាមដែលពោលហើយនោះ ។ ពាក្យថា **ដល់បុគ្គលក្រៅពីនេះ** គឺ ដល់បុគ្គលដែលមិនកាន់យកយ៉ាងនោះ ។

លោកអាចារ្យពោលថា ដោយអាការទាំងពួងដូច្នេះទុក ព្រោះថា ប្រការណាៗក្នុងកម្មដ្ឋានទាំងនោះ លោកក៏មិនបានធ្វើឲ្យសល់ទុក ។

## បរិច្ឆេទទី ៣

## មហាដីកា កម្មដ្ឋានគហណនិទ្ទេស ចប់ដោយបរិបូរណ៍

# បឋវីកសិណនិទ្ទេស

ឥឡូវនេះបណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យដែលខ្ញុំម្ចាស់ពោលទុក ( ក្នុងកម្មដ្ឋានគហណនិទ្ទេស ក្នុងដំណោះស្រាយសមាធិភាវនា ) ថា " ការដែលព្រះយោគីលះវិហារដែលមិនសមគួរដល់ការបំពេញសមាធិចេញ ហើយនៅក្នុងវិហារដែលសមគួរ " ដូច្នេះតទៅ ។

ជាដំបូង កាលព្រះយោគីណានៅក្នុងវិហារជាមួយព្រះអាចារ្យ មានសេចក្ដីសុខ ព្រះយោគីនោះកាលបើនឹងជម្រះកម្មដ្ឋាន គប្បីនៅក្នុងវិហារនោះឯង បើនៅក្នុងវិហារនោះ មិនមានសេចក្ដីសុខទេ វិហារដទៃណាជាសប្បាយមាននៅក្នុងទីឆ្ងាយ ( ពីវិហាររបស់អាចារ្យ ) ប្រមាណ ១ គាវុត ឬ កន្លះយោជន៍ ឬសូម្បីប្រមាណដល់មួយយោជន៍ក្ដី ក៏គប្បីទៅនៅក្នុងវិហារនោះចុះ កាលបាននៅយ៉ាងនោះ បើមានការភ្លេចភ្លាំង ឬកើតសេចក្ដីវង្វេងក្នុងកម្មដ្ឋានត្រង់កន្លែងណាក្ដី ធ្វើវត្តក្នុងវិហារពីព្រលឹមរួចហើយ ត្រាច់បិណ្ឌបាតក្នុងរវាងផ្លូវ កាលទៅដល់វិហារព្រះអាចារ្យស្នាក់នៅ ពេលស្រេចភត្តកិច្ចហើយ ថ្ងៃនោះគប្បីជម្រះកម្មដ្ឋានក្នុងសម្នាក់អាចារ្យ ថ្ងៃរះឡើង ក្រាបលាព្រះអាចារ្យទៅបិណ្ឌបាតក្នុងរវាងផ្លូវ កាលបើមិនទាន់នឿយហត់ អាចមកកាន់ទីលំនៅរបស់ខ្លួនបាន ។ ចំណែកព្រះយោគីណាមិនបានទីលំនៅជាសុខសូម្បីនៅឆ្ងាយរាប់យោជន៍ ព្រះយោគីនោះ គប្បីលះបង់សេចក្ដីកង្វល់ទាំងពួងក្នុងកម្មដ្ឋាន ធ្វើកម្មដ្ឋានដែលទាក់ទងជាមួយការពិចារណាឲ្យបរិសុទ្ធល្អ ហើយទៅឲ្យឆ្ងាយក៏បាន លះវិហារដែលមិនសមគួរដល់ការបំពេញសមាធិចេញ ស្នាក់នៅក្នុងវិហារដែលសមគួរចុះ ។

# មហាដីកា

# ពណ៌នា បឋវីកសិណនិទ្ទេស

ពាក្យថា **មានសេចក្ដីសុខ** គឺ មានសេចក្ដីសុខក្នុងការមនសិការ បានដល់សេចក្ដីអនុកូលដល់ការចម្រើន ព្រោះការបានទីនៅដែលជាសប្បាយជាដើម ។

ពាក្យថា **អ្នកនឹងជម្រះកម្មដ្ឋានឲ្យបរិសុទ្ធ** គឺ អ្នកនឹងជម្រះឲ្យបរិសុទ្ធដោយទាក់ទងជាមួយការលះបង់ឋានៈដែលជាគ្រឿងកង្វល់ទាំងឡាយនោះចេញ ។

ពាក្យថា **មិនទាន់នឿយហត់** គឺ នៅមិនទាន់នឿយហត់កាយនៅឡើយ ។ អធិប្បាយថា ពិតហើយបើមានការនឿយហត់ផ្លូវកាយ ការមនសិការកម្មដ្ឋាននឹងអន្តរធានបាន ។ ពាក្យថា **ឋានៈដែលជាគ្រឿងកង្វល់** គឺ ឋានៈដែលជាគ្រឿងកង្វល់ព្រោះលះបង់បានដោយលំបាកដោយអត្ថ និង ដោយពាក្យអធិប្បាយ ។

ពាក្យថា **លះបង់** គឺ លះបង់ចេញដោយការធ្វើសេចក្ដីសម្គាល់នឹងពាក្យអធិប្បាយឲ្យជាក់ច្បាស់បានតាមសេចក្ដីពិត អធិប្បាយថា ធ្វើឲ្យជាក់ច្បាស់ គឺ ឲ្យប្រាកដ ។ ពាក្យថា **ធ្វើឲ្យបរិសុទ្ធ** គឺ ធ្វើឲ្យបរិសុទ្ធបានដោយល្អ មានន័យថា ធ្វើមិនឲ្យបិទបាំង គឺ មានរបៀប ។

( ចប់ មហាដីកា )

# វិហារមិនសមគួរ

ក្នុងវិហារមិនសមគួរ និងវិហារសមគួរ ២យ៉ាងនោះ វិហារដែលប្រកបដោយទោស ១៨ ប្រការ ណាមួយ ឈ្មោះថា វិហារមិនសមគួរ ទោស ១៨ ប្រការ ក្នុងពាក្យនោះគឺ :

១ . មហន្តំ — វិហារធំ ។
២ . នវត្តំ — វិហារថ្មី ( ធ្វើមិនទាន់ហើយល្អ ) ។
៣ . ជិណ្ណកត្តំ — វិហារចាស់ ( ទ្រុឌទ្រោមហើយ ) ។
៤ . បន្ថសន្និស្សិតត្តំ — វិហារជាប់ផ្លូវដើរ ។
៥ . សោណ្ឌី — វិហារមានត្រពាំងទឹក ។
៦ . បណ្ណំ — វិហារមានស្លឹកឈើ ។
៧ . បុប្ផំ — វិហារមានផ្កាឈើ ។
៨ . ផលំ — វិហារមានផ្លែឈើ ។
៩ . បត្ថនីយតា — វិហារដែលមនុស្សទាំងឡាយប្រាថ្នា ។
១០ . នគរសន្និស្សិតតា — វិហារជាប់ក្រុង ។
១១ . ទារុសន្និស្សិតតា — វិហារជាប់ព្រៃឈើ ។
១២ . ខេត្តសន្និស្សិតតា — វិហារក្បែរស្រែ ( របស់អ្នកស្រុក ) ។
១៣ . វិសភាគានំ បុគ្គលានំ អត្ថិតា — វិហារដែលមានបុគ្គលជាវិសភាគៈគ្នា រស់នៅ ។
១៤ . បដ្ដនសន្និស្សិតតា — វិហារជាប់កំពង់ទឹក ។
១៥ . បច្ចន្តសន្និស្សិតតា — វិហារជាប់ព្រំដែន ។

**១៦ . វជ្ជសីមន្តរសន្និស្សិតតា** វិហារជាប់ចន្លោះព្រំដែន ។

**១៧ . អសប្បាយតា** វិហារមិនជាទីសប្បាយ ។

**១៨ . កល្យាណមិត្តានំ អលាភោ** វិហាររកកល្យាណមិត្តមិនបាន ។

វិហារដែលប្រកបដោយទោស ១៨ ប្រការ នេះណាមួយ ឈ្មោះថា វិហារមិនសមគួរ ព្រះយោគីមិនគួរនៅក្នុងវិហារនោះទេ ។

ព្រោះហេតុអ្វី ?

## មហាវាសំ ( វិហារធំ )

ជាដំបូងក្នុងវិហារធំ ភិក្ខុដោយច្រើនមានឆន្ទៈផ្សេង ៗ គ្នា នៅរួមគ្នា លោកទាំងឡាយ មានការខុសចិត្តគ្នានិងគ្នា ក៏មិនធ្វើវត្តក្នុងបរិវេណទាំងឡាយ មានលានដើមពោធិ៍ជាដើម ដែលថាមិនបោសសម្អាត ទឹកឆាន់ ទឹកប្រើ ក៏មិនមាន សូម្បីក្នុងវិហារធំនោះ កាលលោកគិតថា នឹងត្រូវទៅបិណ្ឌបាតក្នុងគោចរគ្រាម កាន់បាត្រនិងចីវរចេញទៅ បើឃើញវត្តនៅមិនទាន់បានរៀបចំក្តី ក្អមទឹកផឹកនៅមិនទាន់មានទឹកក្តី វត្តក៏លោកចាំបាច់ត្រូវធ្វើ ទឹកផឹកក៏ចាំបាច់យកមកតម្កល់ទុក បើមិនធ្វើ ក៏នឹងត្រូវអាបត្តិទុក្កដព្រោះវត្តភេទ កាលលោករវល់ធ្វើវត្តនោះ ក៏ជ្រុលពេល ចូលទៅកាន់ស្រុកថ្ងៃពេក បើភិក្ខាអស់ហើយ ក៏នឹងមិនបានអ្វីឆាន់ សូម្បីលោកទៅក្នុងទីស្ងាត់កំបាំងនៅតែរាយមាយទៅបាន ដោយសំឡេងគឹកកង និង ការធ្វើការរុកកួនគ្នានៃសាមណេរព្រមទាំងភិក្ខុកំលោះទាំងឡាយ តែបើក្នុងវិហារធំណា វត្តទាំងពួងគេធ្វើបានរៀបរយហើយ សូម្បីការរំខានទាំងនោះ ក៏មិនមានក្នុងវិហារដូច្នេះ ជាវិហារធំគួរនៅបាន ។

## នវត្តំ ( វិហារថ្មី )

ក្នុងវិហារថ្មី ( ធ្វើមិនទាន់ហើយល្អ ) ការកសាងមានច្រើន មិនធ្វើក៏គេពោលទោស តែក្នុងវិហារថ្មីណា ភិក្ខុទាំងឡាយប្រាប់ថា “ សូមលោកចូរធ្វើសមណធម៌តាមសប្បាយចុះ ពួកខ្ញុំម្ចាស់នឹងធ្វើការកសាងជំនួស ” ដូច្នេះ ក្នុងវិហារថ្មីដូច្នោះ គួរនៅបាន ។

## ជិណ្ណកត្តំ ( វិហារចាស់ )

ចំណែកក្នុងវិហារចាស់ វត្ថុដែលត្រូវថែរក្សាមើលមានច្រើន ទីបំផុតសូម្បីសេនាសនៈសម្រាប់ខ្លួន បើមិនថែរក្សា គេនឹងពោលទោស រវល់ថែរក្សា នឹងនាំឲ្យវិនាសកម្មដ្ឋាន ។

## បន្ថសន្និស្សិតត្តំ ( វិហារជាប់ផ្លូវដើរ )

ក្នុងវិហារជាប់ផ្លូវដើរ គឺ វិហារជាប់ផ្លូវធំ អាគន្តុកៈជួបជុំទាំងយប់ទាំងថ្ងៃ បើពួកគេ មកក្នុងវេលាវិកាល ក៏ចាំបាច់ត្រូវរើអាសនៈរបស់ខ្លួនទៅនៅក្រោមដើមឈើ ឬមិនដូច្នោះ ក៏ទៅនៅទីលានថ្ម សូម្បីស្អែកឡើងក៏នៅយ៉ាងនោះ ព្រោះដូច្នោះ ឱកាសសម្រាប់កម្មដ្ឋានក៏មិនមាន តែក្នុងវិហារជាប់ផ្លូវដើរណា មិនមានភាពរឹករវរដោយអាគន្តុកៈ គួរនៅក្នុងវិហារនោះបាន ។

## សោណ្ឌី ( វិហារមានត្រពាំងទឹក )

ស្រះបោក្ខរណីរាំងដោយថ្ម ឈ្មោះថា ត្រពាំង ក្នុងវិហារមានត្រពាំងនោះ សម្បូរដោយមនុស្សច្រើនមកដងទឹកផឹក ពួកអន្តេវាសិករបស់ព្រះថេរៈ រាជកុលុបកៈទាំងឡាយ អ្នកនៅវត្តក្នុងព្រះនគរ ក៏នឹងនាំគ្នាមក ដើម្បីប្រយោជន៍ដោយរជនកម្ម

( ការបោកគក់ ) កាលពួកលោកសួរដល់គ្រឿងប្រើប្រាស់ មានភាជនៈ សំពត់ និង តម្រងទឹកជាដើម ក៏នឹងត្រូវបង្អុលប្រាប់ថា នៅឯណោះ ការជួយខ្វាយខ្វល់ជាប្រចាំ រមែងមានអស់កាលទាំងពួងយ៉ាងនេះ ។

**បណ្ណំ** ( វិហារមានស្លឹកឈើ )

ក្នុងវិហារណាដែលមានស្លឹកឈើជាបន្លែផ្សេង ៗ ពេលលោករៀនកម្មដ្ឋានអង្គុយពេលថ្ងៃនៅក្នុងវិហារនោះ ពួកស្ត្រីរកបន្លែមកស្រែកច្រៀងផង បេះបន្លែផងជិត ៗ ទីនោះ រមែងនឹងធ្វើអន្តរាយដល់កម្មដ្ឋានដោយការរំខានពីសំឡេងដែលជាវិសភាគៈបាន ។

**បុប្ផំ** ( វិហារមានផ្កាឈើ )

ចំណែកក្នុងវិហារណា សម្បូរឈើផ្កានានា មានផ្ការីកស្គុសស្គាយ សូម្បីក្នុងវិហារនោះ ក៏នឹងមានឧបទ្រវៈដូចគ្នា ។

**ផលំ**( វិហារមានផ្លែឈើ )

ក្នុងវិហារណាមានផ្លែឈើច្រើនប្រភេទ ដូចជា ស្វាយ ជម្ពូ ខ្នុរ ក្នុងវិហារនោះ ពួកមនុស្សដែលត្រូវការផ្លែឈើ ក៏នឹងនាំគ្នាមកសុំ បើមិនឲ្យ គេក៏នឹងក្រោធ បើមិនដូច្នោះ គេក៏កាន់យកដោយកម្លាំង ពេលត្រជាក់ លោកដើរចង្ក្រមកណ្ដាលវិហារ ជួបគេ ក៏សួរថា ពួកឧបាសកធ្វើអ្វី ហេតុអ្វីពួកលោកធ្វើយ៉ាងនោះ គេក៏នឹងជេរតាមចិត្ត នឹងព្យាយាមមិនឲ្យលោកនៅបានតទៅទៀត ។

**បត្ថនីយតា** ( វិហារដែលមនុស្សចង់បាន )

ចំណែកភិក្ខុនៅក្នុងវិហារដែលមនុស្សទាំងឡាយពេញចិត្ត គឺ ដែលអ្នកស្រុក

សម្គាល់ថា ( វិហារវិសេស ) ដូចជា ទក្ខិណាគិរីវិហារ ហត្ថិកុច្ឆិវិហារ ចិត្តលបព៌តវិហារ មនុស្សសម្គាល់ថា ជាព្រះអរហន្ត ប្រាថ្នានឹងបានថ្វាយបង្គំ ក៏មកចោមរោម ព្រោះហេតុនោះ លោកក៏មិនមានសេចក្ដីសុខ តែបើវិហារនោះ ជាសប្បាយសម្រាប់ព្រះយោគីរូបណា ព្រះយោគីរូបនោះ គប្បីទៅនៅក្នុងទីដទៃពេលថ្ងៃ ពេលយប់ត្រឡប់មកវិញចុះ ។

## **នគរសន្និស្សិតតា** ( វិហារជាប់ក្រុង )

ក្នុងវិហារជាប់ក្រុង វិសភាគារម្មណ៍ទាំងឡាយ រមែងមកកាន់គន្លងនៃទ្វារមានចក្ខុទ្វារជាដើម ពួកកុម្ភទាសីទាំងនោះក៏ដើរកាន់ក្អមទឹកទៅ គេទាំងនោះក៏មិនចៀសផ្លូវឲ្យ ចំណែកពួកចៅហ្វាយនាយក៏មកអង្គុយប្រជុំគ្នាកណ្ដាលវិហារ ។

## **ទារុសន្និស្សិតតា** ( វិហារជាប់ព្រៃ )

ចំណែកវិហារជាប់ព្រៃឈើ គឺ ជាទីដែលមានឈើងាប់ និង មានដើមឈើដែលប្រើធ្វើជាគ្រឿងផ្ទះបាន ពួកអ្នករកឧសនឹងរំខាន ដូចពួកអ្នករកបន្លែ និងផ្កាឈើដែលពោលមកក្នុងខមុន មនុស្សទាំងឡាយគិតគ្នាថា ត្រូវកាត់ឈើនៅជិតវិហារមកធ្វើផ្ទះ ក៏នាំគ្នាមកកាត់យក ពេលត្រជាក់ព្រះយោគីចេញអំពីកុដិធ្វើសេចក្ដីព្យាយាម ចង្រ្កមនៅកណ្ដាលវិហារ ឃើញមនុស្សទាំងនោះក៏ពោលឡើងថា “ ពួកឧបាសក ហេតុអ្វីទើបអ្នកធ្វើយ៉ាងនោះ ” គេក៏នឹងជេរតបវិញ នឹងព្យាយាមដើម្បីមិនឲ្យលោកនៅបានទៀត ។

## **ខេត្តសន្និស្សិតតា** ( វិហារជាប់ស្រែ )

ចំណែកវិហារណាជាប់ស្រែ ស្រែព័ទ្ធជុំវិញវិហារនោះ មនុស្សទាំងឡាយនឹង

ធ្វើលានបញ្ជាន់ស្រូវកណ្ដាលវិហារនោះឯង ហាលស្រូវនៅមុខវិហារ រមែងធ្វើសេចក្ដីមិនជាសុខ នៅក្នុងវិហារច្រើនទៀត សូម្បីក្នុងវិហារណាមានភោគសម្បត្តិរបស់សង្ឃច្រើន ពួកញោមវត្តការពារហ្វូងគោនៃត្រកូលទាំងឡាយ ( មិនឲ្យចូលស៊ីក្នុងវត្ត ) បិទផ្លូវទឹក ( ទប់ទឹកទុកប្រើក្នុងវត្ត ទឹកក៏មិនហូរទៅកាន់ស្រែរបស់អ្នកស្រុក ស្រូវក៏ស្វិតស្រពោន ) មនុស្សទាំងឡាយនាំគ្នាកាន់ស្រូវស្វិតទៅបង្ហាញដល់សង្ឃ យំស្រែកថា " លោកម្ចាស់ទាំងឡាយ មើលចុះ ការធ្វើរបស់ញោមវត្តរបស់លោកម្ចាស់ " ព្រោះហេតុនោះ ( កាលសង្ឃមិនអាចចាត់ការឲ្យបានជាទីគាប់ចិត្តរបស់ពួកគេបាន គេក៏នឹងយំស្រែកប្រាប់ដល់ចៅហ្វាយនាយរបស់គេ ) ព្រះយោគីនោះចាំបាច់ទៅកាន់រាជនិវេសន៍ ឬសាលាស្រុក ឬផ្ទះរបស់រាជអមាត្យ ( ដែលជាអ្នកទទួលរឿងរ៉ាវប្ដឹងផ្ដល់ ដើម្បីផ្ដល់ចម្លើយដល់អ្នកកាត់ក្ដី ) សូម្បីវិហារ ដែលមានភោគសម្បត្តិសង្ឃច្រើននោះ ក៏សង្គ្រោះចូលក្នុងវិហារដែលជាប់ស្រែបានដែរ ។

## វិសភាគានំ បុគ្គលានំ អត្ថិតា

( វិហារមានបុគ្គលជាវិសភាគៈគ្នានៅ )

មានសេចក្ដីថា " **វិហារមានបុគ្គលដែលជាវិសភាគៈគ្នារស់នៅ** " មានវិនិច្ឆ័យថា ក្នុងវិហារណា ភិក្ខុទាំងឡាយដែលជាវិសភាគៈ គឺ ជាសត្រូវដល់គ្នា និងគ្នា នៅរួមគ្នា ភិក្ខុពួកណាឈ្លោះគ្នាហើយ កាលព្រះយោគីហាមថា " លោកម្ចាស់ដ៏ចម្រើនទាំងឡាយ " សូមលោកទាំងឡាយកុំធ្វើយ៉ាងនោះឡើយ ភិក្ខុពួកនោះត្រឡប់និយាយវិញថា " តាំងពីភិក្ខុកាន់បង្សុកូលរូបនេះមក ពួកយើងជាមនុស្សវិនាសហើយ " ។

## **បដ្ដនសន្និស្សិតតា** ( វិហារជាប់កំពង់ទឹក )

ចំណែកវិហារណាជាប់កំពង់ទឹក ឬ ចំណតផ្លូវគោក ក្នុងវិហារនោះពួកមនុស្សដែលមកតាមទូកក្ដី រទេះក្ដី រឿយៗ រមែងរំខានមិនឲ្យបានសុខ ដោយការបន្ទឺពាក្យសុំឱកាស សុំទឹកផឹក សុំអំបិល ។

## **បច្ចន្តសន្និស្សិតតា** ( វិហារជាប់ជាយដែន )

ចំណែកក្នុងវិហារជាប់ជាយដែន មនុស្សទាំងឡាយណាជាមនុស្សមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធរតនៈជាដើម ( សូម្បីមិនធ្វើអន្តរាយ ក៏មិនឧបត្ថម្ភនឹងបានសេចក្ដីសុខអំពីណា ) ។

## **រជ្ជសីមន្តរសន្និស្សិតតា** ( វិហារជាប់ចន្លោះព្រំដែន )

ក្នុងវិហារជាប់ចន្លោះព្រំដែន រាជភ័យនឹងមានព្រោះព្រះរាជា អង្គនោះក៏ពោលថា ទីត្រង់នេះនៅមិនបាន ព្រោះនៅក្នុងអំណាចរបស់យើង ក៏វាយយកទីនោះ ព្រះរាជាផ្សេងទៀតក៏ពោលថា ទីត្រង់នេះនៅមិនបាន គឺ ស្ថិតក្នុងអំណាចរបស់ខ្លួន ក៏វាយយកទីនោះ ភិក្ខុនេះនៅក្នុងវិហារនោះ គ្រាខ្លះក៏ត្រាច់ទៅក្នុងដែនរបស់ព្រះរាជាអង្គនោះ គ្រាខ្លះក៏ត្រាច់ទៅក្នុងដែនរបស់ព្រះរាជាអង្គមួយទៀត កាលបើយ៉ាងនោះ រាជការអាចសម្គាល់ថា អ្នកនេះជាចារបុរស ក៏នឹងយកលោកទៅធ្វើទុក្ខទោស ។

## **អសប្បាយតា** ( វិហារមិនជាទីសប្បាយ )

មានវិនិច្ឆ័យថា “ វិហារដែលបានឈ្មោះថា មិនជាទីសប្បាយ ព្រោះជាទីប្រជុំទៅដោយវិសភាគារម្មណ៍ មានរូបជាដើមខ្លះ ព្រោះជាទីដែលអមនុស្សហួងហែងខ្លះ

មានរឿងក្នុងវិហារអមនុស្សហួងហែង :

មានរឿងតំណាលមកថា ព្រះថេរៈមួយរូបរស់នៅក្នុងព្រៃ មានយក្ខិនីមួយ ( ប្រាថ្នានឹងធ្វើឲ្យព្រះថេរៈទៅធ្លាក់ជ្រោះស្លាប់ ខ្លួននឹងបានស៊ីសាច់ព្រះថេរៈជាអាហារ ) ជាដំបូងបានឈរស្រែកនៅជិតទ្វារបណ្ណសាលារបស់លោក លោកចេញទៅឈរនៅជិតទ្វារ មើលមិនឃើញអ្វី យក្ខិនីនោះទៅស្រែកនៅមុខទីចង្ក្រម ព្រះថេរៈតាមទៅមើលដល់ទីចង្ក្រម ក៏មិនឃើញអ្វីទៀត យក្ខិនីនោះឃើញថា បញ្ឆោតព្រះថេរៈចេញមកបានពីរដងហើយ នឹងបានការ គ្រានេះ ទើបទៅឈរស្រែកនៅជិតមាត់ជ្រោះដ៏ជ្រៅស្មើ ១០០ ជួរមនុស្ស ព្រះថេរៈក៏ត្រឡប់មកវិញ ពេលនោះយក្ខិនី ក៏ស្ទុះលោតមកចាប់លោក ស្រែកគំរាមថា “ យើ ! មនុស្សល្អិតល្អោចយើងស៊ីអស់មិនមែនម្នាក់ពីរនាក់ឡើយ ” ។

## កល្យាណមិត្តានំ អលាភោ

( វិហារដែលគ្មានកល្យាណមិត្ត )

សេចក្តីថា “ **វិហារដែលគ្មានកល្យាណមិត្ត** ” មានន័យថា ក្នុងវិហារណា ព្រះយោគីមិនអាចរកអាចារ្យ ឬ ភិក្ខុរបស់អាចារ្យក្តី ឧបជ្ឈាយ៍ ឬភិក្ខុរបស់ឧបជ្ឈាយ៍ក្តី ជាកល្យាណមិត្តបាន ការមិនបានកល្យាណមិត្តនោះ ក្នុងវិហារនោះ មានទោសច្រើនតែម្យ៉ាង ។

វិហារដែលប្រកបដោយទោស ១៨ យ៉ាង នេះ ណាមួយ គប្បីជ្រាបថា ជាវិហារមិនសមគួរ ពិតហើយ សូម្បីក្នុងអដ្ឋកថាទាំងឡាយ លោកក៏បានពោលពាក្យប្រព័ន្ធទុកថា :

## គាថាសរុបទោស ១៨

បណ្ឌិតស្គាល់នូវអាវាស ( ដែលប្រកបដោយទោស ) ១៨ យ៉ាង គឺ : អាវាសធំ១ អាវាសថ្មី១ អាវាសចាស់១ អាវាសជាប់ផ្លូវ១ អាវាសមានត្រពាំងទឹក១ អាវាសមានស្លឹកឈើបន្លែ១ អាវាសមានឈើផ្កា១ អាវាសមានឈើផ្លែ១ អាវាសដែលមនុស្សទាំងឡាយពេញចិត្តមួយ១ អាវាសជាប់ក្រុង១ អាវាសជាប់ព្រៃឈើ១ អាវាសជាប់ស្រែ១ អាវាសមានភិក្ខុជាវិសភាគៈគ្មានិងគ្នា១ អាវាសជាប់កំពង់ទឹក១ អាវាសជាប់ជាយដែន១ អាវាសនៅរវាងព្រំដែន១ អាវាសមិនជាទីសប្បាយ១ អាវាសគ្មានកល្យាណមិត្ត១ ទាំងអស់នេះ( ជាទីមិនសមគួរ ) ដូច្នេះ ហើយគប្បីចៀសចេញទៅឲ្យឆ្ងាយ ដូចចៀសផ្លូវដែលមានភ័យនៅចំពោះមុខដូច្នេះ ។

## មហាដីកា

## វិហារមិនសមគួរ

ពាក្យថា **ដោយទោស**( ១៨ យ៉ាង ) **ណាមួយ** អធិប្បាយថា ដោយទោសសូម្បីយ៉ាងណាមួយ នឹងចាំបាច់ពោលថ្វីដល់វិហារដែលដល់ព្រមដោយទោសច្រើនយ៉ាងនោះ ។ ភាពជាវិហារធំ ឈ្មោះថា **មហត្តំ** ។ សូម្បីក្នុងបទដ៏សេសក៏មានវិនិច្ឆ័យយ៉ាងនោះ ។

បទថា **សោណ្ឌី** មានន័យថា វិហារដែលមានត្រពាំងទឹក ឈ្មោះថា **សោណ្ឌិ** **សោណ្ឌិ** នោះជា **សោណ្ឌី** ។ សូម្បីក្នុងបទថា **បណ្ណំ** ជាដើម ក៏មានវិនិច្ឆ័យយ៉ាងនោះ ។ កិច្ចដែលគួរធ្វើនៅទីលានដើមពោធិ៍ជាដើម លោកបំណាងថា “ វត្ត ”

ក្នុងទីនេះ ។ ព្រោះហេតុនោះ ទើបពោលថា " ឃើញផ្ទាំងតម្កល់ទឹកដែលទទេក្តី " ដូច្នេះ ។

ពាក្យថា **ភិក្ខុអស់ហើយ** គឺ អស់ទៅហើយដោយការថ្វាយដល់ភិក្ខុគ្រប់ ៗ រូបដែលចូលទៅ ។ សូម្បីក្នុងវិហារចាស់ក៏រមែងមានន័យដូច្នេះថា ក្នុងវិហារចាស់ណា ភិក្ខុទាំងឡាយ ពោលយ៉ាងនេះថា " លោកដ៏មានអាយុ លោកចូរធ្វើសមណធម៌តាមសប្បាយចុះ ពួកយើងជាអ្នកជួសជុល " ដូច្នេះ ។ លោកក៏គួរនៅក្នុងវិហារចាស់ដែលមានសភាពយ៉ាងនេះបាន ដូច្នេះ តែព្រោះមានន័យដែលបានពោលហើយ លោកទើបមិនពោលទុក ។

ពាក្យថា **ក្នុងវិហារនៅជាប់ផ្លូវធំ** គឺ ក្នុងវិហារជិតផ្លូវធំ ។ ពាក្យថា **ឧបករណ៍មានភាជនៈ និង ឧសជាដើម** បានដល់ ឧបករណ៍យ៉ាងនេះ គឺ ភាជនៈសម្រាប់ប្រើក្នុងការចម្អិន កំណាត់ឈើ ដើម្បីប្រយោជន៍ដល់ការចម្អិន ស្នូកខាងក្រោមសម្រាប់ការជ្រលក់ និង ផ្នែកខាងលើសម្រាប់ការបោកគក់ជាដើម ។

ពាក្យថា **សាកហារិកា** ប្រែថា ស្រីបេះបន្លែ ។

អាចារ្យទាំងឡាយពោលថា ឈ្មោះថា សំឡេងដែលជាវិសភាគៈ បានដល់ សំឡេងច្រៀងដែលទាក់ទងជាមួយ នឹងកាមគុណ សំឡេងស្ត្រីសូម្បីទាំងអស់ចាត់ជាសំឡេងដែលជាវិសភាគៈតែម្យ៉ាង ។

បទថា **តត្រ** បានដល់ ក្នុងវិហារដែលមានផ្កាឈើ ។ ពាក្យថា **អន្តរាយដូច្នោះឯង** គឺ អន្តរាយក្នុងវិហារ មានស្ទឹកឈើដែលលោកពោលទុកដោយពាក្យថា "ក្នុងវិហារនោះ សូម្បីអ្នកកាន់យកកម្មដ្ឋាន" ដូច្នេះជាដើម ជាយ៉ាងណា ( អន្តរាយក្នុងវិហារមានផ្កាឈើ ) ក៏ដូច្នោះ ដូចគ្នា ។ តែគួរពោលពាក្យថា " ពួកស្ត្រីបេះផ្កា

ឈើទាំងឡាយ ដើរច្រៀងបេះផ្កាឈើ " ដូច្នេះជាដើម ។ នេះជាសេចក្ដីដែលប្លែកគ្នាក្នុងវិហារមានផ្កាឈើនេះ ។

ពាក្យថា **ក្នុងវិហារដែលមនុស្សទាំងឡាយតែងតាំង** បានដល់ ក្នុងវិហារដែលគេគប្បីត្រូវការដោយកិច្ច មានការចូលទៅរកជាដើម ដោយទាក់ទងនឹងការលើកសរសើរក្នុងបុគ្គលទាំងឡាយ សូម្បីដែលនៅក្នុងវិហារនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា " គឺ ក្នុងវិហារដែលមនុស្សលោកសន្មតគ្នា " ។

ពាក្យថា **ទក្ខិណាគិរីវិហារ អាចារ្យទាំងឡាយ** ពោលថា បានដល់ ទក្ខិ-ណាគិរីវិហារក្នុងដែនមគធៈ ។

ឈ្មោះថា **អារម្មណ៍ដែលជាវិសភាគៈ** មានបានទាំងឥដ្ឋារម្មណ៍ និងទាំងអនិដ្ឋារម្មណ៍ ។

លោកអាចារ្យពោលថា " នឹងមានក្អមទឹក ដើរទៅទង្គិចគ្នា "ជាដើម ដើម្បីសម្ដែងអនិដ្ឋារម្មណ៍ ។ ដើមឈើដែលប្រើប្រាស់ជាឧបករណ៍ សម្រាប់គ្រឿងផ្ទះឈ្មោះថា **ទព្វូបករណរុក្ខា** ។

ពាក្យថា **យោ បន** ប្រែថា ចំណែកវិហារណា ។ ពាក្យថា **លាន** បានដល់ ស្ថានទីសម្រាប់ធ្វើការងារទាក់ទងជាមួយស្រូវ ( ដូចជាលានបញ្ជាន់ស្រូវជាដើម )។ ពួកញោមវត្ត ឈ្មោះថា រមែងការពារហ្វូងគោ ក៏ព្រោះគិតថា " ហ្វូងគោនឹងចូលស៊ីស្រូវអស់ហើយ " ដូច្នេះ ។ ពាក្យថា **ធារទឹក** បានដល់ ប្រឡាយទឹកដែលត្រូវផ្គត់ផ្គង់សន្ទូងក្នុងស្រែទាំងឡាយ ។ ពាក្យថា **វិហារ** នេះ គឺ វិហារដែលមានវត្ថុប្រើប្រាស់របស់សង្ឃច្រើន។ ពួកភិក្ខុទាំងឡាយ ឈ្មោះថា ត្រូវលោកហាមប្រាមហើយ គឺ ត្រូវភិក្ខុបំពេញកម្មដ្ឋានហាមប្រាម ។

កំពង់ទឹកដែលនៅជាប់សមុទ្រ ឬ ទន្លេដែលកើតពីសមុទ្រ ឈ្មោះថា កំពង់ទឹក។ ចំណតដែលជាប់ផ្សារជាដើម ដែលជាតំបន់យកកាស៊ីរបស់ក្រុងធំទាំងឡាយ ឈ្មោះថា ចំណតលើគោក ។ អធិប្បាយថា ពួកមនុស្សទាំងឡាយជាអ្នកមិនជ្រះថ្លា ។ ព្រោះហេតុនោះ ក្នុងវិហារនៅជាប់ជាយដែននោះ លោកនឹងរកការនៅជាសុខមិនបាន ។ ឈ្មោះថា **ពួកមនុស្សដែលសម្គាល់លោកថាជាចារបុរស** បានដល់មនុស្សរបស់ស្តេច ។

ពាក្យថា **ដោយជាទីជំនុំ** គឺ ជាទីសញ្ចរទៅខាងនេះ ខាងនោះ ។ ពាក្យថា **ជិតជ្រោះ** គឺ ឈរស្រែកច្រៀងនៅជិតមាត់ជ្រោះ ដោយគិតថា យើងនឹងអាស្រ័យសំឡេងស្រែកធ្វើឲ្យបុគ្គលដែលមកដល់ទីនេះធ្លាក់ទៅក្នុងជ្រោះ ហើយនឹងទំពាស៊ីដូច្នេះ ។ ពាក្យថា **ចាប់លោកដោយរហ័ស** គឺ ស្ទុះមកចាប់ព្រះថេរៈត្រង់កដោយរហ័ស ពោលថា នឹងទៅណា ។

បទថា **យត្ថ** មានពាក្យប្រកបសេចក្តីឲ្យបរិបូរណ៍ ថា ក្នុងវិហារណា ឬទីជុំវិញវិហារ ព្រះយោគីមិនអាចនឹងបានកល្យាណមិត្ត ការមិនបាននោះ ចាត់ជាទោសដ៏ធំក្នុងវិហារនោះ ។

បទថា **បន្ថនី** មានន័យថា វិហារនៅជាប់ផ្លូវ ឈ្មោះថា **បន្ថនី** ព្រោះអត្ថថានាំទៅ គឺ ធ្វើនៅជិតផ្លូវដើរ ។ បណ្ឌិតស្គាល់វិហារនោះ ឈ្មោះថា **បន្ថនី** ។

បទថា **សោណ្ឌី** មានន័យថា វិហារដែលប្រកបដោយត្រពាំងទឹក ឈ្មោះថា **សោណ្ឌី** បណ្ឌិតស្គាល់វិហារនោះ ថា **សោណ្ឌី** ។ ក្នុងបទថា **បណ្ណំ** ជាដើម ក៏យ៉ាងនោះដូចគ្នា ។ លោកពោលដល់វិហារនៅជាប់នគរ ថា **នគរំ** ដោយការលុបបទក្រោយ ពាក្យ ពេញ គឺ ( នគរនិស្សិតំ ) ដូចដែលពោលថា “ **ភិមសេនោ**

( បក្សីមួយប្រភេទដែលគួរខ្លាច ) ថា **ភីមោ** ” ដូច្នេះ ។

បទថា **ទារុនា** បានដល់ ស្ថានទីដែលនៅជិតនឹងវិហារជាប់មាត់ព្រៃ ។

បទថា **វិសភាគេន** មានន័យថា វិហារណា ភិក្ខុដែលជាវិសភាគៈនឹងគ្នាទាំងឡាយ អាស្រ័យនៅ ឬ ជាទីនៅនៃភិក្ខុទាំងឡាយដែលជាវិសភាគៈនឹងគ្នា វិហារនោះ ឈ្មោះថា ជាវិសភាគៈ ។ បានដល់ ដឹងចំពោះស្ថានទីដែលនៅជិតវិហារ ដែលជាវិសភាគៈនោះ ។

**បច្ចន្តនិស្សិតំ១ សីមានិស្សិតំ១ អសប្បាយំ១** រួមជាបទមួយថា **បច្ចន្តសីមាសប្បាយំ** ។ ព្រោះសម្ដីដល់ឋានសព្ទក្នុងបទទាំងពួង ទើបមានពាក្យសម្ដែងអធិប្បាយជា **នបុំសកលិង្គ** ថា **យត្ថ មិត្តោ ន លព្ភតិ តម្បិ** ។ ពាក្យថា **ឥតិ វិញ្ញាយ** គឺ ដឹងហើយយ៉ាងនេះថា “ ស្ថានទីមិនសមគួរដល់ភាវនា ” ដូច្នេះ ។

( ចប់ មហាដីកា )

# លក្ខណៈវិហារដែលសមគួរ

ចំណែកវិហារណាដែលប្រកបដោយអង្គ ៥ មានសភាពជាវិហារមិនឆ្ងាយពេក មិនជិតពេកពីគោចរគ្រាមជាដើម វិហារនេះ ឈ្មោះថា **វិហារសមគួរ** ពិតហើយ ពាក្យនេះ ព្រះមានព្រះភាគបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលប្រកបដោយអង្គ ៥ តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងសាសនានេះ មិនឆ្ងាយពេក មិនជិតពេក ទៅមកងាយស្រួល ពេលថ្ងៃមិនអ៊ូអរ ពេលយប់មិនមានសំឡេងគឹកកងប្រាសចាកសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់ក្អែប កាលបើភិក្ខុអាស្រ័យនៅក្នុង សេនាសនៈនោះ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ រមែងកើតឡើងដោយមិនលំបាកឡើយ ម្យ៉ាងទៀត ភិក្ខុទាំងឡាយដែលជាថេរៈ ជាពហុស្សូត ជំនាញក្នុងអាគម ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា រមែងនៅក្នុងសេនាសនៈនោះ ភិក្ខុចូលទៅរកព្រះថេរៈទាំងនោះតាមកាលដ៏គួរ បានសាកសួរ ( ធម្ម និង អត្ថ ) ថា “ លោកម្ចាស់ បទនេះយ៉ាងដូចម្ដេច ” លោកទាំងនោះ រមែងប្រាប់នូវកន្លែងណាដែលមិនដឹង ធ្វើឲ្យច្បាស់នូវសេចក្ដីដែលមិនទាន់ច្បាស់ និង បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយដែលគួរសង្ស័យច្រើនយ៉ាង ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលប្រកបដោយអង្គ ៥ នេះ យ៉ាងនេះឯង ” នេះជាសេចក្ដីពិស្ដារក្នុងសេចក្ដីថា “ លះបង់វិហារដែលមិនសមគួរដល់ការបំពេញសមាធិចេញ ហើយអាស្រ័យនៅក្នុងវិហារដែលសមគួរ ” ។

# មហាដីកា

## លក្ខណៈវិហារដែលសមគួរ

ពាក្យថា **វិហារនេះ ឈ្មោះថា វិហារដែលសមគួរ** គឺ វិហារនេះ ឈ្មោះថា វិហារដែលសមគួរដល់ការនៅ ។

ពាក្យថា **មិនឆ្ងាយពេក** គឺ ឈ្មោះថា មិនឆ្ងាយពេក ព្រោះមានកំណាត់ផ្លូវតិចជាងកន្លះគាវុតរាប់ពីទីគោចរ ( ត្រាច់បិណ្ឌបាត ) ។

ពាក្យថា **មិនជិតពេក** គឺ ឈ្មោះថា មិនជិតពេក ព្រោះមានចម្ងាយ ៥០០ ធ្នូរផ្លូវ ដោយប្រមាណយ៉ាងតិចរាប់ពីស្ថានទីគោចរ ។ ព្រោះភាពជាសេនាសនៈមិនឆ្ងាយពេក មិនជិតពេកនោះ និង ព្រោះការដែលមានផ្លូវទៅកាន់ស្ថានទីគោចរដែលប្រាសចាកអន្តរាយ ចំពោះមុខជាដើម ទើបឈ្មោះថា ងាយស្រួលដោយការទៅមក ព្រោះមានសភាពដែលសមគួរដល់ការទៅ និង ការមក ។

ពាក្យថា **ពេលថ្ងៃមិនអ៊ូអរ** ព្រោះពេលថ្ងៃមិនដេរដាសដោយមហាជន ។ ក៏ **អប្ប** ស័ព្ទ ( ក្នុងពាក្យថា **អប្បាកិញ្ច** មិនអ៊ូអរ ) នេះមានអត្ថថា មិនមាន ។ ក្នុងពាក្យថា " **អប្បិច្ឆា** " ដែលប្រែថា មិនប្រាថ្នាច្រើនជាដើម ។ ឈ្មោះថា **ពេលយប់មិនមានសំឡេង** ព្រោះក្នុងពេលយប់ មិនមានសំឡេងមនុស្សនិយាយគ្នា ។ ឈ្មោះថា **ប្រាសចាកសំឡេងអឺកធឹក** ព្រោះមិនមានសំឡេងអឺកធឹក ពីការជំនុំគ្នារបស់មនុស្សអស់កាលទាំងពួង ។ ពាក្យថា **ដោយមិនលំបាក** មានន័យថា ឈ្មោះថា ដោយមិនលំបាក បានដល់ ដោយងាយនោះឯង ។

ភិក្ខុទាំងឡាយ ឈ្មោះថា **ថេរៈ** ព្រោះដល់នូវភាពមាំទាំនៃគុណទាំងឡាយមានសីលជាដើម ។ ឈ្មោះថា **ពហុស្សុត** ព្រោះអត្ថថា មានសុតៈ ( ធម៌ដែល

បានស្តាប់ ) យ៉ាងច្រើន មាន សុត្តៈ គេយ្យៈ ជាដើម ។ ឈ្មោះថា ដល់អាគម ក៏ព្រោះអត្ថថា មានអាគម ពោលគឺ ការដល់ព្រមដោយព្រះបរិយត្តិធម៌ ដោយការធ្វើឲ្យឡើងកាន់វាចា ( រត់មាត់ ) និង ដោយភាពជាវត្ថុដែលធ្វើឲ្យដល់ព្រមហើយក្នុងសម្នាក់របស់គ្រូទាំងឡាយដោយល្អនោះឯង ។ ឈ្មោះថា **ទ្រទ្រង់ធម៌** ព្រោះទ្រទ្រង់ទុកនូវព្រះធម៌ ពោលគឺ ព្រះសូត្រ និង ព្រះអភិធម្ម ។ ឈ្មោះថា **ទ្រទ្រង់វិន័យ** ព្រោះទ្រទ្រង់នូវព្រះវិន័យ ។ ឈ្មោះថា **ទ្រទ្រង់នូវមាតិកា** ព្រោះទ្រទ្រង់ទុកនូវមាតិកានៃព្រះធម៌ និង ព្រះវិន័យទាំងនោះឯង ។ ឈ្មោះថា **សាកសួរក្នុងធម៌បរិបុច្ឆា** ( បានដល់ ក្នុងធម៌ គឺ ពាក្យនិយាយដែលបានពោល ឬ បានបញ្ញត្តិទុក ឬ ក្នុងធម៌ គឺ ហេតុដែលជាប្រការគួរសាកសួរ ) នោះៗ ។ ឈ្មោះថា **តែងតាំងបញ្ហា** បានដល់ សាកសួរ ពិចារណាក្នុងអត្ថ បរិបុច្ឆា ( បានដល់ ក្នុងអត្ថ គឺ សេចក្តីនៃពាក្យពោល ឬ ក្នុងអត្ថ គឺ ផល ដែលជាប្រការគួរសាកសួរ ) ។

ពាក្យថា **បពិត្រលោកម្ចាស់ដ៏ចម្រើន បទនេះយ៉ាងណា អ្វីជាអត្ថនៃបទនេះ** ជាពាក្យសំដែងអាការដែលសាកសួរ និងតាំងបញ្ហា ។ លោកដ៏មានអាយុទាំងនោះរមែងបើកបង្ហាញអត្ថនៃព្រះបាលី ដែលមិនទាន់បានបើកបង្ហាញ ដោយអាគម ( បរិយត្តិជាគោលដែលមក ) ដោយការអាងព្រះបាលីចំណែកដទៃ ។ រមែងធ្វើឲ្យបានច្បាស់នូវអត្ថដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ដោយការសម្តែងយុត្តិ (ប្រការត្រឹមត្រូវ ដោយហេតុផល ) ។ រមែងបន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយដែលតាំងនៅក្នុងឋានៈគួរសង្ស័យ ដោយការឲ្យនូវសេចក្តីវិនិច្ឆ័យយ៉ាងត្រឹមត្រូវ ក្នុងចំណែកនៃព្រះបាលីដែលមានឋានៈមិនច្បាស់លាស់ ដោយភាពជាហេតុកើតឡើងនូវសេចក្តីសង្ស័យ ។

ក្នុងបណ្ដាអង្គទាំងនោះ សេចក្ដីថា “ មិនឆ្ងាយពេក មិនជិតពេក ងាយស្រួលដោយការទៅមក ” ចាត់ជាអង្គ១ ។ សេចក្ដីថា “ ពេលថ្ងៃមិនអ៊ូអរ ពេលយប់មិនមានសំឡេង ប្រាសចាកសំឡេងអឺកធឹក ” ចាត់ជាអង្គ១ ។ សេចក្ដីថា “ មិនមានសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និង ពស់តូចពស់ធំ ” ចាត់ជាអង្គ១ ។ សេចក្ដីថា “ កាលបើភិក្ខុ នៅក្នុងសេនាសនៈនោះ ។ ល ។ បរិក្ខាររមែងកើតឡើងដោយមិនលំបាកឡើយ ” ចាត់ជាអង្គ១ ។ សេចក្ដីថា “ ក្នុងសេនាសនៈនោះ ភិក្ខុដែលជាព្រះថេរៈទាំងឡាយ ។ ល ។ រមែងបន្ទោបង់សេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយ ដែលតាំងនៅក្នុងឋានៈគួរសង្ស័យ ” ចាត់ជាអង្គ១ ។

បណ្ឌិតគប្បីជ្រាបអង្គ ៥ ប្រការ តាមដែលពោលហើយមកនេះចុះ ។

( ចប់មហាដីកា )

## ការលះបង់បលិពោធតូចតាច

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីថា “ **ធ្វើការលះបង់បលិពោធតូចតាចចេញ** ” ព្រះយោគីអ្នកបាននៅក្នុងវិហារដ៏សមគួរយ៉ាងនេះ បលិពោធទាំងឡាយ សូម្បីតូចតាចដែលលោកមានហើយ ក៏គប្បីលះបង់ចេញផង បលិពោធតូចតាច គឺអ្វីខ្លះ គឺសក់វែង ក្រចកវែង រោម ( ប្រមុះ ពុកមាត់ ពុកចង្កា )វែង ត្រូវកោរ កាត់ចេញ គប្បីធ្វើការជួសជុល ឬ ការដេរប៉ះចីវរចាស់ៗ ឬថាជ្រលក់ចីវរ ដែលសៅហ្មង បើបាត្រមានស្និមគប្បីដុសសម្អាតចេញ គ្រឿងសេនាសនៈ មានគ្រែ តាំង ជាដើម គប្បីបោសសម្អាតឲ្យបានស្អាត ។

នេះជាសេចក្តីពិស្តារក្នុងសេចក្តីថា “ធ្វើការលះបង់បលិពោធតូចតាចចេញ”។

## មហាដីកា

## ការលះបង់បលិពោធតូចតាច

ប្រយោជន៍ក្នុងការលះបង់បលិពោធតូចតាចនឹងមកដល់ខាងមុខ ។ ការដែលភិក្ខុគួរធ្វើការជួសជុល ដើម្បីឲ្យប្រើប្រាស់បាន មានការដេរប៉ះជាដើមខ្លះ ។ គួរតភ្ជាប់ចំណែកអំបោះដែលដាច់ ឡើងវិញខ្លះ ។

( ចប់មហាដីកា )

# វិត្ថារកថានៃការនាវិធី
# បឋវីកសិណ

ពាក្យពណ៌នាតទៅនេះ ជាពាក្យពោលយ៉ាងពិស្តារក្នុងសេចក្តីថា “ **កុំធ្វើការនាទាំងពួងឲ្យវិនាសទៅ ធ្វើឲ្យសម្រេចផលចុះ** ” នេះពោលដោយការនាវិធីនៃកម្មដ្ឋានទាំងអស់ ចាប់ផ្តើមពីបឋវីកសិណជាដើមតទៅ ក្នុងកាលឥឡូវនេះ :

សេចក្តីពិស្តារថា ភិក្ខុអ្នកលះបង់បលិពោធតូចតាចចេញ បានយ៉ាងនេះហើយ ត្រឡប់ពីបិណ្ឌបាត ក្រោយពេលឆាន់ បន្ទោបង់សេចក្តីស្រវឹងក្នុងអាហារហើយ អង្គុយយ៉ាងសប្បាយ ក្នុងឱកាសដែលស្ងាត់ គប្បីកាន់យកនិមិត្តក្នុងដីដែលតាក់តែងឡើង ឬ មិនបានតាក់តែងក៏បាន ពិតហើយ សេចក្តីនេះព្រះបុរាណាចារ្យក៏បានពោលទុកថា “ ព្រះយោគី ដែលនឹងកាន់យកបឋវីកសិណ កាន់យកនិមិត្តក្នុងដីដែលតាក់តែងឡើង ឬ មិនបានតាក់តែងក៏ដោយ ត្រូវតែជាដីដែលមានទីបំផុត គឺ មានកំណត់សណ្ឋានមូលព័ទ្ធជុំវិញបាន មិនមែន( ធំរហូត ) គ្មានទីបំផុត គឺ មិនមានការកំណត់ទីបំផុត សណ្ឋានមិនមូល ព័ទ្ធជុំវិញមិនបានខ្នាតប៉ុនក្រឡ ឬ ប៉ុនចានគោម លោកធ្វើនិមិត្តនោះឲ្យល្អហើយ កំណត់ចំណាំទុកយ៉ាងល្អ ពេលលោកធ្វើនិមិត្តនោះបានល្អ កំណត់ចំណាំទុកយ៉ាងល្អហើយ នឹង ជាអ្នកឃើញអានិសង្ស មានសេចក្តីសម្គាល់(ក្នុងបឋវីនិមិត្ត) ថាជាដួងកែវ ហើយកើតសេចក្តីកោតក្រែង( ក្នុងនិមិត្តនោះ ដោយឃើញថាជារបស់សំខាន់ មិនបណ្តោយឲ្យវិនាសទៅឡើយ ) ស្រឡាញ់ចងចិត្តទុកយ៉ាងមាំក្នុងអារម្មណ៍នោះ ដោយការជឿថា “ យើងនឹងត្រូវរួចផុតចាក ជរា មរណៈ ដោយបដិបទានេះយ៉ាងពិតប្រាកដ ” លោកស្ងាត់ចាកកាមទាំងឡាយតែម្យ៉ាង ។ ល ។ ចូលដល់បឋមជ្ឈាន ដូច្នេះ ។

ព្រះយោគាវចរណា ដែលធ្លាប់បួសក្នុងព្រះសាសនា ឬថា បួសជាឥសី ធ្វើចតុត្ថជ្ឈាន ឬបញ្ចមជ្ឈានក្នុងបឋវីកសិណឲ្យកើតឡើងហើយ សូម្បីក្នុងអតីតកព និមិត្តក្នុងដីដែលមិនបានតាក់តែង ( ដូចពោល )ក្នុងពាក្យអដ្ឋកថាបុរាណនោះ គឺ ក្នុងកន្លែងដែលគេភ្ជួរហើយ ក្នុងរង្វង់មូលនៃលានបញ្ជាន់ស្រូវ រមែងកើតឡើងបាន ដល់ព្រះយោគាវចរដែលមានបុណ្យ អ្នកដល់ព្រមដោយឧបនិស្ស័យ( នៃភាវនា ) ដូចព្រះមល្លកត្ថេរៈ ... ។

បានឮថា កាលព្រះថេរៈអង្គនោះ មើលដីដែលគេភ្ជួរហើយ និមិត្តប្រមាណ ប៉ុនទីដែលមើលឃើញនោះ បានកើតឡើង លោកពង្រីកនិមិត្តនោះ ធ្វើបញ្ចមជ្ឈាន ឲ្យកើតឡើង ហើយចម្រើនវិបស្សនា មានឈានជាបទដ្ឋាន ក៏បានសម្រេច ព្រះអរហត្ត ។

ចំណែកព្រះយោគាវចរណា ដែលមិនបានធ្វើបុញ្ញាធិការទុក យ៉ាងនោះ ព្រះយោគាវចរនោះ កុំធ្វើកម្មដ្ឋានវិធីដែលបានរៀនមកពីសម្នាក់របស់អាចារ្យឲ្យខុស ឡើយ វៀរចាកទោសកសិណ ៤ ប្រការ ចេញ ធ្វើកសិណចុះ ។ ទោសនៃ បឋវីកសិណមាន ៤ ទាក់ទងដោយការលាយឡំគ្នានៃដីពណ៌ខៀវ ដីពណ៌លឿង ដីពណ៌ក្រហម និង ដីពណ៌ស ព្រោះហេតុនោះ ព្រះយោគាវចរកុំកាន់យកដីដែល មានពណ៌ មានពណ៌ខៀវជាដើម គប្បីធ្វើវង់កសិណដោយដីឥដ្ឋមានពណ៌សុទ្ធដូច ពណ៌អរុណ ដូចជាដីក្នុងទន្លេគង្គា កសិណនោះមិនគួរធ្វើក្នុងកន្លែងដែលជាទីសញ្ចរ ទៅមករបស់អនុបសម្បន្នទាំងឡាយ មានសាមណេរជាដើម នៅក្នុងវិហារ តែគួរ ធ្វើក្នុងទីកំបាំងនៅក្រោយវិហារនៅញកភ្នំ ឬបណ្ណសាលាក្តី ធ្វើជាប្រភេទអាចផ្លាស់ ទីបាន ឬ ជាប្រភេទតាំងនៅមួយកន្លែងក៏បាន ។

## វិធីធ្វើវង់កសិណប្រភេទផ្លាស់ទីបាន

ក្នុងកសិណ ២ ប្រភេទនោះ ប្រភេទផ្លាស់ទីបាន គួរចងកំណាត់សំពត់ ឬ កំណាត់ស្បែក ឬកំណាត់កន្ទេលក៏បាន ជាមួយឈើខ្វែងជាបួន ហើយយកដីដែលមិនមានឫសស្មៅ ដុំក្រួស និង ខ្សាច់ចេញហើយ ញីល្អហើយ យកមកពាសធ្វើជាវង្វង់រាងមូល បានខ្នាតដូចដែលពោលមកហើយ ដាក់នៅលើកំណាត់សំពត់ ឬ កំណាត់ស្បែក ឬកំណាត់កន្ទេលដែលបានចងទុកនោះ កសិណដែលប្តូរទីបាននោះ ពេលនឹងបរិកម្ម ត្រូវដាក់ឲ្យរាបស្មើលើផែនដី ហើយទើបសម្លឹង ។

## វិធីធ្វើវង់កសិណប្រភេទនៅមួយកន្លែង

វង់កសិណប្រភេទតាំងនៅជាប់មួយកន្លែង ត្រូវបោះបង្គោលច្រើនចុះក្នុងផែនដី ដោយអាការនៃត្របកផ្កាឈូក (គឺបោះចុះក្រោម ហើយនៅសល់ខាងលើស្មើគ្នា ដោយជុំវិញដូចសណ្ឋាននៃត្របកផ្កាឈូក ) ហើយចងដោយវល្លិ ធ្វើជាគ្រោងឡើង បើដីនោះមិនគ្រប់គ្រាន់ ត្រូវប្រើរបស់ផ្សេងទៀតទ្រពីក្រោម ហើយធ្វើវង់កសិណឲ្យមានសណ្ឋានមូល ទំហំប្រមាណ ១ ចំអាម ៥ ធ្នាប់ ដោយដីពណ៌អរុណដែលជម្រះល្អហើយនៅផ្ទៃខាងលើ ការពិតពាក្យថា “ ខ្នាតប៉ុនក្រឡ ឬ ខ្នាតប៉ុនចានគោម ” ព្រះបុរាណាចារ្យពោលសំដៅយកប្រមាណ ( ១ ចំអាម ៤ ធ្នាប់ )នោះឯង ចំណែកពាក្យថា “ជាដីមានទីបំផុត មិនមែនគ្មានទីបំផុត” ជាដើម លោកពោលទុកដើម្បីកំណត់ខ្នាតបឋវីនិមិត្តនោះ ព្រោះហេតុនោះ ព្រះយោគាវចរធ្វើវង់កសិណឲ្យបានតាមកំណត់ខ្នាតដូចពោលនោះហើយ កុំប្រើឈើកៀស ព្រោះវាធ្វើឲ្យកសិណនោះកើតពណ៌ជាវិសភាគៈ ត្រូវប្រើថ្មកៀសធ្វើឲ្យរាបស្មើ ដូចជា

ផ្ទៃស្គរ ហើយបោសសម្អាតទីកន្លែងនោះចេញ ទៅងូតទឹកហើយ ទើបមកអង្គុយនៅលើទីតាំងដែលបានរៀបចំស្រួលបួលហើយ ដែលមានជើងកម្ពស់ប្រមាណ ១ ចំអាម ៤ ធ្នាប់ ដែលបានចាត់ចែងទុកពីមុន មានចម្ងាយ ២ ហត្ថ ១ ចំអាម ពីវង់កសិណ ព្រោះបើអង្គុយឆ្ងាយជាងនោះ កសិណនឹងមិនច្បាស់ ជិតជាងនោះ ទោសកសិណនឹងប្រាកដ ម្យ៉ាងទៀត អ្នកអង្គុយខ្ពស់ពេក នឹងត្រូវឱនកចុះមើល ( យូរទៅនឹងចុកក ) បើអង្គុយទាបពេក ត្រូវលុតជង្គង់ឡើងមើល ជង្គង់នឹងត្រូវមានការឈឺចាប់ ព្រោះដូច្នោះ គប្បីអង្គុយតាមន័យដែលបានពោលហើយនោះចុះ ហើយពិចារណាឃើញទោសក្នុងកាមទាំងឡាយ ដោយន័យថា កាមទាំងឡាយមានសេចក្ដីត្រេកអរតិច ដូច្នេះជាដើម រហូតកើតការពេញចិត្តក្នុងនេក្ខម្មៈ ដែលជាគ្រឿងនាំចេញចាកកាម ជាឧបាយឈានកន្លងទុក្ខ ទាំងពួង ញុំាងបីតិ និង បាមោជ្ជឲ្យកើតឡើងដោយរឭកដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានការគោរពកើតឡើងក្នុងខបដិបត្តិដោយគិតឃើញថា “ នេក្ខម្មប្បដិបទានេះ ជាផ្លូវដែលព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និង ព្រះអរិយសាវកទាំងឡាយ បានបដិបត្តិមកហើយដល់ពេលនេះ ” ៗ ញុំាងសេចក្ដីឧស្សាហៈឲ្យកើតឡើង ដោយប្រាថ្នាថា “ យើងក៏ជាអ្នកមានចំណែកនៃរសរបស់វិវេកសុខ ដោយការបដិបត្តិនេះយ៉ាងពិតប្រាកដ ” ដូច្នេះ ហើយបើកភ្នែកដោយអាការល្មម ( សម្លឹងមើល ) កាន់យកនិមិត្តភាវនាចុះ ព្រោះពេលអ្នកបើកភ្នែកធំពេក ភ្នែកនឹងឈឺ ហើយដួងកសិណក៏ប្រាកដធំពេក ការធ្វើដោយវិធីនេះ និមិត្តក៏មិនអាចកើតឡើងដល់លោកបាន ចំណែកការបិទភ្នែកតូចពេក ដួងកសិណក៏មិនប្រាកដច្បាស់ ចិត្តនឹងរួញរា សូម្បីដោយវិធីយ៉ាងនេះ និមិត្តក៏មិនកើត ព្រោះហេតុនោះ ត្រូវបើកភ្នែកដោយអាការល្មម កាន់យកនិមិត្តភាវនាចុះ

ដូចមើលនិមិត្តនៃមុខរបស់ខ្លួន នៅមុខកញ្ចក់ដូច្នោះ មិនត្រូវពិចារណាពណ៌ មិនត្រូវធ្វើទុកក្នុងចិត្តដល់លក្ខណៈ ( នៃបឋវីនិមិត្តនោះ ) តែថា នឹងលះបង់ពណ៌ចេញក៏មិនបាន ត្រូវធ្វើឲ្យវាស្មើគ្នាក្នុងទីអាស្រ័យ គឺ នឹកថា ពណ៌នេះតែមួយដូចគ្នានឹងដីដែលជាទីអាស្រ័យរបស់ខ្លួន បំបែកចេញពីគ្នាមិនបាន តាំងចិត្តទុកក្នុងបណ្ណត្តិធម៌( គឺ លោកវោហារ ) មនសិការទៅដោយឧសទវោហារ ( គឺ ពាក្យសំដែងតាមមាត់និយាយ ) បណ្តាឈ្មោះរបស់ដីទាំងឡាយ ដូចជា បឋវី មហីមេទនី ភូមិ វសុធា វសុន្ធរា ព្រះយោគាវចរពេញចិត្តឈ្មោះណា ជាពាក្យអនុកូលដល់សញ្ញា ( គឺ ជួយឲ្យការកំណត់ចាំបានងាយ ) សម្រាប់លោក គប្បីពោលឈ្មោះនោះ ប៉ុន្តែថាឈ្មោះគឺ បឋវី នោះឯងងាយ ព្រោះដូច្នោះគប្បីភាវនាថា **បឋវី បឋវី** ជាឈ្មោះដែលងាយតែម្យ៉ាងចុះ ត្រូវបើកភ្នែកមើលម្តង ហើយបិទភ្នែកពិចារណាមើលម្តង ( ផ្លាស់ប្តូរគ្នា ) បើឧគ្គហនិមិត្តមិនទាន់កើតដរាបណា គប្បីភាវនាទៅតាមន័យនោះឯងដរាបនោះ សូម្បី ១០០ ដង ១០០០ ដង សូម្បីច្រើនជាងនោះក្តី កាលបើលោកភាវនាទៅយ៉ាងនេះ ក្នុងខណៈណាបិទភ្នែកពិចារណាមើលនិមិត្តមកកាន់គន្លង ( នៃមនោទ្វារិកជវន ) ដូចក្នុងវេលាបើកភ្នែក ក្នុងខណៈនោះ ឈ្មោះថា ឧគ្គហនិមិត្តកើតហើយ តាំងពីវេលាដែលឧគ្គហនិមិត្តនោះកើតហើយ មិនគប្បីអង្គុយក្នុងទីនោះទេ គប្បីចូលទៅកាន់ទីនៅរបស់ខ្លួន ហើយអង្គុយនៅក្នុងទីនៅរបស់ខ្លួននោះ ភាវនា( តទៅ ) ។

ដើម្បីសម្រួលដល់ការយឺតយូរ ដោយការដែលត្រូវលាងជើង ត្រូវការស្បែកជើង១ជាន់ ១គូ និងឈើច្រត់១ សម្រាប់លោក បើថាសមាធិដែលទន់នោះ វិនាសទៅ ដោយហេតុជាអសប្បាយណាមួយក្តី លោកត្រូវពាក់ស្បែកជើង កាន់ឈើច្រត់

ទៅកាន់ទី( កន្លែងវង់កសិណ )នោះ កាន់យកនិមិត្ត( បានហើយ ) មកអង្គុយតាមសប្បាយ ភាវនា( បន្តទៅ ) គប្បីពិចារណានិមិត្ត( សាចុះឡើង ) ធ្វើឲ្យជាវិតក្កាហតៈ ( នឹកបានៗ ) ( នឹកធ្វើឲ្យមានសភាពផ្សេង ៗ បាន ) កាលលោកធ្វើយ៉ាងនោះ នីវរណៈទាំងឡាយនឹងស្ងប់ទៅ កិលេសទាំងឡាយនឹងស្ងប់ចុះតាមលំដាប់ ចិត្តនឹងតាំងមាំដោយឧបចារសមាធិ បដិភាគនិមិត្តនឹងកើតឡើង ។

## មហាដីកា

## អំពីភាវនាវិធី

ពាក្យថា **ទាក់ទងជាមួយកម្មដ្ឋានទាំងពួង** គឺ ទាក់ទងជាមួយនឹងកម្មដ្ឋានទាំងអស់ ៤០ យ៉ាង ដែលលោកអាចារ្យនឹងសម្តែងអធិប្បាយទៅតាមលំដាប់ ។

ពាក្យថា **ត្រឡប់ពីបិណ្ឌបាត** គឺ ត្រឡប់ពីឆាន់បិណ្ឌបាត មានន័យថា ឆាន់បិណ្ឌបាតហើយ ដាក់បាត្រចុះពីដៃហើយ ។ ពាក្យថា **បន្ទោបង់សេចក្តីស្រវឹងក្នុងភត្ត** គឺ បន្ទោបង់សេចក្តីមិនសប្បាយព្រោះភោជនជាហេតុ ។ ពិតហើយ សូម្បីត្រឹមតែអាហារចូលទៅដល់ទីអាស្រ័យហើយប៉ុណ្ណោះ ដោយច្រើនរាងកាយអាចមានសេចក្តីមិនសប្បាយខ្លះបាន ព្រោះមានអាហារនោះជារបស់ចរចូលទៅ ព្រះយោគីបន្ទោបង់ការមិនសប្បាយនោះចេញ ។ ព្រោះថា កាលសេចក្តីមិនសប្បាយនោះមិនទាន់ស្ងប់ ចិត្តនឹងមិនអាចបានភាពជាឯកគ្គៈ( មានអារម្មណ៍តែមួយ ) ព្រោះរាងកាយមានភាពមិនសប្បាយ ។

ពាក្យថា ( ក្នុងឱកាស ) **ទីស្ងាត់** គឺ ក្នុងឱកាសដែលស្ងាត់ចាកមនុស្ស ។

ពាក្យថា **អង្គុយជាសុខ** គឺ ឈ្មោះថាអង្គុយជាសុខ ក៏ដោយការអង្គុយតែន

ក្អែនតាំងកាយឲ្យត្រង់ ។ ពាក្យថា **សេចក្តីនោះសមពិតដូចបុរាណាចារ្យបានពោលទុក** មានន័យថា ការកាន់យកនិមិត្តក្នុងបឋវី ដែលលោកអាចារ្យពោលដល់ក្នុងទីនេះ ដោយពាក្យថា " ដែលធ្វើឡើងក៏បាន " ដូច្នេះឯណា ការកាន់យកនិមិត្តនេះលោកពោលទុកក្នុងអដ្ឋកថាបុរាណ ។

ពេលនេះ លោកអាចារ្យកាលនឹងសម្តែងបាលីនៃអដ្ឋកថានោះ ទើបពោលថា " ព្រះយោគីកាលនឹងកាន់យកបឋវីកសិណា " ដូច្នេះជាដើម ។ តទៅនេះជាន័យដោយសង្ខេបក្នុងបាលីអដ្ឋកថានោះ :

ពាក្យថា **កាលនឹងកាន់យកបឋវីកសិណា** បានដល់ កាលនឹងកាន់ គឺ កាលនឹងយកបឋវីកសិណាដោយឧគ្គហនិមិត្ត មានន័យថា កាលនឹងធ្វើបឋវីកសិណាដែលជាឧគ្គហនិមិត្តឲ្យកើតឡើង ។ ការធ្វើឲ្យកើតឡើងក្នុងទីនេះ គប្បីឃើញថា ការចូលទៅតាំងទុកនូវនិមិត្តដោយអាការនោះ ។

ពាក្យថា **ក្នុងបឋវី** គឺ ក្នុងដួងបឋវី ដែលមានសេចក្តីពិសេសត្រូវពោលដល់ ។

ពាក្យថា **រមែងកាន់យកនិមិត្ត** គឺ រមែងកាន់យកបឋវីនិមិត្តក្នុងដួងបឋវីនោះដែលមានភាពពិសេសគួរពោលដល់ដោយការនាញាណ ដូចកាន់យកស្រមោលមុខក្នុងផ្ទៃកញ្ចក់ដោយភ្នែកដូច្នោះ ។ សូម្បីពោលថា **បឋវិយំ** ដូច្នេះហើយ ក៏មានពាក្យសម្តែងអធិប្បាយជានបុំសកលិង្គថា ( **កតេ វា អកតេ វា** ជាដើម ) ព្រោះសម្ទឹងដល់ពាក្យថា **មណ្ឌលំ** ។

ពាក្យថា **ដែលធ្វើឡើង** មានន័យថា ដែលគាត់តែងឡើងតាមវិធីដែលនឹងពោលដល់ ។

**វា** សត្ត មានអត្ថថា មិនកំណត់ពិតប្រាកដ ( ក្នុងទីនេះប្រែថា ក៏បាន ) ។

ពាក្យថា **ដែលមិនបានធ្វើឡើង** គឺ ទីលានដី មានលានស្រូវជាដើមដែលមានហើយតាមប្រក្រតី ។ ពាក្យថា **សាន្តកេ** ស្មើគ្នានិង **សអន្តកេ ឯវ** ( ប្រែថា ដែលមានទីបំផុតប៉ុណ្ណោះ ) មានន័យថា ដែលមានព្រំដែនប៉ុណ្ណោះ ។ ព្រោះថា នេះជាពាក្យនិយាយដែលមានអវធារណៈ ( មានពាក្យកំណត់សេចក្ដី គឺ **ឯវ** សត្ត ដែល ប្រែថា ប៉ុណ្ណោះ ) ។ ពិតយ៉ាងនោះ ដើម្បីឲ្យឃើញវត្ថុ ដែលលោកហាមទុក ដោយពាក្យពោលដែលមានអវធារណៈនោះ ទើបលោកពោលថា "**នោ អនន្តកេ**" មិនមែនគ្មានទីបំផុតដូច្នេះ ។ សូម្បីបទថា **សកោដិយេ** ដែលមានទីបំផុតជាដើម ក៏ជាពាក្យវេវចនៈរបស់ពាក្យថា **សាន្តកេ** នោះឯង ។ ពាក្យថា **សុប្បមត្តេ វា** ជាដើម លោកត្រូវការចង្អេរ និង ចានគោមធ្វើដោយដី មានខ្នាតប៉ុនគ្នា ។ ប៉ុន្តែអាចារ្យពួកខ្លះពោលថា " ឈ្មោះថា ដួងកសិណខ្នាតចានគោម ជាកសិណមានខ្នាត ១ ចំអាម ៤ ធ្នាប់ , ឈ្មោះថា ដួងកសិណខ្នាតចង្អេរ មានប្រមាណធំជាង ១ ចំអាម ៤ ធ្នាប់ ដូច្នេះ ។ ពាក្យថា **ខ្នាតចង្អេរ ឬ ខ្នាតចានគោម** លោកពោលទុក ដើម្បីរួបរួមប្រភេទដួងកសិណដែលជាបរិត្ត និង ជាអប្បមាណៈថា ដួងកសិណដែលធ្វើឡើង មានខ្នាតចានគោម ដោយការកំណត់យ៉ាងតូច ខ្នាតចង្អេរដោយការកំណត់យ៉ាងធំ , មិនតូចជាង មិនធំជាងនោះដូច្នេះ ។

ការដែលលោកពោលន័យនេះថា ដួងកសិណដែលព្រះយោគីពង្រីក សូម្បីត្រឹមតែមួយម្រាមដៃក្នុងអារម្មណ៍តាមដែលប្រាកដ ក៏ឈ្មោះថា ជាអប្បមាណៈនោះឯង ។ ចំណែកអាចារ្យពួកខ្លះពោលថា " ដួងកសិណដែលមានខ្នាតប៉ុនឆត្រ គួរធ្វើ ដូច្នេះ " ។

ពាក្យថា **ព្រះយោគាវចរនោះ រមែងធ្វើនិមិត្តនោះឲ្យជាការកាន់យកដោយល្អ** មានន័យថា ព្រះយោគាវចរនោះ រមែងធ្វើដួងបឋវីនោះឲ្យជានិមិត្តដែលកាន់យកដោយល្អ ។ ក្នុងវេលាណាដែលលោកបើកភ្នែកមើល កាន់យកនិមិត្ត ក្នុងដួងបឋវីនោះ ហើយបិទភ្នែក នឹកដល់ និមិត្តប្រាកដ ដូចក្នុងខណៈដែលបើកភ្នែកមើលក្នុងវេលានោះ ឈ្មោះថា រមែងធ្វើឲ្យជាការកាន់យកដោយល្អ ។

លំដាប់នោះ កាលធ្វើសតិឲ្យចូលទៅតាំងទុកដោយល្អក្នុងនិមិត្តនោះ កំណត់រឿយៗ ដោយចិត្តដែលមិនស្ទុះទៅខាងក្រៅ ក៏ឈ្មោះថា រមែងទ្រទ្រង់ចាំទុកដោយល្អ ។

ចំណែកការនឹកដល់ កាលមនសិការដល់និមិត្ត ដែលបានចាំទុកមាំទាំ នោះហើយ យ៉ាងនេះរឿយៗ ញុំាងការសេព គឺ ការនាំឲ្យប្រព្រឹត្តទៅប្រារព្ធនិមិត្តនោះឯងបានច្រើន ក៏ឈ្មោះថា រមែងកំណត់ទុកបានដោយល្អ ។

ពាក្យថា **ក្នុងអារម្មណ៍នោះ** គឺ ក្នុងអារម្មណ៍ដែលសម្គាល់ថា ជាបឋវីកសិណនោះ ដែលប្រាកដល្អហើយ ដោយការធ្វើឲ្យជាការកាន់យកដោយល្អហើយជាដើម យ៉ាងនេះ នោះឯង ។ ពាក្យថា **ចូលទៅចងចិត្តទុក** គឺ នាំចិត្តរបស់ខ្លួនចូលទៅចងទុកនឹងឧបចារជ្ឈាន ។ ធ្វើឲ្យបែរត្រឡប់ចាកពីអារម្មណ៍ដទៃ ។ ពាក្យថា **អទ្ធា ឥមាយ** ( ដោយបដិបទានេះជាប្រាកដ ) ជាដើម ជាពាក្យសំដែងដល់ភាពជាអ្នកសម្លឹងឃើញអានិសង្ស ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងបើកបង្ហាញវិធីចម្រើន ព្រមជាមួយនឹងការប្រកាសអត្ថនៃបាឋអដ្ឋកថាតាមដែលបានសំដែងទុក កាលនឹងសម្ដែងការកាន់យកនិមិត្តក្នុងបឋវីដែលមិនបានធ្វើទុកមកពីមុន ទើបពោលថា “ **តត្ថ យេន**

***អតីតករបិ*** " ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា ***តត្ថ*** ប្រែថា ក្នុងបាឋអដ្ឋកថានោះ ។ លោកពោលថា ឈាន ៤ ឈាន ៥ ដោយទាក់ទងនឹងឈានចតុក្កន័យ និង បញ្ចកន័យ ។

*ពាក្យថា **ចំពោះព្រះយោគាវចរអ្នកមានបុណ្យ** គឺ ចំពោះព្រះយោគាវចរអ្នកមានបុណ្យ គឺ ភាវនាមយៈ ។ ពាក្យថា **ដល់ព្រមដោយឧបនិស្ស័យ** គឺ ដល់ព្រមដោយឧបនិស្ស័យដែលមានដូច្នោះនោះឯង ។*

*បទថា **ខលមណ្ឌលេ** ( ក្នុងលានបញ្ជាន់ស្រូវ ) គឺ ក្នុងទីកន្លែងដែលមានការធ្វើទាក់ទងនឹងស្រូវដែលមានអាការដូចលាន ។ ពាក្យថា **មានខ្នាតប៉ុនទីកន្លែងនោះឯង** គឺ មានខ្នាតស្មើនឹងទីកន្លែងដែលលោកសម្លឹងមើលនោះឯង ។ ពាក្យថា **កុំធ្វើឲ្យឃ្លៀងឃ្លាត** គឺ មិនខុសពីវិធីដែលបានពោលហើយនោះឯង ។ ពាក្យថា **ទាក់ទង ដោយការលាយប្រឡំជាមួយ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌ស** គឺ ទាក់ទងនឹងការលាយប្រឡំគ្នាដោយដីច្រើនយ៉ាង ដែលមានច្រើនពណ៌ មាន ពណ៌ខៀវជាដើម ញែកចេញជាពណ៌នីមួយៗ ហើយរួមជាពណ៌តែមួយ ។ បទថា **គង្គាវហេ** ប្រែថា ខាងក្រោមទន្លេគង្គា ។ បានឮមកថា នៅឯសីហឡទ្វីបមានទន្លេមួយខ្សែឈ្មោះថា **រាវនគង្គា** ដីត្រង់នោះមានមុខត្រូវទឹកច្រោះ មានពណ៌ដូចពណ៌អរុណ ។ លោកអាចារ្យសំដៅយកដីនោះ ពោលថា " ដោយដីដែលមានពណ៌ដូចពណ៌អរុណ " ដូចជាដីខាងក្រោមទន្លេគង្គាចុះ " ដូច្នេះ ។ ឈ្មោះថា មានពណ៌ដូចពណ៌អរុណ គឺ ស្រដៀងពណ៌អរុណ មានន័យថា មានពណ៌ដូចពន្លឺនៃព្រះអាទិត្យ។ លោកអាចារ្យ កាលសំដែងទោសនៃកសិណាយ៉ាងនេះ ហើយឥឡូវនេះបំណាង សម្តែងវត្ថុដែលគួរបោះបង់ដ៏សេស មានការធ្វើកសិណា ជាដើម*

ទើបពោលថា “ **តញ្ច ខោ** ” ជាដើម ។ បទថា **សំហារិមំ** ប្រែថា ប្រភេទផ្លាស់ប្តូរទីបាន គឺ ប្រើដៃចាប់លើកយកទៅបាន ។ ពាក្យថា **ប្រភេទកម្រើកចាកទីមិនបាន** គឺ ធ្វើទុកទីណាក៏តាំងនៅទីនោះឯង ។ ពាក្យថា **មានខ្នាត ប៉ុនដែលពោលហើយ** គឺ មានខ្នាតប៉ុនដែលបានពោលទុកថា “ ខ្នាតចង្អេរ ឬ ខ្នាតចានគោម ” ដូច្នេះ ។ ពាក្យថា **ធ្វើជារង្វង់មូល** គឺ មានសណ្ឋានមូល ។

ពាក្យថា **ក្នុងវេលាបរិកម្ម** គឺ ក្នុងវេលាចម្រើនដើម្បីកាន់យកនិមិត្ត ។

បទថា **ឯតទេវ** មានន័យថា ខ្នាតទំហំ ១ ចំអាម ៤ ធ្នាប់ឯណា ខ្នាតទំហំ ១ ចំអាម ៤ ធ្នាប់នោះឯង ដែលលោកសំដៅយកថា “ ខ្នាតចង្អេរ ឬ ខ្នាតចានគោម ”ដូច្នេះ ។ ពិតហើយ ចង្អេរមិនធំពេក ហើយចានគោមមិនធំពេក មិនល្មមប្រើប្រាស់ជាគម្របពាង ព្រោះហេតុនោះ ទើបឈ្មោះថា មានខ្នាតសមល្មម ។

ពាក្យថា **ព្រោះហេតុនៃទី** គឺ ព្រោះការដែលលោកពោលទុក ដើម្បីប្រយោជន៍ គឺ ដែនខេត្តរបស់កសិណ ។ ពាក្យថា **ធ្វើដែនខេត្តមានខ្នាតប៉ុនដែលបានពោលទុកយ៉ាងនេះ** គឺ ធ្វើដែនខេត្តតាមខ្នាតដែលបានពោលទុកហើយ គឺ ទំហំ ១ ចំអាម ៤ ធ្នាប់ ឬថា ធ្វើដួងកសិណ មានខ្នាតដែលបានពោលទុកយ៉ាងនេះឲ្យជាដែនខេត្ត ដោយពណ៌ដែលខុសគ្នា ។ ពាក្យថា **ឈើកៀស** មានន័យថា ឈើច័ន្ទសម្រាប់កៀសជាដើម រមែងធ្វើពណ៌ឲ្យកើតឡើងផ្សេងពីពណ៌អរុណ ។ ទើបលោកអាចារ្យពោលថា ព្រោះដូច្នោះ កុំប្រើឈើកៀសនោះ។ ចំណែកឈើកៀសប្រក្រតី ក៏មានគតិជាថ្មកៀសនោះឯង ។ ឈ្មោះថា ធ្វើឲ្យរាបស្មើដូចផ្ទៃស្គរ ក៏ដោយការមិនមានចំណែករដិបរដុប ។ ពាក្យថា **ក្នុងទីឆ្ងាយជាងនោះជាដើម** គឺ ក្នុងទីឆ្ងាយ សូម្បីពីទីតាំងតាមដែលបានពោលហើយ ក្នុងទីជាទៃពីទីតាំងនោះ (ដែលជិតពេក) ក៏មាន

ការឃើញទោស ។ ពាក្យថា **ទោសកសិណ** មានន័យថា ស្នាមបាតដៃជាដើម ឈ្មោះថា ទោសកសិណក្នុងទីនេះ ។ ពាក្យថា **តាមន័យដែលបានពោលហើយប៉ុណ្ណោះ** គឺ តាមវិធីដែលបានពោលហើយថា “ ត្រង់ទីតាំងដែលមានចម្ងាយ ២ ហត្ថកន្លះ និងថា តាំងដែលមានកម្ពស់ ១ ចំអាម ៤ ធ្នាប់ ” ដូច្នេះ ។ ពាក្យថា **ទោសក្នុងកាមទាំងឡាយ** បានដល់ ពិចារណាអាទីនវៈ គឺ ទោសក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយដែលមានភាពអាក្រក់ថោកទាបដោយអាការជាច្រើន ដោយន័យថា “ ឈ្មោះថា កាមទាំងឡាយនេះប្រៀបបាននឹងកំណាត់ឆ្អឹង ព្រោះអត្ថថា មិនគួរត្រេកអរ ប្រៀបបាននឹងគប់ភ្លើង ព្រោះអត្ថថា ធ្វើឲ្យក្តៅដ៏ខ្លាំងក្លា ប្រៀបបាននឹងយល់សប្តិ ព្រោះអត្ថថា ប្រាកដត្រឹមមួយជួរខណៈ ប្រៀបបាន នឹងរបស់ខ្ចីគេ ព្រោះអត្ថថា មានវេលាត្រឹមតែប៉ុណ្ណោះ ប្រៀបបាននឹងផ្លែឈើមានពិស ព្រោះអត្ថថា កម្ចាត់អវយវៈតូចធំទាំងពួង ប្រៀបបាននឹងមុខកាំបិត ព្រោះអត្ថថា នឹងត្រូវមុតស្លាប់ ប្រៀបបាននឹងផ្លែស្នួ ព្រោះអត្ថថា ចាក់ទម្លុះ ប្រៀបបាននឹងក្បាលពស់ព្រោះអត្ថថា មានការគួរឲ្យភ័យខ្លាច ” ដូច្នេះ ។

ដោយន័យថា កាមទាំងឡាយមានគុណតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ” ដូច្នេះ ហើយដោយន័យថា “ ម្យ៉ាងទៀត ដែលឈ្មោះថា កាមសុខនេះ មានអន្តរាយច្រើន គួរឲ្យតក់ស្លុត មានភ័យ សៅហ្មង អាក្រក់លាមក ដូចបរិភោគឧច្ចារៈ ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ ប្រកបដោយសេចក្តីវិនាស ” ជាដើម ។ ពាក្យថា **ក្នុងធម៌ជាគ្រឿងរលាស់ចេញចាកកាម** គឺ ក្នុងធម៌ដែលជាគ្រឿងរលាស់បោលនូវកាមទាំងឡាយ ឬក្នុងធម៌ដែលរលាស់ចេញចាកកាមទាំងនោះ ។ ឈ្មោះថា ជាឧបាយឈានកន្លងទុក្ខ

ទាំងឡាយ ក៏ដោយភាពជាបាទនៃមគ្គថ្នាក់កំពូល ( អរហត្តមគ្គ ) ។

ពាក្យថា **នេក្ខម្ម** បានដល់ ឈាន ។

ពាក្យថា **មានសេចក្ដីស្រឡាញ់ពេញចិត្តកើតឡើង** បានដល់ មានការពេញចិត្តកើតឡើង ។

ធ្វើបីតិ និងបាមោជ្ជដែលមានព្រះរតនត្រ័យជាអារម្មណ៍ឲ្យកើតឡើង ដោយការរលឹកដល់ព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឃគុណរឿយ ៗ យ៉ាងនេះថា ព្រះមានព្រះភាគទ្រង់ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ព្រោះទ្រង់សម្ដែងធម៌មិនវិបរិត ព្រះធម៌ព្រះមានព្រះភាគត្រាស់ទុកល្អហើយ ព្រោះទៀងតែនាំចេញចាកទុក្ខបានតែម្យ៉ាង ព្រះសង្ឃជាអ្នកបដិបត្តិល្អ ព្រោះបដិបត្តិបាន តាមដែលទ្រង់អនុសាសន៍ ទុកដូច្នេះ ។

ឈ្មោះថា **នេក្ខម្មប្បដិបទា** ព្រោះអត្ថថា ជាគ្រឿងបដិបត្តិនេក្ខម្មៈ មានន័យថា ជាហេតុឲ្យសម្រេចឈាន និង ឧបចារឈាន វិបស្សនា មគ្គ និង និព្វាន ។ ព្រោះពោលទុកក្នុងខាងដើមហើយថា បឋមជ្ឈាននោះ ឈ្មោះថា **នេក្ខម្ម** កុសលធម៌ដ៏សេសពីបឋមជ្ឈានដែលបានពោលហើយសូម្បីទាំងអស់ ឈ្មោះថា **នេក្ខម្មធម៌** ។

ដូចដែលពោលថា :

ការបួស បឋមជ្ឈាន វិបស្សនា និព្វាន និង កុសលធម៌ទាំងពួង ហៅថា **នេក្ខម្ម** ដូច្នេះ ។

ពាក្យថា **នៃរសរបស់វិវេកសុខ** គឺ នៃរសរបស់សេចក្ដីសុខ ដែលកើតពីវិវេក មានចិត្តវិវេកជាដើម ។ គប្បីឃើញថា អត្ថន័យនៃបទថា “ **ជាអ្នកសម្លឹងឃើញអានិសង្ស** ” ជាដើម គឺ លោកអាចារ្យបានសម្ដែងទុក ដោយ ៥ បទ នេះ

តាមប្រការដែលពោលមកនេះ ។ ពាក្យថា **ដោយអាការល្មម** គឺ ដោយអាការដែលសម្លឹងមើលល្មម ពោលគឺ មិនបើកភ្នែកមើលធំពេក មិនបើកភ្នែកមើលតូចពេក វៀរចាកការបើកភ្នែកមើលធំពេក និង បើកភ្នែកមើលតូចពេក ។

ពាក្យថា **កាន់យកនិមិត្ត** គឺ កាន់យកដោយចិត្ត នូវនិមិត្តក្នុងបបរិកសិណដែលបានកាន់យកហើយដោយចក្ខុ ។ ពាក្យថា **ចម្រើនទៅចុះ** គឺ គប្បីចម្រើនបានដល់ គប្បីសេព គប្បីធ្វើឲ្យច្រើននូវការកាន់យកនិមិត្តដែលប្រព្រឹត្តទៅហើយដោយអាការនោះៗ ។ ឈ្មោះថា ភ្នែកនឹងឈឺ ក៏ដូចជាភ្នែករបស់អ្នកដែលសម្លឹងរូបល្អិតពេក និងភ្លឺច្បាស់ពេក ដូច្នោះ ។ ឈ្មោះថា ច្បាស់ហួសពេក ក៏ព្រោះការបើកបង្ហាញនូវសភាពរបស់ខ្លួន ។ ព្រោះយ៉ាងនោះ ទើបគប្បីតាំងឡើងដោយពណ៌ខ្លះ ដោយលក្ខណៈខ្លះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ ព្រោះហេតុដែលដួងកសិណាច្បាស់ពេក និមិត្តរបស់ដួងកសិណានោះនឹងមិនកើតឡើង ” ដូច្នេះ ។ ឈ្មោះថា នឹងមានការមិនច្បាស់ដល់អ្នកដែលសម្លឹងមើល ដោយអាការបើកភ្នែកដូចជាជាងដូច្នេះ ។ ឈ្មោះថា **ចិត្ត** ក៏នឹងអាចមានការរួញរាបាន ក៏ដោយការធ្លាក់ទៅក្នុងកោសជ្ជៈ( ការខ្ជិលច្រអូស ) ព្រោះសេចក្តីព្យាយាមក្នុងការសម្លឹងមើលទន់ខ្សោយ ។ ព្រោះហេតុនោះ ទើបលោកពោលថា “ សូម្បីយ៉ាងនេះ និមិត្តក៏មិនកើតឡើង ”ដូច្នេះ ។ ពាក្យថា **ដូចជាអ្នកមើលស្រមោលមុខក្នុងកញ្ចក់** រមែងមិនបើកភ្នែកមើលក្នុងផ្ទៃកញ្ចក់នោះធំពេក ទាំងមិនតូចពេក រមែងមិនពិចារណាពណ៌របស់កញ្ចក់ ទាំងមិនធ្វើទុកក្នុងចិត្តចំពោះលក្ខណៈ តែថា កាលក្រឡេកមើលដោយអាការល្មម ក៏រមែងមើលឃើញចំពោះស្រមោលមុខរបស់ខ្លួនយ៉ាងណា សូម្បីព្រះយោគាវចរនេះសម្លឹងមើលបបរិកសិណាដោយអាការល្មម រមែងឈ្មោះថា ជាអ្នក

ខ្វល់ខ្វាយក្នុងការកាន់យកនូវនិមិត្តប៉ុណ្ណោះ ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា “ **ដោយអាការល្មម** ” ដូច្នេះជាដើម ។

ពាក្យថា **មិនគួរពិចារណាពណ៌** មានន័យថា ពណ៌ដូចអរុណក្នុងបឋវីកសិណនោះ មិនគួរនឹកដល់ពណ៌នោះ ។ តែថា នរណាៗ មិនអាចហាមការកាន់យកដោយចក្ខុវិញ្ញាណបាន ។ ព្រោះហេតុនោះ ទើបលោកមិនពោលថា “ មិនគួរសម្លឹងមើលពណ៌ ” ក្នុងបឋវីកសិណនោះ ត្រឡប់ប្រើសព្ទថា ពិចារណា ។

ពាក្យថា **មិនគួរធ្វើទុកក្នុងចិត្តចំពោះលក្ខណៈ** មានសេចក្តីថា លក្ខណៈរឹងរបស់បឋវីធាតុក្នុងបឋវីកសិណនោះយ៉ាងណា ព្រះយោគាវចរមិនគួរធ្វើទុកក្នុងចិត្តនូវលក្ខណៈនោះឡើយ ។

លោកអាចារ្យសូម្បីពោលថា “ មិនលះបង់ពណ៌ ” ព្រោះភាពដែលត្រូវឃើញពណ៌ ទើបអាចកាន់យកនិមិត្តបាន កាលនឹងសម្តែងថា ព្រះយោគាវចរមិនគួរធ្វើការនឹកដល់ក្នុងដួងកសិណនោះ ដោយទាក់ទងជាមួយនឹងពណ៌ តែគួរធ្វើពណ៌នោះឲ្យប្រព្រឹត្តទៅជាមួយនឹងទីអាស្រ័យ ដូច្នេះ ទើបពោលថា ធ្វើពណ៌ឲ្យស្មើនឹងទីអាស្រ័យដូច្នេះ ។ សេចក្តីថា ពណ៌នោះមានទីអាស្រ័យដោយអាការដែលស្មើគ្នាជាមួយនឹងទីអាស្រ័យ ព្រះយោគីគប្បីធ្វើឲ្យមានគតិស្មើគ្នាជាមួយនឹងបឋវី( ដែលជាទីអាស្រ័យនោះ ) ហើយមនសិការថា **បឋវី** ព្រមជាមួយនឹងពណ៌នោះឯង ។

ពាក្យថា **ក្នុងបញ្ញត្តិធម៌ដោយទាក់ទងនឹងឈ្មោះដែលប្រើច្រើនយ៉ាង** មានន័យថា វោហាររបស់មនុស្សលោកពោលថា “ បឋវី ” ក្នុងសសម្ភារៈបឋវី ព្រោះមានបឋវីធាតុច្រើន គឺ ព្រោះមានបឋវីធាតុច្រើនជាង( ធាតុ ៣ ដ៏សេស ) ដោយកម្លាំងយ៉ាងណា ព្រះយោគីគប្បី តាំងចិត្តទុកក្នុងវោហាររបស់មនុស្សលោកដែល

ជាបញ្ញត្តិធម៌នោះ មនសិការថា “ **បឋវី បឋវី** ” ចុះ ។ ប្រសិនបើព្រះយោគីតាំងចិត្តទុកដោយត្រឹមតែបញ្ញត្តិដែលជាវោហាររបស់មនុស្សលោកបាន គប្បីមានបឋវីដែលគួរមនសិការដោយទាក់ទងនឹងឈ្មោះដទៃក៏បាន ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងថា នឹងមានទោសអ្វីទៅ ដូច្នេះទើបពោលថា “ **មហី មេទនី** ” ជាដើម ។ ក្នុងឈ្មោះទាំងឡាយនោះ ពាក្យថា លោកបំណងឈ្មោះថា សេចក្តីថា លោកត្រូវការនឹងពោលឈ្មោះណា ក៏គួរពោលឈ្មោះនោះ ។ **ឈ្មោះ** នោះឯងឈ្មោះថា ជាឈ្មោះដ៏សមគួរដល់ការចងចាំរបស់លោក គឺ ឈ្មោះណា ជាឈ្មោះដែលសមគួរដោយអំណាចការចងចាំដែលព្រះយោគីនោះធ្លាប់កាន់យក ក្នុងឈ្មោះនោះ រមែងមកដោយភាពជាឈ្មោះច្រើនយ៉ាង ឬដោយភាពស្ទាត់ជំនាញ លោកគួរពោលឈ្មោះនោះ ។ ក៏ពាក្យថា **គួរពោល** លោកពោលទុក ព្រោះធ្វើអធិប្បាយថា ក្នុងការប្រមូលចិត្ត( ចុះក្នុងកម្មដ្ឋាន ) គ្រាដំបូងៗ ព្រះយោគីខ្លះលោកនឹងមានការថ្លែងវាចាផងក៏បាន ឬថាលោកអាចារ្យសំដៅយកឈ្មោះដែលគួរពោលដល់ ។

ម្យ៉ាងទៀត ដើម្បីសម្តែងថា ប្រយោជន៍អ្វីដោយឈ្មោះច្រើន ភាពជាឈ្មោះដែលប្រាកដច្បាស់ប៉ុណ្ណោះ ជាប្រមាណក្នុងរឿងនេះ ទើបលោកពោលថា “ ប៉ុន្តែថា ” ដូច្នេះជាដើម ។ ពាក្យថា **គប្បីបើកភ្នែកមើលតាមកាលដែលគួរ គប្បីបិទភ្នែកនឹកដល់តាមកាលដែលគួរ** មានន័យថា ក្នុងកាលខ្លះគប្បីបើកភ្នែកសម្លឹងមើលដួងបឋវីដោយទាក់ទងនឹងការកាន់យកនិមិត្ត ក្នុងកាលខ្លះក៏បិទភ្នែកនឹកដល់ទៀត ។

សេចក្តីថា លោកសម្លឹងមើលហើយ កាន់យកនិមិត្តបានដោយអាការណា គួរបង្អោននឹកយកនិមិត្តនោះមកដោយអាការនោះទៀត ។ ពាក្យថា **មកកាន់គន្លង** គឺ រមែងចូលដល់ភាពជាអារម្មណ៍នៃជវនទាំងឡាយតាមមនោទ្វារ ។ ពាក្យថា **តស្ស**

បានដល់ ឧគ្គហនិមិត្តនោះ ។ ព្រោះហេតុអ្វីទើបមិនគួរអង្គុយ នៅទីកន្លែងនោះ ? ឆ្លើយថា ប្រសិនបើថា កាលឧគ្គហនិមិត្តកើតឡើងហើយ ព្រះយោគីនៅសម្លឹងមើលដួងបឋវីបម្រើនទៅទៀត ក៏មិនអាចកើតបដិភាគនិមិត្តបាន ។ តែលោកដែលឈរនៅទីជិតក៏អាចនឹងសម្លឹងមើលបានក៏ទេ ។ ព្រោះហេតុនោះ ទើបលោកពោលថា " ចូលទៅកាន់ទីកន្លែងនៅរបស់ខ្លួន "ដូច្នេះជាដើម ។ ការប្រើស្បែកជើងមួយជាន់ក៏ដើម្បីការប្រាសចាកសំឡេង ការប្រើឈើច្រត់ក៏ដើម្បីបន្ទោបង់អន្តរាយ ។

ក្នុងសេចក្ដីថា **សាចេ នស្សតិ អប្បាយេន សុខនិសិន្នេន ភាវេតព្វំ** ។

សមាធិដែលនៅទន់ខ្សោយមែងវិនាសបាន ព្រោះអសប្បាយ ដែលជាហេតុខ្វះប៉ុណ្ណោះ ក្នុងបណ្ដាអសប្បាយទាំងឡាយដែលនឹងពោលដល់ ។ ពាក្យថា **កាន់យកនិមិត្ត** គឺ កាន់យកឧគ្គហនិមិត្តតាមដែលកើតហើយ ។ ពាក្យថា **គប្បីទឹកដល់** អធិប្បាយថា គប្បីទឹកដល់និមិត្ត ឬមានន័យថា គប្បីនាំយកកម្មដ្ឋានមករឿយ ៗ ដោយល្អ ។

ពាក្យថា **គប្បីធ្វើឲ្យការត្រិះរិះកំណត់បាន ឲ្យការត្រិះរិះវិសេសកំណត់បាន** អធិប្បាយថា គប្បីធ្វើកម្មដ្ឋានឲ្យជាវត្ថុ ដែលសម្មាសង្កប្បៈសម្បយុត្តជាមួយនឹងភាវនាចិត្ត ដែលបានឈ្មោះយ៉ាងនេះថា "សេចក្ដីត្រិះរិះ" ព្រោះកិរិយាដែលត្រិះរិះ និងថា " សេចក្ដីត្រិះរិះវិសេស " ព្រោះកិរិយាដែលត្រិះរិះយ៉ាងវិសេស ដែលមានការកំណត់ទូទៅ និងកំណត់ដោយជុំវិញជាកិច្ច ដែលប្រព្រឹត្តទៅជាប់តគ្នា កំណត់បានទូទៅហើយ និង កំណត់បានជុំវិញហើយ មានន័យថា ព្រះយោគីគប្បីធ្វើវិតក្កដែលដល់កម្លាំង គឺ មនសិការឲ្យប្រព្រឹត្តទៅច្រើន ។

ពាក្យថា **កាលព្រះយោគីនោះធ្វើហើយយ៉ាងនេះ** គឺ កាលធ្វើកម្មដ្ឋានឲ្យការ

ត្រិះរិះកំណត់បាន ឲ្យសេចក្តីត្រិះរិះវិសេសកំណត់បានហើយយ៉ាងនេះ ។ បានដល់កាលប្រកបរឿយៗ ដោយប្រការដែលភាវនា នឹងនាំមកនូវគុណវិសេសក្រៃលែងឡើងៗ ។ ពាក្យថា **តាមលំដាប់** គឺ តាមលំដាប់ភាវនា ។ ក្នុងកាលណាឥន្ទ្រិយ៍ទាំងឡាយ មានសទ្ធាជាដើម ជាធម្មជាតិផូរផង់ ក្លៀវក្លា ប្រព្រឹត្តទៅក្នុងកាលនោះ អង្គឈានទាំងឡាយ មានវិតក្កៈជាដើម ដែលជាកាមាវចរនោះឯង បានទទួលការឧបត្ថម្ភពីពលៈ ៧ ដែលប្រកបដោយកម្លាំងដ៏ក្រៃលែង ព្រោះភាវៈដែលឆ្ងាយពីសត្រូវ មានភាពជាអ្នកមិនមានសទ្ធាជាដើម រមែងប្រាកដដ៏ខ្លាំងក្លា ។ ព្រោះហេតុនោះ នីវរណធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម ដែលជាសត្រូវដោយត្រង់របស់អង្គឈានទាំងនោះ ព្រមទាំងបាបធម៌ទាំងឡាយ ដែលតាំងនៅក្នុងចិត្តុប្បាទជាមួយគ្នានឹងនីវរណធម៌នោះ រមែងជាធម្មជាតិមាននៅក្នុងទីឆ្ងាយ អង្គឈានដែលជាឧបចារៈ រមែងប្រារព្ធយកបដិភាគនិមិត្តនោះកើតឡើង ព្រមជាមួយនឹងការកើតឡើងនៃបដិភាគនិមិត្ត ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ នីវរណៈទាំងឡាយក៏ស្ងប់រំងាប់ទៅ ” ដូច្នេះ ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ស្ងប់** គឺ ស្ងប់យ៉ាងល្អ មានន័យថា ចូលទៅស្ងប់រំងាប់បាន ។

( ចប់មហាដីកា )

# ភាពផ្សេងគ្នានៃ
# ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត

តទៅនេះ ជាសេចក្ដីផ្សេងគ្នានៃឧគ្គហនិមិត្តដែលពោលមកមុន និងបដិភាគ-និមិត្តនេះ ក្នុងពាក្យដែលពោលមកនោះ ។

ក្នុង**ឧគ្គហនិមិត្ត** ទោសកសិណនៅប្រាកដ , **បដិភាគនិមិត្ត** ហាក់ដូចជាជ្រែកឧគ្គហនិមិត្តចេញមក ប្រាកដជានិមិត្តដែលបរិសុទ្ធជាងឧគ្គហនិមិត្ត ១០០ ដង ១០០០ ដង ដូចកញ្ចក់ឆ្លុះមុខដែលនាំចេញពីស្រោម ដូចសម្បកស័ង្ខដែលខាត់យ៉ាងល្អហើយ ដូចព្រះចន្ទចេញពីពពក ដូចហ្វូងសត្វកុក ( ស ) ហើរកាត់ពីខាងមុខពពក(ខ្មៅ) តែថា និមិត្តនោះ មិនមែនជាវត្ថុដែលមានពណ៌សណ្ឋាន ព្រោះបើជាវត្ថុមានពណ៌សណ្ឋាន ដូចនោះសោត ក៏គប្បីជាវត្ថុដែលដឹងបានតាមចក្ខុ ជារបស់គ្រោតគ្រាត ស្ទាបអង្អែលបាន ចាត់ចូលក្នុងលក្ខណៈ៣បាន ប៉ុន្តែនេះមិនមែនដូច្នោះ ពិតណាស់ និមិត្តនោះវាជាវត្ថុដែលកើតពីសញ្ញា ( ក្នុងភាវនា ) ត្រឹមតែជាអាការដែលប្រាកដដល់អ្នកបានសមាធិប៉ុណ្ណោះ តាំងពីពេលដែលបដិភាគនិមិត្តនោះកើតឡើងហើយ នីវរណៈទាំងឡាយក៏ទ្រោមចុះទៅ កិលេសទាំងឡាយក៏ស្ងប់រំងាប់ទៅ ចិត្តក៏តាំងមាំដោយឧបចារសមាធិដោយពិត ។

# មហាដីកា

# ភាពផ្សេងគ្នានៃឧគ្គហនិមិត្ត និង បដិភាគនិមិត្ត

បទថា **ឥមស្ស** ប្រែថា ជាមួយបដិភាគនិមិត្ត ។ ស្នាមម្រាមដៃ ស្នាមបាតដៃជាដើម ឈ្មោះថា ទោសនៃកសិណ ។ ដោយឧបមាទាំងឡាយ មានវង់កញ្ចក់ជាដើម លោកសម្ដែងដល់ភាពដែលបដិភាគនិមិត្តបរិសុទ្ធល្អ និង ហួតចត់ជាងឧគ្គហនិមិត្ត ។ បដិភាគនិមិត្តនោះឯង ឈ្មោះថា មិនមានពណ៌ មិនមានសណ្ឋាន ក៏ព្រោះរកសភាពដែលជាបរមត្ថមិនបាន ។ ពាក្យថា **បើមាន** គឺ ជាវត្ថុដែលមានពណ៌ និង សណ្ឋាន ។ ពាក្យថា **ចាត់ចូលក្នុងលក្ខណៈ ៣** គឺ មានលក្ខណៈ ៣ មានឧប្បាទលក្ខណៈជាដើមតទៅ ឬថា ប្រកបដោយលក្ខណៈ ៣ មានភាពជារបស់មិនទៀងជាដើម ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើបដិភាគនិមិត្តនេះមិនជាដូច្នេះ គឺ គ្មានពណ៌ជាដើមសោត នឹងមានភាពជាអារម្មណ៍របស់ឈានបានយ៉ាងណា ដូច្នេះហើយទើបពោលថា " **កេវលំ ហិ** " ដូច្នេះ ជាដើម ។ ពាក្យថា **ដែលកើតពីសញ្ញា** បានដល់ ដែលការនាសញ្ញាធ្វើឲ្យកើត គឺ ត្រឹមតែកើតឡើងហើយពីការនាសញ្ញា ។ ពិតហើយ ធម៌ដែលមិនមែនជាសភាវៈ រមែងមិនមានសមុដ្ឋាន សួម្បីចាកធម៌ណា ៗ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " **មានត្រឹមតែអាការប្រាកដ** " ដូច្នេះ ។

( ចប់ មហាដីកា )

# ភាពផ្សេងគ្នានៃសមាធិ២យ៉ាង

សមាធិមាន **២ យ៉ាង** គឺ **ឧបចារសមាធិ ១ អប្បនាសមាធិ ១** ចិត្តជាសមាធិដោយអាការ២ ក្នុងឧបចារភូមិម្យ៉ាង ក្នុងបដិលាភភូមិម្យ៉ាង ។ ក្នុង ២ ភូមិនោះ ក្នុងឧបចារភូមិ ចិត្តជាសមាធិដោយការលះបង់នីវរណៈ ក្នុងបដិលាភភូមិ ចិត្តជាសមាធិដោយការប្រាកដនៃអង្គ( ឈាន ) ចំណែកប្រការដែលធ្វើឲ្យផ្សេងគ្នានៃសមាធិ២យ៉ាងនោះ គឺ ក្នុងឧបចារៈ អង្គទាំងឡាយនៅមិនទាន់មានកម្លាំង ព្រោះអង្គទាំងឡាយនៅខ្សោយ កាលឧបចារសមាធិកើតឡើងហើយ ចិត្តទើបកាន់យកនិមិត្តជាអារម្មណ៍បានមួយខណៈ ក៏ធ្លាក់ចុះកាន់ភវង្គមួយខណៈ(កើតឡើងធ្លាក់ចុះៗ) ប្រៀបដូចក្មេងតូចដែលរៀនក្រោកឈរក៏ដួលចុះវិញដូច្នោះ ចំណែកក្នុងអប្បនា អង្គទាំងឡាយមានកម្លាំងហើយ ព្រោះអង្គទាំងឡាយមានកម្លាំងហើយ កាលអប្បនា-សមាធិកើតឡើងហើយ ចិត្តកាត់ភវង្គមួយវារៈ ហើយរមែងតាំងនៅ គឺ ប្រព្រឹត្តទៅក្នុងផ្លូវកុសលជវនៃតាមលំដាប់ អស់យប់ និង ថ្ងៃបាន ប្រៀបដូចបុរសដែលមានកម្លាំងក្រោកឡើងអំពីទីអង្គុយ ហើយឈររហូតមួយថ្ងៃក៏បាន ដូច្នោះឯង ។

ក្នុងសមាធិ ២ យ៉ាងនោះ ការធ្វើបដិភាគនិមិត្តដែលកើតឡើងព្រមជាមួយឧបចារសមាធិនោះ ឲ្យកើតឡើងបានជាការលំបាកណាស់ ព្រោះដូច្នោះ បើព្រះ-យោគាវចរធ្វើនិមិត្តនោះឲ្យចម្រើន សម្រេចអប្បនាដោយភ្នែនតែមួយនោះបានសោតនេះជាការល្អ បើមិនអាចទេ ដូច្នេះលោកគប្បីជាអ្នកមិនប្រមាទរក្សានិមិត្តនោះទុកដូចស្ត្រីកែវរក្សាគភ៌ដែលបានពីព្រះបាទចក្រពត្តិដូច្នោះចុះ កាលបើរក្សានិមិត្តទុកបានយ៉ាងនេះ សេចក្តីវិនាសនៃឈានដែលបានពោលហើយ រមែងមិនមាន តែកាលរក្សាមិនបាន ឈានដែលបានហើយ ក៏រមែងវិនាសទៅ ។

# វិធីរក្សានិមិត្ត

*នេះជាវិធីរក្សា ក្នុងការរក្សានិមិត្តនោះ ព្រះយោគាវចរគប្បីវៀរវត្ថុ ៧ គឺ : អាវាស គោចរគ្រាម ការនិយាយឡេះឡោះ បុគ្គល ភោជន រដូវ ឥរិយាបថ ទាំងនេះ ដែលជាអសប្បាយចេញ គប្បីសេពវត្ថុ ៧ នេះ ដែលជាសប្បាយចុះ បើព្រះយោគាវចរណា បដិបត្តិបានយ៉ាងនេះ អប្បនា រមែងនឹងកើតឡើងក្នុងកាលមិនយូរឡើយ ។*

# មហាដីកា

## ភាពផ្សេងគ្នានៃសមាធិ២យ៉ាង

*នីវរណៈដែលស្ងប់រំងាប់ទៅហើយនោះឯង ឈ្មោះថា កិលេសដែលស្ងប់រំងាប់ទៅហើយនោះឯង អធិប្បាយថា ព្រះយោគី មិនគប្បីធ្វើនូវការឧស្សាហៈដើម្បីប្រយោជន៍នោះ ។*

*កាលលោកអាចារ្យពោលថា “ ( ចិត្តរមែងតាំងមាំស្មើ ) **ដោយឧបចារសមាធិ** ” ដូច្នេះ ពាក្យពោល ក៏យកជាការបាន ដោយអត្ថថា សមាធិក្រៅពីឧបចារសមាធិនេះ ក៏មាន ព្រោះហេតុនោះ លោកបំណងសំដែងសមាធិក្រៅពីឧបចារសមាធិនោះ ទើបផ្ដើមពាក្យថា “ ពិតហើយសមាធិមាន ២ យ៉ាង ” ដូច្នេះជាដើម ។ ពាក្យថា **ដោយអាការ ២** គឺ ដោយហេតុ ២ នេះ គឺ ឈានធម៌ទាំងឡាយឆ្ងាយពីធម៌ដែលជាបដិបក្ខ១ ការដល់នូវភាពតាំងមាំ១ ដូច្នេះ ។*

*ឥឡូវនេះ លោកបំណងសម្ដែងហេតុទាំងនោះ ដោយភូមិដែលតាំងចុះជាលំនាំផ្លូវ ទើបពោលថា “ ក្នុងឧបចារភូមិម្យ៉ាង ” ដូច្នេះជាដើម ។*

ពាក្យថា **ក្នុងឧបចារភូមិ** គឺ ក្នុងខណៈដែលតាំងចុះនៃឧបចារៈ ។ សូម្បីក្នុងវេលានោះ អង្គឈានដែលប្រាកដច្បាស់ ដែលដល់ភាពជាមហគ្គតនៅមិនទាន់កើតឡើងក៏ដោយ សូម្បីដូច្នោះ ចិត្តរមែងតាំងមាំល្អបាន ក៏ព្រោះអង្គឈានទាំងនោះគ្របសង្កត់ធម៌ដែលជាបដិបក្ខបាន ។

ព្រោះហេតុនោះ ទើបលោកពោលថា " **ចិត្តរមែងតាំងមាំបាន ដោយការលះនីវរណធម៌** " ដូច្នេះ ។ ពាក្យថា **ក្នុងបដិលាភភូមិ** គឺក្នុងខណៈដែលតាំងចុះនៃការសម្រេចឈាន ។ ពិតណាស់ ក្នុងវេលានោះ ចិត្តរមែងតាំងមាំល្អបានដោយការកើតឡើងនៃឈានធម៌ដែលដល់អប្បនា ។ ព្រោះហេតុនោះ ទើបលោកពោលថា " **ដោយការ ប្រាកដនៃអង្គ** " ដូច្នេះ ។ ភ្ជាប់ ( ពាក្យថា **អង្គបាតុភាវេន** ) ចូលជាមួយនឹង ពាក្យថា **ចិត្តំ សមាហិតំ ហោតិ** ។

ពាក្យថា **មិនមែនជាធម្មជាតិដែលមានកម្លាំង** គឺ មិនមែនមានកម្លាំងដែលកើតហើយ មានន័យថា មិនដល់កម្លាំងនៃភាវនា ។ ពាក្យថា **ចិត្ត** បានដល់ឈានចិត្ត ។ ពាក្យថា **រមែងតាំងនៅបានរហូតមួយយប់មួយថ្ងៃ ឬទាំងយប់ទាំងថ្ងៃ** លោកពោលសំដៅយកវេលាចូលសមាបត្តិ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា សមគួរចម្រើនក្នុងឧបចារភូមិ ទើបពោលថា " ចម្រើននិមិត្ត " ដូច្នេះ ។

ពាក្យថា **សេចក្តីវិនាសនៃឈានដែលបាន** គឺ ការវិនាសនៃឧបចារជ្ឈានដែលបាន ។ បើនិមិត្តនៅមិនទាន់វិនាសទៅ សូម្បីឈានដែលមាននិមិត្តនោះជាអារម្មណ៍ ក៏ឈ្មោះ ថា នៅមិនទាន់វិនាសទៅឡើយ តែបើនិមិត្តវិនាសហើយ ព្រោះគ្មានការរក្សាទុក សូម្បីឈានណាមួយដែលបានហើយ ក៏រមែងវិនាសទៅដែរ ព្រោះមានការប្រព្រឹត្តទៅទាក់ទងជាមួយនឹងនិមិត្តនោះ ។

ព្រោះហេតុនោះ ទើបលោកពោលថា “ កាលគ្មានការរក្សា ” ដូច្នេះជាដើម ។

លោកអាចារ្យពោលថា “ ( និមិត្តដែលកើតឡើងហើយ ) រមែងជាធម្មជាតិតាំងមាំផង ” ដូច្នេះហើយ បំណងសម្តែងអាការដែលតាំងមាំ ទើបពោលថា “ សតិរមែងចូលទៅតាំងទុកបាន ចិត្តរមែងតាំងមាំបាន ” ដូច្នេះ ។ ពិតហើយ និមិត្តតាមដែលបានឈ្មោះថា ជាធម្មជាតិដែលតាំងមាំនិងរក្សាទុកបានល្អ ក៏សម្រាប់ព្រះយោគីដែលធ្វើសតិឲ្យចូលទៅតាំងទុកល្អហើយ បានឯកគ្គតាក្នុងនិមិត្តនោះ ។

ម្យ៉ាងទៀត ក្នុងទីនេះជាការសង្គ្រោះសម្បជញ្ញៈទុកដោយស័ព្ទថា **សតិ** និងជាការសង្គ្រោះ **វីរិយ** ទុកដោយស័ព្ទថា **សមាធិ** ព្រោះមិនមានភាពផ្សេងគ្នា ។

( ចប់មហាដីកា )

## អាវាស

គប្បីវិនិច្ឆ័យក្នុងបទមាតិកាទាំងនោះ ដូច្នេះ កាលព្រះយោគីនោះ នៅក្នុងអាវាសណា និមិត្តដែលមិនទាន់កើតក៏មិនកើតឡើងក្តី ដែលកើតឡើងហើយវិនាសទៅវិញក្តី សតិដែលមិនទាន់តាំងមាំក៏មិនតាំងមាំ ចិត្តដែលមិនទាន់ជាសមាធិក៏មិនជាសមាធិ អាវាសនេះចាត់ថា ជាអសប្បាយ កាលលោកនៅក្នុងអាវាសណា និមិត្តកើត និងគង់វង្ស សតិក៏តាំងមាំ ចិត្តក៏ជាសមាធិ ដូចព្រះបធានិយតិស្សត្ថេរអ្នកគង់នៅក្នុងនាគបព៌ត អាវាសនេះចាត់ថាជា សប្បាយ ព្រោះហេតុនោះ ក្នុងវិហារណា អាវាសមានច្រើនកន្លែង ព្រះយោគាវចរគប្បី ( សាកល្បង ) ការនៅក្នុងអាវាសនោះមួយកន្លែង៣ថ្ងៃ ចិត្តរបស់លោកជាឯកគ្គៈ( មានអារម្មណ៍តែមួយ ) នៅត្រង់អាវាសណា ចូរនៅក្នុងអាវាសនោះចុះ ព្រោះការដែលមានអាវាសជាទីសប្បាយពិតៗ ។ ភិក្ខុ ៥០០ អង្គ ដែលនៅក្នុងល្អាងចូឡនាគក្នុងតម្ពបណ្ណិទ្វីបកាន់យកកម្មដ្ឋាន ( បំពេញ ) ក្នុងគុហាចូឡនាគនោះឯង បានសម្រេចព្រះអរហត្តទាំងអស់ ចំណែកព្រះអរិយបុគ្គលថ្នាក់ទាប មានព្រះសោតាបន្នជាដើម ហើយលោកដែលបានអរិយភូមិក្នុងទីដទៃហើយ មកសម្រេចព្រះអរហត្តក្នុងល្អាងចូឡនាគនោះ គណនាមិនបាន សូម្បីក្នុងអាវាសសប្បាយដទៃៗ ដូចជាចិត្តបព៌តវិហារ ក៏ដូច្នោះ ។

## គោចរគ្រាម

ចំណែកគោចរគ្រាម គប្បីជ្រាបដូច្នេះ គោចរគ្រាមណាមាននៅក្នុងទីមិនឆ្ងាយពេក មិនជិតពេក ក្នុងចម្ងាយប្រមាណកន្លះកោសៈ(១.០០០ ធ្នូរធ្នូ) តែសេនាសនៈ

នៅទិសខាងជើង ឬនៅទិសខាងត្បូង ជាកន្លែងសម្បូរភិក្ខា រកបានដោយងាយ គោចរគ្រាមនោះចាត់ជា សប្បាយ ផ្ទុយគ្នាចាត់ជា អសប្បាយ ។

## ការនិយាយឡេះឡោះ

បទថា **ការនិយាយឡេះឡោះ** មានន័យថា ពាក្យពេចន៍ដែលរាប់ចូលក្នុង តិរច្ឆានកថា ៣២ ចាត់ជាអសប្បាយ ព្រោះជាការប្រព្រឹត្តទៅដើម្បីសេចក្តីអន្តរធាន នៃនិមិត្តរបស់លោក ពាក្យពេចន៍ដែលអាស្រ័យកថាវត្ថុ១០ចាត់ជាសប្បាយ សូម្បី ពាក្យពេចន៍អាស្រ័យកថាវត្ថុនោះឯង ក៏គប្បីនិយាយតែល្មមប្រមាណ ។

## បុគ្គល

សូម្បីបុគ្គលដែលជាអ្នកមិននិយាយតិរច្ឆានកថា ដល់ព្រមដោយសីលាទិគុណ ដែលព្រះយោគាវចរបានអាស្រ័យហើយ ជាហេតុឲ្យចិត្តដែលនៅមិនទាន់ជាសមាធិ រមែងជាសមាធិបាន ចិត្តដែលមានសមាធិហើយនឹងកាន់តែមាំទាំឡើង ដូច្នេះ ជា សប្បាយ ចំណែកអ្នកច្រើនទៅដោយការធ្វើកាយឲ្យរឹងមាំ ច្រើននិយាយតិរច្ឆាន-កថា ជាអសប្បាយ ព្រោះថា គេមានតែធ្វើអ្នកឲ្យសៅហ្មង ដូចទឹកកក់ធ្វើទឹកថ្លាឲ្យ ល្អក់ទៅដូច្នោះ ហើយព្រោះអាស្រ័យបុគ្គលបែបនោះ សមាបត្តិរមែងវិនាស ដូច សមាបត្តិរបស់ភិក្ខុកំលោះដែលរស់នៅក្នុងកោដិបព៌ត វិនាសព្រោះអាស្រ័យបុគ្គល បែបនោះ នឹងចាំបាច់ពោលថ្វីដល់និមិត្តនោះ ។

## ភោជននិងរដូវ

ចំណែកភោជន សម្រាប់បុគ្គលខ្លះ ចូលចិត្តរសផ្អែម បុគ្គលខ្លះចូលចិត្តរស ជូរ ជាសប្បាយ សូម្បីរដូវ បុគ្គលខ្លះក៏ចូលចិត្តត្រជាក់ បុគ្គលខ្លះក៏ចូលចិត្តក្តៅ ជា

សប្បាយ ព្រោះដូច្នោះ កាលព្រះយោគាវចរ សេពភោជនណាក្តី វដ្តវណាក្តី សេចក្តីសុខរមែងកើតមាន ( ចិត្តរបស់លោក )ដែលនៅមិនទាន់ជាសមាធិ រមែងជាសមាធិ ឬថាចិត្តដែលមានសមាធិហើយ រមែងតាំងមាំក្រៃលែងឡើងក្តី ភោជននោះ និងវដ្តវនោះចាត់ជាសប្បាយ ភោជនក្រៅពីនេះ និង វដ្តវក្រៅពីនេះចាត់ជាអសប្បាយ ។

## ឥរិយាបថ

ក្នុងឥរិយាបថទាំងឡាយ បុគ្គលខ្លះចូលចិត្តចង្ក្រមជាសប្បាយ បុគ្គលខ្លះចូលចិត្តដេក ឈរ អង្គុយ យ៉ាងណាមួយជាសប្បាយ ព្រោះដូច្នោះ គប្បីសាកល្បងមើល ( ត្រឹម ) ៣ ថ្ងៃ ដូចសាកល្បងអាវាស( ដែលពោលហើយ )នោះ ក្នុងឥរិយាបថណា ចិត្ត( របស់ព្រះយោគាវចរ ) ដែលនៅមិនទាន់មានសមាធិ មានសមាធិកើតឡើងក្តី ចិត្តដែលមានសមាធិហើយកាន់តែក្រៃលែងឡើង ឥរិយាបថនោះចាត់ជាសប្បាយ ឥរិយាបថក្រៅពីនេះ ( ដែលចិត្តមិនមានសមាធិ ) រាប់ជាអសប្បាយ ។

ព្រះយោគាវចរគប្បីវៀរវត្ថុ ៧ នេះ ដែលជាអសប្បាយ ហើយសេពវត្ថុ ៧ នោះដែលជាសប្បាយ ដូច្នេះចុះ កាលបដិបត្តិយ៉ាងនេះ មានការសេពក្នុងនិមិត្តច្រើន អប្បនានឹងកើតមានសម្រាប់បុគ្គលខ្លះដោយកាលមិនយូរឡើយ តែបើបុគ្គលណា សូម្បីបដិបត្តិយ៉ាងនោះ អប្បនាក៏មិនកើត អ្នកនោះគប្បីធ្វើអប្បនាកោសល្យ ១០ ប្រការឲ្យដល់ព្រមចុះ ។

# មហាដីកា

## ពណ៌នា សប្បាយ ៧

បទថា **តត្ថ** ប្រែថា ក្នុងអាវាសទាំងនោះ ។ ពាក្យថា **មួយកន្លែង៣ថ្ងៃ** គឺ ក្នុងអាវាសតែមួយកន្លែង នៅកន្លែងនីមួយៗ៣ថ្ងៃ ដោយកំណត់ដល់ការនៅក្នុងស្ថានទីដែលបានអាស្រ័យនៅកន្លែងនីមួយៗ ។ ពាក្យថា **ផ្លូវទិសខាងជើងក៏ដោយ ទិសខាងត្បូងក៏ដោយ** លោកពោលទុក ដើម្បីប្រយោជន៍ដល់ការការពារភាវៈដែលបែរមុខត្រង់ព្រះអាទិត្យ ក្នុងវេលាទៅនិងមកនោះឯង ។ ចម្ងាយផ្លូវប្រមាណ ១.០០០ ជួរធ្នូ ឈ្មោះថា កន្ទះកោសៈ ។ ពាក្យថា **តិរច្ឆានកថា៣២ប្រការ** លោកពោលសំដៅយកកថាពោលដោយរឿងព្រះរាជាជាដើម ។ ក៏កថាពោលដោយរឿងព្រៃ ភ្នំ ទន្លេ និង កោះ សូម្បីថា មិនបានពោលមក ដោយមានការបញ្ជាក់ទុកក្នុងព្រះបាលីនោះ លោកក៏សង្គ្រោះទុកដោយ **ឥតិ** សព្ទ ពោលថាជា " តិរច្ឆានកថា៣២ប្រការ " ព្រោះភាពដែល ហាមឃាត់ការទៅកាន់សួគ៌ និង ការរួចផុត ។

ពាក្យថា **ការពោលដោយកថាវត្ថុ ១០** មានន័យថា វត្ថុទាំងនេះគឺ " ការប្រាថ្នាតិច សេចក្ដីសន្ដោស ភាពស្ងប់ស្ងាត់ ការមិនច្រឡូកច្រឡំ ការប្រារព្ធសេចក្ដីព្យាយាម សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ " ដូច្នេះ ឈ្មោះថា វត្ថុនៃកថាពោលដោយបុគ្គលប្រាថ្នាតិចជាដើម ពាក្យពោលដែលអាស្រ័យ កថាវត្ថុទាំងនោះចាត់ជាសប្បាយ ។ ពាក្យថា **បុគ្គលមិនពោលតិរច្ឆានកថា** គឺ មិនមែនជាអ្នកពោលតិរច្ឆានកថា អធិប្បាយថា មានតែពាក្យដែលជាសត្រូវដល់តិរច្ឆានកថា គឺ ប្រកបដោយធម៌ទាក់ទងនឹងកម្មដ្ឋានប៉ុណ្ណោះ ។ ពាក្យថា **ដល់ព្រមដោយគុណមានសីល សមាធិជាដើម** គឺ ដល់ព្រមដោយគុណមាន សីល សមាធិ ជាដើម ។

ពិតហើយ បុគ្គលណាជាអ្នកប្រកបដោយសមាធិកម្មដ្ឋាន ឬថាសម្រេចត្រើយនៃសមាធិកម្មដ្ឋាន បុគ្គលនោះឈ្មោះថា ជាសប្បាយដល់ព្រះយោគីនោះៗ ព្រោះហេតុនោះទើបលោកពោលថា “ ជាបុគ្គលដែលលោកអាស្រ័យហើយ ”ដូច្នេះជាដើម ។

ពាក្យថា **បុគ្គលច្រើនដោយការធ្វើកាយឲ្យរឹងមាំ** គឺ ជាអ្នកខ្វល់ខ្វាយក្នុងការទំនុកបម្រុងរាងកាយឲ្យឆ្អែតស្កប់ស្កល់ បានដល់ បុគ្គលដែលទ្រង់ត្រាស់ទុកថា “ **ជាអ្នកបរិភោគតាមត្រូវការរហូតពេញពោះ ហើយប្រកបរឿយៗ នូវសុខក្នុងការដេក សុខក្នុងការពត់ខ្លួន សុខក្នុងការដេកលក់** ” ដូច្នេះ ។

ភោជនសម្រាប់ការបរិភោគនៃសត្វទាំងឡាយ រមែងទាក់ទងជាមួយនឹងរសផ្អែម និងរសជូរដោយច្រើន ព្រោះប្រាកដថា មានយ៉ាងនោះក្នុងវត្ថុទាំងឡាយ មានទឹកដោះថ្លាជាដើម ។ ចំណែករសហឹរជាដើម ជាគ្រឿងផ្សំតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ ព្រះយោគីខ្លះមានភោជនដែលមានរសផ្អែមជាសប្បាយ ព្រះយោគីខ្លះមានភោជនដែលមានរសជូរជាសប្បាយ ” ដូច្នេះ ។

ឈ្មោះថា **ក្នុងឥរិយាបថណា** គឺ ក្នុងឥរិយាបថដែលឈប់នៅស្ងៀម ឬដែលកំពុងប្រព្រឹត្តទៅ ឬដល់ព្រះយោគីដែលប្រព្រឹត្តទៅក្នុងឥរិយាបថណាមួយ ។

ពាក្យថា **អ្នកច្រើនដោយការសេពនិមិត្ត** គឺ អ្នកច្រើនដោយការសេពក្នុងនិមិត្ត បានដល់ ការសេពច្រើននូវភាវនា មនសិការក្នុងបដិភាគនិមិត្តដែលជាអារម្មណ៍ ឬថាអ្នកច្រើនដោយការសេពនូវនិមិត្ត ដោយទាក់ទងនឹងគោចរអាសេវនៈ ( សេពដោយធ្វើឲ្យជាអារម្មណ៍ )ៗ ពិតហើយ ភាវនាអាសេវនៈ( ការសេព គឺចម្រើនឲ្យច្រើនៗ ) គប្បីប្រាថ្នា បានដល់ ព្រះយោគីចម្រើនហើយដោយនិមិត្តណា សូម្បីគោចរអាសេវនៈ ក៏គប្បីប្រាថ្នាបានដោយនិមិត្តនោះ ដូច្នោះឯង ៗ ( **ចប់មហាដីកា** )

## ពណ៌នា អប្បនាកោសល្ល ១០ យ៉ាង

នេះជានិ័យក្នុងអប្បនាកោសល្លនោះ ព្រះយោគាវចរ គប្បីប្រាថ្នាអប្បនា-កោសល្លដោយអាការ ១០ គឺ :

១ . ធ្វើវត្ថុឲ្យស្អាត ។

២ . ធ្វើឥន្ទ្រិយឲ្យដល់នូវភាពស្មើគ្នា ។

៣ . ឆ្លាតក្នុងនិមិត្ត ។

៤ . លើកចិត្តក្នុងសម័យដែលគួរលើក ។

៥ . គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់ ។

៦ . ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួររីករាយ ។

៧ . សម្លឹងមើលចិត្តដែលព្រងើយៗ ក្នុងសម័យដែលចិត្តគួរសម្លឹងព្រងើយ ៗ ។

៨ . ជៀសវាងបុគ្គលដែលមិនមានចិត្តជាសមាធិ ។

៩ . សេពគប់តែបុគ្គលដែលមានចិត្តជាសមាធិ ។

១០ . បង្អោនចិត្តទៅក្នុងសមាធិនោះៗ ។

## អធិប្បាយ មាតិកានៃអប្បនាកោសល្ល

### ១. ការធ្វើវត្ថុឲ្យស្អាត

ក្នុងអាការ១០នោះ ការធ្វើ គឺ ការសម្អាតវត្ថុទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅ ឈ្មោះថា ការធ្វើវត្ថុឲ្យស្អាត កាលណាសក់ ក្រចក រោម របស់ព្រះ-យោគាវចរនោះវែង ឬថារាងកាយក្រាស់ដោយញើសក្អែលក្តី កាលនោះឈ្មោះ ថា វត្ថុខាងក្នុងមិនល្អស្អាត គឺ មិនបរិសុទ្ធ ចំណែកកាលណាចីវររបស់លោកចាស់

ដាច់ដាច មានក្លិនអាក្រក់ ឬថា សេទាសនៈរខេករខាកក្តី កាលនោះ ឈ្មោះថា វត្ថុខាងក្រៅមិនបរិសុទ្ធ គឺ មិនស្អាត ក៏កាលវត្ថុខាងក្នុង និងខាងក្រៅ មិនបរិសុទ្ធ សូម្បីញាណក្នុងចិត្តចេតសិកទាំងឡាយដែលកើតឡើង ក៏រមែងមិនបរិសុទ្ធផងដែរ ដូចពន្លឺនៃអណ្តាតប្រទីបដែលអាស្រ័យចង្កៀង ប្រេងះនិងប្រេងមិនស្អាត ពន្លឺក៏មិនបរិសុទ្ធផងដែរ ។ កាលបើព្រះយោគាវចរពិចារណា សង្ខារដោយញាណដែលមិនបរិសុទ្ធនោះ សង្ខារទាំងឡាយក៏មិនប្រាកដច្បាស់ សូម្បីប្រកបការបដិបត្តិកម្មដ្ឋាន កម្មដ្ឋានក៏មិនអាចរីកចម្រើនបានដែរ ប៉ុន្តែបើវត្ថុខាងក្នុង និងខាងក្រៅបរិសុទ្ធ សូម្បីញាណក្នុងចេតសិកទាំងឡាយ ដែលកើតឡើងក៏រមែងបរិសុទ្ធផងដែរ ដូចពន្លឺនៃអណ្តាតប្រទីបដែលអាស្រ័យចង្កៀង ប្រេងះនិងប្រេងដែលស្អាត ភ្លឺឡើងក៏បរិសុទ្ធផង ដូច្នោះហើយកាលព្រះយោគាវចរ ពិចារណាសង្ខារដោយញាណដែលបរិសុទ្ធនោះ សង្ខារទាំងឡាយក៏ប្រាកដច្បាស់ សូម្បីការបដិបត្តិកម្មដ្ឋាន កម្មដ្ឋាននឹងដល់នូវការរីកចម្រើនបាន ។

## ២.ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា

ការធ្វើឥន្ទ្រិយទាំងឡាយឲ្យមានភាពស្មើគ្នា មានសទ្ធាជាដើម ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ព្រោះបើសទ្ធិន្ទ្រិយរបស់លោកខ្លាំង ឥន្ទ្រិយក្រៅពីនេះទន់ខ្សោយសោត ពេលនោះវីរិយិន្ទ្រិយ ក៏មិនអាចធ្វើបគ្គហកិច្ច( កិច្ច គឺការផ្គងចិត្ត ) សតិន្ទ្រិយ មិនអាចធ្វើឧបដ្ឋានកិច្ច( កិច្ច គឺ ការមិនភ្លេច ) សមាធិន្ទ្រិយមិនអាចធ្វើអវិក្ខេបកិច្ច ( កិច្ច គឺធ្វើចិត្តមិនឲ្យរាយមាយ ) បញ្ញិន្ទ្រិយមិនអាចធ្វើទស្សនកិច្ច ( កិច្ច គឺការឃើញតាមសេចក្តីពិត ) ព្រោះហេតុនោះ សទ្ធិន្ទ្រិយខ្លាំងនោះ ព្រះ-យោគាវចរត្រូវធ្វើឲ្យថយចុះ ដោយពិចារណានូវ សភាវៈនៃធម៌ ឬដោយមិនធ្វើទុក

ក្នុងចិត្ត ដូចកាលដែលធ្វើសទ្ធិន្ទ្រិយឲ្យមានកម្លាំងនោះ ពិតហើយ រឿងព្រះវក្កលិត្ថេរជានិទស្សនៈក្នុងសេចក្តីនេះបាន តែបើវីរិយិន្ទ្រិយខ្លាំងក្លាសោត ពេលនោះសទ្ធិន្ទ្រិយក៏មិនអាចធ្វើអធិមោក្ខកិច្ច( កិច្ច គឺការបង្អោនចិត្តជឿ ) ឥន្ទ្រិយក្រៅពីនេះក៏មិនអាចធ្វើកិច្ចរបស់ខ្លួនបាន ព្រោះដូច្នោះ វីរិយិន្ទ្រិយដែលខ្លាំងក្លានោះព្រះយោគីចាំបាច់ត្រូវបន្ថយចុះ ដោយចម្រើនសម្ពោជ្ឈង្គៈ មានបស្សទ្ធិជាដើម សូម្បីក្នុងសេចក្តីនេះ ក៏គប្បីសម្តែងរឿងព្រះសោណត្ថេរ(ជានិទស្សនៈ)បាន កាលដែលភាពខ្លាំងក្លានៃឥន្ទ្រិយណាមួយមានហើយ ឥន្ទ្រិយក្រៅពីនោះ មិនអាចធ្វើកិច្ចរបស់ខ្លួនបាន បណ្ឌិតគប្បីជ្រាបក្នុងឥន្ទ្រិយដ៏សេស ( គឺ សតិ សមាធិ បញ្ញា ) តាមន័យដែលបានពោលហើយនោះចុះ ។

## ធ្វើឥន្ទ្រិយ ២ គូ ឲ្យស្មើគ្នា

តែដោយពិសេស( មិនទូទៅ ) ក្នុងឥន្ទ្រិយ៥នោះ បណ្ឌិតទាំងឡាយសរសើរសេចក្តីស្មើគ្នានៃ សទ្ធា និងបញ្ញា , សមាធិ និងវីរិយៈ ព្រោះថា បុគ្គលអ្នកមានសទ្ធាខ្លាំងក្លា តែបញ្ញាទន់ខ្សោយ រមែងជាអ្នកជ្រះថ្លាក្នុងទីដែលមិនមែនជាវត្ថុ ( នៃសេចក្តីជ្រះថ្លា ) បុគ្គលដែលមានបញ្ញាខ្លាំងក្លា តែសទ្ធាទន់ខ្សោយ រមែងទៅជាមនុស្សអួតអាង ជាបុគ្គលកែមិនបាន ដូចរោគដែលកើតពីថ្នាំ ព្យាបាលមិនបាន ដូច្នោះ បើធម៌ទាំងពីរស្មើគ្នា បុគ្គលទើបជ្រះថ្លានឹងវត្ថុ ( នៃសេចក្តីជ្រះថ្លាពិត ) , កោសជ្ជៈរមែងគ្របសង្កត់បុគ្គលដែលមានសមាធិខ្លាំងក្លា តែវីរិយៈទន់ខ្សោយ ព្រោះសមាធិជាបក្ខពួកកោសជ្ជៈ ឧទ្ធច្ចៈរមែងគ្របសង្កត់ បុគ្គលដែលមានវីរិយៈខ្លាំងក្លា តែសមាធិទន់ខ្សោយ ព្រោះវីរិយៈជាបក្ខពួកឧទ្ធច្ចៈ តែសមាធិដែលមានវីរិយៈប្រកបជាមួយហើយ មិនធ្លាក់ទៅក្នុងកោសជ្ជៈ វីរិយៈដែលមានសមាធិប្រកបជាមួយក៏មិន

ធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះដូច្នោះ ឥន្ទ្រិយទាំង២គូនោះ ព្រះយោគីត្រូវធ្វើឲ្យស្មើគ្នា ។ ដោយថា អប្បនានឹងមានបានក៏ព្រោះភាពស្មើគ្នានៃឥន្ទ្រិយទាំង ២ ។

## ឥន្ទ្រិយនីមួយៗ មានកម្លាំងគួរដល់កម្មិកៈផ្សេងៗ

ន័យម្យ៉ាងទៀត សទ្ធាសូម្បីមានកម្លាំង ក៏គួរសម្រាប់សមាធិកម្មិកៈ ( អ្នកបំពេញសមថកម្មដ្ឋាន ) កាលបើសទ្ធាមានកម្លាំងយ៉ាងនោះ លោកជឿមាំទៅ ទើបសម្រេចអប្បនាបាន ក្នុងសមាធិនិងបញ្ញានោះ ឯកគ្គតាមានកម្លាំងរមែងគួរសម្រាប់សមាធិកម្មិកៈ ព្រោះកាលបើឯកគ្គតាមានកម្លាំងយ៉ាងនោះ លោករមែងសម្រេចអប្បនាបាន , បញ្ញាមានកម្លាំងរមែងគួរដល់វិបស្សនាកម្មិកៈ ( អ្នកបំពេញវិបស្សនាកម្មដ្ឋាន ) ព្រោះកាលបើបញ្ញាមានកម្លាំងយ៉ាងនោះ លោករមែងសម្រេចនូវលក្ខណៈបដិវេធ ( ឃើញច្បាស់ត្រៃលក្ខណ៍ )បាន តែសូម្បី សមាធិ និងបញ្ញា ទាំងពីរស្មើគ្នា អប្បនាក៏គង់មានបាន ។

## សតិ ជាសព្វត្ថិកា

ចំណែកសតិមានកម្លាំងរមែងគួរក្នុងទីទាំងពួង ព្រោះសតិរក្សាចិត្តឲ្យផុតពីការធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះអំណាចនៃសទ្ធា វីរិយៈ និងបញ្ញា ដែលជាបក្ខពួកឧទ្ធច្ចៈ និង រក្សាចិត្តឲ្យផុតពីការធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាបក្ខពួកកោសជ្ជៈ ព្រោះហេតុនោះ សតិនោះត្រូវចាំបាច់មានក្នុងទីទាំងពួង ដូចអំបិលជាវត្ថុដែលត្រូវមានក្នុងម្ហូបទាំងពួង ហើយដូចសព្វកម្មិកអមាត្យ (អ្នកជំនាញក្នុងការងារទាំងពួង) ជាអ្នកត្រូវមានមុខសព្វរាជកិច្ច ដូច្នោះ ព្រោះដូច្នោះ ទើបព្រះអដ្ឋកថាពោលទុកថា " ក៏សតិ ព្រះមានព្រះភាគ ត្រាស់ទុកថា ជាគុណជាតិចាំបាច់ប្រាថ្នាក្នុងទីទាំងពួង

ព្រោះហេតុអ្វី ព្រោះចិត្តមានសតិជាទីអាស្រ័យទៅ និង សតិមានការរក្សាបាន ជាអាការប្រាកដ ការលើក និង ការគ្របសង្កត់ចិត្ត វៀរសតិចេញ មិនបាន ។

## ៣.ការឆ្លាតក្នុងនិមិត្ត

ការឆ្លាតក្នុងការធ្វើនិមិត្តនៃចិត្តេកគ្គតា មានបឋវីកសិណជាដើម ដែលនៅមិនទាន់បានធ្វើ ការឆ្លាតក្នុងការញ៉ាំងនិមិត្តដែលធ្វើហើយឲ្យចម្រើន និង ការឆ្លាតក្នុងការរក្សានិមិត្ត ដែលបានហើយដោយភាវនា ឈ្មោះថា **ការឆ្លាតក្នុងនិមិត្ត** ក្នុងទីនេះលោកបំណងយកការឆ្លាតក្នុងការរក្សានោះឯង ។

## ៤.លើកចិត្តក្នុងសម័យដែលគួរលើក

សួរថា ព្រះយោគាវចរ លើកចិត្តក្នុងសម័យដែលគួរលើកយ៉ាងណា ?

ឆ្លើយថា ក្នុងកាលណាចិត្តរបស់លោករួញរា ព្រោះហេតុ មានការព្យាយាមតិចជាដើម ក្នុងកាលនោះកុំចម្រើនពោជ្ឈង្គៈ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គៈ ជាដើម ហើយចម្រើនសម្ពោជ្ឈង្គៈ ៣ មានធម្មវិចយសម្ពោជ្ឈង្គៈជាដើម ពិតហើយសេចក្តីនេះ ព្រះមានព្រះភាគក៏បានត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើថាបុរសប្រាថ្នានឹងបង្កាត់ភ្លើងតូចឲ្យឆេះឡើង គេដាក់ស្មៅស្រស់ចុះទៅ អាចម៍គោស្រស់ចូលទៅ ដាក់អុសសើមចូលទៅ ឲ្យខ្យល់លាយដោយទឹកចុះចូលទៅ និងយកលំអងដីរោយចុះទៅលើភ្លើងនោះ ម្នាលភិក្ខុទាំងឡាយ បុរសនោះនឹងអាចបង្កាត់ភ្លើងតូចនោះឲ្យឆេះឡើងបានឬទេហ្ន ” ភិក្ខុទាំងឡាយក្រាបទូលថា “ករុណាព្រះអង្គ សេចក្តីនោះមិនដូច្នោះទេ” ទ្រង់ត្រាស់តទៅទៀតថា “ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាចិត្តរួញរាហើយ ក្នុងសម័យនោះ មិនមែនជាកាល

ដែលត្រូវចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ មិនមែនជាកាលគួរចម្រើនសមាធិសម្ពោជ្ឈង្គៈ មិនមែនជាកាលគួរចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈទេ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តរួញរា ចិត្តរួញរានោះ លំបាកនឹងធ្វើឲ្យកើតឡើងបានដោយធម៌នោះ ម្នាលភិក្ខុទាំងឡាយ ឯក្នុងសម័យណាចិត្តរួញរាហើយ ក្នុងសម័យនោះ គប្បីចម្រើននូវធម្មវិចយសម្ពោជ្ឈង្គៈ ជាកាលចម្រើននូវវីរិយសម្ពោជ្ឈង្គៈ ជាកាលចម្រើននូវបីតិសម្ពោជ្ឈង្គៈ នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តរួញរាហើយ , ចិត្តរួញរា ព្រះយោគាវចរអាចធ្វើឲ្យឧស្សាហ៍ ឡើងវិញបានដោយងាយ ដោយធម៌ទាំងនោះ ប្រៀបដូចបុរសប្រាថ្នានឹងបង្កាត់ភ្លើងឲ្យឆេះឡើង គេដាក់ស្មៅស្ងួតចូលទៅ ដាក់លាមកគោស្ងួតៗចូលទៅ ដាក់អុសស្ងួតៗចូលទៅ ផ្លុំខ្យល់សុទ្ធចូលទៅ និងមិនយកលំអងដីទៅរោយលើភ្លើង ម្នាលភិក្ខុទាំងឡាយ បុរសនោះអាចបង្កាត់ភ្លើងនោះឲ្យឆេះឡើងបានឬទេ ? ” ភិក្ខុទាំងឡាយក្រាបទូលថា “ ករុណាព្រះអង្គបាន ” ដូច្នេះ ។

## អាហាររបស់ធម្មវិចយសម្ពោជ្ឈង្គៈ

ក្នុងអធិការនេះ គប្បីជ្រាបនូវការចម្រើន សម្ពោជ្ឈង្គៈ ៣ មានធម្មវិចយ-សម្ពោជ្ឈង្គៈ ជាដើម ដោយទាក់ទងជាមួយធម៌ដែលជាអាហាររបស់ខ្លួន ពិតហើយ សេចក្តីនេះ ព្រះមានព្រះភាគបានត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង-ឡាយដែលគ្រោតគ្រាត និង ប្រណីតមានហើយ ធម៌ទាំងឡាយដែលមានចំណែកប្រៀបធៀបដោយ ស និង ខ្មៅ មានហើយ ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងឡាយនេះ ជាអាហារដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ដែល

នៅមិនទាន់កើត ឲ្យកើតឡើងខ្វះ ដើម្បីកិរិយាភាពពេញលេញគ្រប់គ្រាន់នៃធម្មវិចយសម្ពោជ្ឈង្គៈដែលកើតឡើងហើយខ្វះ ” ដូច្នេះ ។

## អាហាររបស់វីរិយសម្ពោជ្ឈង្គៈ

ន័យដូចគ្នា ទ្រង់ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ **អារម្ភធាតុ** ( ធាតុ គឺ ការផ្ដើមសេចក្ដីព្យាយាម ) មានហើយ , **និក្កមធាតុ** ( ធាតុ គឺ ការចុះដៃធ្វើ ) មានហើយ , **បរក្កមធាតុ** ( ធាតុ គឺ ការព្យាយាមមិនធូរថយ ) មានហើយ ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងធាតុទាំងនោះ នេះជាអាហារដើម្បីការកើតឡើងនៃវីរិយសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើតឡើងខ្វះ ដើម្បីភាពរីកចម្រើននៃវីរិយសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយខ្វះ ” ដូច្នេះ ។

## អាហាររបស់បីតិសម្ពោជ្ឈង្គៈ

ន័យដូចគ្នា ទ្រង់ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានហើយ ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហារ ដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈដែលនៅមិនទាន់កើតខ្វះ ដើម្បីការរីកចម្រើនពេញលេញនៃបីតិសម្ពោជ្ឈង្គៈដែលកើតឡើងហើយខ្វះ ” ។

## កែអត្ថ ចាប់បទខ្វះ

មនសិការដែលប្រព្រឹត្តទៅ ដោយការចាក់ធ្លុះនូវសការលក្ខណៈ និងសាមញ្ញលក្ខណៈ ឈ្មោះថា យោនិសោមនសិការក្នុងធម៌ទាំងឡាយ មានធម៌ជាកុសលជាដើម ក្នុងព្រះបាលីនោះ មនសិការដែលប្រព្រឹត្តទៅដោយការញ៉ាំងធាតុ

ទាំងឡាយ មានអារម្ភធាតុជាដើមឲ្យកើតឡើង ឈ្មោះថា យោនិសោមនសិការក្នុងអារម្ភធាតុ ជាដើម ក្នុងធាតុទាំង៣នោះ សេចក្ដីព្យាយាមដំបូងហៅថា **អារម្ភធាតុ** សេចក្ដីព្យាយាមដែលមានកម្លាំងជាងនោះ ព្រោះចេញចាកកោសជ្ជៈបាន ហៅថា **និក្កមធាតុ** សេចក្ដីព្យាយាមមានកម្លាំងជាងនិក្កមធាតុនោះ ព្រោះឈានឡើងកាន់ឋានៈក្រៃលែងតទៅ ហៅថា **បរក្កមធាតុ** ក៏ពាក្យថា " ធម៌ទាំងឡាយដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ " នោះ ជាឈ្មោះនៃបីតិនោះឯង មនសិការដែលញ៉ាំងបីតិនោះ ឲ្យកើតឡើងនោះឯង ឈ្មោះថា **យោនិសោមនសិការ** ។

## ការកើតនៃធម្មវិចយៈ វីរិយៈ បីតិ

## ( ន័យម្យ៉ាងទៀត )

ម្យ៉ាងទៀត ធម៌ ៧ ប្រការ ជាផ្លូវកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ គឺ :-

| | | |
|---|---|---|
| ១ . | **បរិបុច្ឆកតា** | ភាពជាអ្នកសាកសួរ ។ |
| ២ . | **វត្ថុវិសទកិរិយតា** | ការធ្វើវត្ថុឲ្យស្អាត ។ |
| ៣ . | **ឥន្ទ្រិយសមត្តបដិបាទនា** | ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។ |
| ៤ . | **ទុប្បញ្ញាបុគ្គលបរិវជ្ជនា** | ការវៀរបុគ្គលអប្បឥតបញ្ញា ។ |
| ៥ . | **បញ្ញវន្តបុគ្គលសេវនា** | សេពគប់បុគ្គលអ្នកមានបញ្ញា ។ |
| ៦ . | **គម្ភីរញ្ញាណចរិយបច្ចវេក្ខណា** | ពិចារណា បាប: ដែលត្រូវប្រើបញ្ញាដ៏ជ្រាលជ្រៅ ។ |
| ៧ . | **តទធិមុត្តតា** | ការបង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ ។ |

## ធម៌ ១១ ប្រការ ជាផ្លូវកើតឡើងនៃវីរិយសម្ពោជ្ឈង្គៈ គឺ :

១ . **អបាយាទិភយប្បច្ចវេក្ខណតា** ការពិចារណាឃើញភ័យ មានអបាយជាដើម ។

២ . **វីរិយាយត្ត** ... វិសេសាធិគមានិសំសទស្សិតា ភាពជាអ្នកមានប្រក្រតីឃើញអានិសង្ស គឺ ការសម្រេចគុណវិសេសដែលជាលោកិយ និងលោកុត្តរដែលទាក់ទងជាមួយនឹងវីរិយៈ ។

៣ . **គមនវីថិបច្ចវេក្ខណតា** ការពិចារណាឃើញវិថីធ្វើដំណើរដោយន័យដូច្នេះថា “ មគ្គដែលព្រះមានព្រះភាគ ព្រះបច្ចេកពុទ្ធនិងព្រះមហាសាវកទាំងឡាយធ្វើដំណើរទៅហើយ យើងត្រូវធ្វើដំណើរទៅ តែថាមគ្គនោះបុគ្គលខ្ជិលច្រអូសមិនអាចធ្វើដំណើរទៅបានឡើយ ” ។

៤ . **បិណ្ឌាបចាយនតា** ធ្វើសេចក្តីកោតក្រែងក្នុងការនិមន្តបិណ្ឌបាត ដោយធ្វើឲ្យមានផលច្រើនដល់ទាយកទាំងឡាយ ។

៥ . **សត្ថុមហត្តបច្ចវេក្ខណតា** ការពិចារណាឃើញភាពជាធំនៃព្រះសាស្តាដោយន័យថា “ ព្រះសាស្តារបស់យើង ទ្រង់មានប្រក្រតីត្រាស់សរសើរវីរិយារម្ភៈ ពាក្យទូន្មានរបស់ព្រះអង្គ អ្នកណាក៏មិនគប្បីប្រព្រឹត្តល្មើសផង ព្រះអង្គមានព្រះ-ឧបការៈច្រើនដល់យើងទាំងឡាយផង ព្រះអង្គកាលយើងបូជាដោយការបដិបត្តិទើបជាការបូជា មិនមែនដោយប្រការដទៃទេ ។

៦ . **ទាយជ្ជមហត្តបច្ចវេក្ខណតា** ការពិចារណាឃើញភាពជាធំនៃមត៌កដោយន័យដូច្នេះ ថា “ មត៌កដ៏ធំ ពោលគឺ ព្រះសទ្ធម្ម យើងគប្បីនឹងបានទទួល ប៉ុន្តែមត៌កធំនោះ បុគ្គលខ្ជិលច្រអូសមិនអាចទទួលបានទេ ” ។

៧ . **ថីនមិទ្ធវិនោទនតា** ការបន្ទោបង់ថីនមិទ្ធៈចេញ ដោយការបដិបត្តិទាំងឡាយ មានការធ្វើអាលោកសញ្ញាទុកក្នុងចិត្ត ការផ្លាស់ប្តូរឥរិយាបថ និង ការសេពអព្ភោកាសជាដើម ។

៨ . **កុសីតបុគ្គលបរិវជ្ជនតា** ការវៀរចាកបុគ្គលខ្ជិលច្រអូស ។

៩ . **អារទ្ធវិរិយបុគ្គលសេវនតា** ការសេពគប់បុគ្គលដែលប្រារព្ធនូវ សេចក្តីព្យាយាម ។

១០ . **សម្មប្បធានបច្ចវេក្ខណតា** ការពិចារណាឃើញនូវ( អានុភាព ) នៃសម្មប្បធាន ។

១១ . **តទធិមុត្តតា** ការបង្អោនចិត្តទៅក្នុងវិរិយៈនោះ ។

## ធម៌ ១១ ប្រការ ជាផ្លូវឲ្យកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ គឺ :-

| | |
|---|---|
| ១ . ពុទ្ធានុស្សតិ | រលឹកព្រះពុទ្ធគុណ ។ |
| ២ . ធម្មានុស្សតិ | រលឹកព្រះធម្មគុណ ។ |
| ៣ . សង្ឃានុស្សតិ | រលឹកព្រះសង្ឃគុណ ។ |
| ៤ . សីលានុស្សតិ | រលឹកដល់សីលដែលបានរក្សា ។ |
| ៥ . ចាគានុស្សតិ | រលឹកដល់ការបរិច្ចាគ ។ |
| ៦ . ទេវតានុស្សតិ | រលឹកដល់ទេវតា និង ទេវធម៌ ។ |
| ៧ . ឧបសមានុស្សតិ | រលឹកដល់គុណព្រះនិព្វាន ។ |
| ៨ . លូខបុគ្គលបរិវជ្ជនតា | ការវៀរចាកបុគ្គលមានចិត្តមួម៉ៅ ។ |
| ៩ . សិនិទ្ធបុគ្គលសេវនតា | ការគប់រកបុគ្គលមានចិត្តស្រស់ថ្លា ។ |

**១០ . បសាទនីយសុត្តន្ត-បច្ចវេក្ខណតា** ការពិចារណា សេចក្ដីនៃព្រះសូត្រ ដែលនាំឲ្យជ្រះថ្លា ។

**១១ . តទធិមុត្តតា** ការបង្អោនចិត្តទៅក្នុងបីតិនោះ ។

ព្រះយោគាវចរ កាលញុំាងធម៌ទាំងឡាយនោះឲ្យកើតឡើងដោយអាការទាំងនេះ ដូចពោលមក ឈ្មោះថា ធ្វើសម្ពោជ្ឈង្គៈ ៣ មានធម្មវិចយសម្ពោជ្ឈង្គៈជាដើមឲ្យចម្រើន ព្រះយោគាវចរលើកចិត្តក្នុងសម័យដែលគួរលើកយ៉ាងនេះឯង ។

## ៥.គ្របសង្កត់ចិត្តក្នុងសម័យដែលគួរ

សួរថា “ ព្រះយោគាវចរគ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់យ៉ាងណា ” ឆ្លើយថា ក្នុងកាលណាចិត្តរបស់លោករាយមាយ ព្រោះហេតុ ជាអ្នកប្រារព្ធសេចក្ដីព្យាយាមខ្លាំងពេកជាដើម ក្នុងកាលនោះកុំចម្រើនសម្ពោជ្ឈង្គៈ៣ មានធម្មវិចយសម្ពោជ្ឈង្គៈជាដើម ហើយចម្រើនសម្ពោជ្ឈង្គៈ៣ មានបស្សទ្ធិសម្ពោជ្ឈង្គៈជាដើម ។ ពិតហើយ សេចក្ដីនេះ ព្រះមានព្រះភាគជាម្ចាស់ ក៏បានត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុរសប្រាថ្នានឹងពន្លត់គំនរភ្លើងធំ បើគេដាក់ស្មៅស្ងួតៗចូលទៅ ដាក់លាមកគោក្រៀមៗចូលទៅ ដាក់អុសស្ងួតៗចូលទៅ បក់ខ្យល់ចូលសុទ្ធទៅ ហើយមិនយកធូលីដីរោយទៅលើគំនរភ្លើងនោះ ម្នាលភិក្ខុទាំងឡាយ បុរស នោះនឹងអាចពន្លត់គំនរភ្លើងធំនោះបានឬទេ ” ភិក្ខុទាំងឡាយ ក្រាបទូលថា “ សេចក្ដីនោះ មិនបានទេព្រះអង្គ ” ទ្រង់ត្រាស់តទៅថា “ យ៉ាងនោះហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាចិត្តរាយមាយហើយ ក្នុងសម័យនោះ មិនមែនជាកាលដែលនឹងត្រូវចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ មិនមែនជាកាលដែលនឹងត្រូវ

ចម្រើនវីរិយសម្ពោជ្ឈង្គៈ មិនមែនជាកាលដែលនឹងត្រូវចម្រើនបីតិសម្ពោជ្ឈង្គៈ នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ កាលចិត្តរាយមាយហើយ លំបាកនឹងធ្វើឲ្យស្ងប់បាន ដោយធម៌ទាំងឡាយនោះ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាចិត្តរាយមាយហើយ ក្នុងសម័យនោះ ជាកាលគួរចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ ជាកាលនឹងត្រូវចម្រើនសមាធិសម្ពោជ្ឈង្គៈ ជាកាលត្រូវចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ កាលចិត្តរាយមាយ ចិត្តដែលរាយមាយនោះ ព្រះយោគាវចរអាចធ្វើឲ្យស្ងប់បានដោយងាយ ដោយធម៌ទាំងឡាយនោះ ប្រៀបដូចបុរសប្រាថ្នានឹងពន្លត់ភ្លើងធំ បើគេដាក់ស្មៅស្រស់ ៗ ចូលទៅ ដាក់លាមកគោស្រស់ៗចូលទៅ ដាក់អុសស្រស់ចូលទៅ ឲ្យខ្យល់លាយដោយទឹកចូលទៅ និងយកល្អងធូលីរោយចុះទៅលើគ្នក់ភ្លើងធំនោះ ម្នាលភិក្ខុទាំងឡាយ បុរសនោះ អាចនឹងពន្លត់ភ្លើងធំនោះបានឬទេ ភិក្ខុទាំងឡាយក្រាបទូលថា “ បានព្រះអង្គ ”ដូច្នេះ ។ ( សំ . មហាវារវគ្គ )

## អាហារនៃបស្សទ្ធិសម្ពោជ្ឈង្គៈ

សូម្បីក្នុងអធិការនេះ គប្បីជ្រាបការចម្រើនសម្ពោជ្ឈង្គៈ ៣ មានបស្សទ្ធិ-សម្ពោជ្ឈង្គៈជាដើម ទាក់ទងដោយធម៌ដែលជាអាហាររបស់ខ្លួន ពិតហើយ សេចក្តីនេះព្រះមានព្រះភាគបានត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ កាយបស្សទ្ធិ( ស្ងប់កាយ ) ចិត្តបស្សទ្ធិ( ស្ងប់ចិត្ត ) ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងបស្សទ្ធិនោះ នេះជាអាហារដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គៈដែលមិនទាន់កើតឡើងខ្លះ ដើម្បីកិរិយាភាពពេញលេញនៃបស្សទ្ធិសម្ពោជ្ឈង្គៈដែលកើតឡើងហើយខ្លះ ” ដូច្នេះ ។

## អាហារនៃសមាធិសម្ពោជ្ឈង្គ:

ន័យដូចគ្នាទ្រង់ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ សមាធិនិមិត្ត(និមិត្តស្ងប់) អព្យគ្គនិមិត្ត(និមិត្តមិនរាត់រាយ) ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងនិមិត្តនោះ នេះជាអាហារដើម្បីញ៉ាំងសមាធិសម្ពោជ្ឈង្គៈឲ្យកើតឡើងខ្លះ ដើម្បីកិយ្យោភាពនៃសមាធិសម្ពោជ្ឈង្គៈដែលកើតឡើងហើយខ្លះ ដូច្នេះ ។

## អាហារនៃឧបេក្ខាសម្ពោជ្ឈង្គ:

ន័យដូចគ្នា ទ្រង់ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ: គឺ ការធ្វើយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហារដើម្បីឲ្យឧបេក្ខាសម្ពោជ្ឈង្គៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងខ្លះ ដើម្បីកិយ្យោភាពពេញលេញនៃឧបេក្ខាសម្ពោជ្ឈង្គៈដែលកើតហើយខ្លះ ” ដូច្នេះ ។

## កែអត្ថ ចាប់:បទខ្លះ

មនសិការ ដែលប្រព្រឹត្តទៅដោយកិរិយាដែលព្រះយោគីកំណត់អាការដែលធ្លាប់មាន ជាហេតុឲ្យកើតឡើងនៃធម៌ទាំង ៣ មានបស្សទ្ធិជាដើមបានហើយ ញ៉ាំងធម៌ទាំង ៣ នោះឲ្យកើតឡើង ឈ្មោះថា យោនិសោមនសិការក្នុងបទទាំង ៣ ក្នុងព្រះបាលីនោះ ពាក្យថា “ **សមថនិមិត្ត** ” នោះ ជាឈ្មោះនៃសមថ:នោះឯង និងពាក្យថា “ **អព្យគ្គនិមិត្ត** ” ក៏ជាពាក្យហៅសមថ:នោះដូចគ្នា ដោយអត្ថថា មិនរាយមាយ ។

# ហេតុនាំឱ្យកើតនៃបស្សទ្ធិ សមាធិ ឧបេក្ខា

## ( ន័យម្យ៉ាងទៀត )

ម្យ៉ាងទៀត ធម៌ ៧ ប្រការ ជាហេតុឲ្យកើតឡើងនៃបស្សទ្ធិ-សម្ពោជ្ឈង្គៈ គឺ :

១ . បណីតភោជនសេវនតា — សេពភោជនដ៏ប្រណីត ។

២ . ឧតុសុខសេវនតា — សេពរដូវដែលជាសុខ ។

៣ . ឥរិយាបថសុខសេវនតា — សេពឥរិយាបថដែលជាសុខ ។

៤ . មជ្ឈត្តប្បយោគតា — ប្រកបសេចក្ដីព្យាយាមជាកណ្ដាល ។

៥ . សារទ្ធកាយបុគ្គលបរិវជ្ជនតា — ចៀសវាងបុគ្គលមានកាយសោប់សល់។

៦ . បស្សទ្ធកាយបុគ្គលសេវនតា — សេពបុគ្គលមានកាយស្ងប់ ។

៧ . តទធិមុត្តតា — បង្អោនចិត្តទៅក្នុងបស្សទ្ធិនោះ ។

ធម៌ ១១ ប្រការ ជាហេតុឲ្យកើតឡើងនៃសមាធិសម្ពោជ្ឈង្គៈ គឺ :

១ . វត្ថុវិសទតា — ភាពស្អាតនៃវត្ថុ ។

២ . និមិត្តកុសលតា — ភាពឆ្លាតក្នុងនិមិត្ត ។

៣ . ឥន្ទ្រិយសមត្តបដិបាទនតា — ការធ្វើឥន្ទ្រិយឲ្យស្មើ ។

៤ . សមយេ ចិត្តស្ស និគ្គហណតា — ការគ្របសង្កត់ចិត្តក្នុងសម័យ ។

៥ . សមយេ ចិត្តស្ស បគ្គហណតា — ការលើកចិត្តក្នុងសម័យ ។

៦ . និរស្សទស្ស ចិត្តស្ស .... សម្បហំសនតា — ការធ្វើចិត្តដែលមិនមាន អស្សាទៈ ឲ្យរីករាយ ដោយអំណាចសទ្ធានិងសង្វេគ។

៧ . សម្មាបវត្តស្ស អជ្ឈុបេក្ខណតា — សម្លឹងជាព្រងើយ ៗ នូវចិត្តដែលប្រព្រឹត្តទៅដោយប្រពៃហើយ ។

៨ . អសមាហិតបុគ្គលបរិវជ្ជនតា — ជៀសវាងបុគ្គល ដែលមិនមានចិត្តជាសមាធិ ។

៩ . សមាហិតបុគ្គលសេវនតា — សេពគប់បុគ្គលដែលមានចិត្តជាសមាធិ ។

១០ . ឈានវិមោក្ខប្បច្ចវេក្ខណតា — ពិចារណាវិមោក្ខក្នុងឈាន ។

១១ . តទធិមុត្តតា — បង្អោនចិត្តទៅក្នុងសមាធិនោះ ។

## ធម៌ ៥ ប្រការ ជាហេតុឲ្យកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ គឺ :

១ . សត្តមជ្ឈត្តតា — ភាពជាកណ្តាល ៗ ក្នុងពួកសត្វ ។

២ . សង្ខារមជ្ឈត្តតា — ភាពជាកណ្តាល ៗ ក្នុងសង្ខារ ។

៣ . សត្តសង្ខារកេលាយន-បុគ្គលប្បរិវជ្ជនតា — ការវៀរចាកបុគ្គលដែលជាប់ស្អិតក្នុងសត្វ និង សង្ខារ ។

៤ . សត្តសង្ខារមជ្ឈត្តបុគ្គលសេវនតា — សេពគប់បុគ្គលដែលមានភាពជាកណ្តាលក្នុងសត្វ និង សង្ខារ ។

៥ . តទធិមុត្តតា — ការបង្អោនចិត្តទៅក្នុងឧបេក្ខានោះ ។

ព្រះយោគាវចរ កាលបើញ៉ាំងធម៌ទាំងឡាយនោះឲ្យកើតឡើង ដោយអាការទាំងឡាយនេះ ដូចពោលមកហើយ ឈ្មោះថា ធ្វើសម្ពោជ្ឈង្គៈ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គៈជាដើមឲ្យចម្រើន ព្រះយោគាវចរ រមែងគ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់យ៉ាងនេះឯង ។

## ៦.ធ្វើចិត្តឱ្យរីករាយក្នុងសម័យដែលគួរ

សួរថា ព្រះយោគាវចរ ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរធ្វើឲ្យរីករាយយ៉ាងដូចម្ដេច? ឆ្លើយថា ចិត្តរបស់លោកជាចិត្តមិនមានអស្សាទៈព្រោះការព្យាយាមតាមបញ្ញាដែលទន់ខ្សោយក្ដី ព្រោះមិនបានសេចក្ដីសុខ ដែលកើតពីសេចក្ដីស្ងប់ក្ដី ក្នុងកាលនោះព្រះយោគាវចរ រមែងញ៉ាំងចិត្តនោះឲ្យសង្វេគ ដោយការពិចារណាសង្វេគវត្ថុ៨ វត្ថុទាំងឡាយគឺ ជាតិ ជរា ព្យាធិ មរណៈ ជា៤ , អបាយទុក្ខជាទី ៥ វដ្តមូលកទុក្ខ( ទុក្ខមានវដ្តៈជាមូល ) ក្នុងអតីត ១ វដ្តមូលកទុក្ខក្នុងអនាគត ១ អាហារបរិយេដ្ឋិមូលកទុក្ខ( ទុក្ខមានការស្វែងរកអាហារជាមូល ) ក្នុងបច្ចុប្បន្ន ១ ឈ្មោះថា សង្វេគវត្ថុ៨ ។ម្យ៉ាងទៀត លោករមែងញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើតឡើងដល់ចិត្តនោះ ដោយរលឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះយោគាវចររមែងតាំងចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយដោយប្រការដូច្នេះ ។

## ៧.សម្លឹងមើលចិត្តដោយព្រងើយ។

សួរថា ព្រះយោគាវចរ រមែងសម្លឹងមើលចិត្តដោយព្រងើយ ៗ ក្នុងសម័យដែលចិត្ត គួរនឹងសម្លឹងមើលយ៉ាងព្រងើយៗ យ៉ាងណា ?

ឆ្លើយថា ក្នុងកាលណាចិត្តរបស់លោកបដិបត្តិហើយយ៉ាងនោះ ជាចិត្តមិនរួញរា មិនរាយមាយ មិនប្រាសចាកអស្សាទៈ ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ប្រព្រឹត្តទៅនៅក្នុងវិថីនៃសមថៈ ក្នុងកាលនោះ លោកមិនត្រូវខ្វល់ខ្វាយក្នុងការលើក ការគ្របសង្កត់ ហើយធ្វើឲ្យចិត្តនោះរីករាយ ដូចសារថី កាលបើសេះទាំងឡាយរត់ទៅរៀបរយហើយ ក៏មិនត្រូវខ្វល់ខ្វាយដូច្នោះ ព្រះយោគាវចរ រមែងសម្លឹងមើលចិត្តដោយព្រងើយៗ ក្នុងសម័យដែលគួរសម្លឹងមើលយ៉ាងព្រងើយៗ យ៉ាងនេះ ។

## ៨.ចៀសវាងបុគ្គលដែលមានចិត្តមិនជាសមាធិ

ការវៀរចាកឲ្យឆ្ងាយចំពោះបុគ្គលទាំងឡាយណា ដែលមិនធ្លាប់ឡើងកាន់នេក្ខម្មប្បដិបទា រវល់តែនៅក្នុងកិច្ចការច្រើនយ៉ាង មានចិត្តរាយមាយ ឈ្មោះថា ចៀសវាងបុគ្គលមានចិត្តមិនជាសមាធិ ។

## ៩.សេពគប់បុគ្គលមានចិត្តជាសមាធិ

ការចូលទៅរកបុគ្គលទាំងឡាយណា ដែលប្រកបដោយនេក្ខម្មប្បដិបទា បានសមាធិជាប្រក្រតី តាមកាលដែលគួរ ឈ្មោះថា សេពគប់បុគ្គលដែលមានចិត្តជាសមាធិ ។

## ១០.ការបង្អោនចិត្តទៅក្នុងសមាធិ

ការបង្អោនចិត្តទៅក្នុងសមាធិ ឈ្មោះថា **តទធិមុត្តតា** មានន័យថា ធ្ងន់ទៅក្នុងសមាធិ ទោរទៅក្នុងសមាធិ បង្អោនទៅក្នុងសមាធិ ធ្លាក់ទៅក្នុងសមាធិ ។

អប្បនាកោសល្យ ១០ យ៉ាងនេះ ព្រះយោគីគប្បីធ្វើឲ្យដល់ព្រមដោយប្រការដូច្នេះចុះ ។

កាលបើនិមិត្តកើតឡើងដល់ព្រះយោគាវចរហើយ នឹងធ្វើឲ្យអប្បនាកោសល្យនេះដល់ព្រមយ៉ាងនេះ អប្បនាទើបប្រព្រឹត្តទៅបាន កាលលោកបដិបត្តិយ៉ាងនេះហើយ អប្បនានោះនៅតែមិនទាន់កើត សូម្បីដូច្នោះ លោកដែលជាបណ្ឌិតក៏មិនគប្បីលះបង់ការព្យាយាមឡើយ ព្រោះដែលបានឈ្មោះថា បុគ្គលលះបង់សម្មាវាយាមៈចេញហើយ នឹងគប្បីបានសម្រេចគុណវិសេសសូម្បីតិចតួចនោះ មិនមែនជាឋានៈឡើយ ព្រោះហេតុនោះ បណ្ឌិតកំណត់អាការប្រព្រឹត្តទៅនៃចិត្តបាន គប្បីប្រកបភាពស្មើគ្នានៃវីរិយៈ ( ជាមួយនឹងសមាធិ )ទុក គប្បីលើកចិត្តដែល ( មាន

សេចក្តីព្យាយាម )តិចតួចទុក គប្បីគ្របសង្កត់ចិត្តដែលមានសេចក្តីព្យាយាមក្លៀវក្លាពេកឲ្យប្រព្រឹត្តទៅដោយល្មម ។ គប្បីផ្លាស់ប្តូរចិត្តដែលមានសភាពខ្សត់ខ្សោយ និងការស្ទុះឡើងដោយប្រការទាំងពួង ហើយលើកចិត្តដែលមាន ( បដិភាគ ) និមិត្តនៅចំពោះមុខឲ្យប្រព្រឹត្តទៅ ធ្វើត្រាប់តាមការប្រព្រឹត្តទៅនៃសត្វល្អិតមួយក្បាល មានមេឃ្មុំជាដើម នៅក្នុងកេសរផ្កាឈើ ក្នុងស្លឹកឈូក ក្នុងសរសៃសំបុកពីងពាងក្នុងទូក ក្នុងត្រឡោក(ប្រេង) ដែលលោកពណ៌នាទុកក្នុង( អដ្ឋកថា ) ដូច្នេះចុះ ។

## ឧបមាផ្សេងៗនៃសម្មាវាយាមៈ

### “ ឧបមាសម្មាវាយាមៈ ”

តទៅនេះ ជាពាក្យសំដែងសេចក្តីក្នុង២គាថាខាងចុង ឧបមាដូចឃ្មុំល្ងង់(មួយក្បាល ) ដឹងថាផ្កាឈើនៅដើមឯណោះរីកហើយ ក៏ស្ទុះទៅរហ័សពេក ( រហូតទប់ខ្លួនមិនទាន់ ) ក៏ហើរកន្លងហួសផ្កាឈើនោះទៅ ពេលត្រឡប់មកវិញកេសរផ្កាក៏រោយអស់ទៅ ឃ្មុំល្ងង់មួយក្បាលទៀតទៅដោយការយឺតយ៉ាវ ពេលទៅដល់ផ្កាឈើនោះក៏រោយដូចគ្នា ចំណែកឃ្មុំមួយក្បាលដែលឆ្លាត រមែងស្ទុះទៅដោយភាពរហ័សល្មមចូលដល់កញ្ចុំផ្កាហើយ ក៏ក្រេបយកកេសរតាមដែលត្រូវការ មកផ្សំជាទឹកឃ្មុំ ក៏បានក្រេបរសដ៏ឆ្ងាញ់សប្បាយទៅ យ៉ាងណា ម្យ៉ាងទៀត ឧបមាដូចពួកកូនសិស្សជាងចម្លាក់ ប្រើកាំបិតឆ្លាក់លើស្លឹកឈូក ដែលបណ្តែតទុកក្នុងពាងទឹក សិស្សម្នាក់ឆ្លាតពេកក៏ដាក់កាំបិតចុះយ៉ាងរហ័ស ស្លឹកឈូករហែកខ្លះ លិចទឹកខ្លះ , ម្នាក់ទៀតមិនឆ្លាត មិនហ៊ានសូម្បីយកកាំបិតប៉ះ ព្រោះខ្លាចស្លឹកឈូកនោះរហែកហើយលិចទឹក , ចំណែកសិស្សម្នាក់ទៀតដែលឆ្លាតបានសំដែងស្នាមកាំបិត ( ជាក្បាច់ក្បូរ ) ក្នុងស្លឹកឈូកនោះ ដោយប្រយោគយ៉ាងសមល្មម ក៏ជាអ្នកបានឈ្មោះ

ថា មានសិល្បៈសម្រេច ធ្វើការងារក្នុងតំណែងទាំងឡាយ ( ដែលត្រូវប្រើសិល្បៈ ) ដូច្នោះ រមែងបានលាភយ៉ាងណា ម្យ៉ាងទៀត ឧបមាដូចព្រះរាជាទ្រង់ប្រកាសថា “ អ្នកណានាំសរសៃពីងពាងដែលមានប្រវែងប្រមាណ ៤ ព្យាម មកថ្វាយបាន អ្នកនោះនឹងបានទ្រព្យ ៤០០០ កាក់ បុរសម្នាក់ឆ្លាតពេក បានទាញសរសៃពីងពាងប្រញាប់ពេកក៏ដាច់ បុរសម្នាក់ទៀតមិនឆ្លាត មិនហ៊ានសូម្បីយកដៃទៅប៉ះ ព្រោះខ្លាចសរសៃពីងពាងនោះដាច់ ចំណែកបុរសដែលឆ្លាតបានព័ន្ធសរសៃចូលក្នុងកំណាត់ឈើតាំងពីចុងចូលទៅ ដោយប្រយោគសមល្មម នាំទៅថ្វាយព្រះរាជាបាន ក៏បានទទួលលាភនោះ យ៉ាងណា ម្យ៉ាងទៀតឧបមាដូចអ្នកដើរនាវាឆ្លាតពេក បានបើកក្ដោងក្នុងពេលខ្យល់ខ្លាំង ធ្វើឲ្យទូកស្ទុះទៅខុសទិសដៅ ម្នាក់ទៀតមិនឆ្លាត ក្នុងកាលមានខ្យល់តិចៗ ក៏ទម្លាក់ក្ដោងចុះ ទូកឈប់នៅទីនោះឯង ចំណែកអ្នកដើរទូកដែលឆ្លាត លើកក្ដោងក្នុងពេលដែលមានខ្យល់ល្មម ទម្លាក់ក្ដោងចុះពាក់កណ្ដាលក្នុងកាលខ្យល់ខ្លាំង រមែងទៅដល់ទី តាមសេចក្ដីប្រាថ្នាដោយសុវត្ថិភាពយ៉ាងណា ម្យ៉ាងទៀត ឧបមាដូចកាលអាចារ្យ ប្រកាសដល់អន្តេវាសិកទាំងឡាយថា “ អ្នកណាចាក់ប្រេងចូលក្នុងត្រឡោកឲ្យពេញ មិនឲ្យកំពប់ អ្នកនោះនឹងបានលាភ ” អន្តេវាសិកម្នាក់ដែលឆ្លាតហួស ចង់បានលាភ ចាក់រហ័សពេកក៏ធ្វើឲ្យប្រេងកំពប់ ម្នាក់ទៀតមិនឆ្លាតមិនហ៊ានសូម្បីនឹងចាក់ ព្រោះខ្លាចប្រេងកំពប់ រីឯអន្តេវាសិកដែលឆ្លាត ចាក់ឲ្យពេញដោយប្រយោគដែលសមគួរ ក៏ទទួលបានលាភយ៉ាងណា ឧបមេយ្យក៏ដូច្នោះ ភិក្ខុមួយរូប កាលដែលបដិភាគនិមិត្តកើតឡើងហើយប្រាថ្នានឹងឲ្យដល់អប្បនាដោយរហ័សពេក ធ្វើសេចក្ដីព្យាយាមខ្លាំងក្លាពេក ចិត្តរបស់លោកក៏ធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះប្រារព្ធសេចក្ដីព្យាយាមខ្លាំងពេក លោកក៏មិន

អាចដល់អប្បនាបាន ភិក្ខុមួយរូបឃើញទោស ព្រោះប្រារព្ធសេចក្ដីព្យាយាម ខ្លាំងពេកក៏បានគិតថា “ យើងមានសេចក្ដីត្រូវការដោយអប្បនាក្នុងពេលនេះធ្វើអ្វី ” ដូច្នេះហើយ ក៏ទម្លាក់សេចក្ដីព្យាយាមចោល ចិត្តរបស់លោកក៏ធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះមានការព្យាយាមទន់ខ្សោយ សូម្បីលោកក៏មិនអាចដល់អប្បនាបាន ចំណែក ភិក្ខុណាទូន្មានចិត្តដែលខិលច្រអូសសូម្បីបន្តិចបន្តួច ការរាយមាយសូម្បីតិចតួច ក៏ចេញចាកពីសេចក្ដីរាយមាយនោះ ញុំាងចិត្តដែលមាន ( បដិភាគ )និមិត្តនៅចំពោះមុខឲ្យប្រព្រឹត្តទៅដោយប្រយោគដ៏សមល្មម លោករមែងដល់នូវអប្បនាបាន ។ ព្រះយោគាវចរគប្បីប្រព្រឹត្តដូចភិក្ខុរូបទី ៣ នោះចុះ ខ្ញុំម្ចាស់សំដៅយកសេចក្ដីនេះ ទើបពោលពាក្យប្រព័ន្ធ ( ២ គាថាខាងចុង ) នេះទុកថា :

“ គប្បីទូន្មានចិត្តឲ្យចេញពីការខិលច្រអូស និង សេចក្ដីរាយមាយដោយប្រការទាំងពួង ហើយញុំាងចិត្តដែលមាន( បដិភាគ )និមិត្តនៅចំពោះមុខឲ្យប្រព្រឹត្តទៅ ដូចការប្រព្រឹត្តទៅនៃសត្វល្អិត និង មនុស្ស មានតួយ៉ាងសត្វឃ្មុំជាដើម ក្នុងកេសរផ្កា ក្នុងស្លឹកឈូក ក្នុងសរសៃពីងពាង ក្នុងទូក ក្នុងត្រឡោក ដែលលោកពណ៌នាទុកដូច្នោះចុះ ” ។

## ចិត្តក្នុងខណៈដែលអប្បនាត្រូវសម្រេច

កាលព្រះយោគាវចរនោះ ធ្វើចិត្តដែលមាន(បដិភាគ)និមិត្ត នៅចំពោះមុខឲ្យដំណើរទៅដោយប្រការដូចពោលមកនេះ ក្នុងខណៈដែលអប្បនា ត្រូវសម្រេច មនោទ្វារាវជ្ជនចិត្ត រមែងផ្ដាច់ភវង្គ ធ្វើបឋវីកសិណដែលប្រាកដដោយអំណាចនៃការអនុយោគ ( ភាវនា )ថា **បឋវី បឋវី** នោះឯង ឲ្យជាអារម្មណ៍កើតឡើង បន្ទាប់ពីនោះ ជវនចិត្ត ៤ ឬ ៥ ដួង រមែងស្ទុះទៅក្នុងអារម្មណ៍នោះៗឯង ក្នុងទីបំផុត

ក្នុងជវនចិត្តនោះ ដួង១ជារូបាវចរៈ ដ៏សេស( ៣ ឬ ៤ ) ជាកាមាវចរៈ ជាចិត្តមាន វិតក្កៈ វិចារៈ បីតិ សុខៈ និង ចិត្តេកគ្គតា មានកម្លាំងជាប្រក្រតី ( កាមាវចរចិត្ត ) ដែលលោកហៅថា បរិកម្មចិត្ត ព្រោះជាចិត្តតាក់តែងអប្បនាខ្លះហៅថា ឧបចារចិត្ត ព្រោះជាចិត្តជិតដល់អប្បនា ឬ ចូលទៅក្នុងទីជិតនៃអប្បនា ដូចជាទីកន្លែងដែលចូល ទៅដល់ជិតភូមិស្រុកជាដើម ក៏ហៅថា ឧបចារភូមិ ឧបចារស្រុក , ហៅថា អនុលោមចិត្ត ព្រោះជាចិត្តអនុលោមដល់បរិកម្មចិត្ត ( ក្នុងនានាវជ្ជនវិថី ) ទាំងឡាយ មុននឹងដល់អប្បនាខាងមុខខ្លះ ។ មួយ៉ាងទៀត ក្នុងបណ្តាចិត្ត ( ដែលបាន ឈ្មោះថា បរិកម្ម ឧបចារៈ និង អនុលោម ) ទាំងឡាយនេះ ដួងណាមួយដែល នៅចុងគេបង្អស់ ដួងនោះ លោកហៅថា គោត្រភូ ព្រោះគ្របសង្កត់បរិត្តគោត្របាន និង ធ្វើមហគ្គតគោត្រឲ្យកើតឡើង ។

ពោលតាមលំដាប់នៃជវនចិត្ត ដែលលោកនៅមិនទាន់បាត់ទុកក្នុងជវនចិត្តទាំងនោះ ដួងទី១ ជាបរិកម្ម ដួងទី២ ជាឧបចារៈ ដួងទី៣ ជាអនុលោម ដួងទី៤ ជាគោត្រភូ ។

មួយ៉ាងទៀត ដួងទី១ ជាឧបចារៈ ដួងទី២ ជាអនុលោម ដួងទី៣ ជាគោត្រភូ ដួងទី ៤ ឬ ទី ៥ ជាអប្បនាចិត្ត សេចក្តីពិតជវនដួងទី ៤ ប៉ុណ្ណោះ ឬក៏ទី ៥ រមែងជាអប្បនា សេចក្តីនោះ មានដោយអំណាចនៃខិប្បាភិញ្ញា និងទន្ធាភិញ្ញា ជវនបន្ទាប់ពីនោះទៅ រមែងធ្លាក់ជាភវៈនៃភវង្គ ។

ចំណែកព្រះគោទត្តត្ថេរ អ្នកអភិធម្ម អាងសូត្រនេះថា " ធម៌ទាំងឡាយជាកុសលដែលកើតមុនៗ រមែងជាបច្ច័យដោយអាសេវនប្បច្ច័យ នៃធម៌ទាំងឡាយដែលជាកុសលកើតក្រោយៗ " ដូច្នោះហើយ ពោលថា " ធម៌ដែលកើតក្រោយៗ

រមែងមានកម្លាំងឡើងដោយអាសេវនប្បច្ច័យ ព្រោះហេតុនោះ អប្បនា រមែងមាន បានសូម្បីក្នុងជវនទី៦ ទី៧ " ពាក្យរបស់ព្រះគោទត្តត្ថេរនោះ លោកពោលជំទាស់ទុកក្នុងអដ្ឋកថាទាំងឡាយ " នោះមានត្រឹមតែអត្តនោមតិរបស់ព្រះថេរៈ " ហើយពោលថា " អប្បនា រមែងមានក្នុងជវនទី៤ ឬទី៥ ប៉ុណ្ណោះជវនតពីនោះរាប់បានថា ធ្លាក់ហើយ ព្រោះជិតនឹងធ្លាក់ចុះកាន់ភវង្គ " ដូច្នេះ នរណាៗ ក៏មិនអាចជំទាស់ពាក្យក្នុងអដ្ឋកថានោះបាន ព្រោះជាពាក្យដែលលោកបានពិចារណាហើយយ៉ាងនេះ ទើបពោលទុក សេចក្តីពិតចិត្តមិនអាចជាអប្បនាបានក្នុងជវនទី៦ ទី៧ ក៏ដោយ ព្រោះជិតនឹងធ្លាក់ចុះកាន់ភវង្គ ប្រៀបដូចបុរសរត់ទៅជិតធ្លាក់ជ្រោះ សូម្បីនរណានឹងបញ្ឈប់ ក៏មិនអាចញុំាងជើងឲ្យឈប់នៅមាត់ជ្រោះបាន រមែងនឹងធ្លាក់ទៅក្នុងជ្រោះតែម្យ៉ាង ព្រោះហេតុនោះ អប្បនា បណ្ឌិតគប្បីជ្រាបថា រមែងមានក្នុងជវនទី៤ ឬទី៥ ប៉ុណ្ណោះ ។

ឯអប្បនានោះប្រព្រឹត្តទៅក្នុងខណៈចិត្ត១ប៉ុណ្ណោះ ពិតហើយ ឈ្មោះថា កំណត់កាលក្នុងស្ថាន៧ មិនមាន គឺ ក្នុងបឋមអប្បនា១ ក្នុងលោកិយអភិញ្ញាទាំងឡាយ១ ក្នុងមគ្គបួន១ ក្នុងផលដែលជាលំដាប់នៃមគ្គ១ ក្នុងភវង្គឈានក្នុងរូបាវចរភព១ ក្នុងនេវសញ្ញានាសញ្ញាយតនៈដែលជាបច្ច័យនៃនិរោធ១ ក្នុងផលសមាបត្តិរបស់លោកដែលចេញពីនិរោធ១ ក្នុងស្ថានទាំងនោះ ផលដែលជាលំដាប់នៃមគ្គមិនមានលើសពីជវន៣ខណៈទៅទេ នេវសញ្ញានាសញ្ញាយតនៈដែលជាបច្ច័យនៃនិរោធសមាបត្តិក៏ជវនមិនលើសពី ២ ខណៈ ភវង្គឈានក្នុងរូបារូបភពរាប់ប្រមាណ ( ខណៈចិត្ត ) មិនបាន ក្នុងស្ថានដ៏សេស៤ មានតែខណៈចិត្ត១ប៉ុណ្ណោះឯង ។ អប្បនាប្រព្រឹត្តទៅក្នុងខណៈចិត្តមួយដូចពោលមកនេះ តពីនោះ ក៏ជាភវង្គបាត ហើយអាវជ្ជនៈទើប

កាត់ខ្សែកវង្គកើតឡើង ដើម្បីជាប្រយោជន៍ដល់ឈានបច្ចវេក្ខណៈ បន្ទាប់ពីនោះ ក៏ជាឈានបច្ចវេក្ខណៈ ។

# មហាដីកា

## ពណ៌នា អប្បនាកោសល្យ ១០ យ៉ាង

ឈ្មោះថា មិនកើតឡើង ក៏គឺ **អប្បនា** ។ ព្រះយោគីជាអ្នកឆ្លាតក្នុងអប្បនា ដោយវិធីណា វិធីនោះមាន១០យ៉ាង ឈ្មោះថា **អប្បនាកោសល្យ** ឬថា បានដល់ញាណដែលជាហេតុនៃអប្បនានោះ ។ បទថា **វត្ថុវិសទកិរិយាតោ** ប្រែថា ដោយការធ្វើវត្ថុឲ្យមានសណ្តាប់ធ្នាប់ ។ ភ្ជាប់សេចក្តីចូលនឹងពាក្យថា **អប្បនាកោសល្លំ ឥច្ឆិតព្វំ** ( ដែលប្រែឲ្យពេញ បានសេចក្តីថា ព្រះយោគាវចរ គប្បីប្រាថ្នាអប្បនា-កោសល្យបាន ដោយការធ្វើវត្ថុឲ្យមានសណ្តាប់ធ្នាប់ ) ។

សូម្បីក្នុងបទដ៏សេស ក៏មានការភ្ជាប់សេចក្តីចូលទុកយ៉ាងនេះ ។ ពិតហើយ រាងកាយនិងគ្រឿងប្រើប្រាស់ មានចីវរជាដើមដែលទាក់ទងនឹងរាងកាយនោះ លោកបំណងថាជា “ វត្ថុ ” ក្នុងទីនេះ ព្រោះជាទីតាំងនៃការប្រព្រឹត្តទៅរបស់ចិត្ត និងចេតសិកទាំងឡាយ ។ ការធ្វើវត្ថុទាំងនោះ ដើម្បីឲ្យជាហេតុ នាំមកនូវភាពសុខស្រួលដល់ព្រះយោគាវចរនោះ ឈ្មោះថា ការធ្វើវត្ថុទាំងនោះឲ្យមានសណ្តាប់ធ្នាប់ ។ ព្រោះហេតុនោះ ទើបលោកពោលថា “ វត្ថុទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ” ដូច្នេះជាដើម ។

**វា** ស័ព្ទ មានសេចក្តីថា **សរីរំ វា** លោកប្រកបទុកឲ្យខុស ( គឺ ដែលពិតជា **សរីរំ សេទមលគ្គហិតំ វា** ) អធិប្បាយថា ជារាងកាយដែលស្អុះស្អាប់

ដោយសារញើសហូរ ឬលំបាកទ្រាំដោយកិច្ចដទៃៗ ។ ដោយ **វា** ស័ព្ទ ក្នុងបទថា **សេនាសនំ វា** គប្បីឃើញថា សង្គ្រោះយកសូម្បីគ្រឿងប្រើប្រាស់យ៉ាងដទៃ មានបាត្រជាដើម ។ សួរថា ក៏ន័យនេះសង្គ្រោះចូលដោយប្រការកាត់បលិពោធតូច ៗ ហើយ មិនមែនឬ ព្រោះហេតុអ្វី ទើបពោលទុកទៀត ?

ឆ្លើយថា សង្គ្រោះហើយពិតមែន តែថា ន័យដែលថានោះ លោកពោលទុកក្នុងវេលាដែលផ្ដើមចម្រើន ។ តែក្នុងទីនេះ ការបដិបត្តិយ៉ាងនោះ លោកពោលទុកដើម្បីភាពជាអ្នកច្លាតក្នុងអប្បនានៃព្រះយោគី ព្រះយោគីអ្នកប្រារព្ធកម្មដ្ឋានហើយ ក៏ឈប់អប់រំអប្បនានៅក្នុងកាលនៃឧបចារជ្ឈានដែលកើតឡើង សួរថា បើភាពមិនស្អាតមានហើយ ឬថា បើវត្ថុដែលជាវិស័យមានហើយ វត្ថុទាំងនោះនឹងជា វិស័យរបស់ព្រះយោគីដែលប្រកបរឿយៗនូវភាវនា យ៉ាងណា ? ឆ្លើយថា ដែលលោកពោលទុកយ៉ាងនេះ ក៏ដោយទាក់ទងនឹងចិត្តុប្បាទដែលប្រព្រឹត្តទៅជាខណៈៗ ។

ព្រោះថា ចិត្តុប្បាទទាំងនេះ រមែងប្រព្រឹត្តទៅព្រម ដើម្បីភាពមិនបរិសុទ្ធនៃឯកគ្គតាចិត្ត ។

ពាក្យថា **ក្នុងចិត្ត និង ចេតសិក** គឺក្នុងចិត្ត និងចេតសិកដែលជាបច្ច័យ មាននិស្សយប្បច្ច័យជាដើម ។ **បិ** ស័ព្ទ ក្នុងបទថា **ញាណម្បិ** ប្រព្រឹត្តទៅក្នុងអត្ថថារួបរួម ។ ដោយ **បិ** ស័ព្ទ នោះ លោកអាចារ្យសម្ដែងហើយថា “ មិនមែនតែវត្ថុនោះតែម្យ៉ាងប៉ុណ្ណោះ ជារបស់មិនបរិសុទ្ធ ប៉ុន្តែថា កាលវត្ថុនោះមិនបរិសុទ្ធ សូម្បីញាណក៏ជារបស់មិនបរិសុទ្ធ ” ដូច្នេះ ។

ចំណែកភាពមិនបរិសុទ្ធនៃធម៌ ដែលសម្បយុត្តជាមួយញាណនោះ សម្រេចហើយដោយមិនត្រូវពោលដល់ ក៏ការដែលលោកកាន់យកចំពោះញាណ ក៏ព្រោះ

ការដែលមានឧបការច្រើនដល់អប្បនា ។ ពិតយ៉ាងនោះ **ឈាន** លោកសំដែង អធិប្បាយទុកដោយញាណជាដំណើរផ្លូវថា “ **ទន្ធាភិញ្ញំ** ញាណដែលដឹងយឺតយូរ **ខិប្បាភិញ្ញំ** ញាណដែលដឹងរហ័ស ” ។

ទាំងការអាស្រ័យនូវទីអាស្រ័យ ទាំងទីអាស្រ័យ ក៏ហៅថា **និស្សយ** ទាំងអស់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ អាស្រ័យតួចង្កៀង ប្រឆេះ និង ប្រេង ” ដូច្នេះ ។

សូម្បីសម្តែងថា កាលបើញាណមិនបរិសុទ្ធ សូម្បីសមាធិភាវនា ក៏រមែងជាធម្មជាតិខ្សោយកម្លាំងដោយជុំវិញ ដូចគ្នានឹងវិបស្សនាភាវនា ទើបលោកពោលថា “ កាលលោកពិចារណាសង្ខារទាំងឡាយដោយញាណដែលមិនបរិសុទ្ធ ” ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **កម្មដ្ឋាន** លោកពោលដល់សមថកម្មដ្ឋាន ។ គប្បីជ្រាបថា ចម្រើនក៏ដោយការប្រាកដនៃអង្គ គប្បីជ្រាបថា លូតលាស់ ក៏ដោយមានភាពឈ្លាសវៃ គប្បីជ្រាបថា ចម្រើនឡើង ក៏ដោយការដល់ភាពជាវសី ដោយប្រការទាំងពួង ។ ចំណែកខាងល្អ ក្នុងពាក្យថា **ប៉ុន្តែកាលវត្ថុទាំងខាងក្នុងទាំងខាងក្រៅមានភាពបរិសុទ្ធិ** គប្បីជ្រាបអត្ថ នៃចំណែកនោះ ដោយបរិយាយដែលពោលហើយចុះ ។

ពាក្យថា **ការធ្វើឲ្យមានភាពស្មើគ្នា** បានដល់ ការធ្វើមិនឲ្យខ្សោយពេក មិនឲ្យខ្លាំងពេកដោយកិច្ច ។ ឈ្មោះថា សទ្ធិន្ទ្រីយ៍ជាធម្មជាតិមានកម្លាំង ព្រោះកិច្ច គឺការបង្អោនចិត្តជឿក្នុងវត្ថុដែលគួរជឿ ខ្លាំងក្លាក្រៃលែងឡើងសមគួរដល់បច្ច័យ ។

ព្រោះបញ្ញាមិនបរិសុទ្ធ និងព្រោះឥន្ទ្រីយ៍ដទៃ មានវីរិយិន្ទ្រីយ៍ជាដើម មានភាព

ទន់ខ្សោយជាដើម ព្រោះហេតុនោះ ទើបលោកពោលថា " **ឥន្ទ្រិយ៍ក្រៅពីនេះ ទន់ខ្សោយ** " ។

ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះសទ្ធិន្ទ្រិយ៍មានកម្លាំង និង ព្រោះឥន្ទ្រិយ៍ក្រៅពីនេះ ទន់ខ្សោយ ។

ការលើកសម្បយុត្តធម៌ទាំងឡាយទុក មិនឲ្យធ្លាក់ទៅក្នុងចំណែកនៃការខ្ជិលច្រអូស បានដល់ ការតាមផ្តល់កម្លាំង ឈ្មោះថា **បគ្គហ** , កិច្ច គឺ **បគ្គហ** ឈ្មោះថា **បគ្គហកិច្ច** គួរភ្ជាប់ចូលនឹងពាក្យថា **កាតុំ ន សក្កោតិ** ( ជា **បគ្គហកិច្ចំ កាតុំ ន សក្កោតិ** ) ការចូលទៅកាន់អារម្មណ៍ ហើយតាំងនៅ ឬការមិនលះបង់ចោល ឈ្មោះថា **ឧបដ្ឋាន**( ជាកិច្ចរបស់សតិ ) សភាវៈដែលជាបដិបក្ខដល់សេចក្តីរាយមាយ ឬជាហេតុឲ្យសម្បយុត្តធម៌ទាំងឡាយមិនរាយមាយ នេះឈ្មោះថា **អវិក្ខេប** ។

ព្រះយោគី រមែងឃើញសភាវៈនៃអារម្មណ៍តាមពិត ដោយបញ្ញិន្ទ្រិយ៍ណា ដូចឃើញរូបដោយភ្នែក បញ្ញិន្ទ្រិយ៍នោះឈ្មោះថា មិនអាចធ្វើទស្សនកិច្ចបាន ព្រោះត្រូវសទ្ធិន្ទ្រិយ៍ដែលមានកម្លាំងគ្របសង្កត់ ។ ពិតហើយ ក្នុងបណ្តាធម៌ដែលកើតរួមគ្នាទាំងឡាយ ធម៌ទាំងឡាយដែលកំពុងប្រព្រឹត្តទៅរួមគ្នា ដែលកំពុងធ្វើភាវៈជាឥន្ទ្រិយ៍( ជាធំ ) រមែងមានការសម្រេចភាវៈ( ជាឥន្ទ្រិយ៍ )បាន ក៏ដោយទាក់ទងនឹងការមានរស(កិច្ច) ដូចគ្នាប៉ុណ្ណោះ មិនមែនដោយប្រការដទៃទេ ( មានពាក្យពោលក្នុងអដ្ឋកថា **បដិសម្ភិទាមគ្គ** ថា ពាក្យថា មានរសដូចគ្នា គឺ មានកិច្ចដូចគ្នាក្នុងការធ្វើអប្បនាឲ្យកើតឡើង ) ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា លោកត្រឡប់មកបញ្ជាក់ខ្លឹមសារដែលបានពោលហើយនោះឯង ដោយភាពជាហេតុ ។

បទថា **តំ** បានដល់ សទ្ធិន្ទ្រិយ៍ ។

ពាក្យថា **ដោយការពិចារណាសភាវធម៌** មានន័យថា សទ្ធិន្ទ្រីយ៍កើត ជាធម្មជាតិមានកម្លាំងព្រោះការបង្អោនចិត្តទៅក្នុងគុណ មានវត្ថុដ៏ប្រសើរជាដើម នៃវត្ថុដែលគួរជឿឲ្យប្រព្រឹត្តទៅយ៉ាងក្រៃលែង ព្រះយោគីគួរធ្វើសទ្ធិន្ទ្រីយ៍នោះឲ្យថយចុះ ដោយការពិចារណាវត្ថុដែលគួរជឿនោះ តាមសេចក្ដីពិត ដោយការចែកជាបច្ច័យ និង បច្ចុប្បន្នៈជាដើម ។

ពិតហើយ បើវត្ថុដែលគួរជឿត្រូវព្រះយោគីកំណត់ដោយរស គឺ សភាវៈ ដោយ **ឯវំធម្មតានយ** ( ន័យដែលពិចារណាថា មានអាការយ៉ាងនេះជាធម្មតា គឺ មានបច្ច័យយ៉ាងនេះហើយ ក៏រមែងមានផលកើតឡើង ព្រោះបច្ច័យយ៉ាងនេះជាធម្មតា ) យ៉ាងនេះហើយ រមែងមិនកើតអធិមោក្ខៈដែលមានការផ្សាយទៅ ព្រោះការព្យាយាមរបស់បញ្ញាមានកម្លាំងខ្លាំង ដោយទាក់ទងនឹងការកំណត់ដឹងថា “ នេះជាសភាវៈរបស់ធម៌នេះ ” ដូច្នេះ ។

ដូចសេចក្ដីថា ក្នុងបណ្ដាធម៌ដែលជាគូគ្នា បញ្ញាមានសភាពទន់ខ្សោយ ក៏ព្រោះសទ្ធាមានកម្លាំងយ៉ាងណា សទ្ធាមានសភាពទន់ខ្សោយ ក៏ព្រោះបញ្ញាមានកម្លាំងដូច្នោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា “ គួរធ្វើសទ្ធិន្ទ្រីយ៍នោះឲ្យថយចុះដោយការពិចារណាសភាវធម៌ ” ដូច្នេះ ។

ពាក្យថា **ដោយមិនមនសិការដោយអាការនោះ** មានអធិប្បាយថា សទ្ធិន្ទ្រីយ៍របស់ព្រះយោគី ដែលប្រកបរឿយៗនូវភាវនា ជាធម្មជាតិមានកម្លាំងបាន ដោយអាការណា លោកគួរធ្វើឲ្យថយចុះ ដោយការមិនប្រកបរឿយៗនូវភាវនាដោយអាការនោះ ។ ក្នុងទីនេះ សទ្ធិន្ទ្រីយ៍មានកម្លាំងដោយ២វិកប្ប គឺ ដោយកិច្ចដ៏ក្រៃលែងឡើងទៅតាមសភាពវិសេសនៃបច្ច័យរបស់ខ្លួន ១ ដោយភាវៈនៃឥន្ទ្រីយ៍ដ៏សេស មាន

វីរិយៈជាដើម មានកិច្ចទន់ខ្សោយ១ ។ ក្នុងវិកប្បទាំង២នោះ វិកប្បដំបូងលោកបាន សំដែងវិធីធ្វើសទ្ធិន្ទ្រីយ៍ឲ្យថយចុះទុកហើយ ចំណែកក្នុងវិកប្បទី ២ កាលព្រះ-យោគាវចរមនសិការដោយអាការណា សទ្ធិន្ទ្រីយ៍មានកម្លាំងខ្លាំង ព្រោះឥន្ទ្រីយ៍ទាំងឡាយដ៏សេស មានវីរិយៈជាដើម មានកិច្ចទន់ខ្សោយ លោកនឹងធ្វើសទ្ធិន្ទ្រីយ៍ឲ្យមានកិច្ចស្មើនឹងឥន្ទ្រីយ៍ដ៏សេសទាំងនោះ គួរធ្វើឲ្យថយចុះ ដោយមិនមនសិការដោយអាការនោះ តែដោយមនសិការដែលនាំមកនូវឥន្ទ្រីយ៍ដ៏សេស មានវីរិយៈជាដើម ឲ្យមានកិច្ចក្លៀវក្លាចុះ ។ បណ្ឌិតគប្បីជ្រាបវិធីធ្វើឲ្យថយចុះ សូម្បីក្នុងឥន្ទ្រីយ៍ដ៏សេស តាមន័យនេះចុះ ។

ពាក្យថា **រឿងរបស់ព្រះវក្កលិត្ថេរ** មានន័យពិស្តារថា លោកដ៏មានអាយុនោះជាអ្នកបានសន្សំបុញ្ញាធិការទុក ដើម្បីភាពជាព្រះអរិយបុគ្គល ប្រភេទសទ្ធាវិមុត្ត លោកជាអ្នកខ្វល់ខ្វាយក្នុងការសម្លឹងមើលព្រះរកាយរបស់ព្រះសាស្តាតែម្យ៉ាង សូម្បីព្រះសាស្តាទ្រង់ប្រទាននូវឱវាទដោយន័យថា “ ម្នាលវក្កលិ ប្រយោជន៍អ្វីដល់អ្នក ដោយកាយស្អុយដែលអ្នកបានឃើញនេះ ម្នាលវក្កលិអ្នកណាឃើញធម៌ អ្នកនោះនឹងបានឃើញតថាគត ” ដូច្នេះជាដើម ហើយទ្រង់ឲ្យប្រកបក្នុងកម្មដ្ឋាន កាលបើអ្នកមិនប្រកបក្នុងកម្មដ្ឋាននោះ ក៏ត្រូវបណ្តេញចេញ ទើបប្រឹងឡើងទៅកាន់មាត់ជ្រោះដើម្បីនឹងលោតទៅក្នុងជ្រោះនោះ ។ លំដាប់នោះ ព្រះសាស្តា ប្រថាប់គង់នៅទីនោះឯង ទ្រង់បញ្ចេញពន្លឺទៅកាន់ព្រះថេរៈ សម្តែងព្រះអង្គឲ្យប្រាកដ ត្រាស់ព្រះ-គាថា ថា :

“ **ភិក្ខុច្រើនដោយបាមោជ្ជ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នឹងអាចសម្រេចនូវបទដ៏ស្ងប់ដែលជាទីស្ងប់ចាកសង្ខារ រមែងនៅជាសុខ** ” ដូច្នេះហើយទើបត្រាស់ថា

“ **មកចុះវក្កលិ** ” ព្រះថេរៈនោះបានត្រូវទឹក គឺ ព្រះតម្រាស់ដែលជាអមតៈនោះ ស្រោចស្រប់ហើយ ក៏ជាអ្នករីករាយស្រស់ស្រាយ តាំងវិបស្សនាឡើង ។ តែព្រោះសទ្ធាមានកម្លាំង ទើបលោកមិនចុះកាន់វិបស្សនាវិថី ។ ព្រះមានព្រះភាគកាលទ្រង់ជ្រាបសេចក្ដីនោះហើយ កាលទ្រង់ត្រាស់ឲ្យព្រះថេរៈធ្វើឥន្ទ្រិយ៍ឲ្យស្មើគ្នា ទើបទ្រង់ជម្រះកម្មដ្ឋានប្រទានឲ្យទៅ ។ ព្រះថេរៈនោះ លុះធ្វើវិបស្សនាឲ្យបានតាមន័យដែលព្រះសាស្ដាប្រទានឲ្យ ក៏បានសម្រេចជាព្រះអរហន្តតាមលំដាប់មគ្គ ។

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ ក៏រឿងព្រះវក្កលិត្ថេរ ទុកជានិទស្សនៈក្នុងសេចក្ដីនេះ ” ដូច្នេះ ។

ពាក្យថា **ប្រភេទនៃកិច្ចក្រៅពីនេះ** បានដល់ កិច្ចផ្សេងៗគ្នា មានឧបដ្ឋានកិច្ចជាដើម ។

ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **បស្សទ្ធាទិ**( បស្សទ្ធិ-សម្ពោជ្ឈង្គៈជាដើម ) គប្បីឃើញថា សង្គ្រោះយកសមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខា-សម្ពោជ្ឈង្គៈ ។ ពាក្យថា **គួរធ្វើ**( វីរិយិន្ទ្រិយ ) **ឲ្យថយចុះ** មានន័យថា ភាវៈដែលសទ្ធិន្ទ្រិយមានកម្លាំងរមែងថយចុះទៅបាន ដោយការពិចារណាសភាវធម៌ យ៉ាងណាភាវៈដែលវីរិយិន្ទ្រិយមានប្រមាណក្រៃលែង រមែងថយចុះទៅបានដោយការចម្រើនពោជ្ឈង្គៈ មានបស្សទ្ធិសម្ពោជ្ឈង្គៈជាដើម ព្រោះបស្សទ្ធិនោះជាបក្ខពួកនៃសមាធិ ។

ពិតហើយ ការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈនេះ កាលរក្សានូវប្រយោជន៍ ដ៏ក្រៃលែងនៃវីរិយិន្ទ្រិយចាកពីការធ្លាក់ទៅក្នុងឧទ្ធច្ចៈ ក៏ឈ្មោះថា ធ្វើឲ្យថយចុះទៅបានដោយចំណែកមួយ ដូចគ្នានឹងការចម្រើនវីរិយិន្ទ្រិយសម្ពោជ្ឈង្គៈជាដើម ដែលរក្សាការមានប្រមាណក្រៃលែងនៃសមាធិន្ទ្រិយឲ្យចាកពីការធ្លាក់ទៅក្នុងកោសជ្ជៈដូច្នេះ ។

ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គួរធ្វើវីរិយិន្ទ្រិយ៍នោះ ឲ្យថយចុះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈជាដើមដូច្នេះ ។

ពាក្យថា **រឿងរបស់ព្រះសោណត្ថេរ** គឺ រឿងរបស់ព្រះសោណត្ថេរ ដែលជាអ្នកមានសុខុមាលជាតិ ។ មានសេចក្តីពិស្តារថា លោកដ៏មានអាយុនោះ កាលកាន់យកកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ហើយទៅកាន់ឧទ្យានសីតវ័នគិតថា “ រាងកាយរបស់យើងល្អិត ទន់ មិនអាចប្រសព្វសេចក្តីសុខបានដោយងាយឡើយ យើងត្រូវធ្វើសមណធម៌ សូម្បីនឹងត្រូវធ្វើរាងកាយឲ្យលំបាកក៏ដោយ ” ដូច្នេះហើយ ក៏តាំងចិត្តថា នឹងឈរ នឹងចង្ក្រមប៉ុណ្ណោះ តាមប្រកបសេចក្តីព្យាយាម សូម្បីរហូតពងបាតជើងឡើងហើមទាំងសងខាង លោកក៏អត់ទ្រាំនូវវេទនា ធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា នៅតែមិនអាចសម្រេចគុណវិសេសបាន ព្រោះការប្រារព្ធសេចក្តីព្យាយាមខ្លាំងពេក ។

ព្រះសាស្តាស្តេចយាងទៅកាន់ឧទ្យានសីតវ័ននេះ ទ្រង់ប្រទាននូវព្រះឱវាទដោយឱវាទដែលឧបមាដូចជាពិណ ទ្រង់សម្តែងវិធីប្រកបឲ្យសមល្មម នៃសេចក្តីព្យាយាម ជម្រះកម្មដ្ឋាន ( របស់ព្រះថេរៈ ) ឲ្យបរិសុទ្ធ ហើយស្តេចយាងទៅកាន់ភ្នំគិជ្ឈកូដ ។ សូម្បីព្រះថេរៈកាលប្រកបនូវសេចក្តីព្យាយាមឲ្យសមល្មម តាមន័យដែលព្រះសាស្តាប្រទាន ក៏ធ្វើវិបស្សនាឲ្យប្រព្រឹត្តទៅ រហូតតាំងនៅក្នុងព្រះអរហត្តបាន ។ ហេតុនោះ ទើបលោកអាចារ្យពោលថា “ បណ្ឌិត គួរសម្តែងរឿងរបស់ព្រះសោណត្ថេរ ” ដូច្នេះ ។

ពាក្យថា **ក្នុងបណ្តាឥន្ទ្រិយដ៏សេស** គឺ សូម្បីក្នុងសតិន្ទ្រិយ សមាធិន្ទ្រិយ និង បញ្ញិន្ទ្រិយ ។

ពាក្យថា **បើឥន្ទ្រិយណាមួយ** គប្បីឃើញថា នេះជាពាក្យសម្តែងអធិប្បាយដោយទូទៅចំពោះឥន្ទ្រិយនីមួយៗ ។ លោកអាចារ្យកាលសម្តែងសភាពស្មើគ្នាដោយទាក់ទងនឹងការធ្វើឲ្យថយចុះ ព្រោះក្នុងកាលដែលឥន្ទ្រិយ ៥ មួយៗ មានប្រមាណខ្លាំងក្លាយ៉ាងនេះហើយ ឥឡូវនេះ ក្នុងបណ្តាឥន្ទ្រិយទាំងនោះ លោកបំណងសម្តែងឥន្ទ្រិយដែលមានភាពស្មើគ្នាដែលគប្បីប្រាថ្នាបាន ដោយពិសេស គឺ មិនជាសាធារណៈ និង ជាសាធារណៈ ទើបពោលថា “ តែពោលដោយពិសេស ” ដូច្នេះជាដើម ។

បទថា **ឯត្ថ** បានដល់ ក្នុងឥន្ទ្រិយ៥ទាំងនេះ ។ ពាក្យថា **សភាពស្មើគ្នា** បានដល់ ភាពមិនខ្លាំង មិនខ្សោយជាងគ្នានៃសទ្ធា និង បញ្ញា ។ សមាធិ ជាមួយនឹងវីរិយៈ ក៏ដូចគ្នា ។ ក៏ដូចសេចក្តីថា ការប្រព្រឹត្តទៅមិនលើសគ្នានិងគ្នាដោយកិច្ចនៃសទ្ធា និង បញ្ញា ដែលផ្សេងគ្នា ជាធម៌គូនឹងគ្នា បណ្ឌិតគប្បីប្រាថ្នាដោយពិសេស ព្រោះការដែលធម៌ទាំងពីរនេះមានធុរៈស្មើគ្នា ក៏ជាហេតុ ឲ្យអប្បនាសម្រេចបានយ៉ាងណា បើសមាធិជាចំណែកនៃកោសជ្ជៈ និង វីរិយៈជាចំណែកនៃឧទ្ធច្ចៈ មានកិច្ចស្មើគ្នា អប្បនាក៏សម្រេចបានដោយល្អ ដូច្នោះ ដូចគ្នា ព្រោះសម្បយុត្តធម៌ទាំងឡាយ គ្មានការធ្លាក់ទៅក្នុងចំណែកទាំងពីរដោយការឧបត្ថម្ភដល់គ្នានិងគ្នា ។

ពាក្យថា “ **ពិតហើយ ក្នុងបុគ្គលដែលមានសទ្ធាខ្លាំងក្លា** ” ជាដើម លោកពោលទុក ដោយទំនាក់ទំនងជានិទស្សនៈ ។ ន័យរបស់ពាក្យថា បុគ្គលណាជាអ្នកដល់ព្រមដោយសទ្ធាខ្លាំងក្លា មានបញ្ញាទន់ខ្សោយ បុគ្គលនោះរមែងជាអ្នកជ្រះថ្លាខុសទំនង គឺ មិនមែនជ្រះថ្លាមាំមួន បុគ្គលនោះរមែងជ្រះថ្លាក្នុងវត្ថុដែលមិនសមគួរដូចពួកសាវ័ករបស់តិរ្ថិយ ។

ពាក្យថា( រមែងសេពគប់ជាមួយ ) **ចំណែកមិនត្រង់** គឺ រមែងសេពគប់ជាមួយចំណែកដែលអាក្រក់លាមក ។ សេចក្ដីថា កាលហួសទៅដោយបញ្ញាដែលលះបង់សទ្ធា រមែងនឹងគិតរឿងជាដើមថា “ វៀរចាកការបរិច្ចាគវត្ថុដែលគួរឲ្យហើយ បុណ្យដែលជាទានមយៈ ក៏នឹងមានបាន សូម្បីត្រឹមតែកើតការគិតឡើង ” ដូច្នេះ ទើបជាបុគ្គលលាមក ដោយហេតុមិនត្រឹមត្រូវទាំងឡាយ បុគ្គលរបៀបនេះមានចិត្តត្រូវប្ចូន់យកការទឹកគិតដែលល្អទៅ មិនកាន់យកពាក្យពោលរបស់បណ្ឌិតរមែងមិនដល់នូវភាពស្ចួតបូត ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ ជាអ្នកដែលនរណាៗ ព្យាបាលរោគមិនបាន ដូចរោគដែលកើតព្រោះថ្នាំដូច្នោះ ” ។

ក្នុងបណ្ដាឥន្ទ្រិយទាំងនេះ ការលះបង់គ្នានិងគ្នានៃសទ្ធា និង បញ្ញា រមែងមិននាំមកនូវប្រយោជន៍ តែរមែងនាំមកនូវសេចក្ដីវិនាស យ៉ាងណា សូម្បីក្នុងទីនេះគប្បីជ្រាបថា ការលះបង់គ្នានិងគ្នានៃសមាធិ និងវីរិយៈ រមែងមិននាំមកនូវអវិក្ខេបៈ ( សភាពដែលមិនរាយមាយនៃសមាធិ ប៉ុន្តែនាំមកនូវវិក្ខេបៈ សភាពរាយមាយនៃឧទ្ធច្ចៈ ) ដូច្នោះ អធិប្បាយថា ឈ្មោះថា កោសជ្ជៈ រមែងគ្របសង្កត់ គឺ ព្រះ-យោគាវចរមិនបានសម្រេចអប្បនា ព្រោះកោសជ្ជៈនោះ ។ សូម្បីក្នុងពាក្យថា ឧទ្ធច្ចៈ រមែងគ្របសង្កត់ ក៏មានន័យនេះឯង ។ ពាក្យថា **ឥន្ទ្រិយទាំង២នោះ** បានដល់ឥន្ទ្រិយទាំង ២ គឺ សទ្ធា និង បញ្ញា និង ឥន្ទ្រិយទាំង ២ គឺ សមាធិ និង វីរិយៈនោះ ។ ពាក្យថា **គួរធ្វើឲ្យស្មើគ្នា** គឺ គួរធ្វើឲ្យមានរស ( កិច្ច ) ស្មើគ្នា ។

ពាក្យថា **សម្រាប់ព្រះយោគីអ្នកជាសមាធិកម្មិកៈ** គឺសម្រាប់ព្រះយោគីដែលចម្រើនសមថកម្មដ្ឋាន ។ ពាក្យថា **ឯវំ** ប្រែថា កាលបើយ៉ាងនេះ មានន័យថា បើសទ្ធាមានកម្លាំងជាងឥន្ទ្រិយទាំងនោះ ។ ពាក្យថា **អ្នកជឿ** គឺ អ្នកមិនបានគិតថា

ដោយត្រឹមតែធ្វើទុកក្នុងចិត្តថា **បឋវី បឋវី** ដូច្នេះ នឹងកើតឈានបានយ៉ាងណា ជឿហើយ គឺ ធ្វើសទ្ធាឲ្យកើតឡើងថា " វិធី ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុក នឹងសម្រេចបានយ៉ាងពិតប្រាកដ " ដូច្នេះ ។ ពាក្យថា **ដាក់ចិត្តហើយ** បានដល់ ដាក់ចិត្តហើយ គឺ ស្ទុះទៅដោយអំណាចបង្អោនចិត្តទៅ ដូចតាមអារម្មណ៍ចូលទៅ ដូច្នោះ ។

ឈ្មោះថា ឯកគ្គតាដែលមានកម្លាំងល្មមប្រើបាន ព្រោះឈានមានសមាធិជាប្រធាន ។

ពាក្យថា ឥន្ទ្រិយទាំង២ បានដល់ សមាធិនិងបញ្ញា សូម្បីភាវៈដែលសមាធិមានប្រមាណក្រៃលែង ក៏គប្បីប្រាថ្នាបានចំពោះព្រះយោគីដែលជា សមាធិកម្មិកៈ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " **សមតាយបិ** " , សេចក្ដីថា **សមភាវេនាបិ** ( សូម្បីព្រោះភាពដែលឥន្ទ្រិយទាំង២ស្មើគ្នា ) ។

ពាក្យថា **អប្បនា** បានដល់ អប្បនាដែលបំណងក្នុងទីនេះ ។ ពិតដូច្នោះ លោកពោលពាក្យដែលមានប្រការគួរសង្ស័យថា " **ហោតិយេវ** " រមែងមានបានតែម្យ៉ាង ដូច្នេះ ចំណែកលោកុត្តរអប្បនា ក៏ប្រាថ្នាបានដោយភាវៈដែលឥន្ទ្រិយទាំងនោះស្មើគ្នា ដូចគ្នា ។ ដូចដែលព្រះអានន្ទត្ថេរពោលទុកថា " រមែងចម្រើនសមថៈ និង វិបស្សនា ឲ្យស្របគ្នា ជាគូ " ដូច្នេះ ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា បើពោលដោយពិសេស ប្រាថ្នាសេចក្ដីស្មើគ្នានៃ សទ្ធានិងបញ្ញា និង នៃសមាធិនិងវីរិយៈ បានសោត តើសតិទៅជាយ៉ាងណា ដូច្នេះហើយទើបពោលថា " ចំណែកសតិមានកម្លាំងរមែងគួរក្នុងឥន្ទ្រិយទាំងពួង " ដូច្នេះ ។

បទថា **សព្វត្ថ** បានដល់ ក្នុងឥន្ទ្រិយ ៥ ដែលជាបក្ខពួកនៃសេចក្ដីខ្ជិលច្រអូស និង សេចក្ដីរាយមាយ ។ លោកអាចារ្យកាលនឹងកាន់យកចំណែកមួយនៃឥន្ទ្រិយដែលជាបក្ខពួកនៃសេចក្ដីរាយមាយ ទើបពោលថា “ ( ព្រោះអំណាច )នៃសទ្ធា វិរិយៈ និង បញ្ញា ” ដូច្នេះ ។

បើនឹងកាន់យកសេចក្ដីដោយប្រការមួយទៀត ក៏នឹងត្រូវកាន់យកបីតិផង ( ថាជាបក្ខពួកនៃសេចក្ដីរាយមាយ ) ។ ព្រោះថា លោកកាន់យកចំណែកមួយនៃឥន្ទ្រិយដែលជាបក្ខពួកនៃកោសជ្ជៈ ពោលទុកយ៉ាងនេះដូចគ្នាថា “ ព្រោះសមាធិជាបក្ខពួកនៃកោសជ្ជៈ ” ដូច្នេះ ។ មិនបានពោលថា “ ព្រោះបស្សទ្ធិ សមាធិ និង ឧបេក្ខា ” ដូច្នេះ ។ បទថា **សា** បានដល់ សតិ ។ អមាត្យអ្នកប្រកបក្នុងការងារទាំងពួងរបស់ព្រះរាជា ឈ្មោះថា **សព្វកម្មិក** ( អ្នកធ្វើការងារទាំងពួង ) ។ ព្រោះហេតុនោះ គឺ ព្រោះអត្ថថា គួរប្រាថ្នាក្នុងឥន្ទ្រិយទាំងពួង ។ ទើបព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថា ។

**សតិ** ដែលប្រកបក្នុងឥន្ទ្រិយទាំងពួង ឈ្មោះថា **សព្វត្ថិកា** ឬថា សតិដែលឥន្ទ្រិយជាបក្ខពួកនៃសេចក្ដីខ្ជិលច្រអូស និងសេចក្ដីរាយមាយទាំងពួង គប្បីត្រូវការដោយការកាន់យកជាពោជ្ឈង្គៈ ឈ្មោះថា **សព្វត្ថិយា** , **សព្វត្ថិយា** នោះឯងជា **សព្វត្ថិកា** ។ ពាក្យថា **ចិត្ត** បានដល់ កុសលចិត្ត ។ ពិតហើយ កុសលចិត្តនោះ

ឈ្មោះថា **មានសតិនោះជាគ្រឿងការពារ** គឺ ជាទីទៅខាងមុខ ដើម្បីការដល់នូវគុណវិសេសដែលមិនទាន់បានសម្រេច ។ ព្រោះហេតុនោះ ទើបលោកពោលថា “ សតិមានការរក្សាទុកបានជាផល ” ដូច្នេះជាដើម ។

បទថា **ចិត្តេកគ្គតានិមិត្តស្ស** ប្រែថា និមិត្តនៃចិត្តេកគ្គតា ( និមិត្តនៃចិត្តមាន

អារម្មណ៍តែ១ ) ក៏បាន , ប្រែថា និមិត្តដែលហៅថា **ចិត្តេកគ្គតា** ក៏បាន ។ ពិតហើយ ព្រះយោគីកាលកំណត់អាការដែលតាំងមាំនៃចិត្ត រក្សាសមថនិមិត្តនោះឯងឈ្មោះថា រក្សាកសិណនិមិត្តទុក ។ ព្រោះដូច្នោះដោយ **អាទិ** ស័ព្ទ ( ដែលប្រែថាជាដើម ) ក្នុងបទថា **បឋវីកសិណាទិកស្ស** ( មានបឋវីកសិណជាដើម ) មិនគប្បីឃើញថា កាន់យកចំពោះបដិភាគនិមិត្តតែម្យ៉ាងប៉ុណ្ណោះ តែថាកាន់យកសមថនិមិត្តផង ។ បទថា **តំ** បានដល់ ភាពឆ្លាតក្នុងការរក្សា ។ ក្នុងទីនេះ គឺ ក្នុងកថាពោលដោយអប្បនាកោសល្យ លោកបំណងយកថាជា " ភាពឆ្លាតក្នុងនិមិត្ត " អធិប្បាយថា ព្រោះភាពឆ្លាតក្នុងការធ្វើនិមិត្ត និង ភាពឆ្លាតក្នុងការចម្រើននិមិត្ត សម្រេចទៅមុនហើយ ។

ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **អតិសិថិលវីរិយតាទីហិ** ( ព្រោះហេតុ មានការព្យាយាមទន់ខ្សោយពេកជាដើម ) សង្គ្រោះយកហេតុផ្ទុយគ្នា និងហេតុដែលធ្វើឲ្យរីករាយ និងធ្វើឲ្យតក់ស្លុតទាំងឡាយ ។

បទថា **លីនំ** ( រួញរា ) គឺ នឿយណាយ បានដល់ ធ្លាក់ទៅក្នុងចំណែកនៃកោសជ្ជៈ ។ ពាក្យថា **ចិត្ត** បានដល់ ភាវនាចិត្ត ។

ក្នុងបទថា **ធម្មវិចយសម្ពោជ្ឈង្គាទយោ ភាវេតិ** នេះ គួរនាំបទថា "**តយោ**" ចូលមកភ្ជាប់ទុក ( គឺ ប្រែថា ចម្រើនពោជ្ឈង្គៈ ៣ មានធម្មវិចយសម្ពោជ្ឈង្គៈជាដើម ) ។ ក៏លោកអាចារ្យនឹងពោលអាការដែលគួរចម្រើនពោជ្ឈង្គៈ ទាំងនោះឯងតែម្យ៉ាង ។

បទថា **បរិត្តំ** ប្រែថា តូច ។ ពាក្យថា **ជាអ្នកប្រាថ្នានឹងធ្វើឲ្យប្រាកដឡើង** គឺ ជាអ្នកប្រាថ្នានឹងធ្វើឲ្យច្បាស់ឡើង ។ ពាក្យថា **គប្បីឲ្យខ្យល់លាយទឹក** គឺ គប្បីបក់

ខ្យល់ដែលលាយដោយទឹកចូលទៅ ។ បទថា **អកាលោ** ប្រែថា មិនមែនវេលា ឬប្រែថា វេលាដែលមិនសមគួរ ។ ឈ្មោះថា **ពោជ្ឈង្គៈ** ព្រោះអត្ថថា ជាអង្គនៃពោធិ ពោលគឺ ធម្មសាមគ្គី មានសតិជាដើម ធ្វើសេចក្តីថា ជាហេតុត្រាស់ដឹង , ម្យ៉ាងទៀត ឈ្មោះថា **ពោជ្ឈង្គៈ** ព្រោះអត្ថថា ជាអង្គនៃព្រះយោគីដែលព្រមព្រៀងដោយធម្មសាមគ្គី មានសតិជាដើមនោះ ដែលជាអ្នកបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹងពោជ្ឈង្គៈដ៏ប្រសើរ ឬថាល្អស្អាត ឈ្មោះថា **សម្ពោជ្ឈង្គៈ** ។

**សម្ពោជ្ឈង្គៈ** គឺ បស្សទ្ធិដែលមានការចូលទៅស្ងប់សេចក្តីខ្វល់ខ្វាយនៃកាយនិង ចិត្ត ជាលក្ខណៈនោះឯង ឈ្មោះថា **បស្សទ្ធិសម្ពោជ្ឈង្គៈ** បានដល់ បស្សទ្ធិ-សម្ពោជ្ឈង្គៈនោះ ។ សូម្បីសមាធិសម្ពោជ្ឈង្គៈជាដើម ក៏មានន័យដូច្នេះឯង ។

តទៅនេះជាសេចក្តីផ្សេងទៀត ជាដំបូងអត្ថនៃបទ និង លក្ខណៈនៃសមាធិមានមកក្នុងបទមុនហើយ ។

ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា ឃើញតាមដែលឧប្បត្តិ ។ ក៏ឧបេក្ខានេះដោយសភាវៈ បានដល់ តត្រមជ្ឈត្តុបេក្ខានោះឯង គប្បីជ្រាបថា ឈ្មោះថា **ពោជ្ឈង្គុបេក្ខា** ក្នុងទីនេះ ។

ពាក្យថា **ជាធម្មជាតិដែលភិក្ខុគប្បីធ្វើឲ្យកើតឡើងបានដោយលំបាក** គឺ ភិក្ខុមិនអាចធ្វើឲ្យកើតឡើងបាន ។ ការវិច័យនូវធម៌ទាំងឡាយ ឬ ក្នុងធម៌ទាំងឡាយ ឈ្មោះថា **ធម្មវិចយ** សេចក្តីថា បានដល់ បញ្ញា ។ ភាវៈ ឬ ការធ្វើរបស់បុគ្គលក្លៀវក្លា ឈ្មោះថា **វីរិយៈ** , ម្យ៉ាងទៀត ឈ្មោះថា **វីរិយៈ** ព្រោះអត្ថថា ដែលបុគ្គលគប្បីធ្វើឲ្យទៅ គឺ ឲ្យប្រព្រឹត្តទៅដោយវិធី បានដល់ ការឧស្សាហ៍ ។ ឈ្មោះថា **បីតិ** ព្រោះអត្ថថា រីករាយ គឺ ធ្វើឲ្យកាយ និង ចិត្ត រីករាយ ។

របស់ខ្លួនៗ ឈ្មោះថា **យថាសកំ** ស្មើនឹង **អត្តនោ អត្តនោ** ។ ពាក្យថា **ដោយទាក់ទងនឹងអាហារ** គឺ ដោយទាក់ទងនឹងបច្ច័យ ។ ពាក្យថា **ការបម្រើន** បានដល់ ការធ្វើឲ្យកើតឡើង និង ការបម្រើន ។ ពាក្យថា **ដែលជាកុសល** និង អកុសល មានន័យថា ឈ្មោះថា **កុសល** ព្រោះអត្ថថា កើតពីភាពឆ្លាត , ឈ្មោះថា **អកុសល** ព្រោះជាបដិបក្ខចំពោះកុសលនោះ ។ ធម៌ទាំងឡាយណាជាអកុសល ធម៌ទាំងឡាយនោះឈ្មោះថា មានទោស ។ ធម៌ទាំងឡាយណាជាកុសល ធម៌ទាំងឡាយនោះឈ្មោះថា មិនមានទោស ។

**អកុសល** ឈ្មោះថា **ថោកទាប** ក្រៅពីនេះឈ្មោះថា ប្រណីត ។

ម្យ៉ាងទៀត ធម៌ទាំងឡាយ សូម្បីជាកុសលដែលបុគ្គលប្រារព្ធដោយឆន្ទៈជាដើម ថោកទាប ឈ្មោះថា ថោកទាប ក្រៅពីនេះឈ្មោះថា ប្រណីត ។ បទថា **កណ្ហា** ប្រែថា ខ្មៅ បានដល់ ធ្វើភាពមិនផូរផង់ឲ្យដល់ចិត្ត ។ បទថា **សុក្កា** ប្រែថា ស បានដល់ ធ្វើភាពផូរផង់ឲ្យដល់ចិត្ត ។ ម្យ៉ាងទៀត ឈ្មោះថា **ខ្មៅ** ព្រោះជាហេតុនាំឲ្យកើតបាប , ឈ្មោះថា **ស** ព្រោះជាហេតុនាំឲ្យកើតបុណ្យ ។ ធម៌ទាំងឡាយនោះៗ ឈ្មោះថា មានចំណែកប្រៀប ។

ម្យ៉ាងទៀត ធម៌ខ្មៅ ឈ្មោះថា មានចំណែកប្រៀបជាមួយធម៌ស ដោយភាពជាសត្រូវដោយត្រង់ ។ យ៉ាងនោះដូចគ្នា សូម្បី ធម៌ស ក៏ឈ្មោះថា មានចំណែកប្រៀបជាមួយធម៌ ក្រៅពីនេះ ។ ន័យម្យ៉ាងទៀត ធម៌ខ្មៅផង ធម៌សផង ធម៌ដែលមានចំណែកប្រៀបគ្នាបានផង ឈ្មោះថា **កណ្ហសុក្កសប្បដិភាគា** ។ ពិតហើយ សុខវេទនា ឈ្មោះថាមានចំណែកប្រៀបគ្នាបាន ជាមួយទុក្ខវេទនា ហើយទុក្ខវេទនាក៏ឈ្មោះថា មានចំណែកប្រៀបគ្នាបានជាមួយសុខវេទនាដែរ ។ ពាក្យថា **ដែលនៅ**

**មិនទាន់កើតឡើង** បានដល់ ដែលនៅមិនទាន់កើត ។ ពាក្យថា **ដើម្បីការកើតឡើង** គឺ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យកើតឡើង ។ ពាក្យថា **ដែលកើតឡើងហើយ** គឺ ដែលបង្កើតហើយ ។ ពាក្យថា **ដើម្បីភាពក្រៃលែងឡើងទៅ** គឺ ដើម្បីការកើតឡើងរឿយៗ ។ បទថា **វេបុល្លាយ** ប្រែថា ដើម្បីភាពពេញលេញ ។ បទថា **ភាវនាយ** ប្រែថា ដើម្បីសេចក្តីចម្រើន ។ ពាក្យថា **ដើម្បីភាពបរិបូរណ៍** គឺ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យពេញ ។ បទថា **តត្ថ**( ក្នុងព្រះបាលីនោះ ) គឺ ក្នុងបាឋៈដែលទ្រង់សម្តែងទុកដោយពាក្យថា “ **អត្ថិ ភិក្ខវេ** ” ជាដើម ។ ពាក្យថា **ដោយទាក់ទងនឹងការចាក់ធ្លុះសភាវលក្ខណៈនិងសាមញ្ញលក្ខណៈ** គឺ ដោយទាក់ទងនឹងការចាក់ធ្លុះសភាវលក្ខណៈ មានលក្ខណៈដែលមិនមានទោស និងមានវិបាកជាសុខជាដើម ក្នុងការកាន់យករួមជាចំណែកជាមួយគ្នា ចំណែកការកាន់យកបែកពីគ្នា ក៏បានដល់ ដោយទាក់ទងនឹងការចាក់ធ្លុះសភាវលក្ខណៈ មានលក្ខណៈដែលប៉ះខ្ទប់ជាដើម និងដោយទាក់ទងក្នុងការចាក់ធ្លុះសាមញ្ញលក្ខណៈ មានលក្ខណៈមិនទៀងជាដើម ។

ពាក្យថា **មនសិការដែលប្រព្រឹត្តទៅ** បានដល់ ជវនចិត្តុប្បាទដែលកើតឡើងដោយទាក់ទងនឹងការដឹងតាមសេចក្តីពិត នូវលក្ខណៈ មានសភាវលក្ខណៈជាដើមនោះៗ នៃកុសលធម៌ជាដើម ។

ពិតហើយ ជវនចិត្តុប្បាទនោះ លោកហៅថា **យោនិសោមនសិការ** ព្រោះជាការធ្វើទុកក្នុងចិត្តមិនវិបរិត ។ សូម្បីអាវជ្ជនៈ ក៏មានគតិជាយោនិសោមនសិការនោះៗឯង ព្រោះភាវៈដែលនឹកភាវរកក្នុងវេលានោះ ។ សូម្បីលក្ខណៈ មានលក្ខណៈដែលរូបបែកធ្លាយជាដើម បណ្ឌិតគប្បីឃើញថា ក្នុងទីនេះ លោកសង្គ្រោះចូល

ដោយសាមញ្ញលក្ខណៈនោះឯង ។ សេចក្ដីព្យាយាមដែលប្រព្រឹត្តទៅដោយទាក់ទងនឹងការប្រារព្ធខាងដើមនូវការធ្វើកុសល លោកហៅថា " **ធាតុ** " ព្រោះមានការទ្រទ្រង់ទុកជាសភាវៈ ព្រោះហេតុនោះ ទើបលោកពោលថា " សេចក្ដីព្យាយាមជាដំបូង ត្រាស់ហៅថា **អារម្ភធាតុ** " ។

សេចក្ដីព្យាយាមដែលសេពរហូតជាប់ ជាធម្មជាតិមានកម្លាំង រមែងញាំញីធម៌ដែលជាបដិបក្ខបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " សេចក្ដីព្យាយាមដែលមានកម្លាំងខ្លាំងក្លាជាង អារម្ភធាតុនោះ ទ្រង់ត្រាស់ហៅថា **និក្កមធាតុ** ព្រោះឈានកន្លងនូវការខ្ជិលច្រអូសបាន " ។ សេចក្ដីព្យាយាមដែលអាចញាំញីធម៌ដែលជាបដិបក្ខទាំងឡាយ ដែលមានប្រមាណក្រៃលែង និងមានប្រមាណក្រៃលែងឡើងៗ រមែងជាធម្មជាតិដែលដល់នូវភាពក្លៀវក្លា និងក្លៀវក្លាក្រៃលែងឡើងៗ ព្រោះហេតុនោះ ទើបលោកពោលថា សេចក្ដីព្យាយាមដែលមានកម្លាំងខ្លាំងជាងនិក្កមធាតុនោះ ទ្រង់ត្រាស់ហៅថា **បរក្កមធាតុ** ព្រោះជាការចុះកាន់ឋានៈកាត់ផ្ដាច់បាន " ។ ធម៌ទាំងឡាយឈ្មោះថា **ឋានិយា** ព្រោះអត្ថថា ជាទីតាំង គឺ ជាទីប្រព្រឹត្តទៅ , ទីតាំងនៃបីតិសម្ពោជ្ឈង្គៈ ឈ្មោះថា **បីតិសម្ពោជ្ឈង្គដ្ឋានិយា** ។ ម្យ៉ាងទៀត ធម៌ដែលគួរតាំងទុក ឈ្មោះថា **ឋានិយា** បីតិសម្ពោជ្ឈង្គៈ ជាធម៌ដែលគួរតាំងទុកក្នុងធម៌ទាំងនេះ ព្រោះហេតុនោះ ធម៌ទាំងនេះទើបឈ្មោះថា **បីតិសម្ពោជ្ឈង្គដ្ឋានិយា** បានដល់ ធម៌ទាំងឡាយដែលសម្បយុត្តជាមួយបីតិសម្ពោជ្ឈង្គៈដែលកំពុងប្រព្រឹត្តទៅបន្តគ្នា ។ ប៉ុន្តែព្រោះហេតុដែលក្នុងបណ្ដាធម៌ទាំងនោះ បីតិនោះឯងជាហេតុវិសេសនៃបីតិសម្ពោជ្ឈង្គៈ ព្រោះដូច្នោះ ទើបលោកពោលថា " ពាក្យថា ធម៌ទាំងឡាយ ។ល។ បីតិសម្ពោជ្ឈង្គៈនេះ ក៏ជាឈ្មោះរបស់បីតិនោះឯង " ។

ពាក្យថា **មនសិការដែលធ្វើឲ្យបីតិកើតឡើង** បានដល់ មនសិការដែលប្រព្រឹត្តទៅដល់យោគីអ្នកមនសិការដោយប្រការដែលបីតិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើតឡើង រមែងកើតឡើង និងដែលកើតឡើងហើយ រមែងចម្រើន ។ ពាក្យថា **ភាពជាអ្នកសាកសួរ** បានដល់ ភាពជាអ្នកសិក្សាហើយសួរ ។ ពិតហើយ កាលព្រះយោគីអង្គុយជិតអាចារ្យ រៀននិកាយទាំង៥ហើយ សាកសួរអត្ថនៃពាក្យនោះៗ ឬថា សិក្សានិកាយនោះៗ ព្រមទាំងអដ្ឋកថា ហើយឋានៈដែលមានការងឿងឆ្ងល់ក្នុងនិកាយនោះ សួរដល់ឋានៈដែលងឿងឆ្ងល់នោះៗថា " លោកដ៏ចម្រើន សេចក្តីនេះ តើដូចម្តេច ? អ្វីជាអត្ថរបស់ពាក្យនេះ " ដូច្នេះ ធម្មវិចយសម្ពោជ្ឈង្គៈ រមែងកើតឡើង ។

ការធ្វើវត្ថុឲ្យបរិសុទ្ធ ការសម្រួលឥន្ទ្រិយឲ្យមានភាពស្មើគ្នា លោកបានប្រកាសទុកដោយសង្ខេប និង ដោយពិស្តារហើយ ។ តែថា ក្នុងទីនេះ មានហើយដោយភាពជាកិច្ច ដែលគួរធ្វើឲ្យប្រព្រឹត្តទៅព្រមដើម្បីសមាធិ , ក្នុងទីនេះ មានហើយដោយភាពជាកិច្ច ដែលគួរធ្វើឲ្យប្រព្រឹត្តទៅព្រមដើម្បីបញ្ញា ។

ពិតហើយ ការធ្វើវត្ថុឲ្យបរិសុទ្ធ និង ការសម្រួលឥន្ទ្រិយឲ្យមានភាពស្មើគ្នា មានការប្រព្រឹត្តទៅព្រមដើម្បីសមាធិបាន ព្រោះហេតុណា ក៏មានការប្រព្រឹត្តទៅព្រមដើម្បីបញ្ញាបានព្រោះហេតុនោះ , ព្រោះសមាធិមានបញ្ញា ជាផល ។

សមពិតដូចទ្រង់ត្រាស់ទុកថា " **សមាហិតោ យថាភូតំ បជានាតិ** " ភិក្ខុដែលមានចិត្តតាំងមាំហើយ រមែងដឹងច្បាស់បានតាមសេចក្តីពិត ។ ឈ្មោះថា **ការវៀរចាកបុគ្គលដែលមានបញ្ញាទន់ខ្សោយ** បានដល់ ការវៀរចាកឲ្យឆ្ងាយពីបុគ្គលវង្វេង បញ្ញាទន់ខ្សោយ គឺ មានការដឹងដ៏ទន់ខ្សោយ ដូចក្អែកដែលជាប់ក្នុងអាហារ

ឬ ដូចសុនខដែលជាប់នៅក្នុងដុំសាច់ ។ ឈ្មោះថា **ការសេពគប់បុគ្គលដែលមានបញ្ញា** បានដល់ ការចូលទៅរកតាមកាលដែលគួរ នូវព្រះអរិយបុគ្គលជាម្ចាស់ទាំងឡាយ អ្នកបានសាងបុញ្ញាធិការទុកក្នុងបញ្ញា ឆ្លាតក្នុងធម៌ មាន សច្ចៈ និង បដិច្ចសមុប្បាទជាដើម ឬលោកដែលប្រកបការងារក្នុងវិបស្សនា ដែលជាអ្នកមានបញ្ញាច្រើនទាំងឡាយ ។ ពាក្យថា **ការពិចារណាធម៌ ដែលញាណដ៏ជ្រាលជ្រៅគប្បីត្រាច់ទៅ** គឺ ការពិចារណាធម៌ទាំងឡាយដែលជាទីគោចររបស់ញាណដ៏ជ្រាលជ្រៅ ដែលបានដល់ ធម៌ទាំងឡាយ មាន ខន្ធ អាយតនៈ ធាតុ ជាដើម ឬ បានដល់ ព្រះសូត្រដែលមានសម្តែងសច្ចៈ និង បច្ចយាការជាដើម ទាក់ទងនឹងសុញ្ញតា ។

ពាក្យថា **ការបង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ** បានដល់ ការបង្អោនចិត្តទៅក្នុងបញ្ញា មានន័យថា ការទេរទៅ ឱនទៅ ទោរទៅ ក្នុងបញ្ញានោះ ។

ដោយ **អាទិ** ស័ព្ទ( ប្រែថា ជាដើម ) ក្នុងពាក្យថា **អបាយាទិ** ( ភ័យមានអបាយជាដើម ) សង្គ្រោះយកទុក្ខមានជាតិជាដើម ( ជាតិ ជរា ព្យាធិ មរណៈ ) ទុក្ខដែលមានវដ្តៈជាមូល ក្នុងអតីត ទុក្ខដែលមានវដ្តៈជាមូលក្នុងអនាគត និងទុក្ខដែលមានការស្វែងរកអាហារជាមូល ក្នុងបច្ចុប្បន្ន ។ ការសម្រេចគុណវិសេសដែលជាលោកិយ និង លោកុត្តរ ទាក់ទងនឹងការព្យាយាមនោះឯងជាអានិសង្ស , ភាពជាអ្នកមានប្រក្រតីសម្លឹងឃើញអានិសង្សនោះ ឈ្មោះថា **វីរិយាយត្ត** ។ បេ ។ **ទស្សិតា** ។ មគ្គដែលជាហេតុឲ្យដល់ព្រះនិព្វាន ព្រមទាំងខបដិបត្តិជាចំណែកខាងដើម ឈ្មោះថា ផ្លូវធ្វើដំណើរ ព្រោះធ្វើអត្ថាធិប្បាយថា ជាបដិបទាដែលគួរដើរ គឺគួរបដិបត្តិ ។ ពាក្យថា **ការគោរពកោតក្រែងចំពោះបិណ្ឌបាត ដោយការធ្វើឲ្យមានផលច្រើនដល់ទាយកទាំងឡាយ** បានដល់ ការបូជាតបចំពោះដុំបាយ គឺ កិក្ខា

ដោយការធ្វើសក្ការៈចំពោះខ្លួន គឺ ការបដិបត្តិត្រូវរបស់ខ្លួន រមែងសាងផលដ៏ច្រើនសន្ទឹកសន្ធាប់ដល់បុគ្គលដែលថ្វាយបច្ច័យទាំងឡាយ ។ ពាក្យថា **ដោយប្រការក្រៅពីនេះ** គឺ ដោយអាមិសបូជា ។ ពាក្យថា **ការវៀរចាកបុគ្គលខ្ជិលច្រអូស** គឺ ការវៀរចាកឲ្យឆ្ងាយអំពីបុគ្គលដែលខ្ជិលច្រអូសទាំងឡាយ អ្នកមិនដឹងសូម្បីត្រឹមតែឈ្មោះរបស់ការនៅ អ្នកច្រើនដោយការធ្វើរាងកាយឲ្យមាំទាំ អ្នកបរិភោគតាមដែលត្រូវការ ហើយប្រកបរឿយៗនូវសុខក្នុងការដេកជាដើម អ្នកពោលតិរច្ឆានកថា ។ ពាក្យថា **ការសេពគប់បុគ្គលដែលប្រារព្ធសេចក្ដីព្យាយាម** បានដល់ ការចូលទៅរកតាមកាលដែលគួរ ចំពោះបុគ្គលអ្នកប្រារព្ធសេចក្ដីព្យាយាម អ្នកមានសេចក្ដីព្យាយាមឈានមុខដ៏មាំទាំ ដោយទាក់ទងនឹងការប្រារព្ធការនៅតាមដែលទ្រង់ត្រាស់ទុកថា “ **ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ រមែងជម្រះចិត្តឲ្យបរិសុទ្ធចាកនីវរណធម៌ទាំងឡាយ ដោយចង្ក្រម ដោយការអង្គុយអស់ទាំងថ្ងៃ** ” ដូច្នេះជាដើម ។

ពាក្យថា **ការពិចារណាសម្មប្បធាន** បានដល់ ការពិចារណាអានុភាពនៃសម្មប្បធាន ៤ យ៉ាង ។

បទថា **តទធិមុត្តតា** ប្រែថា ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ បានដល់ ការទោរទៅ ឱនទៅ ទោរទៅក្នុង(វីរិយៈនោះ) គ្រប់ឥរិយាបថទាំងពួង ។

ម្យ៉ាងទៀតក្នុងអធិការនេះ គប្បីឃើញថា ការបន្ទោបង់ថីនមិទ្ធៈ ការវៀរចាកបុគ្គលដែលខ្ជិលច្រអូស ការសេពគប់អ្នកប្រារព្ធសេចក្ដីព្យាយាម និងការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ ជាតួធ្វើឲ្យវីរិយសម្ពោជ្ឈង្គៈកើតឡើង ដោយទាក់ទងនឹងការបង្អោនយកបច្ច័យសម្រាប់ញ៉ាំងធម៌ដែលជាបដិបក្ខចូលទៅ ការពិចារណា

នូវភ័យ មានអបាយជាដើម ជាតួធ្វើឲ្យវីរិយសម្ពោជ្ឈង្គៈ កើតឡើងដោយទាក់ទងនឹងការជំរុញ ។

បុគ្គលដែលមានចិត្តសៅហ្មង ព្រោះគ្មានចិត្តជ្រះថ្លា និង ការស្រឡាញ់ពេញចិត្តក្នុងវត្ថុដែលគួរជ្រះថ្លា មានព្រះពុទ្ធជាដើម ឈ្មោះថា បុគ្គលដែលសៅហ្មង គប្បីជ្រាបថា បុគ្គលដែលជ្រះថ្លា មានដោយពាក្យបរិយាយដែលផ្ទុយគ្នា ដូចពោលមកហើយ ។ ព្រះសូត្រទាំងឡាយមាន **សម្បសាទនីយសូត្រ** ជាដើម ដែលមានការសម្តែងគុណរបស់ព្រះសម្ពុទ្ធជាដើម ឈ្មោះថា ព្រះសូត្រដែលគួរជ្រះថ្លា ។

ពាក្យថា **ដោយអាការទាំងនេះ** គឺ ដោយអាការទាំងឡាយ មានការចាក់ធ្លុះសភាវលក្ខណៈ និងសាមញ្ញលក្ខណៈជាដើមនៃធម៌ទាំងឡាយ មានកុសលជាដើម និងដោយអាការទាំងឡាយ មានភាពជាអ្នកសាកសួរជាដើម តាមដែលបានពោលហើយ ។ ពាក្យថា **ធម៌ទាំងឡាយនេះ** បានដល់ ធម៌ មានយោនិសោមនសិការជាដើម ក្នុងធម៌មានកុសលជាដើម និងធម៌ មានភាពជាអ្នកដឹងធម៌និងអត្ថជាដើម។

ពាក្យថា **ព្រោះសេចក្តីព្យាយាមដែលប្រារព្ធខ្លាំងពេកជាដើម** គឺ ព្រោះសេចក្តីព្យាយាមដែលផ្គងឡើងហួសប្រមាណជាដើម ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) សង្គ្រោះយកការធ្វើឲ្យភ័យខ្លាច និង ការធ្វើឲ្យរីករាយជាដើម ។

ពាក្យថា **រាយមាយ** បានដល់ មិនស្ងប់ ព្រោះធម៌ទាំងឡាយ មានសមាធិជាដើម ទន់ខ្សោយ ។ ពាក្យថា **ធ្វើឲ្យស្ងប់បានដោយលំបាក** គឺ មិនអាចធ្វើឲ្យស្ងប់ គឺ មិនអាចធ្វើឲ្យតាំងមាំបាន ។ ពាក្យថា **ព្រោះកំណត់អាការនោះបាន** មានន័យថា ធម៌ទាំងឡាយមានបស្សទ្ធិជាដើម ទាំងនេះគឺ បស្សទ្ធិ សមាធិ ឧបេក្ខា ធ្លាប់កើតឡើងក្នុងកាលមុនៗ តាមសមគួរដល់ព្រះយោគាវចរនេះ បានដោយអាការណា

( មនសិការដែលប្រព្រឹត្តទៅ ) ព្រោះចូលទៅកំណត់ទុក ចូលទៅទ្រទ្រង់ទុកនូវអាការដែលស្ងប់រំងាប់ អាការដែលតាំងមាំ និង អាការដែលព្រងើយៗនោះ នៃចិត្ត និង ធម៌ដែលសម្បយុត្តជាមួយចិត្តនោះ ។ ពាក្យថា **ក្នុងបទទាំង៣** គឺ ក្នុងពាក្យទាំង៣ ដែលមានហើយ ដោយពាក្យថា " **ម្នាលភិក្ខុទាំងឡាយ កាយបស្សទ្ធិមានហើយ** " ជាដើម ឬក្នុងចំណែកនៃធម៌៣ដែលទ្រង់ប្រកាសទុកដោយពាក្យទាំងឡាយនោះ ។ **សមថៈ** ដែលព្រះយោគីកាន់យកហើយ ព្រោះកំណត់អាការតាមដែលតាំងមាំបានហើយនោះឯង ឈ្មោះថា **សមថនិមិត្ត** ព្រោះហេតុនោះ ទើបលោកពោលថា " ពាក្យថា **សមថនិមិត្តនេះ** ជាឈ្មោះ របស់សមថៈនោះឯង " ។

ឈ្មោះថា **ព្យគ្គ** ព្រោះអត្ថថា មានអារម្មណ៍ច្រើនយ៉ាង ព្រោះរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ បានដល់ សេចក្តីរាយមាយ ។ ពិតហើយ សេចក្តីរាយមាយនោះ លោកពោលថា មានការមិនតាំងមាំជារស និង មានការរាយមាយជាអាការប្រាកដ ។ ឈ្មោះថា **អព្យគ្គ** ព្រោះអត្ថថា ជាបដិបក្ខដល់ **ព្យគ្គ** ដោយមានភាពជាឯកគ្គតា បានដល់ សមាធិ ។ គួរពោលដូចក្នុងផ្នែកមុនថា សមាធិនោះៗ ឯងឈ្មោះថា និមិត្ត ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " ពាក្យថា **អព្យគ្គនិមិត្ត** ក៏ជាឈ្មោះរបស់សមថៈនោះឯង ដោយន័យថា មិនរាយមាយ " ដូច្នេះ ។

អាហារដែលប្រណីត ដែលព្រះយោគីជ្រាបខកំណត់រាងកាយ ហើយបរិភោគល្មមប្រមាណ រមែងជាបច្ច័យដល់បស្សទ្ធិ ដោយការធ្វើកាយលហុតា ( ការស្រាលកាយ ) ជាដើម ឲ្យតាំងឡើង ។ ឧតុដែលជាសប្បាយ និង ឥរិយាបថដែលជាសប្បាយ ដែលព្រះយោគីសេពហើយ និង ការព្យាយាមផ្លូវកាយដែល

ព្រះយោគីធ្វើឲ្យប្រព្រឹត្តទៅ ក៏រមែងជាបច្ច័យដល់បស្សទ្ធិ ដោយអាការនោះដូចគ្នា ព្រោះហេតុ នោះ ទើបលោកពោលថា “ ការសេពភោជនដែលប្រណីត ” ដូច្នេះ ជាដើម ។ បុគ្គលអ្នកមាន កាយ និង ចិត្ត រសាប់រសល់ ព្រោះមិនល្មមក្នុងការ ប្រកបសេចក្តីព្យាយាមជាដើម ឈ្មោះថា **សារទ្ធបុគ្គលា** បុគ្គលអ្នករសាប់រសល់ ( ក្នុង វិសុទ្ធិមគ្គជា **សារទ្ធកាយបុគ្គលា** បុគ្គលដែលមានកាយរសាប់រសល់ ) ។

គប្បីជ្រាបថា បុគ្គលដែលមានកាយស្ងប់រំងាប់ហើយ ដោយពាក្យបរិយាយ ផ្ទុយគ្នានឹងពាក្យដែលពោលហើយនោះ ។

ពាក្យថា **ចិត្តដែលប្រាសចាកសេចក្តីត្រេកអរ** បានដល់ ចិត្តដែលវៀរចាក សេចក្តីត្រេកអរក្នុងភាវនា ។ ពិតហើយ ភាវនាដែលធ្វើដំណើរត្រង់តាមវិថីហើយ មានភាពវិសេសជាប់គគ្នាទៅតាមលំដាប់ កំពុងប្រព្រឹត្តទៅហើយ រមែងនាំមកនូវ សេចក្តីត្រេកអរ គឺ សេចក្តីសុខស្ងប់នៃចិត្តបាន , ចិត្តជាធម្មជាតិប្រាសចាកសេចក្តី ត្រេកអរ ក៏ព្រោះមិនមានភាវនាដែលធ្វើដំណើរត្រង់តាមវិថីហើយនោះ ។

បទថា **សទ្ធាសង្វេគវសេន** បានដល់ ដោយអំណាចសទ្ធានិងដោយអំណាច សង្វេគ ។

បទថា **សម្បហំសនតា** បានដល់ ការធ្វើឲ្យរីករាយដោយប្រពៃនោះឯង គឺ ការធ្វើភាវនាចិត្តឲ្យត្រេកអរ ដោយការធ្វើសេចក្តីជ្រះថ្លាដែលមានការតក់ស្លុតចេញ មុខ ឲ្យកើតឡើង ។

ពាក្យថា **ដែលប្រព្រឹត្តទៅដោយប្រពៃ** គឺ ភាវនាចិត្តដែលប្រព្រឹត្តទៅដោយ ប្រពៃនោះឯង ព្រោះវៀរចាកការរួញរានិងសេចក្តីរាយមាយ ព្រោះបដិបត្តិបានត្រឹម ត្រូវតាមលំអានផ្លូវសមថៈ និង ព្រោះប្រព្រឹត្តទៅបានស្មើល្អ និង ភាពវិសេស ។

ពាក្យថា **ការព្រងើយកន្តើយ** បានដល់ ការមិនមានសេចក្តីខ្វាយខ្វល់ក្នុងការលើកសរសើរ ការបន្តុះបង្អាប់ និង ការធ្វើឲ្យរីករាយ ។ ពាក្យថា **ការពិចារណាឈានវិមោក្ខ** មានន័យថា ឈានទាំងឡាយមានបឋមជ្ឈានជាដើម ទាំងឡាយនោះឈ្មោះថា **វិមោក្ខ** ព្រោះការរួចផុតដោយល្អជាដើម ពីធម៌ដែលជាសត្រូវទាំងឡាយ បានដល់ ការពិចារណាជាចំណែកៗ នូវឈានវិមោក្ខទាំងនោះថា " ការចម្រើនយ៉ាងនេះ ការចូលយ៉ាងនេះ ការនៅយ៉ាងនេះ ការចេញយ៉ាងនេះ ការសៅហ្មងយ៉ាងនេះ ការផូរផង់យ៉ាងនេះ " ដូច្នេះ ។

ពាក្យថា **ភាពជាកណ្តាលក្នុងសត្វ** បានដល់ អាការជាកណ្តាល គឺ ការព្រងើយកន្តើយ ក្នុងសត្វ និងក្នុងគ្រហស្ថ និងបព្វជិតទាំងឡាយ សូម្បីតាំងនៅក្នុងឋានៈជាទីស្រឡាញ់ ។ ឈ្មោះថា **ភាពជាកណ្តាលក្នុងសង្ខារ** បានដល់ អាការជាកណ្តាល គឺការព្រងើយក្នុងសង្ខារខាងក្នុងទាំងឡាយ មានចក្ខុជាដើម ក្នុងសង្ខារខាងក្រៅទាំងឡាយ មានបាត្រ និងចីវរជាដើម ។ ការប្រកាន់ក្នុងសត្វ និង សង្ខារទាំងឡាយថា របស់យើង ឈ្មោះថា ការជាប់ក្នុងសត្វ និង សង្ខារ ។ ពាក្យថា **ដោយអាការទាំងនេះ** គឺ ដោយអាការមានការកំណត់អាការដែលស្ងប់រំងាប់នៃកាយ និងចិត្ត និងដោយអាការ មានការសេពអាហារដែលជាសប្បាយជាដើម តាមដែលពោលហើយទាំងនេះ ។ ពាក្យថា **ធម៌ទាំងនេះ** បានដល់ ធម៌មានបស្សទ្ធិជាដើម ។

ពាក្យថា **ព្រោះសេចក្តីព្យាយាមរបស់បញ្ញាទន់ខ្សោយ** គឺ ព្រោះសេចក្តីព្យាយាមរបស់បញ្ញាតិចតួច ។ ពិតហើយ **ការនា** ដោយពិសេសជាការនាដែលនាំមកនូវអប្បនា មានអមោហៈជាប្រធាន ដូចជាទានដែលមានអលោភៈជាប្រធាន សីលមានអទោសៈជាប្រធានដូច្នោះ ។ ក្នុងពាក្យនោះ មានន័យថា ក្នុងវេលាណា

បញ្ញាជាធម្មជាតិមិនមានកម្លាំង ក្នុងពេលនោះ ភាវនា រមែងមិនធ្វើចិត្តឲ្យកើតការពេញចិត្តឡើង ដូចជាអាហារដែលមិនបានតាក់តែង ក៏មិនធ្វើឲ្យបុរសមានការពេញចិត្តដូច្នោះ, ព្រោះហេតុនោះ ចិត្តនោះ ទើបជាចិត្តដែលប្រាសចាកសេចក្តីត្រេកអរ ។

ម្យ៉ាងទៀត ក្នុងវេលាណា ភាវនា ជាធម្មជាតិមិននាំមកនូវគុណវិសេស បន្តគ្នាទៅតាមលំដាប់ ព្រោះមិនបដិបត្តិបានត្រង់តាមវិធីដោយល្អនោះឯង ក្នុងវេលានោះ ចិត្ត រមែងជាចិត្តដែលប្រាសចាកសេចក្តីត្រេកអរ ព្រោះការមិនបានសេចក្តីសុខស្ងប់ ។ លោកអាចារ្យសំដៅយកហេតុទាំង២នោះ ពោលថា “ ព្រោះសេចក្តីព្យាយាមរបស់បញ្ញាទន់ខ្សោយ ” ជាដើម ។ បទថា **នំ** បានដល់ ចិត្ត ។ ឈ្មោះថា ជាតិ ជរា ព្យាធិ មរណៈ រមែងមានក្នុង សុគតិ ទុគ្គតិ តាមសមគួរ ព្រោះហេតុនោះ ទុក្ខ ដែលមានការរងទុក្ខ៥យ៉ាងជាដើម ជាហេតុ មានការស្រេកឃ្លានជាដើមជាហេតុ និងមានការបៀតបៀនដល់គ្នានិងគ្នាជាដើមជាហេតុ ដែលផ្សេងពីជាតិជាដើមនោះប៉ុណ្ណោះ បណ្ឌិតគប្បីឃើញថា ជាអបាយទុក្ខ ។

ទុក្ខ៥យ៉ាង មានជាតិជាដើមទាំងអស់នេះ ដែលលោកកាន់យក បានដល់ទុក្ខដែលអាស្រ័យកពបច្ចុប្បន្ននៃសត្វទាំងនោះ ព្រោះហេតុនោះ ទើបលោកកាន់យកទុក្ខដែលមានវដ្តៈជាមូល ក្នុងអតីតកាល និង ក្នុងអនាគតកាល បែកជាចំណែកមួយៗ ផ្សេងៗគ្នា ។ ចំណែកសត្វទាំងឡាយណា ចិញ្ចឹមជីវិតដោយអាហារ និងក្នុងបណ្តាសត្វដែលចិញ្ចឹមជីវិតដោយអាហារនោះ សត្វទាំងឡាយណា ចិញ្ចឹមជីវិតដោយផលនៃការព្យាយាម គប្បីឃើញថា លោកពោលដល់ទុក្ខ ដែលត្រូវស្វែងរកអាហារចិញ្ចឹមជីវិតនៃសត្វទាំងឡាយនោះ ដែលមិនទូទៅដល់សត្វដទៃ ថាជាសង្វេគវត្ថុ ប្រការ ទី ៨ ចុះ ។

បទថា **អសង្ខេ** បានដល់ ចិត្ត ។ ក្នុងពាក្យថា **អលីនំ** ជាដើម មានអធិប្បាយថា **ចិត្ត** ឈ្មោះថា មិនរួញរា ព្រោះធម៌ទាំងឡាយដែលជាបក្ខពួកនៃកោសជ្ជៈ មិនមានប្រមាណ ។

ឈ្មោះថា **មិនរាយមាយ** ព្រោះធម៌ទាំងឡាយដែលជាបក្ខពួកនៃឧទ្ធច្ចៈ មិនមានប្រមាណ ។

ឈ្មោះថា **មិនប្រាសចាកសេចក្ដីត្រេកអរ** ព្រោះការដល់ព្រមនៃការព្យាយាមរបស់បញ្ញា និងព្រោះការសម្រេចសេចក្ដីស្ងប់ ។ មានភាពវិសេសបន្តគ្នាទៅតាមលំដាប់ ព្រោះហេតុនោះ ឈ្មោះថា ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ និង ឈ្មោះថា ដំណើរត្រង់តាមសមថវិថីបាន ។

ក្នុងបណ្ដាអាការទាំងនោះ ព្រះយោគី ឈ្មោះថា មិនដល់ការព្យាយាមក្នុងការផ្គង ក៏ព្រោះចិត្តមិនរួញរា ឈ្មោះថា មិនដល់ការព្យាយាមក្នុងការគ្របសង្កត់ ក៏ព្រោះចិត្តមិនរាយមាយ ឈ្មោះថា មិនដល់ការព្យាយាមក្នុងការធ្វើឲ្យរីករាយ ក៏ព្រោះចិត្តមិនប្រាសចាកសេចក្ដីត្រេកអរ ។ ក៏បណ្ឌិតគប្បីឃើញថា **ចិត្ត** ឈ្មោះថា ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍បាន ព្រោះភាពមិនរួញរា និង មិនរាយមាយ ឈ្មោះថា ដំណើរត្រង់តាមសមថវិថីបាន ក៏ព្រោះការដែលមិនប្រាសចាកសេចក្ដីត្រេកអរ ។

ម្យ៉ាងទៀត **ចិត្ត** ឈ្មោះថា មិនរួញរា មិនរាយមាយ ព្រោះការប្រព្រឹត្តទៅស្មើ ឈ្មោះថា មិនប្រាសចាកសេចក្ដីត្រេកអរ ព្រោះដំណើរត្រង់តាមសមថវិថីបាន ។

ពាក្យថា **នេក្ខម្មប្បដិបទា** បានដល់ ការបដិបត្តិឈាន ។ ពាក្យថា **ការបង្អោនចិត្តទៅក្នុងសមាធិ** បានដល់ ភាពជាអ្នកប្រកបត្រូវក្នុងការធ្វើសមាធិឲ្យកើត គឺ ក្នុងការសម្រេចឈាន ។ ប៉ុន្តែព្រោះហេតុនៃការបង្អោនចិត្តទៅក្នុងសមាធិនោះ

រមែងមានដោយការធ្វើសមាធិឲ្យធ្ងន់ចូលទុក ហើយប្រព្រឹត្តទៅដោយការទេរ ទៅបង្អោនទៅក្នុងសមាធិនោះ ព្រោះហេតុនោះ ទើបលោកពោលថា ធ្ងន់ទៅក្នុងសមាធិជាដើម ។

ក្អាប់សេចក្តីថា កាលព្រះយោគីធ្វើអប្បនាកោសល្យនេះឲ្យដល់ព្រមបាន ក្នុងនិមិត្តដែលបានហើយ តាមប្រការដែលពោលមកនេះ **អប្បនា** ទើបនឹងប្រព្រឹត្តទៅព្រមបាន ។

បទថា **សា យោគ អប្បនា** ។ **ហិ** ស័ព្ទ ក្នុងបទថា **ហិត្វា ហិ** មានអត្ថថា ហេតុ ( ប្រែថា ព្រោះថា ) ។ សេចក្តីថា ព្រោះហេតុថា ឋានៈនេះរកមិនបាន ព្រោះដូច្នោះ លោកកាលកំណត់ គឺ កាលចាំទុកនូវអាការដែលប្រព្រឹត្តទៅ របស់ចិត្ត គឺ អាការដែលប្រព្រឹត្តទៅដោយទាក់ទងនឹងការរួញរា និង ការរាយមាយជាដើម របស់ការនៃចិត្ត ។

គប្បីប្រកបឲ្យល្មមនូវការព្យាយាមនោះឯង គឺ ការមានកិច្ចស្មើគ្នានៃវីរិយៈ និង សមាធិ នោះឯង ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា គប្បីប្រកបយ៉ាងណាទៅដូច្នេះហើយ ទើបពោលថា " **ឰសកម្បិ** " ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ទន់ជ្រាយ** គឺ មានការរួញរា សេចក្តីថា រួញរា ។ បទថា **យន្តំ** ប្រែថា ប្រព្រឹត្តទៅ អធិប្បាយថា គប្បីផ្គងទុកនោះឯង ឲ្យសមល្មម ។ ព្រោះហេតុនោះ ទើបលោកពោលថា " គប្បីហាមសេចក្តីព្យាយាមដែលប្រារព្ធខ្លាំងពេក ហើយធ្វើឲ្យប្រព្រឹត្តទៅសមល្មមតែម្យ៉ាង " ដូច្នេះ ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា គប្បីធ្វើឲ្យប្រព្រឹត្តទៅសមល្មមនោះឯង បានយ៉ាងណាទៅ ដូច្នេះហើយទើបពោលថា " **រេណុម្ហិ** " ដូច្នេះជាដើម ។ ឈ្មោះថា

**យថា ហិ** មានន័យថា ព្រះយោគីគប្បីផ្លាស់ប្តូរចិត្តពីការរួញរា និង ការរាយមាយ ហើយធ្វើចិត្តឲ្យបែរមុខឆ្ពោះនិមិត្ត ឲ្យប្រព្រឹត្តទៅ គឺ គប្បីធ្វើការនាចិត្តដែលមានមុខត្រង់ចំពោះបដិភាគនិមិត្ត ឲ្យដល់ព្រម ដោយការប្រកបសេចក្តីសមល្មមនៃសេចក្តីព្យាយាម ដូចជាការប្រព្រឹត្តទៅរបស់សត្វទាំងឡាយ មានឃ្មុំជាដើម ក្នុងកេសរផ្កាឈើជាដើម ដែលលោកពណ៌នាទុកក្នុងអដ្ឋកថា ដោយការឧបមាដូច្នេះចុះ ។

## ពណ៌នា វិធីធ្វើចិត្ត ដែលបែរមុខត្រង់ឆ្ពោះនិមិត្ត ឲ្យប្រព្រឹត្តទៅ

បទថា **តត្រ** ស្មើនឹង **តស្មឹ** ប្រែថា ក្នុងគាថា ២ ដែលលោកពោលទុកថា " **រេណុម្ហិ** " ជាដើមនោះឯង ។ ឈ្មោះថា **ពាក្យបើកបង្ហាញនូវខ្លឹមសារ** គឺ បើកបង្ហាញខ្លឹមសារនៃឧបមា និងឧបមេយ្យ ។ បទថា **អច្ឆេកោ** ប្រែថា មិនច្លាត ។ ពាក្យថា **កាលហើរទៅ** គឺ ផ្តើមនឹងហើរទៅ ។ ផ្កាឈើដែលមានសភាពស្រស់ថ្មីមានរស ក៏ក្នុងខណៈដែលកំពុងរីកនោះឯង ក្រោយពីស្វិតស្រពោនទៅ ឬអស់រសទៅ ក៏ព្រោះហេតុមានខ្យល់ជាដើម ។ ព្រោះដូច្នោះ កេសរនឹងអស់ទៅ ក្នុងពេលដែលឃ្មុំហើរត្រឡប់មក ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " ត្រឡប់មកដល់ក្នុងកាលកេសរអស់ហើយ " ដូច្នេះ ។ ពាក្យថា **កញ្ចុំផ្កាឈើ** បានដល់កញ្ចុំផ្កាដែលរីកចេញនៅតាមមែកឈើទាំងឡាយ ។ ពាក្យថា **ពួកសិស្សរបស់ជាងចម្ងាក់** គឺ ពួកសិស្សរបស់អាចារ្យដែលជា ជាងចម្ងាក់ ។ ពាក្យថា **ដែលបណ្តែតនៅក្នុងអាងទឹក** គឺ ដែលគេដាក់នៅក្នុងអាងទឹក ។ ពាក្យថា **ការប្រើកាំបិត** គឺ ការឆារទាក់ទងនឹងកាំបិតជាដើម ។ ភ្ជាប់សេចក្តីថា **មិនខ្វាំងក្លា** សូម្បីតែនឹងប្រើ

កាំបិតពាល់ត្រូវស្ទីកឈូក ។ ពាក្យថា **ដោយការព្យាយាមដ៏សមគួរ** គឺ ដោយការព្យាយាមល្មមប្រមាណ មិនព្យាយាមខ្លាំងពេក និង ធូរពេក ដូចសិស្សមុនៗ ។

បទថា **តត្ថ** បានដល់ លើស្ទីកឈូក ។ បទថា **បរិយោទាតសិប្បោ** ប្រែថា មានវិជ្ជាសិល្បៈដែលបរិសុទ្ធល្អ បានដល់ សម្រេចវិជ្ជាសិល្បៈ ។

បទថា **មក្កដកសុត្តំ** ប្រែថា សរសៃពីងពាង ។ ឈ្មោះថា **អ្នកដើរនាវា** បានដល់ អ្នកដើរកប៉ាល់ ។ បទថា **លការំ** បានដល់ ក្ដោងកប៉ាល់ដែលធ្វើដោយកន្ទេលជាដើម ។ ពាក្យថា **បន្ថែមប្រេងឲ្យពេញត្រឡោក មិនធ្វើប្រេងឲ្យកំពប់** គឺ បន្ថែមប្រេងក្នុងត្រឡោកដែលមានមាត់តូចឲ្យពេញ មិនធ្វើប្រេងក្នុងចានជាដើម ឲ្យកំពប់ ។

ពាក្យថា **ឧបមេយ្យ ក៏ដូច្នោះដូចគ្នា** មានន័យថា បណ្ឌិតគប្បីជ្រាបការប្រៀបធៀបដោយរឿងឧបមាថា ប្រៀបដូចជាមេឃុំ សិស្សរបស់ជាងចម្លាក់ អ្នកប្រមូលសរសៃពីងពាង អ្នកដើរនាវា និងសិស្សអ្នកប្រកប្រេងឲ្យពេញ ដែលលោកពោលទុកខាងដើមទាំងនោះ រមែងធ្វើសេចក្ដីព្យាយាមដោយកម្លាំង យ៉ាងណា ឧបមេយ្យក៏ដូច្នោះដូចគ្នា ភិក្ខុមួយរូបដែលគិតថា “ យើងនឹងសម្រេចអប្បនាឲ្យបានឆាប់ ” ដូច្នេះហើយធ្វើសេចក្ដីព្យាយាមយ៉ាងខ្លាំងក្ដី ភិក្ខុមួយរូបដែលមិនធ្វើសេចក្ដីព្យាយាមដូចឃុំជាដើម ដែលលោកពោលទុកត្រង់កណ្ដាលក្ដី ភិក្ខុទាំង២រូបនេះ រមែងមិនអាចសម្រេចអប្បនាបាន ព្រោះគ្មានភាពសមល្មមនៃការព្យាយាម។ ចំណែកភិក្ខុអ្នកមានការព្យាយាមសមល្មម ដូចជាឃុំជាដើម ដែលលោកពោលទុកនៅផ្នែកខាងចុង ភិក្ខុរូបនេះ រមែងអាចសម្រេចអប្បនាបាន ព្រោះមានការប្រកបសេចក្ដីព្យាយាមសមល្មម ដូច្នេះជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា

កិត្តិមួយរូបដូច្នេះជាដើម ។ អធិប្បាយថា ឈ្មោះថា **ចិត្ត** ដែលរួញរា បានដល់ការនាចិត្ត ( បាលី **: លីនំ ភាវនាចិត្តន្តិ អធិប្បាយោ** ) ។

**ឥត្ថិ សត្ថិ បរំ សុខំ**

( ចប់មហាដីកា )

# បឋមជ្ឈាន

ដោយលំដាប់នៃការភាវនាត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ឈ្មោះថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយដែលជាអកុសល ចូលដល់ឈានទី១ ដែលមាន វិតក្ក វិចារ បីតិ និង សុខ កើតពីវិវេក បឋមជ្ឈានបឋវីកសិណដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ មានលំអ ៣ ប្រការ ដល់ព្រមដោយលក្ខណៈ ១០ ដែលព្រះយោគាវចរនោះ បានសម្រេចហើយ ដោយប្រការដូច្នេះ ។

## ពន្យល់អត្ថ **វិវិច្ចេវ កាមេហិ**

ក្នុងឈានបាឋៈទាំងនោះ បាឋៈថា ***វិវិច្ចេវ កាមេហិ*** មានន័យថា ស្ងាត់ គឺប្រាសទៅ ចៀសចេញទៅចាកកាមទាំងឡាយ ចំណែក **ឯវ** ស័ព្ទ ដែលប្រកបក្នុងបាឋៈនោះ បណ្ឌិតគប្បីជ្រាបថា ជាស័ព្ទកំណត់សេចក្តី ក៏ព្រោះហេតុដែល **ឯវ** ស័ព្ទ នោះ ជាស័ព្ទកំណត់សេចក្តី ទើបវាបញ្ជាក់ដល់សេចក្តីដែលកាមទាំងឡាយសូម្បីមិនមាននៅក្នុងសម័យ ដែលចូលដល់បឋមជ្ឈាននោះ ក៏ជាបដិបក្ខដល់បឋមជ្ឈាននោះ ហើយកាលដែលនឹងសម្រេចដល់បឋមជ្ឈានបាន ក៏ដោយការលះបង់កាមទាំងឡាយនោះចេញប៉ុណ្ណោះ គឺ យ៉ាងណា ? គឺ កាលធ្វើការកំណត់ទៅដោយបាឋៈថា " ***វិវិច្ចេវ កាមេហិ*** ស្ងាត់ចាកកាមទាំងឡាយ " ដូច្នេះ ពាក្យអធិប្បាយនេះ ក៏ដឹងបានច្បាស់ថា " កាមទាំងឡាយជាបដិបក្ខដល់ឈាននេះតែម្យ៉ាង " បើកាមទាំងឡាយមានហើយ ឈាននេះ រមែងប្រព្រឹត្តទៅមិនបាន ដូចជា កាលបើភាពងងឹតមានហើយ ពន្លឺប្រទីបក៏មិនមាន ។ ការសម្រេចឈាននឹងមានបាន ក៏ដោយការលះបង់កាមទាំងឡាយនោះចេញប៉ុណ្ណោះ ដូចការទៅដល់

ត្រើយនាយបាន ក៏ដោយការលះត្រើយអាយ ព្រោះហេតុនោះ **ឯវ** ស័ព្ទនោះ ទើបឈ្មោះថា ធ្វើការកំណត់ដូច្នេះ ។

ក្នុងបាឋៈនោះ បញ្ហាគប្បីមានថា " ក៏ព្រោះហេតុដូចម្តេច **ឯវ** ស័ព្ទនោះ ទើបលោកពោលទុកតែក្នុងបទដើម មិនពោលទុកក្នុងបទចុង សូម្បីបុគ្គលមិនស្ងាត់ចាកធម៌ទាំងឡាយដែលជាអកុសលហើយ នឹងអាចចូលដល់ឈានបាន មែនឬ ? ពាក្យឆ្លើយគប្បីមានថា " ក៏សេចក្តីដែល **ឯវ** ស័ព្ទ លោកពោលទុកតែក្នុងបទដើម មិនពោលទុកក្នុងបទចុងនោះ បណ្ឌិតមិនគប្បីឃើញដូច្នេះ ដែល **ឯវ** ស័ព្ទ នោះលោកពោលទុកក្នុងបទដើម ក៏ព្រោះ ឈានជានិស្សរណៈនៃកាមនោះ ពិតណាស់ឈាននោះឈ្មោះថា ជាហេតុចេញចាកកាមទាំងឡាយប៉ុណ្ណោះ ព្រោះជាផ្លូវឈានកន្លងកាមធាតុ និងព្រោះជាបដិបក្ខដល់កាមរាគៈ ដូចព្រះសារីបុត្តពោលទុក ( ក្នុងបដិសម្ភិទា ) ថា " ធម្មជាតិនោះ ជានិស្សរណៈនៃកាមទាំងឡាយ ធម្មជាតិនេះគឺអ្វី ? ធម្មជាតិនោះ គឺ **នេក្ខម្ម** " ដូច្នេះ ប៉ុន្តែថា **ឯវ** ស័ព្ទ ក្នុងបាឋៈនេះ គួរពោលក្នុងបទចុងផង ដូចគ្នាជាមួយ **ឯវ** ស័ព្ទ ក្នុងបាឋៈនេះថា " **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** " ដែលលោកនាំមកពោលទុកក្នុងបទចុងដែរ ព្រោះថា នរណាៗ មិនអាចស្ងាត់ចាកធម៌ទាំងឡាយដែលជាអកុសលពោលគឺ នីវរណៈដទៃៗ តែកាមច្ឆន្ទៈនេះនៅហើយ មិនអាចចូលដល់ឈានបានទេ ព្រោះហេតុនោះ **ឯវ** ស័ព្ទនោះ បណ្ឌិតគប្បីឃើញក្នុងបទទាំង២ ថា " **វិវិច្ចេវ កាមេហិ វិវិច្ចេវ អកុសលេហិ ធម្មេហិ** " ដូច្នេះចុះ ។

**វិវេក** ទាំងឡាយ ( ប្រភេទ ៥ ) មានតទង្គវិវេកជាដើមក្តី ( ប្រភេទ ៣ ) មានចិត្តវិវេកក្តី រមែងសង្គ្រោះចូលបានទាំងអស់ដោយសាធារណវចនៈថា " **វិវិច្ច** "

នេះទាំង២បទ ក៏ពិត ប៉ុន្តែបណ្ឌិតគប្បីឃើញថា **ក្នុងឈានកថានេះ** យក វិវេក ៣ គឺ **កាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក** ប៉ុណ្ណោះ ។

ដោយបទថា " **កាមេហិ** " នេះ បណ្ឌិតគប្បីជ្រាបថា លោកសង្គ្រោះយកទាំងវត្ថុកាម ដែលពោលទុកក្នុងនិទ្ទេសដោយន័យថា " វត្ថុកាមទាំងឡាយ គឺអ្វី គឺរូបដែលគួរស្រឡាញ់ គួរពេញចិត្ត... " ដូច្នេះជាដើម ។ ទាំងកិលេសកាមដែលពោលទុកក្នុងឈានវិភង្គ ក្នុងមហានិទ្ទេសនោះ ដូចគ្នាថា " សេចក្តីពេញចិត្តជាកាម សេចក្តីប្រាថ្នាជាកាម ការប្រាថ្នាដោយសេចក្តីពេញចិត្តជាកាម សេចក្តីសង្ឃឹមជាកាម តម្រេកជាកាម តម្រេកតាមសេចក្តីសង្ឃឹមជាកាម កិលេសទាំងនេះហៅថាកាម " ដូច្នេះ ។ រួមចូលគ្នាទាំងអស់តែម្យ៉ាង បើដូច្នេះ បាឋៈថា " **វិវិច្ចេវ កាមេហិ** "នោះ សូម្បីនឹងមានន័យថា "ស្ងាត់ចាកវត្ថុកាមទាំងឡាយ" ដូច្នេះក៏ត្រូវ , កាយវិវេកដែលពោលដោយការស្ងាត់ចាកវត្ថុកាមនោះ ចំណែកបាឋថា " **វិវិច្ច អកុសលេហិ ធម្មេហិ** " នឹងមានន័យថា " ស្ងាត់ចាកកិលេសកាមទាំងឡាយ ឬថា ចាកអកុសលទាំងពួង " ដូច្នេះ ក៏ត្រូវ , ចិត្តវិវេកដែលពោលដោយការស្ងាត់ចាកកិលេសកាមនោះ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ក្នុង ២ បាឋ នោះ ការលះកាមសុខ គឺ ជាការប្រកាសដោយបាឋដំបូង ព្រោះពោលដល់ការស្ងាត់ចាកវត្ថុកាមទាំងឡាយតែម្យ៉ាង ការកាន់យកនេក្ខម្មសុខ ជាការប្រកាសដោយបាឋទី ២ ព្រោះពោលដល់ការស្ងាត់ចាកកិលេសកាមទាំងឡាយ និង ព្រោះពោលដល់ការស្ងាត់ចាកវត្ថុកាម និងកិលេសកាម ដូចគ្នានោះឯង ក្នុង២បាឋនោះ ការលះបង់វត្ថុនៃសង្កិលេស ជាការប្រកាសដោយបាឋទី១ ការលះបង់តួសង្កិលេស ប្រកាសដោយបាឋទី២ ការលះបង់ហេតុនៃភាពល្មោភ ប្រកាសដោយបាឋទី១ ការលះបង់

ហេតុនៃភាពល្ងង់ខ្លៅ ប្រកាសដោយបាឋទី២ និង **បយោគសុទ្ធិ** ( សេចក្តីបរិសុទ្ធិនៃប្រយោគព្យាយាម ) ប្រកាសដោយបាឋទី១ **អាសយបោសន** ( ការអប់រំអធ្យាស្រ័យ ) ប្រកាសដោយបាឋទី២ ក្នុងកាមដែលពោលទុកក្នុងបទថា **កាមេហិ** នោះ នេះជាន័យក្នុងចំណែកវត្ថុកាមមុន ។

ចំណែកក្នុងកិលេសកាម លោកបំណងយកកាមច្ឆន្ទៈដែលមានច្រើនប្រភេទដោយឈ្មោះថា ឆន្ទៈក៏មាន រាគៈក៏មានដូច្នេះជាដើម នោះឯងថា **កាម** ក៏កាមច្ឆន្ទៈនោះ សូម្បីមានទោសដែលរាប់ចូលក្នុងអកុសល លោកពោលទុកមួយផ្នែកដោយជាសត្រូវនៃឈាន ក្នុងវិភង្គដោយន័យថា " **តត្ថ កតមេ កាមា ឆន្ទោ កាមោ** " ដូច្នេះជាដើម ន័យម្យ៉ាងទៀត កាមច្ឆន្ទៈនោះរាប់ថា ពោលក្នុងបទដើម ព្រោះវាជាកិលេសកាម រាប់ថាពោលក្នុងបទទី ២ ព្រោះវារាប់ចូលក្នុងអកុសល ព្រោះវាមានច្រើនប្រភេទ ទើបទ្រង់មិនត្រាស់ជា( ឯកវចនៈ )ថា **កាមតោ** ទ្រង់ត្រាស់ជា(ពហុវចនៈ) ថា **កាមេហិ** ។ ម្យ៉ាងទៀត សូម្បីកាលបើធម៌ទាំងឡាយដទៃជាអកុសលមានហើយ នីវរណៈទាំងឡាយប៉ុណ្ណោះ លោកពោលទុកក្នុងវិភង្គដោយន័យថា " **តត្ថ កតមេ អកុសលា ធម្មា កាមច្ឆន្ទោ** " ដូច្នេះជាដើម ដោយការសម្តែងនូវកាមនោះ ជាបដិបក្ខនៃអង្គឈាន នឹងពោលខាងមុខ ដែលជា( សត្រូវនៃកាម ) មានពាក្យអធិប្បាយថា " ព្រោះថា នីវរណៈទាំងឡាយជាសត្រូវដល់អង្គឈាន អង្គឈានទាំងនោះក៏ជាសត្រូវ គឺ ជាគ្រឿងកម្ចាត់នីវរណធម៌នោះ " ពិតយ៉ាងនោះ សេចក្តីនេះ ព្រះមហាកច្ចានត្ថេរពោលទុកក្នុងគម្ពីរបេដកៈថា " សមាធិជាបដិបក្ខដល់កាមច្ឆន្ទៈ បីតិជាបដិបក្ខដល់ព្យាបាទ វិតក្កជាបដិបក្ខដល់ថីនមិទ្ធៈ សុខជាបដិបក្ខដល់ឧទ្ធច្ចកុក្កុច្ចៈ វិចារជាបដិបក្ខដល់វិចិកិច្ឆា " ដូច្នេះ តាមន័យដែល

ពោលមកនេះ ក្នុងបាឋ២បទនោះ (**វិក្ខម្ភនវិវេក**) ការស្ងាត់ដោយការគ្របសង្កត់ទុកនូវកាមច្ឆន្ទៈ បានពោលដោយបទដំបូងនេះ គឺ “ **វិវិច្ចេវ កាមេហិ** ” ការស្ងាត់ដោយការគ្របសង្កត់ទុកនូវនីវរណៈទាំង៥ ជាការពោលដោយបទទី២ គឺ “ **វិវិច្ច អកុសលេហិ ធម្មេហិ** ” ។

តែកាលបើថា ការកាន់យកប្រការដែលនៅមិនទាន់បានកាន់យក បណ្ឌិតគប្បីជ្រាបថា “ ការស្ងាត់ដោយការគ្របសង្កត់ទុកបាននូវកាមច្ឆន្ទៈ បានពោលដោយបទដើម ការស្ងាត់ដោយការគ្របសង្កត់បាននូវនីវរណៈដ៏សេស បានពោលដោយបទទី ២ ន័យនោះដូចគ្នា ក្នុងអកុសលមូល៣ ការស្ងាត់ដោយគ្របសង្កត់បាននូវលោភៈដែលមានប្រភេទនៃកាមគុណ៥ជាអារម្មណ៍ បានពោលដោយបទដើម ការស្ងាត់ដោយគ្របសង្កត់បាននូវ ទោសៈនិងមោហៈ ដែលមានប្រភេទនៃអាឃាតវត្ថុជាដើមជា អារម្មណ៍ បានពោលទុកក្នុងបទទី២ ឬថាក្នុងធម៌ទាំងឡាយ មានឱឃៈជាដើម ការស្ងាត់ដោយការគ្របសង្កត់ទុកបាននូវ កាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈាកាយគន្ថៈ និង កាមរាគសំយោជនៈ បានពោលទុកដោយបទដើម ការស្ងាត់ដោយការគ្របសង្កត់ទុកបាននូវឱឃៈ យោគៈ អាសវៈ ឧបាទាន កាយគន្ថៈ និង សំយោជនៈដ៏សេស បានពោលទុកដោយបទទី ២ និងការស្ងាត់ដោយការគ្របសង្កត់ទុកបាននូវតណ្ហា និង ធម៌ទាំងឡាយដែលសម្បយុត្តជាមួយតណ្ហានោះ បានពោលដោយបទដំបូង ការស្ងាត់ដោយការគ្របសង្កត់ទុកបាននូវអវិជ្ជា និង ធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយអវិជ្ជានោះ បានពោលទុកដោយបទទី ២ ។ ម្យ៉ាងទៀត ភាពស្ងាត់ដោយការគ្របសង្កត់ទុកបាននូវចិត្តុប្បាទដែលសម្បយុត្តដោយលោភៈ ៨ ដួង ជាការពោលដោយបទដើម ការស្ងាត់ដោយការ

គ្របសង្កត់ទុកបាននូវអកុសលចិត្តុប្បាទដ៏សេស ៤ ដួង ជាការពោលដោយបទទី ២ " ដូច្នេះ ។ ពាក្យដែលពោលនេះ ជាពាក្យចង្អុលបង្ហាញនូវខ្លឹមសារ ក្នុងឈាន បាឋៈថា " **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** " នេះជាលំដាប់ដំបូង ។

## អធិប្បាយអង្គឈាន បទ **សវិតក្កំ សវិចារំ**

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សំដែងអង្គដែលគប្បីលះនៃបឋមជ្ឈាន ដោយបាឋៈត្រឹមប៉ុណ្ណេះហើយ ឥឡូវនេះទ្រង់នឹងសម្ដែងអង្គដែលគប្បីប្រកបចូល ( នៃបឋមជ្ឈាននោះ ) ទើបទ្រង់ត្រាស់ពាក្យថា " **សវិតក្កំ សវិចារំ** " ជាដើម ។

ក្នុងពាក្យទាំងនោះ ការត្រិះរិះ ឈ្មោះថា **វិតក្ក** មានអធិប្បាយទុកថា ការលើកចិត្តទៅ ។ វិតក្កនេះមានការផ្ចោតចិត្តទៅក្នុងអារម្មណ៍ជាលក្ខណៈ មានការខ្ទប់នឹងអារម្មណ៍ជាកិច្ច ពិតហើយ ដោយអង្គ គឺវិតក្កនោះ ព្រះយោគាវចរបានឈ្មោះថា ធ្វើអារម្មណ៍ឲ្យជាវត្ថុដែលវិតក្កខ្ទប់ទូទៅហើយ ឲ្យជាវត្ថុដែលវិតក្កផ្ចោតដោយជុំវិញហើយ ដូច្នេះវិតក្កនោះ មានការនាំចិត្តចូលមកកាន់អារម្មណ៍បាន ជាអាការប្រាកដ ។

ការពិចារណា ឈ្មោះថា **វិចារ** មានពាក្យអធិប្បាយថា ការពិចារណាទៅតាមវិតក្ក ។ **វិចារ** នេះមានការតាមសង្កេតអារម្មណ៍ជាលក្ខណៈ មានការតាមប្រកបសហជាតធម៌ឲ្យនៅតែក្នុងអារម្មណ៍នោះ ជាកិច្ច មានការតាមចងចិត្តទុកក្នុងអារម្មណ៍នោះ ជាអាការប្រាកដ ។

បើវិតក្ក និង វិចារនោះ សូម្បីថាបែកគ្នាមិនបានក្នុងទីណាៗក្ដី ( តែបណ្ឌិតគប្បីជ្រាបថា **វិតក្ក** គឺ ការលើកចិត្តជាដំបូង ដូចសំឡេងគោះរគាំង ព្រោះអត្ថថានៅមានសភាពគ្រោតគ្រាតជាងវិចារនិងព្រោះអត្ថថា មានសភាពទៅមុន( វិចារ )។

**វិចារ** គឺ ការតាមសង្កេតពិនិត្យ ដូចសំឡេងញ័រនៃរគាំង ព្រោះអត្ថថា មាន សភាពសុខុម( ជាងវិតក្ក ) និង ព្រោះមានសភាពតាមសង្កេតអារម្មណ៍ ។

ម្យ៉ាងទៀត ក្នុង២យ៉ាងនោះ វិតក្កនៅមានការញាប់ញ័រ មានការកម្រើកនៃចិត្ត ក្នុងពេលកើតដំបូង ដូចការទទះស្លាបហើរ នៃបក្សីដែលប្រាថ្នានឹងហើរឡើងទៅក្នុង អាកាស និង ដូចកិរិយាហើរចុះ នៃសត្វកន្លង់ឆ្ពោះទៅរកផ្កាឈូកដែលមានចិត្តជាប់ជំពាក់នៅក្នុងក្លិនដូច្នោះ ចំណែកវិចារមានការប្រព្រឹត្តទៅរៀបរយ( ជាងវិតក្ក ) ជាភាវៈដែលចិត្តមិនញាប់ញ័រពេក ដូចការត្រដាងស្លាប( សំកាំងរំពៃ ) នៃបក្សីដែលហើរឡើងទៅក្នុងអាកាស និងដូចការហើរវិលរបស់សត្វកន្លង់នៅលើផ្កាឈូកដែលចុះមកជិតដល់ផ្កាឈូកនោះ ។

ចំណែកអដ្ឋកថាទុកនិបាតពោលទុកថា “ វិតក្កប្រព្រឹត្តទៅដោយភាវៈ គឺ លើកចិត្តឡើងកាន់អារម្មណ៍ ដូចកិរិយារបស់បក្សីបោះពួយទៅក្នុងអាកាស ដោយ ទទះស្លាបទាំងសងខាង ហើយសំកាំងស្លាបដូច្នោះ វិចារប្រព្រឹត្តទៅដោយសភាវៈ តាមពិនិត្យ( អារម្មណ៍ ) ដូចកិរិយារបស់បក្សីកម្រើកស្លាបតិចៗទប់ខ្យល់ដូច្នោះ ។

ពាក្យក្នុងអដ្ឋកថាទុកនិបាតនោះ ត្រឹមត្រូវតែក្នុងការប្រព្រឹត្តទៅដោយការបន្ត គ្នា ចំណែកសេចក្តីផ្សេងគ្នានៃវិតក្កនិងវិចារនោះ រមែងប្រាកដហើយក្នុងបឋមជ្ឈាន និង ទុតិយជ្ឈាន ។

ន័យម្យ៉ាងទៀត **វិតក្ក** ដូចជាដៃដែលចាប់ទុកយ៉ាងមាំ **វិចារ** ដូចជាដៃដែល ដុសខាត់ នៃបុគ្គលអ្នកចាប់ភាជនៈសំរឹទ្ធិមានស្នឹម ដោយដៃម្ខាងទៀត ហើយប្រើ ប្រាស់ឧបករណ៍ ប្រាស់រោមសត្វជ្រលក់ប្រេង ដុសខាត់ដោយដៃម្ខាងទៀតដូច្នោះ ។

ន័យដូចគ្នា **វិតក្ក** ដូចជាដៃដែលទះ( សូនរូប ) **វិចារ** ដូចជាដៃចាំតាក់តែង

ត្រង់នេះត្រង់នោះនៃស្នូនថ្នាំង ដែលបង្វិលកង់ក្រឡឹងធ្វើភាជនៈ ដោយប្រើឈើទះ ។

នយដូចគ្នានោះ វិតក្កមានសភាពដោតចុះ ដូចដែកស្រួចដោតចំត្រង់កណ្ដាល ( ភាជនៈ ) វិចារមានសភាពតាក់តែង ដូចដែកស្រួចដែលបង្វិលធ្វើដាន នៅផ្នែកខាងក្រៅនៃស្នូនថ្នាំង ដែលធ្វើស្នាមវង្វង់មូលដូច្នោះ ។

**ឈាន** នេះបានឈ្មោះថា **សវិតក្កំ សវិចារំ** ព្រោះប្រព្រឹត្តទៅជាមួយវិតក្កនិង វិចារនេះ ដូចពោលមក ដូចដើមឈើប្រព្រឹត្តទៅជាមួយផ្កានិងផ្លែ ដូច្នោះ តែក្នុងវិភង្គលោកធ្វើជាបុគ្គលាធិដ្ឋានទេសនាដោយន័យថា " បុគ្គលជាអ្នកចូលដល់ជាអ្នកដល់ព្រមដោយវិតក្កនេះនិងវិចារនេះ "ដូច្នេះជាដើម ហេតុដូច្នោះអត្ថាធិប្បាយសូម្បីក្នុងវិភង្គបាឋៈនោះ បណ្ឌិតគប្បីឃើញថា ដូចគ្នាយ៉ាងនេះឯង ។

## អធិប្បាយអត្ថនៃ បទថា **វិវេកជំ**

បណ្ឌិតគប្បីជ្រាបអត្ថនៃបទថា **វិវេកជំ** នេះ សេចក្ដីស្ងាត់ ឈ្មោះថា **វិវេក** មានន័យថា ប្រាសទៅចាកនីវរណធម៌ ន័យមួយទៀត ធម៌ណាស្ងាត់ហើយ ហេតុនោះ ធម៌នោះ ទើបឈ្មោះថា **វិវេក** គឺ ធម៌ដែលស្ងាត់ចាកនីវរណៈ សំដៅពួកធម៌ដែលសម្បយុត្តជាមួយឈាន បីតិ សុខ ឈ្មោះថា **វិវេកជ** ព្រោះកើតពីវិវេកនោះ ឬ កើតក្នុងវិវេកនោះ ។

## អធិប្បាយអត្ថនៃ បទថា **បីតិសុខំ**

គប្បីជ្រាបអត្ថក្នុងបទថា **បីតិសុខំ** ដូច្នេះ ធម្មជាតិណាធ្វើឲ្យរីករាយ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **បីតិ** បីតិនោះមានសេចក្ដីរីករាយជាលក្ខណៈ មានការញ៉ាំង កាយ និង ចិត្ត ឲ្យរីករាយជាកិច្ច មានការព្រឺរោមជាអាការប្រាកដ ។

**បីតិ** នោះមាន ៥ យ៉ាង គឺ :

១ . **ខុទ្ទកាបីតិ** បីតិបន្តិចបន្តួច ។
២ . **ខណិកាបីតិ** បីតិមួយជួរខណៈ ។
៣ . **ឱក្កន្តិកាបីតិ** បីតិជាស្រេបក់ៗ ។
៤ . **ឧព្វេង្គាបីតិ** បីតិខ្លាំងក្លា ។
៥ . **ផរណាបីតិ** បីតិជ្រួតជ្រាប ។

ក្នុងបីតិ៥យ៉ាងនោះ **ខុទ្ទកាបីតិ** អាចធ្វើត្រឹមតែឲ្យព្រឺរោមក្នុងរាងកាយប៉ុណ្ណោះ , **ខណិកាបីតិ** រមែងមានដោយជួរខណៈ ដូចជាផ្លេកបន្ទោរ , **ឱក្កន្តិកាបីតិ** ចុះកាន់កាយហើយក៏អស់ទៅ ដូចជារលកទឹកបោកផ្ទប់ច្រាំងសមុទ្រហើយក៏បែកអស់ទៅ , **ឧព្វេង្គាបីតិ** មានកម្លាំងខ្លាំងអាចធ្វើកាយឲ្យអណ្តែតទៅក្នុងអាកាសបាន , **ផរណាបីតិ** ត្រេកអរចិត្តជ្រួតជ្រាបពាសពេញកាយដូចសំឡីជប់ទឹក ។

ពិតយ៉ាងនោះ ព្រះមហាតិស្សត្ថេរដែលគង់នៅក្នុងបុណ្ណវល្លិកវិហារ ក្នុងពេលរសៀលថ្ងៃពេញបូណ៌មី បានទៅកាន់លានព្រះចេតិយ( ទៅមិនទាន់ដល់ ) ក៏ឃើញពន្លឺព្រះចន្ទ ក៏បែរមុខឆ្ពោះព្រះចេតិយរំពឹងគិតថា “ ក្នុងវេលានេះ ល្អណាស់ ហ្ន៎ ដែលបរិស័ទទាំង៤ កំពុងសំពះព្រះចេតិយ ” ក៏ញ៉ាំងឧព្វេង្គាបីតិដែលមានព្រះពុទ្ធ-គុណជាអារម្មណ៍ឲ្យកើតឡើង ដោយអំណាចនៃអារម្មណ៍ដែលខ្លួនឃើញមកហើយជាប្រក្រតី ក៏អណ្តែតខ្លួនឡើងទៅក្នុងអាកាស ទៅចុះឈរនៅមុខលានព្រះចេតិយតែម្តង ប្រៀបដូចជាគ្រាប់ឃ្លីដ៏ស្អាតដែលគេចោលមកធ្លាក់នៅលើដីកំបោរ ហើយលោតឡើងទៅក្នុងអាកាសដូច្នោះ ។

សូម្បីកុលធីតាម្នាក់ នៅក្នុងស្រុកវត្តកាលគ្រាមដែលជាទីអាស្រ័យ ( ត្រាច់

បិណ្ឌបាត )នៃភិក្ខុវត្តគិរិកណ្ឌវិហារ ក៏អណ្តែតទៅកាន់អាកាសបានដោយឧព្វេគ្គាបីតិដែលមានព្រះពុទ្ធគុណជាអារម្មណ៍ដ៏ខ្លាំងក្លាដូចគ្នា ។

បានឮមកថា មាតាបិតារបស់កុលធីតានោះ កាលនឹងទៅវត្តដើម្បីស្តាប់ធម៌នៅពេលរសៀលបានប្រាប់ថា " នែ៎ កូន ! កូនមានភារៈច្រើនមិនអាចទៅបានក្នុងពេលយប់ ម៉ែស្តាប់ធម៌ហើយ នឹងឲ្យចំណែកបុណ្យដល់កូន " ដូច្នេះហើយទើបបានទៅ ។ កុលធីតានោះ សូម្បីប្រាថ្នាចង់ទៅ តែមិនហ៊ានបំពានពាក្យម្តាយ ក៏នៅចាំផ្ទះ បានចេញទៅឈរខាងមុខផ្ទះ សម្លឹងមើលលានព្រះចេតិយ ដែលដូចជាអណ្តែតក្នុងផ្ទៃមេឃ លើកំពូលភ្នំគិរិកណ្ឌកៈ តាមពន្លឺព្រះចន្ទ បានឃើញការបូជាព្រះចេតិយដោយប្រទីប បានឃើញបរិស័ទទាំង៤ធ្វើការបូជាដោយគ្រឿងបូជា មានផ្កាឈើនិងគ្រឿងក្រអូបជាដើម ហើយនាំគ្នាធ្វើប្រទក្សិណ និង បានឮសំឡេងស្វាធ្យាយរបស់ពួកភិក្ខុផង គ្រានោះនាងបានរំពឹងទៅថា " ពួកគេជាអ្នកមានបុណ្យពិតមែន ដែលបានទៅវត្ត ហើយបានដើរជុំវិញលានព្រះចេតិយ និង បានស្តាប់ធម្មកថាដ៏ពីរោះដូច្នោះ " គិតបណ្តើរក្រឡេកមើលបណ្តើរទៅព្រះចេតិយដ៏សក្បុស ដូចគំនរគជ់ខ្យងនោះឯង ឧព្វេគ្គាបីតិក៏កើតឡើង នាងក៏អណ្តែតលឿនស្ទេរទៅក្នុងអាកាស ហើយចុះនៅទីលានព្រះចេតិយមុនមាតាបិតាទៀត បានសំពះព្រះចេតិយ ហើយឈរស្តាប់ព្រះធម៌ ពេលមាតាបិតាមកដល់បានសួរនាងថា " កូនអើយ កូនមកតាមផ្លូវណា " នាងប្រាប់ថា " ខ្ញុំមកតាមផ្លូវអាកាស មិនបានមកដោយថ្មើរជើងទេ " នាងត្រូវសួរទៀតថា " ផ្លូវអាកាស ! ពួកព្រះខីណាស្រពទើបទៅមកបាន ចំណែកនាងមកបានយ៉ាងណា " ទើបនាងប្រាប់ថា " កាលខ្ញុំឈរសម្លឹងមើលព្រះចេតិយតាមពន្លឺព្រះចន្ទ ពលវបីតិមានព្រះពុទ្ធគុណជាអារម្មណ៍ក៏កើតឡើង ពេលនោះខ្ញុំមិនដឹង

ជាខ្លួនឈរ ឬ អង្គុយឡើយ ដឹងថាខ្លួនខ្ញុំអណ្ដែតឡើងទៅក្នុងអាកាស តាមនិមិត្ត ដែលចិត្តកាន់យកនោះឯង ហើយក៏បានមកឈរនៅត្រង់ទីលានព្រះចេតិយនេះ ។

**ឧព្វេង្គាបីតិ** ជាបីតិ( ដ៏មានកម្លាំង ) រហូតធ្វើឲ្យកាយអណ្ដែតទៅក្នុងអាកាស បាន ដូចនិទស្សនៈដែលបានពោលមកនេះ ។

នៅពេល **ផរណាបីតិ** កើតឡើង សរីរៈរមែងជ្រួតជ្រាបទូទៅពេញរាងកាយ ដូចជាតម្រងនោមដែលពេញទៅដោយទឹកនោម និងដូចជាអន្លង់ទឹកដែលទឹកជំនន់ធំ ជន់ ហូរចូលទៅ ។

បីតិ ៥ យ៉ាងនេះ កាលតាំងគភ៌រហូតដល់កម្រិត រមែងញ៉ាំងបស្សទ្ធិ២យ៉ាង គឺ កាយប្បស្សទ្ធិ និង ចិត្តប្បស្សទ្ធិឲ្យកើតបរិបូរណ៍ , **បស្សទ្ធិ** កាលតាំងគភ៌ រហូតដល់កម្រិត រមែងញ៉ាំងសុខទាំង២យ៉ាង គឺ កាយិកសុខ និង ចេតសិកសុខ ឲ្យកើតបរិបូរ , **សុខ** កាលតាំងគភ៌ដល់កម្រិត រមែងញ៉ាំងសមាធិ ៣ យ៉ាង គឺ ខណិកសមាធិ ឧបចារសមាធិ និង អប្បនាសមាធិឲ្យពេញបរិបូរ ។

ក្នុងបីតិ ៥ យ៉ាងនោះ **ផរណាបីតិ** ណាដែលចម្រើនឡើង ជាមូលនៃ អប្បនាសមាធិ រហូតប្រកបចូលជាមួយសមាធិបាន ផរណាបីតិនេះជាបីតិដែល លោកបំណងយកក្នុងអត្ថនេះ ។ ចំណែកបទក្រៅពីនេះ គឺ **សុខំ** មានអត្ថដូច្នេះ សេចក្ដីសប្បាយ ឈ្មោះថា **សុខ** ។ ន័យម្យ៉ាងទៀត ធម្មជាតិណាផ្ដាច់ចោល ឬ បំបាត់ចេញ គឺកម្ចាត់ចោលដោយល្អនូវអាពាធក្នុងកាយនិងចិត្ត ហេតុនោះ ធម្មជាតិ នោះ ទើបឈ្មោះថា **សុខ** សុខនោះមានការគាប់ចិត្ត ជាលក្ខណៈ មានការធ្វើ សម្បយុត្តធម៌ដែលរួមជាមួយខ្លួន ឲ្យចម្រើនជារស មានការជួយឧបត្ថម្ភសម្បយុត្ត ធម៌ ជាអាការប្រាកដ ។ សូម្បីថា គ្មានការញែកឲ្យដាច់ពីគ្នាបានវាង បីតិនិងសុខ

ក៏ពិត បណ្ឌិតគប្បីជ្រាបថា សេចក្ដីត្រេកអរព្រោះបាននូវឥដ្ឋារម្មណ៍ ជាបីតិ , ការសោយរសនៃឥដ្ឋារម្មណ៍ដែលបាន ជាសុខ , បីតិមាននៅក្នុងទីណា សុខរមែងមាននៅក្នុងទីនោះ , តែសុខមាននៅក្នុងទីណា បីតិមិនប្រាកដថាមាននៅក្នុងទីនោះទេ ។ បីតិ លោកសង្គ្រោះក្នុងសង្ខារក្ខន្ធ សុខ សង្គ្រោះក្នុងវេទនាខន្ធ បីតិប្រៀបដូចជាការត្រេកអរ ព្រោះបានឃើញ ឬបានឮដំណឹងថា មានម្លប់ឈើ ឬ ទឹក , សុខប្រៀបដូចជាការរីករាយព្រោះបានចូលជ្រកក្នុងម្លប់ឈើ ឬបានបរិភោគទឹកនៃបុគ្គលដែលអស់កម្លាំងនៅក្នុងសមុទ្រខ្សាច់ នេះពោលតាមបីតិ និង សុខមានប្រាកដនៅក្នុងសម័យនោះ ។

បីតិផង សុខផង មានប្រការដូចដែលពោលមក មានហើយដល់ឈាននោះ ឬថា មាននៅក្នុងឈាននោះ ហេតុនោះ ឈាននេះ ទើបលោកពោលថា " **បីតិសុខំ** "មានបីតិនិងសុខ ។ ន័យម្យ៉ាងទៀត បីតិផង សុខផង ឈ្មោះថា **បីតិសុខំ** បីតិនិងសុខ ដូចបទគូទាំងឡាយ មានបទថា **ធម្មវិនយ** ( ធម៌ និង វិន័យ ) ជាដើម ។ បីតិ និង សុខ ដែលកើតពីវិវេក មានហើយដល់ឈាននោះ ឬ មានហើយក្នុងឈាននោះ ហេតុនោះឈាននោះ ទើបលោកហៅថា ( **វិវេកជម្បីតិសុខំ** ) មាន បីតិនិងសុខ ដែលកើតពីវិវេក ដូច្នេះក៏បាន ការពិត ឈានជាវត្ថុដែលកើតពីវិវេក យ៉ាងណាក្ដី សូម្បីបីតិ និង សុខក្នុងឈាននោះ ក៏ជាវត្ថុកើតពីវិវេកដូចគ្នា ដូច្នោះហើយបីតិ និង សុខ ដែលកើតពីវិវេកនោះ មានហើយដល់ឈាននោះផង ព្រោះហេតុនោះ ទើបលោកពោលថា **វិវេកជម្បីតិសុខំ** ដោយបទដូចគ្នានោះឯងទើបត្រឹមត្រូវ ។ ចំណែកក្នុងវិភង្គពោលទុក ដោយន័យថា " សុខនេះប្រព្រឹត្តទៅព្រមជាមួយនឹងបីតិ " ដូច្នេះជាដើម ។ តែវីមសារ សូម្បីក្នុងវិភង្គបាឋៈនោះ ក៏គួរ

ឃើញតែម្យ៉ាងដូចគ្នា ។ ពាក្យថា **បឋមំ ឈានំ** នេះ នឹងមានប្រាកដច្បាស់ខាងមុខ ។

បទថា **ឧបសម្បជ្ជ** ប្រែថា ចូលដល់ហើយ មានអធិប្បាយថា សម្រេចហើយ ឬ ប្រែថា ឲ្យចូលដល់ព្រមហើយ មានអធិប្បាយថា ឲ្យសម្រេចហើយ តែក្នុងវិភង្គអធិប្បាយទុក ( ជា **នាមកិតក** )ថា " បទថា **ឧបសម្បជ្ជ** គឺ ការបានចូល ការចូលដល់ ការចូលត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការសម្រេចដល់នូវឈានទី ១ " ដូច្នេះបណ្ឌិតគប្បីឃើញថា ខ្លឹមសារសូម្បីវិភង្គបាឋ:នោះ ក៏តែម្យ៉ាងដូចគ្នា ។

បទថា **វិហរតិ** គឺ ព្រះយោគាវចរជាអ្នកបានឈាន មានប្រការដូចពោលមកនេះ ហើយញុំាងការកម្រើកញាប់ញ័រ ការប្រព្រឹត្តទៅ ការរក្សាទុក ការបន្តដំណើរទៅ ការទៅមកបាន ការរស់នៅបាននៃអត្តភាពឲ្យសម្រេចដោយឥរិយា-បថវិហារ ( ការផ្លាស់ប្តូរឥរិយាបថ ) ដែលសមគួរដល់ឈាននោះ សមដូចពាក្យដែលលោកពោលទុកក្នុងវិភង្គថា " បទថា **វិហរតិ** មានន័យថា រមែងកម្រើក ប្រព្រឹត្តទៅ រក្សា បន្ត ដំណើរទៅ ទៅមកបាន នៅបាន ទៅបាន ព្រោះហេតុនោះ ទើបពោលថា **វិហរតិ** " ដូច្នេះ ។

ចំណែកពាក្យណាដែលខ្ញុំម្ចាស់ពោលទុកថា បឋមជ្ឈានលះអង្គ ៥ ដូច្នេះ ។ សភាពដែលបឋមជ្ឈានលះអង្គ៥ ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃការលះបង់នីវរណៈ ៥ ទាំងនេះ គឺ កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ព្រោះបើនីវរណធម៌ទាំងនោះ នៅមិនទាន់បានលះបង់ទេ ឈាននឹងកើតឡើងមិនបាន ហេតុនោះ នីវរណធម៌ទាំងនោះ ទើបហៅថា " អង្គដែលត្រូវលះ " នៃបឋមជ្ឈាននោះ សូម្បីថា ធម៌ទាំងឡាយដែលជាអកុសលដទៃៗ ក៏លះបានក្នុងខណៈនៃឈានផងដែរ ។ ពិតហើយ នីវរណៈ៥ នេះប៉ុណ្ណោះ ជាអ្នកធ្វើអន្តរាយ

ដល់ឈានយ៉ាងវិសេស ជាការពិត ចិត្តដែលត្រូវកាមច្ឆន្ទៈប្រលោមទៅក្នុងអារម្មណ៍ផ្សេងៗហើយ រមែងមិនតាំងមាំនៅក្នុងអារម្មណ៍តែមួយ ។ ន័យមួយទៀត ចិត្តនោះត្រូវកាមច្ឆន្ទៈគ្របសង្កត់ហើយ រមែងមិនអាចទៅកាន់ផ្លូវដែលនឹងលះបង់កាមធាតុបានទេ ។ ម្យ៉ាងទៀត ចិត្តនោះត្រូវព្យាបាទខ្ទាំងខ្ទប់ទៅក្នុងអារម្មណ៍ រមែងប្រព្រឹត្តទៅយ៉ាងលំបាក , ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ រមែងជាចិត្តមិនគួរដល់ការងារ មានឧទ្ធច្ចកុក្កុច្ចៈនៅអំពីខាងមុខហើយ រមែងជាចិត្តស្ងប់មិនបាន មានគំនិតប្រប្រូក-ប្រប្រល់ ត្រូវវិចិកិច្ឆាពាំងហើយ រមែងមិនអាចឡើងកាន់ផ្លូវដែលធ្វើឲ្យដល់នូវការសម្រេចឈានបាន ។ នីវរណៈ ៥ នេះប៉ុណ្ណោះ ដែលលោកហៅថា អង្គដែលចាំបាច់ត្រូវលះ ព្រោះជាហេតុធ្វើឲ្យអន្តរាយដល់ឈានយ៉ាងវិសេស ដូចពោលមកដូច្នេះ ។

ព្រោះថា **វិតក្ក** រមែងលើកចិត្តឲ្យឡើងកាន់អារម្មណ៍ **វិចារ** តាមចងទុក បីតិដែលកើតពីប្រយោគសម្បត្តិធ្វើការរីករាយ ហើយសុខធ្វើសេចក្ដីចម្រើនរុងរឿងដល់ចិត្តដែលមាន(ភាវនា) ប្រយោគត្រូវវិតក្កនោះធ្វើឲ្យសម្រេចហើយ ដោយមិនរាយមាយ គ្រានោះឯកគ្គតាដែលមានការលើកចិត្ត មានការតាមចងព័ទ្ធ សេចក្ដីរីករាយ និងសេចក្ដីចម្រើនទាំងនោះឧបត្ថម្ភហើយ រមែងតាំងទុកនូវចិត្តនោះ ព្រមទាំងសម្បយុត្តធម៌ដ៏សេស ដោយស្មើ និងដោយល្អ ក្នុងអារម្មណ៍តែមួយ ព្រោះហេតុនោះ ការដែលបឋមជ្ឈានប្រកបដោយអង្គ ៥ បណ្ឌិតគប្បីជ្រាបដោយការកើតឡើងនៃអង្គ ៥ នេះ គឺ **វិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតា** កាលបើអង្គ ៥ នេះកើតឡើងហើយ ឈានទើបបានឈ្មោះថា កើតហើយ ដោយហេតុនោះ អង្គ ៥ នោះ ទើបលោកពោលថា “ អង្គប្រកប ” នៃបឋមជ្ឈាននោះ ព្រោះដូច្នោះ

មិនគួរប្រកាន់ថា នៅមានឈានដទៃដែលប្រកបដោយអង្គ ៥ ទៀត ដូចជា **សេនា** លោកពោលថា ប្រកបដោយអង្គ៤ តន្ត្រីពោលថា ប្រកបដោយអង្គ៥ មគ្គពោលថា ប្រកបដោយអង្គ៨ក៏ដោយ អង្គប៉ុណ្ណោះដោយពិត យ៉ាងណា សូម្បីបឋមជ្ឈាននេះ ក៏គប្បីជ្រាបថា លោកពោលថា មានអង្គ៥ ឬថាប្រកបដោយអង្គ៥ ក៏ដោយ អំណាចនៃអង្គប៉ុណ្ណោះ ដូចគ្នាដូច្នោះ អង្គ ៥ នេះ រមែងមាន សូម្បីក្នុងខណៈនៃឧបចារៈដោយពិត ប៉ុន្តែថា ក្នុងឧបចារៈ អង្គ ៥ នោះ មានកម្លាំងក្រៃលែងជាង **បកតិចិត្ត** ( កាមាវចរចិត្ត ) ចំណែកក្នុងឈាននេះ អង្គទាំងនោះ បានលក្ខណៈរូបាវចរចិត្ត រមែងមានកម្លាំងក្រៃលែងជាងឧបចារចិត្ត ។ ការពិតក្នុងអង្គទាំងនោះ វិតក្ក លើកចិត្តឡើងកាន់អារម្មណ៍ ដោយអាការដែលជាក់ច្បាស់ក្រៃលែង វិចារក៏តាមសង្កេតអារម្មណ៍យ៉ាងពេញទំហឹង បីតិ និងសុខក៏ផ្សាយទូទៅសព្វសព៌ាង្គកាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា “ អង្គ( អវយវៈ ) សូម្បីតូចៗ នៃសព៌ាង្គកាយរបស់អ្នកដែលបានបឋមជ្ឈាននោះ រមែងពាល់ត្រូវដោយបីតិ និងសុខដែលកើតពីវិវេក ” ដូច្នេះ សូម្បីចិត្តេកគ្គតា ក៏ពាល់ត្រូវនូវអារម្មណ៍ទាំងឡាយ ដូចជាគម្របស្មុគ្គពាល់ត្រូវមាត់ស្មុគ្គខាងក្រោមដូច្នោះ នេះជាសេចក្តីវិសេសជាងកាមាវចរចិត្ត ក្រៅពីអង្គឈានទាំង ៥ នោះ ។

ក្នុងអង្គ៥នោះ **ចិត្តេកគ្គតា** ព្រះមានព្រះភាគមិនបានចង្អុលទុកក្នុងបាឋៈថា **សវិតក្កំ ... សវិចារំ ...** នេះក៏ពិត សូម្បីយ៉ាងនោះ **ចិត្តេកគ្គតា** ក៏រាប់ចូលជាអង្គបាន ព្រោះទ្រង់ត្រាស់ទុកក្នុងវិភង្គថា “ ពាក្យថា **ឈាន** គឺ វិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតា ”ដូច្នេះ ពិតណាស់ ឧទ្ទេស ព្រះមានព្រះភាគធ្វើដោយអធិប្បាយណា អធិប្បាយនោះ ព្រះអង្គទ្រង់បានប្រកាសហើយក្នុងវិភង្គនោះ ។

ចំណែកវិនិច្ឆ័យក្នុង ២ បទថា “ បឋមជ្ឈានមានលំអ ៣ ប្រការ ដល់ព្រម ដោយលក្ខណៈ១០នោះ ដូច្នេះ ការដែលបឋមជ្ឈានមានលម្អ ៣ ប្រការ បណ្ឌិត គប្បីជ្រាបដោយចាត់ជាខាងដើម កណ្តាល ខាងចុង ហើយការដែលឈាននោះដល់ ព្រមដោយលក្ខណៈ១០ ក៏គប្បីជ្រាបដោយលក្ខណៈខាងដើម កណ្តាល ខាងចុង ទាំងនោះឯង ។ ព្រះបាលីក្នុងរឿងនេះមានដូច្នេះ “ **បដិបទាវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃបដិបទា** ”ជាខាងដើមនៃបឋមជ្ឈាន **ឧបេក្ខានុព្រូហនា** ( ការចម្រើននូវឧបេក្ខា ) ជាកណ្តាលនៃបឋមជ្ឈាន **សម្បហំសនា** សេចក្តីរីករាយ ជាទីបំផុតនៃបឋមជ្ឈាន ។

ក្នុងសេចក្តីថា បដិបទាវិសុទ្ធិជាខាងដើមនៃបឋមជ្ឈាននោះ សួរថា លក្ខណៈនៃខាងដើមមានប៉ុន្មាន ? ឆ្លើយថា លក្ខណៈនៃខាងដើមមាន៣ គឺ ចិត្តបរិសុទ្ធពីអន្តរាយនៃបឋមជ្ឈាននោះ១ ព្រោះសេចក្តីបរិសុទ្ធិហើយ ចិត្តរមែងប្រព្រឹត្តទៅកាន់សមថនិមិត្តដែលជាខ្សែកណ្តាល១ ព្រោះបានការប្រព្រឹត្តទៅហើយ ចិត្តរមែងត្រង់ទៅក្នុងសមថៈនោះ១ សភាពដែលចិត្តបរិសុទ្ធពីអន្តរាយក្តី កាលបើបរិសុទ្ធហើយចិត្តរមែងបង្អោនទៅកាន់សមថនិមិត្តដែលជាខ្សែកណ្តាលក្តី ព្រោះប្រព្រឹត្តទៅក្តី ចិត្តរមែងត្រង់ទៅក្នុងសមថៈក្តី នេះជាបដិបទាវិសុទ្ធិ ជាខាងដើមនៃបឋមជ្ឈាន នេះជាលក្ខណៈ៣នៃខាងដើម ព្រោះហេតុនោះ ទើបលោកពោលថា បឋមជ្ឈានជាគុណមានលំអក្នុងខាងដើមផង ដល់ព្រមដោយលក្ខណៈ ៣ ផង ។

សេចក្តីចម្រើននៃឧបេក្ខាជាផ្នែកកណ្តាលនៃបឋមជ្ឈាននោះ សួរថា លក្ខណៈនៃផ្នែកកណ្តាលនោះមានប៉ុន្មាន ? ឆ្លើយថា លក្ខណៈដែលជាផ្នែកកណ្តាលនោះមាន៣ គឺ ព្រះយោគាវចររមែងសម្លឹងមើលព្រងើយៗ នូវចិត្តដែលបរិសុទ្ធហើយ១ រមែងសម្លឹងមើលព្រងើយៗនូវចិត្តដែលបង្អោនទៅកាន់សមថៈហើយ១ រមែងសម្លឹង

មើលព្រងើយៗ នូវការតាំងមាំក្នុងអារម្មណ៍តែមួយ ១ ។ ការដែលព្រះយោគាវចរ សម្លឹងមើលយ៉ាងព្រងើយៗ នូវចិត្តដែលបរិសុទ្ធហើយក្តី នូវចិត្តដែលបង្អោនទៅកាន់សមថៈហើយក្តី នូវការតាំងមាំក្នុងអារម្មណ៍តែមួយក្តី នេះជាការចម្រើននៃឧបេក្ខា ជាផ្ទៃកកណ្តាលនៃបឋមជ្ឈាន នេះជាលក្ខណៈ៣ នៃផ្ទៃកកណ្តាល ព្រោះហេតុនោះ ទើបលោកពោលថា បឋមជ្ឈានជាគុណមានលម្អផ្ទៃកកណ្តាលផង ដល់ព្រមដោយលក្ខណៈ ៣ ផង ។

សេចក្តីរីករាយជាទីបំផុតនៃបឋមជ្ឈាននោះ សួរថា លក្ខណៈនៃទីបំផុតមានប៉ុន្មាន ? ឆ្លើយថា លក្ខណៈនៃទីបំផុតមាន៤ គឺ សេចក្តីរីករាយ សំដៅដល់ធម៌ទាំងឡាយដែលកើតក្នុងបឋមជ្ឈានចិត្តនោះ មានការប្រព្រឹត្តទៅមិនកន្លងគ្នា១ សេចក្តីរីករាយ សំដៅដល់ឥន្ទ្រិយទាំងឡាយមានរសដូចគ្នា១ សេចក្តីរីករាយសំដៅដល់ការប្រារព្ធសេចក្តីព្យាយាម ដែលសមគួរដល់ការៈនោះឲ្យប្រព្រឹត្តទៅ១ សេចក្តីរីករាយ សំដៅដល់ ឈានចិត្តនោះជាអាសេវនៈ១ ។ ( ៤ ប្រការនេះចាត់ជា ) សេចក្តីរីករាយជាទីបំផុតនៃបឋមជ្ឈាន នេះជាលក្ខណៈ៤នៃទីបំផុត ព្រោះហេតុនោះ ទើបលោកពោលថា បឋមជ្ឈានជាគុណមានលម្អខាងចុងផង ដល់ព្រមដោយលក្ខណៈ ៤ ផង ” ដូច្នេះ ។

## អត្ថាធិប្បាយបាលី តិវិធកល្យាណតា

អាចារ្យមួយពួកពណ៌នាទុកថា “ ក្នុងធម៌ ៣ ប្រការនោះ ឧបចារៈព្រមទាំងសំភារៈ( អង្គប្រកប ) ឈ្មោះថា **បដិបទាវិសុទ្ធិ** , **អប្បនា** ឈ្មោះថា **ឧបេក្ខានុព្រូហនា** , **បច្ចវេក្ខណា** ឈ្មោះថា **សម្បហំសនា** ” ។ តែព្រោះថា ក្នុងព្រះបាលីពោលទុកថា “ ចិត្តដែលដល់នូវភាពតែមួយហើយ រមែងជាចិត្តស្ទុះទៅកាន់

បដិបទាវិសុទ្ធិផង ជាចិត្តដែលឧបេក្ខាចម្រើនផង ជាចិត្តដែលញាណធ្វើឲ្យរីករាយផង " ដូច្នេះ ព្រោះដូច្នោះ **បដិបទាវិសុទ្ធិ** បណ្ឌិតគប្បីជ្រាបថាជា( បរិកម្ម ) មកខាងក្នុងនៃអប្បនានោះឯង **ឧបេក្ខានុព្រូហនា** គប្បីជ្រាបថា ជាកិច្ចនៃតត្រមជ្ឈត្តតានិង **សម្បហំសនា** គប្បីជ្រាបថា ការសម្រេចកិច្ចនៃញាណដែលធ្វើឲ្យផូរផង់ ដោយញុំាងភាវៈ គឺការមិនប្រព្រឹត្តទៅកន្លងគ្នានៃធម៌ទាំងឡាយជាដើមឲ្យសម្រេច សួរថា ពាក្យដែលពោលនេះ មានអត្ថាធិប្បាយយ៉ាងណា ? ឆ្លើយថា អប្បនាកើតឡើងក្នុងវារៈណា ក្នុងវារៈនោះ ចិត្តរមែងបរិសុទ្ធចាកពពួកកិលេស ពោលគឺ នីវរណៈដែលធ្វើអន្តរាយដល់ឈាននោះ ព្រោះបរិសុទ្ធហើយ ចិត្តក៏ជាធម្មជាតិប្រាសចាកគ្រឿងរារាំងដំណើរទៅកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាល អប្បនាសមាធិដែលប្រព្រឹត្តទៅស្មើនោះឯង ឈ្មោះថា សមថនិមិត្តដែលជាផ្លូវកណ្តាល ក៏បុរិមចិត្ត (គោត្រភូចិត្ត) ដែលជាអនន្តរប្បច្ច័យនៃអប្បនាចិត្តនោះ កាលចូលដល់ភាពជាចិត្តមាំទាំដោយបរិណាមន័យ(ន័យនៃការប្រែប្រួល) មួយជួរសន្តតិ ឈ្មោះថា ដំណើរទៅកាន់សមថនិមិត្តដែលជាផ្លូវកណ្តាល ព្រោះដំណើរទៅយ៉ាងនោះ ចិត្តឈ្មោះថា បង្អោនទៅកាន់សមថៈនោះ ដោយចូលដល់ភាពជាចិត្តមាំទាំ បដិបទាវិសុទ្ធិដែលញុំាងអាការ ( មានភាពបរិសុទ្ធិចាកអន្តរាយជាដើម ) ដែលមាននៅក្នុងបុរិមចិត្តនោះឲ្យសម្រេច បណ្ឌិតគប្បីជ្រាបថា (ជាបរិកម្ម)មកក្នុងឧប្បាទខណៈនៃបឋមជ្ឈាននោះឯង តាមន័យដូចពោលមកនេះជាសេចក្តីដំបូង ។

ម្យ៉ាងទៀត កាលបើចិត្តនោះបរិសុទ្ធហើយយ៉ាងនោះ ព្រះយោគាវចរមិនត្រូវធ្វើសេចក្តីខ្វាយខ្វល់ក្នុងការជម្រះទេ ព្រោះមិនមានអ្វីត្រូវជម្រះទៀត ឈ្មោះថា សម្លឹងមើលយ៉ាងព្រងើយ ៗ នូវចិត្តដែលបរិសុទ្ធហើយ កាលចិត្តដំណើរទៅកាន់សមថៈ

ដោយចូលដល់ភាពជាសមថៈហើយ ព្រះយោគាវចរមិនត្រូវធ្វើសេចក្ដីខ្វាយខ្វល់ក្នុងការសមាទានទៀត ឈ្មោះថា សម្លឹងមើលព្រងើយៗនូវចិត្តនោះដែលបង្អោនទៅកាន់សមថៈហើយ ។ កាលចិត្តនោះ លះបង់នូវភាពប្រឡូកប្រឡល់ដោយសង្កិលេសហើយតាំងមាំនៅក្នុងអារម្មណ៍តែមួយ ព្រោះការដែលចិត្តបង្អោនទៅកាន់សមថៈនោះឯង ព្រះយោគាវចរមិនចាំបាច់ធ្វើនូវសេចក្ដីខ្វាយខ្វល់ ក្នុងការតាំងចិត្តទុក នៅក្នុងអារម្មណ៍តែមួយនោះទៀតទេ ។

ឈ្មោះថា មើលដោយភាពព្រងើយៗ នូវការតាំងមាំនៅក្នុងអារម្មណ៍តែមួយ **ឧបេក្ខានុព្រូហនា** បណ្ឌិតគប្បីជ្រាបថា ជាកិច្ចនៃតត្រមជ្ឈត្តុបេក្ខា តាមន័យដូចពោលមកនេះចុះ ។

ម្យ៉ាងទៀត **យុគនទ្ធធម៌** (ធម៌គូ ដូចគូនៃគោដែលចាប់ទឹមក្នុងនឹមជាមួយគ្នា) ពោលគឺ សមាធិនិងបញ្ញា ដែលកើតក្នុងឈានចិត្តនោះ ដែលឧបេក្ខាចម្រើនហើយយ៉ាងនេះ ទាំងនោះ ជាធម៌មិនកន្លងគ្នានិងគ្នា ( គឺ ស្មើគ្នា ) ប្រព្រឹត្តទៅ ហើយក្ដីឥន្ទ្រិយទាំងឡាយមានសទ្ធាជាដើមទាំងឡាយណា ជាគុណមានរសតែ មួយដោយរស គឺ **វិមុត្ត** ព្រោះរួចផុតពីកិលេសផ្សេងៗ ប្រព្រឹត្តទៅហើយក្ដី ព្រះយោគាវចរញុំាងសេចក្ដីព្យាយាមណាដែលគួរដល់ភាវៈនោះ គឺគួរដល់ភាវៈ គឺ ការមិនប្រព្រឹត្តកន្លងគ្នានៃធម៌ទាំងនោះ និង ជាគុណមានរសតែមួយ ( នៃឥន្ទ្រិយទាំងឡាយ ) ឲ្យប្រព្រឹត្តទៅក្ដី **អាសេវនា** (អាស្រ័យការសេព) នៃឈានចិត្តនោះណា ប្រព្រឹត្តទៅហើយនៅក្នុងខណៈនោះក្ដី អាការទាំងពួងនោះ ឈ្មោះថា សម្រេចព្រោះជាអាការដែលព្រះយោគាវចរឃើញទោស និង អានិសង្សនោះៗ ដោយសារភាពសៅហ្មងនិងភាពបរិសុទ្ធិដោយញាណហើយ ញុំាងចិត្តឲ្យរីករាយ គឺឲ្យហ្មត់ចត់

ឲ្យផូរផង់ដោយអាការនោះៗ ព្រោះហេតុណា ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា “ **សម្បហំសនា** ” បណ្ឌិតគប្បីជ្រាបថា ជាការសម្រេចកិច្ចនៃញាណដែលធ្វើឲ្យបរិសុទ្ធ ដោយញុំាងភាវៈ គឺ ការមិនប្រព្រឹត្តកន្លងគ្នានៃធម៌ទាំងឡាយជាដើម ឲ្យសម្រេចដូច្នេះ ។

ព្រោះហេតុ ដែលក្នុងភាវនាចិត្តនោះ ញាណរមែងប្រាកដដោយអំណាចនៃឧបេក្ខា ដូចព្រះបាលីថា ព្រះយោគាវចររមែងសម្លឹងមើលយ៉ាងព្រងើយៗ ដោយល្អនូវចិត្តដែលលើកឡើង ( ដោយវីរិយសម្ពោជ្ឈង្គៈ ) យ៉ាងនោះហើយ បញ្ញិន្ទ្រិយរមែងជាគុណមានប្រមាណយ៉ាងក្រៃលែងដោយអំណាចនៃឧបេក្ខា និងដោយអំណាចនៃបញ្ញា ចិត្តរមែងផុតចាកពីកិលេសផ្សេងៗ ដោយអំណាចនៃឧបេក្ខា បញ្ញិន្ទ្រិយ៍រមែងជាគុណមានប្រយោជន៍ក្រៃលែង ដោយអំណាចនៃការរួចផុត និង ដោយអំណាចនៃបញ្ញា ព្រោះរួចផុតចាកកិលេសផ្សេងៗ ហើយធម៌ទាំងឡាយនោះ (មានសទ្ធាជាដើម) រមែងជាធម៌មានរសតែមួយ ព្រោះអត្ថ គឺ ភាពមានរសតែមួយ ( នៃធម៌ទាំងនោះ ) ភាវនាទើបមាន ដូច្នេះ ព្រោះហេតុនោះ **សម្បហំសនា** ដែលជាកិច្ចនៃញាណ ទើបលោកពោលថា ជាទីបំផុត ( នៃបឋមជ្ឈាន ) ។

ពេលនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបាឋៈថា **បឋមំ ឈានំ អធិគតំ ហោតិ បឋវីកសិណំ** បឋមជ្ឈានបឋវីកសិណដែលព្រះយោគាវចរបានសម្រេចហើយនេះ ។

## បឋមជ្ឈាន

ឈាននេះ ឈ្មោះថា **បឋម** ព្រោះមានលំដាប់នៃចំនួន ១ៈថា ឈ្មោះថា **បឋម** ព្រោះកើតឡើងជាដំបូង គុណណា ឈ្មោះថា **ឈាន** ព្រោះចូលទៅសម្លឹង

អារម្មណ៍ ឬថា ព្រោះដុតបំផ្លាញនូវធម៌ជាសត្រូវ ចំណែកវង្វង់ដីដែលលោកហៅថា **បឋវីកសិណ** ព្រោះសំដៅដល់ដីទូទៅ សូម្បីនិមិត្តដែលព្រះយោគាវចរអាស្រ័យវង្វង់ដីនោះ បានកើតឡើង ក៏ហៅថា **បឋវីកសិណ** សូម្បីឈានដែលបានព្រោះនិមិត្តនោះ ក៏ហៅថា **បឋវីកសិណ** ក្នុងអត្ថនៃបឋវីកសិណ៣យ៉ាងនោះ ក្នុងអត្ថនោះបណ្ឌិតគប្បីជ្រាបថា **ឈាន** ឈ្មោះថា បឋវីកសិណ បាឋៈថា “ **បឋមំ ឈានំ អធិគតំ ហោតិ បឋវីកសិណំ** ” នោះលោកពោលសំដៅយកអត្ថនេះ ។

កាលដែលបានសម្រេចបឋមជ្ឈានយ៉ាងនេះហើយ ព្រះយោគាវចរនោះ គប្បីកំណត់យកអាការក្នុងឈាននេះឲ្យបាន ដូចអ្នកបាញ់រោមទ្រាយ និង ចុងភៅដូច្នោះ នាយខ្មាន់ធ្នូដែលជាអ្នកឆ្លាត ធ្វើការបាញ់រោមទ្រាយ បាញ់ត្រូវរោមទ្រាយក្នុងវារៈណា គប្បីកំណត់យកជំហរដែលឈរជ្រែងល្អ នៃដងធ្នូ នៃខ្សែធ្នូ នៃគ្រាប់ព្រួញក្នុងវារៈនោះថា យើងឈរដោយអាការយ៉ាងនេះ ចាប់ដងធ្នូយ៉ាងនេះ ចាប់ខ្សែធ្នូយ៉ាងនេះ ចាប់គ្រាប់ព្រួញយ៉ាងនេះ ទើបបាញ់ត្រូវរោមទ្រាយ ដូច្នេះ បន្ទាប់ពីនោះទៅគេធ្វើអាការទាំងឡាយនោះឲ្យត្រឹមត្រូវដូច្នោះ នឹងបាញ់រោមទ្រាយមិនខុស យ៉ាងណា សូម្បីព្រះយោគាវចរក៏ដូច្នោះដែរ ត្រូវកំណត់យកអាការទាំងឡាយមាន ភោជនសប្បាយជាដើមយ៉ាងនេះថា “ យើងបរិភោគភោជនឈ្មោះនេះ ហើយសេពគប់បុគ្គលរូបនេះ នៅក្នុងសេនាសនៈដូច្នេះ បានសម្រេចឈាននេះ ដោយឥរិយាបថប៉ុណ្ណេះក្នុងកាលនេះ ” ដូច្នេះ កាលកំណត់បានយ៉ាងនេះ កាលឈាន( ថ្មីៗ ) នោះវិនាសទៅក្តី លោកអាចធ្វើអាការទាំងនោះឲ្យដល់ព្រម ហើយញ៉ាំងឈាននោះឲ្យកើតឡើងបានទៀត កាលធ្វើឈាននោះដែលនៅមិនទាន់ស្ទាត់ជំនាញ ឲ្យស្ទាត់ជំនាញក្តី លោកនឹងអាចធ្វើឲ្យដល់អប្បនាបានរឿយៗម្យ៉ាងទៀត ប្រៀបដូចចុង

ភៅដែលជាអ្នកឆ្លាត ផ្គត់ផ្គង់ចៅហ្វាយ ចៅហ្វាយបរិភោគអាហារណាៗ ដោយការពេញចិត្ត ក៏ចំណាំអាហារនោះៗទុក ហើយបន្ទាប់ពីនោះក៏យកអាហារយ៉ាងនោះឯងចូលទៅឲ្យចៅហ្វាយនោះ រមែងបានរង្វាន់យ៉ាងណា សូម្បីព្រះយោគាវចរ ក៏ដូច្នោះ ចាប់អាការទាំងឡាយ មានការបរិភោគភោជនជាដើម ក្នុងខណៈដែលបានសម្រេចឈាន ហើយធ្វើអាការទាំងនោះឲ្យដល់ព្រម ក៏រមែងជាអ្នកបានអប្បនារឿយៗ ។

ព្រោះហេតុនោះ អាការទាំងឡាយ ( ដូចពោលមក ) ព្រះយោគាវចរនោះត្រូវកំណត់ចំណាំឲ្យបានដូចអ្នកបាញ់រោមទ្រាយ និង ដូចចុងភៅដូច្នោះ ពិតហើយ សូម្បីព្រះមានព្រះភាគក៏បានត្រាស់សេចក្តីនេះទុកថា “ ម្នាលភិក្ខុទាំងឡាយ ចុងភៅដែលជាអ្នកឆ្លាត គប្បីជាអ្នកប្រណិប័តន៍ព្រះរាជាខ្លះ រាជអមាត្យខ្លះដោយសម្លដែលរៀបចំដោយរសផ្សេងៗ គឺ រសជូរខ្លះ រសល្វីងខ្លះ រសហិរខ្លះ រសផ្អែមខ្លះ រសភ្លាវខ្លះ រសប្រៃខ្លះ រសសាបខ្លះ ម្នាលភិក្ខុទាំងឡាយចុងភៅដែលជាអ្នកឆ្លាតជំនាញនោះឯង រមែងសិក្សានិមិត្តរបស់ចៅហ្វាយនាយរបស់ខ្លួនថា “ ថ្ងៃនេះ សម្លនេះ ពេញចិត្តចៅហ្វាយនាយរបស់យើង ឬថាចៅហ្វាយនាយរបស់យើង រមែងលូកចំពោះសម្លនេះ ឬថាចៅហ្វាយនាយរបស់យើងដួសសម្លនេះច្រើន ឬថាចៅ-ហ្វាយនាយរបស់យើងសរសើរសម្លនេះ ឬថាថ្ងៃនេះរសសម្លជូរល្មមពេញចិត្តចៅហ្វាយនាយរបស់យើង ឬថាចៅហ្វាយនាយរបស់យើងលូកដៃចំពោះសម្លដែលមានរសជូរ ឬថាចៅហ្វាយនាយរបស់យើងដួសសម្លបន្ទោសថាជូរពេក ឬថាចៅហ្វាយនាយរបស់យើងសរសើរសម្លដែលមានរសជូរ ។ ល ។ ឬថាចៅហ្វាយនាយរបស់យើងសរសើរសម្លដែលមានរសសាប ” ម្នាលភិក្ខុទាំងឡាយ ចុងភៅដែលជាអ្នកឆ្លាតជំនាញនោះឯង រមែងជាអ្នកបាននូវគ្រឿងស្លៀកដណ្តប់ បានប្រាក់បំណាច់ និង

បានទទួលពាក្យសរសើរ នោះព្រោះហេតុអ្វី ព្រោះចុងភៅដែលជាអ្នកឆ្លាតនោះសិក្សានូវនិមិត្តរបស់ចៅហ្វាយនាយទុក ដូចបានពោលដូច្នោះយ៉ាងណាក្តី ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលជាបណ្ឌិតឆ្លាតរូបខ្លះក្នុងធម្មវិន័យនេះតាមមើលកាយក្នុងកាយ តាមមើលវេទនាក្នុងវេទនា តាមមើលចិត្តក្នុងចិត្ត តាមមើលធម៌ក្នុងធម៌ទាំងឡាយ គប្បីជាអ្នកមានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិកម្ចាត់អភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន កាលគេតាមមើលកាយក្នុងកាយ តាមមើលវេទនាក្នុងវេទនា តាមមើលចិត្តក្នុងចិត្ត តាមមើលធម៌ក្នុងធម៌ទាំងឡាយហើយ ចិត្តក៏រមែងជាសមាធិ ឧបក្កិលេសទាំងឡាយគេរមែងលះបង់បាន គេក៏រៀនយកនិមិត្តនោះទុក ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាបណ្ឌិតឆ្លាតនោះឯង រមែងជាអ្នកបានទិដ្ឋធម៌ សុខវិហារ ( ឈាន ) ទាំងឡាយ បានសតិសម្បជញ្ញៈ នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុដែលជាបណ្ឌិតឆ្លាតនោះរៀនយកនិមិត្តនៃចិត្តរបស់ខ្លួនទុក ដូចបានពោលហើយនោះឯង ” ដូច្នេះ ។

កាលព្រះយោគាវចរនោះប្រើវិធីចាប់យកនិមិត្ត( នៃចិត្តរបស់ខ្លួនជាលំអាន ) ធ្វើអាការទាំងឡាយនោះ ឲ្យដល់ព្រមបានទៀត ក្នុងខណៈដែលអប្បនាសម្រេចហើយតាំងនៅមិនបានយូរ ការតាំងនៅបានយូរ មានបានក៏ព្រោះធម៌ទាំងឡាយដែលជាសត្រូវនៃសមាធិត្រូវជម្រះទៅបានយ៉ាងល្អហើយ មែនពិត ភិក្ខុណាមិនបានគ្របសង្កត់កាមច្ឆន្ទៈដោយល្អ ដោយបច្ចវេក្ខណវិធី មានការពិចារណាទោសរបស់កាមជាដើម មិនបានធ្វើកាយដែលរសាប់រសល់ឲ្យស្ងប់រំងាប់ដោយអំណាចនៃកាយប្បស្សទ្ធិ មិនបានបន្ទោបង់នូវថីនមិទ្ធៈចេញដោយល្អ ដោយអំណាចនៃមនសិការវិធីមានមនសិការដល់អារម្ភធាតុជាដើម មិនបានធ្វើឧទ្ធច្ចកុក្កុច្ចៈឲ្យសណ្តកឡើងដោយ

ល្អ ដោយអំណាចនៃមនសិការវិធី មានមនសិការដល់សមថនិមិត្តជាដើម មិនបាន ជម្រះធម៌ដែលជាសត្រូវរបស់សមាធិដទៃៗទៀតចេញដោយល្អ ហើយចូលឈាន ភិក្ខុនោះនឹងឆាប់ចេញចាកឈានយ៉ាងពិត ដូចសត្វកន្ធង់ចូលក្នុងបំពង់ផ្សែង ព្រោះមិនបានធ្វើឲ្យហ្មត់ចត់ រមែងឆាប់ចេញដោយរហ័ស និង ដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលមិនស្អាត រមែងស្ដេចឆាប់ចេញមកវិញយ៉ាងរហ័សដូច្នោះ ចំណែកភិក្ខុណាញ៉ាំងធម៌ទាំងឡាយដែលជាសត្រូវរបស់សមាធិឲ្យហ្មត់ចត់ល្អហើយ ទើបចូលឈាន ភិក្ខុនោះអាចនៅក្នុងសមាបត្តិពេញមួយថ្ងៃ ដូចសត្វកន្ធង់ចូលក្នុងបំពង់ផ្សែងដែលបានធ្វើឲ្យស្អាតហើយ( នៅក្នុងបំពង់ផ្សែងនោះបានយូរ ) និង ដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលស្អាត( ស្ដេចនៅក្នុងឧទ្យាននោះបានយូរ )ដូច្នោះ ព្រោះហេតុនោះ ទើបព្រះបុរាណាចារ្យទាំងឡាយពោលទុកថា :

“ ព្រះយោគាវចរគប្បីដកចេញនូវឆន្ទៈក្នុងកាមទាំងឡាយ នូវបដិឃៈ នូវឧទ្ធច្ចកុក្កុច្ចៈ នូវថីនមិទ្ធៈ គម្រប់៥ទាំងវិចិកិច្ឆា មានចិត្តរីករាយនៅក្នុងវិវេក រីករាយនៅក្នុងឈាននោះ ដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលស្អាតគ្រប់កន្លែង ទ្រង់រីករាយនៅក្នុងឧទ្យាននោះ ដូច្នោះ ” ។

ព្រោះហេតុនោះ ព្រះយោគាវចរដែលប្រាថ្នានូវការតាំងនៅបានយូរ ( នៃឈាន ) គប្បីញ៉ាំងធម៌ដែលជាសត្រូវទាំងឡាយឲ្យហ្មត់ចត់ហើយ ចូលឈានចុះ ។

ម្យ៉ាងទៀត ដើម្បីភាពចម្រើននៃចិត្តភាវនា ព្រះយោគាវចរ គប្បីពង្រីកបដិភាគនិមិត្តតាមដែលបានហើយ ភូមិនៃការពង្រីកបដិភាគនិមិត្តនោះមាន ២ គឺ : ឧបចារក៏បាន អប្បនាក៏បាន មែនពិត សូម្បីដល់ឧបចារហើយ ពង្រីកបដិភាគ-និមិត្តនោះ ក៏គួរ សូម្បីដល់អប្បនាហើយ ចាំបាច់ត្រូវពង្រីកក្នុងឋានៈមួយដែលពិត

ប្រាកដ ព្រោះហេតុនោះ ទើបខ្ញុំម្ចាស់ពោលថា “ **គប្បីពង្រីកបដិភាគនិមិត្ត ដែលបានហើយ** ” ។

តទៅនេះ ជាន័យនៃការពង្រីកបដិភាគនិមិត្តនោះ ព្រះយោគាវចរនោះ មិនគប្បីពង្រីកបដិភាគនិមិត្តនោះដោយទំនងដូចជាការពង្រីកបាត្រ ទំនងដូចការពង្រីកនំ ទំនងដូចការពង្រីកបាយ ទំនងដូចការពង្រីកខ្លួននៃលតាវល្លិ និង ទំនងដូចការពង្រីកសំពត់ គួរទឹកកំណត់ថា ពង្រីកខ្នាតនៃនិមិត្តដែលបានហើយយ៉ាងណានោះ ចូរពង្រីក ១អង្គុលី ២អង្គុលី ៣អង្គុលី ៤អង្គុលី ... តាមលំដាប់ ហើយទើបពង្រីកប៉ុនដែលកំណត់ទុក បើមិនបានកំណត់ មិនគួរពង្រីកឡើយ ប្រៀបដូចអ្នកស្រែកំណត់ទីភ្ជួរ កំណត់គន្លង ហើយទើបភ្ជួរក្នុងទីដែលកំណត់ទុកនោះដូច្នោះ ម្យ៉ាងទៀត កាលដែលភិក្ខុទាំងឡាយចងសីមា កំណត់និមិត្តទាំងឡាយមុនសិន ហើយទើបចងជាខាងក្រោយដូច្នោះ តែមុននឹងពង្រីក គប្បីកំណត់ដោយខ្នាត ១ហត្ថ ១ចំអាម ប៉ុនបរិវេណផ្នែកខាងមុខនៃវិហារ ប៉ុនសីមាវិហារ ប៉ុនដែនស្រុក ប៉ុនដែននិគម ដែនជនបទ ដែនរាជអាណាខេត្ត និង ដែនសមុទ្រ ឬដោយខ្នាត ប៉ុនចក្រវាឡ ឬសូម្បីធំជាងនោះ ក៏ពង្រីកទៅបាន ប្រៀបដូចជាកូនហង្សតាំងពីកាលដែលរោមស្លាបដុះចេញ វាហាត់ហើរបន្តិចម្តងៗ រហូតហើរស្ទាត់ វាអាចហើរទៅជិតព្រះចន្ទ និង ព្រះអាទិត្យបានតាមលំដាប់យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា កាលកំណត់( ខ្នាត )ហើយ ពង្រីកនិមិត្តទៅតាមន័យដូចពោលហើយ រមែងពង្រីកទៅរហូតប៉ុនចក្រវាឡ ឬធំជាងនោះបាន និមិត្តនោះ រមែងប្រាកដដល់លោក ដូចជាស្បែកគោដែលត្រូវចិញ្ច្រាំដោយដឹង ១០០ ផ្ទៃ ព្រោះក្នុងទីទួល ទីទំនាប ជាទន្លេ ជាល្បាប់កក់ ជាភ្នំរដិបរដុបនៃផែនដី ក្នុងកន្លែងដែលពង្រីកទៅនោះ ។

ឯព្រះអាទិកម្មិក អ្នកបានបឋមជ្ឈានដោយនិមិត្តនោះហើយ គប្បីជាអ្នកចូលឈានឲ្យច្រើន មិនគប្បីបច្ចវេក្ខណៈច្រើន ព្រោះបើលោកបច្ចវេក្ខណៈច្រើនពេកទៅ អង្គឈានទាំងឡាយនឹងប្រាកដជារបស់គ្រោតគ្រាត ហើយមានកម្លាំងខ្សោយ ទីនេះព្រោះប្រាកដវិនាសយ៉ាងនោះហើយ អង្គឈាននោះ ក៏មិនសម្រេចជាបច្ច័យដល់ការចម្រើនឈានជាន់លើបាន លោកវល់តែខ្វាយខ្វល់ទៅក្នុងឈានដែលមិនស្ទាត់ជំនាញ នឹងវិនាសចាកបឋមជ្ឈាន ហើយក៏មិនអាចសម្រេចទុតិយជ្ឈានបានដែរ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាមេគោរកស៊ីនៅលើកំពូលភ្នំ ជាសត្វល្ងង់ មិនស្គាល់ច្បាស់ទីកន្លែង ( ទៅបាន មិនបាន ) មិនឆ្លាត ធ្វើដំណើទៅលើភ្នំរដិបរដុប វាមានការគិតថា ធ្វើដូចម្ដេចនឹងបានទៅកាន់ទិសដែលមិនធ្លាប់ទៅខ្លះ នឹងបានស៊ីស្មៅដែលមិនធ្លាប់ស៊ីខ្លះ នឹងបានផឹកទឹកដែលមិនធ្លាប់បានផឹកខ្លះ ដូច្នេះហើយ វា( ក៏ចេញដំណើរទៅ ) មិនទាន់បានឈរជើងមុខឲ្យមាំផង លើកជើងក្រោយឡើង វា(ក៏គ្រេចជើង) មិនបានទៅកាន់ទិសដែលមិនធ្លាប់បានទៅ មិនបានស៊ីស្មៅដែលមិនធ្លាប់បានស៊ី មិនបានផឹកទឹកដែលមិនធ្លាប់បានផឹក ទាំងមិនបានត្រឡប់មកកាន់កន្លែងដែលវាឈរគិតថា ធ្វើដូចម្ដេចហ្ន៎ នឹងបានទៅកាន់ទិសដែលមិនធ្លាប់បានទៅ ។ល។ ដោយសួស្ដីផង នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះមេគោនោះ ជាសត្វរកស៊ីលើភ្នំតែល្ងង់ មិនស្គាល់ទីកន្លែង មិនឆ្លាតក្នុងការធ្វើដំណើរទៅលើភ្នំរដិបរដុប យ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ ក៏ដូច្នោះដូចគ្នា ជាមនុស្សល្ងង់ខ្លៅមិនស្គាល់នូវដែន(នៃភាវនា) មិនឆ្លាតក្នុងការស្ទាត់ចាកកាមទាំងឡាយ។ល។ ចូលដល់បឋមជ្ឈានហើយ មិនសេព មិនចម្រើន មិនធ្វើឲ្យច្រើននូវនិមិត្តនោះ ហើយមិនតាំងនិមិត្តនោះ

ទុកឲ្យមាំទាំល្អ ក៏មានការគិតថា ធ្វើដូចម្ដេចហ្ន៎ គប្បីចូលដល់ទុតិយជ្ឈាន។ល។ ព្រោះវិតក្កវិចារស្ងប់ទៅដូច្នេះ គេក៏មិនអាច ចូលដល់ទុតិយជ្ឈាន។ល។ ដែលគ្មានវិតក្កវិចារដូច្នេះ គេគិតថា ធ្វើដូចម្ដេចហ្ន៎ដើម្បីឲ្យស្ងាត់ចាកកាមទាំងឡាយ ហើយចូលបឋមជ្ឈានបានវិញ ដូច្នេះ គេក៏មិនអាចស្ងាត់ចាកកាមទាំងឡាយ។ ល ។ ចូលបឋមជ្ឈានវិញមិនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ភ្លាត់ជើងទាំងសងខាង វិនាសទាំងពីរផ្លូវ ប្រៀបដូចមេគោនោះដែលរកស៊ីនៅលើភ្នំ តែល្ងង់ខ្លៅមិនស្គាល់ទីកន្លែង មិនឆ្លាតក្នុងការធ្វើដំណើរទៅលើភ្នំដែលរដិបរដុបដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរនោះ គប្បីជាអ្នកបំពេញវសីដោយអាការ៥ ក្នុងបឋមជ្ឈាននោះមុនសិន ។

## វសី៥

ក្នុងអាការទាំងឡាយនោះ វសី ៥ គឺ :

១ . **អាវជ្ជនវសី** ជំនាញក្នុងការនឹករាវរក ។

២ . **សមាបជ្ជនវសី** ជំនាញក្នុងការចូល ។

៣ . **អធិដ្ឋានវសី** ជំនាញក្នុងការអធិដ្ឋាន ។

៤ . **វុដ្ឋានវសី** ជំនាញក្នុងការចេញ ។

៥ . **បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណា ។

ព្រះយោគាវចរនឹករាវរកបឋមជ្ឈានបានក្នុងស្ថានទីដែលត្រូវការ ក្នុងកាលដែលត្រូវការ ក្នុងរយៈ(ជវនវារៈ)ដែលត្រូវការ គ្មានការយឺតយ៉ាវក្នុងការនឹករាវរកនោះទេ ព្រោះដូច្នោះ អាការដូច្នេះ ទើបឈ្មោះថា **អាវជ្ជនវសី** , ព្រះយោគាវចរចូលបឋមជ្ឈានបានក្នុងស្ថានទីដែលត្រូវការ ។ ល ។ គ្មានការយឺតយ៉ាវក្នុងការចូល

ព្រោះដូច្នោះ អាការរបៀបនោះ ទើបឈ្មោះថា **សមាបជ្ជនវសី** សូម្បីវសីដ៏សេស គប្បីពង្រីកសេចក្តីដូចគ្នាតែម្យ៉ាង ។

នេះជាពាក្យច្បាស់លាស់ក្នុងវសី៥នោះ កាលព្រះយោគាវចរអាចលើកចិត្តទៅក្នុងអង្គឈាន៥មិនឲ្យមានចន្លោះ ( វិសភាគារម្មណ៍កើតឡើង ) បានយ៉ាងនេះ គឺ ពេលចេញចាកបឋមជ្ឈានហើយ នឹកពាវរកវិតក្កជាវារៈដំបូង ជវនដែលមានវិតក្កជាអារម្មណ៍នោះស្ទុះទៅ៤ឬ៥វារៈ ក្នុងលំដាប់នៃអាវជ្ជនៈដែលកាត់ភវង្គហើយកើតឡើង បន្ទាប់ពីនោះភវង្គកើត២វារៈ បន្ទាប់ពីនោះអាវជ្ជនៈដែលមានវិចារជាអារម្មណ៍ (កាត់ភវង្គកើតឡើង)ទៀត ហើយជវនក៏ស្ទុះទៅតាមន័យដូចពោលហើយនោះឯង ពេលនោះអាវជ្ជនវសីក៏បានសម្រេចដល់លោក ឯវសីនេះដល់នូវភាពជាកំពូលបានមាននៅក្នុងយមកប្បាដិហារ្យរបស់ ព្រះមានព្រះភាគ ឬរបស់លោកដទៃ មានព្រះធម្មសេនាបតីជាដើម(ក្នុងកាលសម្តែងបាដិហារ្យភ្លាមៗ) ដូច្នោះឈ្មោះថា **អាវជ្ជនវសី** , ដែលរហ័សក្រៃលែងជាងនេះមិនមាន ចំណែកភាពជាអ្នកអាចក្នុងការចូលឈានបានរហ័ស ដូចជាការចូលឈានពេលដែលបង្ក្រាបនន្ទោបនន្ទនាគរាជរបស់ព្រះមហាមោគល្លាន ឈ្មោះថា **សមាបជ្ជនវសី**, ភាពជាអ្នកអាចញុំាងឈានទុកបាន១ខណៈមួយផ្ទាត់ម្រាមដៃក្តី មួយផ្ទាត់ម្រាមដៃ១០ដងក្តីឈ្មោះថា **អធិដ្ឋានវសី**, ភាពជាអ្នកអាចនឹងចេញចាកឈានបានរហ័សដូចគ្នា ឈ្មោះថា **វុដ្ឋានវសី** ។

ដើម្បីសម្តែង **អធិដ្ឋានវសី** និង **វុដ្ឋានវសី** ទាំងពីរយ៉ាងនោះ មានរឿងព្រះពុទ្ធរក្ខិតត្ថេរ( មកសាធកៈ ) ក៏គួរ :

មានរឿងពោលថា ព្រះថេរៈអង្គនោះ តាំងពីឧបសម្បទមកបាន៨វស្សា ថ្ងៃមួយអង្គុយនៅកណ្តាលភិក្ខុសង្ឃ ដែលមានឫទ្ធិ ប្រមាណ ៣០.០០០ អង្គ អ្នកមក

ឧបដ្ឋាកជំនឺព្រះមហារោហណគុត្តត្ថេរ នៅឯថេរម្ពត្ថលវិហារ បានឃើញស្ដេចគ្រុឌស្ទុះចុះមកពីអាកាសសំដៅនឹងចាប់ស្ដេចនាគ លោកជាឧបដ្ឋាក ដែលកំពុងប្រគេនយាគូដល់ព្រះថេរៈ ក៏និម្មិតភ្នំឡើង ប្រើដៃក្ដោបស្ដេចនាគយកទៅដាក់នៅក្នុងរូងភ្នំភ្លាម ស្ដេចគ្រុឌប្រទះឃើញភ្នំក៏គេចបាត់ទៅ ទើបព្រះមហាថេរៈពោលឡើងថា " អាវុសោទាំងឡាយ បើពុទ្ធរក្ខិតមិននៅទីនេះទេ ពួកយើងគ្រប់គ្នានឹងជាអ្នកត្រូវគេតិះដៀលហើយ " ដូច្នេះ ។

ចំណែក **បច្ចវេក្ខណវសី** បានពោលហើយដោយអាវជ្ជនវសីនោះឯង ព្រោះថា ជវនទាំងឡាយដែលឋិតនៅតាមលំដាប់បន្ទាប់ពីអាវជ្ជនៈ ក្នុងអាវជ្ជនវសីនោះក៏គឺ ជវនក្នុងបច្ចវេក្ខណៈនោះឯង ។

# មហាដីកា

## ពណ៌នា អំពី បឋមជ្ឈាន

ពាក្យថា **ឯវំ** ប្រែថា កាលព្រះយោគាវចរនោះ ញុំាងភាវនាចិត្តដែលមានដំណើរត្រង់ទៅតាមវិថីហើយ ដោយអំណាចសេចក្ដីព្យាយាមសមល្មម ដែលមានមុខឆ្ពោះនិមិត្ត ដោយអំណាចការតាំងមាំនៃបដិភាគនិមិត្តប៉ុណ្ណោះ ឲ្យប្រព្រឹត្តទៅតាមប្រការដែលពោលហើយ ។

បទថា **ឥជ្ឈិស្សតិ** ប្រែថា នឹងសម្រេច មានន័យថា នឹងកើតឡើង ។

បទថា **អនុយោគវសេន** មានន័យថា ដោយអំណាចនៃការប្រកបរឿយ ៗ គឺ ដោយអំណាចនៃភាវនា ។

ពាក្យថា **ជវនដ៏សេស** បានដល់ ជវន ៣ ដួង ឬ ៤ ដួង ដ៏សេស ។

ពាក្យថា **ប្រសើរជាងបកតិចិត្ត** គឺ ប្រសើរជាងកាមាវចរចិត្ត ដែលប្រព្រឹត្តទៅតាមប្រក្រតី ។ ឈ្មោះថា មានវិតក្កៈ វិចារៈ បីតិ សុខៈ និងចិត្តេកគ្គតា មានកម្លាំងជាង ព្រោះដល់ភាវៈដែលក្លៀវក្លាដោយកម្លាំងនៃភាវនា ។ បទថា **បរិកម្មត្តា** ប្រែថា ព្រោះតាក់តែង ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើ ឧបចារៈគប្បីមាននៅក្នុងទីជិត គោត្រភូក៏គប្បីមានសមញ្ញាថា ជាឧបចារៈបានដូចគ្នា ដូច្នោះហើយ ទើបពោលថា ឬព្រោះការចូលទៅជិត ។

ពិតណាស់ បុគ្គលសូម្បីនៅជិត ប្រព្រឹត្តទៅហើយក្នុងទីមិនឆ្ងាយ ក៏ឈ្មោះថា ជាសមីបចារី អ្នកនៅក្បែរ ។ កាមាវចរជវន ឈ្មោះថា **ឧបចារៈ** ព្រោះអត្ថថា ចូលទៅជិតអប្បនា ។ ពាក្យថា **ព្រោះអនុលោមដល់បរិកម្មទាំងឡាយ ក្នុងខាងដើម** គឺ ព្រោះអនុលោមដល់បរិកម្មទាំងឡាយក្នុងវិថីដែលមានអាវជ្ជនៈផ្សេង ៗ គ្នា ។ ពាក្យថា **ក្នុងកាមាវចរជវនទាំងឡាយនេះ** គឺ ក្នុងកាមាវចរជវនដែលជាបរិកម្ម ឧបចារៈ និង អនុលោមទាំងឡាយនេះ ។ ពាក្យថា **ដួងចុងក្រោយបង្អស់** បាន ដល់ ដួងទី ៣ ឬ ដួងទី ៤ ។

បទថា **បរិត្តគោត្តាភិភវនតោ** ប្រែថា ព្រោះគ្របសង្កត់បរិត្តគោត្ត ។ ពិតណាស់ ឈ្មោះថា **គោត្ត** ព្រោះអត្ថថា រក្សាឈ្មោះទុក ។ ឈ្មោះថា **បរិត្តគោត្ត** ព្រោះអត្ថថា រក្សាអភិធាន ( ឈ្មោះ ) ដែលប្រព្រឹត្តទៅថា “ បរិត្តៈ ” និង ពុទ្ធិ “ ការស្គាល់ឈ្មោះ ” ដោយភាពជាវិស័យមួយចំណែក ។ ប្រៀបដូចជា ពុទ្ធិរមែងមិនប្រព្រឹត្តទៅដោយវៀរសភាវៈដែលជាអារម្មណ៍ យ៉ាងណា , អភិធាន ក៏រមែងមិនប្រព្រឹត្តទៅ ដោយវៀរសភាវៈដែលជាវត្ថុ គួរតាំងឈ្មោះ ក៏ដូច្នោះ ។ ព្រោះដូច្នោះ សភាវៈនោះ ទើបពោលបានថា រមែងការពារ គឺ រមែងរក្សានូវពុទ្ធិ និង

អភិធានទាំងឡាយនោះទុក ។ **បរិត្តគោត្ត** នោះ គប្បីឃើញថា ជាសភាវៈតែម្យ៉ាង ចំពោះកាមាវចរធម៌ ដែលផ្សេងចាកមហគ្គតធម៌ និងលោកុត្តរធម៌ ជាអារម្មណ៍នៃកាមតណ្ហា ។ គប្បីជ្រាបសេចក្ដីក្នុងមហគ្គតគោត្ត ដោយន័យដូច្នេះ ។ បទថា **ភាវេនតោ** ប្រែថា ធ្វើមហគ្គតគោត្តឲ្យកើតឡើង ។

ន័យដំបូង ជាការកាន់យកនូវឈ្មោះដែលបានកាន់យកហើយ ដោយមិនផ្សេងគ្នា គឺ ជវនចិត្តគ្រប់ដួង បានឈ្មោះ ( តែមួយ ) ទាំងអស់ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដោយការកាន់យកឈ្មោះដែលមិនទាន់បានកាន់យក ។ ព្រោះសំដៅយកបរិកម្មដែលមានអាវជ្ជនៈផ្សេង ៗ គ្នា ( មានក្នុងវិថីផ្សេង ៗ គ្នា ) នោះឯង ឈ្មោះថា **បរិកម្ម** លោកអាចារ្យទើបពោលថា ន័យម្យ៉ាងទៀត ដួងទី ១ ឈ្មោះថា **ឧបចារៈ** ដូច្នេះជាដើម ។ សេចក្ដីថា ដួងទី ៤ ជាអប្បនាចិត្ត ឬថា ដួងទី ៥ ជាអប្បនាចិត្ត ប្រសិនបើជវនដួងទី ៤ ជាគោត្រភូ តាមន័យដែលបានពោលហើយក្នុងខាងដើម ។ **វា** សព្ទ ក្នុងបទថា **បញ្ចមំ វា** មានអត្ថថា មិនកំណត់ពិតប្រាកដ ។

ដើម្បីសំដែងថា ការមិនកំណត់ពិតប្រាកដនេះនោះ មានបានដោយហេតុនេះ ដូច្នេះ ទើបលោកពោលថា “ អប្បនាចិត្តនោះ រមែងប្រព្រឹត្តទៅដោយអំណាចខិប្បាភិញ្ញា ឬទន្ធាភិញ្ញា ” ដូច្នេះ ក្នុងជវនចិត្តទាំងឡាយនោះ ចំពោះខិប្បាភិញ្ញា-បុគ្គល ជវនដួងទី ៤ រមែងជាអប្បនា , ចំពោះទន្ធាភិញ្ញាបុគ្គល ជវនដួងទី ៥ រមែងជាអប្បនា ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ព្រោះហេតុអ្វី ទើបជវនដួងទី ៤ ឬ ដួងទី ៥ ជាអប្បនា ជវនដួងបន្ទាប់ពីនោះ មិនជាអប្បនា ដូច្នេះហើយទើបពោលថា “ បន្ទាប់ពីនោះទៅ ជវនរមែងធ្លាក់ចុះ ” ។ អធិប្បាយថា ជវនដួងទី ៦

និងជវនដួងទី ៧ ផុតចាកជវនដួងទី ៥ រមែងដូចជាធ្លាក់ទៅ ព្រោះស៊ុះទៅអស់ដោយល្អហើយ ។

ពាក្យអធិប្បាយរបស់ព្រះថេរៈថា ប្រៀបដូចជា ជវនដួងទី ១ ដែលមិនបានអាសេវនប្បច្ច័យ ក៏មិនអាចធ្វើគោត្រភូឲ្យកើតឡើងបាន ព្រោះមានកម្លាំងខ្សោយ ចំណែកជវនដួងទី ២ ឬ ទី ៣ ដែលបានអាសេវនប្បច្ច័យហើយ រមែងធ្វើគោត្រភូឲ្យកើតឡើងបាន ព្រោះមានកម្លាំងខ្លាំង យ៉ាងណា , ជវនដួងទី ៦ ឬ ដួងទី ៧ រមែងជាអប្បនាបាន ព្រោះមានកម្លាំងខ្លាំង ដោយភាវៈដែលបានអាសេវនប្បច្ច័យដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា “ ព្រោះដូច្នោះ អប្បនារមែងមានសម្បីក្នុងជវនដួងទី ៦ ឬ ជវនដួងទី ៧ ” ។ បទថា **តំ** បានដល់ ពាក្យពោលរបស់ព្រះថេរៈ ។

លោកពោលថា ត្រឹមតែជាអត្តនោមតិ ( ការយល់ឃើញដោយខ្លួនឯង ) ដូច្នេះ ព្រោះពាក្យពោលដែលជាវាទៈរបស់អាចារ្យ អនុលោមចំពោះសូត្រនៃព្រះ-សូត្រដែលមិនបានពោលអះអាងទុកៗ បទនៃសូត្រដែលថា **បុរិមា បុរិមា កុសលា ធម្មា** កុសលធម៌ទាំងឡាយដែលកើតមុនៗ ដូច្នេះ មិនមែនជាហេតុ ព្រោះកាលបានអាសេវនប្បច្ច័យ មិនមែនជាហេតុដែលប្រាកដប្រជាក្នុងការមានកម្លាំង ។ ពិតយ៉ាងនោះ ចេតនាក្នុងជវនដួងទី ១ សូម្បីមិនទាន់បានអាសេវនប្បច្ច័យ ក៏ជាទិដ្ឋធម្មវេទនីយា (មានផលគប្បីសោយបានក្នុងអត្តភាពនេះ) បាន ចាប់អំពីចេតនាក្នុងជវនដួងទី ២ រហូតដល់ចេតនាក្នុងជវនដួងទី ៦ ដែលបានអាសេវនប្បច្ច័យហើយ ជាអបរាបរិយវេទនីយា ( មានផលគប្បីសោយបានក្នុងភពត ៗ ទៅ ) ។

ពាក្យថា **ក្នុងជវនដួងទី ៤ ឬ ដួងទី ៥ ប៉ុណ្ណោះជាដើម** លោកពោលទុក

ដើម្បី បញ្ជាក់ដល់អត្ថាធិប្បាយដែលបានពោលហើយនោះឯង ដោយការសម្ដែងសេចក្ដីយុត្តិ ( ពាក្យពោលក្នុងអដ្ឋកថា ) ទុកជាប្រមុខ ។ សួរថា ក្នុងបណ្ដាជវនទាំងឡាយនោះ ប្រសិនបើជវនដួងទី ៦ និង ដួងទី ៧ ឈ្មោះថា ធ្លាក់ទៅហើយ ព្រោះអស់សន្ទុះហើយ ចេតនាក្នុងជវនដួងទី ៧ នឹងជាឧបបជ្ជវេទនីយា ( មានផលគប្បីសោយក្នុងភពបន្ទាប់ពីភពនេះ ) នឹងជាអនន្តរិយា ( មានផលក្នុងលំដាប់ភពនេះ មិនមានចេតនាកម្មដទៃរារាំងបាន ) បានយ៉ាងណា ? , ឆ្លើយថា សេចក្ដីពិសេសប្រការនេះ មិនមែនមានកម្លាំង ដោយការបានអាសេវនប្បច្ច័យនោះទេ ដោយពិត រមែងមានដោយភាពផ្សេងគ្នានៃកិច្ចដែលធ្វើ ។

ពិតណាស់ កិរិយាដែលធ្វើមាន ៣ យ៉ាង ដោយទាក់ទងជាមួយពេលខាងដើម កណ្ដាល និងចុងក្រោយ ។ ក្នុងកិរិយា ៣ យ៉ាងនោះ គប្បីឃើញថា ភាពជាឧបបជ្ជវេទនីយា ជាដើម រមែងមានដោយភាវៈនៃចេតនាក្នុងកិច្ចចុងក្រោយ ជាសន្និដ្ឋាបកៈ ( ជាអ្នកឲ្យតាំងចុះ គឺ ឲ្យសម្រេចកម្ម ) មិនមែនដោយការមានកម្លាំងឡើយ ។ អាចារ្យច្រើននាក់ពោលថា ចេតនាដែលជាឧបបជ្ជវេទនីយា រមែងមាន ព្រោះត្រូវបច្ច័យតាក់តែងទុកដោយអាការយ៉ាងនោះ ដោយភាពជាអនន្តរ-ប្បច្ច័យដល់ការបន្តគ្នានៃវិបាក ដែលមានភាពជាអនន្តរប្បច្ច័យដល់បដិសន្ធិ។ ព្រោះដូច្នោះ នរណា ៗ ក៏មិនអាចហាមការអស់សន្ទុះទៅដោយជុំវិញ ដោយភាវៈដែលបែរមុខឆ្ពោះទៅកាន់ជវនដួងទី ៦ និង ដួងទី ៧ បាន ។ ពិតយ៉ាងនោះ លោកអាចារ្យបានពោលទុកហើយថា “ ដូចជាបុរស ” ដូច្នេះជាដើម ។

ពាក្យថា **សា ច បន** គឺ **សា ច បន អប្បនា** ។ បទថា **អទ្ធានបរិច្ឆេទោ** ប្រែថា ការកំណត់ពេល ។ ការកំណត់ពេលក្នុងទីនេះ លោកពោលថា មិនមាន

ក្នុងស្ថាន ៧ ព្រោះក្នុងស្ថានខ្លះ មានខណៈចិត្តកប្រមាណមិនបាន ក្នុងស្ថានខ្លះ មានខណៈចិត្តតិចក្រៃលែង ។ សេចក្ដីថា ក្នុងស្ថានទាំងឡាយនេះ មិនមានវិថីដែលមានជវនសំបូរពិតប្រាកដ ។ ព្រោះហេតុនោះ លោកទើបពោលថា " ក្នុងស្ថានទាំងឡាយនេះ ផលមានក្នុងលំដាប់នៃមគ្គ " ដូច្នេះជាដើម ។ ពាក្យថា **ក្នុងស្ថានដ៏សេស** បានដល់ ក្នុងស្ថាន ៤ ទាំងនេះ គឺ អប្បនាគ្រាដំបូង លោកិយអភិញ្ញា ខណៈនៃមគ្គ ខណៈនៃផលរបស់លោកដែលចេញចាកនិរោធ ដូច្នេះ ។

បទថា **ឯត្តាវតា** ក្នុងសេចក្ដីថា ដោយលំដាប់នៃការនាត្រឹមតែប៉ុណ្ណេះ ព្រះយោគាវចរនេះ បានដល់បឋមជ្ឈានហើយ ។ បឋមជ្ឈាននោះឯង ព្រះយោគីនេះ បានសម្រេចហើយ តាមប្រការដូចដែលពោលមកនេះ ឈ្មោះថា **បឋវីកសិណ** ។

បទថា **តត្ថ** មានន័យស្មើនឹង **តស្មឹ យោគ ឈានបាឋេ** ប្រែថា ក្នុងឈានបាឋៈនោះ ។ បទថា **វិវិច្ចិត្វា** ( ស្ងាត់ហើយ ) គឺ បែកដាច់ពីគ្នាបានហើយ ។ ព្រោះហេតុនោះ លោកទើបពោលថា " ជាការវៀរទៅ គេចទៅ " ដូច្នេះ , សេចក្ដីថា **គេចទៅ** ដោយអំណាចការលះបង់បាន ។ ដើម្បីសម្ដែង សេចក្ដីថា ដោយបទថា " **វិវិច្ច** " ( ស្ងាត់ហើយនេះ ) ក្នុងប្រការថា **វិវិច្ចេវ កាមេហិ** ដូច្នេះ ជាការត្រាស់ដល់ភាពស្ងាត់ថា ត្រឹមតែការមិនមាននៃកាមទាំងឡាយ ក្នុងខណៈនៃឈាន ។

ចំណែកបទថា **វិវិច្ចេវ** ( ស្ងាត់ស្ងៀមហើយ ) នេះ ទ្រង់សម្ដែងដល់ឈានជាបដិបក្ខដល់កាមនោះ ដោយការសម្ដែងភាវៈដែលកាមទាំងឡាយ គប្បីត្រូវធ្វើឲ្យស្ងាត់ទៅដោយអស់ជើង និងទ្រង់សម្ដែងដល់ការដែលស្ងាត់ចាកកាម ជាឧបាយក្នុងការសម្រេចឈាន ដូច្នេះ លោកអាចារ្យទើបពោលថា " **បឋមំ ឈានំ** " ដូច្នេះ

ជាដើម ហើយពោលថា គឺ “ ដូចម្តេច ” ដូច្នេះជាដើម ដើម្បីធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ក្រៃលែងឡើង ។

ដោយពាក្យថា **ដូចពេលមានភាពងងឹត ពន្លឺនៃប្រទីប រមែងប្រព្រឹត្តទៅមិនបាន ដូច្នោះ** នេះលោកសម្តែងថា ភាពងងឹតគ្របសង្កត់បានក្នុងពេលកណ្តាលរាត្រី ក៏ព្រោះមិនមានពន្លឺនៃប្រទីប យ៉ាងណា , កាមគ្របសង្កត់បានក្នុងសន្តានរបស់សត្វ ក៏ព្រោះមិនមានឈានដូច្នោះ ។

បទថា **ឥតំ** គឺ ពាក្យកំណត់សេចក្តីក្នុងបទដើមនោះឯង ។ ក៏ពាក្យកំណត់សេចក្តីថា **ឯវ** នេះ មិនគួរឃើញយ៉ាងនេះ ព្រោះទ្រង់មិនបានធ្វើពាក្យកំណត់សេចក្តីទូទៅ ថា “ **កាមេហិ ឯវ** ” ចាកកាមទាំងឡាយនោះឯង ( ទ្រង់ធ្វើទុកថា **វិវិច្ចេវ** ស្ងាត់ហើយនោះឯង ) ។ **ឈាន** ឈ្មោះថា និស្សរណៈ ព្រោះអត្ថថា ជាគ្រឿងរលាស់ចេញ ឬ ដែលរលាស់ចេញ គឺ ចាកចេញ ។ អ្វីចាកចេញ ? កាមទាំងឡាយចាកចេញ , គ្រឿងរលាស់ចេញទៅ គឺគ្រឿងលះបង់កាមនោះឯង , ឈ្មោះថា **គ្រឿងរលាស់ចេញទៅនូវកាមទាំងនោះ** បានដល់ ព្រោះជាគ្រឿងរលាស់ចេញចាកទៅនូវកាមទាំងឡាយនោះ ។ ក៏ដើម្បីនឹងជម្រះ ប្រការដែលទាក់ទងថា កាលបើការគ្របសង្កត់កិលេសមានហើយ ឈាននេះ ជាគ្រឿងរលាស់ចេញចាកនូវកាមទាំងឡាយប៉ុណ្ណោះ , មិនមែនជាគ្រឿងរលាស់ចេញនូវធម៌ដទៃ មានព្យាបាទជាដើម ឬយ៉ាងណា ? ដូច្នេះ ដោយយុត្តិ និងអាគម លោកទើបពោលថា “ ( ព្រោះឈានកន្លង ) កាមធាតុបាន ” ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រោះឈានកន្លងកាមធាតុបាន** គឺ ព្រោះជាបដិបទា ឈានកន្លងកាមភព សូម្បីទាំងពួងបានដោយពាក្យនោះ លោកពោលដល់ ឈាននេះ ជា **កាមបរិញ្ញា**

( ការកំណត់ដឹងកាម ) ។

ពាក្យថា **ព្រោះជាបដិបក្ខដល់កាមរាគៈ** គឺ ព្រោះជាសត្រូវដល់កិលេសកាម ដែលកំពុងពោលដល់ការបែក ។ ដោយពាក្យនោះ លោកសំដែងថា ឈាននេះ ជាសត្រូវដោយត្រង់ដល់កាមរាគៈ ដូចជា មេត្តា ជាសត្រូវដោយត្រង់ដល់ព្យាបាទ , ករុណា ជាសត្រូវដោយត្រង់ដល់វិហិង្សា ដូច្នោះ ។ ឈាននេះ ជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយបាន ដោយពិសេសតែម្យ៉ាង ព្រោះមានសភាពគេចចេញចាកកាមរាគៈ , និងចាកកាមធាតុ តាមការប្រព្រឹត្តទៅរបស់ខ្លួន , និងតាមការប្រព្រឹត្តទៅនៃវិបាក តាមប្រការដូចពោលមកនេះ ។ ប្រការនេះ មានហើយក្នុងព្រះបាលី ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " ដូចដែលព្រះសារីបុត្តពោលទុក " ដូច្នេះជាដើម ទ្រង់កាន់យកពាក្យកំណត់សេចក្ដីទុក ក្នុងបទដើមនោះឯង ដើម្បីសម្ដែងន័យនោះ ក៏ពិត , សូម្បីដូច្នោះ ដើម្បីសម្ដែងថា សូម្បីក្នុងបទចុង ក៏គួរកាន់យកពាក្យកំណត់សេចក្ដីនោះឯង ព្រោះមានន័យយ៉ាងនោះដូចគ្នា ដូច្នេះ លោកអាចារ្យទើបពោលថា " ( តែក៏គួរពោលទុក ) ក្នុងបទក្រោយផង " ដូច្នេះជាដើម ។ បទថា **ឥតោ** បានដល់ ចាកកាមច្ឆន្ទៈ ។ បទថា **ឯស** បានដល់ ប្រការកំណត់ពិតប្រាកដ ។ ពាក្យថា **ដោយពាក្យនិយាយដែលជាសាធារណៈ** គឺ ដោយពាក្យនិយាយមិនពិសេស ។ **តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក** និង **និស្សរណវិវេក** ឈ្មោះថា វិវេកទាំងឡាយ មានតទង្គវិវេកជាដើម ។ **ចិត្តវិវេក កាយវិវេក** និង **ឧបធិវិវេក** ឈ្មោះថា វិវេកទាំងឡាយ មានចិត្តវិវេកជាដើម ។ គប្បីឃើញថា **ក្នុងឈានកថានេះ** បានដល់ **វិវេក ៣** ប៉ុណ្ណោះ ព្រោះវិវេកទាំងឡាយ មានសមុច្ឆេទវិវេកជាដើម កើតមិនបាន ។

ពាក្យថា **ក្នុងគម្ពីរនិទ្ទេស** គឺ ក្នុងគម្ពីរមហានិទ្ទេស ។ ពិតណាស់ ក្នុងគម្ពីរមហានិទ្ទេសនោះ ព្រះសារីបុត្ត លើកមាតិកាឡើងសម្ដែងថា “ កាមមាន ២ យ៉ាង ដោយសង្ខេប គឺ វត្ថុកាម និង កិលេសកាម ” ដូច្នេះ ហើយសម្ដែងខែវត្ថុកាម ទុកដោយពាក្យថា “ ក្នុងកាម ២ យ៉ាងនោះ វត្ថុកាម ដូចម្ដេច ? បានដល់ រូបដែលគួរស្រឡាញ់ គួរពេញចិត្ត ។ល។ ផោដ្ឋព្វៈដែលគួរស្រឡាញ់ គួរពេញចិត្ត ” ដូច្នេះ ជាដើម ។ ក៏ធម៌ទាំងនោះ គប្បីជ្រាបថា ឈ្មោះថា កាម ព្រោះអត្ថថា ដែលសត្វទាំងឡាយរមែងប្រាថ្នា ។ បទថា **តត្ថ** បានដល់ ក្នុងគម្ពីរនិទ្ទេសនោះឯង ។ ពាក្យថា **ក្នុងគម្ពីរវិភង្គ** គឺ ក្នុងឈានវិភង្គ ។ លោភៈដែលខ្សោយកម្លាំង ដែលប្រព្រឹត្តទៅដោយអាការដែលប្រាថ្នា ឈ្មោះថា **ឆន្ទៈ** ដោយន័យថា ពេញចិត្ត , លោភៈដែលមានកម្លាំងជាងឆន្ទៈនោះ ឈ្មោះថា **រាគៈ** ដោយន័យថា តម្រេក , **រាគៈ** ដែលក្រាស់ណែន មានកម្លាំងក្រៃលែងជាងរាគៈនោះ ឈ្មោះថា **ឆន្ទរាគៈ** ។ ឈ្មោះថា **សង្កប្បៈ** ព្រោះអត្ថថា ជាគ្រឿងត្រិះរិះដល់និមិត្តនិងអនុព្យញ្ជនៈ បានដល់ លោភៈដែលប្រព្រឹត្តទៅដោយអាការនោះ , លោភៈដែលមានកម្លាំងជាងសង្កប្បៈនោះ ឈ្មោះថា **រាគៈ** ដោយន័យថា តម្រេក , លោភៈដែលមានកម្លាំងក្រៃលែងជាងរាគៈនោះ ដែលប្រព្រឹត្តទៅដោយទាក់ទងនឹងការត្រិះរិះនោះឯង ឈ្មោះថា **សង្កប្បរាគៈ** ដូច្នេះឯង ។ ការបែកនេះ បណ្ឌិតគប្បីជ្រាបដោយទាក់ទងនឹងអាការប្រព្រឹត្តទៅ , និងដោយទាក់ទងនឹងសេចក្ដីផ្សេងគ្នានៃឋានៈទីតាំង ( អវត្ថា ) នៃលោភៈតែមួយនោះឯង ។ ដូចដែលពោលថា “ **វច្ឆោ**-កូនគោ , **ទម្មោ**-គោហ្វឹក , **ពលិពទ្ទោ**-គោប្រើ ” ។ ឈ្មោះថា ធម៌ទាំងនេះ បានដល់ កិលេសកាមទាំងឡាយ ។ **កិលេស** មានឆន្ទៈជាដើម

ឈ្មោះថា **កាម** ព្រោះអត្ថថា ប្រាថ្នា , ឬព្រោះអត្ថថា ជាហេតុឲ្យប្រាថ្នា ។

ពាក្យថា **ក៏កាលបើយ៉ាងនេះ** គឺ កាលបើមានការសង្គ្រោះយកកាមទាំង ២ យ៉ាង យ៉ាងនេះ ។ ពាក្យថា ( ស្ងាត់ ) **សូម្បីចាកវត្ថុកាមទាំងឡាយ** មានន័យថា **បិ** សព្ទ ( ដែលប្រែថា សូម្បី ) មានអត្ថថា រួបរួមយកអត្ថដទៃដែលសមគួរចូលមក យ៉ាងនេះថា នឹងមានន័យថា " ស្ងាត់ចាកវត្ថុកាមទាំងឡាយផង " ដូច្នេះ ក៏គួរ , មិនមែនមានអត្ថថា រួបរួមយកកិលេសកាមចូលមក ។ ព្រោះហេតុអ្វី ? ព្រោះក្នុងអត្ថនេះ លោកពោលការស្ងាត់ចាកកិលេសកាមទាំងឡាយទុក ដោយបទទី ២ ហើយ ។ បទថា **តេន** ( ដោយបទថា ស្ងាត់ចាកកាមទាំងឡាយហើយនោះឯង ) បានដល់ ដោយការស្ងាត់ចាកវត្ថុកាម ។ ឈ្មោះថា **ជាការត្រាស់ដល់កាយវិវេក** ព្រោះសំដែងដល់សេចក្តីស្ងាត់ចាកការគ្រប់គ្រងអ្នកដទៃ មានបុត្តភរិយាជាដើម ។ ពាក្យថា **ដោយបទដំបូង** គឺ ដោយកាយវិវេក ។ បទថា **ឯត្ថ** គឺ ក្នុង ២ បទដែលថា " **វិវិច្ចេវ កាមេហិ , វិវិច្ច អកុសលេហិ ធម្មេហិ** " នេះ , ឬក្នុងវិវេកទាំង ២ ដែលដកចេញពីបទទាំងនេះ ។ ដោយសព្ទថា អកុសល នឹងជាការកាន់យកកិលេសកាមទាំងឡាយ ឬ សូម្បីអកុសលទាំងពួងបានក៏ពិត តែក៏ជាការត្រាស់ដល់សេចក្តីស្ងាត់ចាកកិលេសកាមទាំងឡាយបាន ដោយប្រការទាំងពួង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " ដោយបទទី ២ ... ព្រោះជាពាក្យត្រាស់ដល់សេចក្តីស្ងាត់ចាកកិលេសកាមទាំងឡាយ " ដូច្នេះ ។ ក៏ពាក្យថា ដោយបទទី ២ មានន័យថា ដោយចិត្តវិវេក ។ បទថា **ឯតេសំ** ( បណ្តាបទទាំងនេះ ) គឺ បណ្តាបទទាំង ២ តាមដែលពោលហើយ , ក៏ពាក្យនេះជាឆដ្ឋីវិភត្តិ ក្នុងអត្ថថា និទ្ធារណៈ ។ ការលះបង់ទីតាំង ទីអាស្រ័យនៃសង្កិលេស មាន

តណ្ហាជាដើម ឈ្មោះថា ការលះបង់វត្ថុនៃសង្កិលេស ។ **តណ្ហា** ដែលមានការកើតឡើងក្នុងអារម្មណ៍នោះ ៗ មានរូបជាដើម ឈ្មោះថា ភាពល្មោភ , គប្បីជ្រាបថា ហេតុនៃភាពល្មោភនោះ ក៏បានដល់ វត្ថុកាមនោះឯង ។ ឈ្មោះថា **ភាពជាពាល** បានដល់ អវិជ្ជា , ឬ គំនិត ដែលគិតអាក្រក់ជាដើម , អយោនិសោមនសិការ ឬ អកុសលធម៌ទាំងអស់ ឈ្មោះថា ហេតុនៃភាពជាពាលនោះ ។ ប្រយោគដែលមិនបរិសុទ្ធ មានបាណាតិបាតជាដើម រមែងមាន សូម្បីព្រោះការបានកាមគុណជាហេតុ ព្រោះហេតុនោះ សេចក្តីបរិសុទ្ធនៃប្រយោគ ទើបជាការបើកផ្សារឡើងបាន ដោយសេចក្តីស្ងាត់ចាកកាមនោះ ។ ការធ្វើអធ្យាស្រ័យឲ្យបរិសុទ្ធ ដោយការជម្រះសង្កិលេស គឺ តណ្ហា និងដោយការធ្វើជាឧបនិស្ស័យនៃវិវដ្តៈឲ្យចម្រើន ឈ្មោះថា ការទំនុបម្រុងអធ្យាស្រ័យ ។ បទថា **កាមេសុ** ជាសត្តមីវិភត្តិក្នុងអត្ថថា និទ្ធារណៈ ។

ពាក្យថា ( កាមច្ឆន្ទៈ ) **ដែលមានប្រភេទជាច្រើន** គឺ មានប្រភេទជាច្រើនទាក់ទងនឹងកាមាសវៈ កាមរាគសំយោជនៈជាដើម , និងដោយទាក់ទងជាមួយនឹងរូបតណ្ហាជាដើម ។ ពាក្យថា **កាមច្ឆន្ទៈនោះឯង** បានដល់ ឆន្ទៈដែលមានសេចក្តីប្រាថ្នា ជាសភាវៈនោះឯង ។ អធិប្បាយថា មិនមែនកត្តុកម្យតាឆន្ទៈ , ទាំងមិនមែនជាកុសលឆន្ទៈ ។ ពាក្យថា **ព្រោះជាបដិបក្ខដល់ឈាន** មានន័យថា ព្រោះជាបដិបក្ខដល់ឈាន គឺ ព្រោះជាហេតុដែលបដិបក្ខដល់ឈាននោះ ព្រោះនិមិត្តដែលជាបដិបក្ខដល់ឈាននោះ ទើបទ្រង់ត្រាស់ចែកជាម្យ៉ាងទៀត ឲ្យផ្សេងគ្នា ។ គឺ ទ្រង់កាន់យកកាមច្ឆន្ទៈ ដោយជាសភាវៈមានហើយ ទ្រង់មិនកាន់យកតាមសភាពដែលជាអកុសល ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើថា ត្រាស់ចំពោះ

កិលេសកាមប៉ុណ្ណោះទុកក្នុងបទដើម , ពាក្យពោល នឹងជាពហុវចនៈបានយ៉ាងណា ដូច្នេះហើយ ទើបពោលថា “ ព្រោះកាមច្ឆន្ទៈនោះ មានប្រភេទជាច្រើន ” ដូច្នេះជាដើម ។

ឈ្មោះថា **ធម៌ទាំងឡាយសូម្បីយ៉ាងដទៃ** បានដល់ ធម៌ទាំងឡាយ មានទិដ្ឋិ មានៈ អហិរិកៈ អនោត្តប្បៈជាដើម , និងធម៌ទាំងឡាយ មានផស្សៈជាដើម ដែលប្រព្រឹត្តទៅរួមជាមួយទិដ្ឋិជាដើមនោះ ។ អង្គឈានទាំងឡាយដែលនឹងពោលដល់ខាងមុខ ឈ្មោះថា **ឧបរិឈានង្គានិ** , មានព្រះតម្រាស់ដល់នីវរណៈ ដែលជាសត្រូវនៃអង្គឈាននោះ ព្រោះទ្រង់សម្តែងដល់ភាវៈ នៃអង្គឈានទាំងនោះ ជាបដិបក្ខដល់ធម៌ ដែលជាសត្រូវរបស់ខ្លួន ។ ពិតណាស់ នីវរណៈទាំងឡាយ ជាសត្រូវនៃអង្គឈាន ព្រោះហាមការប្រព្រឹត្តទៅនៃអង្គឈានទាំងនោះ ។ សមាធិ ឈ្មោះថា ជាបដិបក្ខដល់កាមច្ឆន្ទៈ ព្រោះជាសត្រូវដោយត្រង់នៃបណិធិ ( សេចក្តីប្រាថ្នា ) គឺ រាគៈ , និងព្រោះការធ្វើចិត្តដែលត្រូវអារម្មណ៍ផ្សេង ៗ លួងលោមហើយ ឲ្យតាំងមាំបាន ។

**បីតិ** ឈ្មោះថា ជាបដិបក្ខដល់ព្យាបាទ ព្រោះដោយបាមោជ្ជ ទើបមានសេចក្តីក្រេមចាកយោគៈបាន ។ **វិតក្ក** ឈ្មោះថា ជាបដិបក្ខដល់ថីនមិទ្ធៈ ព្រោះប្រព្រឹត្តទៅព្រមជាមួយការផ្សាយទៅ ដោយទាក់ទងនឹងការត្រិះរិះ ដោយត្រូវផ្លូវ ។ **សុខ** ឈ្មោះថា ជាបដិបក្ខដល់ឧទ្ធច្ចកុក្កុច្ចៈ ដែលមានសេចក្តីមិនស្ងប់ និងសេចក្តីក្តៅក្រហាយក្នុងពេលក្រោយ ព្រោះជាសភាវៈដែលស្ងប់ និងត្រជាក់ ។ **វិចារៈ** ឈ្មោះថា ជាបដិបក្ខដល់វិចិកិច្ឆា ព្រោះមានសភាវៈប្រៀបដូចជាបញ្ញា ដោយទាក់ទងនឹងការតាមពិចារណាក្នុងអារម្មណ៍ ។ ពាក្យសំវណ្ណនាបិដក ដែលព្រះមហា-

កច្ចាយនត្ថេរសំដែងទុក ឈ្មោះថា គម្ពីរបេដកៈ, បានដល់ ក្នុងគម្ពីរបេដកៈនោះ ។

ពាក្យថា **ដែលមានប្រភេទនៃកាមគុណ ៥ ជាអារម្មណ៍** គឺ ដែលមានកាម-គុណ ៥ ផ្សេងៗ គ្នា មានរូបជាដើម ជាអារម្មណ៍ ។ ពាក្យថា **ដែលមានប្រភេទនៃអាឃាតវត្ថុជាដើម ជាអារម្មណ៍** មានន័យថា ដោយពាក្យថា ស្ងាត់ចាកព្យាបាទ គឺ លោកពោលដល់ សេចក្ដីស្ងាត់ ព្រោះការគ្របសង្កត់ទោសៈ ដែលមានប្រភេទនៃអាឃាតវត្ថុ មានជាអាទិ៍ថា " គេបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់យើង " ដូច្នេះ ជាអារម្មណ៍ , ដោយពាក្យថា ស្ងាត់ចាកនីវរណៈ មានថីនមិទ្ធៈជាដើម ដែលមានមោហៈជាធំ គឺ លោកពោលដល់សេចក្ដីស្ងាត់ ព្រោះការគ្របសង្កត់មោហៈ ដែលមានប្រភេទនៃសច្ចៈ ៤ មានទុក្ខជាដើម និង ខន្ធដែលជាចំណែកអតីតជាដើម ជាអារម្មណ៍ ដោយទាក់ទងនឹងការបិទបាំងទុក ។

ក៏បឋមជ្ឈាននេះ ជាអ្នកគ្របសង្កត់កាមរាគៈ និងព្យាបាទ ព្រមទាំងនីវរណៈដ៏សេស មានថីនមិទ្ធៈជាដើម ដែលតាំងនៅក្នុងចិត្តុប្បាទដូងជាមួយគ្នា ជាមួយកាមរាគៈ និងព្យាបាទនោះ ព្រោះជាសភាវៈបដិបក្ខដល់អកុសលទាំងពួង ។ ដោយសភាវៈនោះ ទើបជាអ្នកលះបង់អកុសលទាំងពួង , សូម្បីកាលនឹងកើតឡើងក៏រមែងកើតឡើង ជាសភាវៈដែលគ្របសង្កត់កាមរាគៈ ជាដើម ព្រោះកុសលទាំងពួង មានការគ្របសង្កត់កាមរាគៈជាដើម ជាសភាវៈ ព្រោះហេតុនោះ លោកអាចារ្យទើបពោលទុក មិនឲ្យខុសគ្នាថា " ជាការត្រាស់ដល់ភាពស្ងាត់ ព្រោះការគ្របសង្កត់ " នូវនីវរណៈ និងអកុសលមូលជាដើម ដូច្នេះ ។

ចំពោះសភាវធម៌ទាំងឡាយ ដែលកំពុងប្រព្រឹត្តទៅតាមបច្ច័យ មិនមានការប្រព្រឹត្តទៅក្នុងអំណាចអ្វី ៗ ព្រោះហេតុនោះ ដើម្បីការពារសេចក្ដីយល់ឃើញថា

ប្រព្រឹត្តទៅក្នុងអំណាច លោកអាចារ្យទើបពោលថា “ **សេចក្ដីត្រិះរិះ ឈ្មោះថាវិតក្កៈ** ” ដូច្នេះ ។ ក៏សេចក្ដីត្រិះរិះនោះ ជាសេចក្ដីត្រិះរិះដល់អារម្មណ៍ថា “ សេចក្ដីត្រិះរិះនេះ ជាដូច្នេះ ” ព្រោះហេតុនោះ លោកទើបពោលថា “ មានអត្ថាធិប្បាយថា “ **ផ្ដោតចិត្ត** ” ដូច្នេះ ។ ព្រោះហេតុថា ចិត្តឡើងកាន់អារម្មណ៍បាន ដោយកម្លាំងរបស់វិតក្កៈ , ព្រោះដូច្នោះ លោកទើបពោលដល់វិតក្កៈនោះថា មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ ។ ប្រៀបដូចជា បុគ្គលខ្លះ ព្រោះអាស្រ័យបុគ្គលដែលស្និទ្ធស្នាលនឹងព្រះរាជា , ឬជាញាតិនឹងអ្នកដែលស្និទ្ធស្នាលជាមួយព្រះរាជានោះ ទើបទៅ គឺ តាមចូលទៅក្នុងព្រះរាជវាំងបានយ៉ាងណា ចិត្តព្រោះអាស្រ័យវិតក្កៈ ទើបឡើងកាន់អារម្មណ៍បានដូច្នេះ ។ សួរថា បើយ៉ាងនេះ ចិត្តដែលមិនមានវិតក្កៈ នឹងឡើងកាន់អារម្មណ៍បានដូចម្ដេច ? ឆ្លើយថា ចិត្តដែលមិនមានវិតក្កៈ ក៏ ឡើងកាន់អារម្មណ៍បាន ដោយកម្លាំងវិតក្កៈនោះឯង ។ ប្រៀបដូចជាបុគ្គលនោះ ព្រោះមានការជ្លាប់ សូម្បីថា វៀរចាកមិត្តដែលស្និទ្ធស្នាលនឹងព្រះរាជានោះ ក៏ជាអ្នកមិនវង្វេង គង់ចូលទៅកាន់រាជវាំងបាន យ៉ាងណា ចិត្តព្រោះមានការជ្លាប់ សូម្បីវៀរចាកវិតក្កៈ មិនមានវិតក្កៈ ក៏នៅតែឡើងកាន់អារម្មណ៍បានដែរ ។

ក៏ពាក្យថា **ព្រោះមានការជ្លាប់** បានដល់ ព្រោះមានការជ្លាប់ ពោលគឺ មានការចម្រើននូវវិតក្កៈ ដែលប្រព្រឹត្តទៅក្នុងសន្តាន ។ ពិតណាស់ ការឡើងកាន់អារម្មណ៍ គឺ ចិត្តជ្លាប់មកយូរហើយ ក៏ដោយអំណាចនៃវិតក្កៈដែលប្រព្រឹត្តទៅរឿយៗក្នុងសន្តាន ។ ព្រោះហេតុនោះ ក្នុងពេលខ្លះ ចិត្ត សូម្បីវៀរចាកវិតក្កៈ ក៏ប្រព្រឹត្តទៅក្នុងអារម្មណ៍នោះ បានដែរ ។ ប្រៀបដូចជា ចិត្តនោះ ជាធម្មជាតិដែលប្រកប

រួមជាមួយនឹងញាណ ធ្លាប់ទាក់ទងនឹងការពិចារណា ( សង្ខារ ឬ សភាវធម៌ ) មកយូរហើយ ក្នុងវេលាខ្លះ សូម្បីថា វៀរចាកញាណ ក៏ប្រព្រឹត្តទៅដោយអំណាចនៃការពិចារណាបាន យ៉ាងណា , ម្យ៉ាងវិញទៀត ប្រៀបដូចជាចិត្ត ជាធម្មជាតិដែលប្រកបនឹងកិលេសប្រព្រឹត្តទៅ ( តមក ) សូម្បីថា វៀរចាកកិលេសហើយ ដោយប្រការទាំងពួង ក៏នៅប្រព្រឹត្តទៅដោយអំណាចនៃកិលេស ព្រមទាំងវាសនា ព្រោះដោយទម្លាប់ យ៉ាងណា បណ្ឌិតគប្បីឃើញឧបមេយ្យនេះ ដូច្នោះដូចគ្នា ។

ការផ្តោតចិត្ត បានជាដំបូង , ឬថា ចំពោះមុខ ឈ្មោះថា **អាហននំ** ។ ការលើកចិត្តឡើងកាន់ ( អារម្មណ៍ ) គឺ ការផ្តោតចិត្តទៅដោយជុំវិញ ឈ្មោះថា **បរិយាហននំ** ។ គប្បីជ្រាបថា ការប្រព្រឹត្តទៅនៃចិត្ត ដែលទឹកចំពោះអារម្មណ៍រឿយ ៗ ថា “ រូប រូប , បឋវី បឋវី ” ដូច្នេះ ហៅថា “ **អាហននំ** , និង **បរិយាហននំ** ” ។ ឈ្មោះថា **ការនាំមកទុក** បានដល់ ការនាំចិត្តចូលទៅ ឬ ការលើកចិត្តឡើងកាន់អារម្មណ៍ ។

ឈ្មោះថា **ការសញ្ចរតាមទៅ** បានដល់ ការតាមទៅដោយជុំវិញ ។ សេចក្តីផ្សេងគ្នា ( នៃវិតក្កៈ និងវិចារ ) នោះ គប្បីឃើញថា រកបានក្នុងចិត្តសន្តានទោះឯង ជាការប្រាកដហើយក្នុងសន្តាន ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ ឈ្មោះថា **ការតាមប្រនៀល** បានដល់ ការតាមពិចារណាក្នុងអារម្មណ៍នៃចិត្ត , សេចក្តីថា សង្កេតដោយជុំវិញ ។ ពិតយ៉ាងនោះ លោកពោលដល់វិចារៈទុកថា “ ប្រៀបដូចជាដៃដែលដុសខាត់ដោយជុំវិញ និងប្រៀបដូចដៃដែលរបទាខាងនេះខាងនោះ ” ដូច្នេះ ។ បទថា **តត្ថ** បានដល់ ក្នុងអារម្មណ៍ គប្បីជ្រាបដល់ការញាំងធម៌ដែលកើតរួមគ្នា ឲ្យតាមប្រកបក្នុងអារម្មណ៍ ដោយទាក់ទងនឹងការតាម

ពិចារណា ពោលគឺ ការត្រាច់ទៅរឿយ ៗ នោះឯង ។ ឈ្មោះថា **ការតាមប្រកៀក** បានដល់ ការប្រព្រឹត្តទៅក្នុងអារម្មណ៍នៃចិត្ត ដោយមិនដាច់ខ្សែដូច្នេះ ។ ពិតដូច្នោះ វិចារៈនោះ លោកបានសម្តែងទុកហើយ ថា " **អនុសន្ធានតា** " ការតាមប្រកៀក ដូច្នេះ ។ ព្រោះហេតុនោះឯង លោកអាចារ្យ ទើបពោលថា " ដូចសម្លេងញ័រនៃ គងដំ , និងដូចការហើរថ្ងេល " ដូច្នេះ ។

ពាក្យថា **ក្នុងចិត្តដួងខ្លះ** គឺ ក្នុងបឋមជ្ឈាន ។ និងក្នុងបរិត្តចិត្តុប្បាទ ទាំងឡាយ ។ វិតក្កៈដូចជាការវាយគងដំដែលគ្រោតគ្រាត ជាងសម្លេងញ័រ និងមាន ការដល់មុនសម្លេងញ័រនោះ ដោយអត្ថថា គ្រោតគ្រាតជាងវិចារៈ , នឹងដោយអត្ថ ថា ដល់មុនវិចារៈនោះឯង ប្រៀបដូចជាការវាយគងដំ ដែលវាយលើកដំបូង យ៉ាង ណា , **វិតក្ក** ក៏មានការធ្វើចិត្តឲ្យដល់មុនក្នុងអារម្មណ៍ជាដំបូង ដោយអត្ថថា លើក ចិត្តឡើងកាន់អារម្មណ៍ ដូច្នោះ ។ ក៏ដោយសព្ទថា **អភិឃាត** ការវាយក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកសម្លេងដែលកើតចាកការវាយ ។ ពាក្យថា **មាន ការផ្សាយទៅ** គឺ ប្រកបដោយការត្រាច់ទៅ ប្រព្រឹត្តទៅជាមួយការញ័រ ។ **វិចារ** ឈ្មោះថា ដូចការហើរថ្ងេល ក៏ដើម្បីពិចារណាដល់ការមិនមាននៃអន្តរាយ ( ត្រួត ពិនិត្យនូវការមិនមានភ័យ ) ។ ពាក្យថា **ក្នុងការប្រព្រឹត្តទៅតាមជាប់គ្នា** គឺ ក្នុង ការប្រព្រឹត្តទៅដោយបន្តគ្នាក្នុងឧបចារៈ ឬក្នុងអប្បនា ។

ពិតណាស់ ក្នុងឧបចារៈ និងអប្បនានោះ វិតក្កៈជាធម្មជាតិដែលមិនមានការ ញាប់ញ័រ ប្រព្រឹត្តទៅហាក់បីដូចជា តាមចូលទៅកាន់អារម្មណ៍ , មិនមែនវិតក្កក្នុង ការលើកចិត្តឡើងកាន់អារម្មណ៍ជាដំបូងនោះទេ ។ ពាក្យថា **រមែងជាការប្រាកដ ច្បាស់** មានន័យថា វិតក្កៈមានសេចក្តីផ្សេងពីវិចារៈ បានដល់ អាការដែលលើកចិត្ត

ឡើងកាន់អារម្មណ៍ រមែងប្រាកដច្បាស់ក្នុងបឋមជ្ឈាន ក៏ព្រោះមានអាការគ្រោតគ្រាត , ភាពផ្សេងគ្នានៃវិចារៈ ពីវិតក្កៈ បានដល់ អាការដែលតាមប្រទៀល រមែងប្រាកដច្បាស់ក្នុងទុតិយជ្ឈាន ក្នុងបញ្ចកន័យ ព្រោះមិនមានវិតក្កៈនោះ ។

ប្រាសដែលធ្វើពីរោមសត្វ មានរោមសត្វកេះជាដើម ឈ្មោះថា **វាលណ្ឌុបកំ** ។ ពាក្យថា **ដៃដែលចាំចាប់ប្រចាប់** បានដល់ ដៃដែលចាំចាប់ប្រចាប់ដុំដី ។ ដៃដែលរបនាដុំដីទៅខាងនោះខាងនេះ ឈ្មោះថា ដៃដែលរបនាខាងនោះខាងនេះ ។ ពាក្យថា **រូបរង្វង់** គឺ ពេលបុគ្គលធ្វើរូបរង្វង់មូល គឺ ធ្វើស្នាមជារង្វង់មូលណា ៗ នៅលើវត្ថុទាំងឡាយ មានភាជន៍សំរឹទ្ធិជាដើម ។ លោកអាចារ្យបំណាងសម្ដែងថា ដើមឈើ កាលបើមិនទាន់មានផ្លែ ផុតចាកអង្គប្រកប មានផ្កា ផ្លែ មែកជាដើម ក៏គេនៅហៅថា ឈើផ្កា ឈើផ្លែ យ៉ាងណា , **ឈាន** សូម្បីមិនមានអង្គប្រកប មានវិតក្កៈជាដើម ក៏គេរមែងហៅថា " **មានវិតក្ក មានវិចារ** " ដូច្នោះ ដូច្នេះទើបពោលថា " ដូចដើមឈើ " ដូច្នេះជាដើម ។ ព្រោះការបម្រើនឈាន គប្បីសម្ដែងទុកដោយទាក់ទងនឹងបុគ្គល ព្រះដ៏មានព្រះភាគ ទ្រង់ទើបលើកឈានឡើងសម្ដែង ដោយទាក់ទងនឹងបុគ្គលាធិដ្ឋាន ដោយពាក្យថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ហើយត្រាច់ទៅ " ដូច្នេះជាដើម ។ ក្នុងគម្ពីរវិភង្គ ទ្រង់ទេសនាជាបុគ្គលាធិដ្ឋានក៏ពិត តែសេចក្ដីបំណាងក្នុងទីនោះ គឺ សូម្បីក្នុងគម្ពីរវិភង្គ ក៏ទ្រង់ត្រាស់ទុកដោយទាក់ទងនឹងធម៌ ដោយពាក្យថា " **ឥមិនា ច វិតក្កេន** " ដោយវិតក្កៈនេះ ដូច្នេះជាដើម បណ្ឌិតគប្បីឃើញដូចគ្នាតែម្យ៉ាងក្នុងទីនេះចុះ អធិប្បាយថា ដោយបរមត្ថ មិនមានបុគ្គលឡើយ ។

ន័យម្យ៉ាងទៀត គប្បីឃើញអត្ថាធិប្បាយក្នុងពាក្យនេះ យ៉ាងនេះថា សូម្បី

សេចក្តីក្នុងទីនោះ បណ្ឌិតគប្បីឃើញតែម្យ៉ាងដូចគ្នា ព្រោះត្រាស់ដល់ឈានទោះឯង មានវិតក្កៈ មានវិចារៈ ដោយការសម្តែងដល់បុគ្គលអ្នកព្រមព្រៀងដោយឈាន ជាអ្នកព្រមព្រៀងដោយវិតក្កៈ និងវិចារៈដូច្នេះចុះ ។

លោកអាចារ្យពោលថា **វិវេកា** ចាកវិវេក សំដៅយក **វិវេក** សព្ទ ជាការសាធនៈ ( ភាពស្ងាត់ ) ថា ចាកវិវេកជាហេតុ ។ បទថា **វិវេកេ** ក្នុង វិវេក លោកអាចារ្យសំដៅយកសេចក្តីជា កត្តុសាធនៈ ( ធម៌ដែលស្ងាត់ ) , ឬកម្មសាធនៈ (ធម៌នៃបុគ្គលស្ងាត់ ) ។ ពិតហើយ ដោយពាក្យថា **វិវិត្តា** ( ធម៌ដែលស្ងាត់ , ធម៌នៃបុគ្គលស្ងាត់ ) នេះ ជាការសង្គ្រោះបានទាំងពីរសាធនៈ តែមួយថា ជាអ្នកវៀរចាកនីវរណៈទាំងឡាយ និងបុគ្គលធ្វើឲ្យស្ងាត់ចាកនីវរណធម៌ទាំងឡាយនោះ ។

បទថា **បីនយតិ** ប្រែថា ធ្វើឲ្យឆ្អែត , ឬ ធ្វើឲ្យចម្រើន ។ បទថា **សម្បិយាយនលក្ខណា** ប្រែថា មានសេចក្តីរីករាយ ជាលក្ខណៈ ។ ពាក្យថា **មានការធ្វើ** (កាយ និងចិត្ត) ឲ្យឆ្អែត ជារស គឺ មានការធ្វើកាយ និងចិត្តឲ្យចម្រើនដោយជុំវិញ ជារស ។ ពាក្យថា មានការផ្សាយទៅ ជារស គឺ មានការធ្វើឲ្យរូបប្រណីតទាំងឡាយ ផ្សាយទៅក្នុងកាយ ជារស ។ ភាពព្រឺរោមព្រឺស្បែក ឈ្មោះថា **ឱទគ្យំ** ។ **ខុទ្ទិកាបីតិ** ( ក្នុងវិសុទ្ធិមគ្គ ជាខុទ្ទកាបីតិ ) ភាពព្រឺរោមបន្តិចបន្តួចហើយក៏អស់ទៅ មិនកើតឡើងទៀត ។ **ខណិកាបីតិ** កើតឡើងបានជាខណៈៗ ។ **ផរណាបីតិ** ប្រណីតជាង **ឧព្វេង្គាបីតិ** ព្រោះមិនមានភាពញាប់ញ័រ ព្រោះតាំងនៅបានយូរ ។ ពាក្យថា **ទៅកាន់លានព្រះចេតិយ** គឺ ទៅកាន់លានព្រះចេតិយក្នុងបុណ្ណវល្លិកវិហារ ។ ពាក្យថា **ដោយទាក់ទងជាមួយអារម្មណ៍ ដែលបានឃើញ**

**ហើយតាមប្រក្រតី** គឺ ដែលទាក់ទងជាមួយអារម្មណ៍ ដែលបានកាន់យកព្រះមហាចេតិយក្នុងថ្ងៃមុន ៗ ។ ឈ្មោះថា **កូនឃ្លីដ៏វិចិត្រ** បានដល់ កូនឃ្លីដែលគេធ្វើហើយដោយអាការដ៏វិចិត្រ ។ បទថា **ឧបនិស្សយេ** បានដល់ ស្ថានទីជិតខឿនឬជាទីអាស្រ័យនៃវិហារនោះ , មានន័យថា ជាស្ថានទីគោចរ ។

បទថា **ឃរាជិរេ** ប្រែថា រាលហាលផ្ទះ លោកហៅចេតិយដែលសាងទុកលើក្អមថា អាកាសចេតិយ ។ ពាក្យថា **ដោយនិមិត្តដែលបានកាន់យកនោះឯង** គឺ ដោយនិមិត្ត នៃកុសលដែលសម្ទឹងដល់ការថ្វាយបង្គំព្រះចេតិយ និងការស្តាប់ធម៌ ហើយកាន់យកដោយគិតថា " បុគ្គលទាំងឡាយនេះ មានបុណ្យហ្ន៎ " ដូច្នេះជាដើម ជាហេតុ ។ ន័យម្យ៉ាងទៀត ចិត្តដែលប្រព្រឹត្តទៅដោយអាការដូចដែលពោលហើយ ឈ្មោះថា **គហិតនិមិត្តំ** ព្រោះអត្ថថា ជាហេតុកាន់យកនិមិត្ត បានដល់ ស្ទុះទៅឰដ៏អាកាសដោយចិត្ត ដែលជាហេតុកាន់យកនិមិត្តនោះឯង ។ បទថា **បក្ខន្ទំ** ប្រែថា អណ្តែតចូលទៅ ។ បទថា **អនុបរិផុដំ** ប្រែថា ផ្សាយចូលទៅដោយជុំវិញ គឺ ផ្សាយជាប់តគ្នាដោយប្រការទាំងពួង ។

**បីតិ** ឈ្មោះថា តាំងគភ៌ ក៏ដោយភាពជាហេតុនៃបស្សទ្ធិ ។ ឈ្មោះថា ដល់នូវភាពចាស់ដោយជុំវិញ ទាក់ទងជាមួយសេចក្តីសុខ ។ **បីតិ** ដែលសម្បយុត្តជាមួយអប្បនាប៉ុណ្ណោះ ជាបីតិដែលធ្វើអប្បនាសមាធិឲ្យពេញ ។ លោកអាចារ្យកាលនឹងមិនប៉ះពាល់បីតិទាំងពីរយ៉ាងនោះ គឺ បីតិដែលធ្វើខណិកសមាធិឲ្យពេញ និងបីតិដែលធ្វើឧបចារសមាធិឲ្យពេញ ព្រោះនៅឆ្ងាយពីអប្បនាសមាធិ ទើបពោលថា " ក្នុងបណ្តាបីតិទាំងឡាយនោះ ផរណាបីតិ ដូចម្តេច ... " ដូច្នេះជាដើម ។ ពាក្យថា **ដល់នូវការប្រកបរួមគ្នានឹងសមាធិ** គឺ ក្នុងខាងដើម ជាបីតិដែលសម្បយុត្ត

ជាមួយឧបចារសមាធិ ចម្រើនទៅតាមលំដាប់ហើយ ក៏ដល់ព្រមក្នុងការប្រកបរួមជាមួយអប្បនាសមាធិ ។

ឈ្មោះថា **សុខ** ព្រោះអត្ថថា ធ្វើឲ្យសុខ មានន័យថា ធ្វើធម៌ទាំងឡាយដែលសម្បយុត្តជាមួយខ្លួនឲ្យបានទទួលនូវសេចក្តីរីករាយ ។ ពាក្យសម្តែងអធិប្បាយជាកត្តុ ( អ្នកធ្វើ ) នោះ បានដោយបរិយាយ មានអត្ថថា ហាមកត្តុយ៉ាងដទៃចាកធម៌ , តែដោយនិប្បរិយាយ រមែងបានសភាវសាធនៈប៉ុណ្ណោះ ព្រោះហេតុនោះលោកអាចារ្យទើបពោលថា " សេចក្តីសុខ ឈ្មោះថា **សុខ** " ។ ឈ្មោះថា **សាតំ** ( សប្បាយ , រីករាយ ) ព្រោះអត្ថថា ញ៉ាំងបុគ្គលដែលព្រមព្រៀងដោយសុខនោះ ឬសម្បយុត្តធម៌ទាំងឡាយ ឲ្យរីករាយក្នុងខ្លួន ព្រោះមានសភាពដែលគួរប្រាថ្នា លោកធ្វើ **ទ** អក្សរ ឲ្យជា **ត** អក្សរ ។ អាចារ្យជាច្រើនពោលដល់ **សាតំ** ថា បានដល់ មានរសឆ្ងាញ់ ។

**សាតំ** ជាលក្ខណៈនៃសុខនេះ ព្រោះហេតុនោះ សុខនេះ ទើបឈ្មោះថា **សាតលក្ខណំ** មានសេចក្តីសប្បាយ ជាលក្ខណៈ ។ ឈ្មោះថា **ចូលទៅកពូន** បានដល់ ការធ្វើសម្បយុត្តធម៌ទាំងឡាយឲ្យចម្រើនព្រម ។ ការមិនលះបង់ ( សម្បយុត្តធម៌ ) ដូចជាទុក្ខ មិនមែនព្រងើយដូចជាអទុក្ខមសុខ ( ឧបេក្ខា ) ហើយតាមទំនុកបម្រុង , ឬជាអ្នកឧបការៈ ឈ្មោះថា សេចក្តីអនុគ្រោះ ។ ពាក្យថា **ក្នុងចិត្តុប្បាទដូចខ្លះ** បានដល់ ក្នុងចិត្តុប្បាទ មានបឋមជ្ឈានជាដើម ។ ពាក្យថា **សេចក្តីរីករាយដែលទាក់ទងនឹងការបានមក** គឺ សេចក្តីរីករាយដែលកើតឡើងដោយទាក់ទងដល់ការបានមក ។

បទថា **បដិលទ្ធរសានុភវនំ** ប្រែថា ការសោយរសនៃអារម្មណ៍ ដែលបាន

មកហើយ លោកសម្តែងចែកបីតិ និងសុខ ដោយសការៈទុកយ៉ាងនេះ ។ លោកពោលដល់បីតិប្រកបបួរមជាមួយសុខតែម្យ៉ាង ដូចពោលដល់វិតក្កៈ ត្រូវប្រកបបួរមជាមួយវិចារៈ ដោយប្រាកដថា ក្នុងទីណាមានបីតិ ក្នុងទីនោះមានសុខ ។ លោកពោលដល់សុខ ប្រកបបួរមជាមួយបីតិ មិនពិតប្រាកដ ដូចពោលដល់វិចារៈ ត្រូវប្រកបជាមួយវិតក្កៈ មិនពិតប្រាកដថា ក្នុងទីណាមានសុខ ក្នុងទីនោះមិនប្រាកដថាមានបីតិ ។ ដោយពាក្យនោះ លោកសម្តែងដល់ភាពផ្សេងគ្នានៃបីតិ និងសុខដែលជាធម៌ប្រកបបួរមគ្នា បានប្រាកដ និងមិនប្រាកដ ។ ស្ថានទី ឈ្មោះថា ទីកន្តារ ព្រោះអត្ថថា ជាទីដែលបុគ្គលឆ្លងទៅបាន ព្រោះអាស្រ័យមានទឹក បានដល់ ស្ថានទីដែលប្រាសចាកទឹក មានតែខ្សាច់ ( សមុទ្រខ្សាច់ ) ។ **វនំ** នោះឯង ជា **វនន្តំ** ប្រែថា ព្រៃ ឬមែកឈើ ។ ពាក្យថា **ក្នុងសម័យនោះ ៗ** គឺ ក្នុងសម័យដែលបានឥដ្ឋារម្មណ៍មក , ក្នុងសម័យដែលបានសោយរសនៃឥដ្ឋារម្មណ៍ហើយ , ក្នុងសម័យដែលបានឮ ឬឃើញម្លប់ឈើជាដើម , និងក្នុងសម័យចូលទៅកាន់គល់ឈើហើយបរិភោគទឹក ។ ពាក្យថា **តាមការប្រាកដច្បាស់** គឺ តាមការៈនៃបីតិ និងសុខ ប្រាកដច្បាស់តាមលំដាប់ ។

ក្នុងបទថា **វិវេកជំ បីតិសុខំ** នេះ ក្នុងអត្ថដំបូង លោកពោលដល់ឈានថា **វិវេកជំ** ឈានកើតចាកវិវេក ។ **អ** អក្សរ ក្នុងពាក្យនេះថា **អស្ស ឈានស្ស** ដល់ឈាននេះ , **អស្មឹ វា ឈានេ** ក្នុងឈាននេះ គប្បីឃើញដោយសព្ទថា **បីតិសុខ** និងដោយអត្ថពិសេសថា មានហើយ ។ ក្នុងអត្ថទី ២ បីតិ និងសុខនោះឯង ឈ្មោះថា **វិវេកជំ** បីតិ និងសុខ កើតចាកវិវេក ។ លោកធ្វើជាពាក្យសមាសជាមួយអត្ថនៃបទដទៃ , និងមិនលុបពាក្យអធិប្បាយចំពោះបទថា “ **វិវេកជម្បីតិ-**

**សុខំ** ” ។ ឬកាលមានការលុប ក៏មានបាឋៈថា **វិវេកជបីតិសុខំ** ដូច្នេះ នេះចាត់ជាសេចក្ដីផ្សេងគ្នា ។

លោកអាចារ្យបំណងសម្ដែងថា **ឧប** សព្ទ និង **សំ** សព្ទ ក្នុងបទថា **ឧបសម្បជ្ជ** នេះ ជាសព្ទដែលមិនមានការសម្គាល់ ដូចគ្នានឹងសព្ទថា **ឧបលព្ភតិ** , **សមុព្ភតិ** ជាដើម ទើបពោលថា **ឧបគន្ត្វា** ជាដើម ដើម្បីសម្ដែង **ឧប** សព្ទ និង **សំ** សព្ទ ទាំងឡាយនោះ ជាសព្ទនៅមានសេចក្ដីទៀត ទើបពោលថា **ឧបសម្បាទយិត្វា** ចូលទៅធ្វើឲ្យដល់ព្រមដូច្នេះជាដើម ព្រោះដូច្នោះ ទើបមានសេចក្ដីថា សម្រេច ឬឲ្យសម្រេច ។ បទថា **ឥរិយំ** បានដល់ កិរិយា ។ បទថា **វុត្តិ** ការប្រព្រឹត្តទៅជាដើម ជាពាក្យវេវចនៈ នៃបទថា **ឥរិយំ** នោះឯង ។ បទថា **បាលនា** ការរក្សាទុក គឺ រក្សាការឈរក្នុងឥរិយាបថមួយ ដោយឥរិយាបថដទៃ ។

## អធិប្បាយ បឋមជ្ឈានលះអង្គ៥

បឋមជ្ឈាន ឈ្មោះថា **បញ្ចង្គវិប្បហីនំ** លះអង្គ ៥ ព្រោះអត្ថថា មានអង្គ ៥ ទាក់ទងនឹងការគ្របសង្កត់ ។ ក្នុងពាក្យថា **បញ្ចង្គវិប្បហីនំ** នេះ ចំពោះសព្ទថា **វិប្បហីនំ** ប្រែថា លះ គប្បីឃើញថា ជាពាក្យមានវិសេសនៈនៅខាងចុង ដូចសព្ទថា **អាហិត** ក្នុងពាក្យថា **អគ្យាហិតោ** ភ្លើងដែលគេនាំមកបូជាដូច្នោះ , ន័យម្យ៉ាងទៀត បឋមជ្ឈាន ឈ្មោះថា **បញ្ចង្គវិប្បហីនំ** ព្រោះអត្ថថា លះដោយអង្គ ៥ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា អកុសលធម៌ សូម្បីដទៃ ក៏ត្រូវឈាននេះលះ មិនមែនឬ កាលបើដូច្នេះ ហេតុអ្វីលោកទើបពោលដល់ឈានលះអង្គ ៥ ប៉ុណ្ណោះ ដូច្នេះហើយ ទើបពោលថា **កិញ្ចាបិ** ដូច្នេះជាដើម ។ លោក

អាចារ្យពោលថា **ក្នុងខណៈនៃឈាន** ព្រោះក្នុងវេលាដែលមិនព្រមព្រៀង ដោយឈាន លោកចិត្តជាដើម ដែលជាបដិបក្ខដល់ឈាន ក៏មានការកើតឡើងបានជាប្រក្រតីដល់ព្រះយោគាវចរ សូម្បីជាអ្នកបានឈាន ។

ពាក្យថា **រមែងត្រូវលះបង់ទៅ** គឺ ទៅប្រាសហើយ មានន័យថា មិនប្រព្រឹត្តទៅ ។ បទថា **ឯកគ្គារម្មណេ** គឺ ក្នុងអារម្មណ៍ដែលមានសភាពតែមួយដោយទាក់ទងជាមួយបឋវីកសិណជាដើម , ឬក្នុងអារម្មណ៍ដែលជាហេតុនាំមកនូវភាពតែមួយ ពោលគឺ **ឯកគ្គតា** ។ ពាក្យថា **ចិត្ត** (ដែលត្រូវកាមច្ឆន្ទៈគ្របសង្កត់) **នោះ** បានដល់ ចិត្តដែលត្រូវអារម្មណ៍ផ្សេង ៗ ប្រលោមហើយ ។ ពាក្យថា **ដើម្បីលះកាមធាតុ** មានន័យថា មិនឡើងកាន់ឈាន ដែលជាបដិបទាដើម្បីលះ គឺដើម្បីឈានកន្លងកាមធាតុ ដែលជាអារម្មណ៍ផ្សេង ៗ ចូលទៅពង្វក់ហើយ ។ ពាក្យថា **ជាប់តគ្នា** បានដល់ មិនត្រូវសេចក្តីពយាបាទរារាំង មានន័យថា តាំងមាំជានិច្ច ។ បទថា **អកម្មញ្ញំ** ប្រែថា មិនគួរដល់ការងារ មានន័យថា ជាចិត្តមិនគួរដល់ការងារ គឺ ការនៃ ។ ពាក្យថា **ត្រូវឧទ្ធច្ចកុក្កុច្ចៈទម្លាយ** គឺ ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ ។ ឈ្មោះថា **រសាត់ទៅ** ក៏ព្រោះមិនតាំងស៊ប់ មានន័យថា ព្រោះមិនមានការតាំងចុះ គឺ មិនតាំងមាំជានិច្ច ។ ពាក្យថា **ត្រូវវិចិកិច្ឆាចូលទៅរារាំងទុក** មានន័យថា ត្រូវវិចិកិច្ឆាប្រព្រឹត្តទៅថា ព្រះសម្មាសម្ពុទ្ធ មានពិតឬហ្ន៎ , ព្រះមានព្រះភាគ មានពិតឬហ្ន៎ ដូច្នេះ និងដោយន័យថា ដោយការធ្វើទុកក្នុងចិត្តថា **បឋវី** ជាដើម ឈាននឹងមាន ឬ មិនមានហ្ន៎ ដូច្នេះជាដើម ក៏ចូលទៅរារាំងទុក ព្រោះមិនមានវិចារៈដែលមានភាពល្អឯក ។ ឈ្មោះថា **មិនឈានឡើង** ក៏ព្រោះមិនជាហេតុនៃការបដិបត្តិ ។ ពាក្យថា **ព្រោះធ្វើអន្តរាយដល់ឈានបានយ៉ាង**

**ពិសេស** គឺ ព្រោះធ្វើអន្តរាយដល់ការសម្រេចឈាន ព្រោះជាសត្រូវដោយត្រង់នៃអង្គឈាន មានសមាធិជាដើម ។

ពាក្យថា **វិតក្កៈ និង វិចារៈទាំងឡាយនោះ ញុំាងឲ្យដល់ព្រមហើយ** គឺ វិតក្កៈ និងវិចារៈ ជាបច្ច័យដល់ការសម្រេចឈាន ។ ពាក្យថា **មានប្រយោគដែល វិតក្កៈ និងវិចារៈទាំងឡាយនោះ ញុំាងឲ្យដល់ព្រមហើយ ដោយការមិនរាយមាយ** គឺ ដល់ចិត្តដែលមានការប្រកបក្នុងភាវនា ដែលវិតក្កៈ និងវិចារៈទាំងឡាយនោះ ធ្វើឲ្យសម្រេចហើយ ដោយភាពតាំងមាំជានិច្ចនោះឯង ។ ពាក្យថា **ដែលកើតចំពោះប្រយោគសម្បត្តិនៃចិត្ត** គឺ ដែលមានការដល់ព្រមនៃការប្រកបក្នុងភាវនា តាមដែលពោលហើយ ជាសមុដ្ឋាន ។ សម្ព័ន្ធសេចក្តីថា **បីតិ** រមែងធ្វើការផ្អែត គឺ ការផ្អែតដោយអំណាចភាវនា ។ **សុខ** រមែងធ្វើការបូលទៅចម្រើន គឺ ការចម្រើនដោយជុំវិញដល់ចិត្ត ដោយអំណាចនៃភាវនា ។

បទថា **នំ** បានដល់ ចិត្ត ។ សម្ព័ន្ធសេចក្តីថា រមែងតាំងចិត្តព្រមទាំងសម្បយុត្តធម៌ដ៏សេស គឺ ចិត្តដែលប្រព្រឹត្តទៅរួមជាមួយធម៌ មានផស្សៈជាដើម ឲ្យស្មើគ្នា និងដោយប្រពៃ ។ សេចក្តីថា តាំងមាំជានិច្ច ដោយទាក់ទងនឹងភាពស្មើគ្នានៃឥន្ទ្រិយ និងដោយប្រពៃ ដោយមិនមានការរួញរា និងរាយមាយ ព្រោះនៅឆ្ងាយពីធម៌ជាបដិបក្ខទាំងឡាយ ។ ពិតហើយ ឯកគ្គតា កាលនឹងធ្វើចិត្ត និងសម្បយុត្តធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅតាមខ្លួន ដោយកិច្ច គឺ ការតាំងមាំជានិច្ច រមែងធ្វើឲ្យតាំងមាំបានដ៏ប្រសើរ ក្នុងខណៈនៃឈាននោះឯង ។

ពាក្យថា **ទាក់ទងជាមួយនឹងឧប្បត្តិ** គឺ ទាក់ទងជាមួយនឹងការកើតឡើងតាមសមគួរដល់បច្ច័យ ។ កាលអង្គទាំងឡាយ មានវិតក្កៈជាដើម កើតឡើងហើយ

ឈាន ឈ្មោះថា កើតឡើងហើយ ព្រោះមានវោហារថា ឈាន ក៏ដោយសារអង្គ ទាំងនោះឯង ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ ព្រោះហេតុនោះ ” ដូច្នេះ ជាដើម ។ សូម្បីដោយពាក្យថា “ **យថា បន** ” ជាដើម លោកធ្វើសេចក្តី នោះឯង ឲ្យជាក់ច្បាស់ក្រៃលែង ដោយអំណាចនៃឧបមា ។ ពាក្យថា ប្រសើរជាង បកតិចិត្ត គឺ ប្រសើរជាងកាមាវចរចិត្តដែលមានតាមប្រក្រតី ។ បទថា **សុវិស-ទេន** គឺ ដោយអាការក្លៀវក្លា មានន័យថា ដោយអាការដែលប្រាកដច្បាស់ ។ ពាក្យថា **ទូទាំងកាយដែលមានគ្រប់ចំណែក** គឺ ទូទាំងកាយដែលមានអវយវៈទាំង ពួង មានន័យថា ទូទាំងកាយមិនមានចំណែកសល់ ។ ពាក្យថា **មិនផ្សាយទៅដល់** គឺ មិនសម្ផស្ស ។ ពាក្យថា **ខ្ទប់ក្នុងអារម្មណ៍ទាំងឡាយ** លោកអធិប្បាយថា **ចិត្តេ-កគ្គតា** ដែលប្រព្រឹត្តទៅទាក់ទងនឹងអប្បនា រមែងដូចការផ្សាយទៅកាន់អារម្មណ៍ ដោយជុំវិញ លោកអាចារ្យសំដៅយក ពាក្យសួរថា ព្រោះហេតុអ្វី ក្នុងទីនេះលោក ទើបកាន់យក **ចិត្តេកគ្គតា** ដែលព្រះមានព្រះភាគទ្រង់មិនបានកាន់យកក្នុងឈានបឋមៈ ដូច្នេះ ទើបពោលថា **តត្ថ ចិត្តេកគ្គតា** ដូច្នេះជាដើម ។ បទថា **តត្ថ** ប្រែថា ក្នុង បណ្តាអង្គឈានទាំងឡាយនោះ ។ ពាក្យថា **មិនបានទ្រង់សម្តែងអធិប្បាយទុក** គឺ ទ្រង់មិនបានសម្តែងអធិប្បាយទុក ជាសភាវៈដែលមាន សូម្បីដូច្នោះ ក៏ឈ្មោះថា ទ្រង់កាន់យកហើយ ដោយសព្ទថា **ឈាន** ព្រោះភាពជាឈានដូចគ្នា ។ ព្រោះ ត្រាស់ទុកយ៉ាងនេះ គឺ ព្រោះត្រាស់ទុកដោយជាសភាវៈដែលមានហើយ ភ្ជាប់សេចក្តី ថា **ចិត្តេកគ្គតា** ចាត់ជាអង្គឈានមួយដែរ ។ ពាក្យថា **ដោយព្រះបំណងណា** គឺ ទ្រង់ធ្វើឧទ្ទេសដោយពាក្យថា “ **សវិតក្កំ សវិចារំ** ” ជាដើម ទ្រង់ព្រះបំណងដើម្បី ប្រកាសនូវឈាននោះ ដើម្បីសម្តែងធម៌ដែលកំពុងប្រព្រឹត្តទៅព្រមជាមួយអង្គឈាន

មានវិតក្កៈជាដើម យ៉ាងណា , ព្រះបំណាងនោះឯង ដែលព្រះមានព្រះភាគទ្រង់សម្តែងអធិប្បាយថា **ចិត្តេកគ្គតា** ទ្រង់ប្រកាសទុកក្នុងវិភង្គ ។ ព្រោះដូច្នោះ បណ្ឌិតមិនគប្បីគិតថា **ចិត្តេកគ្គតា** នោះ ទ្រង់មិនបានកាន់យកក្នុងឈានបាឋៈឡើយ ។

## អធិប្បាយបឋមជ្ឈាន មានលំអ ៣ យ៉ាង

ពាក្យថា **ទាក់ទងនឹងខាងដើម កណ្តាល ខាងចុង** គឺ ទាក់ទងខាងដើម កណ្តាល ខាងចុងនៃឈាន ។ ពាក្យថា **ទាក់ទងដោយលក្ខណៈ** គឺ ទាក់ទងនឹងភាវៈដែលជាខាងដើម កណ្តាល និងខាងចុងនោះឯង ដែលបណ្ឌិតគប្បីកំណត់បានក្នុងអប្បនា ។

បទថា **តត្រ** បានដល់ ក្នុងការបើកផ្ការទូវលំអ និងលក្ខណៈនោះ ។ បទថា **បដិបទាវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃបដិបទា មានន័យថា ការនាន័យ ជាចំណែកខាងដើម មានគោត្រភូជាទីបំផុត , ឈ្មោះថា **បដិបទា** ព្រោះអត្ថថា ជាឧបាយក្នុងការបដិបត្តិឈាន ។ សេចក្តីបរិសុទ្ធចាកអន្តរាយ ឈ្មោះថា **វិសុទ្ធិ** , សេចក្តីបរិសុទ្ធចាកអន្តរាយនៃបដិបទា ឈ្មោះថា **បដិបទាវិសុទ្ធិ** ។ ព្រោះហេតុសេចក្តីបរិសុទ្ធនៃបដិបទានោះ ព្រះយោគីរមែងបានក្នុងឧប្បាទខណៈនៃឈាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានសេចក្តីបរិសុទ្ធនៃបដិបទាជាខាងដើម ដូច្នេះ ។

ពាក្យថា **សេចក្តីចម្រើននៃឧបេក្ខា** មានន័យថា ព្រោះមិនមានអន្តរាយដែលគប្បីជម្រះឲ្យបរិសុទ្ធជាដើម **តត្រមជ្ឈត្តុបេក្ខា** ឧបេក្ខា គឺ ភាពជាកណ្តាលក្នុងសហជាតធម៌ ដែលទាក់ទងក្នុងឈាន ទើបមានសេចក្តីតាមចម្រើនដើម្បីភាពសម្រេច

នៃកិច្ច ។ ការតាមចម្រើននៃឧបេក្ខានោះ រមែងមានក្នុងឋិតិខណៈនៃឈានដោយពិសេស ។ ព្រោះហេតុនោះ លោកទើបពោលថា **មានការចម្រើននៃឧបេក្ខាជាកណ្ដាល** ដូច្នេះ ។

ពាក្យថា **ការរីករាយ** បានដល់ សេចក្ដីផូរផង់ទាក់ទងនឹងញាណដែលប្រព្រឹត្តទៅមិនលើសគ្នាជាដើម នៃធម៌ទាំងឡាយក្នុងបឋមជ្ឈាននោះឲ្យសម្រេច មានការសម្រេចកិច្ច ។ ក៏ព្រោះការរីករាយនោះ រមែងប្រាកដក្នុងខណៈនៃឈានដល់ទីបំផុត ព្រោះហេតុនោះ លោកទើបពោលថា **មានសេចក្ដីរីករាយជាទីបំផុត** ដូច្នេះ ។ ពាក្យថា **លក្ខណៈ ៣ នេះ** គឺ ឈានមានលក្ខណៈដែលដល់អប្បនា ក្នុងខាងដើម គឺ ក្នុងឧប្បាទៈ ៣ នេះ គឺ ចិត្តបរិសុទ្ធចាកអន្តរាយ ១ , ចិត្តដែលប្រព្រឹត្តទៅក្នុងសមថនិមិត្តជាកណ្ដាល ១ , ចិត្តដែលស្ទុះទៅក្នុងសមថនិមិត្តនោះ ១ ព្រោះបើវៀរចាកអាការទាំងឡាយនោះហើយ ក៏មិនមានការដល់អប្បនា និងព្រោះបើអប្បនាមិនមាន អាការទាំងនោះក៏មិនមាន ។

បឋមជ្ឈាន ឈ្មោះថា មានលម្អខាងដើម ជាដើមនោះឯង ព្រោះបទដែលដល់នូវសេចក្ដីបរិសុទ្ធិ ។ ឈ្មោះថា **សំបូរណ៌ដោយលក្ខណៈ ៣** ព្រោះប្រកបព្រមដោយលក្ខណៈ តាមដែលពោលហើយ និងព្រោះមានលក្ខណៈដល់ព្រម ។ បណ្ឌិតគប្បីជ្រាប ពាក្យប្រកបសេចក្ដីចំពោះលក្ខណៈនៃបទកណ្ដាល និងបទចុងតាមន័យនេះចុះ ។

**បរិកម្ម** មានអាវជ្ជនៈផ្សេង ៗ គ្នា ឈ្មោះថា **សម្ភារៈ** ព្រោះអត្ថថា ជាគ្រឿងឧបត្ថម្ភឈាន ។ ឈ្មោះថា **សសម្ភារៈ** ព្រមទាំងសម្ភារៈ ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយសម្ភារៈ សសម្ភារៈនោះឯងជា **សសម្ភារិកៈ** ។ ពាក្យថា **ឧបចារៈ** លោក

ពោលដល់ឧបចារៈដែលមានអាវជ្ជនៈដូចគ្នា ។ ព្រោះកិច្ចមានការផ្គង ( នៃវិរិយៈ ) ជាដើម ព្រះយោគីធ្វើឲ្យសម្រេចបានហើយ ដោយការនាក្នុងចំណែកខាងដើមនោះឯង ភាពព្រងើយដែលសម្រេចក្នុងឧបចារៈ ដែលមានអាវជ្ជនៈដូចគ្នា យ៉ាងណា ការព្រងើយនោះ ឈ្មោះថា មានការចម្រើនដោយជុំវិញហើយ ក្នុងខណៈនៃឈាន ព្រោះហេតុនោះ លោកទើបពោលថា " **អប្បនា** ឈ្មោះថា ការតាមចម្រើននូវឧបេក្ខា " ដូច្នេះ ។

អាការដែលរីករាយ ជាការរីករាយនៃចិត្ត ព្រោះអាស្រ័យឈានដែលបានសម្រេចហើយ លោកសំដៅយកអាការដែលរីករាយនោះ ប្រព្រឹត្តទៅទាក់ទងនឹងការពិចារណា ពោលថា " ការពិចារណា ឈ្មោះថា ការរីករាយ " ។ ពាក្យថា អាចារ្យមួយពួកទៀត គឺ អាចារ្យដែលអាស្រ័យនៅអភ័យគីរីវិហារ ។ ពិតណាស់ អាចារ្យពួកនោះ ពណ៌នាបដិបទាវិសុទ្ធិជាដើមទុកយ៉ាងនេះ ពាក្យនោះមិនត្រឹមត្រូវ ។

ព្រោះថា បើដូច្នោះ ក៏ឈ្មោះថា ជាការធ្វើការសរសើរគុណនៃឈានទុកដោយធម៌មិនមែនជាឈាន ។ ពិតណាស់ ធម្មជាតិដែលមានភូមិមួយ និងធម្មជាតិដែលទាក់ទងនឹងភូមិមួយទៀត រកមិនបាន ។ លោកអាចារ្យបំណងសម្តែងថា ពាក្យដែលពោលនេះ ខុសនឹងព្រះបាលី ទើបពោលថា " តែព្រោះហេតុដែល " ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា ចិត្តដែលមានភាពតែមួយ មានន័យថា ព្រោះដល់នូវភាពជាកំពូលដោយការៈ ដែលឥន្ទ្រិយទាំងឡាយ មានរសតែមួយដូចគ្នា និងដោយការៈដែលមានអារម្មណ៍តែមួយ ចិត្តទើបមានការស្រេបតាមការៈនោះ ។

បទថា **ឯកត្តគតំ** បានដល់ ចិត្តដែលដល់នូវភាពតែមួយ គឺ ចិត្តដែល

សម្បយុត្តដោយអប្បនា ។ លោកពោលដល់ចិត្តដែលដល់អប្បនានោះឯង ជាធម្ម-ជាតិស៊ុះទៅកាន់ភាពបរិសុទ្ធនៃបដិបទាជាដើម ទុកនៅក្នុងលំដាប់ទីមួយ ។ ពាក្យថា **ព្រោះដូច្នោះ** គឺ ព្រោះសេចក្ដីបរិសុទ្ធិនៃបដិបទាជាដើម លោកពោលទុកក្នុងព្រះបាលីក្នុងខណៈនៃអប្បនាចិត្តមួយនោះឯង ។ ពាក្យថា **ដោយទាក់ទងនឹងធម៌ដែលជាហេតុមក** គឺ ដោយទាក់ទងនឹងបរិកម្ម ដែលជាហេតុមក ។

ដោយ **អាទិ** សព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **អនតិវត្តនាទិ** ប្រព្រឹត្តទៅមិនលើសគ្នានិងគ្នាជាដើម លោករួមយកការៈនៃឥន្ទ្រិយទាំងឡាយ មានរសតែមួយដូចគ្នា ការញ៉ាំងសេចក្ដីព្យាយាមដែលចូលដល់ការៈនោះ ឲ្យប្រព្រឹត្តទៅ និងការសេព រួមទុក ។ បទថា **បរិយោទាបកស្ស** ប្រែថា ( ញាណ ) ដែលធ្វើឲ្យបរិសុទ្ធ បានដល់ ការធ្វើឲ្យបរិសុទ្ធិ ។ ក្នុងទីនេះ គប្បីជ្រាបថា ការធ្វើការៈនៃធម៌ទាំងឡាយ ប្រព្រឹត្តទៅមិនលើសគ្នានិងគ្នាជាដើម ឲ្យសម្រេច នោះឯងជាការសម្រេចកិច្ចនៃញាណ ។

បទថា **តស្មឹ** ប្រែថា ក្នុងវារៈនោះ មានន័យថា ក្នុងអប្បនាវិថី ដែលមានបរិមាណនៃជវនចិត្ត ៤ ឬ ៥ ដួង ។ បទថា **តតោ** បានដល់ ចាកអន្តរាយ ។ ដើម្បីនឹងកាន់យកបរិកម្មដែលជាហេតុមក លោកទើបពោលទុក ប្រសិនបើមិនមានភាពផ្សេងគ្នាថា ចិត្តរមែងបរិសុទ្ធ ដូច្នេះក៏ពិត , សូម្បីដូច្នោះ សេចក្ដីបរិសុទ្ធិនៃអប្បនា មានភាពប្រសើរជាងសេចក្ដីបរិសុទ្ធិនៃបរិកម្ម ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ព្រោះបរិសុទ្ធ ដូច្នេះជាដើម ។

ពាក្យថា ជាធម្មជាតិដែលវៀរចាកគ្រឿងរារាំង មានន័យថា ក្នុងកាលដើមឡើយ ចិត្តរមែងមិនអាចឡើងកាន់សមថនិមិត្តជាផ្លូវកណ្ដាលបាន ព្រោះត្រូវគ្រឿង

រារាំងណាឃាំងទុក ជាធម្មជាតិដែលវៀរចាកគ្រឿងរារាំងនោះ មានន័យថា គ្រប សង្កត់គ្រឿងរារាំងនោះបាន ។ អប្បនាសមាធិ ឈ្មោះថា ជាផ្លូវកណ្ដាល ព្រោះ មិនចូលដល់ផ្លូវអមទាំងពីរ គឺ ការរួញរា និងការរាយមាយ ។ ឈ្មោះថា សមថៈ ព្រោះមានការចូលទៅស្ងប់ធម៌ដែលជាសត្រូវបានយ៉ាងពិសេស និងឈ្មោះថា និមិត្ត ព្រោះជាហេតុនៃសុខពិសេសរបស់ព្រះយោគី ព្រោះហេតុនោះ ទើបឈ្មោះថា សមថ-និមិត្ត ជាផ្លូវកណ្ដាល ។

ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ អប្បនាសមាធិ ដែលមាន ការប្រព្រឹត្តទៅស្មើហើយ នោះឯង ” ។ ពាក្យថា **ចិត្តដួងមុន នៃអប្បនាចិត្ត** បាន ដល់ ចិត្តដួងមុនជាអនន្តរប្បច្ច័យដល់អប្បនាចិត្តនោះ មានន័យថា គោត្រភូចិត្ត ។ ពាក្យថា **ដោយន័យដែលផ្លាស់ប្ដូរ ក្នុងការបន្តគ្នាជាខណៈ** មានន័យថា ក្នុងភាព ផ្សេងគ្នានៃបរិត្តៈ និងមហគ្គតៈ និងភាពផ្សេងគ្នានៃបច្ច័យ និងបច្ចុប្បន្នៈ និងមាន ( ចិត្តដួងមុននៃអប្បនាចិត្តនោះ ចូលដល់ភាពជាយ៉ាងនោះបាន ) ក៏ដោយការចូល ដល់សភាពប្រែប្រួលទៅក្នុងការបន្តគ្នានោះឯង គឺ ដោយអំណាចឯកត្តន័យ ដូច ពាក្យថា “ ទឹកដោះជូរ បានមកអំពីទឹកដោះស្រស់ ” ។ បទថា **តបត្តំ** ភាពពិត នោះ បានដល់ ការតាំងមាំ ដោយអំណាចអប្បនាសមាធិ ។ ពាក្យថា **ព្រោះ ការប្រព្រឹត្តទៅយ៉ាងនេះ** គឺ ព្រោះការប្រព្រឹត្តទៅ ដូចអាការបានពោលហើយ ។ ពិតណាស់ ក្នុងខណៈណាព្រះយោគីប្រព្រឹត្តយ៉ាងនោះហើយ គឺ ឡើងកាន់សមថ-និមិត្តជាផ្លូវកណ្ដាល ខណៈនោះឯង ឈ្មោះថា ស្ទុះទៅក្នុងសមថនិមិត្តនោះ ដោយ ការចូលដល់សេចក្ដីពិតនោះ គឺ ដោយចូលដល់ការតាំងមាំក្នុងអប្បនាសមាធិនោះ ។

ពាក្យថា **ក្នុងចិត្តដួងមុន** គឺ ក្នុងចិត្តដួងមុននៃអប្បនាចិត្ត បានដល់ ក្នុង

គោត្រភូចិត្ត ។ ពាក្យថា **ធ្វើអាការដែលមានឲ្យសម្រេច** គឺ ធ្វើឲ្យបរិសុទ្ធចាកអន្ត-រាយ ។ អាការដែលឡើងកាន់សមថនិមិត្តជាផ្លូវកណ្តាល និងអាការដែលស្ទុះទៅ ធ្វើឲ្យចិត្តនោះសម្រេច មានន័យថា ដែលកំពុងសម្រេចដោយអាការនោះ ។

ពិតណាស់ អាការដែលកំពុងសម្រេចក្នុងខណៈនៃឈាន ដោយបច្ច័យពិសេស ទាំងឡាយនោះ លោកពោលដូចគ្នាថា ធ្វើភាពពិសេសនោះឲ្យសម្រេចដល់ឈាន ដែលបានសមញ្ញាថា “ បដិបទាវិសុទ្ធិ ” ដូច្នោះ ។ ពាក្យថា **ក្នុងឧប្បាទខណៈនោះឯង** គឺ ក្នុងវេលាដែលបានខួននោះឯង ។ លោកអាចារ្យធ្វើពាក្យរំពឹងទុក ក្នុងចិត្តថា ប្រសិនបើដូច្នោះ អាការទាំងឡាយនោះ សម្រេចបានដូចម្តេច ទើប ពោលថា **ដោយទាក់ទងនឹងហេតុមក** ។

បទថា **តស្ស** បានដល់ ចិត្តនោះ ។ ច្រើនបទថា **វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ** រមែងព្រងើយក្នុងចិត្តដែលបរិសុទ្ធហើយ មកហើយក្នុងព្រះបាលី ជាបុគ្គលាធិដ្ឋាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ព្រះយោគីមិនធ្វើសេចក្តីព្យាយាម** ដូច្នេះ ។ ការប្រព្រឹត្តទៅក្នុងសមថៈ និងការចូលដល់សេចក្តីពិតនោះ ឈ្មោះថា ចូលដល់ភាពជាសមថៈក្នុងទីនេះ ព្រោះហេតុនោះ លោកទើបពោលថា **ដោយការចូលដល់ភាពជាសមថ** ។ ពាក្យថា **កាលបើចិត្តនោះប្រាកដដោយភាពតែមួយ ព្រោះលះបង់ការប្រឡូកប្រឡល់ដោយសង្កិលេស** មានន័យថា កាលឈានចិត្តប្រាកដ ដោយភាពតែមួយ មិនមានការប្រឡូកប្រឡល់ដោយកិលេស ព្រោះលះបង់កិលេស នោះបានហើយ ដោយការប្រព្រឹត្តទៅក្នុងសមថៈនៃព្រះយោគី ដែលខាងដើមបាន គិតថា “ យើងនឹងលះបង់សេចក្តីប្រឡូកប្រឡល់ដោយកិលេស បានយ៉ាងណាហ្ន៎ ” ដូច្នេះ ហើយក៏បដិបត្តិ ។

ក្នុងឈានចិត្ត ដែលត្រូវការសម្រេចដល់ភាពច្បាស់ ព្រោះសេចក្តីបរិសុទ្ធិចាក អន្តរាយ ការប្រព្រឹត្តទៅក្នុងសមថនិមិត្តដែលជាផ្លូវកណ្តាល និងការស្ទុះទៅតាម ការទាហើយ តត្រមជ្ឈត្តុបេក្ខាដែលបានឱកាសហើយ កំពុងប្រព្រឹត្តទៅដោយសភាវៈ ដែលធ្វើឲ្យប្រព្រឹត្តទៅដោយស្មើក្នុងសម្បយុត្តធម៌ទាំងឡាយ រមែងដូចគ្នា ក្នុងការតាម ចម្រើនសម្បយុត្តធម៌ទាំងឡាយនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បី ជ្រាបន័យក្នុងការតាមចម្រើនឧបេក្ខា ដោយទាក់ទងនឹងកិច្ចនៃតត្រមជ្ឈត្តុបេក្ខា ដូច្នេះ ។ ក្បាប់សេចក្តីថា **យេ បនេតេ យុគនទ្ធធម្មា** ( យុគនទ្ធធម៌ទាំងនេះណា ) ។ បទថា **តត្ថ** បានដល់ ក្នុងឈានចិត្តនោះ ។ សមាធិ និងបញ្ញា ជាគូគ្នា ដូចជាគោទឹម ក្នុងនឹមតែមួយ ព្រោះធ្វើកិច្ចឲ្យប្រព្រឹត្តទៅ ដោយមិនលើសខ្វះគ្នា ទើបឈ្មោះថា យុគនទ្ធធម៌ ។ ពាក្យថា **ដោយវិមុត្តិរស** គឺ ដោយការរួចផុត ជាកិច្ច , ឬដោយ ការរួចផុត ជាសម្បត្តិ ។ ឈ្មោះថា **ឯស** បានដល់ ព្រះយោគី ។ បទថា **វាហយតិ** ប្រែថា ធ្វើឲ្យប្រព្រឹត្តទៅ ។ បទថា **អស្ស** បានដល់ នៃឈានចិត្ត ។

ពាក្យថា **ក្នុងខណៈនោះ** គឺ ក្នុងភង្គខណៈ ។ ការពិត កាលឧប្បាទខណៈ កន្លងទៅហើយ **ការសេព** ចាប់តាំងពីឋិតិខណៈទៅ ឈ្មោះថា ការប្រព្រឹត្តទៅ ។ ពាក្យថា **អាការទាំងនោះ** បានដល់ អាការប្រព្រឹត្តទៅនៃធម៌ទាំងឡាយក្នុងឈាន-ចិត្តនោះ ដែលមានការមិនឈានកន្លងហួសគ្នានិងគ្នាជាដើម ។ ពិតហើយ សូម្បីការ សេព ក៏ជាការប្រព្រឹត្តទៅនៃធម៌ទាំងឡាយ ដែលមានចំណែកនៃអាសេវនប្បច្ច័យ នោះឯង ។

ពាក្យថា **ក្នុងភាពសៅហ្មង និងផូរផង់** មានន័យថា ការមិនធ្វើសមាធិ និង បញ្ញាឲ្យមានរសស្មើគ្នា ចាត់ជាភាពសៅហ្មងនៃភាវនា ការធ្វើ ចាត់ជាភាពផូរផង់ ។

សូម្បីក្នុងធម៌ទាំងឡាយដ៏សេស ក៏ដូច្នោះ ព្រោះឃើញ **អាទីនវៈ** គឺ **ទោស** និង **អានិសង្ស** គឺ គុណនោះៗ ក្នុងភាពសៅហ្មង និងផូរផង់នេះ ឲ្យប្រាកដដោយបារិហារិយប្បញ្ញា យ៉ាងនេះហើយ ទើបមានការប្រព្រឹត្តទៅ មិនកន្លងគ្នានិងគ្នាជាដើម យ៉ាងណា ព្រោះការៈដែលធ្វើការនាឲ្យរីករាយ គឺ ធ្វើឲ្យបរិសុទ្ធបានដោយញាណនោះ ៗ ឯង ទើបមានភាពរីករាយបាន ។ ក៏ការធ្វើឲ្យបរិសុទ្ធ ចាត់ជាការរីករាយក្នុងទីនេះ ។ លោកអាចារ្យសំដែងដោយអំណាចការបញ្ជាក់ តាមដែលបានពោលទុកក្នុងខាងដើម នៃការសំវណ្ណនាលក្ខណៈថា ព្រោះហេតុដែលអាការទាំងនោះឈ្មោះថា ជាការសម្រេចហើយ ព្រោះដូច្នោះខ្ញុំម្ចាស់ទើបពោលថា “គប្បីជ្រាបសេចក្តីរីករាយ ។ល ។ ដោយការធ្វើការៈ នៃធម៌ទាំងឡាយឲ្យប្រព្រឹត្តទៅ មិនកន្លងគ្នានិងគ្នា ឲ្យសម្រេចដូច្នេះ ។

លោកអាចារ្យសំដៅយកពាក្យទំនាក់ទំនងដែលថា ចំពោះពាក្យថា “ ព្រោះហេតុដែលញាណប្រាកដដោយអំណាចនៃឧបេក្ខា ” ដូច្នេះ មានអ្វីជាសម្ព័ន្ធគ្នា ។ ព្រោះហេតុអ្វី ទើបពោលដល់ភាពរីករាយថាជាទីបំផុត មិនពោលដល់ការតាមចម្រើនឧបេក្ខាថា ជាទីបំផុតទៅវិញ ដូច្នេះទើបពោលថា ក្នុងការនាចិត្តនោះ ព្រោះហេតុដែលញាណប្រាកដច្បាស់បាន ដោយអំណាចនៃឧបេក្ខាដូច្នេះ ។ បទថា **តត្ថ** បានដល់ នៃការនាចិត្តនោះ ។ ពាក្យថា **ញាណដែលប្រាកដច្បាស់បានដោយអំណាចនៃឧបេក្ខា** មានន័យថា ក្នុងកាលនៃអប្បនា រមែងមានតែភាពព្រងើយតែម្យ៉ាង ព្រោះមិនចាំបាច់ធ្វើសេចក្តីព្យាយាមក្នុងការលើកចិត្តជាដើម ព្រោះការនាប្រព្រឹត្តទៅស្មើល្អ និងព្រោះលះបង់ធម៌ដែលជាបដិបក្ខបាន ដែលបានដល់ ភាពព្រងើយ ដែលលោកសំដៅយក ការពោលទុកថា “ភាពព្រងើយនៃចិត្តក្នុងសម័យ និងរមែងនៅ

ព្រងើយៗ ក្នុងចិត្តដែលផូរផង់ហើយ ” ដូច្នេះជាដើម ។ ភាពកណ្តាលនោះ រមែង មានបានដោយញាណសម្រេចកិច្ច , ដោយពិសេស រមែងមានបានដោយផលដែល ដឹងបានដោយការអនុលោមតាមហេតុថា ព្រោះសេចក្តីមិនព្យាយាមនៃអប្បនា មាន ញាណជាអ្នកធ្វើឲ្យសម្រេចដូច្នេះ ។ ភ្ជាប់សេចក្តីថា ព្រោះហេតុដែលញាណប្រាកដ ច្បាស់បានដោយអំណាចនៃឧបេក្ខា ព្រោះដូច្នោះ ភាពរីករាយដែលជាកិច្ចនៃញាណ ទើបលោកពោលថា ជាទីបំផុតដូច្នេះ ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងធ្វើន័យតាមដែលបានពោលហើយ ឲ្យធ្ងន់ ដោយព្រះបាលី ទើបពោលថា ដូចព្រះសារីបុត្តត្ថេរពោលទុកថា ដូច្នេះជាដើម ។

ពាក្យថា **នូវចិត្តដែលបានលើកទុកហើយដោយអាការនោះ** គឺ នូវភាវនាចិត្ត ដែលបានលើកទុកហើយ ដោយអាការដែលនឹងមិនធ្លាក់ទៅក្នុងចំណែកនៃកោសជ្ជៈ ដោយអំណាចនៃការធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃវីរិយសម្ពោជ្ឈង្គៈ ។ ពាក្យថា **រមែងព្រងើយយ៉ាងល្អ** គឺ រមែងព្រងើយយ៉ាងគោរព ព្រោះសូម្បីព្រះ- យោគីអ្នកលើក បានលើកហើយដោយអំណាចការប្រកបភាពស្មើគ្នានៃសមាធិ និង វីរិយៈនោះឯង ។ តត្រមជ្ឈត្តុបេក្ខារមែងបានឱកាស ។ ក៏ភាពព្រងើយនោះ បាន ដល់ ភាវៈនៃអប្បនាបញ្ញាជាធម្មជាតិដែលក្រៃលែងដោយកិច្ច ដោយទាក់ទងនឹង ភាពព្រងើយ ដោយអំណាចនៃបារិហារិយប្បញ្ញាដែលប្រព្រឹត្តទៅក្នុងខាងដើម ព្រោះ ហេតុនោះ ទើបលោកពោលថា បញ្ញិន្ទ្រិយមានប្រមាណក្រៃលែងដោយអំណាចនៃ បញ្ញាដូច្នេះ ។ ព្រោះបញ្ញិន្ទ្រិយនោះ មានប្រមាណក្រៃលែងនោះឯង អប្បនាចិត្ត របស់ព្រះយោគីដែលកំពុងព្រងើយនោះឯង រមែងផុតចាកអំពីកិលេសទាំងឡាយ ដែលមានសភាពផ្សេង ៗ គ្នា មាននីវរណៈជាប្រធាន ។ ឈ្មោះថា **ដោយអំណាច**

**នៃវិមោក្ខ** គឺ ដោយអំណាចនៃការរួចផុត ។ ពាក្យថា **ដោយអំណាចនៃបញ្ញា** គឺ ដោយអំណាចនៃបារិហារិយបញ្ញាដែលប្រព្រឹត្តទៅក្នុងខាងដើម ។

ពាក្យថា **ព្រោះរួចផុតហើយ** គឺ ព្រោះផុតចាកកិលេសផ្សេងៗ បានហើយនោះឯង ។

ឈ្មោះថា **ធម៌ទាំងនោះ** បានដល់ ធម៌ មានសទ្ធាជាដើម និងដោយពិសេសបានដល់ ធម៌ មានសទ្ធា និងបញ្ញា , វីរិយៈ និងសមាធិ ឈ្មោះថា មានរសតែមួយដូចគ្នា គឺ មានកិច្ចស្មើគ្នា ។ ការនាំដែលសម្រេចទៅដោយសភាវៈនៃឥន្ទ្រិយទាំងឡាយមានរសតែមួយដូចគ្នាយ៉ាងនេះ ចាត់ជាការព្យាយាមរបស់ញាណ ព្រោះហេតុនោះ ទើបលោកពោលថា ភាពរីករាយជាកិច្ចនៃញាណ ទើបលោកហៅថាជាទីបំផុត ដូច្នេះ ។ ព្រោះបញ្ញិន្ទ្រិយមានភាពជាធំ ព្រោះមានការតាមចម្រើននូវឧបេក្ខា ៣ យ៉ាង ដែលបានភាពវិសេសហើយ អំពីបដិបទាវិសុទ្ធិ ៣ យ៉ាង យ៉ាងនេះ ភាពរីករាយទាំង ៤ យ៉ាង ទើបសម្រេចបាន ព្រោះហេតុនោះ ទើបគប្បីជ្រាបអាការទាំង ១០ ក្នុងឈានទោះឯង ដោយការទាក់ទងជាមួយកិច្ចរបស់ញាណ ព្រោះភាពព្រងើយដែលជាហេតុមក ( ដែលជាហេតុឲ្យសម្រេច ) ។

បទថា **គណនានុបុព្វតា** មានន័យថា ឈាននេះឈ្មោះថា **បឋម** ក៏ដោយលំដាប់នៃការរាប់ ឬត្រឹមតែលំដាប់នៃការរាប់ ។ ដោយពាក្យថា **ឈាន** ឈ្មោះថា **បឋម** ក៏ដោយលំដាប់នៃការរាប់នោះ លោកបញ្ជាក់ដល់លំដាប់នៃទេសនា ។

ដោយពាក្យថា ឈ្មោះថា **បឋម** ព្រោះអត្ថថា កើតឡើងជាគ្រាដំបូងនេះ លោកសំដៅដល់លំដាប់នៃការបដិបត្តិ ។ ព្រោះថា ពាក្យថា **កើតឡើង** មានន័យថា សម្រេច ។ ចំណែកពាក្យថា ឈ្មោះថា **បឋម** ព្រោះអត្ថថា គប្បីចូលជាគ្រា

ដំបូងដូច្នេះ នេះមិនកាន់យកក្នុងទីនេះ ព្រោះលោកបានបដិសេធទុកក្នុងអដ្ឋកថា ហើយថា វកលក្ខណៈដែលពិតប្រាកដមិនបាន ។

ក្នុងឈាន ២ យ៉ាង គឺ **អារម្មណូបនិជ្ឈាន ១ លក្ខណូបនិជ្ឈាន ១** លោកអាចារ្យបំណងសំដែងចំពោះឈានដែលបំណងក្នុងទីនេះ ទើបពោលថា ព្រោះចូលទៅសម្ងឹងអារម្មណ៍ គឺ ( ព្រោះជាអារម្មណូបនិជ្ឈាន ) ដូច្នេះ ។ សេចក្តីថា ព្រោះចូលទៅសម្ងឹងអារម្មណ៍របស់ខ្លួន ពោលគឺ បឋវីកសិណ ដូចបុរសប្រើភ្នែកសម្ងឹងមើលរូបដូច្នោះ ។ ពាក្យថា **ព្រោះដុតធម៌ដែលជាសត្រូវ** មានន័យថា ព្រោះដុតកម្តៅ គឺ លះបង់ធម៌ដែលជាសត្រូវ មាននីវរណធម៌ជាដើម ដោយអំណាចនៃវិក្ខម្ភនប្បហាន ។

ពាក្យថា **ដោយន័យថាអស់ជើង** គឺ ន័យថា ធ្វើឲ្យជាអារម្មណ៍ដោយអស់ជើងក្នុងចំណែកនៃបឋវី គឺក្នុងដួងបឋវីដែលធ្វើឡើង ឬមិនបានធ្វើឡើង ដែលបានកំណត់យកហើយ តាមន័យដែលបានពោលហើយពីខាងដើម ។ អធិប្បាយថា មិនធ្វើត្រឹមតែចំណែកមួយនៃដួងបឋវីនោះ ឲ្យជាអារម្មណ៍ ។ **និមិត្ត** ក៏ឈ្មោះថា បឋវីកសិណ ព្រោះមានបឋវីកសិណជាទីអាស្រ័យ ដូចជាពាក្យថា “ គ្រែទាំងឡាយធ្វើការស្រែកហ៊ោរ ” ដូច្នេះ ដូច្នោះអ្នកដែលនៅលើគ្រែប៉ុណ្ណោះ ស្រែកហ៊ោរ ទើប បានវោហារថា គ្រែស្រែកហ៊ោរ ។ **ឈាន** ក៏ឈ្មោះថា បឋវីកសិណ ព្រោះត្រាច់ទៅព្រមជាមួយនិមិត្ត ដែលឈ្មោះថា បឋវីកសិណនោះ ដូចមានពាក្យថា “ លំពែង ទាំងឡាយរមែងត្រាច់ទៅ ” ដូច្នេះ “ សេចក្តីពិតអ្នកកាន់លំពែងត្រាច់ទៅ លំពែងដែលត្រាច់ទៅព្រមជាមួយអ្នកកាន់ ទើបបានវោហារថា លំពែងត្រាច់ទៅ ។

# វិធីឱ្យសម្រេចការតាំងនៅចានយ្ធរ

នាយខ្មាន់ធ្នូ ឈ្មោះថា អ្នកបាញ់រោមទ្រាយ ព្រោះអត្ថថា ប្រើកូនសរបាញ់រោមទ្រាយដែលតាំងនៅត្រង់ក្តារគោល ។ ក្នុងទីនេះលោកបំណងយកនាយខ្មាន់ធ្នូដែលបាញ់រោមទ្រាយបំបែកជាច្រើនចំណែកថា អ្នកបាញ់រោមទ្រាយ ។ បានដល់គប្បីដូចជានាយខ្មាន់ធ្នូអ្នកបាញ់រោមទ្រាយនោះ ។ ពាក្យថា **ចុងភៅ** បានដល់ អ្នកធ្វើអាហារ ។ ដើម្បីបើកផ្លូវ អត្ថន័យ ដែលបានពោលទុកដោយសង្ខេបថា គប្បីកំណត់កាន់យកអាការទាំងឡាយថា ដូច្នេះទើបលោកពោលថា **យថា ហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សុកុសលោ** ប្រែថា ឆ្លៀវឆ្លាតល្អ ។ បទថា **ធនុគ្គហោ** ប្រែថា នាយខ្មាន់ធ្នូ ។ ពាក្យថា **ការងារ** បានដល់ ការងារដែលគួរប្រកប ។ ពាក្យថា **នៃជើងដែលជាន់ផែនដី** គឺ នៃជើងដែលប្រព្រឹត្តទៅទាក់ទងដោយការជាន់ផែនដីក្នុងវេលាដែលបាញ់ ។ ពាក្យថា **អាការ** បានដល់ អាការដែលចាប់ដងធ្នូ ខ្សែធ្នូ និង កូនសរ ។ ពាក្យថា **គប្បីកំណត់** គឺ ចាំទុកឲ្យច្បាស់ ។ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **ភោជនសប្បាយាទយោ** មានភោជនដែលជាទីសប្បាយជាដើម គប្បីឃើញថា សង្គ្រោះយកអាការទាំងឡាយដែលមិនបានពោលដល់ផង ។ ដោយពាក្យថា អាការទាំងឡាយ មានភោជនដែលជាទីសប្បាយជាដើមនោះ គឺ លោកពោលដល់ការកំណត់កាន់យក សូម្បីអាការទាំងឡាយ មានឧតុនិមិត្តនៃការវនាជាដើម ។

ពាក្យថា **កាលសមាធិនោះ** ( វិនាសទៅ ) គឺ កាលសមាធិនោះនៅទន់ខ្សោយ ( វិនាសទៅ ) ។

ពាក្យថា **ចៅហ្វាយ** បានដល់ បុគ្គលដែលជាម្ចាស់ បានដល់ អ្នកផ្គត់ផ្គង់អាហារដោយថ្លៃឈ្នួលជាដើម ។ ពាក្យថា **ប្រណិបត្តិ** បានដល់ ឲ្យបរិភោគ ។ ប្រកបសេចក្តីថា កំណត់អាហារដែលចៅហ្វាយនោះចូលចិត្តបរិភោគបានហើយ ក៏បង្អោនយកទៅជូនចៅហ្វាយនោះ ។ ឈ្មោះថា **អយម្បិ** បានដល់ ព្រះយោគី ។ ពាក្យថា **អាការទាំងឡាយ មានភោជនជាដើម ក្នុងខណៈដែលសម្រេច** បានដល់ អាការសម្រេចដោយភោជន ដែលញ៉ាំងកិច្ចឲ្យសម្រេច ក្នុងខណៈនៃការសម្រេចឈានក្នុងគ្រាមុន ។ ពាក្យថា **កាន់យក** បានដល់ កំណត់កាន់យក សម្គាល់ទុក ។ ឈ្មោះថា រមែងជាអ្នកបានអប្បនារឿយៗ ក៏ក្នុងកាលសមាធិវិនាសទៅតែមួយគ្រា ។

ចុងភៅ ឈ្មោះថា **ជាបណ្ឌិត** ក៏ព្រោះការសន្សំវិជ្ជាការធ្វើម្ហូប ។ ឈ្មោះថា **ស្ទាត់ជំនាញ** ក៏ព្រោះមានចំណេះដឹងស្ទាត់ជំនាញក្នុងវិជ្ជាធ្វើម្ហូបនោះ ។

ឈ្មោះថា **ឈ្លាសវៃ** ក៏ព្រោះប្រកបដោយភាពច្លាត ដែលជាហេតុឧប្បត្តិនៃឋានៈ ។ ពាក្យថា ( ជាមួយម្ហូប ) **នានាប្រការ** គឺ ច្រើនប្រការ បានដល់ មានសភាពផ្សេងៗ មានន័យថា មានរសផ្សេងៗ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អម្ពិលគ្គេហិ** ម្ហូបដែលមានរសជូរជាដើម ។

បទថា **សូបេហិ** ប្រែថា ដោយម្ហូប ។ បទថា **អម្ពិលគ្គេហិ** បានដល់ មានគ្រឿងផ្សំជូរ ។ ឬដោយម្ហូបដែលលាយគ្នាដោយគ្រឿងផ្សំមានរស ៤ យ៉ាង មានរសជូរជាដើម ដែលមានរសជូរជាកំពូល ។ សូម្បីក្នុងម្ហូបដែលមានគ្រឿងផ្សំល្វីងជាដើម ក៏មានន័យដូចគ្នា ។ ពាក្យថា **ដែលមានគ្រឿងផ្សំភ្ញាវ** បានដល់ ដែលលាយដោយគ្រឿងផ្សំ ៣ យ៉ាង មានទំពាំងជាដើម ។ ពាក្យថា **និមិត្ត** បានដល់ អាការ គឺ អាការដែលបរិភោគដោយអំណាចការពេញចិត្ត ។ ពាក្យថា **រមែងរៀន**

**យក** គឺ កាន់យកឲ្យក្រៃលែងឡើងៗ ទៅ បានដល់ ចាំទុកជានិច្ច ។ ឈ្មោះថា **ឬថា លូកដៃជួសម្ហូបនេះ** គឺ ដើម្បីប្រយោជន៍ដល់ម្ហូបនេះ ។

បទថា **អភិហារាទំ** បានដល់ គ្រឿងបណ្ណាការដែលគេគប្បីនាំទៅផ្លូវខាងមុខ ឬបានដល់អភិហារៈ គឺ ការបូជា ។ ពាក្យថា (ភិក្ខុនោះ) **រមែងរៀនយកនិមិត្ត** គឺ រមែងកាន់យក បានដល់ កំណត់ទុកដោយល្អនូវនិមិត្តថា “ ចិត្តរបស់យើងដែលតាំងមាំស្មើបាន ក៏ដោយអាការយ៉ាងនេះ ” ដូច្នេះ ។

បទថា **សមាធិបរិបន្ថានំ** ប្រែថា ដែលជាអន្តរាយចំពោះសមាធិ ។ ពាក្យថា **ធម៌ទាំងឡាយ** បានដល់ នីវរណធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម ។

ពាក្យថា **ព្រោះជម្រះបានដោយល្អ** គឺ ព្រោះបានធ្វើឲ្យបរិសុទ្ធដោយល្អ មានន័យថា ព្រោះលះបង់បានដោយប្រពៃ ដោយអំណាចវិក្ខម្ភនប្បហាន ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងពាក្យថា **កាមាទីនវ បច្ចវេក្ខណាទីហិ** ដោយការពិចារណាទោសរបស់កាមជាដើម សង្គ្រោះយកអសុភមនសិការ ការពិចារណាអានិសង្សរបស់នេក្ខម្មៈជាដើម ។

ពិតណាស់ សូម្បីការសម្លឹងឃើញគុណនៃនេក្ខម្មៈ ទោសក្នុងកាមច្ឆន្ទៈ ដែលជាគ្រឿងរាំងនេក្ខម្មៈនោះ រមែងប្រាកដយ៉ាងពិសេស ដូច្នេះឯង ។

ពាក្យថា **ឋានៈដែលគ្រោតគ្រាតនៃកាយ** គឺ ការក្រវល់ក្រវាយនៃកាយ បានដល់ ភាពដែលកាយសោប់សេល់ ។ ដោយពាក្យថា ឋានៈដែលគ្រោតគ្រាតនៃកាយនោះ លោកមិនបានពោលដល់ការជម្រះព្យាបាទនីវរណៈ ដែលជាហេតុឲ្យសោប់សេល់នៃកាយ និងចិត្ត ។ ដោយ **អាទិ** ស័ព្ទ (ប្រែថា ជាដើម) ក្នុងពាក្យថា **អារព្ភធាតុមនសិការាទិ** ( ការធ្វើទុកក្នុងចិត្តដោយអារព្ភធាតុជាដើម ) គប្បី

ឃើញថា សង្គ្រោះយកធម៌ទាំងឡាយដែលជាហេតុនៃវីរិយសម្ពោជ្ឈង្គៈ និងអាលោ-កសញ្ញាជាដើម ។ ដោយ **អាទិ** ស័ព្ទ ក្នុងពាក្យថា **សមថនិមិត្តមនសិការាទិ** (ការមនសិការក្នុងសមថនិមិត្តជាដើម) គប្បីឃើញថា សង្គ្រោះយកធម៌ទាំងឡាយដែលជាទីតាំងនៃសមាធិសម្ពោជ្ឈង្គៈ ។ ពាក្យថា **ធម៌ទាំងឡាយដែលជាអន្តរាយចំពោះសមាធិ សូម្បីយ៉ាងដទៃ** លោកពោលសំដៅយកធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា និងធម៌ទាំងឡាយ ដែលមាន **មទ** (ស្រវឹង) **មានះ** (ប្រកាន់ខ្លួន) ជាដើម ។ ពាក្យថា **ទីអាស្រ័យ** បានដល់ កន្លែងស្នាក់នៅ ។ ពាក្យថា (ឧទ្យាន) **ដែលស្អាតល្អហើយ** គឺ ដែលស្អាតដោយល្អ ព្រោះមិនមានភាពជាស្ថានទីដែលគួររង្កៀស ។ ក្នុងរឿងនេះ សួរថា ព្រះយោគីរូបនេះ ពិចារណាទោសរបស់កាមស្រេចហើយនោះឯង ទើបបដិបត្តិសមថបដិបទា មិនមែនឬ ? នីវរណៈទាំងឡាយលោកក៏គ្របសង្កត់បានដោយឈានក្នុងឧបចារខណៈនោះឯង ។ កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបលោកកាន់យកការពិចារណាទោសរបស់កាមជាដើម ទៀតទៅវិញ ដូច្នេះ ?

ឆ្លើយថា សេចក្តីដែលពោលមកនេះ ក៏ពិតមែនហើយ តែដែលពោលនោះត្រឹមតែជាការលះបាន ព្រោះហេតុនោះ ដើម្បីជាប្រយោជន៍ដល់ការលះបង់ បានយ៉ាងល្អប្រពៃ សម្រាប់ការតាំងនៅបានយូរនៃឈាន ទើបកាន់យកការពិចារណាទោសរបស់កាមជាដើមទៀត ។

ពាក្យថា **ឧទ្ធច្ចមិទ្ធ** លោកពោលដល់ការធ្វើទុកក្នុងចិត្តថា ជាការកាន់យកកុក្កុច្ចៈ និងថីនៈផងដែរ ព្រោះការតាំងនៅក្នុងចិត្តប្បាទមួយជាមួយគ្នានឹងឧទ្ធច្ចៈ និងមិទ្ធៈនោះ ។ ពាក្យថា **ដែលស្តេចយាងទៅកាន់បរិវេណជាទីផ្ទូរផង់** គឺ ស្តេច

យានទៅកាន់ឧទ្យានដែលមានបរិវេណបរិសុទ្ធល្អ បានដល់ មានបរិវេណ គឺ ព្រំដែនដែលជម្រះហើយ ដោយប្រការទាំងពួង ។ បទថា **តហឹ រមេ** បានដល់ គប្បីត្រេកអរក្នុងឈាននោះ គឺ គប្បីជាអ្នកនៅក្នុងឈានរហូតអស់មួយថ្ងៃ ។

ពាក្យថា **ដើម្បីភាពសម្បូរនៃភាវនាចិត្ត** គឺ ដើម្បីភាពសម្បូណ៌នៃសមាធិ-ភាវនា ។ ប្រៀបដូចជាការកើតឡើងនៃនិមិត្ត រមែងមានបានដោយអំណាចនៃភាវនាយ៉ាងណា សូម្បីការពង្រីកនិមិត្តនេះ ក៏រមែងមានដោយអំណាចនៃភាវនានោះឯង ។ ព្រោះដូច្នោះ កាលព្រះយោគាវចរពង្រីកនិមិត្ត ត្រឹមតែ ១ អង្គុលីជាដើម សូម្បីឈានភាវនា ក៏រមែងដល់នូវភាពចម្រើន ភាពលូតលាស់ ភាពសម្បូណ៌ ដោយការចម្រើនរឿយ ៗ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដើម្បីភាពសម្បូណ៌នៃភាវនាចិត្ត ក៏គួរពង្រីកបដិភាគនិមិត្ត តាមដែលបានហើយដូច្នេះ ។

បទថា **តស្ស** បានដល់ នៃបដិភាគនិមិត្ត ។

( ចប់មហាដីកា )

# ការពង្រីកនិមិត្ត

( តទៅនេះ ) ជានយក្នុងការពង្រីកបដិភាគនិមិត្តនោះ ព្រះយោគីនោះមិនគប្បីពង្រីកនិមិត្តនោះ ដោយទំនងបែបពង្រីកបាត្រ ពង្រីកនំ ពង្រីកបាយ ពង្រីកខ្ទឹមនៃវល្លិ និងពង្រីកសំពត់ គប្បីទឹកកំណត់ទំហំនៃនិមិត្តដែលបានកំណត់ទុកយ៉ាងណានោះថា ចូរមានប្រមាណ ១ អង្គុលី , ២ អង្គុលី , ៣ អង្គុលី , ៤ អង្គុលី.... តាមលំដាប់ហើយ ទើបពង្រីកប៉ុនដែលកំណត់ទុក ប្រសិនបើមិនបានកំណត់( ដូចពោល ) មិនគួរពង្រីក ប្រៀបដូចអ្នកស្រែកំណត់ទីដែលនឹងត្រូវភ្ជួរ ដោយគន្លងនង្គ័ល ទើបភ្ជួរទៅខាងក្នុងដីដែលកំណត់ទុកដូច្នោះ ម្យ៉ាងទៀត ដូចភិក្ខុទាំងឡាយនឹងចងសីមា ត្រូវកំណត់និមិត្តទាំងឡាយមុនហើយ ទើបចងខាងក្រោយ ដូច្នោះតអំពីនោះ កាលនឹងពង្រីក ក៏គប្បីកំណត់ដោយទំហំ ១ហត្ថ១ចំអាម ប៉ុនបរិវេណខាងមុខ (នៃវិហារ) ប៉ុនដែនវិហារ និងប៉ុនភូមិនិគមជនបទ រាជាណាខេត្ត និងដែនសមុទ្រ ឬដោយទំហំប៉ុនចក្រវាឡ ឬសូម្បីក្រៃលែងជាងនោះ ក៏ពង្រីកទៅបាន ប្រៀបដូចកូនហង្ស តាំងអំពីកាលដែលស្លាបដុះទៅ ក៏លោតទៅទីជិតៗ លុះរឹងប៉ឹងគេក៏ហើរទៅជិតព្រះចន្ទ ព្រះអាទិត្យបានដោយលំដាប់ យ៉ាងណា ភិក្ខុក៏ ដូច្នោះដូចគ្នា កាលកំណត់ទំហំហើយ ពង្រីកនិមិត្តទៅ ដោយន័យដែលពោលហើយ ក៏រមែងពង្រីកទៅរហូតប៉ុនទំហំចក្រវាឡ ឬក្រៃលែងជាងនោះបាន ទីនេះនិមិត្តនោះ រមែងកើតដល់លោក ដូចស្បែកគោដែលត្រូវចិញ្ចាំដោយដឹង ដល់ទៅ ១០០ ផ្ទៃ ព្រោះតែទីទួល ទីទំនាប ជាទន្លេ ជាល្បាប់កក់ ជាភ្នំខ្ពស់ទាបនៃផែនដី ក្នុងទីដែលពង្រីកទៅ ៗ ។

ឯភិក្ខុអាទិកម្មិកៈ ដែលបានបឋមជ្ឈានដោយនិមិត្តនោះហើយ គប្បីជាអ្នកចូលឈានឲ្យច្រើន មិនគប្បីបច្ចវេក្ខណៈច្រើន ព្រោះកាលលោកបច្ចវេក្ខណៈច្រើនទៅ អង្គឈានទាំងឡាយនឹងប្រាកដជាគ្រោតគ្រាត នឹងមានកម្លាំងខ្សោយ ទីនេះ ព្រោះប្រាកដយ៉ាងនោះហើយ អង្គឈានទាំងឡាយនោះ ក៏នឹងមិនសម្រេច ជាបច្ច័យនៃការខ្វល់ខ្វាយជាបន្តទៅរបស់លោក លោកខ្វល់ខ្វាយនៅក្នុងឈានដែលមិនស្ទាត់ជំនាញ នឹងវិនាសអំពីបឋមជ្ឈាន នឹងមិនអាចសម្រេចទុតិយជ្ឈានបានទៀតផង ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចមេគោដែលរកស៊ីលើភ្នំ ជាសត្វល្ងង់ខ្លៅ មិនស្គាល់ខេត្ត (នឹងទៅបាន មិនបាន) មិនឈ្លាសក្នុងការត្រាច់ទៅលើភ្នំដែលរដិបរដុប វាមានសេចក្ដីរំពឹងថា ធ្វើម្ដេចវានឹងបានទៅក្នុងទិសដែលមិនធ្លាប់ទៅខ្លះ និងបានផឹកទឹកដែលមិនធ្លាប់បានផឹកខ្លះ ដូច្នេះហើយ វាក៏ចេញដើរទៅ មិនទាន់ជាន់ជើងមុខឲ្យបានស៊ប់ផង ក៏លើកជើងក្រោយឡើង ( វាក៏ភ្លាត់ជើង ) មិនបានទៅតាមទិសដែលមិនធ្លាប់ទៅផង មិនបានស៊ីស្មៅដែលមិនធ្លាប់បានស៊ីផង មិនបានផឹកទឹក ដែលមិនធ្លាប់បានផឹកផង ទាំងមិនបានត្រឡប់មកកាន់ទីដែលវាឈររំពឹងថា ធ្វើម្ដេចវាបានទៅកាន់ទិសដែលមិនធ្លាប់ទៅ ។ល។ ដោយសួស្ដីផង នោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះមេគោនោះ ជាសត្វរកស៊ីលើភ្នំ តែល្ងង់ខ្លៅ មិនស្គាល់ខេត្ត មិនឈ្លាសក្នុងទីដែលនឹងត្រាច់ទៅលើភ្នំដែលរដិបរដុប យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុច្រើនរូបក្នុងធម្មវិន័យនេះក៏ដូច្នេះដូចគ្នា ជាបុគ្គលល្ងង់ខ្លៅ មិនស្គាល់ខេត្ត ( នៃភាវនា ) មិនឈ្លាសក្នុងទីដែលស្ងាត់ចាកកាមទាំងឡាយ ។ ល ។ ចូលដល់បឋមជ្ឈាន ភិក្ខុនោះមិនសេព មិនចម្រើន មិនធ្វើឲ្យច្រើននូវនិមិត្តនោះ និងមិនតាំងនិមិត្តនោះទុកឲ្យមាំល្អ ហើយមាន

សេចក្តីរំពឹងថា ពេលណាហ្ន៎ យើងនឹងគប្បីចូលដល់ទុតិយជ្ឈាន ។ ល ។ ព្រោះវិតក្កវិចារៈស្ងប់ទៅ ដូច្នេះ ភិក្ខុនោះក៏មិនអាចចូលដល់ទុតិយជ្ឈាន ។ល។ ព្រោះវិតក្កវិចារៈស្ងប់ទៅបាន ( កាលចូលទុតិយជ្ឈានមិនបាន ) ភិក្ខុនោះបែរទៅរំពឹងថា ពេលណាហ្ន៎ យើងនឹងគប្បីស្ងាត់ចាកកាមទាំងឡាយហើយ ។ល។ ចូលកាន់បឋមជ្ឈានដូច្នេះ ភិក្ខុនោះក៏មិនអាចស្ងាត់ចាកកាមទាំងឡាយ ។ល។ ចូលកាន់បឋមជ្ឈានបានឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា ភ្លាត់ទាំងពីរខាង វិនាសទាំងពីរផ្លូវ ប្រៀបដូចគោនោះ ដែលរកស៊ីលើភ្នំ ហើយល្ងង់ខ្លៅមិនស្គាល់ខេត្ត មិនឈ្លាសក្នុងការត្រាច់ទៅលើភ្នំដែលរដិបរដុបដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរនោះគប្បីជាអ្នកបំពេញវសីដោយអាការ ៥ ក្នុងបឋមជ្ឈាននោះឯងជាមុន ។

## មហាដីកា

## ពណ៌នា អំពីការពង្រីកនិមិត្ត

បទថា **តត្រ** ជាសត្តមីវិភត្តិ ក្នុងអត្ថនៃឆដ្ឋីវិភត្តិ មានន័យស្មើនឹង **តស្ស** ។ ពាក្យថា **កុំពង្រីក** មានន័យថា ប្រៀបដូចនាយស្ទូនឆ្នាំង កាលនឹងប្រើដីធ្វើបាត្រមែងមិនកំណត់ជាមុនឡើយ ហើយពង្រីកបាត្រយ៉ាងណា ព្រះយោគីកុំពង្រីក ដោយវិធីពង្រីកបាត្រ គឺ ដោយបែបផែននៃការពង្រីកបាត្រដូច្នោះ សម្រាប់បុគ្គលធ្វើនំក៏មានការពង្រីកនំ ។ ការដាក់កត្តបន្ថែមទៅលើកត្ត ឈ្មោះថា ការពង្រីកកត្ត ។ ការហាលសំពត់សើមជាដើម ឈ្មោះថា ការពង្រីកសំពត់ ។ **យោគ** សព្ទ ( ប្រែថាវិធី ) គប្បីប្រកបទុកជាបទមួយ ។ ឈ្មោះថា មិនទាន់បានកំណត់ទុក ក៏មិនគួរពង្រីក ព្រោះនៅក្នុងនិមិត្តដែលមានការកំណត់ទុកប៉ុណ្ណោះ ទើបមានការប្រព្រឹត្តទៅ

នៃភាវនា ។ ពិតយ៉ាងនោះ លោកបានពោលទុកហើយថា **បបរីកសិណាត្រូវមានទីបំផុតប៉ុណ្ណោះ មិនមែនមិនមានទីបំផុត** ដូច្នេះ ។

ពាក្យថា **កូនហង្ស** បានដល់ កូនហង្សដែលហើរបានលឿន ។

ឈ្មោះថា **ឧក្កូលំ** បានដល់ ទីទួល ។ ឈ្មោះថា **វិក្កូលំ** បានដល់ ទីទំនាប ។ កក់ល្បាប់ដែលខ្សែទឹកស្ទឹងច្រោះ ឈ្មោះថា **នទីវិទុគ្គំ** ។ ចំណែកថ្មភ្នំដែលតាំងនៅដោយអាការដែលខ្ពស់ទាប ឈ្មោះថា ទីរដិបរដុបនៃភ្នំ ។

ឈ្មោះថា រមែងប្រាកដជាធម្មជាតិដែលគ្រោតគ្រាត ព្រោះការប្រាកដច្បាស់អាស្រ័យការពិចារណាច្រើន ។

ឈ្មោះថា រមែងប្រាកដជាធម្មជាតិដែលខ្សោយកម្លាំង ព្រោះមិនធ្វើឲ្យស្ទាត់ជំនាញ ឲ្យមានកម្លាំង ។ ពាក្យថា **ដល់ភាពខ្វាយខ្វល់ឲ្យក្រៃលែងឡើងទៅ** គឺ ខ្វាយខ្វល់ក្នុងភាវនាខាងលើ មានន័យថា (ប្រាថ្នា) នឹងសម្រេចទុតិយជ្ឈាន ។

បទថា **បញ្ចតេយ្យា** គឺ ត្រាច់ទៅច្រើនលើភ្នំ ។ ពាក្យថា **មិនស្គាល់ខេត្ត** បានដល់ មិនស្គាល់ទីដែលត្រាច់ទៅរកស៊ី ។ ភិក្ខុឈ្មោះថា **ល្ងង់** ព្រោះការមិនដឹងច្បាស់នូវវិធីជម្រះអន្តរាយនៃសមាធិ ។ ឈ្មោះថា **ខ្លៅ** ព្រោះមិនមានភាពឈ្លាសវៃក្នុងការធ្វើឈានឲ្យដល់ភាពស្ទាត់ជំនាញ ។ ឈ្មោះថា **មិនស្គាល់ខេត្ត** ព្រោះមិនទាន់ស្គាល់បទដ្ឋាននៃឈានជាន់លើ ។ ឈ្មោះថា **មិនឈ្លាស** ព្រោះមិនឆ្លាតក្នុងការចូលឈាន សូម្បីដោយប្រការទាំងពួង ។

ម្យ៉ាងទៀត គប្បីប្រកបពាក្យនិយាយថា ឈ្មោះថា **ល្ងង់** ព្រោះមិនមានការសេពនូវនិមិត្តនៃសមាធិ ។ ឈ្មោះថា **ខ្លៅ** ព្រោះគ្មានការចម្រើន ។ ឈ្មោះថា **មិនស្គាល់ខេត្ត** ព្រោះមិនមានការធ្វើឲ្យច្រើន ។ ឈ្មោះថា **មិនឈ្លាស** ព្រោះមិន

មានភាពតាំងមាំដោយប្រពៃនោះឯង ។ បទថា **ឧភតោ ភដ្ឋោ** ប្រែថា ឃ្លាត ហើយចាកឈានទាំង ២ ។

ពិតណាស់ ភិក្ខុអង្គនោះ សូម្បីថា មានភាពឧស្សាហ៍ ក៏ឈ្មោះថា វិនាស ដោយជុំវិញហើយចាកឈានទាំង ២ ព្រោះការវិនាសទៅ ( នៃឈានទី ១ ) និង ព្រោះគ្មានសមត្ថភាពក្នុងការចូលឈានទី ២ ហេតុ ព្រោះនៅមិនទាន់ស្ទាត់ជំនាញ ព្រោះមិនទាន់តាំងមាំល្អ ។

ពាក្យថា **អ្នកសន្សំវសី** គឺ អ្នកមានភាពជំនាញដែលបានសេពហើយ ។

( ចប់មហាដីកា )

# វសី ៥

ក្នុងអាការទាំងនោះ វសីមាន ៥ គឺ :

- **អាវជ្ជនវសី** ជំនាញក្នុងការនឹករាវរក ។
- **សមាបជ្ជនវសី** ជំនាញក្នុងការចូលឈាន ។
- **អធិដ្ឋានវសី** ជំនាញក្នុងការអធិដ្ឋាន ។
- **វុដ្ឋានវសី** ជំនាញក្នុងការចេញចាកឈាន ។
- **បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណា (អង្គឈានសាឡើងវិញ) ។

ព្រះយោគាវចរ នឹករាវរកបឋមជ្ឈានបានក្នុងស្ថានទីដែលត្រូវការ ក្នុងកាលដែលត្រូវការ ក្នុងរយៈ (ជវនវារៈ) ដែលត្រូវការ ភាពយឺតយូរនៃការនឹករាវរក មិនមាន ព្រោះដូច្នោះ អាការដូច្នេះ ទើបឈ្មោះថា **អាវជ្ជនវសី** ( ជំនាញក្នុងការនឹករាវរក ) ។ ព្រះយោគាវចរ ចូលបឋមជ្ឈានបានក្នុងស្ថានទីដែលត្រូវការ ។ល។ ការយឺតយូរនៃការចូលមិនមាន ព្រោះដូច្នោះ អាការដូចនោះ ទើបឈ្មោះថា **សមាបជ្ជនវសី** ( ជំនាញក្នុងការចូលឈាន ) ។ សូម្បីវសីដ៏សេស ក៏គប្បីពង្រីកសេចក្តីតាមន័យដូចគ្នានេះ ។

(តទៅនេះ) ជាពាក្យចង្អុលបង្ហាញក្នុងវសី ៥ នោះ កាលណាព្រះយោគាវចរអាចបញ្ជូនចិត្តទៅក្នុងអង្គឈាន ៥ មិនឲ្យមានរវាង (វិសភាគារម្មណ៍កើតឡើង) បានយ៉ាងនេះគឺ កាលលោកចេញអំពីបឋមជ្ឈានហើយ នឹកសញ្ជឹងយកវិតក្កជាវារៈដំបូង ជវនដែលមានវិតក្កជាអារម្មណ៍នោះឯង ស្ទុះទៅ ៤ ឬ ៥ វារៈ ក្នុងលំដាប់នៃអាវជ្ជនៈដែលកាត់ភវង្គ កើតឡើង តអំពីនោះភវង្គកើត ២ វារៈ តអំពីនោះអាវជ្ជនៈដែលមានវិចារៈជាអារម្មណ៍ (កាត់ភវង្គកើតឡើង) ទៀត ហើយជវន ( ក៏ស្ទុះទៅ)

ដោយន័យដែលបានពោលហើយនោះឯង កាលនោះអាវជ្ជនវសី ក៏ជាការសម្រេច ដល់លោក ឯវសីនេះដែលដល់ភាពជាកំពូល បានមាននៅក្នុងយមកបា្បដិហារ្យ របស់ព្រះមានព្រះភាគជាម្ចាស់ របស់លោកអ្នកដទៃ (មានព្រះធម្មសេនាបតីជាដើម) ក្នុងកាលសំដែងបាដិហារ្យក្លាមៗ ដូច្នោះឈ្មោះថា **អាវជ្ជនវសី** អាវជ្ជនវសីរហ័ស ជាងនេះមិនមាន ។ ចំណែកអ្នកអាចការចូលឈានបានរហ័ស ដូចជាការចូល កាល ទូន្មាន **នន្ទោបនន្ទនាគរាជ** នៃព្រះមហាមោគល្លាន ឈ្មោះថា **សមាបជ្ជនវសី** ។ ភាពជាអ្នកអាចទប់ឈានទុក បានមួយខណៈ មួយផ្ទាត់ក្រចកក្តី មួយដួរផ្ទាត់ម្រាម ដៃយ៉ាងច្រើនដល់ ១០ ដងក្តី ឈ្មោះថា **អធិដ្ឋានវសី** ។ ភាពជាអ្នកអាចចេញ ( ចាកឈាន ) បានរហ័សដូចគ្នានោះ ឈ្មោះថា **វុដ្ឋានវសី** ។

ដើម្បីនឹងសម្តែង អធិដ្ឋានវសី និងវុដ្ឋានវសី ទាំង ២ យ៉ាងនោះ នឹងលើក រឿងព្រះពុទ្ធរក្ខិតត្ថេរ ( មកសាធកៈ ) ក៏គួរ ។

មានរឿងពោលថា លោកអង្គនោះតាំងអំពីឧបសម្បទាមក បាន ៨ វស្សា ថ្ងៃ មួយអង្គុយនៅកណ្តាលភិក្ខុដែលមានឫទ្ធិប្រមាណ ៣០.០០០ អង្គ ដែលមកឧបដ្ឋាក ជំងឺព្រះមហារោហណគុត្តត្ថេរ នៅថេរម្ពត្ថលវិហារ ឃើញស្តេចគ្រុឌបោះពួយចុះមក អំពីអាកាសសំដៅនឹងចាប់ស្តេចនាគ ( ក្លែងខ្លួនជាឧបដ្ឋាក ) ដែលកំពុងប្រគេន បបរដល់ព្រះថេរៈ លោកក៏និម្មិតភ្នំឡើង ហើយយកដៃចាប់ក្តោបស្តេចនាគចូលទៅ ទុកក្នុងរូង ស្តេចគ្រុឌប្រទះភ្នំក៏គេចទៅវិញ ទើបព្រះថេរៈពោលឡើងថា " អាវុសោ ទាំងឡាយ បើពុទ្ធរក្ខិតមិននៅទីនេះសោត ពួកយើងគ្រប់គ្នានឹងជាអ្នកត្រូវគេតិះដៀល ហើយ " ដូច្នេះ ។

ចំណែក **បច្ចវេក្ខណាវសី** បានពោលហើយតាមអាវជ្ជនវសីនោះឯង ។

ព្រោះថា ជវនទាំងឡាយដែលនៅបន្ទាប់ពីអាវជ្ជនៈក្នុងអាវជ្ជនវសីនោះ គឺ ជវនក្នុងបច្ចវេក្ខណៈនោះឯង ។

# មហាដីកា

## អធិប្បាយ វសី៥

ព្រោះមានសេចក្តីបំណងថា ការសំដែងអធិប្បាយកិរិយា រមែងមានបានដោយការៈដែលសំដែងអធិប្បាយធាតុថា **វសនំ វសី** ដូច្នេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ **វសិយោ** ” ដូច្នេះ , សេចក្តីថា ការប្រព្រឹត្តទៅតាមការពេញចិត្ត ( ទើបប្រែថា **ភាពជំនាញ** ) ភាពជំនាញក្នុងការនឹក ឬភាពជំនាញទាក់ទងដោយការនឹក ឈ្មោះថា **អាវជ្ជនវសី** ។ ក្នុងគ្រប់ៗ ទីកន្លែង ដែលមានសេចក្តីត្រូវការនឹងនឹកដល់ឈាន ឈ្មោះថា **យត្ថិច្ឆកំ** ។ ក្នុងគ្រប់ៗ វេលាដែលមានសេចក្តីត្រូវការនឹងនឹកដល់ ឬក្នុងគ្រប់ៗ អង្គឈាន ដែលមានសេចក្តីត្រូវការនឹងនឹកដល់ ឈ្មោះថា **យទិច្ឆកំ** ។ គ្រប់ៗ រយៈដែលត្រូវការនឹកដល់ ឈ្មោះថា **យាវទិច្ឆកំ** ។ **ទ** អក្សរ ជាតួអក្សរធ្វើការភ្ជាប់បទ ។ ពាក្យថា **យាវ** នេះ លោកពោលសំដៅយកការធ្វើឲ្យប្រព្រឹត្តទៅបានយ៉ាងនោះ ហាក់បីដូចជាមិនដាច់ខ្សែនៃជវនវារៈទាំងឡាយដ៏ច្រើន នឹងពោលសំដៅយកជវនវារៈតែមួយ ក៏ទេ ។ ព្រោះថា ព្រះយោគីនោះ ជាអ្នកបានកំណត់ខណៈចិត្តទុកហើយ ដូច្នេះ ។ ពាក្យថា **មិនមានភាពយឺតយូរក្នុងការនឹក** មានន័យថា កាលព្រះយោគីនឹកដល់អង្គឈាន អង្គណាមួយ ក្នុងកន្លែងណាមួយ ក្នុងវេលាណាមួយ តាមន័យដែលបានពោលហើយ ក៏មិនមានភាពយឺតយូរ គឺ ភាពយឺតយ៉ាវ ឬភាពរហ័សក្នុងការនឹក គឺ ក្នុងការប្រព្រឹត្ត

ទៅនៃអាវជ្ជនៈអស់កាលតាមដែលប្រាថ្នា ។ មានន័យថា **អាវជ្ជនវសី** ឈ្មោះថា បានសម្រេចហើយ តាមប្រការដូចពោលមកនេះ ។

ពាក្យថា **វសីដ៏សេស** បានដល់ អធិដ្ឋានវសី វុដ្ឋានវសី និងបច្ចវេក្ខណវសី។

ព្រោះភាពដែលឈានមានការរួមគ្នានៃអង្គ ព្រះយោគី ដែលត្រូវការនឹងធ្វើអាវជ្ជនវសីក្នុងឈានឲ្យសម្រេច ទើបត្រូវនឹកដល់អង្គឈានទៅតាមលំដាប់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា នឹកដល់វិតក្កមុនដូច្នេះ ។ អាវជ្ជនៈនោះឯងដែលត្រូវការក្នុងអាវជ្ជនវសីនេះ ព្រោះលោកបំណងយក ភាពជំនាញក្នុងការនឹកក៏ពិត សូម្បីយ៉ាងនោះ កាលអាវជ្ជនៈកើតឡើងហើយ ជវនទាំងឡាយ ក៏មានហើយ ជវនទាំងនោះឯង មានអង្គឈានតាមដែលនឹកដល់ជាអារម្មណ៍ រមែងមានបន្តិចបន្តួចប៉ុណ្ណោះ គឺ មិនបរិបូរណ៍ដល់ព្រះយោគីដែលបង្អោនចិត្តទៅដោយការៈដែលមានអាវជ្ជនៈជាខាងដើម ព្រោះហេតុនោះ ទើបលោកពោលថា ជវន ៤ ឬ ៥ ខណៈ ដែលមានវិតក្កជាអារម្មណ៍ រមែងស្ទុះទៅដូច្នេះ ។ គប្បីឃើញថា សម្រាប់ព្រះយោគីដែលមានឥន្ទ្រិយចាស់ក្លា ក៏មានជវន ៤ ខណៈ ចំពោះព្រះយោគាវចរដែលមានឥន្ទ្រីយ៍ទន់ខ្ចី ក៏មានជវន ៥ ខណៈ ។ ពាក្យថា **មិនដាច់ខ្សែ** គឺ មិនត្រូវចិត្តដែលជាវិសភាគៈកើតខណ្ឌ ។ ពាក្យថា **ក៏វសីដល់កំពូលនេះ** គឺ អាវជ្ជនវសីដែលប្រព្រឹត្តទៅក្នុងលំដាប់ភវង្គ ២ ខណៈ មានជវនចិត្ត ៤ ខណៈ តាមដែលពោលហើយ ។ ឈ្មោះថា **ឬនៃបុគ្គលដទៃ** គឺ នៃបុគ្គលទាំងឡាយ មានព្រះធម្មសេនាបតីជាដើម ។ ពាក្យថា **ក្នុងកាលដែលជាដូច្នេះ** គឺ ក្នុងកាលដែលតាំងឡើង តាំងឡើងព្រម ធ្វើអាវជ្ជនវសីឲ្យកើតឡើង បានធាប់រហ័សក្រៃលែង ។ ក៏អាវជ្ជនវសីក្រៅពីនេះនោះ មានរយៈពេលបន្តិចបន្តួច មិនមានការបន្តគ្នាបានយូរ

ដូចជាក្នុងកាលដែលព្រះសាស្តាទ្រង់សំដែងយមកប្បាដិហារ្យទេ ។

ពិតណាស់ លោកពោលថា យមកប្បាដិហារ្យនោះមិនសាធារណៈដល់សាវ័កទាំងឡាយ ។ ការដល់បានដោយប្រពៃ គឺ ការធ្វើឈានព្រមទាំងសម្បយុត្តធម៌ឲ្យដំណើរទៅ ដែលដូចគ្នានឹងការសម្រេច ឈ្មោះថា **សមាបជ្ជន** (ការចូលឈាន) បានដល់ ភាពជាអ្នកព្រមព្រៀងដោយឈាន ។

ក្នុងពាក្យថា **រហ័ស** នេះ មានសេចក្តីថា កាលភវង្គ ២ ខណៈ កើតឡើងហើយក្នុងលំដាប់នៃតម្រូវការនឹងចូល ការចូលបានក្នុងលំដាប់នៃអាវជ្ជនៈដែលកាត់ផ្តាច់ភវង្គកើតឡើង ឈ្មោះថា ការចូលបានរហ័ស ។ ក៏ **សមាបជ្ជនវសី** ដែលដល់កំពូលនេះ រមែងបានក្នុងគ្រាដែលព្រះសាស្តាទ្រង់សំដែងធម៌ ។ សំដៅយកពាក្យដែលត្រាស់ទុកថា “ ម្នាលអគ្គិវេស្សនៈ ក្នុងវេលាដែលចប់ពាក្យសន្ទនានោះឯង តថាគតរមែងនៅស្ងៀម រមែងឈប់ រមែងតម្កល់ចិត្តទុក ក្នុងខាងក្នុងសមាធិនិមិត្តដែលមាននៅនោះ ៗ ឯង រមែងធ្វើឲ្យជាធម៌ឯកផុតឡើង មានន័យថា ជាហេតុឲ្យតថាគតស្ថិតនៅបានអស់កប្បជានិច្ច ” ។ ពិតណាស់ **សមាបជ្ជនវសី** ដែលឆាប់រហ័សក្រៃលែងជាងនេះមិនមាន ។ ក្នុងរឿងនេះ គប្បីសំដែងការចូលសមាបត្តិរបស់ព្រះសារីបុត្តដែលទើបកោរសក់ថ្មីៗ នៅត្រង់កបោតកន្ទរវិហារ គឺក្នុងខាងខ្មៅ ក្នុងកាលដែលត្រូវយក្សវាយចំសីសៈ (យ៉ាងខ្លាំង ដែលអាចធ្វើឲ្យកំពូលភ្នំធំៗបាក់ស្រុតចុះបាន ) ។ ពិតណាស់ លោកអាចារ្យពោលថា “ ក្នុងវេលានោះ គឺ ក្នុងសម័យដែលយក្សនោះវាយព្រះថេរៈបានចូលសមាបត្តិហើយ ” ដូច្នេះ ។

ចំណែកក្នុងព្រះបាលីពោលទុកថា “ លោកអង្គុយចូលសមាធិ យ៉ាងណាមួយ ” ។ ចំណែកព្រះថេរៈទាំងនោះពោលថា យក្សនោះប្រហារលោកក្នុងពេល

ដែលលោកចេញចាកអំពីសមាបត្តិ " ដូច្នេះ ។

ពាក្យថា **មួយផ្ទាត់ម្រាមដៃ** គឺ អស់ខណៈមួយជួរផ្ទាត់ម្រាមដៃមួយដង ។ ពាក្យថា (ជំនាញ) **អាចនឹងឃាត់ទុក** គឺ ជំនាញទប់ឈានទុកមួយជួរខណៈ តាមដែលពោលហើយ មិនព្រមឲ្យប្រព្រឹត្តទៅដោយរហ័ស ដូចគ្រឹះស្ថានដែលទប់ស្ពាន ក្នុងទីដែលមានក្រសែទឹកហូរយ៉ាងខ្លាំងក្នុងស្ទឹងបាន ដូច្នោះ ។ ការគ្រប់សង្កត់ហើយ ឈប់នៅ ហៅថា **អធិដ្ឋាន** ម្យ៉ាងទៀត ឈ្មោះថា **អធិដ្ឋាន** ព្រោះអត្ថថា ដូចជានៅស្ងៀម ។ ភាពជំនាញក្នុងអធិដ្ឋាននោះ ឈ្មោះថា **អធិដ្ឋានវសី** ។ ពាក្យថា (ជំនាញ) ដែលអាចចេញបានរហ័សយ៉ាងនោះៗ ឯង បានដល់ ភាពជាអ្នកព្រមព្រៀងដោយឈាន ( ចូលឈាន ) ហើយអាចនឹងចេញអំពីឈានបានរហ័ស គឺ ខណៈ ១ ផ្ទាត់ម្រាមដៃ ឬ ១០ ផ្ទាត់ម្រាមដៃ ។

ក៏ក្នុងទីនេះ ការកើតឡើងនៃភវង្គចិត្តនោះឯងឈ្មោះថា ការចេញចាកឈាន។

ម្យ៉ាងវិញទៀត ក្នុងអធិការនេះ ជំនាញដែលនឹងឃាត់ឈានដោយអំណាចការបរិកម្មក្នុងខាងដើមថា " យើងនឹងញ៉ាំងឈានទុកអស់រយៈត្រឹមប៉ុណ្ណេះ " ដូច្នេះ ឈ្មោះថា **អធិដ្ឋានវសី** យ៉ាងណា ជំនាញក្នុងការចេញដោយអំណាចការបរិកម្មក្នុងខាងដើមថា " យើងនឹងជាអ្នកព្រមព្រៀងដោយឈានហើយចេញចាកឈាន អស់ជួរខណៈត្រឹមប៉ុណ្ណេះ " ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា **វុដ្ឋានវសី** ដូច្នោះ , សមាបត្តិ ហៅថា " **វុដ្ឋានកុសលតា** " ភាពជាអ្នកឈ្លាសក្នុងការចេញ ដូច្នេះ ។

ពាក្យថា **ដើម្បីសំដែងវសីទាំង ២ នោះ** គឺ ដើម្បីសំដែងអធិដ្ឋានវសី និងវុដ្ឋានវសី ។ ពាក្យថា **ក្នុងក្អំនោះ** គឺ ក្នុងក្អំដែលនិម្មិតឡើងនោះ បានដល់ ក្នុងរូបក្អំនោះ ។ អភិញ្ញាចិត្តជួងមួយប៉ុណ្ណោះ នោះជាហេតុឲ្យនិម្មិតក្អំបាន ក៏ពិតដូច្នោះ ក៏

គប្បីឃើញថា ក្នុងទីនេះលោកសំដែងដល់ការឃាត់ទុកបានធាប់របស់នូវឈានដែលជាបាទនៃអភិញ្ញា ( និងការចេញចាកឈានដែលជាបាទ ) ។ ឈ្មោះថា ពួកយើងនឹងជាអ្នកដែលត្រូវគេតិះដៀលថា " អ្នកមានឫទ្ធិដល់ទៅប៉ុណ្ណោះ ក៏គង់មិនអាចរក្សាឧបដ្ឋាកម្នាក់ឲ្យរួចអំពីគ្រោះបាន " ដូច្នេះ ។ ពាក្យថា **ដែលមានទៅក្នុងលំដាប់នៃអាវជ្ជនៈ** មានន័យថា ជវនពួកណាប្រព្រឹត្តទៅបន្ទាប់ពីអាវជ្ជនៈដែលនឹកពារកអង្គឈាន មានវិតក្កៈជាដើម តាមលំដាប់ ដោយភាពជាអាវជ្ជនវសី ជវនទាំងនោះឈ្មោះថា ជាការពិចារណាអង្គឈានទាំងនោះ ។ គប្បីជ្រាបថា ការសម្រេចនៃអាវជ្ជនវសី មានបានដោយបរិយាយណា ការសម្រេចបច្ចវេក្ខណវសី ក៏មានបានដោយបរិយាយនោះដែរ ។

មហាដីកា

( បឋមជ្ឈាន ចប់ដោយបរិបូរណ៍ )

# ទុតិយជ្ឈាន

*ក៏ព្រះយោគាវចរដែលបំពេញវសី ក្នុងវសី **៥** នេះ ចេញចាកបឋមជ្ឈាន ដែលស្ទាត់ជំនាញហើយ ឃើញទោសក្នុងបឋមជ្ឈាននោះថា សមាបត្តិនេះមានសឹកសត្រូវ គឺ នីវរណៈនៅជិត និងថា សមាបត្តិនេះនៅមានអង្គខ្សោយកម្លាំង ព្រោះវិតក្កៈ និងវិចារៈជាធម៌គ្រោតគ្រាត ដូច្នេះហើយ គប្បីធ្វើទុកក្នុងចិត្តដើម្បី ទុតិយ-ជ្ឈានថា ជាធម៌ល្អិត ដកសេចក្តីពេញចិត្តនៅក្នុងបឋមជ្ឈាន ធ្វើយោគៈ គឺ សេចក្តីព្យាយាមដើម្បីសម្រេចនូវទុតិយជ្ឈាន... ។*

*កាលព្រះយោគាវចរនោះ ចេញចាកបឋមជ្ឈានហើយ មានសតិសម្បជញ្ញៈ ពិចារណាអង្គឈានទាំងឡាយ, **វិតក្កវិចារៈ** ក៏ប្រាកដជាអង្គគ្រោតគ្រាត **បីតិ សុខ** និង **ចិត្តេកគ្គតា** ប្រាកដជាអង្គល្អិតក្នុងកាលណា ក្នុងកាលនោះ កាលលោកធ្វើទុកក្នុងចិត្តរឿយៗ ហើយ នូវនិមិត្តនោះៗ ឯង ដោយបរិកម្មថា **បឋវី បឋវី** ដូច្នេះ ដើម្បីលះអង្គគ្រោតគ្រាត និងដើម្បីបានអង្គល្អិត ខណៈដែលប្រាកដថា ទុតិយជ្ឈាននឹងកើតឡើង មនោទ្វារាវជ្ជនចិត្ត រមែងកាត់ភវង្គ ធ្វើបឋវីកសិណនោះឯង ជាអារម្មណ៍កើតឡើង តអំពីនោះជវនៈ ៤ ឬ ៥ ដួង រមែងស្ទុះទៅក្នុងអារម្មណ៍នោះឯង ដែលដួងមួយក្នុងទីបំផុត ជារូបាវចរចិត្ត គឺ ទុតិយជ្ឈាន ដួងដ៏សេសជាកាមាវចរចិត្ត មានប្រការដូចដែលពោលហើយ ( ក្នុងបឋមជ្ឈាន មានបរិកម្មចិត្តជាដើម ) នោះឯង ។ ដោយការនៃនាទុក្រមត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ឈ្មោះថា ចូលដល់ ឈានទី២ ដែលផូរផង់ក្នុងខាងក្នុង មានភាពជាចិត្តខ្ពស់ឯង មិនមានវិតក្កៈ មិនមានវិចារៈ ព្រោះវិតក្កវិចារៈស្ងប់ទៅ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ដោយប្រការដូច្នេះ ទុតិយជ្ឈានបឋវីកសិណដែលលះអង្គ ២ ប្រកបដោយ*

អង្គ ៣ វិចិត្រ ៣ ប្រការ ព្រមទៅដោយលក្ខណៈ ១០ ក៏គឺ ព្រះយោគាវចរនោះ បានសម្រេចហើយ ។

## ពន្យល់អត្ថនៃ ទុតិយជ្ឈានបាឋៈ
## អធិប្បាយពាក្យថា វិតក្ក វិចារានំ វូបសមា

ក្នុងបាឋៈទាំងនោះ បាឋៈថា **វិតក្ក វិចារានំ វូបសមា** នោះ មានសេចក្ដីថា ព្រោះស្ងប់រំងាប់ទៅ គឺព្រោះឈានកន្លងអង្គទាំង ២ នេះ គឺ វិតក្កៈ១ វិចារៈ១ មានអធិប្បាយថា ព្រោះអង្គ ២ នោះ មិនប្រាកដក្នុងខណៈនៃទុតិយជ្ឈាន សូម្បីថា ធម៌ក្នុងបឋមជ្ឈានទាំងអស់ រមែងមិនមានក្នុងទុតិយជ្ឈានក៏ពិត ធម៌ទាំងឡាយមានផស្សៈជាដើមក្នុងបឋមជ្ឈានម្យ៉ាង ក្នុងទុតិយជ្ឈានក៏ម្យ៉ាងដោយពិត សូម្បីយ៉ាងនោះ ក៏គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ពាក្យថា **វិតក្កវិចារានំ វូបសមា** ដូច្នេះ ទុកក្នុងទុតិយជ្ឈានបាឋៈនោះ ក៏ដើម្បីសម្ដែងថា ព្រោះអង្គគ្រោតគ្រាតកន្លងទៅ ការសម្រេចឈាន ដែលក្រៃលែងជាងបឋមជ្ឈានឡើងទៅ មានទុតិយជ្ឈានជាដើម ទើបនឹងមានបាន ។

## អធិប្បាយពាក្យថា អជ្ឈត្តំ

បទថា **អជ្ឈត្តំ** ក្នុងទីនេះសំដៅយកខាងក្នុងខ្លួន ចំណែកវិភង្គពោលទុកថា " **អជ្ឈត្តំ** គឺ ចំពោះខ្លួន " ទាំងនេះឯង ក៏ព្រោះសំដៅយកខាងក្នុងខ្លួន ព្រោះដូច្នោះ សេចក្ដីក្នុងបទ **អជ្ឈត្តំ** នេះ ទើបមានដូច្នេះថា កើតដល់ខ្លួន ឬថា កើតក្នុងខ្លួន កើតក្នុងសន្តាននៃខ្លួន ។

## អធិប្បាយពាក្យថា **សម្បសាទនំ**

បទថា **សម្បសាទនំ** មានវិនិច្ឆ័យថា **សទ្ធា** លោកហៅថា **សម្បសាទន** សូម្បីឈានក៏ហៅថា **សម្បសាទន** ព្រោះប្រកបដោយភាពថ្លាផង ដូចសំពត់ដែលហៅថា សំពត់ខៀវ ព្រោះប្រកបដោយពណ៌ខៀវ , ន័យម្យ៉ាងទៀត ព្រោះហេតុដែលឈាននោះ រមែងញ៉ាំងចិត្តឲ្យថ្លាផង់ ព្រោះខ្លួនឯងប្រកបដោយភាពថ្លាផង់ ព្រោះភាពកម្រើក (នៃចិត្ត)ផង និងវិតក្កវិចារៈស្ងប់រំងាប់ទៅផង ព្រោះហេតុនោះឯង ឈាននោះ លោកហៅថា " **សម្បសាទន** " គ្រឿងញ៉ាំងចិត្តឲ្យថ្លាផង់ ឯក្នុងអត្ថ-វិកប្បនេះ បណ្ឌិតគប្បីជ្រាបបទសម្ពន្ធ ដូច្នេះថា **សម្បសាទនំ ចេតសោ** (ទុតិ-យជ្ឈាន គ្រឿងញ៉ាំងចិត្តឲ្យថ្លាផង់) ចំណែកក្នុងអត្ថវិកប្បមុន បទថា **ចេតសោ** នោះ គប្បីប្រកបចូលជាមួយ **ឯកោទិភាវ** សព្ទ ។

## អធិប្បាយពាក្យថា **ចេតសោ ឯកោទិភាវំ**

នេះជាអត្ថយោជនា ( ពាក្យប្រកបសេចក្តី ) ក្នុង **ឯកោទិភាវ** សព្ទនោះ ធម៌ណាជាឯកខ្ពស់ឡើង ហេតុនោះ ធម៌នោះឈ្មោះ **ឯកោទិ** មានន័យថា ជាឯក ជាធំ ព្រោះមិនត្រូវវិតក្កវិចារៈគ្របសង្កត់ ពិតណាស់បុគ្គលដែលជាធំ ក៏ហៅបានថា ជាបុគ្គលឯកក្នុងលោក ឬនឹងពោលថា "បុគ្គលដែលប្រាសចាក វិតក្កវិចារៈហើយ ក៏ជាឯក មិនមានសម្លាញ់" ដូច្នេះខ្លះក៏បាន ន័យម្យ៉ាងទៀត ធម៌ណាញ៉ាំងសម្បយុត្តធម៌ឲ្យឧទ័យ ហេតុនោះ ធម៌នោះ ទើបឈ្មោះថា **ឧទិ** សំដៅសេចក្តីថាញ៉ាំងសម្បយុត្តធម៌ឲ្យតាំងឡើង , ធម៌នោះជាឯក ដោយអត្ថថា ជាធំផង ជាឧទិផង ហេតុនោះ ធម៌នោះ ទើបឈ្មោះថា **ឯកោទិ** ។ ពាក្យថា **ឯកោទិ** នេះ ជាឈ្មោះ

នៃសមាធិ , ទុតិយជ្ឈាននេះ ញ៉ាំងឯកោទិនេះឲ្យប្រាកដឡើង គឺ ឲ្យចម្រើន ហេតុនោះ ទុតិយជ្ឈាននោះ ទើបឈ្មោះថា **ឯកោទិភាវ** ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត **ឯកោទិ** នេះ ព្រោះហេតុជាធម៌សម្រាប់ចិត្ត មិនមែនសម្រាប់សត្វ មិនមែនសម្រាប់ជីវៈ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ពាក្យនេះ ( ប្រកប **ចេតសោ** ទុកផង ) ថា **ចេតសោ ឯកោទិភាវំ** ដូច្នេះ ។

សួរថា ក៏សទ្ធានេះ និងសមាធិដែលបានឈ្មោះថា **ឯកោទិ** នេះ សូម្បីក្នុងបឋមជ្ឈានក៏មាន មិនមែនឬ ? បើដូច្នោះ ហេតុអ្វីទើបទ្រង់ត្រាស់តែទុតិយជ្ឈាននេះថាជា **សម្បសាទន** និងជា **ចេតសោ ឯកោទិភាវ** ទៅវិញ ?

ឆ្លើយថា “ បណ្ឌិតគប្បីជ្រាបថា ព្រោះបឋមជ្ឈាននោះ នៅមិនទាន់ផូរផង់ល្អ ព្រោះនៅកម្រើកនៅឡើយ ដោយ វិតក្កៈ និង វិចារៈ ដូចទឹកដែលញាប់ញ័រដោយរលកតូច រលកធំ ដូច្នោះ ព្រោះហេតុនោះ សូម្បីមានសទ្ធា លោកក៏មិនហៅថា **សម្បសាទន** ព្រោះនៅមិនទាន់ថ្លាផូរផង់ល្អនោះឯង សូម្បីសមាធិក្នុងបឋមជ្ឈាននេះក៏នៅមិនទាន់ប្រាកដច្បាស់ល្អ ហេតុនោះ ទើបលោកមិនហៅថា **ឯកោទិភាវ** ដែរ តែក្នុងឈាននេះ សទ្ធាបានឱកាស ព្រោះមិនមានវិតក្កវិចារៈជាគ្រឿងកង្វល់ ទើបមានកម្លាំង និងបានពលវសទ្ធាជាសំឡាញ់នោះឯង សូម្បីសមាធិវិញក៏ប្រាកដច្បាស់ ព្រោះដូច្នោះ ទើបលោកពោលតែទុតិយជ្ឈាននេះប៉ុណ្ណោះ ថា ជាយ៉ាងនោះ ” ចំណែកក្នុងវិភង្គ ពោលទុកត្រឹមតែថា “ សទ្ធាឯណា ការជឿ ការដាក់ចិត្ត ការជ្រះថ្លាក្រៃលែងឯណា ទាំងនោះ ឈ្មោះថា **សម្បសាទន** , ការតាំងនៅនៃចិត្តឯណា ។ ល ។ សម្មាសមាធិណា នោះឈ្មោះថា **ចេតសោ ឯកោទិភាវ** ” ដូច្នេះប៉ុណ្ណោះ ក៏ឯពាក្យពណ៌នាសេចក្តី ( នៃបាឋៈទាំង ២ នេះ គង់មិនខុស ប្រៀប

ផ្ទឹមគ្នាបាន និងចុះសម្រុងគ្នាបានពិតៗ ជាមួយវិកន្តបាឋៈ ដែលពោលមកដូច្នេះនោះ គប្បីជ្រាបយ៉ាងនេះចុះ ។

## អធិប្បាយពាក្យថា **អវិតក្កំ អវិចារំ**

បាឋៈថា ***អវិតក្កំ អវិចារំ*** មានការអធិប្បាយថា ការត្រិះរិះ មិនមាននៅក្នុងទុតិយជ្ឈាននោះ ឬថា ដល់ទុតិយជ្ឈាននោះ ព្រោះការត្រិះរិះនោះ លះបង់ទៅហើយដោយភាវនា ហេតុនោះ ទុតិយជ្ឈាននោះ ទើបឈ្មោះថា ***អវិតក្កៈ*** ( មិនមានការត្រិះរិះ ) ***អវិចារៈ*** ( មិនមានការពិចារណា ) គប្បីជ្រាបអត្ថដោយន័យតែមួយដូចគ្នា សូម្បីក្នុងវិភង្គ ក៏ពោលទុកថា " ទាំងវិតក្កៈ និងវិចារៈនេះ ជាធម៌ស្ងប់រំងាប់រលត់ទៅហើយ ដាក់ចុះហើយ វិនាសទៅហើយ ក្រៀមស្ងួតទៅហើយ ត្រូវធ្វើឲ្យអស់ទៅហើយ ហេតុនោះ ឈាននេះ ទើបឈ្មោះថា ***អវិតក្កៈ អវិចារៈ*** " ដូច្នេះ ។

ក្នុងសេចក្ដីនេះ មានបញ្ហាថា " សេចក្ដី ( ដែលពោលថា មិនមានវិតក្កៈ មិនមានវិចារៈ ព្រោះវិតក្កវិចារៈនោះ លះបង់ទៅហើយដោយភាវនា " នេះក៏ជាការសម្រេចសូម្បីដោយបាឋៈថា ***វិតក្កវិចារានំ វូបសមា*** ( ព្រោះវិតក្កវិចារៈស្ងប់រំងាប់ទៅ ) មិនមែនឬ ? កាលបើដូច្នោះ ហេតុអ្វី ទើបទ្រង់ត្រាស់ពាក្យថា ***អវិតក្កំ អវិចារំ*** ( មិនមានវិតក្កៈ មិនមានវិចារៈ ) ទៀតទៅវិញ ?

មានចម្លើយថា " សេចក្ដីនេះជាការសម្រេចហើយដោយបាឋៈដែលពោលយ៉ាងនោះពិត តែពាក្យថា ***វិតក្កវិចារានំ វូបសមា*** នេះ បង្ហាញដល់សេចក្ដីដែលថា មិនមានវិតក្កៈ មិនមានវិចារៈ ប៉ុណ្ណោះក៏ទេ យើងបានពោលហើយ មិនមែនឬថា សូម្បីដូច្នោះ ក៏គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ពាក្យថា ***វិតក្កវិចារានំ***

**វូបសមា** ដូច្នេះទុក ក៏ដើម្បីសម្តែងថា ព្រោះកន្លងបង់នូវអង្គគ្រោតគ្រាត ការសម្រេចឈានដែលក្រៃលែងជាងបឋមជ្ឈានឡើងទៅ មានទុតិយជ្ឈានជាដើម ទើបនឹងមានបាន ” ដូច្នេះ អើ ក៏ពាក្យថា ( **វិតក្កវិចារានំ វូបសមា** ) នេះជាពាក្យសម្តែងហេតុនៃទុតិយជ្ឈានជា **សម្បសាទន** និងជា **ឯកោទិភាវ** យ៉ាងនេះគឺ ឈាននេះជា **សម្បសាទន** ព្រោះស្ងប់រំងាប់វិតក្កៈវិចារៈទាំងឡាយ មិនមែន (ព្រោះការស្ងប់រំងាប់ទៅ) នៃកិលេសដែលកើតឡើងតាមកាលនោះទេ និងជា **ឯកោទិភាវ** ក៏ព្រោះការស្ងប់រំងាប់ទៅនៃវិតក្កវិចារៈទាំងឡាយ មិនមែនព្រោះការលះនីវរណៈបានដូចឧបចារឈាន និង (មិនមែន)ព្រោះការប្រាកដនៃអង្គ ដូចបឋមជ្ឈានដូច្នេះឡើយ ដែលដូចគ្នា គ្រាន់តែជាពាក្យសម្តែងហេតុនៃអវិតក្កអវិចារៈ យ៉ាងនេះ គឺ ឈាននេះឈ្មោះថា **អវិតក្ក អវិចារ** ព្រោះការស្ងប់រំងាប់ទៅនៃវិតក្កវិចារៈទាំងឡាយ មិនមែនព្រោះការមិនមាន (វិតក្កៈវិចារៈ) ដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ដូច្នេះឯង មិនមែនជាពាក្យសម្តែង ត្រឹមតែការមិនមាននៃវិតក្កវិចារៈប៉ុណ្ណោះនោះឡើយ ។ ចំណែកពាក្យ **អវិតក្កំ អវិចារំ** នេះ ជាពាក្យសម្តែងចំពោះការមិនមាននៃវិតក្កៈ វិចារៈប៉ុណ្ណោះ ព្រោះហេតុនោះ ពាក្យ **អវិតក្កំ អវិចារំ** នេះ សូម្បីទ្រង់ត្រាស់ពាក្យខាងដើម គឺ ( **វិតក្កវិចារានំ វូបសមា** ) ហើយ ក៏នៅត្រាស់ដដែលទៀត ហ្នឹងឯង ។

## អធិប្បាយពាក្យថា **សមាធិជំ បីតិសុខំ**

បទថា **សមាធិជំ** មានសេចក្តីថា កើតអំពីសមាធិក្នុងបឋមជ្ឈាន ឬថា អំពីសម្បយុត្តសមាធិ ( សមាធិប្រកបប្រួមគ្នា ) ក្នុងសមាធិ ២ យ៉ាងនោះ សូម្បីក្នុង

បឋមជ្ឈាន ក៏កើតអំពីសម្បយុត្តសមាធិដោយពិត តែសូម្បីយ៉ាងនោះ ក៏សមាធិ ( ក្នុងទុតិយជ្ឈាន ) នេះប៉ុណ្ណោះ គួរហៅថា **សមាធិ** ព្រោះមិនញាប់ញ័រ និង ព្រោះថ្លូវផង់ល្អក្រៃលែង ដោយប្រាសចាកការកម្រើកនៃ វិតក្កៈ វិចារៈ ព្រោះហេតុ នោះ ដើម្បីសរសើរសមាធិនេះ ទើបទ្រង់ត្រាស់ថា **សមាធិជំ** ចំពោះទុតិយជ្ឈាន នេះប៉ុណ្ណោះ ។

បទថា **បីតិសុខំ** នេះ មានន័យដូចពោលមកហើយ ។ បទថា **ទុតិយំ** គឺ ឈាននេះ ជាឈានទី ២ ព្រោះមានលំដាប់នៃចំនួន កន្លែងខ្លះពោលថា ឈ្មោះថា **ទុតិយ** ព្រោះព្រះយោគាវចរចូលដល់ឈាននេះ ជាទី ២ ។

ចំណែកពាក្យណា ដែលខ្ញុំព្រះករុណាបានពោលទុកថា “ ទុតិយជ្ឈាន លះ អង្គ ២ ប្រកបដោយអង្គ ៣ ” ដូច្នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ តទៅ :-

សេចក្ដីដែលឈាននេះ លះអង្គ ២ គប្បីជ្រាបដោយន័យ ដែលលះបង់ វិតក្កវិចារៈបាន ឯនីវរណធម៌ទាំងឡាយ ព្រះយោគាវចរ លះបង់បានក្នុងឧបចារ-ខណៈនៃបឋមជ្ឈាន យ៉ាងណា វិតក្កវិចារៈមិនមែនលះបង់បានក្នុងឧបចារខណៈនៃ ទុតិយជ្ឈាននេះ យ៉ាងនោះទេ តែក្នុងអប្បនាខណៈ ឈាននេះកើតឡើងមក ក៏វៀរ ចាកវិតក្កវិចារៈ ទាំងនោះតែម្ដង ព្រោះហេតុនោះ វិតក្កវិចារៈទាំងនោះ ទើបហៅ ថា ជាអង្គ ដែលគប្បីលះដោយទុតិយជ្ឈាននោះ ។ ក្នុងការដែលឈាននេះប្រកប ដោយអង្គ ៣ គប្បីជ្រាប ដោយការកើតឡើងនៃអង្គ ៣ នេះ គឺ **បីតិ សុខ ចិត្តេកគ្គតា** ព្រោះហេតុនោះ ពាក្យណាដែលពោលទុកក្នុងវិភង្គថា “ **សម្បសាទន** ( ភាពថ្លូវផង់នៃចិត្ត ) **បីតិ សុខ ឯកគ្គតានៃចិត្ត** ឈ្មោះថា **ឈាន** ” ដូច្នេះ ពាក្យ

នោះ លោកពោលដោយបរិយាយ ដើម្បីសម្ដែងឈាននោះ ព្រមទាំងបរិក្ខារ តែលើក **សម្បសាទន** ចេញ ឈាននោះ ក៏មានអង្គ ៣ ប៉ុណ្ណោះ ដោយជាអង្គដែលចូលលក្ខណូបនិជ្ឈានដោយត្រង់ ដូចលោកពោល ( ក្នុងវិភង្គមួយកន្លែង ) ថា “ សួរថា ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ **បីតិ សុខ ឯកគ្គតានៃចិត្ត** ” ។ ពាក្យដ៏សេស មានន័យដូចពោលក្នុងបឋមជ្ឈានទាំងអស់ ។

( ចប់ ទុតិយជ្ឈាន )

# មហាដីកា

## អធិប្បាយ ទុតិយជ្ឈាន

( សមាបត្តិនេះ ) ឈ្មោះថា នៅមាននីវរណៈជាសត្រូវជិត ព្រោះការលះនីវរណធម៌ មានជាគ្រាជំបូងនៃសមាបត្តិនោះ ។ អង្គឈាន ឆាយក្នុងការវិនាស ដូចក្រមរឈើ សូម្បីថា អស្ចារ្យ ក៏នៅឈ្មោះថា គ្រោតគ្រាត ព្រោះហេតុនោះ ទើបលោកពោលថា “ មានអង្គខ្សោយកម្លាំង ព្រោះវិតក្កវិចារៈជាអង្គដែលគ្រោតគ្រាត ” ដូច្នេះ ។ ពាក្យថា **មនសិការ** (ទុតិយជ្ឈាន) **ថាជាធម៌ស្ងប់** គឺ ធ្វើទុកក្នុងចិត្តថា “ ជាធម៌ស្ងប់ ” ព្រោះមិនមានអង្គគ្រោតគ្រាត ដូចបឋមជ្ឈាន និងព្រោះមានការព្រមព្រៀងដោយធម៌ស្ងប់ ។

ពិតណាស់ ធម៌ទាំងឡាយមានបីតិ និងសុខជាដើម ពួកណា មានក្នុងទុតិយ-ជ្ឈាន សូម្បីថា ក្នុងបឋមជ្ឈាន មានធម៌ពួកនោះក៏ពិត តែធម៌ក្នុងទុតិយជ្ឈានទាំងនោះ

ជាធម្មជាតិស្ងប់ជាង និងប្រណីតជាងធម៌ក្នុងបឋមជ្ឈានទាំងនោះ ។

បទថា **និក្កន្តី** ប្រែថា សេចក្ដីស្រឡាញ់ មានន័យថា ការជាប់ជំពាក់ ។

បទថា **បរិយាទាយ** ប្រែថា ធ្វើឲ្យអស់ទៅ ។ **វា** ស័ព្ទ ក្នុងបទថា **ចត្តារិ បញ្ច** លោកសម្ដែងទុកដោយជាស័ព្ទដែលត្រូវលុបចេញ ( សេចក្ដីពិតក្នុងវិសុទ្ធិមគ្គជា **ចត្តារិ បញ្ច វា** មិនបានលុប **វា** ស័ព្ទ ) ទេ ។

**រូបាវចរជវ័ន** ឈ្មោះថា **ទុតិយជ្ឈានិក** ព្រោះអត្ថថា មានទុតិយជ្ឈាន ។ ពាក្យថា **ដែលមានប្រការដូចដែលបានពោលហើយនោះឯង** គឺ ដែលមានប្រការដូចដែលពោលហើយនោះឯង ក្នុងបឋមជ្ឈាន មានសេចក្ដីថា ដែលមានឈ្មោះជាដើមថា **បរិកម្ម** ជាដើម ។

ពាក្យថា **ព្រោះស្ងប់បាន** គឺ ព្រោះហេតុដែលស្ងប់បាន ក៏ពាក្យថា សេចក្ដីស្ងប់ក្នុងទីនេះ បំណងយកការលះបាន ហើយការលះនោះ គឺ លះនូវវិតក្កៈ និងវិចារៈ ។ ការឈានកន្លងដោយអត្ថ បានដល់ ការមិនកើតឡើងក្នុងខណៈនៃទុតិយជ្ឈាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា គឺ ព្រោះឈានកន្លងដូច្នេះជាដើម ។

សួរថា ក៏ក្នុងទុតិយជ្ឈាននេះ បំណងយកសេចក្ដីស្ងប់បាននូវវិតក្កវិចារៈពួកណា ? វិតក្កវិចារៈដែលមានក្នុងបឋមជ្ឈានឬ ? ឬថា វិតក្កវិចារៈដែលមានក្នុងទុតិយជ្ឈានដែរ ?

ក្នុងរឿងនេះ ប្រសិនបើបំណងយកសេចក្ដីស្ងប់នូវវិតក្កវិចារៈ ដែលមានក្នុងបឋមជ្ឈានសោត ក៏នឹងរកស្ងប់វិតក្កៈ និងវិចារៈទាំងនោះមិនបាន ព្រោះក្នុងកាលណាក៏ដោយ មិនមានបឋមជ្ឈានដែលវៀរវិតក្កៈ និងវិចារៈឡើយ ។ កាលបើ

ដូច្នោះ ក៏បំណងយកវិតក្កវិចារៈ ដែលមានក្នុងទុតិយជ្ឈាន សូម្បីយ៉ាងនេះ ក៏រកសេចក្ដីស្ងប់មិនបានដែរ ព្រោះក្នុងទុតិយជ្ឈាននោះ មិនមានវិតក្កៈ និងវិចារៈ (ដែលនឹងស្ងប់)នោះ ដោយប្រការណាមួយឡើយ ។ សូមឆ្លើយថា បឋមជ្ឈាន មានសភាពជាឈានដែលគ្រោតគ្រាត ព្រោះវិតក្កៈនិងវិចារៈពួកណា ព្រោះឈានកន្លងវិតក្កៈនិងវិចារៈពួកនោះចេញបាន ទើបមានការសម្រេចទុតិយជ្ឈាន មិនមែនមានការសម្រេចទុតិយជ្ឈាន ព្រោះឈានកន្លងធម៌ មានផស្សៈជាដើម ដែលមិនមែនគ្រោតគ្រាតដោយសភាវៈនោះឡើយ អធិប្បាយដូចដែលបានពោលមកនេះ ជាការជាក់ច្បាស់បាន ដោយពាក្យថា **"ព្រោះស្ងប់រំងាប់បាន នូវវិតក្កៈនិងវិចារៈ"** នេះ ។ ព្រោះដូច្នោះពាក្យដែលសួរថា " ក្នុងទុតិយជ្ឈាននេះ បំណងយកសេចក្ដីស្ងប់រំងាប់បាននូវវិតក្កៈនិងវិចារៈ ដែលមានក្នុងបឋមជ្ឈានឬ ? ឬថា វិតក្កៈនិងវិចារៈដែលមានក្នុងទុតិយជ្ឈានវិញ ដូច្នេះ ទើបរកឱកាសមិនបាន ។

ព្រោះហេតុដែល ទ្រង់បំណងយកការធ្វើវិតក្កៈជាដើម ដែលបានឃើញទោសហើយ ឲ្យដល់ភាពមិនកើតឡើងជាធម្មតា ក្នុងខណៈនៃឈាននោះៗ ថាជាសេចក្ដីស្ងប់រំងាប់បាន ។ ទើបទ្រង់ធ្វើធម៌ដែលជាអង្គឈាន មានវិតក្កៈជាដើមប៉ុណ្ណោះ ទុកដោយអាការនោះ ( ដោយប្រការដែលជាធម៌នឹងត្រូវធ្វើឲ្យស្ងប់ទៅ ) ទ្រង់មិនបានធ្វើធម៌ដែលសម្បយុត្តជាមួយអង្គឈានទាំងនោះ មានផស្សៈជាដើមទុកដោយអាការនោះ ។ ដូច្នោះ ពាក្យថា ស្ងប់ជាដើម នឹងប្រើបានយ៉ាងត្រឹមត្រូវសម្រាប់ធម៌ដែលជាអង្គឈាន មានវិតក្កៈជាដើមប៉ុណ្ណោះ ។

តែព្រោះហេតុនៃការសម្ដែងទោស សូម្បីធម៌ដែលសម្បយុត្តជាមួយនឹងវិតក្កៈនោះជាដើម ថា "នេះជាធម្មជាតិដែលគ្រោតគ្រាត" ក៏មកហើយក្នុងព្រះសូត្រ ដោយ

ពាក្យនេះ ដូចគ្នានឹងការសម្ដែងទោសនៃធម៌ មានវិតក្កៈជាដើម នោះឯង ។ ដូច្នោះ ដើម្បីនឹងសម្ដែងថា បើគួរនឹងពោលដល់សេចក្ដីស្ងប់រំងាប់បាន ជាដើម នូវធម៌មានវិតក្កៈជាដើម និងធម៌ដែលសហគតៈដោយវិតក្កៈជាដើមនោះ ដោយមិនផ្សេងគ្នា សេចក្ដីស្ងប់រំងាប់បាន ដែលពោលទុកចំពោះធម៌ មានវិតក្កៈជាដើមប៉ុណ្ណោះ រមែងសម្ដែងអត្ថន័យពិសេសខ្វះៗ ព្រោះធ្វើអធិប្បាយថា ពាក្យនិយាយចំពោះ ( គឺពោលដល់វិតក្កៈជាដើមប៉ុណ្ណោះ ) រមែងធ្វើឲ្យដឹងដល់អត្ថន័យដទៃទៀតបាន ដូច្នេះ ទើបលោកអាចារ្យពោលកាន់យកពាក្យថា "ព្រោះមានការឈានកន្លងអង្គគ្រោតគ្រាត" ដូច្នេះ ទុកក្នុងអដ្ឋកថា ព្រោះហេតុនោះ ក្នុងទីនេះ គប្បីឃើញថា ជាការត្រាស់ថា " **យេហិ វិតក្កវិចារេហិ** " ជាដើម ។

សូម្បីក្នុង បទថា " **បីតិយា ច វិរាគា** " ទាំងព្រោះប្រាសចាកបីតិបាន ដូច្នេះជាដើម ក៏មានន័យដូច្នេះ ។ ព្រោះដូច្នោះ ពាក្យពោលដល់ការឈានកន្លង **វិតក្ក វិចារ បីតិ** និង**សុខ** ជាពាក្យដែលសម្ដែងដល់ការសម្រេចទុតិយជ្ឈានជាដើម ព្រោះឈានកន្លងអង្គគ្រោតគ្រាតបាន ព្រោះដូច្នោះ ការដែលលោកពោល ថាពាក្យពោលដល់ការឈានកន្លង វិតក្កៈ និង វិចារៈ ដែលចាត់ទុកជាចំណែកមួយនៃធម៌ទាំងនោះ ជាពាក្យដែលសម្ដែងដល់ការសម្រេចទុតិយជ្ឈាននោះ ។ ពិតណាស់ កាលបានកាន់យកពាក្យពោលទាំងឡាយ មានពាក្យពោលដល់ការឈានកន្លងវិតក្កៈ និងវិចារៈជាដើមសូម្បីតាំងនៅផ្សេងគ្នា មួយពាក្យៗ ព្រមជាមួយចិត្ត ព្រោះសេចក្ដីផ្សេងគ្នា ក៏ជាពាក្យសម្ដែងលម្អិតអង្គ ដែលគប្បីលះបង់ដូចគ្នា ក៏នឹងគប្បីឃើញថា ពាក្យពោលដល់ការស្ងប់វិតក្កៈ និងវិចារៈ ជាចំណែកមួយនៃពាក្យដែលសម្ដែងខែអង្គ ដែលគប្បីលះនោះ ។ ក៏អត្ថន័យនេះ លោកពោលទុកដោយន័យ ដែលកំណត់ដល់

ធម៌ទាំងក្រុម ទុកដោយធម៌ជាចំណែកៗ ( ធម៌ទាំងក្រុម គឺ អង្គឈាន មានវិតក្កៈជាដើម ព្រមទាំងធម៌ដែលសម្បយុត្តជាមួយអង្គឈានទាំងនោះ ធម៌ជាចំណែកៗ គឺ វិតក្កវិចារៈ ) ។ ន័យម្យ៉ាងទៀត ដោយពាក្យ ដែលពោលដល់ភាពស្ងប់រំងាប់ទៅនូវវិតក្កៈ និងវិចារៈ ដែលសម្តែងដល់ការសម្រេចទុតិយជ្ឈាន ព្រោះឈានកន្លងវិតក្កៈ និងវិចារៈនោះបាន នោះឯង ជាការបើកផ្លូវសេចក្តីដែលពោលដល់ការប្រាសចាកបីតិបានជាដើម ព្រោះឈានកន្លងបីតិជាដើមបាន ព្រោះហេតុនោះ ទើបលោកពោលដល់សេចក្តីដែលថា ឈានកន្លង វិតក្កៈ និងវិចារៈនោះ ជាពាក្យសម្តែងដល់ការសម្រេចទុតិយជ្ឈាននោះ ។ ឈ្មោះថាបំណាងយក **និយកជ្ឈត្តំ** ( **អជ្ឈត្ត** ប្រែថា កើតខាងក្នុងខ្លួន ) គឺ មិនបំណងយក **អជ្ឈត្តជ្ឈត្ត** ( **អជ្ឈត្ត** ដែលប្រែថា ខាងក្នុង ) ជាដើម ។ ពាក្យថា **ចំណែកក្នុងវិភង្គជាដើម** លោកពោលដល់ហេតុក្នុង **និយកជ្ឈត្ត** នោះ ។ ពាក្យថា **ដូចជា ឈ្មោះថា សំពត់ខៀវ ព្រោះប្រកបដោយពណ៌ខៀវដូច្នោះ** មានអធិប្បាយថា ដូចសំពត់ ឈ្មោះថា **ខៀវ** ព្រោះប្រកបដោយពណ៌ខៀវ ។ **ឈាន** ឈ្មោះថា **សម្បសាទន** ព្រោះប្រកបដោយសេចក្តីជ្រះថ្លាណា កាលបានសម្តែងនូវសេចក្តីជ្រះថ្លានោះ ក៏ជាការបានសម្តែងនូវការប្រព្រឹត្តទៅនៃសត្វថា ជ្រះថ្លានោះ ទុកក្នុងឈាន ព្រោះប្រកបដោយសេចក្តីជ្រះថ្លានោះ ដោយការសម្តែងលម្អិតពាក្យពោល ដែលមានអធិករណ៍ស្មើគ្នាថា “ **សម្បសាទនំ ឈានំ** ” នោះឯង ព្រោះហេតុនោះ ទើបមិនមានការខុសភ្លាំងភ្លាត់បាន គឺ ត្រឹម-ត្រូវ ។ ប្រសិនបើមានពាក្យសួរថា កាលបានសម្តែង **ឯកោទិ** ថា ឈាន មានភាពជា **ឯកោទិ** ដូចម្តេច ហើយក៏ជាការពោលដល់ឈានដែលជាគ្រឿងចម្រើន **ឯកោទិ** ដោយពាក្យសម្តែងលម្អិត ដែលមានអធិករណ៍ស្មើគ្នាថា **ឯកោទិភាវំ ឈានំ** នោះ

ឯងឬ ?

ពាក្យឆ្លើយគឺ មិនគួរលើកបទថា **ឯកោទិភាវំ** ឡើងធ្វើការសម្តែងលម្អិតទេ , **ឯកោទិ** និងស័ព្ទថា **ឯកោទិភាវ** នោះ រមែងប្រព្រឹត្តទៅក្នុងឈាន ដូចស័ព្ទថា **សម្បសាទន** ដែលប្រព្រឹត្តទៅក្នុងសមាធិដូច្នោះ រមែងជាការត្រឹមត្រូវហើយ ។

ពាក្យថា **ក៏ក្នុងអត្ថវិកប្បនេះ** គឺ ក្នុងចំណែកដែលថា " **ចេតសោ សម្ប-សាទយតិ** " រមែងធ្វើចិត្តឲ្យថ្លូវថង់ ។ ក៏បទថា " **ចេតសោ** " ជាឆដ្ឋីវិភត្តិក្នុងអត្ថនៃទុតិយាវិភត្តិ ។ ពាក្យថា **ក្នុងអត្ថនៃវិកប្បដំបូង** គឺ ក្នុងចំណែកដែលពោល ថា **ឈាន** ឈ្មោះថា **សម្បសាទន** ព្រោះប្រកបដោយសេចក្តីជ្រះថ្លា ។ ពាក្យថា **ចេតសោ** ជាឆដ្ឋីវិភត្តិ ក្នុងអត្ថថា សម្ពន្ធ ។

ឈ្មោះថា ក្នុងផ្លូវលោក សូម្បីបុគ្គលដែលប្រសើរបំផុត ក៏គេហៅថា **ឯក** ដូចក្នុងប្រយោគថា " **យាវ បរេ ឯកាហំ តេ ករោមិ** " ដូច្នេះជាដើម ។ ស័ព្ទថា **ឯក** សូម្បីមានអត្ថថា មិនមានសម្លាញ់ ប្រាកដហើយក្នុងប្រយោគថា **ឯកោ អទុតិយោ** " **ឯកាកិកិខុទ្ទកេហិ ជិតំ** " ដូច្នេះជាដើម ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ជាឯក គឺ មិនមានសំឡាញ់ ដូច្នេះ ។

លោកអាចារ្យកាលសម្តែងថា សូម្បីធម៌ទាំងឡាយ មានសទ្ធាជាដើម រមែងជាបច្ច័យទាំងដោយសាធារណៈ ទាំងដោយអសាធារណៈ ដល់សម្បយុត្តធម៌ទាំងឡាយបានក៏ពិត តែថាក្នុងខណៈនៃឈាន សមាធិរមែងជាបច្ច័យដល់សម្បយុត្តធម៌ទាំងឡាយដ៏ប្រសើរ ដោយការធ្វើភាពជាធំ ដោយលក្ខណៈ ដែលមិនរាយមាយ ដូច្នេះ ទើបពោលថា **ព្រោះអត្ថថា ញ៉ាំងសម្បយុត្តធម៌ ទាំងឡាយឲ្យឧទ័យ។ល។** ពាក្យថា **ឯកោទិ** នេះ ជាឈ្មោះរបស់ **សមាធិ** នោះ ។

ពាក្យវិសេសនៈទាំង ២ ដែលថា **សម្បសាទនំ ចេតសោ ឯកោទិភាវំ** លោកកាន់យក ដោយទាក់ទងជាមួយនឹងការដែលត្រូវពោលដល់ភាពវិសេស នៃឈាន ។ ដើម្បីសម្ដែងភាពផ្សេងគ្នា ក្នុងសេចក្ដីនេះថា ភាពវិសេសនោះ រមែងមិនមានក្នុងបឋមជ្ឈាន ដូចដែលមានក្នុងឈាននេះ ដូច្នេះ ទើបលោកពោលថា " **ននុ ច** " ដូច្នេះជាដើម ។

ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅដោយទាក់ទងជាមួយកិរិយា ដែលផ្ដោតបានអំពីដើម ផ្ដោតបានដោយជុំវិញ ( នៃវិតក្កៈ ) និងដោយទាក់ទងជាមួយកិរិយាដែលតាមពិចារណា តាមប្រកប ( នៃវិចារៈ ) ក្នុងអារម្មណ៍ សូម្បីកាលមានការប្រាសចាកសេចក្ដីស្រវឹង គឺ កិលេស ព្រោះលះបង់នីវរណៈបាន ក៏ហាក់បីដូចជាធ្វើភាពកម្រើកដល់សម្បយុត្តធម៌បានបន្តិចបន្តួច និងសម្បយុត្តធម៌ទាំងនោះ មិនទាន់ស្ងប់បាន ក៏ព្រោះធម៌ទាំងនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " **មិនទាន់មានភាពថ្លាផូរផង់ល្អ ព្រោះនៅមានការកម្រើកនៃវិតក្កៈនិងវិចារៈ** " ដូច្នេះ ។

រលកតូច ៗ ឈ្មោះថា **វីចិ** , រលកធំៗ ឈ្មោះថា **តរង្គ** ។ សូម្បីកាលបើមានការប្រៀបផ្ទឹមគ្នានៃឥន្ទ្រិយ និងសូម្បីកាលបើមានភាពស្មើគ្នាល្អ នៃសេចក្ដីព្យាយាមសមាធិ ( ក្នុងបឋមជ្ឈាន ) ក៏មិនប្រាកដច្បាស់ ព្រោះការកម្រើកនោះៗឯង និងព្រោះមិនមានភាពថ្លាផូរផង់ ដូចត្រីដែលមិនប្រាកដច្បាស់ក្នុងទឹកជ្រៅ ។ ការកម្រើក តាមដែលពោលហើយនោះឯង ឈ្មោះថា សេចក្ដីកង្វល់ ។

ពាក្យថា ( ព្រមជាមួយបាឋៈ ) **ដែលត្រាស់ទុកយ៉ាងនេះ** បានដល់ ដែលត្រាស់ទុកថា " **សទ្ធហនា** " ជាដើម ទាក់ទងដោយការបើកផ្សាយសេចក្ដីផ្សេងគ្នានៃអាការប្រព្រឹត្តទៅដោយអំណាចនៃសទ្ធា ដែលជាហេតុឲ្យហៅឈានថា **សម្បសាទន**

និងដោយអំណាចនៃចិត្តេកគ្គតា ដែលជាហេតុឲ្យហៅឈានថា **ឯកោទិភាវ** នោះឯង ។ បានដល់ ព្រមជាមួយបាឋៈនៃវិភង្គនោះ ។ ពាក្យពណ៌នាសេចក្តីនេះ ដែលប្រព្រឹត្តទៅយ៉ាងនេះថា “ ឈាន ទ្រង់ត្រាស់ហៅថា **សម្បសាទន** ព្រោះប្រកបដោយសេចក្តីជ្រះថ្លា ឬព្រោះធ្វើឲ្យជ្រះថ្លា ទ្រង់ត្រាស់ហៅថា **ឯកោទិភាវ** ព្រោះអត្ថថា ធ្វើឯកោទិភាវៈឲ្យកើត ” ដូច្នេះ រមែងមិនខុស ។ គឺ លោកពោលហើយ ដោយប្រការដែលមិនខុសក្លាំងក្លាត់នោះឯង ។

ពាក្យថា **ជាធម្មជាតិស្ងប់ហើយ** គឺ ជាធម្មជាតិដែលដល់នូវភាពស្ងប់ គឺ ការរលត់ហើយ ។ ពាក្យថា **ត្រូវធ្វើឲ្យដល់នូវភាពស្ងប់** គឺ ត្រូវការនាធ្វើឲ្យដល់នូវភាពស្ងប់ បានដល់ ត្រូវធ្វើឲ្យរលត់ទៅ ។ ពាក្យថា **ចូលទៅស្ងប់វិសេសហើយ** គឺ ព្រោះហេតុនោះឯង ទើបត្រូវចូលទៅស្ងប់បានហើយដោយល្អ ។ ពាក្យថា **ដល់នូវការតាំងនៅមិនបាន** បានដល់ ដល់នូវការតាំងនៅមិនបាន គឺ ការវិនាស ។ លោកពោលពង្រីកបទទុកដោយ ឧបសគ្គថា **អព្ភត្ថង្គតា** ។ ពាក្យថា **ធ្វើឲ្យដល់នូវការអស់ទៅ** បានដល់ ត្រូវធ្វើឲ្យដល់នូវការវិនាសទៅ ។ ពាក្យថា **ត្រូវធ្វើឲ្យហួតហែងទៅ** បានដល់ ត្រូវធ្វើឲ្យដល់នូវការហួតហែង គឺ ភាពដែលក្រៀមស្ងួត ព្រោះមិនមានការបន្ត ពោលគឺ ការប្រព្រឹត្តទៅ ។ បទថា **ព្យន្តីកតា** ត្រូវធ្វើឲ្យមានចំណែកដែលទៅប្រាសហើយ ។

ពាក្យថា **អត្ថន័យនេះ** បានដល់ ការមិនមាននៃវិតក្កវិចារៈ ព្រោះត្រូវលះទៅដោយការនា ។ ដើម្បីនឹងព្រមទទួលអត្ថន័យដែលទាក់ទងដោយអ្នកពោល ហើយឆ្លើយ លោកអាចារ្យកាលពោលថា “ អត្ថន័យនេះ ជាការសម្រេចហើយយ៉ាងនេះទាំងអស់ ” ដូច្នេះហើយ ទើបពោលថា “ តែពាក្យពោលនេះ មិនមែនជាពាក្យ

ដែលសម្តែងអត្ថន័យនោះ ” ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា (តែថា) **ពាក្យនេះ** គឺ ពាក្យថា “ ព្រោះស្ងប់រំងាប់បាននូវវិតក្កៈ និងវិចារៈនេះ ” ។ ពាក្យថា ( មិនមែន ) **ពាក្យដែលសម្តែងអត្ថន័យនោះ** គឺ ( មិនមែន ) ពាក្យដែលសម្តែងអត្ថន័យ ពោលគឺ ត្រឹមតែការមិនមាននៃវិតក្កៈ និងវិចារៈនោះ ។

ដែលពិត ក្នុងពាក្យថា ព្រោះស្ងប់រំងាប់បាននូវវិតក្កៈ និងវិចារៈនោះ មានន័យដូច្នេះ :

ការមិនមានវិតក្កៈ និងវិចារៈ ដែលទ្រង់សម្តែងហើយ ដោយពាក្យថា ស្ងប់រំងាប់បាននូវវិតក្កៈ និងវិចារៈ គឺ សម្តែងដល់ឧបាយសម្រេចទុតិយជ្ឈានជាដើម ដែលសម្តែងដល់ហេតុនៃអជ្ឈត្តៈ និងសម្បសាទនៈ និងភាពជាឯកោទិភាវៈនៃចិត្ត និងដែលសម្តែងដល់ហេតុនៃការមិនមានវិតក្កៈ និងវិចារៈនោះផង , សួរថា ប្រយោជន៍អ្វី ដោយពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈដែលទ្រង់ធ្វើទុកទៀត ?

ឆ្លើយថា មិនមាន ព្រោះទ្រង់មិនទាន់បានសម្តែងទុក ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈ ដូច្នេះ ទ្រង់បំណងនឹងហាមការគិតថា ដែលពិត ដោយពាក្យថា ស្ងប់រំងាប់បាននូវវិតក្កៈ និងវិចារៈ នឹងទ្រង់ត្រាស់ដល់ការមិនប្រព្រឹត្តទៅនៃវិតក្កៈ និងវិចារៈក៏ទេ ។ ការលះបង់តណ្ហាក្នុងវិតក្កៈ និងវិចារៈ ឈ្មោះថា ជាការស្ងប់រំងាប់បាននូវធម៌ទាំងនេះ ប្រៀបដូចជាមគ្គពួកណា ធ្វើការលះបង់តណ្ហាក្នុងសង្ខារទាំងឡាយ ក្នុងមគ្គទាំងនោះ និងក្នុងផលដែលលះបង់តណ្ហាបានហើយ ក៏គង់មានការប្រព្រឹត្តទៅនៃសង្ខារនោះដែរ សូម្បីក្នុងទុតិយជ្ឈាននេះ ក៏ដូច្នោះដូចគ្នា ដោយពាក្យដំបូង (គឺពាក្យថា ព្រោះស្ងប់រំងាប់បាននូវវិតក្កៈ និងវិចារៈ) ក៏មិនទាន់អាចហាមការប្រកបរួមគ្នាជាមួយវិតក្កៈ

និងវិចារៈនៃទុតិយជ្ឈាន ដែលគ្របសង្កត់តណ្ហាក្នុងវិតក្កៈនិងវិចារៈបានហើយ ដូច្នេះ នោះ ហើយទ្រង់បំណាងសម្ដែងថា ការឈានកន្លងសេចក្ដីត្រូវការដែលនឹងនឹកដល់ ជាដើមនោះឯង ជាការស្ងប់រំងាប់បាននូវ វិតក្កៈ និង វិចារៈទាំងនោះ ។ បទថា **បឋមម្បិ** បានដល់ សូម្បីបឋមជ្ឈាន ។

ការនឹងពោលថា ឈ្មោះថា **ទុតិយ** ព្រោះអត្ថថា កើតឡើងជាលើកទី ២ ដូច្នេះក៏បាន ក៏គួរទាំងអស់ ។ ពាក្យថា **ន តថា ឥមស្ស វិតក្កវិចារា** មានន័យថា នីវរណៈទាំងឡាយត្រូវលះបង់ទៅ ក្នុងឧបចារខណៈនៃបឋមជ្ឈានយ៉ាងណា វិតក្កៈ និងវិចារៈនឹងត្រូវលះបង់ទៅ ក្នុងឧបចារខណៈនៃទុតិយជ្ឈាននេះ ដូច្នេះ ដូចគ្នាក៏ទេ ព្រោះមិនមែនសភាវៈដែលសៅហ្មង និងព្រោះឧបចារភាវនា មិនអាចនឹងលះបង់ធម៌ ទាំងនោះបាន ។

តណ្ហា ក្នុងវិតក្កៈ និងវិចារៈទាំងនោះ ត្រូវឧបចារភាវនានោះ លះបង់បាន ក៏ពិត សូម្បីយ៉ាងនោះ ក៏មិនមែនជាការលះបង់ដ៏វិសេសនោះឡើយ ។ ការលះបង់ តណ្ហាក្នុងវិតក្កៈ និងវិចារៈនោះ ដែលមានភាពវិសេស រមែងមានបានក្នុងអប្បនា ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា **ក្នុងអប្បនាខណៈនោះឯង** ដូច្នេះ ជាដើម ។

គប្បីជ្រាបនូវ វិតក្កៈនិងវិចារៈ សូម្បីដល់នូវការលះបង់ ទាក់ទងដោយការ លះបង់បានយ៉ាងល្អក្រៃលែងប៉ុណ្ណោះ ដូចជាការលះបង់នូវនីវរណធម៌ទាំងឡាយ ក្នុង អប្បនាខណៈនៃបឋមជ្ឈានដូច្នោះ ។ ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះហេតុ ដែលឈាននេះ មានអង្គ ៣ នោះឯង ។ បទថា **តំ** បានដល់ ពាក្យពោលក្នុង វិភង្គ ។ **សម្បសាទន** ( សេចក្ដីជ្រះថ្លា ) ឈ្មោះថា ជាបរិក្ខារនៃឈាន , មិនបាន

ជាអង្គឈានឡើយ ដូចជាសំពត់កម្ពលលឿង ជាបរិក្ខារនៃរថដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យ ពោលថា **ដើម្បីសម្តែងនូវឈាន ព្រមទាំងបរិក្ខារ** ។

ចប់ទុតិយជ្ឈាន

ក្នុងការអធិប្បាយរបស់មហាដីកា ដោយបរិបូរណ៍

**( ឆត្ថិ សន្តិ បរំ សុខំ )**

# តតិយជ្ឈាន

កាលបានសម្រេចនូវទុតិយជ្ឈាននោះ យ៉ាងនេះហើយ ព្រះយោគាវចរគប្បី ប្រព្រឹត្តឲ្យជាវសី ដោយអាការ ៥ តាមន័យដែលពោលហើយនោះ ចេញចាក ទុតិយជ្ឈាន ដែលថ្នឹកហើយ ( ពិចារណា ) ឃើញទោសក្នុងទុតិយជ្ឈាននោះថា “ សមាបត្តិនេះមានសត្រូវ គឺ វិតក្កវិចារៈនៅជិត ” និងថា សមាបត្តិនេះ នៅមាន អង្គទុព្វល ព្រោះអង្គ គឺ បីតិ ដែលលោកពោលទុកយ៉ាងនេះថា “ ការរីករាយនៃ ចិត្ត ដែលប្រកបដោយបីតិ ក្នុងទុតិយជ្ឈាននោះឯណា ព្រោះការរីករាយនោះ ទុតិ-យជ្ឈាននោះ ទើបលោកពោលថា នៅគ្រោតគ្រាតដូច្នេះ ” ជាអង្គដែលនៅគ្រោត គ្រាត គប្បីធ្វើទុកក្នុងចិត្តដល់តតិយជ្ឈានថា ជាធម៌ល្អិត កាត់បន្ថយសេចក្ដីពេញចិត្ត ក្នុងទុតិយជ្ឈាន ធ្វើយោគៈ (សេចក្ដីព្យាយាម) ដើម្បីសម្រេចតតិយជ្ឈាន (តទៅ) ។

កាលបើព្រះយោគាវចរនោះ ចេញពីទុតិយជ្ឈានហើយ មានសតិសម្បជញ្ញៈ ពិចារណាអង្គឈានទាំងឡាយ បីតិប្រាកដដោយភាពជាអង្គគ្រោតគ្រាត សុខ និង ឯកគ្គតា ប្រាកដជាអង្គល្អិតក្នុងកាលណា ក្នុងកាលនោះ កាលលោកធ្វើទុកក្នុងចិត្ត ហើយរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្មថា **បឋវី បឋវី** ដូច្នេះ ដើម្បីលះអង្គ គ្រោតគ្រាត និងដើម្បីបានអង្គល្អិត ខណៈដែលប្រាកដថា តតិយជ្ឈាននឹងកើតឡើង មនោទ្វារាវជ្ជនៈរមែងកាត់ភវង្គ ធ្វើបឋវីកសិណនោះឯង ឲ្យជាអារម្មណ៍កើតឡើង តអំពីនោះ ជវន ៤ ឬ ៥ ដួង រមែងស្ទុះទៅក្នុងអារម្មណ៍ នោះឯង ហើយដួង មួយក្នុងទីបំផុត ជារូបាវចរចិត្ត ជាតតិយជ្ឈាន ដួងដ៏សេសជាកាមាវចរចិត្ត ដូចន័យ ដែលពោលហើយ( ក្នុងបឋមជ្ឈាន ) នោះឯង ។

ដោយការនានុក្រមត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ព្រោះបីតិប្រាសចាកទៅផង លោកជាអ្នកព្រងើយចម្មតាៗ ផង មានសតិសម្បជញ្ញៈផង សោយសុខដោយកាយផង ដែលព្រះអរិយៈទាំងឡាយពោល (សរសើរ) ថា ជាអ្នកព្រងើយចម្មតាៗ មានសតិ ជាសុខវិហារី (អ្នកមានសតិនៅជាសុខ) ដូច្នេះ ឈ្មោះថា ចូលដល់ឈានទី ៣ ដោយប្រការដូច្នេះ តតិយជ្ឈានបឋវីកសិណ ដែលលះអង្គ ១ ប្រកបដោយអង្គ ២ មានលម្អ ៣ ប្រការ ប្រកបដោយលក្ខណៈ១០ គឺព្រះយោគាវចរនោះ បានសម្រេចហើយ ។

## *អធិប្បាយសេចក្តីនៃ* តតិយជ្ឈានបាឋៈ
## *ពាក្យថា* បីតិយា ច វិរាគា

ក្នុងបាឋៈទាំងឡាយនោះ បាឋៈថា **បីតិយា ច វិរាគា** (ព្រោះបីតិប្រាសទៅ) នោះ មានវិនិច្ឆ័យថា ការនឿយណាយក្នុងបីតិក្តី ការឈានកន្លងបីតិក្តី ឈ្មោះថា **វិរាគ** ( ការប្រាសទៅ ) ឯ **ច** ស័ព្ទ ក្នុងរវាងបទទាំង២ ជាសម្បិណ្ឌនត្ថនិបាត គឺ **ច** ស័ព្ទនោះ បន្ថែមយក **វូបសម** ឬ **វិតក្កវិចារានំ វូបសម** ចូលមកផង ក្នុងអត្ថ ២ យ៉ាងនោះ កាល **ច** ស័ព្ទ បន្ថែមយក **វូបសម** មួយចូលមក គប្បីជ្រាបយោជនា ( ការប្រកបសេចក្តី ) ដូច្នេះថា " ព្រោះបីតិប្រាសទៅផង ព្រោះកាន់តែស្ងប់រម្ងាប់ក្រៃលែងផង " ឯ **វិរាគ** ស័ព្ទ ក្នុងយោជនានេះ មានអត្ថថា នឿយណាយ ព្រោះហេតុនោះគប្បីឃើញថា " ព្រោះធុញទ្រាន់ក្នុងបីតិផង ព្រោះស្ងប់រំងាប់ផង " តែបើ **ច** ស័ព្ទ នោះ សង្គ្រោះយក **វិតក្កវិចារ វូបសម** ស័ព្ទ ចូលមកគប្បីជ្រាបយោជនាដូច្នេះថា " ព្រោះបីតិប្រាសទៅផង ព្រោះវិតក្កវិចារៈកាន់តែស្ងប់

រំងាប់ក្រៃលែងផង " ៦ **វិរាគ** ស័ព្ទ ក្នុងយោជនានេះ មានអត្ថថា ឈានកន្លង ព្រោះហេតុនោះ គប្បីឃើញសេចក្តីនេះថា " **ព្រោះឈានកន្លងបីតិផង ព្រោះវិតក្កវិចារៈស្ងប់ទៅផង** " ។

ដែលពិត វិតក្កវិចារៈទាំងនោះ ស្ងប់រំងាប់ទៅតាំងអំពីទុតិយជ្ឈានម៉្លេះ តែពាក្យនោះ ( នាំមក ) ពោល ( ក្នុងវារៈនៃតតិយជ្ឈានទៀត ) ដើម្បីសម្តែងផ្លូវរបស់ឈាននេះ និងដើម្បីពោលសរសើរឈាននេះផង , មែនពិត កាលបើពោលថា " **ព្រោះវិតក្កវិចារៈស្ងប់រំងាប់ទៅផង** " ដូច្នេះ សេចក្តីថា " ការស្ងប់រំងាប់នៃវិតក្កវិចារៈ ជាផ្លូវនៃឈាននេះមែនពិត " នេះរមែងប្រាកដ ម្យ៉ាងវិញទៀត បើពោលការលះបង់ ( សំយោជនៈ ) ដោយន័យថា ព្រោះលះសំយោជនៈខាងក្រោម ៥ មានសក្កាយទិដ្ឋិជាដើម ដែលសូម្បីមិនមែនទើបតែមកលះក្នុង អរិយមគ្គទី ៣ ដូច្នេះនោះ ជាការដែលលោកសរសើរតតិយជ្ឈាននោះ ញុំាងឧស្សាហៈឲ្យកើតឡើងដល់ព្រះយោគាវចរទាំងឡាយ ដែលព្យាយាមដើម្បីឲ្យបានសម្រេចតតិយជ្ឈាននោះយ៉ាងណា កាលពោលដល់ការស្ងប់រំងាប់ទៅនៃវិតក្កវិចារៈទាំងឡាយ ដែលសូម្បីមិនមែនទើបតែមកស្ងប់រំងាប់ក្នុងតតិយជ្ឈាននេះ នោះ ជាការដែលលោកពោលសរសើរ ( តតិយជ្ឈាននោះ ) ដូច្នោះដូចគ្នា ហេតុនោះ ទើបខ្ញុំព្រះករុណាពោលដូច្នេះថា " **ព្រោះឈានកន្លងបីតិផង ព្រោះវិតក្កវិចារៈ ស្ងប់រំងាប់ទៅផង** " ។

## ពាក្យថា ឧបេក្ខកោ ច វិហរតិ

គប្បីជ្រាបវិនិច្ឆ័យក្នុងបាឋៈថា **ឧបេក្ខកោ ច វិហរតិ** នេះតទៅ :-

ធម្មជាតិម្យ៉ាង ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា សម្លឹងដោយឧបបត្តិ សំដៅ

យកសេចក្ដីថា មើលយ៉ាងស្ងប់ គឺ មើលមិនលំអៀង ចំណែកអ្នកសម្រេចដល់តតិយជ្ឈាន លោកហៅថា **ឧបេក្ខកោ** ព្រោះប្រកបដោយឧបេក្ខានោះ ដែលផូរផង់រុងរឿង និងប្រកបដោយកម្លាំង ។ ឯ **ឧបេក្ខា** មាន **១០** យ៉ាង គឺ :-

**ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា វីរិយុបេក្ខា សង្ខារុបេក្ខា វេទនូបេក្ខា វិបស្សនូបេក្ខា តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខា បរិសុទ្ធុបេក្ខា** ។

ក្នុងឧបេក្ខា ១០ នោះ គឺ :-

**១** - ឧបេក្ខាណា មានអាការដែលមិនលះប្រក្រតីភាព ដែលបរិសុទ្ធក្នុងគន្លងនៃអារម្មណ៍ ៦ ទាំងដែលជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ក្នុងទ្វារទាំង ៦ នៃព្រះខីណាស្រព ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “ ភិក្ខុខីណាស្រព ក្នុងព្រះធម្មវិន័យនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនត្រេកអរ មិនទាស់ចិត្ត និងជាអ្នកមានសតិសម្បជញ្ញៈ នៅដោយឧបេក្ខា ” ដូច្នេះជាដើម ឧបេក្ខានេះ ឈ្មោះថា **ឆឡង្គុបេក្ខា** ( ឧបេក្ខាមានអង្គ ៦ បានដល់ តត្រមជ្ឈត្តតាចេតសិក ) ។

**២** - ឧបេក្ខាណា មានអាការជាកណ្ដាលក្នុងសត្វទាំងឡាយ ដែលមកក្នុងព្រះបាលីយ៉ាងនេះថា “ ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ” ដូច្នេះជាដើម ឧបេក្ខានេះឈ្មោះថា **ព្រហ្មវិហារុបេក្ខា** (គឺតត្រមជ្ឈត្តតាចេតសិក)។

**៣** - ឧបេក្ខាណា មានអាការជាកណ្ដាល ក្នុងសហជាតធម៌ទាំងឡាយដែលមកក្នុងព្រះបាលីថា “ ភិក្ខុចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ ” ដូច្នេះ ជាដើម ឧបេក្ខានេះ ឈ្មោះថា **ពោជ្ឈង្គុបេក្ខា** ( គឺ តត្រមជ្ឈត្តតាចេតសិក ) ។

**៤** - ឧបេក្ខាណា បានដល់ សេចក្ដីព្យាយាមដែលមិនតឹងពេក មិនធូរពេក

ដែលមកក្នុងព្រះបាលីថា " ភិក្ខុធ្វើទុកក្នុងចិត្តដល់ឧបេក្ខានិមិត្តអស់កាល តាមកាលដ៏សមគួរ " ដូច្នេះជាដើម ឧបេក្ខានេះ ឈ្មោះថា **វីរិយុបេក្ខា** ( គឺ វីរិយចេតសិក ) ។

៥ - ឧបេក្ខាណា គឺ វិបស្សនាបញ្ញា ដែលពិចារណាបាបធម៌ និងអន្តដែលគប្បីលះ មាននីវរណធម៌ជាដើម ( ដែលគ្របសង្កត់ទុក និង លះបង់បានដោយឈាន តាមលំដាប់ ឲ្យឃើញតាមសភាវៈ ) ហើយដាក់ចិត្តជាកណ្តាល ក្នុងការកំណត់ ( វត្ថុដែលលះហើយនោះទៀត ព្រោះឃើញទោស ) ដែលមកក្នុងបាលីយ៉ាងនេះថា " សួរថា សង្ខារុបេក្ខាប៉ុន្មាន កើតឡើងហើយដោយអំណាចសមាធិ សង្ខារុបេក្ខាប៉ុន្មាន កើតឡើងដោយអំណាចវិបស្សនា ? ឆ្លើយថា សង្ខារុបេក្ខា ៨ កើតឡើងដោយអំណាចសមាធិ , សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចនៃវិបស្សនា " ដូច្នេះជាដើម ឧបេក្ខានេះ ឈ្មោះថា **សង្ខារុបេក្ខា** ( គឺ បញ្ញា ) ។

៦ - ឧបេក្ខាណា ដែលដឹងថា មិនសុខ មិនទុក្ខ ដែលមកក្នុងព្រះបាលីយ៉ាងនេះថា " ក្នុងសម័យណា ចិត្តជាកាមាវចរកុសលកើតឡើង សហគតៈដោយឧបេក្ខា " ដូច្នេះជាដើម ឧបេក្ខានេះ ឈ្មោះថា **វេទនុបេក្ខា** ( គឺ ឧបេក្ខាវេទនា )។

៧ - ឧបេក្ខាណា មានអាការដែលជាកណ្តាល ក្នុងការសម្លឹងមើល(សង្ខារ) ដែលមកក្នុងព្រះបាលីថា " វត្ថុណាមាន វត្ថុណាកើត ព្រះយោគាវចរលះបង់វត្ថុនោះចោល រមែងបាន ឧបេក្ខា " ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **វិបស្សនូបេក្ខា** ( គឺ បញ្ញា ) ។

៨ - ឧបេក្ខាណា ដែលគ្រប់គ្រងសហជាតធម៌ទាំងឡាយ ឲ្យស្មើគ្នា ដែលមកក្នុងយេវាបនកធម៌ទាំងឡាយ មានឆន្ទៈជាដើម ឧបេក្ខានេះ ឈ្មោះថា **តត្រ-**

**មជ្ឈត្តុបេក្ខា** (គឺ តត្រមជ្ឈត្តតាចេតសិក) ។ ( ធម៌ដែលកើតឡើងមិនប្រាកដប្រជា ហៅថា **យេវាបនកធម៌** មាន ១៦ គឺ :- **ឆន្ទ អធិមោក្ខ ឧបេក្ខា មនសិការ ករុណា មុទិតា សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវ មាន ឥស្សា មច្ឆរិយ ឧទ្ធច្ច កុក្កុច្ច ថីន មិទ្ធ** ) ។

**៩** - ឧបេក្ខាណា ដែលមិនញ៉ាំងការតក់ស្លុត ជាចំណែក ឲ្យកើតឡើងក្នុង តតិយជ្ឈានទោះ ដែលមានសុខដ៏លើស ដែលមកក្នុង ( តតិយជ្ឈានបាឋ: ) យ៉ាង នេះថា " **ឧបេក្ខកោ ច វិហរតិ** លោកមានប្រក្រតីជាកណ្តាល " ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ឈានុបេក្ខា** ( គឺ តត្រមជ្ឈត្តតាចេតសិក ) ។

**១០** - ឧបេក្ខាណា បរិសុទ្ធចាកបច្ចនិកធម៌ទាំងឡាយ ជាអាការដែល មិនខ្វល់ខ្វាយ សូម្បីក្នុងការស្ងប់រំងាប់បច្ចនិកធម៌ដែល ( មកក្នុងចតុត្ថជ្ឈាន ) យ៉ាងនេះថា " **ឧបេក្ខាសតិប្បារិសុទ្ធឹ ចតុត្ថំ ឈានំ**... ចូលដល់ចតុត្ថជ្ឈានដែល មានសេចក្តីបរិសុទ្ធិនៃសតិ ដែលកើតអំពីឧបេក្ខា " ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **បរិសុទ្ធុបេក្ខា** ( គឺ តត្រមជ្ឈត្តតាចេតសិក ) ។

ក្នុងឧបេក្ខា ១០ នោះ ឆឡង្គុបេក្ខា១ ព្រហ្មវិហារុបេក្ខា១ ពោជ្ឈង្គុបេក្ខា១ តត្រមជ្ឈត្តុបេក្ខា ១ ឈានុបេក្ខា ១ បរិសុទ្ធុបេក្ខា ១ ( រួមជា ៦ ) ក៏គឺជា តត្រមជ្ឈុបេក្ខាតែម្យ៉ាង តែដែលឧបេក្ខានោះចែកចេញជាច្រើនប្រភេទ ក៏ព្រោះការ ផ្សេងគ្នានៃឋាន: (ការប្រព្រឹត្តទៅក្នុងសម័យ)នោះៗ ដូចមនុស្សសូម្បីតែម្នាក់ក៏ផ្សេង គ្នាបានដោយឋាន: ដូចជាកុមារ យុវវ័យ មនុស្សធំ ជាសេនាបតី ជាព្រះរាជា ព្រោះហេតុនោះ ក្នុងឧបេក្ខា ៦ នោះ គប្បីជ្រាបថា ឆឡង្គុបេក្ខា កាលមាននៅក្នុង ទីណា ឧបេក្ខា ( ៥ ទៀត ) មានពោជ្ឈង្គុបេក្ខាជាដើម ក៏មិនមានក្នុងទីនោះ ឬថា

ពោជ្ឈង្គុបេក្ខា មាននៅក្នុងទីណា ឧបេក្ខា ( ៥ ទៀត ) មានឆឡង្គុបេក្ខាជាដើម ក៏មិនមានក្នុងទីនោះ ឯការដែលឧបេក្ខា ៦ នោះ មានសភាពដូចគ្នា យ៉ាងណា សូម្បីការដូចគ្នាដោយសេចក្តីនៃ **សង្ខារុបេក្ខា** និង **វិបស្សនូបេក្ខា** ក៏មានដូច្នោះ មែនពិត ឧបេក្ខាទាំង ២ នោះ គឺ បញ្ញាដូចគ្នា តែចែកជា ២ ដោយកិច្ច ដូចមាន ឧបមាថា កាលបុរសកាន់ឈើចម្តាម ស្វែងរកពស់ដែលលូនចូលទៅក្នុងផ្ទះ លុះដល់ពេលល្ងាចបានឃើញវាពួនសំងំ នៅក្រោមអង្ក្រាម ពិនិត្យមើលថា វាជាពស់ ឬ ក៏មិនមែន ឃើញសវស្តិក ( ឆ្នូត ) បី នៅលើក្បាលហើយ ក៏អស់សង្ស័យ ភាពជាកណ្តាលក្នុងការពិនិត្យមើលថា ពស់ ឬមិនមែនពស់ រមែងមានយ៉ាងណា កាលឃើញលក្ខណៈ ៣ ដោយវិបស្សនាញាណហើយ សភាពជាកណ្តាលឯណា ក្នុងការសម្រេចសេចក្តីថា ទៀង ឬ មិនទៀង នៃសង្ខារទាំងឡាយ ជាដើម រមែងកើតឡើងដល់ព្រះយោគាវចរ ដែលចម្រើនវិបស្សនា ក៏យ៉ាងនោះ ដូចគ្នា ភាពជាកណ្តាល ( ក្នុងការសម្លឹងពិនិត្យសង្ខារ ) នេះ ឈ្មោះថា **វិបស្សនូបេក្ខា** ចំណែកដែលបុរសនោះ ចាប់ពស់ទុកដោយឈើចម្តាម ហើយគិតនឹងបោះវាចោលទៅ ដោយមិនបៀតបៀនវាផង មិនឲ្យវាចឹកខ្លួនផង ( ត្រិះរិះ ) រកឧបាយនឹងបោះវាចោលនោះឯង សភាពជាកណ្តាលក្នុងការចាប់ពស់ រមែងមានយ៉ាងណា កាលព្រះយោគាវចរឃើញភព ៣ ដូចត្រូវភ្លើងឆេះ ព្រោះឃើញលក្ខណៈ ៣ ហើយ រមែងមានភាពជាកណ្តាលក្នុងការកំណត់សង្ខារ ភាពជាកណ្តាលនេះ ឈ្មោះថា **សង្ខារុបេក្ខា** ដោយប្រការដូច្នេះ កាលវិបស្សនូបេក្ខាសម្រេចហើយ សូម្បីសង្ខា-រុបេក្ខា ក៏សម្រេចដូចគ្នាដែរ ឧបេក្ខានេះចែកជា ២ ដោយកិច្ច ពោលគឺ ភាពជាកណ្តាលក្នុងការសម្លឹងពិនិត្យសង្ខារ និង ភាពជាកណ្តាលក្នុងការកំណត់សង្ខារ ។

ចំណែក **វីរិយុបេក្ខា** និង **វេទនូបេក្ខា** ផ្សេងពីគ្នាដោយសេចក្តី គឺ ផ្សេងអំពីឧបេក្ខាដទៃទៀត ។

ដោយន័យដូច្នេះ ក្នុងឧបេក្ខាទាំងនេះ ឈានុបេក្ខា លោកបំណងយកក្នុងទីនេះ ឈានុបេក្ខានោះ មានភាពជាកណ្តាលជាលក្ខណៈ មានការមិនគិតត្រិះរិះជារស មានការមិនខ្វល់ខ្វាយជាអាការប្រាកដ មានការប្រាសទៅនៃបីតិជាហេតុជិត។

ក្នុងសេចក្តីនេះមានសំណួរថា “ ឈានុបេក្ខានេះដោយសេចក្តី ក៏គឺ តត្រមជ្ឈត្តុបេក្ខានោះឯង ហើយតត្រមជ្ឈត្តុបេក្ខានោះ ក៏មាននៅសូម្បីក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន មិនមែនឬ ព្រោះហេតុនោះ ឧបេក្ខានេះ ទើបជាសេចក្តីដែលគួរនឹងត្រាស់ដោយបាឋៈថា **ឧបេក្ខកោ ច វិហរតិ** ទុកក្នុងបឋមជ្ឈាន និងទុតិយជ្ឈានខ្លះ ហេតុអ្វី ឧបេក្ខានោះ ទើបមិនបានត្រាស់ទុក ”( ក្នុងឈានទាំង២នោះ ) មានពាក្យឆ្លើយថា “ ព្រោះឧបេក្ខាក្នុងឈានទាំង២នោះ មានកិច្ចនៅមិនទាន់ប្រាកដច្បាស់ពិតណាស់ កិច្ចនៃឧបេក្ខាក្នុងឈានទាំង២នោះ ចាត់ថា នៅមិនទាន់ប្រាកដច្បាស់ព្រោះត្រូវបច្ចនិកធម៌ មានវិតក្កៈជាដើមគ្របសង្កត់ ចំណែកឧបេក្ខាក្នុងតតិយជ្ឈាននេះ ព្រោះវិតក្កវិចារៈនិងបីតិ មិនគ្របសង្កត់ ហាក់ដូចជាងើបក្បាលឡើងបានហើយ ទើបជាធម្មជាតិមានកិច្ចប្រាកដច្បាស់ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ទុក ” ។

ពណ៌នាសេចក្តីយ៉ាងបរិបូរណ៍នៃបាឋៈថា **ឧបេក្ខកោ ច វិហរតិ** នោះ ចប់ហើយ ។

## អធិប្បាយពាក្យថា **សតោ ច សម្បជានោ**

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបាឋៈថា **សតោ ច សម្បជានោ** នេះតទៅ :

ភិក្ខុឈ្មោះថា **សតោ** ព្រោះរឭកបាន , ឈ្មោះថា **សម្បជានោ** ព្រោះដឹងខ្លួនដោយប្រពៃ ( ២ បទនោះគឺ ) **សតិ** និង**សម្បជញ្ញៈ** ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ដល់បុគ្គលក្នុង ២ យ៉ាងនោះ ។ **សតិ** មានការរលឹកបានជាលក្ខណៈ មានការមិនភ្លេចជាកិច្ច មានការរវាំងរក្សា ជាអាការប្រាកដ , **សម្បជញ្ញៈ** មានការមិនវង្វេងជាលក្ខណៈ មានការពិចារណារកខុសត្រូវជាកិច្ច មានការតាមសង្កេត ជាអាការប្រាកដ ។

ក្នុងឈានទាំងនោះ សតិសម្បជញ្ញៈនេះ រមែងមានសូម្បីក្នុងឈានខាងដើមៗ ដោយហោចសូម្បីត្រឹមតែឧបចារៈ ក៏រមែងមិនសម្រេចដល់ភិក្ខុដែលភ្លេចសតិ មិនមានសម្បជញ្ញៈ នឹងនិយាយថ្វីដល់អប្បនា ក៏ពិតហើយ តែថា ព្រោះភាពដែលឈាន( ខាងដើមៗ )ទាំងនោះ នៅគ្រោតគ្រាតនៅឡើយ ការដំណើរទៅនៃចិត្តមានភាពងាយស្រួល ដូចការដែលបុរសដើរទៅលើផែនដីរាបស្មើ រមែងងាយស្រួល ។ កិច្ចនៃសតិសម្បជញ្ញៈនៃឈានទាំងនោះ នៅមិនទាន់ប្រាកដច្បាស់ តែព្រោះតតិយជ្ឈាននេះល្អិត ព្រោះលះអង្គដែលគ្រោតគ្រាតបាន រង់ចាំដំណើរទៅនៃចិត្ត មានសតិសម្បជញ្ញៈទំនុកបម្រុងប៉ុណ្ណោះ ដូចអ្នកដែលដើរទៅលើផែនដី ក្នុងទីរជិបរជុបដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **សតោ សម្បជានោ** ទុកក្នុងតតិយជ្ឈាននេះ ប៉ុណ្ណោះ ។

គប្បីជ្រាបអត្ថាធិប្បាយបន្ថែមទៀតថា កូនគោដែលនៅជាប់តាមមេ ត្រូវព្រាត់ទៅអំពីមេ ហើយមិនមាននរណាចងទុក ក៏រមែងចូលទៅរកមេទៀតនោះឯង យ៉ាងណា សុខក្នុងតតិយជ្ឈាននេះ ដែលត្រូវប្រាសចេញអំពីបីតិហើយ ក៏ដូច្នោះដែរ សុខនោះ ព្រះយោគាវចរមិនរក្សាទុកដោយគ្រឿងរក្សា គឺ សតិសម្បជញ្ញៈ ក៏នឹង

គប្បីចូលទៅកាន់បីតិវិញ ហើយជាឈានសម្បយុត្តដោយ បីតិ ។ ម្យ៉ាងវិញទៀត បណ្ឌិតគប្បីជ្រាបថា បទទាំង២ គឺ **សតោ សម្បជានោ** នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកតែក្នុងតតិយជ្ឈាននេះ ប៉ុណ្ណោះ ដើម្បីសម្តែងអត្ថពិសេសនេះទៀតថា សូម្បីសត្វទាំងឡាយត្រេកអរខ្លាំងក្នុងសេចក្តីសុខ ឯសុខក្នុងតតិយជ្ឈាននេះវិញ ក៏ជាសុខដ៏ក្រៃលែង ព្រោះមិនមានសុខក្រៃលែងជាងនោះ តែការមិនជាប់ចិត្តក្នុងសុខក្នុងតតិយជ្ឈាននេះ រមែងមានបានដោយអានុភាពនៃសតិសម្បជញ្ញៈ មិនមែនដោយប្រការដទៃនោះឡើយ ។

## អធិប្បាយពាក្យថា សុខញ្ច កាយេន បដិសំវេទេតិ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបាឋៈថា **សុខញ្ច កាយេន បដិសំវេទេតិ** នេះតទៅ :-

ការរំពឹងដល់ការសោយសុខ រមែងមិនមានដល់ព្រះយោគាវចរ អ្នកបានតតិយជ្ឈានដោយពិត ហេតុដូច្នោះ ក៏ព្រោះលោកបានសោយសុខ ដែលសម្បយុត្តដោយនាមកាយរបស់លោក ម្យ៉ាងទៀត ព្រោះហេតុដែលរូបកាយរបស់លោកមានអតិបណីតរូប ដែលមានសេចក្តីសុខសម្បយុត្តដោយនាមកាយនោះ ជាសមុដ្ឋានពាល់ត្រូវហើយ ព្រោះរូបកាយនោះ មានអតិបណីតរូបពាល់ត្រូវហើយ សូម្បីចេញចាកឈានហើយ លោកក៏នៅដឹងជាសុខ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់នឹងសម្តែងសេចក្តីនោះ គឺ ( ការសោយសុខដោយនាមកាយ និង រូបកាយទាំង ២ ន័យ ) ទើបទ្រង់ត្រាស់ថា **សុខញ្ច កាយេន បដិសំវេទេតិ** សោយសុខដោយកាយផង ដូច្នេះ ។

## អធិប្បាយពាក្យថា យន្តំ អរិយា ។បេ។ សុខវិហារី

គប្បីជ្រាបវិនិច្ឆ័យក្នុងបាឋៈថា " **យន្តំ អរិយា ។ បេ ។ សុខវិហារី** " នេះតទៅ :-

បណ្ឌិត គប្បីជ្រាបយោជនា ( ការប្រកបសេចក្តី ) ក្នុងបាឋៈនេះ ដូច្នេះថា " ព្រោះតតិយជ្ឈានណាជាហេតុ ព្រោះតតិយជ្ឈានណាជាការណ៍ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងពោលសម្តែង តែងតាំង បើកផ្សាយធ្វើឲ្យរាក់ មានន័យថា ប្រកាសសរសើរដល់បុគ្គលដែលបានតតិយជ្ឈាននោះ សួរថា សរសើរដូចម្តេច ? ឆ្លើយថា សរសើរថា " ជាអ្នកមានភាពជាកណ្តាល មានសតិជាសុខវិហារី ( មានប្រក្រតីនៅជាសុខ ) " នៃព្រះយោគាវចរដែលចូលដល់តតិយជ្ឈាននោះ " ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់សរសើរបុគ្គលអ្នកបានតតិយជ្ឈាននេះ ?

ឆ្លើយថា ព្រោះគួរដល់ការសរសើរ មែនពិត អ្នកបានតតិយជ្ឈាននេះ ព្រោះហេតុជាអ្នកព្រងើយកន្តើយបានក្នុង ( ខណៈ ) នៃតតិយជ្ឈាន ដែលសូម្បីមានសេចក្តីសុខដ៏ត្រជាក់ ដល់ថ្នាក់ជាសុខបារមី ( សុខដែលនាំឲ្យដល់ត្រើយ គឺ និរាមិសសុខដ៏កំពូល ) មិនត្រូវគ្រឿងជាប់ជំពាក់ គឺ សេចក្តីសុខក្នុងតតិយជ្ឈាននោះទាក់ទុកប្រការ ១ , ព្រោះហេតុដែលជាអ្នកឈ្មោះថា មានសតិ ព្រោះមានសតិតាំងមាំ រហូតបីតិកើតឡើងមិនបានប្រការ ១ , ព្រោះហេតុដែលបានសោយសុខដែលមិនសៅហ្មង ជាសុខដែលព្រះអរិយៈពេញចិត្ត និងជាសុខដែលអរិយជនសេពដោយពិត ដោយនាមកាយប្រការ ១ ព្រោះហេតុនោះ ទើបជាអ្នកគួរដល់ការ

សរសើរ បណ្ឌិតគប្បីជ្រាបថា ព្រោះគួរដល់ការសរសើរដូចពោលមកដូច្នេះៗ ព្រះអរិយៈទាំងនោះនឹងប្រកាសគុណ ដែលជាហេតុនៃការគួរសរសើរ ទើបសរសើរបុគ្គលអ្នកបានតតិយជ្ឈាននោះ ថា " ជាអ្នកកណ្តាលស្មើ ៗ មានសតិ ជាសុខវិហារី " ដូច្នេះ ។ បទថា **តតិយំ** គឺ ឈាននេះ ជាទី៣ ព្រោះមានលំដាប់នៃចំនួនខ្វះ ឈ្មោះថា **តតិយ** ព្រោះព្រះយោគាវចរចូលដល់ឈាននេះ ជាទី ៣ ។

ចំណែកពាក្យដែលខ្ញុំព្រះករុណាពោលទុកថា " តតិយជ្ឈានលះអង្គ១ ប្រកបដោយអង្គ២ " ដូច្នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូចតទៅ :-

ការដែលតតិយជ្ឈានលះអង្គ ១ គប្បីជ្រាបដោយការលះបីតិបាន ឯបីតិនេះនោះ លះនៅក្នុងខណៈអប្បនានោះឯង ដូចវិតក្កវិចារៈដែលលះនៅក្នុងខណៈនៃអប្បនារបស់ទុតិយជ្ឈានដូចគ្នា ព្រោះហេតុនោះ បីតិនោះ ទើបហៅថា ជាអង្គសម្រាប់លះ ចំណែកសេចក្តីដែលតតិយជ្ឈានប្រកបដោយអង្គ ២ គប្បីជ្រាបដោយការកើតឡើងនៃអង្គ ២ នេះ គឺ **សុខ ចិត្តេកគ្គតា** ព្រោះហេតុនោះ ពាក្យណាដែលលោកពោលទុកក្នុងវិភង្គថា **ឧបេក្ខា សតិ សម្បជញ្ញ សុខ ឯកគ្គតាចិត្ត** ឈ្មោះថា **ឈាន** ពាក្យនោះ គឺ លោកពោលទុកដោយអម ដើម្បីសម្តែងឈាន ព្រមទាំងបរិក្ខារ តែថា ឈាននេះ វៀរឧបេក្ខា និងសតិសម្បជញ្ញៈហើយ ក៏គង់មានអង្គ ២ ដោយជាអង្គដែលចូលលក្ខណូបនិជ្ឈានដោយត្រង់ ដូចលោកពោលទុកក្នុងវិភង្គថា " សួរថា ក្នុងសម័យនោះ ឈានប្រកបដោយអង្គ ២ គឺ អ្វីខ្លះ ? ឆ្លើយថា ( ឈានប្រកបដោយអង្គ ២ ) គឺ **សុខ១ ឯកគ្គតានៃចិត្ត១** " ដូច្នេះ ។ ពាក្យវិនិច្ឆ័យដ៏សេស មានន័យដូចន័យដែលពោលហើយក្នុងបឋមជ្ឈាន ។

( ចប់ តតិយជ្ឈាន )

# មហាដីកា

## អធិប្បាយ តតិយជ្ឈាន

ពាក្យថា **ភាពរីករាយ** បានដល់ អាការប្រព្រឹត្តទៅនៃបីតិដែលសហគតៈដោយតណ្ហា នៃបុគ្គលដែលមិនលះបង់សេចក្ដីប្រាថ្នា ដែលមិនឃើញទោសក្នុងការប្រកាន់មាំទាំងឡាយ តែក្នុងទីនេះ បំណងយកបីតិក្នុងទុតិយជ្ឈាន ។ សូម្បីយ៉ាងនោះ ក៏ពោលបានថា បីតិនោះ ក៏នៅតែតាមរុំព័ទ្ធវត្ថុ ដែលលះបង់តម្រេកមិនទាន់បានក្នុងបីតិ ដោយប្រការទាំងពួង គឺ ( ទុតិយជ្ឈាន ) ។ម្យ៉ាងទៀត **បីតិ** ឈ្មោះថា សេចក្ដីត្រេកអរ ព្រោះអត្ថថា ជាភាពរីករាយ ។ គប្បីឃើញថា លោកពោលទុកយ៉ាងនេះ ដើម្បីសម្ដែងទោសក្នុងបីតិនោះ ឲ្យកាន់តែប្រាកដច្បាស់ឡើង ។

ភាពប្រាសចាកតម្រេក ឈ្មោះថា **វិរាគ** ។ ដើម្បីសម្ដែងអត្ថទាំង ២ នោះថា ភាពប្រាសចាកតម្រេកនោះ បានដល់ ការតិះដៀលដែលមានការនឿយណាយ ជាប្រមុខក៏បាន បានដល់ ការលះបង់រាគៈដែលទាក់ទងជាមួយនឹងបីតិនោះក៏បាន ដូច្នេះទើបលោកអាចារ្យពោលថា **សេចក្ដីថា ការរង្កៀសក្ដី ការឈានកន្លងក្ដី នូវបីតិដែលមានប្រការដូចពោលហើយដូច្នេះ** ។ ពាក្យថា **ដែលមានប្រការដូចពោលហើយ** គឺដែលមានប្រការដូចពោលហើយ ដោយពាក្យថា **បីតិក្នុងទុតិយជ្ឈាននោះឯង** ដូច្នេះជាដើម ។ ឈ្មោះថា **បន្ថែម** បានដល់ រួម ។ ពាក្យថា **ផ្លូវ** បានដល់ ឧបាយ ។ បទថា **តទធិគមាយ** ដើម្បីសម្រេចមគ្គទី ៣ ។ ពាក្យថា **តាមការឧប្បត្តិ** គឺ តាមសេចក្ដីសមគួរដោយការៈដែលនាំ ( សម្បយុត្តធម៌ ) ទៅស្មើគ្នា ។ សូម្បីឧបេក្ខាក្នុងឈាន ក៏រមែងប្រព្រឹត្តទៅ ធ្វើឲ្យជាការនាំទៅស្មើគ្នាផងដែរ គឺ ឲ្យមានការកម្ចាត់

ទីបំផុត ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ឃើញស្មើគ្នា** ដូច្នេះ ។ ពាក្យថា **ដែលក្លៀវក្លា** គឺ ដែលផូរផង់ ព្រោះការទៅប្រាសហើយនៃសង្កិលេស ។ ពាក្យថា **ដែលបរិបូរណ៍** គឺ ដែលធំក្រៃលែង ព្រោះដល់នូវភាពជាមហគ្គតៈ យ៉ាងល្អក្រៃលែង ។ ពាក្យថា **មានកម្លាំង** គឺ ដល់នូវភាពមាំទាំ ព្រោះការទៅប្រាសហើយនៃបីតិ ។ ឈ្មោះថា **ប្រក្រតីដែលបរិសុទ្ធ** គឺ ប្រក្រតីរបស់ព្រះខីណាស្រព បានដល់ ភាពជាអ្នកមិនមានកិលេស ។ អាការដែលឃើញភាពស្មើគ្នា ក្នុងសត្វទាំង-ឡាយ ដែលមានការឃើញភាវៈនៃសត្វទាំងឡាយ មានកម្មជារបស់ខ្លួន ជាហេតុឈ្មោះថា អាការដែលជាកណ្ដាល ចាត់ជា **ព្រហ្មវិហារុបេក្ខា** ។

បទថា **សហជាតធម្មានំ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា និទ្ធារណៈ ។ **ពោជ្ឈង្គុ-បេក្ខា** មានអាការជាកណ្ដាល ក្នុងសម្បយុត្តធម៌ទាំងឡាយ ដោយមិនមានសេចក្ដីព្យាយាម ក្នុងការផ្គង ការគ្របសង្កត់ និងការធ្វើឲ្យរីករាយ ព្រោះភាវនាប្រព្រឹត្តទៅស្មើល្អ ប្រព្រឹត្តទៅត្រង់តាមវិថីហើយ មិនរួញរា មិនរាយមាយ និងប្រកបដោយសេចក្ដីរីករាយ ។

ក្នុងពាក្យថា **ឧបេក្ខានិមិត្ត** បានដល់ ឧបេក្ខា គឺ សេចក្ដីព្យាយាមដែលវៀរចាកនូវភាពធូរថយ និងរាយមាយ មានភាពជាកណ្ដាល ។ សេចក្ដីព្យាយាមនោះឯងឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា ដែលព្រះយោគី រមែងព្រងើយ ក្នុងវេលានៃការចម្រើនឧបេក្ខានិមិត្ត ប្រព្រឹត្តទៅស្មើល្អ ព្រោះភាពដែលវីរិយៈនោះ ព្រះយោគីបានកំណត់ដោយអាការនោះ ធ្វើឲ្យប្រព្រឹត្តទៅដូច្នោះ ជានិមិត្ត , **ឧបេក្ខា** គឺ **វីរិយៈ** ឈ្មោះថា **វីរិយុបេក្ខា** ។

**សង្ខារុបេក្ខា ៨** ទាំងនេះ ដែលមកហើយ យ៉ាងនេះថា “ **បញ្ញា** គឺ ការ

ពិចារណានូវនីវរណៈ ដើម្បីជាប្រយោជន៍ដល់ការបានមកនូវបឋមជ្ឈាន ហើយក៏នៅជាកណ្ដាល ឈ្មោះថា ញាណក្នុងសង្ខារុបេក្ខា ណាមួយ.... , បញ្ញា គឺ ការពិចារណា អាកិញ្ចញ្ញាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបានមកនូវនេវសញ្ញា-នាសញ្ញាយតនសមាបត្តិ ហើយនៅដោយភាពជាកណ្ដាល ឈ្មោះថា ញាណក្នុងសង្ខារុបេក្ខា ណាមួយ " ដូច្នេះ ឈ្មោះថា កើតឡើងដោយអំណាចសមាធិ ។

**សង្ខារុបេក្ខា ១០** ទាំងនេះ ដែលមកហើយយ៉ាងនេះ ថា " បញ្ញាដែលពិចារណា ឧប្បាទៈ បវត្ត និមិត្ត អាយូហនៈ បដិសន្ធិ គតិ និព្វត្តិ ឧប្បត្តិ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ឧបាយាសៈ ដើម្បីប្រយោជន៍ដល់ការបានមកនូវសោតាបត្តិមគ្គ ហើយនៅដោយភាពជាកណ្ដាល ឈ្មោះថា ញាណក្នុងសង្ខារុបេក្ខា ណាមួយ.... , បញ្ញាដែលពិចារណា ឧប្បាទៈ..... ឧបាយាសៈ ដើម្បីប្រយោជន៍ដល់ការចូលសោតាបត្តិផលសមាបត្តិ... , បញ្ញាដែលពិចារណាឧប្បាទៈ ... ឧបាយាសៈ ដើម្បីប្រយោជន៍ដល់ការបានមកនូវអរហត្តមគ្គ ដើម្បីប្រយោជន៍ដល់ការចូលអរហត្តផលសមាបត្តិ ... ដើម្បីប្រយោជន៍ដល់ការចូលសុញ្ញតវិហារ-សមាបត្តិ ... ដើម្បីប្រយោជន៍ដល់ការចូលអនិមិត្តវិហារសមាបត្តិ ហើយនៅដោយភាពជាកណ្ដាល ឈ្មោះថា **ញាណក្នុងសង្ខារុបេក្ខា** ណាមួយ " ដូច្នេះ ឈ្មោះថា កើតឡើងដោយអំណាចវិបស្សនា ។

ក្នុងបណ្ដាឧបេក្ខាទាំងនេះ ការពិចារណា គឺ ចូលទៅសង្កេតដោយសភាវៈដែលធម្មជាតិទាំងឡាយមាន នីវរណៈ វិតក្កៈ វិចារៈ ជាដើម ដែលគ្របសង្កត់ទុកដោយបឋមជ្ឈានជាដើម ហើយតាំងមាំ ដោយអំណាចការឃើញច្បាស់នូវទោសឈ្មោះថា ការពិចារណាធម្មជាតិទាំងឡាយ មាននីវរណៈជាដើម ហើយនៅដោយ

ភាពជាកណ្ដាល វិបស្សនាបញ្ញាដែលជាកណ្ដាល ក្នុងការដែលនឹងកំណត់ គឺ ក្នុងការដែលនឹងលើកសង្ខារទាំងនោះឡើង ព្រោះបានឃើញទោសហើយ ឈ្មោះថា ឧបេក្ខាដែលជាកណ្ដាល ក្នុងការដែលនឹងកំណត់ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ឧប្បាទ** លោកពោលដល់ការកើតឡើងនៃខន្ធទាំងឡាយក្នុងភពនេះ ព្រោះកម្មក្នុងភពមុនជាបច្ច័យ ។ ពាក្យថា **បវត្ត** បានដល់ការប្រព្រឹត្តទៅរបស់ខន្ធដែលកើតឡើងហើយនោះឯង ។ ពាក្យថា **និមិត្ត** បានដល់សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ព្រោះប្រាកដដោយភាពជានិមិត្ត ។

ពាក្យថា **អាយូហន** បានដល់ កម្មដែលជាហេតុនៃបដិសន្ធិក្នុងភពតទៅ ។ ពាក្យថា **បដិសន្ធិ** បានដល់ ការកើតឡើងក្នុងភពតទៅ ។ ពាក្យថា **គតិ** បានដល់គតិដែលមានបដិសន្ធិ ។ ពាក្យថា **និព្វត្តិ** បានដល់ ការកើតឡើងនៃខន្ធទាំងឡាយ ។ ពាក្យថា **ឧប្បត្តិ** បានដល់ ការប្រព្រឹត្តទៅនៃវិបាក ដែលព្រះសារីបុត្តពោលទុកថា ក្នុងពាក្យថា " របស់បុគ្គលអ្នកចូលសមាបត្តិក្តី របស់បុគ្គលចូលដល់ក្តី " ដូច្នេះនេះ បានដល់ ការប្រព្រឹត្តទៅនៃវិបាក ដែលកើតឡើងហើយ ដូច្នេះ ។ ពាក្យថា **ជាតិ** បានដល់ ជាតិដែលមានព្រោះភពជាបច្ច័យ ដែលជាបច្ច័យដល់ជរាជាដើម ។

ជរា ព្យាធិ មរណៈ ជាដើម ក៏ច្បាស់ហើយដែរ ។ ក្នុងបណ្ដាធម៌ទាំងនេះ ធម៌ ៥ យ៉ាង មានឧប្បាទៈជាដើមប៉ុណ្ណោះ ដែលលោកពោលទុក ដោយទាក់ទងជាអារម្មណ៍នៃសង្ខារុបេក្ខាញាណ ធម៌ដ៏សេស លោកពោលទុកដោយទាក់ទងជាពាក្យវេវចនៈនៃធម៌ ៥ យ៉ាងនោះ ។ ពិតណាស់ គប្បីជ្រាបថា ពាក្យថា " **និព្វត្តិ ជាតិ** " ២ ពាក្យនេះ ជាពាក្យវេវចនៈនៃពាក្យថា **ឧប្បាទៈ** និងនៃពាក្យថា **បដិ-សន្ធិ** ។ ពាក្យថា " **គតិ ឧប្បត្តិ** " ២ ពាក្យនេះ ជាវេវចនៈនៃពាក្យថា **បវត្ត** ។

ពាក្យថា **ផរា** ជាដើម ជាពាក្យវេវចនៈនៃពាក្យថា **និមិត្ត** ។ សង្ខារុបេក្ខា មាន ១០ យ៉ាង នេះ គឺ **សង្ខារុបេក្ខា** ដែលជាហេតុកើតឡើងនៃមគ្គ ដោយទាក់ទងជាមួយអប្បណិហិតវិមោក្ខ មាន ៤ , **សង្ខារុបេក្ខា** ជាហេតុ នៃការចូលផលសមាបត្តិ ក៏មាន ៤ ដូចគ្នា , **សង្ខារុបេក្ខា** ដែលទាក់ទងជាមួយសុញ្ញតវិហារ និង អនិមិត្តវិហារ មាន ២ ។

បទថា **យា** បានដល់ វិបស្សនាបញ្ញា ។ ពាក្យថា **វត្ថុណាមាន** មានន័យថា លក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើមណា មានហើយ ។ ពាក្យថា **វត្ថុណាកើត** មានន័យថា វត្ថុណា គឺ ខន្ធ ៥ កើត ព្រោះកើតឡើងហើយដោយបច្ច័យ ។ ពាក្យថា **រមែងលះបង់វត្ថុនោះ** មានន័យថា កាលលះបង់នូវអនិច្ចសញ្ញាជាដើម ដោយអនិច្ចានុបស្សនាជាដើម ក៏ឈ្មោះថា រមែងលះបង់ ដោយការលះនូវឆន្ទរាគៈ ដែលទាក់ទងជាមួយវត្ថុនោះ ព្រោះបានឃើញទោសដោយប្រពៃហើយនោះឯង មានន័យថា រមែងលះបង់ដោយការបដិបត្តិ ដោយប្រការដែលមិនមានការប្រកាន់មាំតទៅ ។ ព្រះយោគាវចរនោះ ទើបបានមកនូវឧបេក្ខាក្នុងវត្ថុនោះ ។ ពាក្យថា **ក្នុងការដែលសម្លឹងពិនិត្យ** គឺ សូម្បីក្នុងការពិចារណាដោយទាក់ទងថា ជារបស់មិនទៀងជាដើម ។

ឈ្មោះថា ជាធម្មជាតិធ្វើធម៌ដែលកើតរួមគ្នាទាំងឡាយ ឲ្យប្រព្រឹត្តទៅស្មើគ្នា ជាហេតុដល់ការប្រព្រឹត្តទៅស្មើគ្នានៃសម្បយុត្តធម៌ទាំងឡាយ ។ ឈ្មោះថា បរិសុទ្ធចាកធម៌ដែលជាសត្រូវទាំងឡាយ ក៏ព្រោះការផុតចាកធម៌ជាសត្រូវទាំងពួង មាន នីវរណៈ វិតក្កៈ វិចារៈ ជាដើម ។ ឈ្មោះថា **ជាការមិនព្យាយាម សូម្បីក្នុងការស្ងប់ធម៌ជាសត្រូវ** គឺ ប្រព្រឹត្តទៅ ដោយការៈដែលមិនមានសេចក្តីព្យាយាម ឬ

ដល់នូវសេចក្ដីមិនព្យាយាម ព្រោះស្ងប់ធម៌ជាសត្រូវ ទាំងនោះបានហើយ ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើឧបេក្ខាទាំងនេះដូចគ្នាដោយសភាវៈសោត ភាពផ្សេងគ្នាបែបនេះនឹងមានបានដូចម្ដេចវិញ ដូច្នេះហើយ ទើបពោលថា " **តេន តេន** " ដូច្នេះជាដើម ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះហេតុសូម្បីមានសេចក្ដីមិនផ្សេងគ្នាដោយសភាវៈ តែថា ឧបេក្ខាទាំងនេះមានសេចក្ដីផ្សេងគ្នានៃឋានៈនេះ ដោយបច្ច័យផ្សេងៗ គ្នាពួកណា ព្រោះបច្ច័យពួកនោះ មិនប្រព្រឹត្តទៅព្រមគ្នា ឧបេក្ខាទាំងនោះ នឹងឈ្មោះថា មានការមិនផ្សេងគ្នា ក៏មិនបាន ឬថានឹងមានការប្រព្រឹត្តទៅព្រមគ្នាបានក៏ទេ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក្នុងទីណាមានឆឡង្គុបេក្ខា ដូច្នេះជាដើម ។

បទថា **ឯកីភាវោ** ប្រែថា ភាពតែមួយ ។ សេចក្ដីថា សូម្បីថា នឹងមានភាពជាកណ្ដាលដូចគ្នា តែថា បញ្ហានេះ គង់មានភាពផ្សេងគ្នា តាមការផ្សេងគ្នានៃអារម្មណ៍ ។ លោកអាចារ្យពោលថា " ដែលបែកគ្នាជា ២ យ៉ាង ព្រោះទាក់ទងដោយកិច្ច " ដូច្នេះ សំដៅយកសេចក្ដីអធិប្បាយណា កាលនឹងសម្ដែងសេចក្ដីអធិប្បាយនោះដោយពិស្ដារ ទើបពោលថា " ប្រៀបដូចជា " ដូច្នេះ ជាដើម ។

**វិបស្សនូបេក្ខានេះ** បានដល់ ឧបេក្ខាដែលទ្រង់សំដៅយក ត្រាស់ទុកក្នុងព្រះបាលីថា " **វត្ថុណាមាន វត្ថុណាកើត រមែងលះបង់វត្ថុនោះ ទើបបានមកនូវឧបេក្ខានេះ** " ។ ក្នុងបាឋៈព្រះបាលីនោះ ពាក្យថា **វត្ថុណាមាន វត្ថុណាកើត** បានដល់ ខន្ធ ៥ ។ រមែងលះបង់ខន្ធ ៥ នោះ ដោយមុញ្ចិតុកម្យតាញាណ ។ ដែលបានមកនូវឧបេក្ខា ក្នុងការដែលពិនិត្យពិចារណានូវលក្ខណៈសង្ខារនៃខន្ធ ៥ ដែលកើតឡើងហើយ ដែលបានឃើញត្រៃលក្ខណ៍ហើយ ដូចបានមកនូវភាពជា

កណ្តាល ក្នុងការដែលពិចារណាមើលលក្ខណៈរបស់ពស់ ដែលបានឃើញប្រឡៅផ្កាច័ន្ទហើយដូច្នោះ ។

កាលសម្រេចនូវវិបស្សនូបេក្ខា ដែលជាកណ្តាល ក្នុងការពិចារណាសង្ខារទាំងនោះ ព្រោះការបានឃើញហើយដោយល្អ នូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើម នៃសង្ខារទាំងឡាយ ភាពជាកណ្តាលក្នុងការនឹងកំណត់ សង្ខារទាំងនោះដែលបានឃើញទោសហើយយ៉ាងនោះ គឺ ជាការបានសម្រេចផងដែរ ព្រោះអធ្យាស្រ័យ មានការបង្អោនទៅកាន់វិសង្ខារ ដោយប្រការទាំងពួង ។

ពាក្យថា **មានការមិនរំពឹងដល់ ជារស** មានន័យថា មានភាពជាបដិបក្ខចំពោះការបង្អោនចិត្តទៅ សូម្បីក្នុងសុខដ៏ប្រណីតនោះ ជាកិច្ច ។ ពាក្យថា **មានការមិនព្យាយាមជាបច្ចុប្បដ្ឋាន** មានន័យថា សូម្បីមានការដល់នូវសុខជាបារមី ក៏ប្រាកដជាធម្មជាតិដែលមិនខ្វល់ខ្វាយក្នុងសុខនោះ ឬថា ញុំាងសេចក្តីមិនព្យាយាមក្នុងសុខនោះ ឲ្យប្រាកដដល់សម្បយុត្តធម៌ ។ **កិច្ច** នៃតត្រមជ្ឈត្តុបេក្ខា ក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ ឈ្មោះថា មិនទាន់ជំនាញ ព្រោះត្រូវធម៌ទាំងឡាយមានវិតក្កៈជាដើម នាំមកនូវភាពកម្រើក និងភាពត្រេកអរនៃសម្បយុត្តធម៌ទាំងឡាយគ្របសង្កត់ ។ **កិច្ច** ក្នុងតតិយជ្ឈាននេះ ជាធម្មជាតិជំនាញ ព្រោះមិនមានសភាវៈនោះ ។

ចប់ពាក្យពណ៌នាបាឋៈថា “ **ឧបេក្ខកោ ច វិហរតិ** ” នេះ ដោយប្រការទាំងពួង ។

លោកពោលដល់កត្តុសាធនៈនៃបទថា “ **សរតីតិ សតោ** ” ដូច្នេះ ។

បទថា **សម្បជានាតិ** ប្រែថា ដឹងច្បាស់ដោយប្រពៃ ។ ការរលឹកបាន គឺ

ការគិត ការចូលទៅតាំងទុក ជាលក្ខណៈរបស់សតិ ព្រោះហេតុនោះ សតិនេះទើបឈ្មោះថា មានការរលឹកបាន ជាលក្ខណៈ ។ សភាវៈដែលជាបដិបក្ខចំពោះការភ្លេច ឈ្មោះថា ការមិនភ្លេច ជាកិច្ចរបស់សតិ ព្រោះហេតុនោះ សតិនេះទើបឈ្មោះថា មានការមិនភ្លេច ជាកិច្ច ។ សតិ រមែងប្រាកដជាធម្មជាតិដែលរក្សាចិត្ត (ឲ្យនៅឆ្ងាយ) ពីកិលេសទាំងឡាយ ឬថា ញុំាងសេចក្ដីរក្សាចិត្ត (ឲ្យនៅឆ្ងាយ) ពីកិលេសទាំងឡាយនោះ ឲ្យប្រាកដ ព្រោះហេតុនោះ ទើបឈ្មោះថា មានការរក្សាទុក ជាបច្ចុប្បដ្ឋាន ។ ការមិនវង្វេង គឺ ការដឹងច្បាស់បាន ដោយប្រពៃ ឬថា បានដល់ សភាវៈដែលជាបដិបក្ខចំពោះការវង្វេង ឈ្មោះថា ការមិនវង្វេង ។ ឈ្មោះថា **ការពិចារណា** (តីរណៈ) បានដល់ ការដល់ត្រើយនៃកិច្ច ។ ឈ្មោះថា ការតាមសង្កេត បានដល់ ពិចារណាវិភាគ ។

សូម្បីបឋមជ្ឈាន និងទុតិយជ្ឈាន ប្រៀបធៀបជាមួយនឹងឧបចារជ្ឈានជាដើមហើយ ចាត់ថាល្អិតក៏ពិត សូម្បីយ៉ាងនោះ ព្រោះប្រៀបធៀបជាមួយឈានជាន់ខ្ពស់ជាងនេះ ទើបលោកអាចារ្យពោលថា ព្រោះឈានទាំងនោះគ្រោតគ្រាត ។ ភាពជាឈានគ្រោតគ្រាតនោះ បណ្ឌិតគប្បីជ្រាបបាន ដោយភាពជាឈានដែលមានអង្គគ្រោតគ្រាត មានវិតក្កៈជាដើម ។ អាចារ្យពួកខ្លះពោលថា “ ជាឈានដែលមានចេតសិកច្រើន ” ដូច្នេះ ក៏មាន ។ អធិប្បាយថា ឈ្មោះថា មានការប្រព្រឹត្តទៅបានស្រួលក្នុងឈានទាំងនោះ ។ ឈ្មោះថា ជាកិច្ចរបស់សតិ និងសម្បជញ្ញៈក្នុងឈានខាងដើមៗ នោះ នៅមិនទាន់ជំនាញ ព្រោះកិច្ច ដែលគប្បីពោលបានថា “ រមែងធ្វើកិច្ចដែលធ្វើបានដោយលំបាកនេះ ” ដូច្នេះ មិនមាន ។ ពាក្យថា **ព្រោះឈាននេះល្អិត ក៏ដោយការលះអង្គគ្រោតគ្រាតបាន** មានអត្ថន័យដូច្នេះ , សតិ និង

សម្បជញ្ញៈ រមែងកើតសូម្បីក្នុងទុតិយជ្ឈានបានក៏ពិត សូម្បីយ៉ាងនោះ ក្នុងតតិយ-ជ្ឈាននេះ ការព្យាយាមរបស់សតិ និងសម្បជញ្ញៈ មានភាពល្អក្រៃលែង ព្រោះជាឈានល្អិតដោយការលះអង្គគ្រោតគ្រាត ពោលគឺ បីតិ , ក្នុងបណ្ដាបីតិ និងសុខដោយច្រើន ប្រព្រឹត្តទៅដោយភាវៈមិនបែកគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បុរិសស្ស** ដូច្នេះជាដើម ។

ពាក្យថា **នឹងចូលទៅកាន់បីតិនោះទៀត** គឺ នឹងជាហានភាគិយជ្ឈាន (ឈានដែលមានចំណែកវិនាស) មានន័យថា នឹងចូលដល់ទុតិយជ្ឈាននោះវិញ ។ ព្រោះហេតុនោះ ទើបលោកពោលថា "គប្បីជាសុខដែលសម្បយុត្តជាមួយបីតិ នោះឯង" ដូច្នេះ ។ ពាក្យថា " **ហើយសុខនេះ មានរសដ៏ក្រៃលែង** " លោកពោលសំដៅយកសុខក្នុងតតិយជ្ឈាន ។ បណ្ឌិតគប្បីជ្រាបថា សុខនេះ មានរសប្រណីតក្រៃលែង ក៏ព្រោះមិនមានបីតិ ដែលមានភាពរីករាយជាសភាវៈ ។

បទថា **ឥទំ** បានដល់ ២ បទដែលថា " **សតោ សម្បជានោ** " ។

ពាក្យថា **ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្ដែងសេចក្ដីនេះ** ប្រកបសេចក្ដីថា ព្រោះហេតុព្រះយោគីដែលដល់ព្រមដោយឈាននោះ គប្បីសោយសុខដែលសម្បយុត្តជាមួយនាមកាយណា ព្រះយោគីនោះ គប្បីសោយសុខនោះ ។ ន័យម្យ៉ាងទៀត បទថា **យំ វា តំ** បានដល់ សុខដែលសម្បយុត្តជាមួយនាមកាយតាមដែលពោលហើយនោះឯណា ព្រោះហេតុដែលរូបកាយ របស់ព្រះយោគីដែលព្រមព្រៀងដោយឈាននោះ ត្រូវរូបដែលប្រណីតក្រៃលែង ដែលមានសុខនោះជាសមុដ្ឋាន គឺ តាំងឡើងអំពីសុខនោះ ពាល់ត្រូវហើយ និងព្រោះរូបកាយ ត្រូវរូបដ៏ប្រណីតពាល់ត្រូវហើយ ព្រះយោគីដែលព្រមព្រៀងដោយឈាន សូម្បីថា ចេញ

ចាកឈានហើយ ក៏គប្បីសោយសុខផ្លូវកាយបាន ដូច្នោះ ព្រះដ៏មានព្រះភាគកាល ទ្រង់សម្ដែងន័យ ពោលគឺ ការសោយសុខផ្លូវចិត្ត និងផ្លូវកាយ សេចក្ដីនេះ ទើបទ្រង់ត្រាស់ថា " **សុខញ្ច កាយេន បដិសំវេទេតិ** " ដូច្នេះ ។

ក៏សេចក្ដីសង្ខេបក្នុងពាក្យថា **សុខញ្ច កាយេន បដិសំវេទេតិ** នេះ មានដូច្នេះថា ទ្រង់ត្រាស់ថា ព្រះយោគីដែលព្រមព្រៀងដោយឈាន រមែងសោយសុខផ្លូវចិត្តដោយនាមកាយ និងសុខផ្លូវកាយដោយការធ្វើរូបដែលជាហេតុ នៃសុខផ្លូវកាយឲ្យតាំងឡើងដូច្នេះ ។ ពាក្យថា **ព្រោះរូបកាយ ត្រូវអតិបណីតរូប ពាល់ត្រូវហើយ** មានន័យថា ព្រោះរូបកាយ ត្រូវរូបដ៏ប្រណីតក្រៃលែងផ្សាយទៅហើយ ។ ប្រៀបដូចរាងកាយដែលត្រូវទឹកស្រោចស្រពហើយ កាលផោដ្ឋព្វារម្មណ៍ មានខ្យល់ជាដើម ពាល់ត្រូវ គឺ មិនខ្វាំងពេក បក់ផាត់ត្រូវហើយ ក៏រមែងកើតសេចក្ដីសុខឡើង យ៉ាងណា រីឯរាងកាយ ដែលត្រូវរូបដ៏ប្រណីតទាំងនោះ ពាល់ត្រូវហើយ ក៏យ៉ាងនោះឯង ។

ន័យម្យ៉ាងទៀត ក្នុងពាក្យចោទសួរថា ក្នុងពាក្យថា រមែងសោយសុខដោយកាយផងនេះ ការសោយសុខដោយវៀរចាកការត្រិះរិះដល់ នឹងមានដូចម្ដេច ? មានសេចក្ដីថា " ព្រះយោគាវចរ ដែលព្រមព្រៀងដោយឈាន មិនមានការត្រិះរិះដល់ការសោយសុខក៏ពិត សូម្បីយ៉ាងនេះ " ។ ប្រកបសេចក្ដីថា ព្រោះហេតុដែលសុខរបស់លោកសម្បយុត្តដោយនាមកាយ ដូច្នោះ ទើបសោយសុខដោយកាយផងដូច្នេះ ។ ឥឡូវនេះដើម្បីសម្ដែងដល់ការសោយសុខ សូម្បីព្រមជាមួយការត្រិះរិះ ទើបលោកពោលថា **យំ វា តំ** ជាដើម ។

បទថា **យំ** ជានិបាត ក្នុងអត្ថថា **ហេតុ** មានន័យស្មើគ្នានឹង **យស្មា** ។

ព្រោះហេតុនោះ ទើបលោកពោលថា **ព្រោះហេតុនៃឈានណា** ដូច្នេះ ។ ព្រោះមានអធិប្បាយថា បទថា **អាចិក្ខន្តិ** ( រមែងពោលដល់ ) ជាដើម ។ មានអត្ថថា **សរសើរ** ទើបលោកអាចារ្យពោលថា អធិប្បាយថា **រមែងសរសើរ** ។ ពាក្យថា **សរសើរថាយ៉ាងណា** ជាពាក្យសួរដល់ អាការសរសើរ ។ ក្នុងឋានៈដូច្នេះ ដោយស័ព្ទថា សតិនោះឯង ក៏ជាការកាន់យកសម្បជញ្ញៈផងដែរ តែព្រោះក្នុងបាលីនេះ ទ្រង់កាន់យកចំពោះសតិប៉ុណ្ណោះ ទើបលោកអាចារ្យពោលថា **ជាអ្នកមានសតិ** ដោយការចូលទៅតាំងសតិទុក ដោយប្រការដែលបីតិនឹងមិនកើតឡើង ។ ម្យ៉ាងទៀត ក្នុងព្រះបាលី ទ្រង់កាន់យកចំពោះសតិ ព្រោះទ្រង់ត្រាស់ទុកខាងក្រោយហើយថា **សម្បជានោ** ដឹងច្បាស់ដោយប្រពៃ ដូច្នេះ ។

ក្នុងខណៈនៃឈាន រមែងបានសុខផ្លូវចិត្តប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកពោលថា **រមែងសោយសុខដោយនាមកាយ** ដូច្នេះ ។ ចាប់តាំងអំពីពាក្យថា **បទថា តតិយ មានន័យថា ឈ្មោះថា តតិយ ( ទី ៣ ) ក៏តាមលំដាប់នៃការរាប់**នេះទៅ គឺ លោកពោលដល់ការមិនដូចគ្នា និងការដូចគ្នាទៅអំពីកថា ដែលលោកពោលដោយទុតិយជ្ឈាន និងតតិយជ្ឈាន ដូច្នេះ ។

មហាដីកា

តតិយជ្ឈាន ចប់ដោយបរិបូណ៌

# ចតុត្ថជ្ឈាន

*កាលបើបានសម្រេចតតិយជ្ឈាននោះ យ៉ាងនេះហើយ ព្រះយោគាវចរគប្បីប្រព្រឹត្តឲ្យជាវសី ដោយអាការ ៥ តាមន័យដែលបានពោលហើយនោះឯង ចេញចាកតតិយជ្ឈានដែលស្ទាត់ជំនាញហើយ (ពិចារណា) ឃើញទោសក្នុងតតិយជ្ឈាននេះថា “ សមាបត្តិនេះមានសត្រូវ គឺ បីតិនៅជិតនៅឡើយ ” និងថា “ សមាបត្តិនេះមានអង្គនៅទុព្វល ព្រោះ (អង្គគឺ)* ***សុខ*** *ដែលលោកពោលទុកយ៉ាងនេះថា ការរំពឹងនៃចិត្តថា* ***សុខ*** *ក្នុងតតិយជ្ឈាននោះណា ព្រោះការរំពឹងនោះ តតិយជ្ឈាននេះទើបលោកពោលថា នៅគ្រោតគ្រាត ” ដូច្នេះ (ដោយ) មានអង្គដែលគ្រោតគ្រាតទើបធ្វើទុកក្នុងចិត្តដល់ចតុត្ថជ្ឈានថា ជាធម៌ល្អិត ក៏លះបង់នូវការពេញចិត្តក្នុងតតិយជ្ឈាន ធ្វើនូវយោគៈដើម្បីសម្រេចនូវចតុត្ថជ្ឈាន ( តទៅ )..... ។*

*កាលបើព្រះយោគាវចរនោះចេញអំពីតតិយជ្ឈានហើយ មានសតិសម្បជញ្ញៈពិចារណាអង្គឈានទាំងឡាយ ។* ***សុខ*** *ពោលគឺ សោមនស្ស ជាចេតសិកសុខប្រាកដជាអង្គគ្រោតគ្រាត* ***ឧបេក្ខាវេទនា*** *និង* ***ចិត្តេកគ្គតា*** *ប្រាកដជាអង្គល្អិត ក្នុងកាលណា ក្នុងកាលនោះ កាលលោកធ្វើទុកក្នុងចិត្តរឿយៗ ហើយបរិកម្មនូវនិមិត្តនោះឯង ដោយបរិកម្មថា* ***បឋវី បឋវី*** *ដូច្នេះ ដើម្បីលះអង្គគ្រោតគ្រាត និង ដើម្បីបានអង្គល្អិត ខណៈដែលប្រាកដថា ចតុត្ថជ្ឈាននឹងកើត មនោទ្វារាវជ្ជនៈ រមែងកាត់ផ្តាច់ភវង្គ ធ្វើបឋវីកសិណនោះឯង ឲ្យជាអារម្មណ៍កើតឡើង តអំពីនោះ ជវន ៤ ឬ ៥ ដួង រមែងកើតក្នុងអារម្មណ៍នោះឯង ដែលមានដួងមួយក្នុងទីបំផុត ជារូបាវចរចិត្ត គឺ* ***ចតុត្ថជ្ឈាន*** *, ដួងដ៏សេស ជាកាមាវចរចិត្ត មានប្រការដូចពោល*

ហើយ ( ក្នុងបឋមជ្ឈាន ) នោះឯង តែសេចក្តី ( តទៅនេះ ) ជាការប្លែក ( អំពីការពោលហើយមុនៗ ) ពីព្រោះហេតុដែលសុខវេទនាជាបច្ច័យ ជាអាសេវនប្បច្ច័យនៃអទុក្ខមសុខវេទនាមិនបាន ដែលអទុក្ខមសុខវេទនាត្រូវកើតឡើងក្នុងចតុត្ថជ្ឈាននោះឯង ព្រោះហេតុនោះ ជវន ( ក្នុងអប្បនាវិថី ) ទាំងនោះ ទើបជាចិត្តសម្បយុត្តដោយឧបេក្ខាវេទនា ក៏ព្រោះសម្បយុត្តដោយឧបេក្ខានោះឯង បីតិក្នុងឈាននោះ ក៏វិនាសអស់ទៅ ។

ដោយការនានុក្រមត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ព្រោះលះសុខផង ព្រោះលះទុក្ខផង ព្រោះសោមនស្ស ទោមនស្សរលត់បាត់ទៅមុនហើយ ឈ្មោះថាចូលដល់ឈានទី ៤ ដែលមិនមានទុក្ខ មិនមានសុខ មានភាពបរិសុទ្ធិនៃសតិដែលកើតអំពីឧបេក្ខា ដោយប្រការដូច្នេះ ចតុត្ថជ្ឈានបឋវីកសិណដែលលះអង្គ ១ ប្រកបដោយអង្គ ២ មានលម្អ ៣ ប្រការ ប្រកបព្រមដោយលក្ខណៈ ១០ គឺថា ព្រះយោគាវចរនោះ បានសម្រេចហើយ ។

## ពន្យល់អត្ថនៃ ចតុត្ថជ្ឈានបាឋៈ

( ពន្យល់ពាក្យថា **សុខស្ស ច បហានា ។បេ។ អត្ថង្គមា** )

ក្នុងបាឋៈទាំងនោះ បាឋៈថា **ព្រោះលះសុខផង លះទុក្ខផង** នោះគឺ ព្រោះលះកាយិកសុខ និងកាយិកទុក្ខផង ។ បទថា **មុនហើយ** សំដៅសេចក្តីថា ការលះនោះឯង មានមករួចហើយ មិនមែនទើបតែមានក្នុងខណៈនៃចតុត្ថជ្ឈាន (នេះទេ) ។ ពាក្យថា **ព្រោះសោមនស្ស និងទោមនស្សរលត់បាត់ទៅ** មានន័យថា ធម៌ទាំងពីរនេះគឺ ចេតសិកសុខ និង ចេតសិកទុក្ខផង រលត់បាត់ទៅ ក៏អធិប្បាយបានថា បាន

លះបង់ស្រេចហើយ តាំងអំពីខណៈមុននោះឯង សួរថា ការលះទៅនៃធម៌ទាំងនោះ មានក្នុងខណៈណា ? ឆ្លើយថា មានក្នុងឧបចារខណៈនៃឈានទាំង ៤ , មែនពិត សោមនស្ស លះបង់បានក្នុងឧបចារខណៈនៃចតុត្ថជ្ឈាននោះឯង ទុក្ខ ទោមនស្ស និងសុខ លះបង់បានក្នុងឧបចារខណៈនៃ បឋមជ្ឈាន ទុតិយជ្ឈាន និងតតិយជ្ឈាន (តាមលំដាប់) ការលះសុខ ទុក្ខ សោមនស្ស ទោមនស្ស ក្នុងចតុត្ថជ្ឈានបាឋៈនេះ ទ្រង់មិនបានត្រាស់ទុកតាមលំដាប់នៃការលះបង់ធម៌ទាំងនោះឡើយ តែក៏បានត្រាស់ទុកតាមលំដាប់ឧទ្ទេសនៃឥន្ទ្រិយ ក្នុងឥន្ទ្រិយវិភង្គហើយ ( ក្នុងឥន្ទ្រិយវិភង្គទ្រង់បានត្រាស់តាមលំដាប់ថា **សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ** ) បណ្ឌិតគប្បីជ្រាបតាមន័យដូចពោលមកនេះចុះ ។

សួរថា បើអង្គទាំងនោះលះបង់បានស្រេចហើយ តាំងអំពីឧបចារខណៈនៃឈាននោះៗ កាលបើដូច្នោះ ហេតុអ្វី ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់និរោធក្នុងឈានតែមួយ យ៉ាងនេះថា :

> **ទុក្ខិន្ទ្រិយ ដែលកើតឡើងហើយ រមែងរលត់ទៅមិនមានសេសសល់ក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះស្ងាត់ចាកកាមទាំងឡាយ ។ល។ ចូលដល់ឈានទី ១ ទុក្ខិន្ទ្រិយ ដែលកើតឡើងហើយ រមែងរលត់ទៅ មិនមានសេសសល់ក្នុងទីនេះ ទោមនស្សិន្ទ្រិយ.....សុខិន្ទ្រិយ.... សោមនស្សិន្ទ្រិយ... ដែលកើតឡើងហើយ រមែងរលត់ទៅ មិនមានសេសសល់ក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ព្រោះលះបង់សុខផង ។ល។ ចូលដល់ឈាន ទី ៤ សោមនស្សិន្ទ្រិយដែល**

**កើតឡើងហើយ រមែងរលត់ទៅ មិនមានសេសសល់ក្នុងទីនេះ**

ដូច្នេះទៅវិញ ?

ឆ្លើយថា ព្រោះនិរោធក្នុងឈានទាំងនោះៗ **ជាអតិសយនិរោធ** ( រលត់ស្អិទ្ធ ) មែនពិត ការរលត់នៃអង្គទាំងនោះ ក្នុងតួឈាន មានបឋមជ្ឈានជាដើម ជា**អតិសយនិរោធ** ជានិរោធសាមញ្ញក៏ទេ ចំណែកការរលត់ក្នុងឧបចារៈខណៈ **ជានិរោធសាមញ្ញ** មិនមែនជាអតិសយនិរោធទេ ។ ពិតហើយ ការកើតឡើងនៃទុក្ខិន្ទ្រិយ សូម្បីរលត់ទៅក្នុងឧបចារៈនៃបឋមជ្ឈាន ដែលជានានាវជ្ជនៈហើយ ក៏គប្បីមាន ព្រោះសម្ផស្ស មានរបោម និងមូសជាដើមខ្លះ ព្រោះការចុកស្រពន់ ដែលកើតពីទីអង្គុយមិនរាបស្មើខ្លះ តែថា ក្នុងអប្បនាមិនមានឡើយៗ

ន័យម្យ៉ាងទៀត ទុក្ខិន្ទ្រិយនោះ សូម្បីរលត់ទៅក្នុងឧបចារៈហើយ ក៏ឈ្មោះថាមិនទាន់រលត់ដោយល្អ ព្រោះទុក្ខនោះ មានបដិបក្ខធម៌ ( គឺ សុខ ) ដែលមិនទាន់បានកម្ចាត់ឲ្យអស់ទៅ តែថា ក្នុងអប្បនា សព៌ាង្គកាយ ( របស់ព្រះយោគាវចរ ) មានសភាពឈានចុះកាន់សេចក្តីសុខហើយ ព្រោះការជ្រួតជ្រាបទៅនៃបីតិ ដែលទុក្ខិន្ទ្រិយរបស់អ្នកដែលមានកាយឈានចុះកាន់សេចក្តីសុខហើយ រមែងរលត់ទៅដោយល្អ ព្រោះទុក្ខនោះ ត្រូវបដិបក្ខធម៌ ( គឺ សុខ ) កម្ចាត់បង់ហើយ ។

មួយវិញទៀត ការកើតនៃទោមនស្សិន្ទ្រិយ ដែលសូម្បីរលត់ទៅហើយ ក្នុងឧបចារៈនៃទុតិយជ្ឈាន ដែលជានានាវជ្ជនៈដូចគ្នា ក៏គប្បីមានបាន ព្រោះហេតុដែលទោមនស្សិន្ទ្រិយនោះ កាលសេចក្តីនឿយកាយ និងសេចក្តីនឿយចិត្ត ដែលមានវិតក្កវិចារៈជាបច្ច័យមាននៅ ក៏រមែងកើតឡើង និងព្រោះមិនមានវិតក្កវិចារៈ វានឹងមិនកើតឡើងឡើយ ។

មួយវិញទៀត វិតក្កវិចារៈក្នុងឧបចារៈនៃទុតិយជ្ឈាន រាប់ថានៅមិនទាន់បាន លះបង់នៅឡើយទេ ព្រោះទោមនស្សិន្ទ្រិយ កើតឡើងក្នុងទីណា ក៏មានវិតក្កវិចារៈ ក្នុងទីនោះ ព្រោះហេតុនោះ ការកើតឡើងនៃទោមនស្សិន្ទ្រិយ ទើបគប្បីមានបានក្នុង ឧបចារៈនៃទុតិយជ្ឈាននោះ តែក្នុង (អប្បនា) ទុតិយជ្ឈាន មិនមាន ព្រោះលះបង់ បច្ច័យ ( គឺ វិតក្កវិចារៈ ) បានហើយ ។

ន័យដូចគ្នានេះដែរ ការកើតឡើងនៃសុខិន្ទ្រិយ ដែលសូម្បីលះទៅហើយក្នុង ឧបចារៈនៃតតិយជ្ឈាន ក៏នឹងមានដល់ព្រះយោគាវចរអ្នកមានកាយ ដែលបណីតរូប មានបីតិជាសមុដ្ឋាន សម្ផស្សហើយ តែក្នុង ( អប្បនា ) តតិយជ្ឈាន មិនមាន ព្រោះ ក្នុង (អប្បនា) តតិយជ្ឈាន បីតិដែលជាបច្ច័យនៃសុខរលត់ទៅហើយ ដោយប្រការ ទាំងពួង ។

ន័យដូចគ្នានេះដែរ ការកើតឡើងនៃសោមនស្សិន្ទ្រិយ ដែលសូម្បីលះបង់ទៅ ហើយ ក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏នៅមានបាន ព្រោះសោមនស្សិន្ទ្រិយនោះ នៅ ជិតប្រការ១ ព្រោះនៅមិនទាន់កន្លងទៅដោយល្អ ព្រោះហេតុថា ឧបេក្ខានៅមិនទាន់ ដល់អប្បនាប្រការ១ តែក្នុង (អប្បនា) ចតុត្ថជ្ឈាន រមែងមិនមាន ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើអបរិសេសស័ព្ទ (ប្រកបទុក) ក្នុងព្រះបាលីជាដើមថា **ឯត្ថុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ** ទុក្ខិន្ទ្រិយដែលកើត ឡើងហើយ រមែងរលត់ទៅមិនមានសេសសល់ក្នុងទីនេះ ដោយប្រការដូច្នេះឯង ។

ក្នុងអធិការនេះ អ្នកប្រាជ្ញអធិប្បាយ ( បុច្ឆាវិសជ្ជនា ) ទុកថា សួរថា កាល បើដូច្នោះ វេទនាទាំងនេះ សូម្បីថាលះបង់ទៅហើយ ក្នុងឧបចារៈនៃឈាននោះ ៗ ហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបទ្រង់ប្រមូលមកត្រាស់ក្នុងចតុត្ថជ្ឈាននេះ (ទៀតទៅ

វិញ) ? ឆ្លើយថា ដើម្បីឲ្យងាយយល់ ព្រោះអទុក្ខមសុខវេទនានេះ ដែលទ្រង់ត្រាស់ទុកក្នុងបាឋៈថា **អទុក្ខមសុខំ** នោះ អទុក្ខមសុខវេទនានោះ ជាធម្មជាតិសុខុម ដឹងបានលំបាក មិនអាចចាប់យកបានដោយងាយ ព្រោះហេតុនោះ ព្រះដ៏មាន-ព្រះភាគ ទើបទ្រង់ប្រមូលវេទនាទាំងអស់នោះមក ( ត្រាស់ទុកក្នុងចតុត្ថជ្ឈាន ) ដើម្បីឲ្យយល់សេចក្តីបានងាយស្រួល ប្រៀបដូចនាយគោបាល កៀងគោទាំងអស់ចូលទុកក្នុងក្រោលមួយ ដើម្បីនឹងចាប់គោ ( មួយដែលជាគោកាច ) ដែលនរណាៗ មិនអាចចូលចាប់ផ្តេសផ្តាសបាន ឲ្យបានដោយងាយ កាលស្រេចហើយ ក៏ព្រលែងចេញតែឯង នឹងចង្អុលឲ្យមនុស្សចាប់វានោះឯង ដែលមកតាមក្រោយ ថា នេះគោមួយនោះ ពួកលោកចូរចាប់វាចុះ សេចក្តីនេះយ៉ាងណា កាលទ្រង់សម្តែងវេទនាទាំងនោះ ដែលប្រមូលទុកយ៉ាងនេះហើយ ក៏ទ្រង់អាចញ៉ាំងព្រះយោគាវចរ ឲ្យកំណត់អទុក្ខមសុខវេទនា នោះថា **ភាវៈណា មិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្ស** នោះគឺ **អទុក្ខមសុខវេទនា** ។

ន័យម្យ៉ាងទៀត គប្បីជ្រាបថា វេទនាទាំងឡាយនោះ ព្រះដ៏មានព្រះភាគ ជាម្ចាស់ត្រាស់ទុកដើម្បី សម្តែងបច្ច័យនៃចេតោវិមុត្តិ ដែលជាអទុក្ខមសុខផងក៏បាន ។ ពិតណាស់ អាការទាំងឡាយ មានការលះបង់ទុក្ខជាដើម ជាបច្ច័យនៃចេតោវិមុត្តិ ដែលជាអទុក្ខមសុខនោះ ដូចព្រះធម្មទិន្នាថេរីពោល (ជាមួយវិសាខៈឧបាសក) ថា អាវុសោ បច្ច័យនៃចេតោវិមុត្តិសមាបត្តិ ដែលជាអទុក្ខមសុខ មាន ៤ ប្រការ យ៉ាងនេះ **ភិក្ខុក្នុងធម្មវិន័យនេះ ព្រោះលះសុខផង ។ ល ។ ចូលដល់ឈានទី ៤** នេះឯង អាវុសោ បច្ច័យ ៤ ប្រការ នៃចេតោវិមុត្តិសមាបត្តិ ដែលជាអទុក្ខមសុខ។ ( **អទុក្ខមសុខចេតោវិមុត្តិ** គឺ ចតុត្ថជ្ឈាន , **បច្ច័យ ៤ ប្រការ** គឺ លះសុខ ១ លះ

ទុក្ខ ១ លះសោមនស្ស ១ លះទោមនស្ស ១ ) ។

ឬន័យម្យ៉ាងទៀត គប្បីជ្រាបថា វេទនាទាំងនោះ ព្រះអង្គត្រាស់ទុកក្នុងចតុត្ថជ្ឈានេះ ដើម្បីសរសើរឈាននោះក៏បាន ប្រៀបដូចឱរម្ភាគិយសំយោជនៈ មានសក្កាយទិដ្ឋិជាដើម សូម្បីលះបង់បាន ( ចំណែកក្រោម ) ហើយ ក្នុងមគ្គដទៃ តែទ្រង់ត្រាស់ថា លះបង់ក្នុងតតិយមគ្គ ( ទាំងអស់ ) ក៏ដើម្បីសរសើរតតិយមគ្គនោះដូច្នេះ ។

ឬន័យម្យ៉ាងទៀត គប្បីជ្រាបថា វេទនាទាំងនោះ ទ្រង់ត្រាស់ដើម្បីសម្តែងភាពដែល រាគៈ ទោសៈ ក្នុងឈាននោះ នៅឆ្ងាយក្រៃលែង ព្រោះ ( ឈាននោះ ) កម្ចាត់ចោលបាននូវបច្ច័យ ( របស់វា ) ក៏បាន ពិតណាស់ ក្នុងវេទនាទាំងនោះ សុខជាបច្ច័យនៃសោមនស្ស សោមនស្សជាបច្ច័យនៃរាគៈ ទុក្ខជាបច្ច័យនៃទោមនស្ស ទោមនស្សជាបច្ច័យនៃទោសៈ ក៏ព្រោះឈាននោះ កម្ចាត់វេទនា មានសុខជាដើមចោលបាន រាគៈ ទោសៈ ព្រមទាំងបច្ច័យ ក៏កម្ចាត់ទៅបាន ព្រោះដូច្នោះ រាគៈ ទោសៈ ទើបឈ្មោះថា **នៅឆ្ងាយក្រៃលែង** យ៉ាងនេះ ។

## អធិប្បាយ អទុក្ខមសុខំ

បាឋៈថា **អទុក្ខមសុខំ** មានវិនិច្ឆ័យថា ឈាននេះ ឈ្មោះថា **អទុក្ខ** ព្រោះមិនមានទុក្ខ ឈ្មោះថា **អសុខ** ព្រោះមិនមានសុខ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងវេទនាទី ៣ ដែលជាបដិបក្ខនៃទុក្ខ និងសុខ ដោយពាក្យនោះ មិនមែនទ្រង់សម្តែងត្រឹមតែការមិនមានទុក្ខ និងសុខ ក្នុងឈាននេះ ដែលវេទនាទី ៣ លោកហៅថា អទុក្ខមសុខវេទនាខ្វះ ( ហៅថា ឧបេក្ខាវេទនាខ្វះ វេទនាទី ៣ នោះ បណ្ឌិតគប្បី

ជ្រាបថា មានការសោយអារម្មណ៍ខុសអំពីឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាលក្ខណៈ មានភាពជាកណ្ដាលជារស មានអាការមិនច្បាស់ជាបច្ចុប្បដ្ឋាន មានសុខនិរោធ (សុខរលត់) ជាបទដ្ឋាន ។

## អធិប្បាយ ឧបេក្ខាសតិចារិសុទ្ធិ

បាឋៈថា **ឧបេក្ខាសតិបារិសុទ្ធឹ** ប្រែថា មានសេចក្តីបរិសុទ្ធិនៃសតិដែលឧបេក្ខាឲ្យកើត ព្រោះថា សតិក្នុងឈាននេះបរិសុទ្ធល្អ ឯសេចក្តីបរិសុទ្ធិនៃឈាននោះ ឯណា សេចក្តីបរិសុទ្ធិនោះ ឧបេក្ខាបង្កើតឡើង មិនមែនវត្ថុដទៃបង្កើតឡើងទេ ព្រោះហេតុនោះ ឈាននេះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា **ឧបេក្ខាសតិបារិសុទ្ធិ**( មានសេចក្តីបរិសុទ្ធិនៃសតិដែលឧបេក្ខាឲ្យកើត ) ។ ក្នុងវិភង្គពោលទុកថា សតិនេះជាធម្មជាតិប្រាកដច្បាស់ បរិសុទ្ធផូរផង់ ព្រោះឧបេក្ខានេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ឧបេក្ខាបារិសុទ្ធិ** ( មានភាពបរិសុទ្ធនៃសតិ ព្រោះឧបេក្ខា ) ។ សេចក្តីបរិសុទ្ធិនៃសតិក្នុងឈាននេះ រមែងមានព្រោះឧបេក្ខាណា ឧបេក្ខានោះ បណ្ឌិតគប្បីជ្រាបថា ដោយសេចក្តី គឺ **តត្រមជ្ឈត្តតា** មួយវិញទៀត មិនមែនតែសតិមួយប៉ុណ្ណោះ ដែលបរិសុទ្ធព្រោះឧបេក្ខានោះ ក្នុងឈាននេះ ដោយពិត សូម្បីសម្បយុត្តធម៌ទាំងពួង ក៏បរិសុទ្ធទៅផងដែរ តែទ្រង់ទេសនាដោយ(លើក)សតិជាប្រធានក្នុងឈានទាំងនោះ ឧបេក្ខានេះរមែងមានសូម្បី ក្នុងឈាន ៣ ខាងក្រោមផង ក៏ពិតហើយ តែថា ប្រៀបដូចចន្ទលេខា ( គ្រឿងសម្គាល់ក្នុងវង់ព្រះចន្ទ ) សូម្បីថាមាននៅក្នុងពេលថ្ងៃ ក៏គ្មានពន្លឺភ្លឺស្វាង ព្រោះត្រូវពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ គ្របសង្កត់ប្រការ ១ ព្រោះមិនបានរាត្រីដែលជាសភាគៈគ្នា ដោយភាពត្រជាក់ ( គឺពន្លឺ

ស្រទន់ដូចគ្នា ) ឬ ដោយភាពដែលរាត្រីជួយជ្រោមជ្រែងខ្លួនប្រការ ១ យ៉ាងណា សូម្បីចន្ទលេខា គឺ តត្រមជ្ឈត្តុបេក្ខានេះក៏ដូច្នោះ សូម្បីថាមានហើយ ក៏មិនបរិសុទ្ធ ក្នុងឈានប្រភេទដទៃ មានបឋមជ្ឈានជាដើម ព្រោះត្រូវអានុភាពនៃបច្ចនិកធម៌ មាន វិតក្កៈជាដើម គ្របសង្កត់ប្រការ ១ ព្រោះមិនបានរាត្រី គឺ ឧបេក្ខាវេទនាដែលជា សភាគៈគ្នាប្រការ ១ និងកាលឧបេក្ខានោះ មិនបរិសុទ្ធហើយ សូម្បីសហជាតធម៌ ទាំងឡាយ មានសតិជាដើម ក៏មិនបរិសុទ្ធទៅតាមគ្នា ដូចពន្លឺរបស់ចន្ទលេខាដែល មិនភ្លឺស្វាងក្នុងពេលថ្ងៃ ក៏រមែងមិនច្បាស់ដូចគ្នា ព្រោះហេតុនោះ ក្នុងឈានខាង ក្រោមទាំង ៣ នោះ ទើបទ្រង់មិនត្រាស់ថា **ឧបេក្ខាសតិបារិសុទ្ធិ** សូម្បីណាមួយ តែក្នុងចតុត្ថជ្ឈាននេះ ចន្ទលេខា គឺ តត្រមជ្ឈត្តុបេក្ខានេះ បរិសុទ្ធក្រៃលែង ព្រោះ មិនមានអានុភាពនៃបច្ចនិកធម៌ មានវិតក្កៈជាដើម គ្របសង្កត់ និងព្រោះបានរាត្រី គឺ ឧបេក្ខាវេទនាដែលជាសភាគៈគ្នាផង ព្រោះឧបេក្ខានោះបរិសុទ្ធហើយ សូម្បី សហជាតធម៌ទាំងឡាយ មានសតិជាដើម ក៏បរិសុទ្ធផូរផង់ទៅផងដែរ ដូចពន្លឺចន្ទ-លេខាដែលភ្លឺស្វាង ដូច្នោះ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបចុះថា ចតុត្ថជ្ឈាននេះ ប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា **ឧបេក្ខាសតិបារិសុទ្ធិ** ។

បទថា **ចតុត្ថំ** គឺ ឈាននេះជាទី ៤ ព្រោះមានលំដាប់នៃចំនួន កន្លែងខ្លះថា ឈ្មោះ **ចតុត្ថ** ព្រោះព្រះយោគាវចរចូលដល់ឈាននេះជាទី ៤ ។

ចំណែកពាក្យណា ដែលខ្ញុំម្ចាស់ពោលទុកថា ចតុត្ថជ្ឈានលះអង្គ ១ ប្រកប ដោយអង្គ ២ បណ្ឌិតគប្បីជ្រាបអត្ថាធិប្បាយក្នុងពាក្យនោះតទៅ ការដែលចតុត្ថជ្ឈាន លះអង្គ ១ គប្បីជ្រាបដោយការលះ **សោមនស្ស** ឯសោមនស្សនោះ លះបង់បាន ហើយ ក្នុងជវនខាងដើមៗ ក្នុងវិថីតែមួយ ព្រោះដូច្នោះ សោមនស្សនោះ ទើបហៅថា

**បហានង្គ** ( អង្គដែលគប្បីលះ ) ។ ចំណែក ចតុត្ថជ្ឈានប្រកបដោយអង្គ ២ គប្បីជ្រាបដោយការកើតឡើងនៃអង្គ ២ នេះ គឺ **ឧបេក្ខាវេទនា** និង **ចិត្តេកគ្គតា** ពាក្យដ៏សេស មានន័យដូចពោលហើយនៅក្នុងបឋមជ្ឈាន នេះជាន័យក្នុងចតុកឈាន ( ឈានពួក ៤ ) ។

( ចប់ ចតុត្ថជ្ឈាន )

# មហាដីកា

## កថាពណ៌នា ចតុត្ថជ្ឈាន

ឥឡូវនេះ កាលនឹងសម្តែង សេចក្តីដែលផ្សេងគ្នា ដែលធ្វើឲ្យកើតឡើង លោកអាចារ្យពោលថា **ចំណែកតទៅនេះ ជាសេចក្តីដែលប្លែកតទៅ** ហើយទើបពោលថា **ព្រោះហេតុដែល**..... ដូច្នេះជាដើម ។ ឈ្មោះថា រមែងមិនជាបច្ច័យដោយអាសេវនប្បច្ច័យ ព្រោះក្នុងឋានៈដែលមិនគួរប្រាថ្នា សុខវេទនាមិនមានភាពជាអាសេវនប្បច្ច័យ ដល់ធម៌ដែលសង្គ្រោះចូលដោយបទដទៃឡើយ ។ ឈ្មោះថា អទុក្ខមសុខវេទនាគប្បីកើតឡើង ព្រោះភាពជាការនាំដែលលះសុខបានយ៉ាងល្អក្រៃលែង ។ ពាក្យថា **ជវនទាំងនោះ** លោកពោលសំដៅយកជវនទាំងឡាយ ក្នុងអប្បនាវិថី ។ ព្រោះបានពោលហើយថា ក្នុងកាលមុននោះឯង ដូច្នេះ ក្នុងពាក្យសួរថា ក្នុងវេលាណាវិញ ទើបមានការលះធម៌ទាំងនោះ ទើបលោកអាចារ្យ ឆ្លើយថា ក្នុងឧបចារខណៈនៃឈាន ៤ ដូច្នេះ ។ ក្អប់សេចក្តីថា **ឯវំ វេទិតព្វំ** ។

ឈ្មោះថា **លំដាប់នៃការលះ** បានដល់ លំដាប់នៃការកើតឡើង នៃធម៌ទាំងឡាយដែលជាអ្នកលះ ។ ព្រោះហេតុនោះ កាលនឹងពោលដល់លំដាប់នៃការលះ គួរនឹងពោលថា **ទុក្ខ ទោមនស្ស សុខ សោមនស្ស** ដូច្នេះ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់ទុកដោយប្រការដទៃអំពីលំដាប់នៃការលះនេះទៅវិញ ដូច្នេះហើយ ទើបពោលថា **ឥន្ទ្រិយវិភង្គេ** ដូច្នេះជាដើម ។ ក្តាប់សេចក្តីថា កាលបើដូច្នោះ ព្រោះហេតុអ្វីទើបទ្រង់ត្រាស់ ការរលត់ ទុកក្នុងឈានទាំងឡាយនោះឯងដូច្នេះ ។

ពាក្យថា **ទុក្ខិន្ទ្រិយដែលកើតឡើងហើយ រមែងរលត់ទៅមិនមានសេសសល់ក្នុងទីណា** សេចក្តីថា ទ្រង់ត្រាស់សួរដល់ស្ថានទីរលត់ ថា **ទុក្ខិន្ទ្រិយ** ដែលកើតឡើងហើយ អំពីបច្ច័យទាំងឡាយរបស់ខ្លួន រមែងរលត់ទៅ មិនមានសេសសល់ក្នុងទីណាដូច្នេះ ។ ដោយពាក្យនោះ ក្នុងពាក្យបុច្ឆាថា **កត្ថ** ក្នុងទីណា សូម្បីក្នុងពាក្យវិសជ្ជនាថា **ឯត្ថ** ក្នុងទីនេះ , គប្បីឃើញថា ជាសត្តមីវិភត្តិ ក្នុងអត្ថថា ហេតុ ( គឺ ក្នុងពាក្យថា **កត្ថ** - ក្នុងទីណា , សំដៅសេចក្តីថា ព្រោះធម៌អ្វី , ពាក្យថា **ឯត្ថ** - ក្នុងទីនេះ , សំដៅសេចក្តីថា ព្រោះធម៌នេះ ) ។ ទុក្ខិន្ទ្រិយដែលនៅមិនទាន់កើតឡើង ព្រោះអានុភាពរបស់ឈានជាហេតុ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា **ទុក្ខិន្ទ្រិយរមែងរលត់ទៅ មិនមានសេសសល់** ឈ្មោះថា **រលត់បានយ៉ាងប្រពៃ** គឺ ការលះបង់ដោយល្អ បានដល់ ការចូលទៅស្ងប់នូវធម៌ ដែលជាបដិបក្ខ ដោយត្រង់ ។

ពាក្យថា **ដែលមានអាវជ្ជនៈផ្សេងៗគ្នា** មានន័យថា អប្បនាវិថី មានបានដោយអាវជ្ជនៈណា ឧបចារៈក៏មានអាវជ្ជនៈផ្សេងអំពីអាវជ្ជនៈនោះ ឬថា ឧបចារៈ

មានច្រើនអាវជ្ជនៈ ។ ពិតណាស់ ឧបចារៈក្នុងអប្បនាវិថី មានអាវជ្ជនៈតែ ១ ឧបចារៈក្រៅអំពីនេះ មានអាវជ្ជនៈច្រើន ព្រោះប្រព្រឹត្តទៅច្រើនវារៈ ។ ការស្ពឹកស្រពន់ដែលកើតឡើង ព្រោះការអង្គុយលើទីមិនរាបស្មើ ឈ្មោះថា ការឈឺចាប់ដែលកើតអំពីទីអង្គុយមិនរាបស្មើ ។ លោកពោលថា **ព្រោះការផ្សាយទៅនៃបីតិ** ដូច្នេះ ព្រោះបីតិមានការផ្សាយទៅជារស ឬ ព្រោះរូបដែលប្រណីត ដែលមានបីតិជាសមុដ្ឋាន ជ្រួតជ្រាបក្នុងរាងកាយ ។ ព្រោះដូច្នោះ ទើបលោកពោលថា **សព្វាង្គកាយឈានចុះកាន់សេចក្ដីសុខ** ដូច្នេះ ។ **បិ** ស័ព្ទ ក្នុងពាក្យថា **វិតក្កវិចារបច្ចយេបិ** លោកប្រកបទុកឲ្យខុសទី , គប្បីនាំយក **បិ** ស័ព្ទនោះ ចូលមកភ្ជាប់ក្នុងបទថា **បហីនស្ស** នេះជា “ **បហីនស្សបិ ទោមនស្សិន្ទ្រិយស្ស** ” **ទោមនស្សិន្ទ្រិយ** សូម្បីថា ត្រូវលះទៅហើយ ដូច្នេះចុះ ។ ភ្ជាប់សេចក្ដីថា **ឯតំ ទោមនស្សិន្ទ្រិយំ ឧប្បជ្ជតិ** ។

គប្បីជ្រាបដល់ការលំបាកកាយ និងការរួញរានៃចិត្ត មានវិតក្កៈ និងវិចារៈជាបច្ច័យ ដោយព្រះពុទ្ធវចនៈដែលត្រាស់ថា **តស្ស មយ្ហំ អតិចិរំ វិតក្កយតោ វិចារយតោ កាយោបិ កិលមិ ចិត្តម្បិ ឧហញ្ញិ** កាលតថាគត នោះកំពុងត្រិះរិះអស់វេលាដ៏យូរក្រៃលែង ក៏លំបាកកាយ ទាំងចិត្តក៏រួញរាដូច្នេះ ។ គប្បីនាំបទមកសម្ព័ន្ធគ្នាថា **វិតក្ក វិចារភាវេ ឧប្បជ្ជតិ ទោមនស្សិន្ទ្រិយំ** ។ ច្រើនបទថា **តត្ថស្ស សិយា ឧប្បត្តិ** ប្រែថា ទោមនស្សិន្ទ្រិយនេះ គប្បីមានការកើតឡើងបាន ក្នុងរវាងឧបចារខណៈនៃទុតិយជ្ឈាននោះ ។

ក្នុងរឿងនេះ ប្រសិនបើអាចារ្យពួកមួយនឹងពោលថា លោកអាចារ្យ កាលនឹងពោលថា **ទោមនស្សិន្ទ្រិយនេះ គប្បីមានការកើតឡើងបាន ក្នុងរវាងឧបចារខណៈ**

**នៃទុតិយជ្ឈាននោះ** ដូច្នេះ ក៏រមែងជាការដែលលោកសម្តែងថា បុគ្គលសូម្បីជាឈានលាភី ក៏នៅមានការកើតឡើងនូវទោមនស្សបាន និងដោយពាក្យនោះ លោកសម្តែងថា សូម្បីទោសៈដែលមិនមានសភាវៈជានីវរណៈ ក៏នៅមាន ដូចគ្នានឹងលោភៈ ។ ព្រោះវៀរចាកទោសៈ ទោមនស្សក៏កើតឡើងមិនបាន ។ ក្នុងរឿងនេះមិនត្រូវគិតដល់ការខុសជាមួយនឹងព្រះបាលីបដ្ឋានទេ ។ ព្រោះក្នុងព្រះបាលីបដ្ឋាននោះ ទ្រង់សម្តែងទោមនស្សដែលកើតឡើង ធ្វើឈានដែលវិនាសហើយ ឲ្យជាអារម្មណ៍ ព្រោះទោមនស្សដែលកើតឡើង ធ្វើឈានដែលមិនទាន់វិនាសឲ្យជាអារម្មណ៍ មិនមាន ។ ម្យ៉ាងទៀត នរណា ៗ ក៏មិនអាចនឹងពោលថា ទោមនស្សនឹងមិនកើតឡើងដល់បុគ្គលដែលបានឈាន ដោយប្រការទាំងពួងដូច្នេះបាន ព្រោះទោមនស្សនោះ នៅកើតឡើងដល់បុគ្គល សូម្បីអ្នកបានសមាបត្តិ ៨ បាន ។ ក៏គេនោះជាអ្នកមានឈានវិនាសហើយ ក៏ទេ ដូច្នេះចម្លើយថា ពាក្យរបស់អាចារ្យពួកមួយនោះ មិនត្រឹមត្រូវ ព្រោះទោសៈដែលគ្មានភាពជានីវរណៈ មិនមានឡើយ។ ប្រសិនបើថាមាន ទោសៈក៏គប្បីកើតឡើងបាន សូម្បីដល់ពួករូបាវចរសត្វ តែថាកើតឡើងមិនបាន ។

ពិតយ៉ាងនោះ ក្នុងព្រះបាលីថា ក្នុងអរូប **ថីនមិទ្ធនីវរណ ឧទ្ធច្ចនីវរណ អវិជ្ជានីវរណ** អាស្រ័យកាមច្ឆន្ទនីវរណៈកើតឡើង ដូច្នេះជាដើម ក៏មិនបានទ្រង់លើកយកព្យាបាទនីវរណៈ និងកុក្កុច្ចនីវរណៈ ចូលទុកផង ។ ក៏ក្នុងពាក្យថា ទោម-នស្សិន្ទ្រិយនេះ គប្បីមានការកើតឡើងបាន ក្នុងរវាងឧបចារខណៈ នៃទុតិយជ្ឈាននោះ នេះនឹងមានការអធិប្បាយ ដល់សេចក្តីដែលថា ទោសៈ មិនជានីវរណៈក៏ទេ ព្រោះសូម្បីធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម ដែលមិនមែនជានីវរណៈ ក៏នៅទ្រង់

ត្រាស់ដោយបរិយាយថា ជានីវរណៈ ព្រោះដូចគ្នានឹងនីវរណៈ ។ ចំណែកពាក្យដែលអាចារ្យពួកនោះ ពោលថា **ព្រោះទោមនស្សនោះ កើតឡើងដល់បុគ្គល សូម្បីអ្នកបានសមាបត្តិ ៨** ដូច្នេះ សូម្បីពាក្យនោះ ក៏នៅចាត់ជាហេតុមិនបាន ព្រោះទោ-មនស្សដែលកើតឡើង រមែងធ្វើឲ្យវិនាសឈានបាន ។ តែគប្បីឃើញថា ឈានដែលវិនាសទៅ ព្រោះបច្ច័យបន្តិចបន្តួច ព្រះយោគីអាចធ្វើឈាន ដែលវិនាសនោះឲ្យត្រឡប់កើតជាប្រក្រតីបាន ដោយមិនលំបាកឡើយ ។

ឯពាក្យពោលដែលមានបរិកប្បៈថា ទោមនស្សិន្ទ្រិយនេះ គប្បីមានការកើតឡើងបាន ក្នុងឧបចារខណៈនៃទុតិយជ្ឈាននោះ ដូច្នេះនេះ លោកពោលទុក ដើម្បីសម្តែងថា ក្នុងឧបចារខណៈលះបង់ទោមនស្ស មិនទាន់បាន ។ ពិតយ៉ាងនោះ លោកពោលទុកថា **ខាងក្នុងអប្បនា មិនមានការកើតឡើងបានឡើយ** ដូច្នេះ ។ ប្រសិនបើថា ក្នុងវេលានោះទោមនស្សគប្បីកើតឡើងបានសោត ក៏គប្បីឃើញថាសម្រាប់ព្រះយោគីរូបនេះ សូម្បីបឋមជ្ឈាន ក៏ត្រូវបានវិនាសហើយនោះឯង ។ លោកអាចារ្យទើបធ្វើទុកក្នុងចិត្តថា សោមនស្សិន្ទ្រិយ សូម្បីថា ត្រូវលះបង់ទៅហើយ ក៏មិនឈ្មោះថា នៅក្នុងទីឆ្ងាយ ដូចគ្នានឹងបីតិដែរ ដូច្នេះហើយ ទើបពោលថា **ព្រោះនៅជិត** ( បីតិ ) ដូច្នេះ ។

លោកអាចារ្យ កាលនឹងសម្តែងអត្ថន័យថា អង្គដែលគប្បីលះ សូម្បីត្រូវលះទៅហើយ ក្នុងឧបចារៈដែលមានអាវជ្ជនៈផ្សេងៗគ្នា ក៏គប្បីកើតឡើងបានជាចន្លោះៗ ព្រោះនៅមិនទាន់ត្រូវធម៌ដែលជាបដិបក្ខកម្ចាត់ ដូច្នេះទើបលោកពោលថា **ដោយមិនមានឧបេក្ខាដែលដល់អប្បនា** ដូច្នេះជាដើម ។ អាចារ្យទាំងឡាយ ពោលថា **ប្រៀបដូចជវនវារៈ ២ - ៣ វារៈ ដែលមានអនុបស្សនាដូចគ្នា** ( គឺ មាន អនិច្ចានុបស្សនា

ជាដើម ឯណាមួយត្រឹមតែម្យ៉ាង ) រមែងប្រព្រឹត្តទៅមុនមគ្គវិថី យ៉ាងណា សូម្បីក្នុងចតុត្ថជ្ឈាននេះ ជវនវារៈ ២-៣ វារៈ ដែលសហគតៈដោយឧបេក្ខាប៉ុណ្ណោះ រមែងប្រព្រឹត្តទៅមុនអប្បនាវារៈ ដូច្នោះព្រោះចាំបាច់ត្រូវការអាសេវនៈ ដែលប្រព្រឹត្តទៅដូច្នោះ ។

បទថា **សមាហជា** ប្រែថា រួបរួម មានន័យថា រួបរួមព្រះតម្រាស់ ។ **អទុក្ខមសុខវេទនា** ឈ្មោះថា ជាធម្មជាតិសុខុម ព្រោះការមិនប្រាកដច្បាស់ ព្រោះហេតុមិនមែនជាវេទនាគ្រោតគ្រាត ដូចជា សុខ និង ទុក្ខ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា ដឹងបានដោយលំបាក ព្រោះមានសភាវៈដែលនរណា ៗ កម្រនឹងអនុមាន ( ពិចារណារកភាពពិត ) បាន ។ ពាក្យថា **ព្យស** គឺ មានប្រយោគអាក្រក់ សំដៅសេចក្តីថា បន្ទឹកបានដោយលំបាក ។ អធិប្បាយថា ទ្រង់អាចឲ្យកាន់យកអទុក្ខមសុខវេទនានេះបាន ដោយការដកយកវេទនាដទៃៗ ចេញទៅ ។

ពាក្យថា **ចេតោវិមុត្តិដែលមិនមានទុក្ខ មិនមានសុខ** គប្បីឃើញថា បានដល់ ចតុត្ថជ្ឈាននេះនោះឯង ។ ពាក្យថា **ដើម្បីសម្តែងបច្ច័យ** បានដល់ ដើម្បីសម្តែងបច្ច័យដែលជាឧបាយឲ្យសម្រេច ។ ព្រោះហេតុនោះ ទើបលោកពោលថា ពិតណាស់ ការលះបង់ទុក្ខជាដើម ជាបច្ច័យនៃចេតោវិមុត្តិដែលមិនមានទុក្ខ មិនមានសុខនោះ ដូច្នេះ ។ ក៏ពាក្យថា **ការលះបង់ទុក្ខជាដើម** ក្នុងទីនេះ បំណងយកបឋមជ្ឈានជាដើម ព្រមទាំងឧបចារៈនោះឯង ។

ពាក្យថា **ត្រូវលះបង់ទៅ** ( ក្នុងមគ្គទី ៣ ) បានដល់ ធម៌ដែលទ្រង់ត្រាស់ទុកថា **ព្រោះការអស់ទៅដោយជុំវិញ នៃសំយោជនៈចំណែកខាងក្រោម ៥** ។ ពាក្យថា **វេទនាទាំងនេះ** បានដល់ វេទនា មានសុខជាដើម ។

**សោមនស្ស** ឈ្មោះថា ជាបច្ច័យដល់រាគៈ ។ សមដូចដែលព្រះធម្មទិន្នាថេរីពោលទុកថា អាវុសោ ! វិសាខៈ ដ៏មានអាយុ **រាគានុស័យ រមែងដេកត្រាំក្នុងសុខវេទនា** ដូច្នេះ ។ **ទោមនស្ស** ឈ្មោះថា ជាបច្ច័យដល់ទោសៈ ។ សូម្បីខនេះ សមតាមដែលព្រះធម្មទិន្នាថេរី ពោលទុកថា អាវុសោ ! វិសាខៈ ដ៏មានអាយុ **បដិឃានុស័យ រមែងដេកត្រាំនៅក្នុងទុក្ខវេទនា** ដូច្នេះ ។ ពាក្យថា **ដោយការកម្ចាត់បច្ច័យ មានសុខជាដើម** គឺ ដោយការលះបង់បច្ច័យ មានសុខជាដើម ។ **អស្ស ឈានស្ស** ប្រែថា ឈានោះ ។

ឈ្មោះថា **អទុក្ខំ** ព្រោះអត្ថថា មិនមែនទុក្ខ គឺ ឃ្លាតឆ្ងាយពីទុក្ខ ។ ព្រោះហេតុក្នុងចតុត្ថជ្ឈាននោះ មិនមានទុក្ខ ដូច្នោះ ទើបលោកពោលថា ព្រោះមិនមានទុក្ខដូច្នេះ ។ សូម្បីក្នុងបទថា **អសុខំ** ក៏មានន័យដូច្នេះ ។ ពាក្យថា **ដោយពាក្យនេះ** គឺ ដោយការបដិសេធ សុខ និងទុក្ខ ។

ពាក្យថា **ជាការបដិបក្ខ** នេះ លោកពោលទុក ព្រោះវេទនាទី ៣ ក្នុងចតុត្ថជ្ឈាននេះ គប្បីប្រព្រឹត្តទៅដោយទាក់ទងនឹងការឈានកន្លងទុក្ខជាដើម មិនមែនពោលទុកព្រោះភាពជាសឹកសត្រូវដោយត្រង់ ដូចកុសលជាសត្រូវដោយត្រង់ចំពោះអកុសលនោះទេ ។ អទុក្ខមសុខវេទនា មានការសោយមជ្ឈត្តារម្មណ៍ ដែលដទៃអំពីឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ជាលក្ខណៈ ឬមានការសោយដទៃពីអាការដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា គឺ ដោយអាការជាកណ្តាល ជាលក្ខណៈ ទើបឈ្មោះថា **ឥដ្ឋានិដ្ឋវិបរីតានុភវនលក្ខណា** ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា មានភាពជាកណ្តាលជារស ។ ពាក្យថា **មានអាការដែលមិនប្រាកដ ច្បាស់ជាបទដ្ឋាន** គឺ មានអាការដែលមិនប្រាកដច្បាស់ដូចជាសុខ និង ទុក្ខ មានការប្រាកដ ដោយអាការ

ដែលមិនជាក់ច្បាស់ ដែលគប្បីអនុមានបាន ដោយសុខ និង ទុក្ខនោះ ដូចផ្លូវដើរលើផ្ទាំងថ្មដូច្នោះ ។ ឈ្មោះថា **ការរលត់ទៅនៃសុខក្នុងទីនេះ** បានដល់ ឧបចារនៃចតុត្ថជ្ឈាន ការរលត់ទៅនៃសុខនោះ ជាបទដ្ឋាននៃចតុត្ថជ្ឈាននេះ ព្រោះហេតុនោះចតុត្ថជ្ឈាននេះ ទើបឈ្មោះថា មានការរលត់ទៅនៃសុខ ជាបទដ្ឋាន ។

បទថា **ឧបេក្ខាសតិបារិសុទ្ធី** នេះ ជាបទសមាស ដោយការលុបបទក្រោយព្រោះបទដំបូង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **មានសេចក្ដីបរិសុទ្ធិនៃសតិដែលឧបេក្ខាធ្វើឲ្យកើត** ដូច្នេះ ។ កាលបារិសុទ្ធិឧបេក្ខា ដែលបរិសុទ្ធចាកធម៌ដែលជាសឹកសត្រូវទាំងពួង មិនមានការព្យាយាម សូម្បីក្នុងការស្ងប់ធម៌ដែលជាសឹកសត្រូវប្រព្រឹត្តទៅហើយ សតិក្នុងចតុត្ថជ្ឈាន រមែងជាធម្មជាតិដែលបរិសុទ្ធល្អនិងក្លៀវក្លាល្អ ដូចបញ្ញាដែលមុតស្រួចដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការបរិសុទ្ធិនៃសតិនោះ ឯណា ការបរិសុទ្ធិនៃសតិនោះ ឧបេក្ខាធ្វើឡើងមិនមែនធម៌ដទៃធ្វើឡើងទេ** ។ លោកអាចារ្យ ធ្វើពាក្យរំពឹងទុកក្នុងចិត្ត ថា ប្រសិនបើទ្រង់បំណងយក **តត្រមជ្ឈត្តតា** ថាជា “ **ឧបេក្ខា** ” ក្នុងឈាន នេះសោត នឹងសំដែងតែសតិម្យ៉ាងថា “ បរិសុទ្ធ ” បានដូចម្ដេច ដូច្នេះហើយ ទើបពោលថានឹងមានសតិតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ ដូច្នេះជាដើម ។

លោកពោលថា “ ក្នុងឈានទាំងនោះ ...... ក៏ពិត ” ដូច្នេះជាដើម សំដៅយកពាក្យដែលចោទសួរថា សូម្បីយ៉ាងនេះ ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់ **សតិ** ទុកថា **ឧបេក្ខាសតិបារិសុទ្ធិ** ទុកក្នុងឈាននេះប៉ុណ្ណោះទៅវិញ ។ លោកអាចារ្យបំណងសំដែងអត្ថន័យ ដោយអំណាចនៃឧបេក្ខាថា ក្នុងឈានទាំងនោះ **តត្រ-មជ្ឈត្តតា** ថា សូម្បីថាមាននៅក្នុងឈាន ៣ ខាងក្រោម ក៏រកសេចក្ដីបរិសុទ្ធិមិនបាន

ព្រោះការគ្របសង្កត់នៃធម៌ដែលជាសត្រូវ និងព្រោះកង្វះនៃបច្ច័យដែលជាសម្លាញ់ធម៌ដែលសម្បយុត្តជាមួយតត្រមជ្ឈត្តតានោះ ក៏យ៉ាងនោះ ដូចគ្នា ។

ក្នុងចតុត្ថជ្ឈាននេះ មានភាពបរិសុទ្ធិ ព្រោះមិនមានភាវៈនោះ ដូច្នេះ នេះទើបលោកពោលថា " តែប្រៀបដូចជា " ដូច្នេះជាដើម ។ បទថា **សុរិយប្បភា-ភិភវា** ប្រែថា ព្រោះត្រូវពន្លឺព្រះអាទិត្យគ្របសង្កត់ ។ លោកអាចារ្យ កាលនឹងសម្តែងថា សូម្បីរាត្រីក៏មានសភាពជាសោមៈ(ត្រជាក់ល្អ) ដូចជាចន្ទលេខា ព្រោះភាវៈដែលស្រទន់ និងក្នុងរាត្រីដែលជាសភាគៈនោះឯង ចន្ទលេខា រមែងរុងរឿង ព្រោះហេតុនោះ ចន្ទលេខានោះ ទើបមានរាត្រីនោះជាសភាគៈ ដូច្នេះ ទើបលោកពោលថា រាត្រីដែលជាសភាគៈគ្នា ដោយភាពត្រជាក់ ឬ ដោយសភាពដែលជាឧបការៈដល់ខ្លួន ។

ពាក្យថា **ក្នុងវិថីតែមួយ** នេះ លោកពោលទុក ព្រោះក្នុងវិថីនោះ មិនមានសោមនស្សដោយពិតប្រាកដ នឹងបានពោលទុក ព្រោះក្នុងវិថីទាំងឡាយ មុនអំពីនោះ មានសោមនស្សដោយពិតប្រាកដ ក៏ទេ ។ លោកពោលទុកដើម្បីសម្តែងថា ប្រៀបដូចជាធម៌ទាំងឡាយ មានវិតក្កៈជាដើម ត្រូវលះទៅក្នុងខណៈនៃឈាន មានទុតិយជ្ឈានជាដើមនោះឯង សម្រាប់ធម៌ទាំងនោះ ត្រូវលះទៅក្នុងជវនមុន ៗ ក្នុងវិថីជាមួយគ្នា ក៏ទេ យ៉ាងណា សោមនស្សនេះ នឹងជាដូច្នោះ ក៏ទេ ។ ពាក្យថា **ក្នុងឈានចតុក្កន័យ** គឺ ក្នុងពួក ៤ នៃឈាន ដែលធ្វើឲ្យកើតដោយអំណាចនៃចតុក្កន័យ ។

( មហាដីកាចតុត្ថជ្ឈាន ចប់ដោយបរិបូរណ៍ )

( ចប់ ឈានចតុក្កន័យ )

# បញ្ចកឈាន

## ( ឈានពួក ៥ )

ចំណែកថា ព្រះយោគាវចរដែលនឹងញ៉ាំងបញ្ចកឈានឲ្យកើត ចេញអំពីបឋមជ្ឈានដែលជំនាញហើយ ឃើញទោសក្នុងបឋមជ្ឈាននោះថា " សមាបត្តិនេះមានសត្រូវ គឺ នីវរណធម៌នៅជិត " និងថា " សមាបត្តិនេះ រាប់ថា មានអង្គខ្សោយកម្លាំង ព្រោះវិតក្កៈជាអង្គគ្រោតគ្រាត " ដូច្នេះហើយ គប្បីធ្វើទុកក្នុងចិត្តដល់ទុតិយជ្ឈានថាជាធម៌ល្អិត លះបង់សេចក្តីពេញចិត្តក្នុងបឋមជ្ឈានចោល ធ្វើយោគៈដើម្បីសម្រេចទុតិយជ្ឈាន(តទៅ) កាលបើព្រះយោគាវចរនោះ ចេញអំពីបឋមជ្ឈានហើយ មានសតិសម្បជញ្ញៈ ពិចារណាអង្គឈានទាំងឡាយ វិតក្កៈតែម្យ៉ាងប្រាកដឡើង ដោយភាពជាអង្គគ្រោតគ្រាត , អង្គ ៤ មានវិចារៈ ជាដើម ប្រាកដដោយភាពជាអង្គល្អិត ក្នុងកាលណា ក្នុងកាលនោះ កាលលោក ធ្វើទុកក្នុងចិត្តហើយរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្មថា **បឋវី បឋវី** ដូច្នេះ ដើម្បីលះអង្គគ្រោតគ្រាត និងដើម្បីបានអង្គល្អិត ទុតិយជ្ឈាន រមែងកើតឡើងតាមន័យដូចដែលបានពោលមកហើយនោះឯង វិតក្កៈម្យ៉ាងប៉ុណ្ណោះ ជាអង្គសម្រាប់លះ នៃទុតិយជ្ឈាននោះ អង្គ ៤ មានវិចារៈជាដើម ជាអង្គប្រកប ពាក្យដ៏សេស មានប្រការដូចពោលមកហើយ ។

កាលទុតិយជ្ឈាននោះ ដែលលោកបានសម្រេចហើយយ៉ាងនេះ គប្បីប្រព្រឹត្តឲ្យជាវសី ដោយអាការ ៥ តាមន័យដែលបានពោលមកហើយនោះ ចេញអំពីទុតិយជ្ឈានដែលស្ទាត់ជំនាញហើយ ឃើញទោសក្នុងទុតិយជ្ឈាននោះថា " សមាបត្តិ

នេះ មានសត្រូវ គឺ វិតក្កៈនៅជិត ” និងថា “ សមាបត្តិនេះ រាប់ថា នៅមានអង្គទុព្វល ព្រោះវិចារៈនៅជាអង្គគ្រោតគ្រាត ” ដូច្នេះហើយធ្វើទុកក្នុងចិត្តដល់តតិយជ្ឈានថា ជាធម៌ល្អិត លះបង់ចោលនូវការពេញចិត្តក្នុងទុតិយជ្ឈាននោះ ធ្វើយោគៈដើម្បីសម្រេចតតិយជ្ឈាន (តទៅ) ។ កាលបើព្រះយោគាវចរនោះ ចេញចាកទុតិយជ្ឈានហើយ មានសតិសម្បជញ្ញៈ បច្ចវេក្ខណៈអង្គឈានទាំងឡាយ វិចារៈតែម្យ៉ាង ប្រាកដដោយភាពជាអង្គគ្រោតគ្រាត អង្គ ៣ មានបីតិជាដើម ប្រាកដជាអង្គល្អិត ក្នុងកាលណា ក្នុងកាលនោះ កាលលោកធ្វើទុកក្នុង ចិត្តហើយរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្មថា **បឋវី បឋវី** ដូច្នេះ ដើម្បីលះអង្គគ្រោតគ្រាត និងដើម្បីបានអង្គល្អិត តតិយជ្ឈានរមែងកើតឡើង ដោយន័យ ដូចបានពោលមកហើយនោះ វិចារៈតែម្យ៉ាងប៉ុណ្ណោះ ជាអង្គសម្រាប់លះ នៃតតិយជ្ឈាននោះ អង្គ ៣ មានបីតិជាដើម ជាអង្គប្រកប ដូចក្នុងទុតិយជ្ឈាននៃចតុក្កន័យ ពាក្យដ៏សេស មានន័យដូចពោលហើយ ។

តាមន័យដូចពោលហើយមកនេះ ឈានដែលជាទុតិយៈ ក្នុងចតុក្កន័យ បែកចេញជា ២ មកជាទុតិយៈ និង តតិយៈ ក្នុងបញ្ចកន័យ ចំណែកឈានដែលជាតតិយៈ និង ចតុត្ថៈ ក្នុងចតុក្កន័យ មកជាចតុត្ថៈ និង បញ្ចមៈ ក្នុងបញ្ចកន័យ , បឋម ជាបឋមដូចគ្នា ។

( ចប់ បញ្ចកឈានន័យ )

# មហាដីកា

## ពណ៌នាអំពី ឈានបញ្ចកន័យ

បទថា **តត្ថ** ប្រែថា ក្នុងបឋមជ្ឈាននោះ ។ ពាក្យថា **ដូចគ្នានឹងទុតិយជ្ឈាននៃចតុក្កន័យ** គឺ ដូចគ្នានឹងទុតិយជ្ឈានដែលមានការទាក់ទងនឹងចតុក្កន័យ ។ ពាក្យថា **ចែកទុតិយជ្ឈាននោះចេញជា ២ យ៉ាង** អធិប្បាយថា ចែកទុតិយជ្ឈានក្នុងចតុក្កន័យចេញជា ២ យ៉ាង យ៉ាងនេះគឺ “ ឈានដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ , ឈានដែលមិនមានវិតក្កៈ មិនមានវិចារៈ ១ ដូច្នេះ ក៏ឈ្មោះថា ជាទុតិយជ្ឈាន និង តតិយជ្ឈាន ក្នុងបញ្ចកន័យ ក្នុងព្រះអភិធម្ម ។ ចំណែកក្នុងព្រះសូត្រទាំងឡាយ មិនបានទ្រង់កាន់យកបញ្ចកន័យ ទុកជាសភាវៈមានឡើយ ។

សួរថា ព្រោះហេតុអ្វី ក្នុងវិសុទ្ធិមគ្គនេះ ទើបលោកកាន់យកការចែកដោយន័យទាំង ២ ទុក ដូច្នេះ ? ឆ្លើយថា ព្រោះក្នុងព្រះអភិធម្ម ទ្រង់សំដែងនូវឈានទាំងឡាយទុក ទាក់ទងក្នុងន័យទាំង ២ ។ សួរថា ព្រោះហេតុអ្វី ក្នុងព្រះអភិធម្មនោះ ទ្រង់សម្តែងឈានទាំងនោះ ទុកយ៉ាងនេះទៅវិញ ? ឆ្លើយថា ទ្រង់សម្តែងឈានទាំងនោះ ទុកយ៉ាងនោះ ក៏តាមអធ្យាស្រ័យនៃបុគ្គលនិងតាមទេសនាវិលាសៈ ( លំអនៃទេសនា ) ។ មានរឿងមកថា ក្នុងបរិស័ទនៃទេវតាដែលកំពុងប្រជុំគ្នា ទេវតាពួកណា មានវិតក្កៈក្នុងបឋមជ្ឈាន តាមដែលទ្រង់សម្តែងទុកតែម្យ៉ាង ប្រាកដភាពជាធម៌ដែលគ្រោតគ្រាត ធម៌ក្រៅអំពីនេះប្រាកដភាពជាធម៌ស្ងប់ ។ ទ្រង់សម្តែងឈានដែលមានអង្គ ៤ មិនមានវិតក្កៈ មានត្រឹមតែវិចារៈទុក ដោយអំណាចនៃអធ្យាស្រ័យនៃទេវតាពួកនោះ ។ ទេវតាពួកណា មានវិចារៈប្រាកដជាធម៌ដែលគ្រោត

គ្រាត ទេវតាពួកណាមានបីតិ ប្រាកដជាធម៌ដែលគ្រោតគ្រាត ទេវតាពួកណា មានសុខប្រាកដជាធម៌ដែលគ្រោតគ្រាត ធម៌ក្រៅពីនេះ ប្រាកដជាធម៌ស្ងប់ ។ ទ្រង់សំដែងឈានទាំងឡាយ មានតតិយជ្ឈានជាដើម ដោយអំណាចនៃអធ្យាស្រ័យរបស់ទេវតាទាំងនោះ ។ ដែលពោលមកនេះ ជាអធ្យាស្រ័យនៃបុគ្គលមុន ។

ព្រះមានព្រះភាគ ព្រោះហេតុដែលទ្រង់ដល់នូវទេសនាវិលាសៈ ព្រោះទ្រង់ចាក់ធ្លុះធម្មធាតុទាំងពួងដោយប្រពៃហើយ ដូច្នោះ ព្រោះទ្រង់មានព្រះញាណ ដ៏ក្រៃលែង ទើបឈ្វាសយ៉ាងល្អក្នុងព្រះទេសនា កាលនឹងទ្រង់និយាមព្រះទេសនា តាមសេចក្ដីពេញព្រះទ័យ ដោយអំណាចនៃអង្គឈាន គ្រប់ៗអង្គ ដែលទ្រង់មាន ទើបទ្រង់សំដែងទុកដោយអំណាចចតុក្កន័យ និង ដោយអំណាចនៃបញ្ចកន័យ ។ ក្នុងបញ្ចកន័យនោះ ទ្រង់សំដែងបឋមជ្ឈានមានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៤ តតិយជ្ឈានមានអង្គ ៣ ចតុត្ថជ្ឈានមានអង្គ ២ បញ្ចមជ្ឈានមានអង្គ ២ នោះឯងដែលពោលមកដូចនេះ នេះជាទេសនាវិលាសៈ ។ ម្យ៉ាងទៀត ក្នុងន័យទាំង ២ នេះ ទ្រង់ចែកទុតិយជ្ឈាន ក្នុងបញ្ចកន័យឲ្យជាឈាន មានក្នុងចំណែកនៃទុតិយជ្ឈាន ក្នុងចតុក្កន័យថា " ក្នុងសម័យណាបុគ្គលចម្រើនមគ្គ ដើម្បីចូលដល់រូបភព រមែងដល់នូវទុតិយជ្ឈានដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសមាធិ " ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមានផលដូចគ្នា ជាមួយទុតិយជ្ឈាន ដោយភាពដែលមាន ឯកត្តកាយនានត្តសញ្ញីសត្តាវាស ជាផល និងព្រោះកើតអំពីសមាធិក្នុងបឋមជ្ឈាន ។ ពិតណាស់ បឋមជ្ឈានប៉ុណ្ណោះ ដែលអាចពោលបានថា " ស្ងាត់ចាកកាមទាំងឡាយ និងចាកអកុសលទាំងឡាយហើយ " ឯក្នុងទុតិយជ្ឈាន

នេះ មិនអាចពោលបានថា “ ស្ងាត់ចាកកាមទាំងឡាយហើយ ស្ងាត់ចាកអកុសលទាំងឡាយហើយនោះទេ ” ព្រោះមិនមានភាវៈនោះ ទាំងមិនអាចពោលបានថា “ កើតអំពីវិវេក ” ។ ក្នុងទេសនានៃព្រះសូត្រទាំងឡាយ ទុតិយជ្ឈាន និង តតិយជ្ឈានក្នុងបញ្ចកន័យ រមែងរួមចូលតែមួយ ទុតិយជ្ឈាននោះឯង ព្រោះស្ងប់វិតក្កៈ ព្រោះស្ងប់វិចារៈ ព្រោះមិនមានវិតក្កៈ ព្រោះមិនមានវិចារៈ ។ ក៏ព្រោះធ្វើអធិប្បាយយ៉ាងនេះ ទើបជាការសម្រេចសេចក្ដីថា សូម្បីក្នុងទេសនាព្រះសូត្រ រមែងបានបញ្ចកន័យដូចគ្នា ។ សួរថា ក្នុងព្រះសូត្រ ទ្រង់ចែកឈានទុក ៤ ប៉ុណ្ណោះ មិនមែនឬ ព្រោះហេតុនោះ រមែងមិនបានបញ្ចកន័យ ? ឆ្លើយថា នឹងមិនបានបញ្ចកន័យ មិនមាន ព្រោះបានបញ្ចកន័យ ដោយការអាងសមាធិ ៣ ដោយន័យថា “ សមាធិមានវិតក្កៈ មានវិចារៈ ” ដូច្នេះ ជាដើម ( សមាធិ ៣ គឺ **សវិតក្កសវិចារសមាធិ**-សមាធិមានវិតក្កវិចារៈ១ , **អវិតក្កវិចារមត្តសមាធិ**-សមាធិមិនមានវិតក្កៈ មានត្រឹមវិចារៈ១ , **អវិតក្កអវិចារសមាធិ**-សមាធិមិនមានវិតក្កៈ មិនមានវិចារៈ១ ) ។

ដោយសេចក្ដីថា ទ្រង់ចែកបញ្ចកន័យ ធ្វើឲ្យអាស្រ័យចតុក្កន័យ ព្រោះហេតុនោះ សូម្បីក្នុងទេសនាព្រះសូត្រ ក៏គប្បីពង្រីកជាបញ្ចកន័យបាន ។

បទថា **វិតក្កវិចារានំ វូបសមា** ព្រោះស្ងប់នូវ វិតក្កៈ និងវិចារៈក៏អាចពោលបានថា ព្រោះស្ងប់វិតក្កៈ ព្រោះស្ងប់វិចារៈ និង ព្រោះស្ងប់វិតក្កវិចារៈ ឈ្មោះថា **វិតក្កវិចារានំ** ដូច្នេះ ។ បទថា **អវិតក្កំ អវិចារំ** មិនមានវិតក្កៈ មិនមានវិចារៈ ក៏យ៉ាងនោះ អាចពោលបានថា ឈ្មោះថា **អវិតក្កំ**-មិនមានវិតក្កៈ ដោយការលះតែវិតក្កៈ មិនទាន់លះវិចារៈ ក៏ប្រកបនឹងវិចារៈ , ឈ្មោះថា **អវិចារំ** មិនមានវិចារៈ ក៏ដោយការលះវិចារៈព្រមជាមួយវិតក្កៈ និង វៀរវិតក្កៈ ។ ម្យ៉ាងទៀត អាចសង្គ្រោះ

ឈាន សូម្បីទាំង ៣ យ៉ាង បានថា ឈានមិនមានវិតក្កៈ១ ឈានមិនមានវិចារៈ១ ឈានមិនមានវិតក្កៈមិនមានវិចារៈ១ ដូច្នេះ ។

មួយវិញទៀត បទថា **ទុតិយំ** ( ទី ២ ) មានន័យថា ទេសនាមកហើយ ដោយការដឹង ក្នុងឈានដែលវៀរវិតក្កៈ និងក្នុងឈានដែលវៀរវិតក្កវិចារៈទាំង ២ ព្រោះមានការសម្រេចជាលើកទី ២ ព្រោះសូម្បីក្នុងឈានដែលវៀរត្រឹមតែវិចារៈ ក៏មានធម៌ដូចគ្នានឹងឈាន ដែលព្រះយោគីសម្រេចដោយការលះធម៌ទាំង ២ ។ ព្រោះធ្វើអធិប្បាយយ៉ាងនេះ វិតក្កៈ សូម្បីថាស្ងប់ទៅហើយក្នុងទុតិយជ្ឈាន ក្នុងនិទ្ទេសនៃបញ្ចកន័យ ក៏មិនឈ្មោះថាស្ងប់ដោយល្អ ព្រោះមិនទាន់ស្ងប់នូវវិចារៈដែលជាសំឡាញ់បាន ព្រះដ៏មានព្រះភាគ កាលនឹងសម្តែង ទ្រង់សម្តែងសេចក្តីស្ងប់រំងាប់បាននូវវិតក្កៈនោះ ដោយការស្ងប់វិចារៈតែម្យ៉ាង ដូចជាក្នុងឈាន ដែលវៀរវិតក្កៈនិងវិចារៈទាំង ២ និងជាឈានមានធម៌ដ៏សេស ស្មើដូចគ្នា ទើបទ្រង់បែកតតិយជ្ឈានទុក មិនឲ្យបែកផ្សេងគ្នាជាមួយទុតិយជ្ឈាន ក្នុងចតុក្កន័យទុកថា “ ព្រោះស្ងប់រំងាប់បាននូវវិតក្កៈនិងវិចារៈ ទើបដល់នូវតតិយជ្ឈាន ដែលកើតក្នុងខ្លួន ដែលមានការធ្វើចិត្តឲ្យផូរផង់ ញុំាងធម៌ដែលប្រាកដឡើងជាឯក ឲ្យកើតឡើង មិនមានវិតក្កៈ មិនមានវិចារៈ កើតហើយអំពីសមាធិ មានតែបីតិនិងសុខ ” ។ ឈានទាំង ២ យ៉ាង ( គឺ ឈានដែលវៀរវិតក្កៈម្យ៉ាង មានត្រឹមវិចារៈ និង ឈានដែលវៀរទាំងវិតក្កៈទាំងវិចារៈ ) មានពាក្យសម្តែងលម្អិតថា **ទុតិយ** (ទី ២) ព្រោះឈានសូម្បីទាំង ២ លះវិតក្កៈបានដោយវៀរសម្ងាត់ ( គឺ វិចារៈ ) និង ដោយប្រការដទៃ ( គឺ មិនវៀរវិចារៈ ) សូម្បីជាឈានដែលមានធម៌ស្មើដូចគ្នា គឺការមិនមានវិតក្កៈ និងជាឈានដែលកើតអំពីសមាធិ មានបីតិនិងសុខ ក៏ចាត់ជាការស្មើគ្នា ដូចគ្នា ។ ពិតណាស់

ឈានដែលមានសូម្បីត្រឹមតែវិចារៈ ក៏ទ្រង់ចែកទុកហើយថា ជាឈានដែលមិនមានវិតក្កៈ កើតអំពីសមាធិ មានបីតិនិងសុខ ដូចគ្នានឹងឈានដែលវៀរចាកវិតក្កៈ និងវិចារៈទាំង ២ ដោយទ្រង់ត្រាស់ទុកថា **ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីការចូលដល់រូបភព រមែងដល់នូវទុតិយជ្ឈាន ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈ កើតអំពីសមាធិ មានបីតិនិងសុខ** ដូច្នេះ ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ **តតិយជ្ឈាន** ក្នុងបញ្ចកន័យទុក ក៏ព្រោះគប្បីសម្រេចជាទី ៣ នៃព្រះយោគីដែលឈានកន្លងធម៌មួយ ក្នុងបណ្តាវិតក្កៈ និងវិចារៈ ដែលប្រព្រឹត្តទៅរួមគ្នាក្នុងបឋមជ្ឈាន ហើយឃើញធម៌ សូម្បីដូចទី ២ ដែលតាំងនៅក្នុងបឋមជ្ឈាននោះឯងថា ជាទោស ឈានកន្លងធម៌ទាំង ២ ទៅ ព្រមគ្នា ។ ភាពជាទី ២ នៃឈាននោះ រមែងកើតឡើង ដោយមានលំដាប់ទៅអំពីគ្រាដំបូង ដូច្នោះឯង ។ សួរថា ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ មិនទ្រង់ចែកបញ្ចកន័យទុកដោយជាសភាវៈមានហើយទៅវិញ ? ឆ្លើយថា ទ្រង់មិនចែកបញ្ចកន័យទុក ដោយជាសភាវៈដែលមានហើយ ដោយអធ្យាស្រ័យវេនេយ្យសត្វ ។ ព្រោះថា ទេសនាព្រះសូត្រជាយថានុលោមទេសនា ( ទេសនាអនុលោមតាមអធ្យាស្រ័យ នៃវេនេយ្យសត្វ ) ដូច្នេះឯង ។

ចប់ បរិច្ឆេទទី ៤

ឈ្មោះ បឋវីកសិណនិទ្ទេស

ក្នុងអធិការនៃសមាធិភាវនា ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ

ដែលខ្ញុំព្រះករុណាធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជៈនៃសាធុជន ដូច្នេះឯង ។

# សេសកសិណនិទ្ទេស

# អាបោកសិណ

តទៅនេះ ជាវិត្ថារកថា ក្នុងអាបោកសិណ ក្នុងលំដាប់នៃបឋវីកសិណ ឯព្រះយោគាវចរដែលពេញចិត្ត ចម្រើនបឋវីកសិណ ជាអ្នកអង្គុយឲ្យសប្បាយយ៉ាងណាសោត សូម្បីអ្នកចម្រើនអាបោកសិណ ក៏គប្បីជាអ្នកអង្គុយឲ្យសប្បាយដូច្នោះ ហើយកាន់យកនិមិត្តក្នុងទឹកចុះ ។ បទទាំងពួងថា **កតេ វា អកតេ វា** ( និមិត្តដែលធ្វើឡើងក្ដី ដែលមិនបានធ្វើឡើងក្ដី ) ជាដើម បណ្ឌិតគប្បីពោលឲ្យពិស្ដារ ( តាមន័យដែលពោលហើយក្នុងបឋវីកសិណចុះ ) ។ ម្យ៉ាងវិញទៀត បទទាំងពួងនោះ គប្បីពោលឲ្យពិស្ដារក្នុងអាបោកសិណនេះយ៉ាងណា ក្នុងកសិណទាំងពួងក៏គប្បីឲ្យពិស្ដារយ៉ាងនោះចុះ ព្រោះថា តទៅនេះ ខ្ញុំព្រះករុណានឹងមិនពោលពាក្យ ( **កតេ វា ។ បេ ។ វិត្ថារេតព្វំ** ) ត្រឹមប៉ុណ្ណោះទៀត ពោលតែពាក្យដែលប្លែក ៗ ប៉ុណ្ណោះ ។ សូម្បីក្នុងអាបោកសិណនេះ និមិត្តក្នុងទឹកដែលមិនបានរៀបចំ គឺទឹកក្នុងស្រះ ក្នុងបឹង ឬក្នុងទន្លេ ក្នុងសមុទ្រក៏ដោយ រមែងកើតឡើងដល់ព្រះយោគីដែលមានបុណ្យ មានអធិការបានសាងទុកក្នុងកាលមុនពិត ដូចព្រះចូឡសិវត្ថេរ ដូច្នោះបានឮថា កាលលោកលះបង់លាភសក្ការៈ តាំងចិត្តថា នឹងទៅយ៉ាងស្ងាត់ ឡើងសំពៅត្រង់កំពង់មហាតិត្ថៈ ទៅជម្ពូទ្វីប ក្រឡេកមើលមហាសមុទ្រ ក្នុងរវាង ( ផ្លូវ ) កសិណនិមិត្តដែលមានចំណែកប្រៀបនៃមហាសមុទ្រនោះ បានកើតឡើង ។ រីឯព្រះយោគាវចរ ដែលមិនបានសាងអធិការទុក កាលនឹងលះបង់ទោសនៃកសិណ ទាំង ៤ កុំគប្បីកាន់យកទឹកដែលមាន ពណ៌ខៀវ លឿង ក្រហម ស ពណ៌ណាមួយ ។

ចំណែកទឹក(ភ្លៀង)ណា (ធ្លាក់មក) មិនទាន់ដល់ផែនដី បុគ្គលត្រងយកក្នុងអាកាស ដោយសំពត់ស្អាត ( សំពត់គ្មានពណ៌ ) ឬទឹកដែលថ្លាស្អាតយ៉ាងនោះ ក៏បាន គប្បីដាក់ទឹកនោះឲ្យពេញបាត្រ ឬកុណ្ឌី (ក្អម) ស្មើកណ្ដាប់មាត់បាត្រ ហើយតម្កល់ទុកក្នុងឱកាសដែលកំណត់ មានប្រការដូចពោលហើយ អង្គុយឲ្យបានស្រួល មិនត្រូវពិចារណាពណ៌ មិនត្រូវដាក់ចិត្តដល់លក្ខណៈ គប្បីធ្វើឲ្យជាវត្ថុដែលស្មើគ្នា ជាមួយទីអាស្រ័យ ( គឺ គិតថា ពណ៌នោះ វាជាការដូចគ្នានឹងទឹកដែលជាទីអាស្រ័យរបស់វា ) តាំងចិត្តទុកក្នុងបណ្ណត្តិធម៌ ( គឺ លោកវោហារ ) តាមពាក្យដែលធ្លាប់ប្រើការនាថា **អាបោ អាបោ** ជានាមក្នុងបណ្ដានាម របស់ទឹកទាំងឡាយ ដូចជា **អម្ពុ ឧទកំ វារិ សលិលំ** កាលការនាយ៉ាងនោះ និមិត្តទាំងពីរ រមែងកើតឡើងតាមន័យដែលពោលហើយនោះ តាមលំដាប់ តែក្នុងអាបោកសិណ ឧគ្គហនិមិត្តប្រាកដដូចជានៅញ័រនៅឡើយ បើទឹកនោះជាទឹកលាយដោយពពុះ និង ក្រពេញ ( ព្រូច ៗ ) ឧគ្គហនិមិត្តនឹងប្រាកដជាយ៉ាងនោះដូចគ្នា ឈ្មោះថា ទោសកសិណប្រាកដ ចំណែកបដិភាគនិមិត្តប្រាកដឡើងនឹងថ្កល់ ថ្លាដូចផ្ចិតស្លឹកត្នោតកែវ ដែលមនុស្សព្យួរក្នុងអាកាស និងដូចវង់កញ្ចក់កែវដូច្នោះ ព្រមជាមួយនឹងការប្រាកដនៃបដិភាគនិមិត្តនោះ ឯងព្រះយោគាវចរនោះ ក៏សម្រេចឧបចារឈាន ចតុក្កឈាន បញ្ចកឈាន ក៏មានន័យដូចដែលបានពោលហើយនោះឯង ។

( ចប់ អាបោកសិណ )

# មហាដីកា

## ពណ៌នា **សេសកសិណនិទ្ទេស**

## អាបោកសិណ

សូម្បីពាក្យចន្ទុលបង្ហាញអត្ថ តាមដែលធ្វើឲ្យពិស្តារហើយ ក៏រមែងតាំងនៅក្នុងឋានៈដែលគួរធ្វើឲ្យពិស្តារថែមទៀត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នឹងមានពាក្យពោលដោយពិស្តារ** ។ ពាក្យថា **អាបោកសិណ** ឈានដែលហៅថា **អាបោកសិណ** ឬបានដល់ កម្មដ្ឋាន គឺ អាបោកសិណ ។ ពាក្យថា **ពាក្យពោលទាំងអស់បណ្ឌិតគប្បីធ្វើឲ្យពិស្តារ** គឺគប្បីពង្រីកឲ្យពិស្តារ តាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណកម្មដ្ឋាន ។ ពាក្យថា (នឹងមិនពោល) **ពាក្យត្រឹមប៉ុណ្ណេះទៀត** គឺមិនសុំពោលពាក្យថា “ ពាក្យពោលទាំងអស់ដែលថា ក្នុងអាបោ-កសិណដែលធ្វើឡើងក៏បាន ដែលមិនបានធ្វើឡើងក៏បាន ជាដើម បណ្ឌិតគប្បីពង្រីកឲ្យពិស្តារ ” ដូច្នេះត្រឹមប៉ុណ្ណេះទៀត ។ ប្រកពទឹកដែលពេញដោយទឹកប្រៃ បានមកអំពីសមុទ្រ ហៅថា ទន្លេទឹកប្រៃ ។ លោកពោលថា ដែលប្រើសំពត់ស្អាតត្រងទុក ដូច្នេះដើម្បីចៀសវាងការលាយដោយពណ៌ មានពណ៌ខៀវជាដើម ។ ពាក្យថា **ទឹកដទៃ** បានដល់ ទឹកដែលធ្លាក់ដល់ផែនដី ។ ពាក្យថា **យ៉ាងនោះ** គឺដូចគ្នានឹងទឹកដែលកើតក្នុងអាកាស ។ ព្រោះហេតុនោះ ទើបលោកពោលថា ថ្លាស្អាត ភ្ជាប់សេចក្តីថា **យំ បន ឧទកំ** ។ ក្នុងពាក្យថា **មិនគួរពិចារណាពណ៌** ដូច្នេះជាដើម មានពាក្យដែលគួរអធិប្បាយ គួរពោលដល់ឯណា លោកបានពោលពាក្យអធិប្បាយនោះ ក្នុងកថា ពោលដោយបឋវីកសិណហើយ ។

ចំណែកដែលឈ្មោះថា **លក្ខណៈ** ក្នុងអាបោកសិណនេះ គប្បីជ្រាបថា បានដល់ លក្ខណៈ ជ្រាបសើម ឬ ហូរ ។ ពាក្យថា **តាមន័យដែលបានពោលហើយនោះឯង** គឺ តាមន័យដែលបានពោលហើយ ក្នុងការចម្រើនបឋវីកសិណនោះឯង , ចំណែករលកទឹកជាដើម និងការលាយឡំដោយពពុះជាដើម ជាទោសរបស់កសិណក្នុងឧគ្គហនិមិត្តនេះ ។ បទថា **សោ** បានដល់ ព្រះយោគាវចរ ។ បទថា **តស្ស** ប្រែថា នៃបដិភាគនិមិត្តនោះ ។

( ចប់ មហាដីកា អាបោកសិណ )

# តេជោកសិណ

ចំណែកព្រះយោគាវចរ ដែលប្រាថ្នានឹងចម្រើនតេជោកសិណ គប្បីកាន់យកនិមិត្តក្នុងភ្លើង ក្នុងតេជោកសិណនោះ សម្រាប់ព្រះយោគាវចរដែលមានបុណ្យ មានអធិការបានសាងទុក កាលកាន់យកនិមិត្តក្នុងភ្លើងដែលមិនបានរៀបចំ សម្លឹងមើលអណ្តាតភ្លើងចង្កៀង ភ្លើងចង្ក្រានដែលដុតបាត្រ ឬត្រង់ភ្លើងឆេះព្រៃ ត្រង់ទីណាមួយក៏ដោយ និមិត្តក៏កើតឡើងបាន ដូចព្រះចិត្តគុត្តត្ថេរដូច្នោះ ។ បានឮមកថា កាលលោកអង្គនោះចូលទៅកាន់រោងឧបោសថ ក្នុងថ្ងៃធម្មស្សវនៈ សម្លឹងមើលភ្លើងចង្កៀងប៉ុណ្ណោះ និមិត្តក៏កើតឡើង ។ ចំណែកព្រះយោគាវចរក្រៅពីនេះ ត្រូវរៀបចំ (កសិណនិមិត្ត) ឡើង ។

នេះជាវិធីក្នុងការរៀបចំកសិណនិមិត្តនោះ គប្បីពុះឈើខ្លឹមដែលស្ងួត ហាលថ្ងៃទុកហើយ កាត់ធ្វើជាកង់ ៗ យកទៅកាន់គល់ឈើ ឬ មណ្ឌបដែលសមគួរ គរ

( ឧសដោយអាការដូចដុតបាត្រ ) បន្ទាត់ភ្លើងឡើង ហើយចោះកន្ទេល ឬ ផ្ទាំងស្បែក ឬផ្ទាំងសំពត់ក៏បាន ឲ្យមានប្រហោងប្រមាណ ១ ចំអាម ៤ ធ្នាប់ ( ជារង្វង់មូល ) តាំងកន្ទេល ឬផ្ទាំងស្បែក ឬផ្ទាំងសំពត់នោះ ទុកខាងមុខ អង្គុយតាមន័យ ដូចដែលបានពោលហើយនោះឯង កុំដាក់ចិត្តដល់ស្មៅនិងឈើ ខាងក្រោម ឬផ្សែងនិងអណ្តាតភ្លើងខាងលើ កាន់យកតែនិមិត្តអណ្តាតភ្លើង ក្រាស់ក្នុង(ប្រឡោះ) មិនត្រូវពិចារណាដល់ពណ៌ ( របស់ភ្លើង ដោយថា វាជាពណ៌ ស ឬថា ជាពណ៌លឿងជាដើម មិនត្រូវធ្វើទុកក្នុងចិត្តដល់លក្ខណៈក្តៅ គប្បីធ្វើឲ្យជាវត្ថុស្មើគ្នាជាមួយទីអាស្រ័យ ( របស់វា គឺ នឹកថា ពណ៌នោះ វាតែមួយ ដូចគ្នានឹងភ្លើងដែលជាទីអាស្រ័យរបស់វា ) តាំងចិត្តទុកក្នុងបណ្ណត្តិធម៌ ( គឺ លោកវោហារ ) តាមដែលជាពាក្យប្រើច្រើនគ្នា ភាវនាថា **តេជោ តេជោ** ដែលជានាមកំណត់ក្នុងបណ្តានាមរបស់ភ្លើងទាំងឡាយ ដូចជា **បាវកោ កណ្ហវត្តនិ ជាតវេទោ ហុតាសនោ** កាលភាវនាយ៉ាងនោះ និមិត្តទាំង ២ រមែងកើតឡើងតាម ន័យដែលបានពោលហើយនោះ តាមលំដាប់ ឧគ្គហនិមិត្តក្នុងតេជោកសិណនោះ ប្រាកដដូចជាអណ្តាតភ្លើងដាច់ធ្លាក់ចុះទៅៗ តែសម្រាប់អ្នកដែលកាន់យកនិមិត្តក្នុងភ្លើងដែលមិនបានរៀបចំ ទោសកសិណរមែងប្រាកដ គឺ កំណាត់ឧសខ្លះ ដុំធ្យូងខ្លះ ផេះខ្លះ ផ្សែងខ្លះ រមែងប្រាកដ (ចំណែក) បដិភាគនិមិត្ត ប្រាកដនៅនឹងថ្កល់ ដូចផ្ទាំងសំពត់កម្ពលក្រហម ដែលព្យួរក្នុងអាកាស និងដូចផ្ចិតស្លឹកត្នោតពណ៌មាស ដូចសសរមាស ដូច្នោះ ព្រមជាមួយការប្រាកដនៃបដិភាគនិមិត្តនោះឯង ព្រះយោគាវចរនោះ ក៏សម្រេចឧបចារឈាន ចតុក្កឈាន និងបញ្ចកឈាន តាមន័យដែលបានពោលហើយនោះឯង ។

( ចប់ តេជោកសិណ )

# មហាដីកា

## អធិប្បាយ តេជោកសិណ

ពាក្យថា **សិនិទ្ធ** (ស្និទ្ធ) គឺ មានជ័រ ។ ឈ្មោះថា **ឈើខ្ចឹម** គឺ មិនមែនឈើស្រាយ ។ ការប្រើឈើខ្ចឹមដែលមានជ័រ គឺ ដើម្បីឲ្យអណ្តាតភ្លើងតាំងនៅបានយូរ ។ ឈ្មោះថា **ធ្វើជាកង់ ៗ** គឺ កាត់ជាកំណាត់ ៗ ។ បទថា **បង្កាត់ភ្លើង** គឺ ធ្វើឲ្យឆេះទ្រលោមឡើង ។ ពាក្យថា **អណ្តាតភ្លើងក្រាស់** គឺ ក្នុងអណ្តាតភ្លើងដែលឆេះជាប់គ្នាមិនដាច់ ។ បទថា **បតនសទិសំ** ប្រែថា ដូចអណ្តាតភ្លើងដែល (ដាច់) ធ្លាក់ទៅ។ ពាក្យថា **សម្រាប់ព្រះយោគាវចរដែលកាន់យក (និមិត្ត) ក្នុងតេជោកសិណដែលមិនបានធ្វើឡើង** គឺ សម្រាប់ព្រះយោគាវចរ ដែលកាន់យកនិមិត្តក្នុងភ្លើងដែលមិនបានរៀបចំទុក ដោយប្រការដែលនឹងប្រាកដជាដួងកសិណ តាមន័យដែលបានពោលហើយ ។

( ចប់មហាដីកា តេជោកសិណ )

# វាយោកសិណ

ព្រះយោគាវចរ កាលប្រាថ្នានឹងចម្រើនវាយោកសិណ គប្បីកាន់យកនិមិត្តក្នុងខ្យល់ ឯនិមិត្តក្នុងខ្យល់នោះ គប្បីកាន់យកតាមរយៈនៃការឃើញខ្លះ ការពាល់ត្រូវខ្លះ ។ ពាក្យនេះ លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា “ ព្រះយោគីដែលឡើងកាន់វាយោកសិណ រមែងកាន់យកនិមិត្តក្នុងខ្យល់ គឺ កំណត់យកត្រួយ

អំពៅដែលកម្រើកទៅមក ឬ កំណត់យកចុងឫស្សី ឬ ចុងឈើ ឬ ចុងសក់ដែលកម្រើកទៅមកក៏បាន កំណត់យកខ្យល់ដែលមកត្រូវកាយក៏បាន ” ដូច្នេះ ព្រោះហេតុនោះ ព្រះយោគាវចរ ( ដែលចម្រើនវាយោកសិណា ឃើញចុងអំពៅក្តី គុម្ពឫស្សីក្តី ដើមឈើក្តី ដែលមានស្លឹកស្ថិតនៅកម្ពស់ត្រឹមក្បាល ឬសក់របស់មនុស្សដែលមានសក់ប្រវែងប្រមាណ ៤ អង្គុលីក្តី ដែលខ្យល់បក់ត្រូវ គប្បីតាំងសតិថា “ ខ្យល់បក់នៅត្រង់នោះ ” ឬក៏ថា ខ្យល់ដែលចូលតាមបង្អួចខ្ទះ តាមចន្លោះជញ្ជាំងខ្ទះ មកប៉ះរាងកាយរបស់លោកត្រង់ណា គប្បីតាំងសតិទុក ត្រង់ចំណែកនៃរាងកាយនោះ ការទាថា **វាតោ វាតោ** ដែលជានាមកំណត់ក្នុងបណ្តានាមរបស់ខ្យល់ទាំងឡាយ ដូចជា **វាតៈ មាលុតៈ អនិលៈ** ។ ឧគ្គហនិមិត្តក្នុងវាយោកសិណា នេះប្រាកដមាននិមិត្តញ័រ ដូចចំហាយផ្សែង(ក្តៅ) នៃបាយបាយាសដែលទើបតែ ដាក់ចុះអំពីចង្ក្រាន ឯបដិភាគនិមិត្ត ជាដួងនៅនឹងថ្កល់ ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលបានពោលហើយ នោះហោង ។

( ចប់ វាយោកសិណា )

# មហាដីកា

## អធិប្បាយ វាយោកសិណា

ទិ ស័ព្ទ ក្នុងបទថា **វុត្តណ្ហេតំ** នេះមានអត្ថថា ហេតុ (ប្រែថា ព្រោះ) មានន័យស្មើគ្នានឹង **យស្មា** ។ ទិ ស័ព្ទ នោះមានការសម្ព័ន្ធគ្នា ជាមួយពាក្យថា **តស្មា** នេះ ។ ពាក្យថា **ត្រួយអំពៅ** បានដល់ ចុងរបស់ស្លឹកអំពៅទាំងឡាយ ដែលមាន

មានដើមដុះនៅក្នុងចម្ការអំពៅ ។ បទថា **ឯរិតំ** គឺ ដែលកម្រើកព្រោះខ្យល់ ។ បទថា **សមេរិតំ** គឺ ដែលកម្រើកទៅដោយអាការទាំងពួង ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះលោកពោលទុកក្នុងអដ្ឋកថា យ៉ាងនេះថា " ព្រះយោគីកាលនឹងរៀនយកវាយោកសិណា រមែងកាន់យកនិមិត្តក្នុងខ្យល់ គឺរមែងកំណត់យកចុងអំពៅ " ដូច្នេះ ។ ព្រោះដូច្នោះ ពាក្យថា **ដែលស្ថិតនៅកម្ពស់ត្រឹមក្បាល** គឺ ដែលមានដើម ជាដើម កម្ពស់ស្មើក្បាល ដោយអំណាចផ្នែកខាងលើ ។ សូម្បីក្នុងពាក្យថា **ដើមឫស្សីក្តី ដើមឈើក្តី** នេះ ក៏គប្បីនាំពាក្យពោលចូលមកប្រកបគ្នាថា " ដើមឫស្សីដែលមានស្លឹកក្រាស់ក្តី ដើមឈើដែលមានស្លឹកក្រាស់ក្តី មានដើមកម្ពស់ស្មើក្បាល " ដូច្នេះ ។ ការប៉ះខ្ទប់នៃខ្យល់ រមែងមិនប្រាកដចំពោះសរសៃសក់ប្រវែងប្រមាណ ១ អង្គុលី ជាដើម ព្រោះសក់ខ្លីពេក , ហើយក៏មិនប្រាកដក្នុងសរសៃសក់ដែលវែងហួសប្រមាណ ព្រោះ (ចុងសក់) គ្របសំយុងចុះ និងរមែងមិនប្រាកដក្នុងសក់ដែលរង្វើលៗ ព្រោះខ្យល់ជ្រែកចូលចូលទៅបាន ព្រោះហេតុនោះលោកទើបប្រើសព្ទថា **ប្រវែងប្រមាណ ៤ អង្គុលី** និងសព្ទថា **សក់ក្រាស់** ។

ពាក្យថា **តាំងសតិទុកថា ខ្យល់នោះបក់នៅត្រង់នោះ** គឺ ចូលទៅតាំងសតិទុក ត្រង់គំនរខ្យល់ដែលបក់ប៉ះចំណែកទាំងនោះ ដោយការកាន់យកអាការដែលកម្រើកនៃចុងអំពៅជាដើម ជាគន្លង ។ ពាក្យថា **តាំងសតិទុក ត្រង់ចំណែកនៃរាងកាយនោះ** គឺ ចូលទៅតាំងសតិទុក ក្នុងគំនរនៃខ្យល់នោះ ដែលប្រព្រឹត្តទៅដោយអំណាចនៃការប៉ះខ្ទប់នឹងចំណែកនៃរាងកាយ ដោយកាន់យកអាការដែលប៉ះខ្ទប់ជាគន្លង ។ ដោយពាក្យថា **ដូចចំហាយផ្សែងបាយបាយាស** នេះ លោកសំដៅដល់ភាវៈដែលនិមិត្ត ( ឧគ្គហនិមិត្ត ) នេះ នៅប្រព្រឹត្តទៅជាមួយសរីរៈ ( សរីរៈទីនេះ

គឺ ចុងអំពៅ ឬសរសៃសក់ ) ដូចគ្នានឹងកសិណមុនៗ ។ ដោយពាក្យថា **មិនកម្រើក** នេះ គឺលោកបើកផ្លូវ ក្នុងការបាននូវបដិភាគនិមិត្ត ក៏ដូចជាចំហាយផ្សែងនោះឯងថា ជាភាវៈដែលជាដួងមិនញាប់ញ័រប៉ុណ្ណោះ ជាប្រការដែលផ្សេងអំពីឧគ្គហនិមិត្ត នៃបដិភាគនិមិត្តនេះ ដូច្នេះ ។

( ចប់ មហាដីកា វាយោកសិណា )

# នីលកសិណា

ចំណែក (កសិណ) បន្ទាប់អំពីនោះទៅ ( បណ្ឌិតគប្បីជ្រាបដូច្នេះ ) ដោយពាក្យ (ក្នុងអដ្ឋកថាទាំងឡាយ) ថា “ ព្រះយោគាវចរ ដែលកាន់យកនីលកសិណ រមែងកាន់យកនិមិត្ត ក្នុងពណ៌ខៀវ ( ខៀវចាស់ ) ជាផ្កាឈើខ្លះ ជាសំពត់ខ្លះ ជាធាតុពណ៌ខ្លះ ” ដូច្នេះ សម្រាប់អ្នកមានបុណ្យ មានអធិការបានធ្វើទុកអំពីមុន គ្រាន់តែបានឃើញ គុម្ពផ្កាដែលមានពណ៌យ៉ាងនោះ ឬកម្រាលផ្កាឈើ ដែលមានពណ៌យ៉ាងនោះ ក្នុងទីបូជា ឬសំពត់ខៀវ និងកែវខៀវ យ៉ាងណាមួយ និមិត្តក៏កើតឡើងបាន ព្រះយោគាវចរក្រៅអំពីនេះ (ដែលមិនមានបុណ្យ) គប្បីកាន់យកផ្កាឈើ មានផ្កា នីលុបល (ផ្កាឈូកខៀវ) ផ្កាគិរិកណ្ណិកាជាដើម មកដាក់ចូលឲ្យពេញប្រអប់ ឬចានទៀប ស្មើកណ្តាប់មាត់ តាមវិធីធ្វើកេសរក្តី ទងក្តី មិនឲ្យប្រាកដ ( កុំឲ្យឃើញស្លឹក កេសរ ទង ) ឬប្រើសំពត់ពណ៌ខៀវ ចងចូលជាកញ្ចុំដាក់ចុះទៅក៏បាន ឬប្រើសំពត់ខៀវនោះ ចងសន្ធឹងត្រង់កណ្តាប់មាត់ឲ្យដូចជាស្បែកស្គរក៏បាន ឬប្រើធាតុពណ៌ដែលមានពណ៌ខៀវដូចសំរិទ្ធ ខៀវដូចស្លឹកឈើនិងខៀវដូចផ្កាអញ្ជនជាដើម

យ៉ាងណាមួយ ធ្វើឲ្យជាកសិណាមណ្ឌល ប្រភេទវំកិលបាន តាមន័យដែលពោល ហើយក្នុងបឋវីកសិណា ឬ ចងភ្ជាប់ទុកត្រង់ជញ្ជាំងតែម្ដងក៏បាន ហើយកាត់ដោយជុំវិញ ដោយពណ៌ជាវិសភាគៈ បន្ទាប់មកមនសិការថា **នីលំ នីលំ** ព្រះយោគាវចរ គប្បីឲ្យប្រព្រឹត្តទៅតាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណាចុះ សូម្បីក្នុងនីលកសិណានេះ ទោសកសិណាក៏ប្រាកដក្នុងឧគ្គហនិមិត្ត គឺ វត្ថុដែលទាក់ទងដោយកសិណាមណ្ឌល មានកេសរ ទង ចន្លោះត្របកជាដើម រមែងប្រាកដ ( ចំណែក ) បដិភាគនិមិត្ត ផុតចាកកសិណាមណ្ឌល ប្រាកដដូចជាផ្ទិតកែវមណី ( ឥន្ទនិល = ត្បូងមរកតពណ៌ខៀវខ្ចី ) នៅក្នុងអាកាស ពាក្យពណ៌នាដ៏សេស គប្បីជ្រាបតាមន័យ ដែលបានពោលហើយនោះចុះ ។

( ចប់ នីលកសិណា )

# មហាដីកា

## អធិប្បាយ នីលកសិណា

( រមែងកាន់យកនិមិត្ត ) ក្នុងវណ្ណធាតុ មានក្ដារលាបពណ៌ ក្ដារជ្រលក់ពណ៌ជាដើម ក៏បាន ។ ពាក្យថា **គុម្ពផ្កាដែលមានសភាពបែបនោះ** គឺគុម្ពផ្កាដែលមានផ្កាពណ៌ខៀវ រីកស្គុសស្គាយគ្របដណ្ដប់ ។ ពាក្យថា **ព្រះយោគាវចរក្រៅអំពីនេះ** គឺ ព្រះយោគាវចរដែលមិនបានធ្វើអធិការទុក ។ លោកពោលដល់ផ្កាអញ្ចនខៀវ ទុកដោយស័ព្ទថា **គិរិកណ្ណិកា** ។ ឈ្មោះថា **ករណ្ឌកបដលំ** គឺគម្របហិប ។ ពាក្យថា **ព្រមទាំងស្លឹកប៉ុណ្ណោះ** គឺ ព្រមទាំងស្លឹកតែម្យ៉ាងប៉ុណ្ណោះ កាត់យកកេសរ និង ទង

នៃផ្កាឈូកខៀវជាដើមផងដែរ ។ ពាក្យថា **គប្បីដាក់ឲ្យពេញ** គឺ គប្បីកាន់យក សំពត់ពណ៌ខៀវ ចងទុកឲ្យដូចជាខ្ចប់របស់ ហើយទើបដាក់ឲ្យពេញប្រអប់ ឬ គម្របហិប ធ្វើជាដួង (កសិណ) ពណ៌ខៀវ ។ បទថា **មុខវដ្តិយំវាសស្ស** ប្រែថា ឬ គប្បីចង (សន្ទឹង) ចូលត្រង់កណ្តាប់មាត់នៃប្រអប់ ឬគម្របហិបនោះ ។

ឈ្មោះថា **ផ្ទិតកែវមណី** បានដល់ ផ្ទិតដែលធ្វើដោយកែវឥន្ទនិល ។

( ចប់ មហាដីកា នីលកសិណ )

# បីតកសិណ

ន័យសូម្បីបីតកសិណ ក៏ដូចន័យនោះ សមដូចពាក្យ (អដ្ឋកថា)ដែលពោល ទុកថា **ព្រះយោគាវចរដែលនឹងកាន់យកបីតកសិណ រមែងកាន់យកនិមិត្តក្នុងពណ៌លឿង ក្នុងផ្កាឈើខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុពណ៌ខ្លះ** ដូច្នេះ ព្រោះហេតុនោះ សូម្បីក្នុងបីតកសិណនេះ សម្រាប់អ្នកមានបុណ្យ មានអធិការបានសាងទុក ត្រឹមតែបាន ឃើញផ្កាឈើ ឬ កម្រាលផ្កាឈើដែលមានពណ៌យ៉ាងនោះ ឬ សំពត់ពណ៌លឿង ធាតុពណ៌លឿង ឯណាមួយ និមិត្តក៏កើតឡើងបាន ដូចព្រះចិត្តគុត្តត្ថេរដូច្នោះ បាន ឮថា កាលលោកអង្គនោះ សម្លឹងមើលគ្រឿងបូជា លើអាសនៈបូជា ដែលក្រាល ដោយផ្កាចន្ទន៍លឿងទាំងឡាយ ក្នុងចិត្តលបព៌តវិហារ និមិត្តទំហំប៉ុនអាសនៈបូជា ក៏ កើតឡើងព្រមជាមួយនឹងការសម្លឹងមើល នោះឯង ។ ព្រះយោគាវចរក្រៅពីនេះ ( ដែលមិនមានបុណ្យ ) គប្បីប្រើផ្កាឈើ មានផ្កាកណ្ណិកាជាដើម ឬប្រើសំពត់មាន

ពណ៌លឿន ឬធាតុ (ពណ៌លឿន) ក៏បាន ធ្វើជាកសិណ ហើយញុំាងមនសិការ ថា **បីតកំ បីតកំ** ឲ្យប្រព្រឹត្តទៅតាមន័យដែលបានពោលហើយ ក្នុងនីលកសិណនោះចុះ ។ ពាក្យដ៏សេស ក៏ដូចគ្នាទាំងអស់ ។

( ចប់ បីតកសិណា )

# មហាដីកា

## អធិប្បាយ បីតកសិណា

ក្នុងបីតកសិណា ពាក្យថា **ផ្កាឈើ** បានដល់ ផ្កាស្មៅយ៉ាប្លុងជាដើម ។ **ហរតាល** ឬ **មនោសិលា** ឈ្មោះថា **ធាតុ** ។ ពាក្យថា **ផ្កាចន្ទន៍លឿន** មានន័យថា ដើមឈើមួយប្រភេទ មានឈ្មោះថា ចន្ទន៍លឿន មានផ្កាពណ៌លឿន បានដល់ ផ្ការបស់ដើមឈើនោះ ។ ពាក្យថា **អាសនៈបូជា** បានដល់ ទីអន្ទុយបូជា ដែលគេធ្វើទុកក្នុងលានព្រះចេតិយ ។ ដោយ **អាទិ** ស័ព្ទ ដែលប្រែថា ជាដើម ក្នុងបទថា **កណ្ណិកាបុប្ផទីហិ** ប្រើផ្កាកណ្ណិកាជាដើម គប្បីឃើញថា រួមយកទាំងផ្កាពិកុល ផ្កាកិរាតៈ ជាដើម ។

( ចប់ មហាដីកា បីតកសិណា )

# លោហិតកសិណ

ន័យក្នុងលោហិតកសិណក៏ដូចន័យនោះ សមដូចពាក្យ (អដ្ឋកថា) បានពោលទុកថា **ព្រះយោគាវចរដែលនឹងកាន់យកលោហិតកសិណ រមែងកាន់យកនិមិត្តក្នុងពណ៌ក្រហម ក្នុងផ្កាឈើខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុពណ៌ខ្លះ** ដូច្នេះ ព្រោះហេតុនោះ សូម្បីក្នុងលោហិតកសិណនេះ សម្រាប់អ្នកមានបុណ្យ មានអធិការបានធ្វើទុកត្រឹមតែបានឃើញផ្កា ដូចជាផ្កាសិរមាន់ ឬ កម្រាលផ្កាឈើ ដែលមានពណ៌យ៉ាងនោះ ឬសំពត់ក្រហម កែវក្រហម ធាតុពណ៌ផ្សេង ៗ ឯណាមួយ និមិត្តក៏កើតឡើងបាន ឯព្រះយោគាវចរក្រៅអំពីនេះ ( ដែលគ្មានបុណ្យ ) គប្បីប្រើផ្កាឈើ ដូចជា ផ្កាចប្បា ផ្កាសិរមាន់ និងផ្កាកន្ទុយដំរីក្រហម ឬ សំពត់ពណ៌ក្រហម ឬ ធាតុ(ពណ៌ក្រហម)ក៏បាន ធ្វើជាកសិណ ហើយញុំាងមនសិការថា **លោហិតំ លោហិតំ** ឲ្យប្រព្រឹត្តទៅតាមន័យដែលបានពោលហើយក្នុងនីលកសិណនោះចុះ ពាក្យដ៏សេសដូចគ្នាទាំងអស់ ។

( ចប់ លោហិតកសិណ )

# មហាដីកា

## អធិប្បាយ លោហិតកសិណ

ឈ្មោះថា **កែវក្រហម** បានដល់ កែវមណី មានពណ៌ទទឹមជាដើម ។

ឈ្មោះថា **ធាតុក្រហម** បានដល់ ជ័រមានពណ៌ក្រហម ឬជ័រហិង្គុលជាដើម ។

( ចប់ មហាដីកា លោហិតកសិណ )

# ឱទាតកសិណ

សូម្បី **ឱទាតកសិណ** ( គប្បីជ្រាបន័យដូច្នេះ ) ដោយពាក្យក្នុង (អដ្ឋកថា) ថា **ព្រះយោគាវចរនឹងកាន់យកឱទាតកសិណ រមែងកាន់យកនិមិត្តក្នុងពណ៌ស ក្នុងផ្កាឈើខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុពណ៌ខ្លះ** ដូច្នេះ សម្រាប់អ្នកមានបុណ្យ មានអធិការបានសន្សំទុកក្នុងកាលមុន ត្រឹមតែបានឃើញផ្កាឈើ ដែលមានពណ៌យ៉ាងនោះ ឬព្រំផ្កាឈើ មានផ្កាម្លិះរួតជាដើម ឬគំនរផ្កាឈូកស ( ដែលគេជញ្ជូន ពីទីបូជាទៅចោល ) ឬសំពត់ស ធាតុពណ៌ស ឯណាមួយ និមិត្តក៏កើតឡើងបាន សូម្បីក្នុងផែនដីរាងមូល ផែនប្រាក់រាងមូល និងដួងព្រះចន្ទ និមិត្តក៏កើតឡើងបានដូចគ្នា ឯព្រះយោគាវចរក្រៅពីនេះ គប្បីប្រើផ្កាឈើស ឬសំពត់ស ឬធាតុស ក៏បាន ធ្វើកសិណ ហើយញ៉ាំងមនសិការថា **ឱទាតំ ឱទាតំ** ឲ្យប្រព្រឹត្តទៅតាមន័យដែលបានពោលហើយក្នុងនីលកសិណនោះចុះ ពាក្យដ៏សេសមានន័យដូចគ្នាទាំងអស់ ។

( ចប់ ឱទាតកសិណ )

# មហាដីកា

## អធិប្បាយ ឱទាតកសិណ

ក្នុងឱទាតកសិណ ពាក្យថា **គំនរផ្កាឈើ** បានដល់ ផ្កាឈើ មានផ្កានន្ទិយាវដ្តៈជាដើម ។ ឈ្មោះថា **ធាតុ** បានដល់ កក្ខតិមុត្តសេតិកៈ ( អញ្ញមណីមួយប្រភេទ ) ជាដើម ។

( ចប់ មហាដីកា ឱទាតកសិណ )

# អាលោកកសិណ

ចំណែកក្នុងអាលោកកសិណ តាមពាក្យក្នុងអដ្ឋកថា ថា **ព្រះយោគាវចរដែលនឹងកាន់យកអាលោកកសិណ រមែងកាន់យកនិមិត្តក្នុងពន្លឺត្រង់ប្រហោងជញ្ជាំងខ្លះ ត្រង់ចន្លោះរន្ធកទ្វារខ្លះ ត្រង់ចន្លោះបង្អួចខ្លះ** ដូច្នេះ ។ សម្រាប់អ្នកមានបុណ្យ មានអធិការបានធ្វើទុកអំពីមុន ត្រឹមតែបានឃើញពន្លឺព្រះអាទិត្យ ឬពន្លឺព្រះចន្ទ ចូលមកតាមប្រហោង មានប្រហោងជញ្ជាំងជាដើម ប្រហោងណាមួយហើយ ក៏ធ្វើឲ្យកើតជាដួងកសិណឡើង ត្រង់ជញ្ជាំង ឬត្រង់ផែនដីក្តី ចន្លោះមែកឈើក្តី ដែលមានស្លឹកក្រាស់ ធ្វើឲ្យកើតជាដួង (រង្វង់) ឡើងត្រង់ផែនដីនោះក្តី ប៉ុណ្ណោះ និមិត្តក៏កើតឡើងបាន ។ ចំណែកព្រះយោគាវចរក្រៅពីនេះ គួរ ( សម្លឹងមើល ) ដួងពន្លឺមានប្រការដូចបានពោលហើយនោះ ភាវនាថា **ឱភាសោ ឱភាសោ** ឬថា **អាលោកោ អាលោកោ** ក៏បាន , កាលមិនអាចយ៉ាងនោះទេ គប្បីដុតប្រទីបទុកក្នុងថ្នាំង បិទមាត់ថ្នាំង ពចហប្រហោង ( ចំហៀង ) ថ្នាំង ហើយបែរមុខ ( ប្រហោងពន្លឺ ) ឆ្ពោះជញ្ជាំង ពន្លឺប្រទីបចេញអំពីប្រហោងនោះ ធ្វើឲ្យកើតជាដួងកសិណឡើងត្រង់ជញ្ជាំង គប្បី ( សម្លឹង ) មើលដួងកសិណនោះ ភាវនាថា **អាលោកោ អាលោកោ** ។ ដួងពន្លឺនេះ នៅបានយូរជាងដួងពន្លឺដទៃនោះ ។ ឧគ្គហនិមិត្តក្នុងអាលោកកសិណនេះ ដូចគ្នានឹងដួងកសិណដែលជាប់នៅត្រង់ជញ្ជាំង ឬដីនោះឯង ឯបដិភាគនិមិត្តជាដួងក្រាស់ និងថ្លា ស្រដៀងគ្នានឹងពន្លឺ ពាក្យដ៏សេសក៏ដូចគ្នាទាំងអស់ ។

( ចប់ អាលោកកសិណ )

# មហាដីកា

## អធិប្បាយ **អាលោកកសិណ**

ពាក្យថា **កាលមិនអាចធ្វើយ៉ាងនោះបាន** មានន័យថា ការធ្វើនិមិត្តពន្លឺឲ្យកើតឡើងដោយអំណាចនៃពន្លឺរបស់ព្រះអាទិត្យជាដើម លោកពោលទុកហើយ ដោយប្រការណា ក៏មិនអាចធ្វើនិមិត្តឲ្យកើតឡើងបានដោយប្រការនោះ ព្រោះពន្លឺភ្លឺស្វាងនៃព្រះអាទិត្យជាដើមនោះ តាំងនៅមិនបានយូរ ។ លោកពោលថា **បិទមាត់ផ្ទាំងឲ្យជិត** ដូច្នេះ ព្រោះពន្លឺនឹងចាំងចេញទៅតាមមាត់ផ្ទាំងមានច្រើនពេក ។ បទថា **កិត្តិមុខំ** ប្រែថា បែរមុខឆ្ពោះជញ្ជាំង ។ ពាក្យថា **ដូចដួងពន្លឺដែលតាំងឡើង** (ត្រង់ជញ្ជាំង ឬត្រង់ផ្ទៃដី) គឺ ដូចដួងពន្លឺដែលមានតាមប្រក្រតីដែលតាំងឡើងត្រង់ជញ្ជាំងជាដើម ។ ពាក្យថា **ជាដួងក្រាស់ណែនផូរផង់ ដូចគ្មានរង្វង់ពន្លឺ** មានន័យថា ប្រសិនបើពន្លឺដែលជារង្វង់ក្រាស់ណែនផូរផង់នឹងមានហើយ ដូចជាព្រះរស្មី មានប្រវែងមួយព្យាម របស់ព្រះដ៏មានព្រះភាគសោត ក៏នឹងដូចជាពន្លឺបែបនោះ ។

( ចប់ មហាដីកា អាលោកកសិណ )

# បរិច្ឆិន្នាកាសកសិណ

សូម្បីក្នុងបរិច្ឆិន្នាកាសកសិណ ដោយពាក្យក្នុង ( អដ្ឋកថា ) ថា **ព្រះយោគីដែលនឹងកាន់យកអាកាសកសិណ រមែងកាន់យកនិមិត្តក្នុងអាកាសដែលជាប្រហោងជញ្ជាំងខ្លះ ប្រហោងរន្ធកទ្វារខ្លះ ត្រង់ចន្លោះបង្អួចខ្លះ** ដូច្នេះ , សម្រាប់អ្នកមានបុណ្យ

មានអធិការបានធ្វើទុកអំពីមុន ត្រឹមតែបានឃើញអាកាសត្រង់ប្រហោងផ្សេងៗ មានប្រហោងជញ្ជាំងជាដើម និមិត្តក៏កើតឡើងបាន ឯព្រះយោគាវចរក្រៅពីនេះ គប្បីចោះប្រហោងទំហំ ១ចំអាម ៤ ធ្នាប់ ត្រង់ (ជញ្ជាំង) រោងដែលបិទជិត ឬត្រង់បន្ទះស្បែក និងកន្ទេលជាដើម ឯណាមួយហើយ ( សម្លឹងមើល ) ប្រហោងដែលចោះត្រង់ជញ្ជាំងជាដើមនោះឯង ភាវនាថា **អាកាសោ អាកាសោ** ។ ឧគ្គហនិមិត្តក្នុងអាកាសកសិណនេះ ក៏ជាដូងដូចគ្នានឹងប្រហោងទទេ ព្រមទាំងវត្ថុដែលជាប់ទាក់ទងដោយប្រហោង មានព្រំនៃជញ្ជាំងជាដើមនោះឯង សូម្បីព្រះយោគាវចរពង្រីក ក៏ពង្រីកមិនបាន បដិភាគនិមិត្តប្រាកដជាដួងកសិណពិត ហើយព្រះយោគាវចរនឹងពង្រីក ក៏ពង្រីកបាន ។

ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណនោះចុះ ។

ព្រះទសពលដែលជាសព្វធម្មទស ( ទ្រង់ឃើញធម៌ទាំងពួង ) បានត្រាស់នូវទសកសិណ ដែលជាហេតុនៃចតុក្កឈាន និងបញ្ចកឈាន ក្នុងជាន់រូបាវចរដូចពណ៌នាមកដូច្នេះ បណ្ឌិតបានជ្រាបទសកសិណនេះ និងន័យក្នុងការចម្រើនកសិណទាំងនោះ ដូច្នេះហើយ គប្បីជ្រាប **បកិណ្ណកកថា** ក្នុងកសិណទាំងនោះឯងដូចតទៅនេះ ។

( ចប់ បរិច្ឆិន្នាកាសកសិណ )

# មហាដីកា

## អធិប្បាយ **បរិច្ឆិន្នាកាសកសិណា**

ពាក្យថា **ដូចគ្នានឹងប្រហោងទទេ** ( ព្រមទាំងបរិវេណជញ្ជាំងជុំវិញជាដើម ) នោះឯង មានន័យថា ប្រហោងទទេនោះ ដែលខណ្ឌដោយបរិវេណជញ្ជាំងជុំវិញជាដើម យ៉ាងណា ក៏ដូចគ្នានឹងប្រហោងទទេនោះ សំដៅសេចក្ដីថា ឧគ្គហនិមិត្ត ប្រាកដដោយអាការនោះៗ ឯង ។ លោកពោលថា **សូម្បីកាលនឹងពង្រីក ក៏ពង្រីកមិនបាន** ដូច្នេះ ដើម្បីសម្ដែងដល់ភាពដែលឧគ្គហនិមិត្ត ជានិមិត្តដែលមិនគួរពង្រីកៗ ពិតណាស់ ឧគ្គហនិមិត្ត សូម្បីទាំងពួង ត្រូវព្រះយោគាវចរពង្រីក ក៏មិនរីកឡើងឡើយ ។ ហើយសូម្បីកាលមានសេចក្ដីត្រូវការនឹងពង្រីក ក៏មានការពង្រីកមិនបាន ព្រោះភាវនាទុព្វលដោយជុំវិញ ។ ការពង្រីកនិមិត្ត រមែងប្រព្រឹត្តទៅបានដោយអំណាចនៃភាវនា ។ ចំណែកបដិភាគនិមិត្ត លោកហៅថា កាលនឹងពង្រីកនិមិត្ត ក៏រមែងពង្រីកបាន ដូច្នេះ ព្រោះធ្វើអធិប្បាយថា កាលបដិភាគនិមិត្តនោះកើតឡើងហើយ ភាវនារមែងជាធម្មជាតិមាំទាំ ដូច្នេះ ។ លោកអាចារ្យពោលថា ព្រះទសពលបានត្រាស់ កសិណ ១០ ដូចបានពណ៌នាមកនេះ ឯណាទុក ដូច្នេះ ព្រោះមានបំណងថា កសិណដែលជាអារម្មណ៍របស់រូបឈាន មានបឋវីកសិណជាដើម ដែលមកដោយសភាវៈ មាននៅក្នុងព្រះបាលី មាន ៨ ប៉ុណ្ណោះ ក៏ពិត តែថា ទ្រង់ធ្វើព្រះធម៌ទេសនា រួមយកអាលោកកសិណ ចូលទុកក្នុងឱទាតកសិណ ហើយបរិច្ឆិន្នាកាសកសិណ ចូលទុកក្នុងអាកាសកសិណ ដូច្នេះ ។ ពាក្យថា **គប្បីជ្រាបសូម្បីបកិណ្ណកកថា** មានន័យថា កុំកាន់យកខ្លឹមសារ ដែលមិនជាសាធារណៈ គឺជា

របស់ចំពោះខ្លួនក្នុងកសិណនោះៗ ប៉ុណ្ណោះ ហើយគប្បីជ្រាប សូម្បីបកិណ្ណកកថា ដែលប្រព្រឹត្តទៅ កាន់យកន័យសេចក្តីដែលជាបកិណ្ណកៈ គឺ ដែលបន្ទាប់បន្សំ ក្នុងកសិណនោះៗ ទាំងសេចក្តីជាអសាធារណៈ និងទាំងសេចក្តីជាសាធារណៈចុះ ។

( ចប់ មហាដីកា បរិច្ឆិន្នាកាសកសិណ )

# បកិណ្ណកកថា

## ( គុណវិសេសផ្សេង ៗ ដែលសម្រេចដោយអំណាចកសិណ )

ក៏ឯក្នុងកសិណទាំងនេះ ដោយអំណាចនៃបឋវីកសិណ គុណវិសេសទាំងឡាយ មានជាដើមថា ការបណ្ដាល គឺថា មនុស្សម្នាក់បណ្ដាលឲ្យជាមនុស្សច្រើននាក់ ក៏បានជាដើម និម្មិតផែនដីឡើងក្នុងអាកាស ឬ ក្នុងទឹកហើយដើរទៅបាន ឬសម្រេចឥរិយាបថ មានឈរ និងអង្គុយជាដើមបាន បានអភិភាយតនៈដោយបរិត្តន័យ និងអប្បមាណន័យ យ៉ាងនេះ រមែងសម្រេច ។

ដោយអំណាចនៃអាបោកសិណ គុណវិសេសទាំងឡាយ មានជាដើមថា ផុសឡើង ឬមុជចុះក្នុងផែនដីបាន ធ្វើភ្លៀងឲ្យកើតឡើងបាន និម្មិតវត្ថុជំៗ មានស្ទឹង ទន្លេជាដើមបាន ធ្វើរបស់ធ្ងន់ មានផែនដី ភ្នំ និង ប្រាសាទជាដើម ឲ្យញ័របានដូច្នេះ រមែងសម្រេច ។

ដោយអំណាចនៃតេជោកសិណ គុណវិសេសទាំងឡាយ មានជាដើមថា ធ្វើផ្សែងឲ្យហុយឡើងបាន ធ្វើភ្លើងឲ្យឆាបឆេះឡើងបាន ធ្វើភ្លៀងភ្លើងឲ្យកើតឡើងបាន កម្ចាត់ភ្លើងដោយភ្លើងបាន អាចដុតចំពោះវត្ថុដែលត្រូវការបាន ធ្វើពន្លឺឡើងដើម្បីប្រយោជន៍ដល់ការឃើញរូបដោយទិព្វចក្ខុបាន ធ្វើសរីរៈឲ្យឆេះទៅដោយតេជោធាតុក្នុងគ្រាបរិនិព្វានបាន យ៉ាងនេះរមែងសម្រេច ។

ដោយអំណាចវាយោកសិណ គុណវិសេសទាំងឡាយមានជាដើមថា ( ទៅបានរហ័ស ) ដូចព្យុះ ធ្វើខ្យល់ឲ្យកើតឡើងបាន ដូច្នេះ រមែងសម្រេច ។

ដោយអំណាចនៃនីលកសិណ គុណវិសេសទាំងឡាយ មានជាដើមថា និម្មិត

រូបពណ៌ខៀវឡើងបាន ធ្វើឲ្យងងឹតទៅបាន បានអភិភាយតនៈ ដោយសុវណ្ណន័យ ទុព្វណ្ណន័យ និងសម្រេចសុភវិមោក្ខ ដូច្នេះ រមែងសម្រេច ។

ដោយអំណាចនៃបីតកសិណ គុណវិសេសទាំងឡាយជាដើមថា និម្មិតរូបពណ៌លឿងបាន បង្អោនចិត្តចុះ (អធិដ្ឋាន) ថា ឲ្យទៅជាមាសបាន បានអភិភាយ-តនៈ តាមន័យដែលបានពោលហើយនោះឯង និងសម្រេចសុភវិមោក្ខ ដូច្នេះ រមែងសម្រេច ។

ដោយអំណាចនៃលោហិតកសិណ គុណវិសេសទាំងឡាយ មានជាដើមដូច្នេះ អាចនិម្មិតរូបពណ៌ក្រហមឡើងបាន បានអភិភាយតនៈ និង សម្រេចនូវសុភវិមោក្ខ តាមន័យដែលបានពោលហើយនោះ ដូច្នេះ រមែងសម្រេច ។

ដោយអំណាចនៃឱទាតកសិណ គុណវិសេសទាំងឡាយ មានជាដើមថា អាចនិម្មិតរូបពណ៌សឡើងបាន បណ្តេញថីនមិទ្ធៈបាន កម្ចាត់ភាពងងឹតបាន ធ្វើពន្លឺឲ្យភ្លឺស្វាងឡើង ដើម្បីប្រយោជន៍ដល់ការឃើញរូបដោយទិព្វចក្ខុបាន យ៉ាងនេះ រមែងសម្រេច ។

ដោយអំណាចនៃអាលោកកសិណ គុណវិសេសទាំងឡាយ មានជាដើមថា និម្មិតរូបឲ្យជាប្រហោង ចាំងពន្លឺបាន កម្ចាត់ថីនមិទ្ធៈបាន បើកនូវភាពងងឹតបាន ធ្វើពន្លឺឲ្យភ្លឺស្វាងឡើង ដើម្បីប្រយោជន៍ដល់ការឃើញរូបដោយទិព្វចក្ខុបាន យ៉ាងនេះ រមែងសម្រេច ។

ដោយអំណាចនៃអាកាសកសិណ គុណវិសេសទាំងឡាយជាដើមថា ធ្វើវត្ថុដែលកំបាំង ឲ្យបើកផ្ទារ ( បង្ហាញខ្លួន ) បាន និម្មិតចន្លោះប្រហោងចូលក្នុងទីក្រាស់ ដូចជាខាងក្នុងផែនដី និងខាងក្នុងភ្នំ ហើយសម្រេចឥរិយាបថទៅបាន ដើរឆ្លងនាំង

មានជញ្ជាំងជាដើម ចេញទៅខាងក្រៅបាន មិនមានទើសទាក់ យ៉ាងនេះ រមែងសម្រេច ។

## ភាពផ្សេងគ្នានៃកសិណ

កសិណទាំងអស់នេះ មានភាពផ្សេងគ្នាដូច្នេះ គឺ **ឧទ្ធំ** ពង្រីកឡើងលើ , **អធោ** ពង្រីកចុះក្រោម , **តិរិយំ** ពង្រីកទៅដោយជុំវិញខ្លួន , **អទ្វយំ** ពង្រីកទៅមិនឲ្យមាន ២ , **អប្បមាណំ** ពង្រីកទៅមិនមានប្រមាណ ពិតណាស់ សេចក្តីនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា **បុគ្គលខ្លះកំណត់កសិណទៅខាង លើបុគ្គលខ្លះកំណត់កសិណទៅខាងក្រោម បុគ្គលខ្លះកំណត់កសិណទៅដោយជុំវិញ មិនមាន ២ មិនមានប្រមាណ** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះពាក្យថា **ឧទ្ធំ** គឺផ្ចោះទៅកាន់ផ្ទៃមេឃខាងលើ ។ ពាក្យថា **អធោ** គឺផ្ចោះទៅកាន់ផ្ទៃដីខាងក្រោម ។ ពាក្យថា **តិរិយំ** គឺកំណត់ចេញទៅជុំវិញខ្លួនដូចជាលាន ។ ពិតណាស់ ព្រះយោគាវចររូបខ្លះ ពង្រីកកសិណទៅខាងលើតែម្យ៉ាង ខ្លះទៀតពង្រីកកសិណទៅខាងក្រោម អង្គខ្លះពង្រីកទៅដោយជុំវិញខ្លួន ឬផ្សាយទៅយ៉ាងនោះ តាមហេតុការណ៍នោះ ៗ ដូចជាបុគ្គលកាលប្រាថ្នានឹងឃើញរូបដោយទិព្វចក្ខុ ក៏ផ្សាយពន្លឺទៅដូច្នោះ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ ៣ បទថា **ឧទ្ធំ អធោ តិរិយំ** ។ ចំណែកពាក្យថា **អទ្វយំ** នេះ ទ្រង់ត្រាស់ដើម្បី (សំដែង) សេចក្តីដែលកសិណមួយ មិនក្លាយជាកសិណដទៃ ប្រៀបដូចកាលមនុស្សចុះទឹកទៅ ក៏មានតែទឹកនៅគ្រប់ទិស មិនមានវត្ថុដទៃ យ៉ាងណា បឋវីកសិណ រមែងជាបឋវីកសិណប៉ុណ្ណោះ ការលាយឡំគ្នាជាមួយកសិណដទៃមិន

មានដល់បបរិកសិណនោះឡើយ ដូច្នោះ ន័យដូច្នេះនេះ គប្បីជ្រាបក្នុងកសិណទាំងពួង ( ផងចុះ ) ។ ពាក្យថា **អប្បមាណំ** នេះ ទ្រង់ត្រាស់ដោយការផ្សាយទៅនៃកសិណនោះ រកប្រមាណមិនបាន ។ មែនពិត កាលព្រះយោគាវចរផ្សាយកសិណនោះទៅដោយចិត្ត រមែងផ្សាយជាប់ទៅតែម្យ៉ាង មិនប្រមាណថា នេះខាងលើ នេះជាកណ្ដាល របស់កសិណនោះឡើយ ។

## អ្នកបំពេញកសិណមិនសម្រេច

ឯសត្វពួកណា ដែលលោកហៅថា ជាអ្នកដែលប្រកបដោយកម្មាវរណៈ (គ្រឿងរាំង គឺកម្ម) ក្ដី ប្រកបដោយកិលេសាវរណៈ (គ្រឿងរាំង គឺកិលេស) ក្ដី ប្រកបដោយវិបាកាវរណៈ (គ្រឿងរាំង គឺ វិបាក) ក្ដី មិនមានសទ្ធា មិនមានឆន្ទៈ ទុព្វលប្បញ្ញា ជាអភ័ព្វបុគ្គលក្នុងការឈានចុះកាន់សច្ចភាព ការប្រព្រឹត្តត្រូវល្អក្នុងធម៌ទាំងឡាយដែលជាកុសល ការបំពេញក្នុងកសិណសូម្បីតែមួយប្រការ ក៏មិនសម្រេចដល់សត្វពួកនោះ សូម្បីតែម្នាក់ ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ប្រកបដោយកម្មាវរណៈ** បានដល់ ប្រកបដោយអនន្តរិយកម្ម ។ ពាក្យថា **ប្រកបដោយកិលេសាវរណៈ** បានដល់ ជានិយតមិច្ឆាទិដ្ឋិ និងជាឧភតោព្យញ្ជនកៈ ជាខ្ទើយ ។ ពាក្យថា **ប្រកបដោយវិបាកាវរណៈ** បានដល់ មានបដិសន្ធិជាអហេតុកៈ ជាទ្វិហេតុកៈ ។ ពាក្យថា **គ្មានសទ្ធា** គឺ គ្មានការជឿក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើម ។ ពាក្យថា **មិនមានឆន្ទៈ** គឺ មិនមានឆន្ទៈក្នុងអបច្ចនិកបដិបទា ( បដិបទាដែលមិនជាសត្រូវ បានដល់ អនុលោមប្បដិបទា គឺ វិបស្សនា “ ដីកាពន្យល់ ” ) ។ ពាក្យថា **ទុព្វលប្បញ្ញា** សំដៅ

សេចក្តីថា មិនមានការយល់ត្រូវ ទាំងដែលជាលោកិយ និង លោកុត្តរ ។ ពាក្យថា **ជាអភ័ព្វបុគ្គល ក្នុងការឈានចុះកាន់សច្ចភាព ក្នុងការប្រព្រឹត្តត្រូវក្នុងធម៌ទាំងឡាយ ដែលជាកុសល** នោះ មានន័យថា ជាអ្នកមិនអាចឈានចុះកាន់អរិយមគ្គដែលរាប់ថា ជាសច្ចភាព និងរាប់ថាជាដំណើរប្រពៃ ក្នុងធម៌ទាំងឡាយដែលជាកុសល ។

ម្យ៉ាងវិញទៀត មិនមែនតែក្នុងកសិណប៉ុណ្ណោះឡើយ ការបំពេញ សូម្បីក្នុងកម្មដ្ឋានដទៃៗ ក៏មិនសម្រេចដល់សត្វទាំងនោះ សូម្បីតែម្នាក់ ព្រោះហេតុនោះ កុលបុត្តដែលប្រាសចាកវិបាកាវរណៈហើយ ក៏គប្បីចៀសវាងកម្មាវរណៈ និង កិលេសាវរណៈចេញឲ្យឆ្ងាយ ញ៉ាំង សទ្ធា ឆន្ទៈ និង បញ្ញា ឲ្យចម្រើនដោយវុឌ្ឍិធម៌ មានសទ្ធម្មស្សវនៈ ( ស្តាប់ធម៌របស់សប្បុរស ) និងសប្បុរិសូបស្សយៈ ( ការអាស្រ័យសប្បុរស ) ជាដើម ធ្វើសេចក្តីព្យាយាមក្នុងការប្រកបរឿយ ៗ ក្នុងកម្មដ្ឋាន ហោង ។

# មហាដីកា

## អធិប្បាយ បកិណ្ណកកថា

ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **អាទិកាវា** នេះ រួមយកការនិម្មិតវត្ថុដែលមានក្នុងចំណែកនៃបឋវីឯណាមួយទុក ។ សូម្បីក្នុងបទថា **ឋាននិសជ្ជាទិកប្បនំ វា** នេះ គប្បីនាំពាក្យថា **អាកាសេ វា ឧទកេ វា** មកសម្ព័ន្ធគ្នា ( ដែលនឹងប្រែបានថា ឬសម្រេចឥរិយាបថ មានការឈរ ការអង្គុយជាដើម ក្នុងអាកាស ឬក្នុងទឹកបាន )។ ពាក្យថា **ដោយបរិត្តន័យ និង អប្បមាណន័យ** គឺ ដោយន័យដែលអារម្មណ៍ជាបរិត្ត

( តូចឆ្មារ គឺមិនពង្រីក ) និងមានអារម្មណ៍ជាអប្បមាណ ( រកប្រមាណមិនបាន គឺពង្រីក) ប៉ុណ្ណោះ មិនប៉ះពាល់ពណ៌ មានពណ៌ខៀវជាដើម ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **ឯវមាទីនិ** ( គុណទាំងឡាយមានយ៉ាងនេះថា .... ជាដើម ) រួមយកការនិម្មិតទ.ទឹកដែលបាញ់ចេញ ) អំពីសរីរៈជាដើម ។ ពាក្យថា **អាចដុតចំពោះវត្ថុដែលត្រូវការបាន** មានន័យថា ក្នុងបណ្ដាវត្ថុទាំងឡាយដ៏ច្រើន មានកប្បាស សំឡី ឈើខ្ទឹម ឈើឧសជាដើម ដែលរួមទុកជាគំនរជាមួយគ្នា មានអំណាចក្នុងការដុតចំពោះវត្ថុតែមួយ៉ាង ដែលត្រូវការនឹងដុតបាន ។ ដោយ **អាទិ** ស័ព្ទ ក្នុងតេជោ-កសិណនេះ រួមយកការកម្ចាត់ភាពងងឹតជាដើមផង ។

ការទៅបាន ដូចគ្នានឹងខ្យល់ផាត់ទៅ ឈ្មោះថា **វាយុគតិគមនំ** បានដល់ទៅដោយរហ័សក្រៃលែង ។ ដោយ **អាទិ** ស័ព្ទ ក្នុងវាយោកសិណនេះ រួមយកការទៅដល់ប្រទេសដទៃបាន តាមដែលប្រាថ្នា ជាដើមផង ។

ឈ្មោះថា **ការបង្អោនចិត្ត** ថា ចូរជាមាសចុះ បានដល់ ការអធិដ្ឋានភាពជាមាស ដូចព្រះបិលិន្ទវច្ឆៈ អធិដ្ឋានភាពជាមាស ដល់តិណណ្ឌុបកប្រាសាទជាដើម ។ ពាក្យថា **តាមន័យដែលបានពោលហើយ** គឺ ដោយសុវណ្ណន័យ និងទុព្វណ្ណន័យ ។

ក្នុងវណ្ណកសិណទាំងឡាយ ដោយ **អាទិ** ស័ព្ទ ក្នុងកសិណនោះ ៗ គប្បីឃើញថា រួមយកការនិម្មិតពន្លឺខៀវបានជាដើម ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **បបវិបព្វតាទិ** មានផែនដី ភ្នំ ជាដើម គប្បីឃើញថា រួមយកស្ថានទី មានសមុទ្រជាដើមផង ។

ពាក្យថា **កសិណទាំងអស់នោះឯង** គឺ កសិណទាំង ១០ ។ ពាក្យថា **រមែងបានភាពផ្សេងគ្នាយ៉ាងនេះ** គឺ រមែងដល់ភាពផ្សេងគ្នា ដោយការពង្រីកជាដើមនេះ ។

បទថា **ឯកោ** ប្រែថា បុគ្គលខ្លះ ។ ពាក្យថា **រមែងកំណត់** គឺ កំណត់ទុកដោយការនាសញ្ញា ។ ដោយ **អាទិ** ស័ព្ទ រួមយកព្រះបាលីថា បុគ្គលខ្លះ រមែងកំណត់យកអាបោកសិណ ដូច្នេះជាដើម ។

គប្បីនាំបទព្រះបាលីមកសម្ព័ន្ធគ្នា **ឧបរិ គគណតលាភិមុខំ " បឋវីកសិណ-មេកោ សញ្ជានាតិ** " បុគ្គលខ្លះ កំណត់បឋវីកសិណទុកក្នុងខាងលើ គឺ សំដៅទៅកាន់ផ្ទៃមេឃខាងលើ ដូច្នេះ ។ ក៏ខនោះឯង រមែងប្រព្រឹត្តទៅដោយអំណាចនៃការពង្រីក ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាការពិតថា បុគ្គលខ្លះពង្រីកកសិណទៅខាងលើតែម្យ៉ាង** ដូច្នេះ ។ សូម្បីក្នុងពាក្យថា **សំដៅទៅកាន់ផ្ទៃដីខាងក្រោម** ជាដើម ក៏មានន័យដូច្នេះដែរ ។

លោកអាចារ្យពោលទុកក្នុងបទនេះថា ឬថា រមែងផ្សាយទៅយ៉ាងនេះ ដោយហេតុនោះៗ ដូច្នេះ ព្រោះជាពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកដោយទាក់ទងជាមួយបុគ្គលដែលត្រូវពង្រីក មិនសម្ដែងដល់ប្រយោជន៍ ក្នុងវេលាដែលពង្រីកគ្រាមុនៗ មានន័យថា ពង្រីកកសិណទៅ ។ សួរថា ដូចម្ដេច ? ឆ្លើយថា ដូចអ្នកត្រូវការឃើញរូបដោយទិព្វចក្ខុ ផ្សាយពន្លឺទៅដូច្នោះ ។ មានន័យថា ប្រសិនបើត្រូវការនឹងឃើញរូបក្នុងខាងលើ ក៏រមែងផ្សាយពន្លឺទៅក្នុងខាងលើ ប្រសិនបើត្រូវការនឹងឃើញរូបក្នុងខាងក្រោម រមែងផ្សាយពន្លឺទៅក្នុងខាងក្រោម ប្រសិនបើត្រូវការនឹងឃើញរូបដោយជុំវិញ រមែងផ្សាយពន្លឺទៅដោយជុំវិញ បុគ្គលនេះរមែងផ្សាយកសិណទៅដោយអាការយ៉ាងនេះដូចគ្នា ។ ពាក្យថា **កសិណមួយ** គឺ កសិណតែមួយក្នុងបណ្ដាកសិណទាំងឡាយ មានបឋវីកសិណជាដើម ។ ពាក្យថា **ដើម្បីភាពដែល** ( កសិណមួយ ) **មិនចូលដល់ភាពជាកសិណដទៃ** គឺ ដើម្បីសម្ដែងដល់ ( ភាព

នៃកសិណតែម្យ៉ាង ) មិនចូលដល់ភាពជាកសិណដទៃ ឈ្មោះថា មិនមានយ៉ាងដទៃ គឺ មិនមានដីជាដើម ។ ពិតណាស់ ត្រង់ទីដែលទឹកតាំងនៅ រមែងមិនមានសសម្ភារបឋវី ( ដីព្រមទាំងសម្ភារៈ បានដល់ ដីដែលស្គាល់គ្រប់គ្នាថា ដីឥដ្ឋ ដីខ្សាច់ជាដើម ) ។ ពាក្យថា **មិនមានការលាយឡំ ជាមួយកសិណដទៃ** គឺ មិនមានការលាយឡំជាមួយអាបោកសិណជាដើម ។ ពាក្យថា **ក្នុងកសិណគ្រប់កសិណ** គឺ ក្នុងកសិណដ៏សេស មានអាបោកសិណជាដើម គ្រប់កសិណ ។ ការផ្សាយទៅមិនមានសល់ មិនឈប់នៅត្រង់ចំណែកណាមួយ ជាការផ្សាយទៅដោយមិនកាន់យកប្រមាណ ឈ្មោះថា **អប្បមាណំ** ។ ព្រោះហេតុនោះឯង កសិណទាំងឡាយនោះ ទើបមានសមញ្ញា ( ឈ្មោះហៅ ) ថា **កសិណ** ( ពាក្យថា **កសិណ** ប្រែថា អស់ជើង គឺ មិនមានសល់ ) ។ ដូចដែលលោក ពោលថា **តញ្ហិ** ( គឺថា កាលនឹងផ្សាយទៅដោយចិត្តនូវកសិណនោះ ។ ល ។ ) ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កាលនឹងផ្សាយទៅដោយចិត្ត** គឺ កាលនឹងធ្វើឲ្យជាអារម្មណ៍ ដោយភាវនាចិត្ត ។ ពិតណាស់ ភាវនាចិត្ត រមែងធ្វើកសិណតូច ឬកសិណធំទុកក្នុងចិត្តបានដោយអស់ជើង ក្នុងខណៈតែមួយជាមួយគ្នានោះឯង មិនមែនធ្វើទុកក្នុងចិត្តបានត្រឹមតែមួយចំណែកឡើយ ។

ពាក្យថា **ព្រមព្រៀងដោយអនន្តរិយកម្ម** គឺដល់ព្រមដោយអនន្តរិយកម្ម **៥** យ៉ាងណាមួយ ។ ពាក្យថា **ជាអ្នកមាននិយតមិច្ឆាទិដ្ឋិ** គឺ ជាអ្នកដល់ព្រមដោយនិយតមិច្ឆាទិដ្ឋិ យ៉ាងណាមួយ ក្នុងបណ្តាមិច្ឆាទិដ្ឋិទាំង **៣** យ៉ាង គឺ **អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ នត្ថិកទិដ្ឋិ** ។ ពាក្យថា **ឧភតោព្យញ្ជនកបណ្ឌកា** គឺ ជាឧភតោព្យញ្ជនក ( មនុស្សភេទ២ ) និងខ្ទើយ ។ ក៏ឧភតោព្យញ្ជនកៈ និង ខ្ទើយទាំងនេះ ឈ្មោះថា

ជាអ្នកដល់ព្រមដោយវិបាកាវរណៈ ព្រោះភាពជាអ្នកមានអហេតុកបដិសន្ធិ ក៏ពិតហើយ សូម្បីដូច្នោះ ព្រោះភាពជាអ្នកមានកិលេសក្រាស់ ទើបលោកពោលថា ជាអ្នកដល់ព្រមដោយកិលេសាវរណៈ ។ បទថា **អហេតុកទ្វិហេតុកបដិសន្ធិកា** ប្រែថា ជាអ្នកមានអហេតុកបដិសន្ធិពួក ១ មានទ្វិហេតុកបដិសន្ធិពួក ១ ។

ពិតណាស់ សម្រាប់សត្វទាំងឡាយ សូម្បីមានទុហេតុកបដិសន្ធិ ក៏មិនមានការបាក់ធ្លុះព្រះអរិយមគ្គ និងការបានឈានឡើយ ព្រោះដូច្នោះ ពួកអ្នកមានទ្វិហេតុ-កបដិសន្ធិនោះ ចាត់ជាអ្នកដល់ព្រមដោយវិបាកាវរណៈផងដែរ ។

ពាក្យថា **ក្នុងបដិបទាដែលមិនមែនជាសត្រូវ** មានន័យថា ក្នុងបដិបទាដែលអនុលោមចំពោះមគ្គ គឺ ក្នុងវិបស្សនាដែលអនុលោមចំពោះសច្ចៈ ។ ពាក្យថា **មិនមានឆន្ទៈ** លោកពោលទុកក្នុងសម្មោហវិនោទនីថា “ បានដល់ ជាអ្នកប្រាសចាក**កត្តុកម្យតាឆន្ទៈ** ( ឆន្ទៈ គឺ ការប្រាថ្នានឹងធ្វើ ) ” ។ ពាក្យក្នុងសម្មោហវិនោទនីនោះ គប្បីឃើញថា លោកពោលសំដៅយក **កត្តុកម្យតាឆន្ទៈ** ដែលមានការសម្រេចព្រះនិព្វានជាប្រយោជន៍ប៉ុណ្ណោះ ។ សូម្បីមនុស្សក្នុងឧត្តរកុរុទ្វីប ឬដូចជាពួកមារជាដើម ពួកគេនៅក្នុងឋានៈនៃអ្នកមិនមានឆន្ទៈ ព្រោះប្រាសចាកការពេញចិត្តក្នុងព្រះនិព្វាន ។

ពាក្យថា **មានបញ្ញាទន់ខ្សោយ** គឺ វិនាសប្រាសចាកបញ្ញាក្នុងភវង្គ លោកបានពោលទុក ក្នុងសម្មោហវិនោទនីថា **បុគ្គលណាសូម្បីមានបញ្ញាក្នុងភវង្គបរិបូរណ៍ (តែ) ភវង្គក៏មិនជាបាទនៃលោកុត្តរធម៌ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានបញ្ញាទន់ខ្សោយ** ។ ចំណែកភវង្គណា កាលប្រព្រឹត្តទៅ លោកុត្តរធម៌កើតឡើងបាន ក្នុងការបន្តនៃភវង្គនោះ ភវង្គនោះ ឈ្មោះថា ជាបាទនៃលោកុត្តរធម៌ ។

ពាក្យថា **ក្នុងកុសលធម៌ទាំងឡាយ** គឺ ក្នុងធម៌ដែលមិនជាទោសទាំងឡាយ ឬថាក្នុងធម៌ដែលមានវិបាកជាសុខទាំងឡាយ ។ ពាក្យថា **ដើម្បីជាការឈានចុះ** គឺ ដើម្បីជាការសម្រេច ។ ពាក្យថា **ចំពោះក្នុងកសិណតែមួយប៉ុណ្ណោះ** គឺ ចំពោះកសិណកម្មដ្ឋានប៉ុណ្ណោះ ។ ពាក្យថា **សត្វពួកនេះ** គឺ សត្វដែលដល់ព្រមដោយកម្មាវរណៈជាដើម ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះហេតុដែលអន្តរាយមានវិបាកជាដើមទាំងនេះ ធ្វើឲ្យវិនាសនូវប្រយោជន៍ និង ជាហេតុនៃការអន្តរាយយ៉ាងនេះ ។ ម្យ៉ាងវិញទៀត គប្បីឃើញថា ក្នុងអន្តរាយទាំង ៥ យ៉ាងនេះ ការដែលលោកកាន់យកអន្តរាយ ៣ យ៉ាង ប៉ុណ្ណោះ ក៏ព្រោះការដែលអន្តរាយ ២ យ៉ាងក្រៅពីនេះ ( គឺ ការតិះដៀលព្រះអរិយៈជាម្ចាស់ និង ការក្លែងល្មើសសិក្ខាបទ-បញ្ញត្តិ ) មានផ្លូវកែខៃបាន ឬថា ព្រោះការដែលអន្តរាយ ២ យ៉ាង ក្រៅពីនេះជាចំណែកនៃកម្មន្តរាយ ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **សប្បាយសូបនិស្សយាទីហិ** ( ការអាស្រ័យសប្បាយសជាដើម ) រួមយកយោនិសោមនសិការជាដើម ដែលកើតអំពីការអាស្រ័យសប្បាយសជាដើមនោះផង ។ ពាក្យថា **សទ្ធា** បានដល់ សទ្ធាក្នុងកម្មនិងផលរបស់កម្ម និងសទ្ធាក្នុងព្រះរតនត្រៃ ។ ពាក្យថា **ឆន្ទៈ** បានដល់ កុសល-ឆន្ទៈ ពោលគឺ ការប្រាថ្នានឹងធ្វើយ៉ាងខ្លាំងក្លា ក្នុងការបំពេញភាវនា ។ ពាក្យថា **បញ្ញា** បានដល់ បារិហារិយបញ្ញា ។ ពាក្យថា **ធ្វើឲ្យចម្រើន** គឺ ធ្វើឲ្យរីកលូត-លាស់ ដោយប្រការដែលភាវនានឹងសម្រេចបាន ។ ក្នុងរឿងនេះ ពាក្យណាដែលលោកមិនបានចែកទុកដោយអត្ថ ពាក្យនោះ លោកមិនបានចែកទុក ព្រោះបណ្ឌិតអាចដឹងបានដោយងាយ និងព្រោះមានន័យ បានពោលហើយក្នុងបទដើម ។

# បរិច្ឆេទទី ៥

## ឈ្មោះ សេសកសិណាទិទ្ទេស

## ក្នុងអធិការនៃសមាធិវណ្ណនា ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ

## ខ្ញុំព្រះករុណាធ្វើ ដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះឯង ។

# កល្យាណមិត្ត មានឧបការគុណ
## ក្នុងការប្រែរៀបរៀង គម្ពីរវិសុទ្ធិមគ្គ នេះ

- ឧបាសក **សន ម៉ារឌី** ជួយពិនិត្យអក្ខរាវិរុទ្ធ ។
- ឧបាសក **ឡាន សុខម** ជួយបកប្រែ ។
- ឧបាសក **រឹម សាមេត** ជួយពិនិត្យអក្ខរាវិរុទ្ធ ។

ដោយសេចក្តីព្យាយាមក្នុងកិច្ចការធម្មទាននេះ ខ្ញុំបាទសូមឲ្យមានបញ្ញាជំនាញក្នុងធម៌របស់ព្រះសម្មាសម្ពុទ្ធ រួចផុតចាកទុក្ខទាំងពួង បានដល់នូវព្រះនិព្វាន កុំប្រែទៅជាប្រការដទៃឡើយ ។

សូមសាធុជន ! ដែលមានចិត្តរីករាយ នៅក្នុងព្រះធម្មវិន័យ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បាននូវ បីតិ បាមោជ្ជ សុខក្សេមក្សាន្ត តរៀងទៅ.... ។

# មាតិកាធម៌

មាតិកា                                                                                    លេខទំព័រ

១-កម្មដ្ឋានគហណនិទ្ទេស............................................ ២
២-សមាធិដោយសរុប................................................ ៣
៣-ប្រភេទនៃសមាធិ.................................................. ៤
៤-មហាដីកា កម្មដ្ឋានគហណនិទ្ទេស............................ ៥
៥-សមាធិពួក ១-២.................................................. ១៤
៦-មហាដីកា សមាធិពួក១-២..................................... ១៥
៧-សមាធិពួក ៣....................................................... ១៧
៨-មហាដីកា សមាធិពួក៣.......................................... ១៨
៩-សមាធិពួក ៤ ...................................................... ២២
១០-ភាពសៅហ្មង-ផូរផង់នៃសមាធិ............................ ២៧
១១-មហាដីកា សមាធិពួក ៤..................................... ២៨
១២-ការចម្រើនសមាធិ............................................. ៣៨
១៣-បលិពោធ ១០................................................... ៣៩
១៤-មហាដីកាបលិពោធ ១០...................................... ៥៤
១៥-កម្មដ្ឋាន ២ យ៉ាង............................................... ៦២
១៦-មហាដីកា កម្មដ្ឋាន ២ យ៉ាង............................... ៦៩

១៧-ចរិយា និង ចរិត ៦............................................ ៧៥

-សប្បាយរបស់បុគ្គលចរិតផ្សេងៗ................................ ៨៨

១៨-មហាដីកា ចរិយា-ចរិត ៦................................... ៩៣

១៩-កម្មដ្ឋាន ៤០ ដោយអាការ ១០........................... ១១៥

មាន **ភូមិតោ** ជាដើម ។

-ការសម្រេចឈានក្នុងកម្មដ្ឋានផ្សេងៗ........................... ១១៧

២០-មហាដីកាកម្មដ្ឋាន ៤០ ......................................... ១៣២

២១-បឋវីកសិណានិទ្ទេស............................................... ១៥៣

២២-មហាដីកា បឋវីកសិណ........................................ ១៥៤

២៣-វិហារមិនសមគួរ.................................................. ១៥៥

២៤-មហាដីកា វិហារមិនសមគួរ................................... ១៦៣

២៥-វិហារដែលសមគួរ................................................ ១៦៥

២៦-មហាដីកា វិហារដែលសមគួរ................................ ១៦៩

២៧-ការលះបលិពោធតូចតាច....................................... ១៧២

២៨-បឋវីកសិណ-ការទាវិធី......................................... ១៧៣

២៩-មហាដីកាបឋវីកសិណ-ការទាវិធី........................... ១៧៨

៣០-ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត................................ ១៩១

៣១-មហាដីកា ឧគ្គហនិមិត្ត-បដិភាគនិមិត្ត...................... ១៩២

៣២-សមាធិ ២ យ៉ាង................................................... ១៩៣

៣៣-មហាដីកា សមាធិ ២ យ៉ាង.................................. ១៩៤

៣៤-សប្បាយ-អសប្បាយ ៧ យ៉ាង............................ ១៩៧

៣៥-អប្បនាកោសល្យ ១០ យ៉ាង................................ ២០២

៣៦-មហាដីកា អប្បនាកោសល្យ១០............................ ២២៤

៣៧-បឋមជ្ឈាន........................................................ ២៥៤

- បីត ៥ យ៉ាង........................................................ ២៦១

៣៨-មហាដីកា បឋមជ្ឈាន.......................................... ២៨១

-បឋមជ្ឈានលះអង្គ ៥................................................ ៣០២

៣៩-បឋមជ្ឈាន លំអ ៣ យ៉ាង.................................... ៣០៦

-វិធីធ្វើឲ្យតាំងនៅបានយូរ............................................ ៣១៧

៤០-ការពង្រីកនិមិត្ត.................................................... ៣១៩

៤១-មហាដីកា ការពង្រីកនិមិត្ត.................................... ៣២១

៤២-វសី ៥.............................................................. ៣២៧

៤៣-មហាដីកា វសី ៥................................................ ៣២៩

៤៤-ទុតិយជ្ឈាន........................................................ ៣៣៤

៤៥-វិតក្កវិចារពន៌ រូបសមា......................................... ៣៣៥

៤៦-មហាដីកា ទុតិយជ្ឈាន.......................................... ៣៤១

៤៧-តតិយជ្ឈាន........................................................ ៣៥២

៤៨-ឧបេក្ខា ១០ យ៉ាង.............................................. ៣៥៣

៤៩-មហាដីកា តតិយជ្ឈាន.......................................... ៣៦៤

៥០-ចតុត្ថជ្ឈាន........................................................ ៣៧៥

៥១-មហាដីកា ចតុត្ថជ្ឈាន........................................ ៣៨៤

៥២-បញ្ចកឈាន...................................................... ៣៩៣

៥៣-មហាដីកា បញ្ចកឈាន...................................... ៣៩៥

៥៤-សេសកសិណនិទ្ទេស.......................................... ៣៩០

-អបោកសិណ...បរិច្ឆិន្នាកាសកសិណ........................... ៣៩៩

៥៥-បកិណ្ណកកថា...................................................... ៤១៩

៥៦-មហាដីកា បកិណ្ណកកថា...................................... ៤២៣